# បទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែនៃព្រះរាជាណាចក្រកម្ពុជា (វគ្គ១)  សេចក្តីព្រាង

បទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែនៃព្រះរាជាណាចក្រកម្ពុជា (វគ្គ១) នឹងអនុវត្តស្របពេលជាមួយនឹងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ។ Aug 3, 2015

| សេចក្តីព្រៀងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ | សេចក្តីព្រៀងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ (វគ្គ១) |
|---|---|
| ( | **ជំពូក៦ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែនិងរថយន្ត**<br>**ផ្នែកទី១ បទបញ្ញត្តិទូទៅ**<br><br>មាត្រា១១១<br>ស្តីពីសុវត្ថិភាពទាក់ទងនឹង យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ និងរថយន្ត យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ និង កម្មកររ៉ែ យោងតាមការកំណត់តាមមាត្រា៦នៃច្បាប់ ចាំបាច់ត្រូវតែគោរពតាមចំនុចដែលបានចាត់អនុលោមតាមការកំណត់តាមមាត្រា៣១-២នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។<br><br>**(ការបង្ហាញអំពីផ្លាកលេខរថយន្ត**<br>មាត្រា១១២<br>ម្ចាស់សិទ្ធការងាររ៉ែ ចំពោះរថយន្តនិង យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែនៅក្នុងការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែថ្មរងថ្ម ចាំបាច់ត្រូវតែបង្ហាញអំពីចំនុចចាំបាច់លើការគ្រប់គ្រងការបើកបររថយន្តនៃការដ្ឋានរ៉ែនោះ ដូចជាទំងន់ប្រើបានជាអតិបរិមា ការកំហិតនៃបរិមាណទំងន់ ដែលអាចផ្ទុកបាន ផ្លាកលេខរថយន្តនៃការដ្ឋានរ៉ែនោះដោយដាក់បង្ហាញនូវទីកន្លែងសមរម្យណាមួយ។ |

| | |
|---|---|
| | **ផ្នែក២ ស្តង់ដារចនាសម្ព័ន្ធនៃយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែនិងរថយន្ត**<br>**(ស្តង់ដារចនាសម្ព័ន្ធនៃ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែនិងរថយន្ត)**<br>មាត្រា១១៣<br>1 ម្ចាស់សិទ្ធការងាររ៉ែ ករណីប្រើរថយន្តនិងទយានដែលជាប្រភេគ្រឿងចក្រនៃការដ្ឋានរ៉ែ នៅការដ្ឋានរ៉ែ គោរពតាមការកំណត់នៃ 「សេចក្តីប្រកាសទាក់ទងនឹងចំនុចត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」 បើ រថយន្តឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ មិនត្រូវនឹងស្តង់ដា គឺមិនអាចប្រើ បានឡើយ។<br>2 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋារ៉ែក្រោមដីប្រភេទលោហៈនិងអលោហៈ នៅក្នុងរូងករណីប្រើរថយន្តនិង យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ គោរពតាមការកំណត់នៃ 「សេចក្តីប្រកាសទាក់ទងនឹងចំនុចត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」 បើ ការបញ្ចេញផ្សែងរបស់ រថយន្តឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ មិនត្រូវនឹងស្តង់ដា គឺមិនអាចប្រើ បានឡើយ។<br>3 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋារ៉ែក្រោមដីប្រភេទលោហៈនិងអលោហៈ នៅក្នុងរូងគោរពតាមការកំណត់នៃ「សេចក្តីប្រកាសទាក់ទងនឹងចំនុចត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」 បើ ប្រេងឥន្ទនៈ មិនត្រូវនឹងស្តង់ដា គឺមិនអាចប្រើ បានឡើយ។<br><br>(Head guard)<br>មាត្រា១១៤<br>ម្ចាស់សិទ្ធការងាររ៉ែ នៅការដ្ឋានរ៉ែ នៅទីកន្លែងដែលនឹងអាចមានគ្រោះថ្នាក់កើតឡើងដោយសារថ្មធ្លាក់ ចាំបាច់ត្រូវតែមានសំភារៈមួករឹងសំរាប់ការពារអ្នកដែលប្រើប្រាស់រថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ។ |

**ផ្នែកទី៣ ការត្រួតពិនិត្យ**

**(ការត្រួតពិនិត្យមុនធ្វើការងារ)**

មាត្រា១១៥

នៅការដ្ឋានរ៉ែ អ្នកដែលមានសញ្ញាប័ត្រប្រើប្រាស់ រថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែ មុនចាប់ផ្តើមអនុវត្តការងារនោះចាំបាច់ត្រូវធ្វើការត្រួតពិនិត្យរថយន្តឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ នោះជាមុនសិន។

**(ត្រួតពិនិត្យក្នុងកាលបរិច្ឆេទថេរមួយ)**

មាត្រា១១៦

1 នៅការដ្ឋានរ៉ែ អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ ស្តីពី ឧបករណ៍ខាងក្រោមរបស់ រថយន្តឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ចាំបាច់ត្រូវតែធ្វើការពិនិត្យអោយបានលើសពី១ដងក្នុង១ខែ។

a. ធ្វើការពិនិត្យតើវាមានឬមិនភាពប្រក្រតីដូចជាឧបករណ៍ប្រតិបត្តិការហ្វាំងអំប្រាយ៉ាហ្ស

b. តើខ្សែពួរ និងច្រវ៉ាក់មានខូចខាតឬក៏អត់

c. តើ(bucket) (dipper) មានខូចខាតឬក៏អត់។

d. តើឧបករណ៍ផ្តល់សំឡេងរ៉ោរ៍សំរាប់សុវត្ថិភាពមានភាពប្រក្រតីឬក៏អត់

2 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ អាចអោយ អ្នករៀនចប់នូវការបណ្តុះបណ្តាលសុវត្ថិភាពទាក់ទងនឹងការរៀបចំជួសជុលរថយន្ត ឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ដែលកំណត់ដោយចំនុចមុន អនុវត្តការត្រួតពិនិត្យបាន។

នៅក្នុងករណីនេះ អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ ចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យបញ្ជាក់ពីលទ្ធផលនេះជាថ្មីម្តងទៀត។

3 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ ចាំបាច់ត្រូវតែកត់ត្រាលើ សៀវភៅគ្រប់គ្រង

「រថយន្តនិងយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ」 ស្ដីលទ្ធផលនៃការពិនិត្យដែលកំណត់នៅចំនុច១។

**(ការត្រួតពិនិត្យដោយម៉ត់ចត់)**

មាត្រា១១៧

1 ម្ចាស់សិទ្ធការងាររ៉ែ ស្ដីអំពីមានភាពប្រក្រតីឬមិនមានភាពប្រក្រតីចំពោះគ្រឿងបន្លាស់នីមួយៗរបស់រថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ត្រូវធ្វើការត្រួតពិនិត្យក្នុងរយៈពេលថេរមួយឲ្យបានលើសពី១ដងក្នុង១ឆ្នាំ ចាំបាច់ត្រូវធ្វើការកត់ត្រាអំពីលទ្ធផលនោះលើ「សៀវភៅលើគ្រប់គ្រង」។

2 ម្ចាស់សិទ្ធការងាររ៉ែ នៅពេលឲ្យអ្នកមានសញ្ញប័ត្រទទួលស្គាល់ជាផ្លូវការ ធ្វើការ ត្រួតពិនិត្យជួសជុល ដោយម៉ត់ចត់តាមការកំណត់នៃចំនុចមុន គឺចាត់ទុកថា ត្រូវបានធ្វើការត្រួតពិនិត្យរួចដូចចំនុចមុន។

**(វិធានការនៅពេល ធ្វើការត្រួតពិនិត្យ ជួសជុល)**

មាត្រា១១៨

ម្ចាស់សិទ្ធការងាររ៉ែ នៅការដ្ឋារ៉ែ នៅពេលឲ្យធ្វើការងារជួសជុល ពេលលើកដងនិងដៃ នៃប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែឬរថយន្ត ពិនិត្យមើលនៅខាងក្រោមនៃទីនោះដោយអោយកម្មកររ៉ែធ្វើការពិនិត្យ ចាំបាច់ចាត់វិធានការសមស្រម ដូចជាការ ប្រើបង្គោលជំរសុវត្ថិភាព សសរសុវត្ថិភាព ដើម្បីហាមមិនឲ្យចូលក្នុងទីនោះ។

**ផ្នែកទី៤ ការទប់ស្កាត់គ្រោះថ្នាក់តាមរយៈការប្រើប្រាស់**

**(កាតព្វកិច្ចនៃបើកបរមានសុវត្ថិភាព)**

មាត្រា១១៩

នៅការដ្ឋារ៉ែ អ្នកមានប័ណ្ណផ្នែកបើកបរ ចាំបាច់ត្រូវតែបើកបរ រថយន្តឬ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ក្នុងល្បឿន និង វិធីមានសុវត្ថិភាព។

**(ការកំរិតនៃការប្រើ និង ទំនង់ផ្ទុក ប្រើក្នុងបំណងផ្សេង)**

មាត្រា១២០

1 នៅការដ្ឋារ៉ែអ្នកមានប័ណ្ណផ្នែកបើកបរអនុវត្តការងារដោយប្រើបរ រថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ គឺមិនអាចយកប្រើក្នុងគោលបំណងផ្សេងទៀតបានឡើយ។

2 រថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ មិនអាចមនុស្សជិះថែម ឬធ្វើការផ្ទុកលើសចំណុះនៃទំងន់ ឬ លើសចំនួចមនុស្សដែលបានកំរិតនោះបានឡើយ ។

3 នៅពេលអនុវត្តការងារដោយប្រើ យានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ ដើម្បីទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈការខូចនៃឧបករណ៍ការងារ ដូចជាដៃ ដងសន្ទូច ឬ ការរលំតាមភាពមិនមានលំនឹងតាមការកំណត់លើរចនាសម្ព័ន្ធ ហាមមិនឲ្យប្រើលើសពីទំងន់ ដែលត្រូវជាអតិបរិមាបានទេ។

4 អ្នកមានប័ណ្ណផ្នែកបើកបរអនុវត្តការងារដោយប្រើបរ រថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ គឺមិនអាចអោយកម្មកររ៉ែជិះរថយន្តណាដែលគ្មានកៅអីបានឡើយ។

**(វិធានការនៃករណី ឃ្លាតឆ្ងាយពីរថយន្តឬយានដែលជាប្រភេទគ្រឿងចក្រនៃការដ្ឋានរ៉ែ)**

មាត្រា១២១

នៅការដ្ឋានរ៉ែនៅពេលអ្នកមានប័ណ្ណបើកបរលើផ្នែកបើកបរចេញឃ្លាតឆ្ងាយពី រថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែ ចាំបាច់ត្រូវតែគោរពតាមចំនុចនីមួយៗដែលបានកំណត់ដូចខាងក្រោម៖

a. ការទំលាក់ដៃ និងប៉ែលចុះមកដល់ផ្ទាល់ដី។
b. ការបញ្ឈប់ម៉ាស៊ីន និងវិធានការចាំបាច់ដើម្បីទប់ស្កាត់ការបំលាស់ទីដោយដៃជន្យដោយធ្វើការដាក់ហ្វាំង។

| | |
|---|---|
| | c. ចំពោះរថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែមានសោរចល័ត មានវិធានការចាំបាច់ដោយធ្វើយ៉ាងណាមិនឲ្យអ្នកដែលគ្មានប័ណ្ណបើកបរផ្នែកនេះ ធ្វើការបើកបរបាន។<br><br>**ផ្នែកទី៥ ផ្លូវនៅការដ្ឋានរ៉ែ និង ផ្លូវនៅក្នុងរូង**<br>**(ផ្លូវនៅការដ្ឋានរ៉ែ)**<br>មាត្រា១២២<br>1 ម្ចាស់សិទ្ធការងាររ៉ែ រចនាសម្ព័ន្ធនៃផ្លូវនៅការដ្ឋានរ៉ែ ចាំបាច់ត្រូវតែជាផ្លូវដែលមានសុវត្ថិភាព ដោយសំរបសំរួលតាមស្ថានភាពការធ្វើដំណើររបស់ រថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែ នៅក្នុងការដ្ឋានរ៉ែនោះ និង ស្ថានភាពនៃអាកាសធាតុ ភូគ្គសាស្រ្ត សណ្ឋានដីនៃទីកន្លែងមាននៅការដ្ឋានរ៉ែនោះ។<br>2 ផ្លូវថ្នល់ការដ្ឋានរ៉ែនៃការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែផ្សូងថ្ម ចាំបាច់ត្រូវតែតំឡើងបរិក្ខារសុវត្ថិភាពរួមមាន របង ផ្លាកសញ្ញាចរាចរចំពោះកន្លែងចាំបាច់។<br><br>(**ផ្លូវនៅក្នុងរូង**)<br>មាត្រា១២៣<br>1 ម្ចាស់សិទ្ធការងាររ៉ែ ផ្លូវនៅក្នុងរូងដែលត្រូវបានធ្វើដំណើរជាធម្មតា ដោយរថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែចាំបាច់ត្រូវតែគោរពតាមចំនុចនីមួយៗដែលបានកំណត់ដូចខាងក្រោម៖<br>a. ការរក្សានូវផ្ទៃផ្លូវដែលមានសុវត្ថិភាពក្នុងការធ្វើដំណើរ។<br>b. ទទឹងនៃផ្នែកសំរាប់ផ្តល់ក្នុងការធ្វើដំណើរក្នុងរូង គឺជាទទឹងមានសុវត្ថិភាពលើការធ្វើដំណើរដោយរថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែ។<br>c. ដើម្បីទប់ស្កាត់ចំពោះគ្រោះមហន្តរាយ តាមរយៈការប៉ះទង្គិចឬប៉ះក្នុងច្រកចង្អៀត ចាំបាច់ត្រូវរក្សានូវគំលាតសមរម្យរវាងរថយន្តនិងវត្ថុជាឧបសគ្គ ឬពិដាននៃផ្លូវនៅក្នុងរូង។ |

| | |
|---|---|
| | d. តំឡើងផ្លាកសញ្ញាចរាចរចំពោះកន្លែងចាំបាច់ និងតំឡើងបរិក្ខារសុវត្ថិភាពនៃភ្លើងចរាចរ។<br>e. ចំពោះការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែត្បូងថ្ម ការតំឡើងបរិក្ខារអំពូលបំភ្លឺសំរាប់កន្លែងចាំបាច់។<br>2 ផ្លូវក្នុងដែលជាធម្មតាត្រូវបានអោយ រថយន្តឬប្រភេទយានដែលជាគ្រឿងចក្រនៃការដ្ឋានរ៉ែធ្វើដំណើរ គឺហាមមិនអោយកម្មកររ៉ែប្រើផ្លូវនោះជាមួយបានទេ។ ក៏ប៉ុន្តែ មានការលើកលែងនៅពេលមានវិធានការចាំបាច់សំរាប់សុវត្ថិភាពដល់កម្មករ ឬ បង្កើតកន្លែងជៀសគ្នាដោយមានគំលាតសមរម្យ ឬនៅពេលបង្កើតផ្លូវដើរមានទទឹងលើសពី០,៧ម៉ែត្រចេញពីផ្លូវប្រើរួមដោយប្រើ ។<br><br>**ជំពូកទី៧ ការដឹកជញ្ជូន**<br>**ផ្នែកទី១ បទបញ្ញត្តិទូទៅ**<br>មាត្រា១២៤<br>ស្តីពីសុវត្ថិភាពទាក់ទងនឹង ការដឹកជញ្ជូន យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ និង កម្មកររ៉ែ យោងតាមការកំណត់តាមមាត្រា៦នៃច្បាប់ ចាំបាច់ត្រូវតែគោរពតាមចំនុចដែលបានចាត់អនុលោមតាមការកំណត់តាមមាត្រា៣១-២នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។<br><br>(**ការត្រួតពិនិត្យឧបករណ៍សុវត្ថិភាពដែលជាម៉ាស៊ីន**<br>មាត្រា១២៥<br>អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ ស្តីអំពីគ្រឿងបំលាស់ បរិក្ខារដែលមានដូចខាងក្រោម។ល។ ត្រូវធ្វើការត្រួតពិនិត្យរកមើលនូវភាពមិនប្រក្រតីឬប្រក្រតី ជារៀងរាល់ថ្ងៃ ព្រមទាំងត្រូវតែធ្វើការកត់ត្រានូវលទ្ធផលទាំងនោះលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។ |

a. ឧបករណ៍សុវត្ថិភាពមានលក្ខណៈជាម៉ាស៊ីនសំរាប់ខាយោងដឹកជញ្ជូនមនុស្ស ។
b. ឧបករណ៍សុវត្ថិភាពមានលក្ខណៈជាម៉ាស៊ីននៃខ្សែពានដឹកជញ្ជូន ឧបរណ៍បង្វិល ឧបរណ៍ទាញ ហ្វាំង ខ្សែពាន រលូ ពូលីនិងប្រែហម។
c. ឧបករណ៍ខាដោយប្រើខ្សែពួរ ហ្វាំង និង អំប្រាយ៉ា និង ឧបករណ៍សុវត្ថិភាពមានលក្ខណជាម៉ាស៊ីន។
d. ម៉ាស៊ីនខាប្រើដោយខ្សែពួរដែលភ្ជាប់ជាមួយrope socket, rink, chain, pin។
e. កន្ត្រក cage នៃម៉ាស៊ីនខា រទេះអូសដោយកំឡាំងមនុស្ស និង រទេះអូសដែលភ្ជាប់ជាមួយនឹង rink និង chain, pin ។

មាត្រា១២៦

អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពម៉ាស៊ីន ស្តីពី គ្រឿងបំលាស់ ឧបករណ៍ អគារ។ល។ដែលមានលើកឡើងដូចមាត្រាមុន ធ្វើការអនុវត្តពិនិត្យអើយបានលើសពី១ដងក្នុងរយៈពេល៣ខែ និងចាំបាច់ត្រូវកត់ត្រានូវលទ្ធផលទាំងនោះក្នុងសៀវភៅគ្រប់គ្រង។

មាត្រា១២៧

1 អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពម៉ាស៊ីន ស្តីអំពីឧបរណ៍សុវត្ថិភាពផ្នែកអគ្គិសនីនៃconveyorដែលធ្វើការដឹករបស់ក្រៅពីដឹកមនុស្ស ក៏ដូចជាឧបរណ៍សុវត្ថិភាពផ្នែកអគ្គិសនីនិងឧបករណ៍ផ្តល់សញ្ញាដោយប្រើចរន្តអគ្គិសនីនៃlift និង conveyorដែលសំរាប់ដឹកមនុស្ស និងម៉ាស៊ីនខារ ធ្វើការពិនិត្យរាល់ពេលធ្វើការងាររកមើលឲ្យឃើញនូវភាពមិនប្រក្រតីឬមិនមាន ព្រមទាំងធ្វើការកត់ត្រានូវលទ្ធផលទាំងនោះលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពផ្នែកអគ្គិសនី ធ្វើការអនុវត្តពិនិត្យអើយបានលើសពី១ដងក្នុងរយៈពេល៣ខែ និងចាំបាច់ត្រូវកត់ត្រានូវលទ្ធផលទាំងនោះក្នុង「សៀវភៅគ្រប់គ្រង」។

| | |
|---|---|
| | មាត្រា១២៨<br>1　អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពម៉ាស៊ីន ស្តីអំពីផ្លូវនៅក្នុងរូងដែលបានតំឡើងliftសំរាប់ដឹកមនុស្ស ក៏ដូចជាផ្លូវដែកនិងផ្លូវនៅក្នុងរូងដែលជាយានធ្វើដំណើរសំរាប់ដឹកមនុស្ស រូងបញ្ឈរដែលបានបង្កើតឡើងសំរាប់ធ្វើការដឹកជញ្ជូនមនុស្សដោយម៉ាស៊ីនខារ　ធ្វើការពិនិត្យរាល់ពេលធ្វើការងាររកមើលឲ្យឃើញនូវភាពមិនប្រក្រតីឬមិនមាន ព្រមទាំងធ្វើការកត់ត្រានូវលទ្ធផលទាំងនោះលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។<br>2　អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពម៉ាស៊ីន ផ្លូវដែកនិងផ្លូវនៅក្នុងរូងដែលជាយានធ្វើដំណើរសំរាប់ក្រៅពីការដឹកមនុស្ស　ធ្វើការពិនិត្យរាល់ពេលធ្វើការងាររកមើលឲ្យឃើញនូវភាពមិនប្រក្រតីឬមិនមាន ព្រមទាំងធ្វើការកត់ត្រានូវលទ្ធផលទាំងនោះលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។<br><br>**ផ្នែកទី២　ឧបករណ៍សុវត្ថិភាពទូទៅ**<br><br>**(ហ្វាំង)**<br>មាត្រា១២៩<br>ម្ចាស់សិទ្ធការងាររ៉ែ ចំពោះហ្វាំងនៃliftនិង conveyorធ្វើការដឹកជញ្ជូនមនុស្ស និង ម៉ាស៊ីនខាសំរាប់រូងជំរេល ម៉ាស៊ីនខាសំរាប់រូងបញ្ឈរ ម៉ាស៊ីនខារសំរាប់រូងជំរេល　cageផ្ទុកទំងន់បានជាអតិបរមា កន្ត្រក　skip រថភ្លើង និងbelt ឬ ឧបករណ៍ដឹកជញ្ជូន ទោះបីនៅទីតាំងណាក៏ដោយ ក៏អាចធ្វើការបញ្ឈប់បានជាបន្ទាន់ និងចាំបាច់រក្សាអោយបានល្អ។<br><br>**(អត្រាប្រសិទ្ធិភាព)**<br>មាត្រា១៣០ |

1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះម៉ាស៊ីនខារសំរាប់រូងបញ្ឈរក្នុងការដាក់លើកមនុស្សចុះ នៅពេលតំឡើងខ្សែពួរ និង សំភារៈលោហៈធ្វើការរក្សាចំពោះកន្ត្រកឬcage ចំពោះអត្រាប្រសិទ្ធិភាពនៃការផ្ទុកបានទំងន់អតិបរិមាស្ទាត់គឺត្រូវឲ្យមានលើសពី១០ និង ចំពោះទំងន់អតិបរមាទូទៅគឺត្រូវឲ្យមានលើសពី៥។

2 ស្តីពីវិធីគណនានៃអត្រាប្រសិទ្ធិភាពនៃចំនុចមុន ធ្វើការគណនាដោយអនុវត្តតាម 「សេចក្តីប្រកាសទាក់ទងនឹងចំនុចដែលត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」។

មាត្រា១៣១

1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះម៉ាស៊ីនខារទេះអូសនៃផ្លូវជំរេល ឬម៉ាស៊ីនខារទេះអូសនៃផ្លូវជំរេលនៅការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែត្បូងថ្ម នៅពេលបង្កើតខ្សែពួរនិងសំភារៈលោហៈរក្សារទេះអូសនោះ ចំពោះអត្រាប្រសិទ្ធិភាពនៃការផ្ទុកបានទំងន់អតិបរិមាស្ទាត់គឺត្រូវឲ្យមានលើសពី១០និងចំពោះទំងន់អតិបរមាទូទៅគឺត្រូវឲ្យមានលើសពី៥។

2 ស្តីពីវិធីគណនានៃអត្រាប្រសិទ្ធិភាពនៃចំនុចមុន ធ្វើការគណនាដោយអនុវត្តតាម 「សេចក្តីប្រកាសទាក់ទងនឹងចំនុចដែលត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」។

មាត្រា១៣២

1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះម៉ាស៊ីនខារធ្វើការដឹកជញ្ជូនរបស់ក្រៅពីមនុស្ស នៅពេលតំឡើងខ្សែពួរនិងសំភារៈលោហៈសំរាប់រក្សាកន្ត្រក cage skipឬយាន ចំពោះអត្រាប្រសិទ្ធិភាពនៃការផ្ទុកបានទំងន់អតិបរិមាស្ទាត់គឺត្រូវឲ្យមានលើសពី៦ និង ចំពោះទំងន់អតិបរមាទូទៅគឺត្រូវឲ្យមានលើសពី៣។

2 ចំពោះផ្លូវសំរាប់ខារដោយendlessនៃរូងជំរេលនៅការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែត្បូងថ្ម នៅពេលតំឡើងខ្សែពួរ ចំពោះអត្រាប្រសិទ្ធិភាពនៃការផ្ទុកបានទំងន់អតិបរិមាស្ទាត់គឺត្រូវឲ្យមានលើស

| | |
|---|---|
| | ពី៣និងចំពោះទំងន់អតិបរមាទូទៅគឺត្រូវឲ្យមានលើសពី២។<br>3 ចំពោះរូងបញ្ឈរនៃការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែថ្មុងថ្ម នៅពេលតំឡើងខ្សែពួរនិងសំភារៈលោហៈសំរាប់រក្សាska hoad ចំពោះអត្រាប្រសិទ្ធិភាពនៃការផ្ទុកបានទំងន់អតិបរិមាស្ទាត់គឺត្រូវឲ្យមានលើសពី៦និងចំពោះទំងន់អតិបរមាទូទៅគឺត្រូវឲ្យមានលើសពី៣។<br>4 ស្តីពីវិធីគណនានៃអត្រាប្រសិទ្ធិភាពនៃចំនុចមុន ធ្វើការគណនាដោយអនុវត្តតាម「សេចក្តីប្រកាសទាក់ទងនឹងចំនុចដែលត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」។<br><br>មាត្រា១៣៣<br>1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះអត្រាសុវត្ថិភាពនៃខ្សែពាននៃbelt converyorដែលសំរាប់ធ្វើការដឹកជញ្ជូនមនុស្សនៅការដ្ឋានរ៉ែថ្មុងថ្ម (មានខ្សែពួរនៃbelt conveyorរួមទាំងខ្សែពួរគាំទ្រខ្សែពាន) ចាំបាច់ត្រូវតែមានលើសពី១០ធៀបទៅនឹងទំងន់ដែលលើកដោយស្ទាត់ស្មៀម និង ៥ធៀបទៅនឹងទំងន់ផ្ទុកសរុប។<br>2 ស្តីពីវិធីគណនានៃអត្រាប្រសិទ្ធិភាពនៃចំនុចមុន ធ្វើការគណនាដោយអនុវត្តតាម 「សេចក្តីប្រកាសទាក់ទងនឹងចំនុចដែលត្រូវតែសរសេរធ្វើការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」។<br><br>**(ឧបករណ៍ផ្តល់សញ្ញា)**<br>មាត្រា១៣៤<br>1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះផ្លូវនៅក្នុងរូងដែលបានតំឡើងដោយម៉ាស៊ីនខាររទេះendless ឬផ្លូវសំរាប់រទេះខារ ផ្លូវសំរាប់រទេះខារដោយស្វ័យប្រវត្តិ និងរូងបញ្ឈរដែលត្រូវបានតំឡើងម៉ាស៊ីនខារ ក្រៅនៅពេលប្រើជាសញ្ញាច្បាស់លាស់ដោយសំឡេងមនុស្ស ចាំបាច់ត្រូវតែតំឡើងបរិក្ខារផ្តល់សំឡេង។<br>2 ចំពោះរូងបញ្ឈរដែលត្រូវបានតំឡើងម៉ាស៊ីនខារសំរាប់ដឹកជញ្ជូនមនុស្ស នៅការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែថ្មុងថ្ម ស្តីអំពីគំលាតរវាងទីកន្លែងជិះឬចុះនៃផ្លូវជំរាលនិងរូងជំរាល នឹងកន្លែងទីតាំង |

ម៉ាស៊ីនខារ ចាំបាច់ត្រូវតែតំឡើងឧបករណ៍ផ្តល់សញ្ញាឲ្យបានលើសពី២គ្រឿងរួមទាំងប្រភេទ power of hearing type។ ចំពោះក្នុងករណីនេះ ទូរស័ព្ទអាចចាត់ទុកថាជាប្រភេទpower of hearing type។

3 ចំពោះរូងជំរេលនិងផ្លូវជំរេល ដែលត្រូវបានតំឡើងម៉ាស៊ីនខារសំរាប់ដឹកជញ្ជូនមនុស្ស នៅការដ្ឋានរ៉ែលោហៈនិងការដ្ឋានរ៉ែធ្យូងថ្ម ស្តីអំពីឧបករណ៍ផ្តល់សញ្ញានៃចំនុចមុនមួយ ចាំបាច់ត្រូវតែអាចធ្វើការផ្តល់សញ្ញាជាមួយនឹងទីកន្លែងម៉ាស៊ីនខារនៃទីតាំងនោះដែលមាននៅក្នុងរូងជំរេលនិងផ្លូវជំរេល។ ក៏ប៉ុន្តែ មិនកំណត់ចំពោះនៅពេលអាចធ្វើការផ្តល់សញ្ញាដោយប្រើសំឡេងមនុស្សពីផ្លូវជំរេលនៃការដ្ឋានរ៉ែ ឬនៅពេលតំឡើងបរិក្ខារដែលអាចធ្វើការបញ្ឈប់ម៉ាស៊ីនខារនោះបានដោយពិតប្រាកដ ទោះបីនៅមានមនុស្សនៅក្នុងរថយន្តក៏ដោយ។

4 ផ្លូវរូងដែលបានបង្កើតខ្សែពានធ្វើការដឹកជញ្ជូនមនុស្សនៅការដ្ឋានរ៉ែ តំឡើងទូរស័ព្ទដែលអាចធ្វើការទាក់ទងគ្នា រវាងកន្លែងជិះនិងកន្លែងចុះ តំឡើងវិទ្យុទាក់ទងនៅកន្លែងជិះនិងចុះ នោក្នុងរូង និងចាំបាច់ត្រូវតែតំឡើងឧបករណ៍ ផ្តល់សញ្ញាដល់អ្នកជិះពីកន្លែងឡើងជិះនិងចុះ។

5 មានតំឡើងនៅក្នុងcageដែលធ្វើការដឹកជញ្ជូនមនុស្សនៅក្នុងការដ្ឋានរ៉ែលោហៈ ទោះបីនៅទីណាក៏ដោយឲ្យតែនៅក្នុងរូងបញ្ឈរហើយអាចធ្វើការផ្តល់សញ្ញាបានដោយឧបករណ៍នោះបាន គឺចាត់ទុកថាជាបរិក្ខារផ្តល់សញ្ញានៃចំនុចទី២។

**(ឧបករណ៍ទប់ស្កាត់បោលដោយឯកឯង**

មាត្រា១៣៥

1 ម្ចាស់សិទ្ធការងាររ៉ែ នៅពេលធ្វើការបើកបរយានយន្ត តោងតាមរយៈផ្លូវខារដោយស្វ័យប្រវត្តិ ផ្លូវខារ ឬផ្លូវខារដោយendless (លើកលែងតែផ្លូវខារដោយendlessដែលលក្ខណៈស្រប) ដើម្បីទប់ស្កាត់គ្រោះថ្នាក់តាមរយៈយានបំលាស់ដីដោយឯកឯង ចាំបាច់ត្រូវតែតំឡើងបរិក្ខារចាំបាច់ផ្សេងៗទៀតឲ្យទប់ស្កាត់ការបំលាស់ទីដោយយាននោះ បរិក្ខារទប់ស្កាត់ ការបំលាស់ទីដោយយាននោះ

| | |
|---|---|
| | នៅទីកន្លែងចាំបាច់នៃរូងជំរេលក៏ដូចជារថយន្ត ។<br>2 នៅពេលមានភាពចាំបាច់សំរាប់សុវត្ថិភាព ចាំបាច់ត្រូវតែតំឡើងបរិក្ខារទប់ស្កាត់គ្រោះថ្នាក់ដូចជាឧបករណ៍បញ្ចេញសំឡេងរោរ៍ និង ឧបករណ៍គ្រប់គ្រងល្បឿន។<br>3 ចំពោះការដឹកជញ្ជូនដោយការរុញដោយដៃ នៅពេលអាចនឹងមានគ្រោះថ្នាក់កើតឡើងច្រើនដោយសារការបំលាស់ទីដោយខ្លួនឯងនៃយាននោះ ចាំបាច់ត្រូវតែតំឡើងឧបករណ៍គ្រប់គ្រងល្បឿន បរិក្ខារទប់ស្កាត់គ្រោះថ្នាក់ ចាំបាច់ត្រូវតែតំឡើងឧបករណ៍គ្រប់គ្រងល្បឿនចំពោះយានទាំងនោះ។<br><br>**(វិធានការចំពោះទីកន្លែងមានគ្រោះថ្នាក់។ល។)**<br>មាត្រា១៣៦<br>1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះផ្លូវដែកនៅខាងក្រៅរូង ក៏ដូចជាផ្លូវនៅក្នុងរូងសំរាប់ធ្វើការដឹកជញ្ជូន ទីកន្លែងមានគ្រោះថ្នាក់ច្រើនក្នុងការដឹកជញ្ជូន ទីកន្លែងកំពុងសាងសង់ជួសជុលផ្សេងៗ។ល។ ចាំបាច់ត្រូវតែចាត់វិធានការអាចងាយឃើញចំពោះទីកន្លែងនោះ ដោយប្រើផ្លាកសញ្ញាប្រយ័ត្ន ភ្លើងក្រហមលោតភ្លឹបភ្លែត។<br>2 ចំពោះទីកន្លែងដែលត្រូវការចាំបាច់លើផ្នែកសុវត្ថិភាពផ្សេងៗ នៃទីកន្លែងដំណើរការរថភ្លើងនៃផ្លូវដឹកជញ្ជូនសំខាន់ៗ ចាំបាច់តំឡើងអំពូលបំភ្លឺ ។<br><br>**ផ្នែកទី៣ ការដឹកជញ្ជូនមនុស្ស**<br>**(ម៉ាស៊ីនខារនៅក្នុងរូងបញ្ឈរសំរាប់លើកដាក់មនុស្សចុះ)**<br>មាត្រា១៣៧<br>ម្ចាស់សិទ្ធការងាររ៉ែ ម៉ាស៊ីនខារនៅក្នុងរូងបញ្ឈរសំរាប់លើកដាក់មនុស្សចុះ នៃការដ្ឋានរ៉ែ ចាំបាច់ត្រូវតែគោរពតាមចំនុចនីមួយៗដែលមានដូចខាងក្រោម៖ |

| | |
|---|---|
| | a. រៀបចំឲ្យមានឧបករណ៍ពីការបង្ហាញនៃ ជំរៅ។<br>b. បង្កើតបរិក្ខារទប់ស្កាត់គ្រោះថ្នាក់តាមរយៈល្បឿន លឿនពេក និង ការខារជ្រួលពេក។<br>c. បង្កើតបរិក្ខារទប់ស្កាត់គ្រោះថ្នាក់នៅពេលមានភាពមិនប្រក្រតីដោយសារដាច់ចរន្ត និងដោយកំឡាំងផ្សេងទៀត។<br>d. បង្កើតបរិក្ខារទប់ស្កាត់ការធ្លាក់ចុះនៃរបស់ផ្សេងៗ ទ្វាសុវត្ថិភាពតាមរយៈការបិទដោយដៃឬដោយស្វ័យប្រវត្តិ នៅទីកន្លែងជិះផ្នែកខាងពាក់កណ្តាលជណ្តើរនិងមាត់រូង។<br>e. នៅទីកន្លែងជិះផ្នែកខាងពាក់កណ្តាលជណ្តើរនិងបាតរូង នៅពេលមានផ្លូវរូងទាំងសងខាង ចាំបាច់ត្រូវទុកផ្លូវម្ខាងសំរាប់ជាផ្លូវវាង។<br>f. ចំពោះcage រៀបចំឲ្យមានគំរបដោយបន្ទះដែក និងរៀបចំព័ទ្ធដោយជុំវិញសំរាប់ទប់ស្កាត់ការធ្លាក់ចុះ ចំពោះខាង មុននិងខាងក្រោយ ចាំបាច់រៀបចំឲ្យមានឈើបញ្ឈរឬធ្វើការបិទដើម្បីសុវត្ថិភាព។<br>g. ចំពោះcage រៀបចំបិទឬត្រូវឲ្យមានកន្លែងសំរាប់ដើម្បីសុវត្ថិភាពនិងមានលំនឹងដល់មនុស្សដែលនៅទីនោះ។<br>h. ចំពោះcageរៀបចំtopping liftបំរុងនៃការយោង។<br>i. មិនត្រូវប្រើខ្សែពួរដែលមានចំណង។<br>j. ចំពោះខ្សែពួរ យោងតាមរយៈការពុកផ្លួយ ការកកិត កំឡាំងទាញ ការកាត់ដាច់ នៅពេលបានថយចុះក្រោម៨០%  នៃអត្រាភាគរយសុវត្ថិភាព ដែលកំណត់ដោយមាត្រាទី៣១២៩-១ គឺមិនត្រូវប្រើជាដាច់ខាត។<br>k. វិធីបញ្ចេញសញ្ញានៅទីតាំងខារ ចាំបាច់ត្រូវតែបង្ហាញចំពោះទីកន្លែងនោះដោយរៀបចំម៉ាស៊ីនសញ្ញានៃទីកន្លែង ឡើងជិះ និងទីកន្លែងដែលអ្នកប្រើម៉ាស៊ីនខារងាយមើលឃើញ។<br>l. ធ្វើការបង្ហាញអំពីចំនួនអតិបរមានៃអ្នកជិះចំពោះទីតាំងជិះនោះ។<br>2 វិធីវាស់នៃការបន្ថយអត្រាសុវត្ថិភាពនៃចំនុច j មុន នៃធ្វើការបង្ហាញផ្សេង។ |

| | |
|---|---|
| | **(ម៉ាស៊ីនខារទេះអូសដោយមនុស្សនៃរូងជំរេល)**<br>មាត្រា១៣៨<br>ម្ចាស់សិទ្ធការងាររ៉ែ ម៉ាស៊ីនខាររទេះអូសនៃផ្លូវជំរេល ឬម៉ាស៊ីនខាររទេះអូសនៃរូងជំរេលនៃការដ្ឋានរ៉ែ ក្រៅពីការកំណត់តាមមាត្រាមុនចំនុច១-a រហូតដល់c ចំនុចi ចំនុចk និង លេខ១ ចាំបាច់ត្រូវតែគោរពតាមការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោម៖<br>a. គំលាតរវាងជញ្ជាំងនៃផ្លូវក្នុងរូងឬរបស់ឧបសគ្គដែលនៅជិតមនុស្សនិងរទេះអូស នឹងត្រូវឲ្យមានគំលាតរវាងគ្នានឹងគ្នា0,៧៥ម៉ែត្រ ចំពោះកន្លែងផ្សេងទៀតមានគំលាតគ្នា0,៣ម៉ែត្រ ។<br>b. គំលាតរវាងគំរបនៃរទេះអូសនិងពិដាន ឬរបស់ដែលជាឧបសគ្គត្រូវឲ្យមានលើសពី0,៣ម៉ែត្រ។<br>c. ចំពោះរទេះអូស រៀបចំឲ្យមានគំរប និងផ្នែកម្ខាង ហ៊ុំព័ទ្ធដោយរបស់មានសុវត្ថិភាពនិងមានបង្កោលឈើ។<br>d. ចំពោះរទេះអូសនៅការដ្ឋានរ៉ែលោហៈយោងតាមរយៈល្បឿនលឿនពេកនិងការដាច់ខ្សែពួរ ចាំបាច់ត្រូវឧបករណ៍បញ្ឈប់ដោយដៃនិងមានបរិក្ខារទប់ស្កាត់គ្រោះថ្នាក់។<br>e. ករណីធ្វើការភ្ជាប់នឹងrinkឬច្រវ៉ាកចំពោះ rope socketនិងរទេះអូស ក៏ដូចជារទេះអូសនៃការដ្ឋានរ៉ែលោហៈឬធ្វើការភ្ជាប់ចំពោះរទេះ។<br>f. ខ្សែពួរ យោងតាមភាពពុកផុយ កកឹត សឹក ដាច់។ល។ នៅពេលមានការថយចុះនៅក្រោម ៨0ភាគរយ នៃអត្រាសុវត្ថិភាពតាមការកំណត់នៃមាត្រា១៣0-១។<br>a. នៅពេលមានជំលេលើសពី ៣0ភាគរយ ចាំបាច់ត្រូវតំឡើងឧបករណ៍ទប់ស្កាត់ការភ្លាត់ចេញពីផ្លូវ។<br>2 ស្តីពី វិធីវ៉ាស់នៃភាពចុះសុវត្ថិភាពនៃចំនុចfមុន ធ្វើការរៀបចំកំណត់តាមមាត្រាមុននៃចំនុច២។<br><br>**(belt convoyerដែលប្រើសំរាប់ដឹកមនុស្ស)**<br>មាត្រា១៣៩ |

| | |
|---|---|
| | ម្ចាស់សិទ្ធការងាររ៉ែ ចំពោះbelt convoyerដែលប្រើសំរាប់ដឹកមនុស្សនៅការដ្ឋានរ៉ែធ្យូងថ្ម ចាំបាច់ត្រូវតែអនុលោមតាមការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោមៈ<br>a. ចំពោះទីកន្លែងជិះនិងចុះនិងនៅជិតកន្លែងនោះ ចាំបាច់ត្រូវតែមានការបំភ្លឺសំរាប់រក្សាបាននូវសុវត្ថិភាពនៃការជិះនិងចុះ ដោយតំឡើងបរិក្ខារបំភ្លឺ។<br>b. ចាំបាច់តំឡើងបរិក្ខារទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈការជិះលើសនិងល្បឿនហួសហេតុ។<br>c. ចាំបាច់បង្កើតបរិក្ខារបញ្ឈប់សំរាប់ពេលមានគ្រោះអសន្នដែលអាចដំណើរការបាន ភ្លាមៗដោយអ្នកជិះ។<br>d. ចាំបាច់តំឡើងបរិក្ខារទប់ស្កាត់ភាពគ្រោះថ្នាក់នៅពេលមានភាពមិនប្រក្រតីដោយកំឡាំង នៅពេលមានការដាច់ចរន្ត។<br>e. ចាំបាច់តំឡើងបរិក្ខារទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈការរអិលនៃខ្សែពួរដែលគាំទ្រខ្សែពាននៃ belt conveyor។<br>f. ចំពោះខ្សែពាន ផ្នែកវិលនៃរឡូរបស់belt conveyor ចាំបាច់ការរក្សាបាននូវគំលាតសមរម្យ ដើម្បីទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈការប៉ះរវាងរបស់ជាឧបសគ្គនឹងផ្ទៃបាតនៃផ្លូវនៅក្នុងរូង។<br>g. ចំពោះគំលាតរវាងរបស់ជាឧបសគ្គនឹងពិដានឬខ្សែពាន នៅទីកន្លែងជិះនិងចុះនិងនៅជុំទីនោះ ចាំបាច់ត្រូវមានលើសពី១,៨ម៉ែត្រឡើង និងកន្លែងផ្សេងទៀតត្រូវមានលើសពី១,២ម៉ែត្រឡើង។<br>h. ចំពោះផ្លូវនៅក្នុងរូងដែលតំឡើង belt conveyor ចាំបាច់ត្រូវតែជារូងសំរាប់សង់ដោយប៉េតុង និងមិនឲ្យមានការធ្លាក់នូវថ្មទាំងឡាយចុះទៅបាន។<br>2 នៅពេលបានបញ្ឈប់belt conveyor អ្នកទទួលបន្ទុកគ្រប់គ្រងការងារ ចាំបាច់ត្រូវតែធ្វើការបញ្ជាក់ពីការមានសុវត្ថិភាពឲ្យបានច្បាស់ជាមុនសិន ទើបអាចដំណើរការបាន។<br><br>**(ការហាមឃាត់ដឹកជញ្ជូនមនុស្សនិងសំភារៈនៅពេលជាមួយគ្នា**<br>មាត្រា១៤០ |

1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះនៅផ្លូវរាប ផ្លូវជំរេល រូងជំរេល ឬ រូងបញ្ឈរ នៅក្នុងរូងនៃការដ្ឋានរ៉ែ នៅពេលធ្វើការដឹកជញ្ជូនមនុស្ស មិនត្រូវធ្វើការដឹកជញ្ជូន មនុស្សនិងរបស់ដូចសំភារៈ ឧបករណ៍ គ្រឿងចក្រ។ល។ ដោយរថយន្តតែមួយនៅពេលជាមួយគ្នា បានឡើយ។

2 នៅការដ្ឋានរ៉ែ នៅពេលធ្វើការដឹកជញ្ជូនមនុស្សតាមរយៈbelt conveyor គឺមិនអាចធ្វើការដឹកជញ្ជូនសំភារៈ បរិក្ខារ គ្រឿងចក្រ ថ្មចោល ដោយbelt conveyorនៅពេលជាមួយគ្នា បានទេ។

## ផ្នែកទី៤ ការដឹកជញ្ជូនតាមរយៈក្បាលរថភ្លើង

**(ក្បាលរថភ្លើង)**

មាត្រា១៤១

ម្ចាស់សិទ្ធការងាររ៉ែ ក្បាលរថភ្លើងនៃការដ្ឋានរ៉ែ ចាំបាច់ត្រូវរៀបចំឲ្យមាន headlight ក៏ដូចជា ឧបករណ៍បញ្ចេញសំឡេងរោទ៍ និង ឧបករណ៍បរិក្ខារសំរាប់ជួសជុល នៅពេលមានកង់រថភ្លើងឃ្លៀតចេញពីផ្លូវដែក ។

**(ការត្រួតពិនិត្យចំពោះទិសដៅដំណើការ)**

មាត្រា១៤២

អ្នកមានសញ្ញាប័ត្រទាក់ទងនឹងបើកបរក្បាលរថភ្លើង នៅការដ្ឋានរ៉ែ ករណីបើកបរក្បាលរថភ្លើងជាធម្មតាធ្វើការត្រួតពិនិត្យទិសដៅនៃក្បាលរថភ្លើងរត់ទៅមុខ នៅពេលមានគ្រោះថ្នាក់អាចនឹងកើតមាន ចាំបាច់ត្រូវតែបើកយឺតៗ ឬ បញ្ឈប់ការបើកបរមួយរយៈ ។

**(ហាមឃាត់ការរុញនៅពីខាងក្រោយរថភ្លើង)**

មាត្រា១៤៣

ស្តីអំពីការដឹកជញ្ជូននៅលើផ្លូវនៅក្នុងរូង នៅពេលធ្វើការបើកបររថភ្លើងដោយក្បាលរថភ្លើង អ្នកមានសញ្ញប័ត្តិទាក់ទងនឹងការបើកបរក្បាលរថភ្លើង មិនត្រូវធ្វើការុញរថភ្លើងតាមរយៈក្បាលរថ

| | |
|---|---|
| | ភ្លើងឡើយ។ ក៏ប៉ុន្តែ លើកលែងតែ នៅពេលធ្វើការបើកបរយាននៅទីកន្លែងចំណតយាននោះ នៅពេលអាចនឹងមិនមានគ្រោះថ្នាក់ ដោយសារមានការនែនាំទិសដៅ ដោយកម្មកររ៉េ ។<br><br>**(វិធានការចំពោះករណីឃ្លាតឆ្ងាយចេញពីក្បាលរថភ្លើង)**<br>មាត្រា១៤៤<br>អ្នកមានសញ្ញាប័ត្រទាក់ទងនឹងការបើកបរក្បាលរថភ្លើងនៃការដ្ឋានរ៉េ នៅពេលឃ្លាតឆ្ងាយចេញពីក្បាលរថភ្លើង ចាំបាច់ត្រូវគោរពតាមការកំណត់នៃចំនុចនីមួយៗ ដែលមានដូចខាងក្រោម៖<br>a. ធ្វើការបញ្ឈប់ម៉ាស៊ីន និងចាត់វិធានការចាំបាច់សំរាប់ទប់ស្កាត់ការបំលាស់ទីដោយឯកឯងដោយធ្វើការចាប់ហ្វ៉ាំង។<br>b. ចាំបាច់កាន់កូនសោរទុកនៅក្នុងខ្លួនជាប់ជានិច្ច ចាត់វិធានការចាំបាច់សំរាប់ ក្នុងបំណងមិនឲ្យអ្នកដ៏ទៃក្រៅពីអ្នកមានសញ្ញាប័ត្រទាក់ទងនឹងការបើកបរក្បាលរថភ្លើងធ្វើការបើកបរបាន។<br><br>**(ការបំភ្លឺនៅផ្នែកខាងក្រោយនៃរថភ្លើង)**<br>មាត្រា១៤៥<br>1 ចំពោះនៅក្នុងរូង ឬ នៅពេលយប់នៃការដ្ឋានរ៉េ នៅពេលបើកបររថភ្លើងដោយក្បាលរថភ្លើង ចាំបាច់ត្រូវតែរៀបចំឲ្យមានផ្លាកសញ្ញាសមរម្យនៃការបំភ្លឺនៅផ្នែកខាងក្រោយ។<br>2 នៅការដ្ឋានរ៉ែធ្យូង ចំពោះរូងជំរេលដែលបានតំឡើងបរិក្ខារខា នៅពេលបើកបររថភ្លើង ចាំបាច់ត្រូវតែផ្តល់សញ្ញាភ្លើងក្រហមសំរាប់ឲ្យដឹងពីទិសដៅដែលនឹងត្រូវធ្វើដំណើរ។<br><br>**(ការដឹកជញ្ជូនរបស់មានប្រវែង)**<br>មាត្រា១៤៦<br>នៅការដ្ឋានរ៉េ កម្មកររ៉េ ក្នុងករណីធ្វើការដឹកជញ្ជូនដោយដឹករបស់ មានប្រវែងវែង របស់មានទំងន់ធ្ងន់ របស់មានគ្រោះថ្នាក់។ល។ អ្នកគ្រប់គ្រងការងារទទួលបន្ទុកការងារដឹកជញ្ជូននោះ ចាំបាច់ត្រូវ |

| | |
|---|---|
| | បញ្ហាដល់កម្មកររ៉ែ ទទួលបន្ទុកការងារនោះ ធ្វើយ៉ាងណាមិនឲ្យទំនិញដែលបានដឹករលំ ប៉ះនឹងរបស់ផ្សេងទៀតដែលនាំឲ្យមានគ្រោះថ្នាក់។<br><br>**(belt conveyorដែលដឹកជញ្ជូនរបស់ក្រៅពីមនុស្ស**<br>មាត្រា១៤៧<br>ម្ចាស់សិទ្ធការងាររ៉ែ ការដ្ឋានរ៉ែធ្យូងថ្ម belt conveyorដែលប្រើសំរាប់ដឹកជញ្ជូនដោយប្រើម៉ូទ័រមានកំឡាំងលើសពី២០គីឡូវ៉ាត់ ចាំបាច់ត្រូវតែ គោរពតាមការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោម៖<br>a. តំឡើងបរិក្ខារបញ្ឈប់ជាបន្ទាន់ សំរាប់ពេលមាន អសន្ន នៅពេលមានភាពមិនប្រក្រតីក្នុងធ្វើការបើកបរbelt conveyor។<br>b. មានbelt conveyorដែលត្រូវបានតំឡើងនៅក្នុងរូងជំរេល ចាំបាច់ត្រូវតែតំឡើងបរិក្ខារធ្វើការទប់ស្កាត់ភាពគ្រោះថ្នាក់ នៅពេលមានភាពមិនប្រក្រតីដោយសារដាច់ចរន្តអគ្គិសនី។<br>c. តំឡើងបរិក្ខារធ្វើការទប់ស្កាត់ភាពគ្រោះថ្នាក់ តាមរយៈការរអិលនៃខ្សែពាន។<br>d. តំឡើងបរិក្ខារធ្វើការទប់ស្កាត់ភាពគ្រោះថ្នាក់ ថ្នាក់ តាមរយៈខ្សែពាននៃbelt conveyorរត់ទៅតែម្ខាង។<br>e. ផ្នែកវិលរូឡានៃខ្សែពានរបស់ belt conveyor ដើម្បីទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈ ត្រូវរក្សានូវគំលាតសមរម្យ សំរាប់ការប៉ះរវាងរបស់ជាឧបសគ្គ ឬ ផ្ទៃបាតខាងក្រោម នៃផ្លូវនៅក្នុងរូង ចាំបាច់ត្រូវតែរក្សានូវគំលាតមួយសមរម្យ។<br>f. នៅការដ្ឋានរ៉ែធ្យូងថ្ម (ប្រភេទＡនិងប្រភេទＢ) ចាំបាច់ត្រូវតែបង្កើតបរិក្ខារទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈការឆេះ ដោយសារការប៉ះរបស់ខ្សែពាននឹងថ្មធ្យូង ដែលផ្ទុកជាគំនរនៅទីកន្លែងទុកថ្មធ្យូង។ |

## ជំពូក៨ អគ្គីភ័យ និង ការឆេះដោយធម្មជាតិ
## ផ្នែកទី១ បទបញ្ញតិទូទៅ

មាត្រា១៤៨

ស្តីពីសុវត្ថិភាពទាក់ទងនឹងអគ្គីភ័យ និង ការឆេះដោយធម្មជាតិ យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ និង កម្មកររ៉ែ យោងតាមការកំណត់តាមមាត្រា៦នៃច្បាប់ ចាំបាច់ត្រូវតែគោរពតាមចំនុចដែលបានចាត់ អនុលោមតាមការកំណត់តាមមាត្រា៣១-២នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។

## ផ្នែកទី២ ទប់ស្កាត់នៃអគ្គីភ័យនៅក្នុងរូង
## (បរិក្ខារទប់ស្កាត់អគ្គីភ័យ)

មាត្រា១៤៩

1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែក្រោមដី បន្ទប់ម៉ាស៊ីនខាឡើងចុះ បន្ទប់ម៉ាស៊ីនបូមទឹក បន្ទប់ម៉ាស៊ីនកង្ហា នៅក្នុងរូង ការតំឡើងទីតាំងដាក់បរិក្ខារបំលែងចរន្ត និង បន្ទប់កំប្រែស័រ(compressor) ទីតាំងតំឡើងរ៉ក(polleys)សំខាន់ៗ និង ឧបករណ៍ទាញខ្សែពាន(conveyor) ទីតាំងតំឡើងបរិក្ខារសាកអគ្គិសនីសំរាប់រថភ្លើងដែលប្រើតាមបែបអាគុយសាក ក្នុងតួនាទីជារចនាសម្ព័ន្ធទប់ស្កាត់អគ្គីភ័យ និង ចាំបាច់ត្រូវតែរៀបចំឲ្យមានបរិក្ខារពន្លត់អគ្គីភ័យ។

2 បន្ទប់បរិក្ខារបិទបើកបញ្ចូលប្រេងសំខាន់ៗនៅក្នុងរូង ទីកន្លែងផ្ទុកប្រភេទប្រេង និង ខ្លាញ់នៅក្នុងរូងក៏ដូចជារចនាសម្ព័ន្ធធន់នឹងភ្លើងនៃទីកន្លែងតំឡើងបរិក្ខារបំលែងចរន្តសំខាន់ៗ នៅក្នុងរូង រចនាសម្ព័ន្ធអាចធ្វើការផ្តាច់ចេញពីទីកន្លែងផ្សេងបាននៅពេលមានការចាំបាច់ និង ចាំបាច់ត្រូវតែតំឡើងបរិក្ខារពន្លត់អគ្គីភ័យ។

3 ទីតាំងតំឡើងបរិក្ខារបំលែងចរន្តដែលមានកំណត់តាមចំនុចទី២ នៅពេលប្រើបរិក្ខារអគ្គីសនីនិងគ្រឿងអគ្គីសនីនៃប្រេងដែលងាយឆេះ ចាំបាច់តំឡើងបរិក្ខារសមរម្យដោយមានខ្សាច់គ្រប់គ្រាន់សំ

| | |
|---|---|
| | រាប់ស្រូបយកប្រេងដែលលេចចេញ។<br>4 ទីកន្លែងផ្ទុកប្រភេទប្រេងនិងខ្លាញ់នៅក្នុងរូងនៃការដ្ឋានរ៉ែ ទីកន្លែងផ្គត់ផ្គង់និងស្តុកប្រេងឥន្ធនៈ គឺជារចនាសម្ព័ន្ធធន់នឹងភ្លើងព្រមទាំងបង្កើតបរិក្ខារពន្លត់អគ្គិភ័យ តំឡើងបរិក្ខារសមរម្យគ្រប់គ្រាន់ដោយមានខ្សាច់គ្រប់គ្រាន់សំរាប់ស្រូបយកប្រេងដែលលេចចេញ និង ត្រូវតែជារចនាសម្ព័ន្ធដែលអាចកាត់ផ្តាច់ចេញពីកន្លែងផ្សេងបាន នៅពេលមានពេលមានភាពចាំបាច់។<br>5 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទ A និងប្រភេទ B) ចំពោះទីកន្លែងតំឡើងបរិក្ខារបំលែងចរន្តអគ្គិសនីសំខាន់នៃចំនុចទី៣ និង បន្ទប់កំប្រែស័រនៃចំនុចទី១ ចាំបាច់ត្រូវតែតំឡើងនៅក្នុងទីតាំងបែងចែកដែលមានលក្ខណៈឯករាជ្យ។<br><br>**(រចនាសម្ព័ន្ធទប់ស្កាត់អគ្គីភ័យនិងរចនាសម្ព័ន្ធធន់នឹងភ្លើង)**<br>មាត្រា១៥០<br>1 ម្ចាស់សិទ្ធការងាររ៉ែ ស្តីពីរចនាសម្ព័ន្ធទប់ស្កាត់នឹងភ្លើង ត្រូវតែជារចនាសម្ព័ន្ធដែលគ្របដោយវត្ថុធាតុមិនងាយឆេះដូចជា plaster ដែកសំណាញ់ mortar ជាដើម។<br>2 រចនាសម្ព័ន្ធធន់នឹងភ្លើង ត្រូវតែជារចនាសម្ព័ន្ធដែលសង់ឡើងដោយរបស់រឹងដែលមានសារធាតុមិនងាយឆេះដូចជាឥដ្ឋ ប៉េតុងជាដើម។<br><br>**(បរិក្ខារពន្លត់អគ្គីភ័យ)**<br>មាត្រា១៥១<br>ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទ A និងប្រភេទ B) ចំពោះបន្ទប់កំប្រែស័រ កន្លែងផ្ទុកប្រភេទប្រេងនិងខ្លាញ់ បន្ទប់បិទបើកប្រេងចូលសំខាន់ៗ និង កន្លែងតំឡើងបរិក្ខារបំលែងចរន្តអគ្គិសនីសំខាន់ៗ ចាំបាច់ត្រូវតែមាន តំឡើងបរិក្ខារពន្លត់អគ្គិភ័យដែលអាចធ្វើការពន្លត់បានដោយស្វ័យប្រវត្តិ។ ក៏ប៉ុន្តែលើកលែង នៅពេលបានតំឡើងបរិក្ខារពន្លត់អគ្គិភ័យដែលប្រើឧស្ម័នមិនមានជាតិឆេះ ដោយការប្រើដោយដៃ និង ការដាក់មនុស្សឲ្យនៅចាំមើល។ |

| | |
|---|---|
| | មាត្រា១៥២<br>1 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) ចំពោះទីកន្លែងដែលលើកឡើង នៅ តាមចំនុចនីមួយៗដែលមាននៅខាងក្រោម ចាំបាច់ត្រូវតែតំឡើងបរិក្ខារពន្លត់អគ្គិភ័យ។<br>a. មានផ្លូវនៅក្នុងរូងដែលបានចែកចាយខ្សែអគ្គិសនីប្រើជាខ្សែកំឡាំង ឬ ផ្លូវនៅក្នុងរូងដែលប្រើសំរាប់ការបើកបរក្បាលរថភ្លើងដែកប្រើចរន្តអគ្គិសនីបែបខ្សែព្យួរក៏ដូចជាក្បាលរថភ្លើងដែលម៉ាស៊ីនចំហេះក្នុង, ផ្លូវនៅក្នុងរូង ដែលបានតំឡើងbelt conveyor ទីកន្លែងនៃចាប់ផ្តើមផ្លូវនៃរូង និងចំនុចចុងនៃផ្លូវនៅក្នុងរូង ក៏ដូចជា១០០ ម៉ែត្រម្តងពីចំនុចចាប់ផ្តើមឬចំនុចចុងបញ្ចប់។<br>b. ទីកន្លែងតំឡើង បរិក្ខារអគ្គិសនីដែលមានប្រើប្រេង នៅក្នុងរូង។<br>2 ចំពោះបរិក្ខារពន្លត់អគ្គិភ័យដែលមានកំណត់ក្នុងចំនុចមុន មានសំពាធបញ្ចេញទឹកលើសពី០,១៥ mega pascal នៅខាងចុងនៃច្រកចេញនៃឧបករណ៍បញ្ចេញទឹក និងចំពោះបរិមាណនៃការបញ្ចេញទឹកគឺចាំបាច់ត្រូវតែមានសមត្ថិភាពលើសពី៣០០លីតក្នុង១នាទី។<br>3 នៅក្នុងរូងការដ្ឋានរ៉ែធ្យូងថ្ម ចំពោះបរិក្ខារបញ្ចេញទឹកប្រើសំរាប់ការពន្លត់អគ្គិភ័យ ចាំបាច់ត្រូវតែតំឡើងនៅទីកន្លែងដែលអាចភ្ជាប់បានលឿនទៅនឹងទុយោទឹកសំរាប់ធ្វើការ ពន្លត់បាន។<br><br>មាត្រា១៥៣<br>ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងក្រោមដី ជាប្រភេទលោហៈនិងអលោហៈ ចំពោះការិយាល័យនៅក្នុងរូងដែលនៅជិត បរិក្ខារអគ្គិសនីសំខាន់ៗ កន្លែងស្តុកប្រេង កន្លែងផ្គត់ផ្គង់ប្រេង និង ទីកន្លែងសំខាន់ៗផ្សេងៗទៀត ចាំបាច់ត្រូវតែតំឡើងបរិក្ខារពន្លត់អគ្គិភ័យ។<br><br>**(ប្រភេទប្រេងនិងខ្លាញ់)**<br>មាត្រា១៥៤ |

| | |
|---|---|
| | 1 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែដី នៅក្នុងរូង ប្រភេទប្រេងនិងខ្លាញ់ចាំបាច់ត្រូវតែដាក់នៅក្នុងសំភារៈសំរាប់ដាក់ដោយជាសារធាតុមិនឆេះនិងមានគំរប។<br>2 នៅក្នុងរូង ប្រភេទប្រេងនិងខ្លាញ់ ចាំបាច់ត្រូវតែរក្សាទុកនៅក្នុងសំភារៈសំរាប់ដាក់ដោយជាសារធាតុមិនឆេះនិងមានគំរបបិទ។<br><br>**(ការកំហិតការប្រើភ្លើងនៅពេលផ្គត់ផ្គង់ប្រេងឥន្ធនៈ)**<br>មាត្រា១៥៥<br>ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែក្រោមដី ជាប្រភេទលោហៈនិងអលោហៈ នៅពេលធ្វើការផ្គត់ផ្គង់ប្រេងឥន្ធនៈដល់រថយន្ត ឬ យានដែលគ្រឿងចក្រនៃការដ្ឋានរ៉ែ ចាំបាច់ត្រូវតែធ្វើពន្លត់ម៉ាស៊ីន និង ហាមការប្រើភ្លើងនៅជុំវិញទីនោះ។<br><br>**ផ្នែកទី៣ ការប្រើប្រាស់ភ្លើងនៅនៅខាងក្រៅរូង**<br>**(អគារសំណង់នៅខាងក្រៅរូង)**<br>មាត្រា១៥៦<br>1 ម្ចាស់សិទ្ធការងាររ៉ែ នៅក្រៅរូង នៅពេលធ្វើការតំឡើង ឬ ផ្លាស់ប្តូរ អគារសំណង់ថ្មី ប្រើសំរាប់អាជីវកម្មរ៉ែ នៅក្នុងកន្លែងផ្ទុក ឬនៅពេលធ្វើការផ្លាស់ប្តូរ សំណង់អគារសំខាន់ និង ខ្សែព្រំប្រទល់នៃតំបន់នៅជិតនោះ និងចំពោះចន្លោះរវាងអគារសំខាន់នឹងអគារសំខាន់ផ្សេងទៀតនោះ ចាំបាច់ត្រូវតែរក្សាឲ្យបាននូវគំលាតចាំបាច់សំរាប់ប្រើនៅពេលភៀសខ្លួន។<br>2 នៅការដ្ឋានរ៉ែ ឡ ឧបករណ៍បង្កើនកំដៅ បំពង់ផ្សេង។ល។ ចន្លោះរវាងអគារដែលអាចមានគ្រោះថ្នាក់ផ្សេងៗកើតច្រើន និង សារធាតុដែលងាយឆេះនៃសំណង់អគារនោះ ចាំបាច់ត្រូវតែរក្សាឲ្យបាននូវគំលាតចាំបាច់សំរាប់ទប់ស្កាត់នៃការឆេះ ឬ ចាំបាច់ត្រូវតែការពារដោយវត្ថុធាតុដែលធន់នឹងកំដៅដែលមិនងាយឆេះ។<br>3 បរិក្ខារដែលប្រើប្រាស់របស់ក្តៅខ្លាំងមានបរិមាណច្រើននៅក្នុងឡនៃការដ្ឋានរ៉ែលោហៈ ចាំបាច់ត្រូវ |

តែរចនាសម្ព័ន្ធចាំបាច់សំរាប់ធ្វើការទប់ស្កាត់ការផ្ទុះតាមរយៈ ទឹកក្រោមដី ការជ្រាបចូលតាមរយៈ ទឹកភ្លៀង។

**(បន្ទប់សំរាប់ការបំភ្លឺដើម្បីសុវត្ថិភាព)**

មាត្រា១៥៧

1 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) នៅពេលប្រើបរិក្ខារពិនិត្យឧស្ម័នមានជាតិឆេះ ឬ អំពូលបំភ្លឺសុវត្ថិភាពសំរាប់ប្រើចល័តនៃ ចាំបាច់ត្រូវតែតំឡើង បន្ទប់សំរាប់ការបំភ្លឺដើម្បីសុវត្ថិភាព។

2 ចំពោះ បន្ទប់សំរាប់ការបំភ្លឺដើម្បីសុវត្ថិភាពនៃចំនុចមុន ចាត់វិធានការសមរម្យដើម្បីទប់ស្កាត់អគ្គិភ័យ និង ចាំបាច់ត្រូវតែគោរពតាមការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោម៖

a. ចាំបាច់ត្រូវតែបង្កើតកន្លែងហាមមិនឲ្យមានប្រើភ្លើងនៅក្នុងបន្ទប់។

b. ចាំបាច់ត្រូវមានរចនាសម្ព័ន្ធមិនឲ្យមានឧស្ម័នដែលមានជាតិឆេះ នៅកក នៅក្នុងបន្ទប់។

c. ទីកន្លែងធ្វើការងារបញ្ចូលប្រេង និង កន្លែងផ្សេងទៀតត្រូវតែបែងចែកឲ្យដាច់ពីគ្នា។

**(បរិក្ខារពន្លត់អគ្គិភ័យនៅក្រៅសំណង់អគារ)**

មាត្រា១៥៨

1 ម្ចាស់សិទ្ធការងាររ៉ែ ចំពោះអគារសំណង់នៅក្រៅរូង ចាំបាច់ត្រូវតែបង្កើតទីកន្លែងសមស្របនៃបរិក្ខារពន្លត់អគ្គិភ័យ ដូចជា អាងទឹក ខ្សាច់សំរាប់ធ្វើការពន្លត់អគ្គិភ័យ ឧបករណ៍ពន្លត់អគ្គិភ័យ ក្បាលទុយោសំរាប់ពន្លត់អគ្គិភ័យ និង បង្កើតអាងទឹកដោយសមស្របតាមទំហំនៃសំណង់នោះ។

2 ចំពោះបរិក្ខារពន្លត់អគ្គិភ័យនៃចំនុចមុន ចាំបាច់ជារបស់ដែលតបទល់នឹងសភាពនៃ អគ្គិភ័យ ឬ មានគុណភាពនៃការងារ។

**ផ្នែកទី៤ ការទប់ស្កាត់ នៃភាពឆេះដោយធម្មជាតិ**

**( ការទប់ស្កាត់ នៃភាពឆេះដោយធម្មជាតិ និង ការបិទជិត)**

មាត្រា១៥៩

1 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) និង ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែលោហៈនិងអលោហៈ ចំពោះនៅក្នុងរូងនៃចំពោះទីកន្លែងដែលមានការឆេះដោយធម្មជាតិច្រើននាំឲ្យមានគ្រោះថ្នាក់ ក្រៅពីការបំពាក់បរិក្ខារពន្លត់អគ្គិភ័យទុកជាមុន ចាំបាច់រៀបចំវត្ថុធាតុធន់នឹងកំដៅ និង មានវិធានការសមរម្យផ្សេងទៀត ក្នុងគោលបំណងអាចនឹងធ្វើការបិទឲ្យជិតទាំងស្រុងបានទាន់ពេល ចំពោះទីកន្លែងនោះក្នុងពេលត្រូវការបិទ។

2 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) នៅពេលធ្វើអោយមានខ្យល់ឆ្លងតាមរយៈការកំណត់នៃចំនុចមុន ចំពោះការបញ្ចេញខ្យល់នោះ គឺចាំបាច់ត្រូវមានវិធានការសមរម្យក្នុងការធ្វើការផ្លាស់ប្តូរ ជាច្រើនលើកច្រើនសារចំពោះទីកន្លែងធ្វើការក្នុងរូង ឬ ផ្លូវដែលមានការឆ្លងកាត់ច្រើន ។

3 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) ចំពោះរន្ធដែលខួង ឬ ជញ្ជាំងធ្យូងថ្ម ផ្លូវនៅក្នុងរូងដែលអាចនឹងមានគ្រោះថ្នាក់ ឬ មានអគ្គិភ័យដោយធម្មជាតិ ចាំបាច់ត្រូវតែបញ្ចូលនូវស៊ីម៉ង់ និង ចាត់វិធានការសមរម្យ ផ្សេងៗទៀត។

**(ចំនុចដែលត្រូវតែគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពក្នុងរូង**

មាត្រា១៦០

1 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពក្នុងរូង នៅការដ្ឋានរ៉ែលោហៈ នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) ស្តីពី ការឆេះដោយធម្មជាតិ ឬ ស្តីអំពីទីកន្លែងដែលនឹងមានគ្រោះថ្នាក់ច្រើន ចាំបាច់ត្រូវឲ្យអនុវត្តអោយបានលើសពី១ដងក្នុង១ថ្ងៃ ដូចជា ការវាស់ឧស្ម័ននិងសំណើម កំដៅនៅពេលនោះ ការពិនិត្យក្លិនក្នុងខ្យល់ និង ចាំបាច់ត្រូវតែប្រយ័ត្នចំពោះភាពប្រែប្រួលរបស់វា។

2 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូង នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB ) ធ្វើការពិនិត្យអោយបានលើសពី១ដងក្នុង១ថ្ងៃនូវឧស្ម័ននៅក្នុងបំពង់ឧស្ម័នសំខាន់ៗនៃអគារនាំឧស្ម័ន និង ចាំបាច់ត្រូវតែប្រយ័ត្នចំពោះភាពប្រែប្រួលរបស់វា។

3 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូង នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) និងការដ្ឋានរ៉ែលោហៈ នៅពេលធ្វើការបិទជិតនូវចំនុចកំណត់តាមចំនុច១ ស្តីពីចំនុចនោះ ធ្វើការពិនិត្យ នូវភាពមិនប្រក្រតីឬប្រក្រតីនៃភាពជិតនោះ និង បើចាំបាច់ ធ្វើការវិភាគនូវឧស្ម័ននៅក្នុងនោះ។

4 អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូង នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) និងការដ្ឋានរ៉ែលោហៈ ធ្វើការកត់ត្រានៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ ស្តីអំពី លទ្ធផលនៃការត្រួតពិនិត្យ ឬ ការវាស់តាមការកំណត់នៃចំនុចទី៣មុន នៅពេលមានភាពមិនប្រក្រតីរបស់លទ្ធផលនៃការត្រួតពិនិត្យ ឬការវាស់នៅទីនោះ ចាំបាច់ត្រូវតែធ្វើការរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

**(ភាពបិទជិត)**

មាត្រា១៦១

1 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) និងការដ្ឋានរ៉ែលោហៈ នៅពេលមាន ភាពឆេះដោយធម្មជាតិ ឬ ធ្វើការបិទជិតនូវទីកន្លែងជីករួចដែលមានគ្រោះថ្នាក់ច្រើន អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូង ចាំបាច់ត្រូវតំឡើងនូវបំពង់ ក្នុងគោលបំណងធ្វើការពិនិត្យចំពោះខ្យល់ ដែលមាននៅក្នុងកន្លែងបិទជិតនោះ។

2 ក្នុងករណីមានគ្រោះថ្នាក់អាចនឹងកើតឡើងដោយការផ្ទុះ នៅពេលធ្វើការបិទជិតនូវទីកន្លែងមានការឆេះដោយធម្មជាតិ នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) មុននឹងចាប់ផ្តើមធ្វើការងារបិទទីនោះ អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូង ចាំបាច់ត្រូវ

| | |
|---|---|
| | ទទួលបញ្ហារបស់អ្នកគ្រប់គ្រង និង ចាំបាច់ត្រូវតែចាត់វិធានការសុវត្ថិភាពផ្សេងៗដោយយកដីមកទប់ជាគំន។<br>3 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) នៅពេលបើកទីកន្លែងបិទជិតនោះ ឬ ទីកន្លែងមានការឆេះដោយធម្មជាតិ អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាព និង ការបំផ្ទុះក្នុងរូងចាំបាច់ត្រូវទទួលបញ្ហារបស់អ្នកគ្រប់គ្រង។<br>4 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទAនិងប្រភេទB) និងការដ្ឋានរ៉ែលោហៈ នៅពេលមានការឆេះដោយធម្មជាតិ ឬ បិទនូវទីកន្លែងមានគ្រោះថ្នាក់ច្រើន ឬ បានចាក់បំពេញទីនោះ ត្រូវបង្កើតផែនទីសំរាប់កត់ ចំពោះស្ថានភាពនៃទីកន្លែងនោះ និង នៅក្នុងកំឡុងពេលធ្វើការលុបបំពេញ ឬ ធ្វើការបិទជិត និង ចាំបាច់ត្រូវតែរក្សានូវផែនទីទាំងនោះ។<br><br>**ជំពូកទី៩ វិធានការចំពោះរូងបានបោះបង់ចោល**<br>**ផ្នែក១ បទបញ្ញតិទូទៅ**<br><br>មាត្រា១៦២<br>ស្តីពីសុវត្ថិភាពទាក់ទងនឹង វិធានការចំពោះរូងចាស់(បានបោះបង់ចោល) យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ អនុលោមតាមការកំណត់តាមមាត្រា៣១-១នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។<br><br>**ផ្នែក២ វិធានការចំពោះរូងចាស់។ល។**<br>**(វិធានការចំពោះរូងចាស់។ល។)**<br>មាត្រា១៦៣<br>1 ម្ចាស់សិទ្ធការងាររ៉ែ នៃការដ្ឋានរ៉ែក្រោមដី នៅពេលធ្វើការជីកចូលទៅជិតក្នុងរង្វង់៥០ម៉ែត្រនៃ |

ចរន្តទឹក ឬ រូងចាស់ ដែលមានគ្រោះថ្នាក់ច្រើនគួរអោយកត់សំគាល់គន្លងមក ឧស្ម័នមានភាពឆេះនិង ឧស្ម័នផ្សេងៗទៀតដែលបានកក ផ្តុំនៅទីនោះ ទឹកលិច ឬ រូងចាស់ជាច្រើនដែលនឹងមានទឹកលិចគួរអោយកត់សំគាល់ និង លិចទឹក ចាំបាច់ត្រូវតែ អនុវត្តការខួងទុកជាមុន ឬ ចាត់វិធានការសមរម្យផ្សេងៗទៀត។

2 នៅពេលមានទឹកចេញច្រើនគួរអោយមានគ្រោះថ្នាក់ នៃករណីមុនដែលបានកំណត់ ចាំបាច់ត្រូវតែតំឡើងទំនប់ការពារទឹកផ្សេងៗ ឬ ទំនប់មិនជ្រាប់ទឹក។

3 នៅពេលអនុវត្តការខួងទុកជាមុនតាមការកំណត់នៃចំនុច១ drifting ត្រូវមិនអោយខិតចូលទៅជិតបាតរន្ធ ខួងក្នុង៥ម៉ែត្រ។

4 ការកំណត់នៃចំនុចមួយ ស្តីពីទិសដៅនៃការខួងទៅមុខមុន នៅ drifting ក្រៅស្របតាមផ្លូវបន្តនៃផ្លូវរូង មិនត្រូវអនុវត្តចំពោះទិសដៅ ឆ្វេងស្តាំ លើក្រោម នៃផ្លូវបន្ត ឡើយ។

**(ការតំឡើងតំបន់ការពារ)**

មាត្រា១៦៤

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែក្រោមដី នៅក្នុងរូង ដែលមានទឹកលេច ចំពោះរូងចាស់មានទឹកលិចច្រើនគួរអោយមានគ្រោះថ្នាក់គួរអោយកត់សំគាល់ ចាំបាច់ត្រូវតែតំឡើងជញ្ជាំងការពារចាំបាច់សំរាប់សុវត្ថិភាព ឬ តំបន់ការពារ។

## ជំពូកទី១០ ការទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែ

## ផ្នែកទី១ បទបញ្ញត្តិទូទៅ

មាត្រា១៦៥

1 ស្តីពីសុវត្ថិភាពទាក់ទងនឹង ការទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែ យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ និង កម្មកររ៉ែ យោង

| | |
|---|---|
| | តាមការកំណត់តាមមាត្រា៦នៃច្បាប់ ចាំបាច់ត្រូវតែគោរពតាមចំនុចដែលបានចាត់អនុលោមតាមការកំណត់តាមមាត្រា៣១-២នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។<br><br>**(របាយការណ៍ចំពោះការកើតឡើងការបំពុលដោយសាររ៉ែ**<br>មាត្រា១៦៦<br>1 ម្ចាស់សិទ្ធការងាររ៉ែ យោងតាមការកំណត់មាត្រា២៩-១នៃច្បាប់ នៅពេលនឹងមានគ្រោះថ្នាក់ច្រើននៃការកើតឡើងការបំពុលដោយសាររ៉ែ និង នៅពេលមានកើតឡើងការបំពុលដោយសាររ៉ែ ស្តីពីចំនុចខាងក្រោមនិមួយៗ ចាំបាច់ត្រូវតែធ្វើការរាយការណ៍ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានទទួលបន្ទុកការងាររ៉ែជាបន្ទាន់។<br>a. នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់ នូវការចេញ ផ្សែងកខ្វក់និងផ្សែងរ៉ែ មិនសមស្រមនឹងស្តង់ដានៃការបញ្ចេញផ្សែងកខ្វក់ និង ផ្សែងរ៉ែ ស្ថានភាពនៃគ្រោះថ្នាក់នោះ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។<br>b. នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់ នូវការចេញ ធូលីធ្យូងថ្ម ស្ថានភាពនៃគ្រោះថ្នាក់នោះ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។<br>c. នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់នៃ ការបញ្ចេញទឹកកខ្វក់ ឬទឹកក្នុងរូង ដែលមិនសមស្រមនឹងស្តង់ដាទប់ស្កាត់គុណភាពទឹកកខ្វក់ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។<br>d. នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់នៃ ការបញ្ចេញទឹកកខ្វក់ ឬ បញ្ចេញ ឧស្ម័នដែលមិនសមស្រមការបញ្ចេញនូវប្រភេទdioxin នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។ |

e. នៅពេលមានការកើតឡើងមានគ្រោះថ្នាក់នៃ ការក្រពុកសារធាតុពុល ហូរចេញនិងចេញ ឬ នឹងគួរអោយមានគ្រោះថ្នាក់ ស្ថានភាពនៃគ្រោះថ្នាក់នោះ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។

f. នៅពេលមានការកើតឡើងនូវសំឡេងថ្លង់មិនសមស្រមនឹងស្តង់ដានៃការកំហិតសំឡេងថ្លង់ ឬ នឹងគួរអោយមានគ្រោះថ្នាក់ ស្ថានភាពនៃគ្រោះថ្នាក់នោះ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។

g. នៅពេលមានការកើតឡើងនូវភាពរញ្ជ័រ ដែលមិនសមស្រមនឹងស្តង់ដានៃភាពរញ្ជ័រ ឬ នឹងគួរអោយមានគ្រោះថ្នាក់ ស្ថានភាពនៃគ្រោះថ្នាក់នោះ នៅពេលបានបញ្ចប់ការងារស្តារឡើងវិញ និង ខ្លឹមសារនៃវិធានការឆ្លើយតបបន្ទាន់ស្តីពីគ្រោះថ្នាក់នោះ និងខ្លឹមសារដ៏ទៃទៀត។

h. នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់ នៃទឹក ន្លែងចាក់លុបកាកសំណល់ឧស្សាហកម្មរ៉ែ ឬ ទីកន្លែអលុបនៅក្នុងរូងនៃការដ្ឋានរ៉ែ និងខ្លឹមសារការងារនោះ។

i. នៅការដ្ឋានរ៉ែ នៅពេលមានការកើតឡើងគួរអោយមានគ្រោះថ្នាក់ ចំពោះទីកន្លែងស្តុកកាកសំណល់រង ឬ អាចម៍រ៉ែ ថ្មចោល យោងតាមរយៈភ្លៀងខ្យល់ឃ្លាំង ការដាច់ចរន្ត ការខូចបរិក្ខារនៃអគារ និង ហេតុផលផ្សេងទៀត និងខ្លឹមសារការងារនោះ។

2 ក្រៅពីធ្វើការកំណត់តាមចំនុច១ ម្ចាស់សិទ្ធការងាររ៉ែ អនុលោមតាមការកំណត់មាត្រា២៩-១នៃច្បាប់ នៅពេលមានការកើតឡើងនៃការបំពុលដោយសាររ៉ែ និង អាចនឹមានគ្រោះថ្នាក់តាមរយៈការបំពុលដោយសាររ៉ែ ចាំបាច់ត្រូវតែធ្វើការរាយការណ៍ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានទទួលបន្ទុកការងាររ៉ែជាបន្ទាន់។

**ផ្នែក២ ទប់ស្កាត់នៃការបំពុលដោយសាររ៉ែ យោងតាមរយៈផ្សេងកខ្វក់និងផ្សេងរ៉ែ**
**(ស្តង់ដានៃបញ្ចេញផ្សែងនៃផ្សេងកខ្វក់និងផ្សេងរ៉ែ)**

មាត្រា១៦៧

| | |
|---|---|
| | 1 ម្ចាស់សិទ្ធការងាររ៉ែ ដើម្បីតប់ស្កាត់ការបំពុលដោយសាររ៉ែ យោងតាមរយៈផ្សែងកខ្វក់និងផ្សែងរ៉ែ មិនត្រូវបញ្ចេញផ្សែងកខ្វក់និងផ្សែងរ៉ែ នៅមាត់ច្រកនៃការបញ្ចេញនៃអគារបញ្ចេញផ្សែងរ៉ែ ឬ អគារបញ្ចេញផ្សែងកខ្វក់ ដែលមិនសមស្រមនឹងស្តង់ដានៃ「ច្បាប់ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និង ការការពារបរិដ្ឋាន」គឺមិនអាចធ្វើការបញ្ចេញនូវ ផ្សែងកខ្វក់និងផ្សែងរ៉ែ នោះបានឡើយ។<br>2 ម្ចាស់សិទ្ធការងាររ៉ែ ស្តីអំពីអគារចំភាញ់ផ្សែងកខ្វក់ ឬ អគារ ចំភាញ់ផ្សែងរ៉ែ នៅពេលមាន ការខូចបែកបាក់ កើតឡើងនូវការដាច់ចរន្តនិងគ្រោះថ្នាក់ផ្សេងៗ មានផ្សែងកខ្វក់ដែលចេញមិនសមស្របនឹងស្តង់ដាកំណត់ ឬ ផ្សែងរ៉ែដែលចេញមិនសមស្របនឹងស្តង់ដាកំណត់ ឬ នៅពេលមានកើតចេញនូវបញ្ចេញផ្សែងទាំងនោះដែលនឹងនាំឲ្យមានគ្រោះថ្នាក់ ចាត់វិធានការជាបន្ទាន់ចំពោះគ្រោះថ្នាក់ដែលកើតមាន និង ចាំបាច់ត្រូវតែធ្វើការស្តារឡើងវិញចំពោះគ្រោះថ្នាក់ដែលមាននោះជាបន្ទាន់។<br><br>**(ស្តង់ដានៅលើផ្សែងកខ្វក់និងផ្សែងពុល**<br>មាត្រា១៦៨<br>ម្ចាស់សិទ្ធការងាររ៉ែ ក្រៅពីការកំណត់នៃមាត្រាមុន នៅពេលរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ទទួលស្គាល់ថាំនភាពចាំបាច់ជាពិសេស នៅពេលមានការបញ្ជាចំបាត់ត្រូវតែចាត់វិធានការសមរម្យសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារអាជីវកម្មរ៉ែ តាមរយៈផ្សែងរ៉ែឬផ្សែងកខ្វក់កំហិតដោយការបញ្ចេញផ្សែងរ៉ែឬផ្សែងកខ្វក់ នៅពេលនោះចាំបាច់ត្រូវតែអនុលោមតាមបញ្ជានោះ។<br><br>**(ចំនុចគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ដោយសាររ៉ែ**<br>មាត្រា១៦៩<br>អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ដោយសាររ៉ែ ដើម្បីទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែចាំបាច់ត្រូវតែគោរពតាមការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោម<br>a. ធ្វើការដើរត្រួតពិនិត្យរាល់ថ្ងៃធ្វើការចំពោះបរិក្ខារចំភាញ់ផ្សែងរ៉ែ ឬ បរិក្ខារចំភាញ់ផ្សែងកខ្វក់ និង បរិក្ខារបង្កើតផ្សែងកខ្វក់ ដោយចាំបាច់ត្រូវកត់ត្រានូវលទ្ធផលទាំងនោះនៅក្នុងសៀវភៅសុវត្ថិភាព |

| | |
|---|---|
| | ប្រចាំថ្ងៃ។<br>b. រាល់ពេលវេលានៃការងារដែលលើកឡើងនៅក្នុងតារាងខាងក្រោមចំពោះបរិមាណទាំងនោះ ដោយចំពោះសារ ធាតុដែលមាននៅក្នុងបរិមាណនោះត្រូវបានលើកឡើងនៅក្នុងតារាងបន្ទាប់ ធ្វើការវាស់តាមរយៈវិធីធ្វើការ ប្រកាសផ្សេង និងការវាស់រាល់ថ្ងៃធ្វើការអំពីល្បឿនខ្យល់និងទិសដៅនៃខ្យល់ រួចធ្វើការកត់ត្រាលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃស្តីអំពីលទ្ធផលទាំងនោះ។<br>c. លទ្ធផលនៃការវាស់ចំពោះចំនុច២មុន នៅពេលនឹងអាចមានគ្រោះថ្នាក់កើតឡើងដោយសារការបំពុលបរិដ្ឋានតាមរយៈផ្សែងកខ្វក់ឬផ្សែងរ៉ែ ចាំបាច់ត្រូវតែរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។<br><br>**ផ្នែក៣ ទប់ស្កាត់នៃការបំពុលដោយសាររ៉ែ យោងតាមរយៈធូលីធ្យូងថ្ម**<br>**(ការគ្រប់គ្រងអគារបញ្ចេញធូលីធ្យូងថ្ម)**<br>មាត្រា១៧០<br>1 ម្ចាស់សិទ្ធការងាររ៉ែ ដើម្បីទប់ស្កាត់ការបំពុលតាមរយៈធូលីធ្យូងថ្ម ចាំបាច់ត្រូវតែគោរពតាមការកំណត់នៃចំនុចនិមួយៗដែលមានដូចខាងក្រោម៖<br>a. ស្តីពីទីកន្លែងស្តុករ៉ែដែលមានផ្ទៃក្រឡាលើសពី ១០០០ម៉ែត្រការ៉េ ថ្មចោល ទីកន្លែងស្តុកអាចម៍រ៉ែ ឬ កាកសំណល់រង ទីកន្លែងលុបកាកសំណល់រ៉ែ ករណីមានធូលីធ្យូងថ្មហ៊ុយឡើងគួរអោយមានគ្រោះថ្នាក់ ចាំបាច់ត្រូវ តែគោរពតាមដូចខាងក្រោម៖<br>i) ចាំបាច់ត្រូវតំឡើងនៅក្នុងបន្ទប់នូវរចនាសម្ព័ន្ធដែលនឹងមិនងាយមានធូលីហ៊ុយ។<br>ii) ធ្វើការបាញ់ទឹកដោយបរិក្ខារបាញ់ទឹក។<br>iii) ចាំបាច់ត្រូវធ្វើការគ្របដោយគំរបសំរាប់គ្របធូលី។<br>iv) ចាំបាច់ត្រូវប្រើទឹកថ្នាំធ្វើការបាញ់សំរាប់ធ្វើឲ្យស្រទាប់ខាងលើរឹង និងក្រាលដោយក្រណាត់សើម។<br>v) ចាំបាច់ត្រូវមានវិធានការឲ្យមានប្រសិទ្ធភាពដូចចំនុចដែលបានលើកឡើងរួច។ |

b. ស្តីពីបរិក្ខាររែង ម៉ាស៊ីនកិនបំបែក និង ម៉ាស៊ីនកិនម៉ត់ ដែលមានប្រើម៉ូទ័រដែលមានកំឡាំងលើសពី៧៥គីឡូវ៉ាត់ ចាំបាច់ត្រូវតែ គោរពតាមចំនុចដូចខាងក្រោម។ ក៏ប៉ុន្តែ លើកលែងករណី ប្រភេទបិទជិតនិងប្រភេទមានសំណើម។

i ) ចាំបាច់ត្រូវតំឡើងនៅក្នុងបន្ទប់នូវរចនាសម្ព័ន្ធដែលនឹងមិនងាយមានធូលីហ៊ុយ។

ii ) ចាំបាច់ត្រូវតំឡើងម៉ាស៊ីនប្រមូលធូលីនិងhood។

iii) ធ្វើការបាញ់ទឹកដោយបរិក្ខារបាញ់ទឹក។

iv) ចាំបាច់ត្រូវធ្វើការគ្របដោយគំរបសំរាប់គ្របធូលី។

v ) ចាំបាច់ត្រូវមានវិធានការឲ្យមានប្រសិទ្ធភាពដូចចំនុចដែលបានលើកឡើងរួច។

c. ស្តីពីបរិក្ខារខ្សែពានដែលបានដាក់នៅខាងក្រៅរូង ( ដែលមានទំហំទទឹងលើសពី០,៧៥ម៉ែត្រ) និង backet belt conveyor ( ដែលមានចំណុះលើសពី០,០៣ម៉ែត្រគូប) ចាំបាច់ត្រូវតែគោរពតាមដូចខាងក្រោម។ ក៏ប៉ុន្តែ លើកលែងករណី ប្រភេទបិទជិតនិងប្រភេទមានសំណើម។

i ) ចាំបាច់ត្រូវតំឡើងនៅក្នុងបន្ទប់នូវរចនាសម្ព័ន្ធដែលនឹងមិនងាយមានធូលីហ៊ុយ។

ii ) ម៉ាស៊ីនប្រមូលធូលីដែលត្រូវបានតំឡើងនិងhoodនៅទីកន្លែងទំលាក់ចុះនិងផ្នែកនៃការលើកដាក់ដោយប្រើconveyor ក៏ដូចជាផ្នែកដែលមានការហ៊ុយនៃធូលី បរិក្ខារបាញ់ទឹក និងការការពារដោយមានការគ្រប។

iii) ធ្វើការបាញ់ទឹកដោយបរិក្ខារបាញ់ទឹក។

iv) ចាំបាច់ត្រូវធ្វើការគ្របដោយគំរបសំរាប់គ្របធូលី។

v ) ចាំបាច់ត្រូវមានវិធានការឲ្យមានប្រសិទ្ធភាពដូចចំនុចដែលបានលើកឡើងរួច។

d. ស្តីពីច្រកចេញនៃធូលីរបស់ម៉ាស៊ីនបំបាត់ធូលី នៃ ថ្មកំបោរ រួមទាំង ដូឡូមីត។ ចាំបាច់ត្រូវតែគោរពតាមចំនុចនិមួយៗដូចខាងក្រោមៈ

i ) ចាំបាច់ត្រូវតំឡើងម៉ាស៊ីនប្រមូលធូលី។

ii ) ធ្វើការបាញ់ទឹកដោយបរិក្ខារបាញ់ទឹក។

iii) ចាំបាច់ត្រូវមានវិធានការឲ្យមានប្រសិទ្ធភាពដូចចំនុចដែលបានលើកឡើងរួច។

2 ម្ចាស់សិទ្ធិការងាររ៉ែនៃការដ្ឋានរ៉ែលោហៈ ដើម្បីទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយសារការធ្វើអាជីវកម្មរ៉ែតាមរយៈធូលីនៃasbestos បរិក្ខារដែលលើកឡើងនៅចំនុច b មុន យោងតាមការកំណត់នៃសេចក្តីប្រកាសស្តង់ដាកំហិតចំពោះខ្សែព្រំនៃទីតាំងការដ្ឋានរ៉ែដែលបានតំឡើង ចាំបាច់មិនត្រូវឲ្យមានភាពហ៊ុយឬកើតឡើងនូវធូលីនៃasbestosដែលមិនត្រូវនឹងស្តង់ដានៃធូលីasbestos។

3 ម្ចាស់សិទ្ធិការងាររ៉ែនៃការដ្ឋានរ៉ែ ស្តីអំពីបរិក្ខារចំរាញ់ធូលីឬបរិក្ខារធ្វើឲ្យមានធូលីហ៊ុយក៏ដូចគ្នានឹងការបង្កើតឲ្យមានធូលី នៅពេលមានការខូច បែកបាក់ កើតឡើងនូវការដាច់ចរន្តនិងគ្រោះថ្នាក់ផ្សេងៗមានកើតឡើងនូវការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែតាមរយៈធូលី ឬ នៅពេលមានកើតចេញនូវគ្រោះថ្នាក់ ចាំបាច់ត្រូវតែមានវិធានការទប់ទល់ជាបន្ទាន់ និងធ្វើការស្តារឡើងវិញចំពោះគ្រោះថ្នាក់ដែលកើតមាននោះ។

មាត្រា១៧១

ម្ចាស់សិទ្ធិការងាររ៉ែ ក្រៅពីការកំណត់តាមរយៈមាត្រាមុន មានការទទួលស្គាល់ ជាពិសេសដោយរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ នៅពេលបានធ្វើការបញ្ជាចាត់វិធានការសមរម្យសំរាប់ការទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែតាមរយៈធូលី ចាំបាច់ត្រូវតែគោរពតាមបញ្ជានោះ។

**(ចំនុចគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកការទប់ស្កាត់ការបំពុលដោយសាររ៉ែ)**

មាត្រា១៧២

អ្នកគ្រប់គ្រងការងារទទួលបន្ទុកការទប់ស្កាត់ការបំពុលដោយសាររ៉ែ ដើម្បីទប់ស្កាត់ការបំពុលដោយសារធូលី ចាំបាច់ត្រូវតែគោរពតាមការកំណត់ដូចខាងក្រោម៖

a. ស្តីពីទីកន្លែងស្តុករ៉ែដែលមានផ្ទៃក្រឡាលើសពី ១០០០ម៉ែត្រការ៉េ ថ្មចោល ទីកន្លែងស្តុកអាចម៍រ៉ែ ឬកាក សំណល់រង ទីកន្លែងលុបកាកសំណល់រ៉ែ ធ្វើការដើរពិនិត្យជាប្រចាំ និង ធ្វើការកត់ត្រាលើ

សៀវភៅសុវត្ថិភាពប្រចាំថ្ងៃ ស្តីពីលទ្ធផលនោះ។

b. ស្តីពីបរិក្ខាររែង ម៉ាស៊ីនកិនបំបែក និង ម៉ាស៊ីនកិនម៉ត់ ដែលមានប្រើម៉ូទ័រដែលមានកំឡាំងលើសពី ៧៥គីឡូវ៉ាត់ ស្តីពីបរិក្ខារខ្សែពានដែលបានដាក់នៅខាងក្រៅរូង ( ដែលមានទំហំទទឹងលើសពី ០,៧៥ម៉ែត្រ) និង backet belt conveyor ( ដែលមានចំណុះលើសពី០,០៣ម៉ែត្រគូប) និង ស្តីពីច្រកចេញនៃធូលីរបស់ម៉ាស៊ីនបំបាត់ធូលីនៃ ថ្មកំបោរ រួមទាំង ដូឡូមីត ធ្វើការដើរពិនិត្យជាប្រចាំ និង ធ្វើការកត់ត្រាលើសៀវភៅសុវត្ថិភាព ប្រចាំថ្ងៃស្តីពីលទ្ធផលនោះ។

c. ស្តីពីការដ្ឋានរ៉ែ ធ្វើការជីកយករ៉ែ រួមទាំង asbestos ស្តីពីកំហាប់នៃធូលី asbestosនៅក្នុងខ្យល់ នៅក្នុងតំបន់ព្រំប្រទល់នៃការដ្ឋានរ៉ែ គោរពតាមការកំណត់នៃ សេចក្តីប្រកាស់ទាក់ទងនឹងចំនុចចាំបាច់ត្រូវតែសរសេរកំណត់នៅក្នុងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការវ៉ាស់អោយបានលើសពី១ដងក្នុង៦ខែ និង ធ្វើការកត់ត្រាលើសៀវភៅសុវត្ថិភាព ប្រចាំថ្ងៃ ស្តីពីលទ្ធផលនោះ។

d. លទ្ធផលនៃការវ៉ាស់ និង ដើរត្រួតពិនិត្យកំណត់តាមចំនុច៣មុន នៅពេលមានកើតឡើងនូវគ្រោះថ្នាក់តាមរយៈធូលី ចាំបាច់ត្រូវតែធ្វើការរាយការណ៍ដល់អ្នកគ្រប់គ្រង។

**(ការទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈការបំពុលនៅក្នុងបរិយាកាសមានជាតិពុល**

មាត្រា១៧៣

ម្ចាស់សិទ្ធិការងាររ៉ែ ការក្តាប់ស្ថានភាពនៃភាពហ៊ុយ ឬ ការចេញផ្សែងទៅក្នុងបរិយាកាសនៃសារធាតុបំពុលមានជាតិពុលដែលបំពុលបរិយាកាស ដោយសារការធ្វើអាជីវកម្មរ៉ែ ចាំបាច់ត្រូវមានវិធានការចាំបាច់សំរាប់គ្រប់គ្រងភាពហ៊ុយ ឬ ការចេញផ្សែងនោះ។

**ផ្នែក៤ ទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់ ឬ ទឹកនៅក្នុងរូង**

**(របាយការណ៍ទាក់ទងនឹង ទឹកកខ្វក់ ឬ ទឹកនៅក្នុងរូង**

មាត្រា១៧៤

1 ម្ចាស់សិទ្ធិការងាររ៉ែ ក្នុងការធ្វើអជីវកម្មរ៉ែ មានការប្រើផ្លូវក្នុងរូង ដោយមានចេញនូវ ថ្មចោល អាចម៌

| | |
|---|---|
| | រ៉ែ និង ទីកន្លែងស្តុកកាកសំណល់រង ករណីមានការបញ្ចេញទឹកកខ្វក់ ឬ ទឹកក្នុងរូងនៃស្ថានភាពពុលដែលមិនសមស្របនឹងស្តង់ដាកំហិតអនុលោមតាម 「ច្បាប់គ្រប់គ្រងធនធានធម្មជាតិ និង ការការពារបរិដ្ឋាន」 យោងតាមការកំណត់តាមមាត្រា២៩-១នៃច្បាប់ ស្តីពីបរិមាណនិងស្ថានភាពបំពុលនៃប្រព័ន្ធបញ្ចេញទឹកកខ្វក់ទាំងនោះ ឬ ទឹកក្នុងរូង ចាំបាច់ត្រូវតែធ្វើការរាយការណ៍ដល់រដ្ឋមន្ត្រីទទួលបន្ទុកការងារ។<br>2 ស្តីពីបរិមាណនិងស្ថានភាពបំពុលនៃប្រព័ន្ធបញ្ចេញទឹកកខ្វក់ទាំងនោះ ឬ ទឹកក្នុងរូង កំណត់ដោយចំនុចមុន ចាំបាច់ត្រូវតែភ្ជាប់មកជាមួយនឹងលទ្ធផលនៃការវ៉ាស់ និង ផែទីទាក់ទងនឹងប្រព័ន្ធនៃការបញ្ចេញទឹក។<br><br>**(ការគោរពចំពោះស្តង់ដានៃការបញ្ចេញទឹកកខ្វក់**<br>មាត្រា១៧៥<br>1 ម្ចាស់សិទ្ធិការងាររ៉ែ ដើម្បីទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែ តាមរយៈទឹកកខ្វក់ និង ទឹកនៅក្នុងរូង តាមការបញ្ចេញនៅមាត់រុន្ធនៃការដ្ឋានរ៉ែទឹកកខ្វក់ និង ទឹកនៅក្នុងរូងដែលមានសភាពបំពុល បើមិនជាប់ស្តង់ដានៃការកំណត់ 「ច្បាប់ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និង ការការពារបរិដ្ឋាន」 គឺមិនអាចត្រូវបញ្ចេញទឹកទាំងនោះ ទៅក្នុងប្រភពទឹកសាធារណៈបានឡើយ។<br>2 ម្ចាស់សិទ្ធិការងាររ៉ែ បើមិនសមស្របនឹងលក្ខខ័ណ្ឌដែលបានកំណត់នៃ 「ច្បាប់ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និង ការការពារបរិដ្ឋាន」 គឺមិនអាចអោយ ទឹកកខ្វក់ និង ទឹកនៅក្នុងរូងជ្រៀបចូលទៅក្នុងដីបានទេ។<br>3 ម្ចាស់សិទ្ធិការងាររ៉ែ ស្តីអំពីបរិក្ខារចំរាញ់ទឹកកខ្វក់ក៏ដូចទឹកនៅក្នុងរូងឬបរិក្ខារបង្កើតឲ្យមានទឹកកខ្វក់ក៏ដូចទឹកនៅក្នុងដី នៅពេលមានកើតឡើងនូវគ្រោះថ្នាក់ដោយសារការបញ្ចេញ ក៏ដូចធ្វើការបញ្ចេញទឹកកខ្វក់ក៏ដូចទឹកនៅក្នុងរូង ដែលមិនសមស្របនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ មាន |

| | |
|---|---|
| | គ្រោះថ្នាក់ផ្សេងៗកើតឡើង ដូចជាការដាច់ចរន្តអគ្គិសនី បែកបាក់ ខូច ឬនៅពេលមានគ្រោះថ្នាក់កើតឡើងដោយសារជ្រាបចូលទៅក្នុងដីក៏ដូចជា ការជ្រាបចូលទៅក្នុងដីដោយទឹកកខ្វក់ក៏ដូចជាទឹកនៅក្នុងរូងតាមការកំណត់នៃចំនុចមុន ចាំបាច់ត្រូវមានវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់នោះ និង ចាំបាច់ត្រូវស្តារឡើងវិញជាបន្ទាន់ចំពោះអ្វីដែលបានខូចខាតដោយសារគ្រោះថ្នាក់នោះ។<br>4 ម្ចាស់សិទ្ធិការងាររ៉ែ នៅពេលកើតមានគ្រោះថ្នាក់ ឬ កើតមានការបំពុលបរិដ្ឋានដោយសារការធ្វើអាជីវកម្មរ៉ែ កើតមានការខូចខាតនៃបរិក្ខារប្រើសំរាប់ការងារអាជីវកម្មរ៉ែនិងគ្រោះថ្នាក់ផ្សេងទៀតកើតមានឡើង ដូចជាប្រេងលេចចេញ ចាំបាច់ត្រូវមានវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់នោះ និងចាំបាច់ត្រូវស្តារឡើងវិញជាបន្ទាន់ចំពោះអ្វីដែលបានខូចខាតដោយសារគ្រោះថ្នាក់នោះ។<br><br>មាត្រា១៧៦<br>ម្ចាស់សិទ្ធិការងាររ៉ែ ស្តីអំពីរបស់ដែលបានប្រើចប់មាននៅផ្លូវនៅក្នុងរូងនោះ មានទឹកក្នុងរូងហូរចេញ ក្នុងបរិមាណនិងក្នុងសភាពបំពុលដែលមិនសមស្របនឹងស្តង់ដាកំណត់ដោយ「ច្បាប់ទាក់ទងនឹងការគ្រប់គ្រងធន ធានធម្មជាតិ និង ការការពារបរិដ្ឋាន」 ។ ដើម្បីទប់ស្កាត់ការបំពុលបរិដ្ឋានដោយសារអាជីវកម្មរ៉ែតាមរយៈទឹកក្នុងរូងដែលចេញពីផ្លូវនៅក្នុងរូងនោះ ចាំបាច់ត្រូវតែមានវិធានការសមរម្យដោយតំឡើងបរិក្ខារចំរាញ់ទឹកនៅក្នុងរូង ឬធ្វើការបិទច្រករូងនៃផ្លូវនោះ។<br><br>**(ស្តង់ដាលើ ទឹកកខ្វក់ និង ទឹកក្នុងរូង**<br>មាត្រា១៧៧<br>ម្ចាស់សិទ្ធិការងាររ៉ែ ក្រៅពីការកំនត់តាមមាត្រាមុន ជាពិសេមានទទួលស្គាល់ដោយរដ្ឋមន្ត្រីទទួលបន្ទុកការងារ នូវភាពចាំបាច់ នៅពេលមានបញ្ហាសំរាប់ការអនុវត្តជាចាំបាច់នូវការចាត់វិធានការលើស្តង់ដានៃការបញ្ចេញ សំរាប់ទប់ស្កាត់ការបំពុលដោយសារទឹកក្នុងរូង និង ទឹកកខ្វក់ ចាំបាច់ត្រូវតែអនុវត្តតាម។ |

| | |
|---|---|
| | **(ការគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកការទប់ស្កាត់បំពុលដោយសាររ៉ែ**<br>មាត្រា១៧៨<br>អ្នកគ្រប់គ្រងការងារទទួលបន្ទុកការទប់ស្កាត់បំពុលដោយសាររ៉ែ ដើម្បីធ្វើការទប់ស្កាត់នូវការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់និងទឹកក្នុងរូង ចាំបាច់ត្រូវតែគោរពតាមការកំណត់នៃចំនុចនិមួយៗដែលមានដូចខាងក្រោមៈ<br>a. ធ្វើការដើរត្រួតពិនិត្យរាល់ថ្ងៃ នូវបរិក្ខារចំរាញ់ទឹកកខ្វក់ ឬ ទឹកនៅក្នុងរូង ព្រមទាំងធ្វើការកត់ត្រានូវលទ្ធផលទាំងនោះលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។<br>b. ស្តីពីទឹកកខ្វក់ ឬ ទឹកនៅក្នុងរូង គោរពតាមការកំណត់នៃ 「សេចក្តីប្រកាសទាក់ទងនឹងចំនុចត្រូវតែសរសេរកំណត់ក្នុងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」 ស្តីពីស្ថានភាពបំពុល និងបរិមាណទឹកកខ្វក់ ឬ ទឹកក្នុងរូងដែលចាំបាច់ត្រូវតែពិនិត្យ ត្រូវតែវ៉ាស់ទៅតាមម៉ោងដែលបានកំណត់ និង ធ្វើការកត់ត្រាទុកនៅក្នុងសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។<br>c. ចំពោះលទ្ធផលនៃការវ៉ាស់ ឬ ដើរត្រួតពិនិត្យតាមការកំណត់ ចំនុច២មុន នៅពេលមានភាពគ្រោះថ្នាក់អាចនឹងកើតឡើងច្រើន តាមរយៈហេតុផ្សេងៗ ដូចជាមានភ្លៀងខ្យល់ធ្លាក់ច្រើន ឬ នៅពេលមានភាពគ្រោះថ្នាក់អាចនឹងកើតឡើងច្រើនដល់បរិក្ខារចំរាញ់ទឹកកខ្វក់ ឬ ទឹកនៅក្នុងរូង ចាំបាច់ត្រូវធ្វើការរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។<br><br>**ផ្នែក៥ ទប់ស្កាត់ការបំពុលតាមរយៈ ប្រភេទនៃdioxin**<br>(**ស្តង់ដានៃការបញ្ចេញប្រភេទdioxin។ល។**)<br>មាត្រា១៧៩<br>1 ម្ចាស់សិទ្ធិការងាររ៉ែ ដើម្បីធ្វើការទប់ស្កាត់នូវការបំពុលដោយសាររ៉ែ តាមរយៈប្រភេទdioxin នៅច្រកបញ្ចេញនៃអគារបង្កើតdioxin ឬ នៅច្រកបញ្ចេញទឹកកខ្វក់នៃអគារ ឬ ការដ្ឋានរ៉ែ ដែលតំឡើងអគារនោះ បើទឹកកខ្វក់ ឬ ឧស្ម័នដែលចេញនោះមានរួមទាំងប្រភេទdioxin ដែលមោនត្រូវនឹងស្តង់ដានៃ |

| | |
|---|---|
1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ដើម្បីរក្សាបាននូវខ្យល់ឆ្លងកាត់នៅក្នុងរូង ចាំបាច់ត្រូវតែតំឡើងកង្ហាមេ។

2 កង្ហាមេតាមការកំណត់នៃចំនុចមុន តំឡើងនូវខ្សែចរន្តដែលធន់នឹងកំដៅនៅខាងក្នុងរូង, តំឡើង

នូវចំទីតាំងសមរម្យដែលអាចបញ្ចេញខ្យល់បានខ្លាំង និងផ្លូវខ្យល់ឆ្លងកាត់ដែលភ្ជាប់នឹងផ្លូវនៅក្នុងរូង និងកង្ហាមេសំខាន់ៗ, ចាំបាច់ត្រូវឃ្លាត៦ម៉ែត្រពីរបស់ដែលធន់នឹងកំដៅ។

3 កង្ហាមេនៃការកំណត់ចំនុចទី១ ចាំបាច់ត្រូវតំឡើងនូវទីតាំងដែលមិនឲ្យមានការបឺតខ្យល់ដែលចេញពីមាត់រន្ធ ចូលទៅក្នុងរូងវិញ។

4 កង្ហាមេនៃចំនុចទី១, នៅពេលមានភាពចាំបាច់ និងរៀបចំនូវឧបករណ៍វាស់សំពាធខ្យល់ ឬឧបករណ៍សំពាធខ្យល់ដោយស្វ័យប្រវត្តិ ចាំបាច់ត្រូវតែរៀបចំឲ្យមាននូវឧបករណ៍ចរន្តដោយស្វ័យប្រវត្តិនិងការកត់ត្រានៃការវាស់ដោយខ្លួនឯង។

5 ចំពោះកង្ហាមេនៃចំនុចទី១, ចាំបាច់ត្រូវដាក់មនុស្សចាំមើលជាប្រចាំ។ ក៏ប៉ុន្តែមិនចំពោះ នៅពេលបានរៀបចំនូវបរិក្ខារបញ្ចេញសំឡេងដោយស្វ័យប្រវត្តិនៅពេលមានការឈប់នៃការប្រយ័ត្ន ឬនៅពេលកង្ហាមេមានល្បឿនថយចុះ។

6 បណ្តាញចរន្តនៃដំណើរការកង្ហាមេ ចាំបាច់ត្រូវតែ តំឡើងក្នុងលក្ខណៈឯករាជ្យពីបណ្តាដ៏ទៃទៀត ។

7 នៅពេលមានភាពចាំបាច់សំរាប់សុវត្ថិភាព ចាំបាច់ត្រូវតែតំឡើងកង្ហារបំរុង និង ម៉ូទ័របំរុង។

មាត្រា២៥៣-៣

1 អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និង អ្នកគ្រប់គ្រងសុវត្ថិភាពរួម នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅពេលមាន កង្ហារមេត្រូវបានឈប់ដំណើរការ មានគ្រោះថ្នាក់ច្រើនសំរាប់សុវត្ថិភាពនៅក្នុងរូង ធ្វើការបញ្ឈប់ការផ្តល់ចរន្តទៅក្នុងតំបន់គ្រោះថ្នាក់នោះ និង ចាំបាច់ត្រូវតែជន្លៀសកម្មកររ៉ែទៅទីកន្លែងមានសុវត្ថិភាព។

2 អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និង អ្នកគ្រប់គ្រងសុវត្ថិភាពរួម នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA ) ក្រោយពីបានធ្វើការបញ្ឈប់ដំណើរការកង្ហាសំខាន់រួច នៅពេលចង់ដំណើរការឡើងវិញនៃកង្ហារមេទាំងនោះ បើមិនបានដោះស្រាយឲ្យសមរម្យសំរាប់សុវត្ថិភាពទេ មិនអាច ឲ្យ

| | |
|---|---|
| | កម្មកររ៉ែធ្វើការ ឬ បញ្ជូនចរន្តទៅក្នុងតំបន់គ្រោះថ្នាក់នោះ បានទេ។<br><br>**(ជញ្ជាំងបិទផ្តាច់និងទ្វាសំរាប់ខ្យល់ឆ្លងកាត់)**<br>មាត្រា២៥៧<br>4 ជញ្ជាំងនៃរូងការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ត្រូវប្រើជាសារធាតុមិនឆេះ ប៉េតុងឥដ្ឋស៊ីម៉ង់ឥដ្ឋ ចាំបាច់ត្រូវតែជារបស់មិនមានគ្រោះថ្នាក់និងការលេចខ្យល់ ។<br>5 នៅការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ផ្លូវនៅក្នុងរូងសំរាប់ធ្វើការដឹកជញ្ជូន និង ទ្វាសំរាប់ខ្យល់ឆ្លងកាត់នៃផ្លូវនៅក្នុងរូងសំខាន់សំរាប់ខ្យល់ឆ្លងកាត់ ធ្វើការតំឡើងឲ្យបានលើសពី២ដោយរក្សាបាននូវចំងាយសមរម្យ សំរាប់រថយន្តឬរទេះភ្លើងចូល និងចាំបាច់ត្រូវតែរៀបចំឲ្យមាននូវឧបករណ៍បិទបើកជាស្វ័យប្រវត្តិ ឬ ចាំបាច់ដាក់មនុស្សឲ្យនៅចាំមើល។<br><br>**(រចនាសម្ព័ន្ធនៃការផ្លាស់ប្តូរខ្យល់)**<br>មាត្រា២៥៨<br>2 នៅក្នុងរូងការដ្ឋានរ៉ែធ្យូងថ្មប្រភេទA មិនអាចឲ្យខ្យល់ដែលចេញពីទីកន្លែងយករ៉ែដែលបានបោះបង់ចោល ឬ ទីកន្លែងយករ៉ែតាមបែបវិធីជញ្ជាំងវែង ឲ្យឆ្លងកាត់ទីកន្លែងការងារជីកយករ៉ែធ្យូងថ្មដ៏ទៃទៀតបានទេ។<br>3 នៅក្នុងរូងការដ្ឋានរ៉ែធ្យូងថ្មប្រភេទA នៃ ទីកន្លែងយករ៉ែតាមបែបវិធីជញ្ជាំងវែង ហាមអោយខ្យល់<br>ឆ្លងកាត់បែប ទិសដៅបែទៅក្រោម។<br><br>**ផ្នែកទី៤ ការវាស់ចរន្តខ្យល់នៅក្នុងរូង**<br>**(ការវាស់នៃបរិមាណខ្យល់ឆ្លងកាត់ក្នុងរូង)** |

មាត្រា២៥៩

3 អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅក្នុងរូង ដើម្បី ក្តាប់នូវបរិមាណខ្យល់ឆ្លងកាត់ ចាំបាច់រាល់ថ្ងៃត្រូវក្តាប់ឲ្យបាននូវបរិមាណសុរបនៃខ្យល់ចូលទៅក្នុងរូងនិងបរិមាណសរុបខ្យល់ចេញ ក្នុងរយៈពេល៧ថ្ងៃម្តង ត្រូវតែធ្វើការវាស់នូវបរិមាណខ្យល់ឆ្លងកាត់សំខាន់ៗ និងបរិមាណនៃខ្យល់ចេញនៃកន្លែងសំខាន់ៗ។

4 អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង ចាំបាច់ត្រូវតែកត់ត្រានូវលទ្ធផលទាំងនោះតាមការកំណត់នៃចំនុចមុន លើ「បញ្ជីនៃគ្រប់គ្រងខ្យល់ឆ្លងកាត់ក្នុងរូង」 ។

**ផ្នែកទី៥ ឧស្ម័ននៅក្នុងរូង**

**(ការតំឡើងបរិក្ខាបញ្ចេញសំឡេងប្រយ័ត្នស្វ័យប្រវត្តិនៃឧស្ម័នមានភាពឆេះ**

មាត្រា២៦៤-២

1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ចាំបាច់ត្រូវតែតំឡើងឲ្យបានលើសពី១ឧបករណ៍វាស់សំឡេងប្រយ័ត្នស្វ័យប្រវត្តិនៃឧស្ម័នមានភាពឆេះនៅតាមទីកន្លែងទាំងនោះដែលមានដូចខាងក្រោម៖

1) ទីកន្លែងធ្វើការងារជីកយករ៉ែ។
2) ទីកន្លែងធ្វើការងារខួងឈានទៅមុខ (លើកលែង ទីកន្លែងធ្វើការងារខួងទៅមុខដែលជាកន្លែងមានថ្ម និងមានឧស្ម័នចេញអាចនឹងមានគ្រោះថ្នាក់។ )
3) ទីកន្លែងបានតំឡើងនូវបរិក្ខារផលិតប្រើដោយចរន្តអគ្គិសនី នៅទីកន្លែងជាធម្មតាមានឧស្ម័នមានភាពឆេះមានភាគរយលើសពី១%។
4) នៅពេលមានភាពមិនប្រក្រតីចំពោះខ្យល់ឆ្លងកាត់ ទីកន្លែងមានភាពចាំបាច់ផ្សេងទៀត ដែលជាទីកន្លែងបានតំឡើងនូវបរិក្ខារផលិតប្រើដោយចរន្តអគ្គិសនី នៅទីកន្លែងមាន ឧស្ម័នមានភាពឆេះកកផ្ទុំ។

| | |
|---|---|
| | 2 បរិក្ខារបញ្ចេញសំឡេងប្រយ័ត្នដោយស្វ័យប្រវត្តិចំពោះឧស្ម័នមានភាពឆេះនៃចំនុចមុន ចាំបាច់ត្រូវតែ តំឡើងធ្វើយ៉ាងណាអាចធ្វើការត្រួតពិនិត្យចំពោះឧស្ម័នមានភាពឆេះទាំង នោះឲ្យមានប្រសិទ្ធិភាព។<br>3 ករណីតំឡើងចំពោះទីកន្លែងអាចនឹងមានភាពគ្រោះថ្នាក់កើតច្រើន តាមរយៈការកើនឡើងគួរឲ្យកត់សំគាល់នូវឧស្ម័នមានភាពឆេះ ឬតំបន់ប្រយ័ត្នដែលអាចនឹងមានឧស្ម័នធ្លាយចេញមក នូវបរិក្ខារបញ្ចេញសំឡេងប្រយ័ត្នដោយស្វ័យប្រវត្តិចំពោះឧស្ម័នមានភាពឆេះនៃចំនុចទី១ នៅពេលមានលើសពី១,៥%នៃឧស្ម័នមានភាពឆេះនៃទីកន្លែងឬ តំបន់នោះ ចាំបាច់ត្រូវតែមានការបញ្ឈប់ជាស្វ័យប្រវត្តិនូវការបញ្ជូនចរន្តចំពោះបរិក្ខារ ផលិតដែលប្រើចរន្ត ដែលបានតំឡើងនៅទីកន្លែងនោះឬ តំបន់នោះ ។<br><br>**ផ្នែក៥-២ ការទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយឧស្ម័នចេញ**<br>(**តំបន់ប្រយ័ត្នចំពោះឧស្ម័នចេញ**)<br>មាត្រា២៦៧-២<br>1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេA) នៅពេលធ្វើការខួងសំរាប់បន្តផ្លូវនៅក្នុងរូងទៅមុខ និងការខួងផ្សេងៗទៀត ចាំបាច់ត្រូវតែធ្វើការកំណត់ជាតំបន់ប្រយ័ត្នមានគ្រោះថ្នាក់ដោយសារឧស្ម័នចេញដែលនឹងអាចមានគ្រោះថ្នាក់។<br>2 ចំពោះតំបន់ដែលអាចនឹងមានឧស្ម័នចេញតាមចំនុចមុន តាមរយៈវិធីសមរម្យផ្សេងៗ ធ្វើការបង្ហាញនៅខាងក្រៅរូងនៃការិយាល័យ ចាំបាច់ត្រូវតែឲ្យកម្មកររ៉ែទាំងឡាយដឹង អំពីតំបន់ទាំងនោះ។<br>3 ម្ចាស់សិទ្ធការងាររ៉ែ នៅពេលធ្វើការខួងសំរាប់ផ្លូវនៅក្នុងរូង ចំពោះ តំបន់ប្រយ័ត្តមានឧស្ម័នចេញ ចាំបាច់ត្រូវតែដាក់បុគ្គលិកសុវត្ថិភាពនៅក្នុងរូង នៅតាម ទីកន្លែងខួងទៅមុខ ទាំងនោះ។ |

| | |
|---|---|
| | មាត្រា២៦៧-៣<br>1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅពេលធ្វើការខួងសំរាប់ផ្លូវនៅក្នុងរូង ចំពោះតំបន់ប្រយ័ត្តមានឧស្ម័នចេញ ធ្វើការខួងទុកជាមុន និង រវាងផ្ទៃការងារនៃការខួងទៅមុខនិងរូងនោះ ចាំបាច់ត្រូវតែរក្សានូវចំងាយសុវត្ថិភាពមួយជាប់ជាប្រចាំ។<br>2 ទិសដៅនៃការខួងទៅមុខតាមចំនុចមុន ចំពោះចំនួនរន្ធនិងប្រវែងរន្ធ ចាំបាច់ត្រូវតែក្តាប់ឲ្យបាននូវស្ថានភាពភូគ្គសាស្ត្រនិងស្ថានភាពនៃឧស្ម័នមានភាពឆេះទាំងនោះ និងដើម្បីក្តាប់បាននូវស្ថានភាពនៃឧស្ម័នមានភាពឆេះ ធ្វើការវាស់នូវចំនុចសំខាន់ៗផ្សេងនៃបរិ មាណ និងសំពាធនៃឧស្ម័នដែលចេញដោយខ្លួនឯងនៅតាមមាត់រន្ធទាំងនោះ បើនៅ ពេលមានភាពចាំបាច់ ត្រូវតែប្រយ័ត្នចំពោះការប្រែប្រួលនៃឧស្ម័នទាំងនោះ។<br><br>មាត្រា២៦៧-៤<br>1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ចំពោះនៅតំបន់ប្រយ័ត្នមានឧស្ម័នចេញ បើមិនទាន់បានខួងយកឧស្ម័ននោះ ចេញទេ គឺមិនអាចអនុវត្តការងារខួងយករ៉ែបានទេ។<br>2 នៅពេលអនុវត្តតាមរយៈការខួងយកឧស្ម័នចេញតាមចំនុចមុន ធ្វើការវាស់នូវពេលវេលាបរិមាណនៃឧស្ម័នដែលចេញក្នុងរយៈពេលថេរមួយ, សំពាធនៃឧស្ម័នដែលចេញដោយខ្លួនឯងនៅតាមមាត់រន្ធទាំងនោះ បើនៅពេលមានភាពចាំបាច់ត្រូវតែប្រយ័ត្នចំពោះការប្រែប្រួលនៃឧស្ម័នទាំងនោះ។<br><br>មាត្រា២៦៧-៥<br>1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅពេលអនុវត្តខួងទៅមុខនៃផ្លូវនៅក្នុងរូងចំពោះតំបន់ប្រយ័ត្ន ដែលមានឧស្ម័នចេញ ចំពោះការបញ្ចេញខ្យល់នោះមិនអាចឲ្យឆ្លងទីកន្លែងខួងយករ៉ែធ្យូងថ្មតាមបែបជញ្ជាំងវែងបានឡើយ។ |

2 ចំពោះនៅតំបន់ប្តយ័ត្ននៃឧស្ម័នចេញ មិនត្រូវធ្វើការខួងទៅមុខចំទិសដៅនៃឧស្ម័នដែលចេញមកបានទេ។ ក៏ប៉ុន្តែមិនចំពោះ មានករណីជៀសមិនផុតលើវិធីខួងយករ៉ែ នៅពេលបានចាត់វិធានការសមរម្យសំរាប់ធ្វើការទប់ស្កាត់ភាពគ្រោះថ្នាក់ តាមរយៈឧស្ម័នចេញ។

មាត្រា២៦៧-៦

1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA ) ចំពោះនៅតំបន់ប្រយ័ត្ននៃឧស្ម័នចេញ ចាំបាច់ត្រូវតែ តំឡើងអគារសមរម្យសំរាប់ធ្វើការជន្លៀសកម្មកររ៉ែដោយមានបរិក្ខារផ្គត់ផ្គង់ខ្យល់ទៅទីកន្លែងសមរម្យទាំងនោះ។

2 អគារសុវត្ថិភាព ជាអគារដែលអាចផ្គត់ផ្គងខ្យល់និងអុកស៊ីសែន និង ចាំបាច់ដាក់នូវវិទ្យុសំរាប់ទាក់ទង ណែនាំនៅក្នុងរូង។

មាត្រា២៦៧-៧

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅពេលមានបញ្ហាចាត់នូវវិធានការចាំបាច់សមរម្យសំរាប់ទប់ស្កាត់នូវគ្រោះថ្នាក់តាមរយៈឧស្ម័នចេញ ឬ ការកំណត់តំបន់ ឧស្ម័នចេញ ចាំបាច់ត្រូវតែគោរពតាម។

**(ចំនុចគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនិងសុវត្ថិភាពក្នុងរូង**

មាត្រា២៦៧-៨

1 អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនិងសុវត្ថិភាពក្នុងរូង នៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅពេលបានខួងយកឧស្ម័ន និង ខួងជាមុនសំរាប់ទប់ស្កាត់ឧស្ម័នចេញ ធ្វើការកត់ត្រានូវលើ「សៀវភៅតប់ទល់នឹងឧស្ម័នចេញ」នៅពេលទទួលស្គាល់ថាមានភាពមិនប្រក្រតីចំពោះលទ្ធផលនោះ ចាំបាច់ត្រូវតែរាយការណ៍ដល់អ្នកគ្រប់គ្រង ជាបន្ទាន់។

| | |
|---|---|
| | 2 អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនិងសុវត្ថិភាពក្នុងរូង នៅពេល ទទួលស្គាល់ថាមានសភាពមិនប្រក្រតីនៃឧស្ម័នចេញ ទន្ទឹមនឹងឲ្យកម្មកររ៉ែជន្លៀសខ្លួនទៅទីកន្លែងមានសុវត្ថិភាពជាបន្ទាន់ ចាត់វិធានការតប់ទល់ជាបន្ទាន់ផ្សេងៗដោយបញ្ឈប់ការផ្គត់ចរន្ត និងធ្វើការរាយការណ៍ដល់អ្នកគ្រប់គ្រង។<br><br>**ផ្នែក៥-៣ ការទប់ស្កាត់ភាពគ្រោះថ្នាក់តាមរយៈចរន្តណឺត**<br>**(វិធានការទាក់ទងនឹងចរន្តណឺត)**<br>មាត្រា២៦៧-៩<br>ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ដើម្បីធ្វើការទប់ស្កាត់ការកើតឡើងនៃគ្រោះថ្នាក់តាមរយៈចរន្តណឺត ចាំបាច់ត្រូវតែអនុលោមតាមចំនុចនីមួយៗដែលមានដូចខាងក្រោម៖<br>1) ស្តីអំពីបរិក្ខារនានាដែលមានភាពគ្រោះថ្នាក់តាមរយៈការកកកុំនៃចរន្តណឺត ចាំបាច់ចាត់វិធានការសមរម្យផ្សេងៗដោយបាច់ទឹក តខ្សែម៉ាសទៅនឹងដី ប្រើតង់ ប្រើរបស់ណាដែលដោះស្រាយជាមួយនឹង ចរន្តណឺតបាន។<br>2) នៅពេលអនុវត្តការងារដែលនឹងមានភាពគ្រោះថ្នាក់តាមរយៈចរន្តណឺត ចាត់វិធានការសមរម្យផ្សេងៗដោយបាច់ទឹក។<br><br>**ជំពូក១៣-២ ការផ្ទុះនៃធូលីធ្យូងថ្ម**<br>**ផ្នែក១ បទបញ្ញត្តិទូទៅ**<br>មាត្រា២៦៧-១០<br>ស្តីពីការទប់ស្កាត់ ការផ្ទុះរាលដាលនិងទប់ស្កាត់ការផ្ទុះ ទងនឹងធូលីធ្យូងថ្ម យោងតាមការកំណត់តាមមាត្រា៥នៃច្បាប់ ម្ចាស់សិទ្ធការងាររ៉ែ ចាំបាច់ត្រូវចាត់វិធានការ និង កម្មកររ៉ែ យោងតាមការកំណត់តាមមាត្រា៦នៃច្បាប់ ចាំបាច់ត្រូវតែគោរពតាមចំនុចដែលបានចាត់អនុលោមតាមការកំណត់តាមមាត្រា៣១នៃច្បាប់ ធ្វើការកំណត់ដូចខាងក្រោម។ |

**ផ្នែក២  ការដោះស្រាយចំពោះធូលីធ្យូងថ្ម**

**(ទប់ស្កាត់ចំពោះការគផ្តុំនៃធូលីធ្យូងថ្ម**

មាត្រា២៦៧-១១

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ចំពោះផ្លូវនៅក្នុងរូងផ្សេងនិងផ្លូវនៅក្នុងរូងសំរាប់ធ្វើការដឹកជញ្ជូននៅក្នុងរូង  ស្តីពីធូលីធ្យូងថ្ម  ចាំបាច់ត្រូវតែធ្វើការសំអាតជាប្រចាំក្នុងពេលវេលាថេរមួយ ដោយឆ្លើយតបទៅនឹងភាពគផ្តុំនៃធូលីដែលហ៊ុយមក។

**(ការបាច់ទឹក ឬ ការបាច់ម្សៅថ្ម)**

មាត្រា២៦៧-១២

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅក្នុងរូង ចំពោះទីតាំងនៃចំនុចនីមួយៗដែលមានដូចខាងក្រោមដែលមានធូលីធ្យូងថ្មមានភាពផ្ទុះហ៊ុយរាយប៉ាយ ចាំបាច់ត្រូវមានវិធានការ សមរម្យដោយមានបាញ់ចំពោះជញ្ជាំងថ្មធ្យូងថ្ម ការបាច់ទឹក ដើម្បីធ្វើឲ្យធូលីទាំងនោះបាត់បង់នូវភាពផ្ទុះរបស់វា។

1) នៅជិតទីកន្លែងក៏ដូចជាទីកន្លែងការងារខួងទៅមុខ និងទីកន្លែងការងារខួងយករ៉ែធ្យូងថ្ម ដែលងាយនឹងមានធូលី ហើរតាមរយៈការប្រើម៉ាស៊ីនខួងយករ៉ែ ឬ ប្រើpick ។
2) ទីកន្លែងធ្វើការបំផ្ទុះនិងនៅជិតទីកន្លែងនោះ មុននិងក្រោយពីបានធ្វើការបំផ្ទុះស្រទាប់យកធ្យូងថ្ម។
3) ទីកន្លែងគនិងដឹកចេញ និងច្រកនៃការដឹកចូលនៃថ្មធ្យូង។
4) ទីកន្លែងផ្ទុកធ្យូងថ្មនៅក្នុងរូង និងគ្រប់នៃថ្មធ្យូងដែលបានគជាបណ្តោះអសន្នក្នុងរូង។
5) មុននឹងការលើកដាក់ទៅលើយានដឹករ៉ែ ក៏ដូចជាក្រោយការដឹករ៉ែ។

មាត្រា២៦៧-១៣

1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅក្នុងរូង ចំពោះទីកន្លែងគនៃគំនូធូលីធ្យូងថ្មហ៊ុយមកដែលមានភាពផ្ទុះ ជាធម្មតា ចាំបាច់ត្រូវតែ បាច់ម្សៅថ្មក្នុងបរិមាណសមរម្យជាប្រចាំ។

2 ការកំណត់នៃចំនុចមុន មិនរាប់បញ្ចូល ចំពោះទីកន្លែងដែលជាធម្មតាមានភាគរយនៃទំងន់លើសពី២៥%នៃបិរមាណដែលមានសើមជាមួយ និងធូលីធ្យូងថ្មដែលមានភាពផ្ទុះ។

3 ស្តីពីម្សៅថ្មកំណត់ដោយចំនុច១ ម្សៅធូលីថ្មដែលមាន free sillcic acid ក្នុង បរិមាណច្រើន ចាំបាច់ត្រូវធ្វើការ ឬ ចាំបាច់ត្រូវតែទុកនៅក្នុង rock dust barrier ។

**(ចំនុចគោរពរបស់អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង**

មាត្រា២៦៧-១៤

អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទ A) នៅក្នុងរយៈ៣០ថ្ងៃម្តងស្តីអំពីនៅក្នុងរូងទាំងមូល ធ្វើការពិនិត្យតើមានឬមិនមានគ្រោះថ្នាក់នៃធូលីធ្យូងថ្មដែលមានភាពផ្ទុះ និង ចាំបាច់ត្រូវតែកត់ត្រានៅលើសៀវភៅតប់ទល់នឹងធូលីធ្យូងថ្ម នូវលទ្ធផលទាំងនោះ។

មាត្រា២៦៧-១៥

1 អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទ A ) ដើម្បីទប់ស្កាត់ការរីកដាលនៃការផ្ទុះនិងវិធានការនៃធូលីថ្យូងថ្មនូវភាពផ្ទុះ ចាំបាច់ត្រូវតែគោរពនូវការកំណត់នៃចំនុចនីមួយៗដែលមានដូចខាងក្រោម៖

1) ការផ្ទុះនៃធូលីធ្យូងថ្មដោយភាពផ្ទុះ ឬធ្វើការដើរពិនិត្យរាល់ថ្ងៃតាមចំនុចដែលមាន ធ្វើការពិនិត្យបរិក្ខារទប់ស្កាត់ការរីកដាលនៃការផ្ទុះ និងស្ថានភាពនៃធូលីធ្យូងថ្មដែលមានភាពផ្ទុះ ធ្វើការកត់ត្រានៅលើបញ្ជីចាត់វិធានការធូលីធ្យូងថ្មនៃលទ្ធផលទាំងនោះ នៅពេលមានភាពមិន

ប្រក្រតី ចាំបាច់ត្រូវតែរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

2) ធ្វើការយកវត្ថុគំរូតាមពេលថេរមួយនូវធូលីនៃថ្មទាំងនោះ ធ្វើការវាស់នូវបរិមាណនៃសារធាតុមិនផ្ទុះ និងចាំបាច់ធ្វើការកត់ត្រានូវលទ្ធផលទាំងនោះនៅលើបញ្ជីវិធានការចំពោះធូលី។

2 ទីកន្លែងដែលចាំបាច់ត្រូវតែយកវត្ថុគំរូតាមចំនុច៦មុន ស្តីអំពីវិធីវាស់បរិមាណនៃសារធាតុមិនមានភាពឆេះ ក៏ដូចជាពេលវេលានិងវិធីយកវត្ថុគំរូ នឹងធ្វើការកំណត់នៃ សេចក្តីប្រកាសនៃចំនុចត្រូវតែសរសេរការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ សំរេចថានឹងធ្វើការវ៉ាស់។

**ផ្នែក៣ ការទប់ស្កាត់ការរីកដាលនៃការផ្ទុះ**

**(បរិក្ខារទប់ស្កាត់ការរីកដាលនៃការផ្ទុះជាធម្មតា)**

មាត្រា២៦៧-១៦

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) នៅក្នុងរូង ដើម្បីធ្វើការទប់ស្កាត់ការរីកដាលនៃការផ្ទុះ ចំពោះផ្លូវដឹកជញ្ជូននៅក្នុងរូងសំខាន់ៗ នៅជិតច្រកចេញចូលនៃទីកន្លែងធ្វការងារនៅក្នុងរូង ចាំបាច់ត្រូវតែតំឡើងបរិក្ខារទប់ស្កាត់ការរីកដាលនៃការផ្ទុះ តាមចំនុចនីមួយៗដែលមានដូចខាងក្រោម៖

1) ធូលីថ្មដែលមានលើសពី0,១ម៉ែត្រគូបនៅក្នុង១ម៉ែត្រការ៉េនៃផ្ទៃមុខកាត់គិតជាមធ្យមនៃផ្លូវនៅក្នុងរូង ឬ water barriers ឬ rock barriesដែលផ្ទុកដោយទឹក។
2) តំបន់ដែលមានធូលីថ្មកំហាប់ខ្ពស់ដែលមានធូលីថ្មហ៊ុយមានលើសពី0,៣ម៉ែត្រគូប នៅក្នុង១ម៉ែត្រការ៉េនៃផ្ទៃមុខកាត់គិតជាមធ្យមនៃផ្លូវនៅក្នុងរូង។

**(បរិក្ខារទប់ស្កាត់ការរីករាលដាលនៃការផ្ទុះពិសេស)**

មាត្រា២៦៧-១៧

ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែធ្យូងថ្មក្រោមដី (ប្រភេទA) ដើម្បីធ្វើការទប់ស្កាត់នៃការផ្ទុះរាលដាលនៃធូលីដែលមានភាពផ្ទុះ ចំពោះទីតាំងចាំបាច់ផ្សេងៗនៅជិតច្រកចេញចូលនៃតំបន់ការងារ នៅ

| | |
|---|---|
| | ក្នុងរូងនៃការដ្ឋានរ៉ែថ្មូងថ្ម ធូលីថ្មដែលមានលើសពី០,១ម៉ែត្រគូបនោក្នុង១ម៉ែត្រការ៉េនៃផ្ទៃមុខកាត់គិតជាមធ្យមនៃផ្លូវនៅក្នុងរូង ឬ water barriers ឬ rock barriesដែលផ្ទុកដោយទឹក។<br><br>**(វិធីតំឡើងrock barries water barriers និង តំបន់កំហាប់ម្សៅថ្ម។ល។)**<br>មាត្រា២៦៧-១៨<br>1 ម្ចាស់សិទ្ធការងាររ៉ែនៃការដ្ឋានរ៉ែថ្មូងថ្មក្រោមដី (ប្រភេទA) នៅក្នុងរូង ចំពោះwater barriers ឬ rock barries ធូលីថ្ម ឬ ទឹកដែលការទុកដាក់នូវស្ថានភាពងាយធ្វើឲ្យហ៊ុយតាមរយៈការបំផ្ទុះនៅពេលមានភាពហ៊ុយដោយសារទឹកឬម្សៅថ្ម ចាំបាច់ត្រូវតែតំឡើងធ្វើយ៉ាងណាឲ្យមានការអាចបិទជិតនូវផ្ទៃមុខកាត់នៃរូងទាំងមូល។<br>2 នៅក្នុងរូងនៃការដ្ឋានរ៉ែថ្មូងថ្ម ធ្វើការតំឡើងឲ្យមានគំលាតរវាងស្មើគ្នារវាងwater barriers និង rock barries ។ល។ ហើយគំលាតនោះចាំបាច់ត្រូវឲ្យមានលើសពី១ម៉ែត្រឡើង។និងក្រោម៣០ម៉ែត្រ។<br>3 ចំពោះម្សៅថ្មដែលបាច់នៅក្នុងតំបន់មានម្សៅថ្មកំហាប់ខ្ពស់ ចាំបាច់ត្រូវតែមានផ្ទៃបាតឲ្យមានកំរាស់លើសពី១០សង់ទីម៉ែត្រ។<br><br>**ជំពូក១៤ ទីកន្លែងធ្វើការក្រៅរូង**<br>**ផ្នែក២ ទីកន្លែងធ្វើការនៅក្រៅរូង**<br><br>**(ការវាយតំលៃនៃបរិដ្ឋានការងារ)**<br>មាត្រា២៧៣-២<br>1 ម្ចាស់សិទ្ធការងាររ៉ែ ស្តីអំពីទីកន្លែងធ្វើការងារនៅក្រៅរូងនៅក្នុងបន្ទប់ តាមការកំណត់នៃមាត្រាទី២៧២-១ អ្នកទទួលបន្ទុកការបំផ្ទុះផ្នែកសុវត្ថិភាពនៅក្រៅរូង នៅពេលវាស់កំរិតកំហាប់ធ្យូងថ្ម ស្តី |

ពីទីកន្លែងធ្វើការហ៊ុយធូលីធ្យូងថ្មដែលគួរអោយកត់សំគាល់ អនុលោមតាម 「សេចក្តីប្រកាសទាក់ទងនឹងចំនុចនានាត្រូវតែសរសេរកំណត់ក្នុងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」 ឆ្លើយតបនឹងអត្រាបរិមាណមាន free silicic acid នៅក្នុងធូលីធ្យូងថ្ម និង កំរិតកំហាប់ធូលីនៅក្នុងខ្យល់ នៃទីកន្លែងធ្វើការនៅក្នុងបន្ទប់នោះ ត្រូវតែធ្វើការវាយតំលៃបរិដ្ឋានការងារ។

2 ម្ចាស់សិទ្ធការងាររ៉ែ ធ្វើការកត់ត្រាលទ្ធផលនៃការវាស់តាមការកំណត់នៃចំនុចមុន លើ សៀវភៅគ្រប់គ្រងវ៉ាស់ធូលីធ្យូងថ្ម និង ការវាយតំលៃបរិដ្ឋានការងារ ចាំបាច់ត្រូវតែរក្សាការកត់ត្រានោះក្នុងរយៈពេល៥ឆ្នាំ។

**(វិធានការអនុវត្តការវាយតំលៃបរិដ្ឋានការងារ)**

មាត្រា២៧៣-៣

1 ម្ចាស់សិទ្ធការងាររ៉ែ លទ្ធផលនៃការវាយតំលៃបរិដ្ឋានការងារតាមរយៈការកំណត់នៃមាត្រាមុន១ ស្តីអំពីទីកន្លែងការងារនៅក្រោមរូងក្នុងបន្ទប់ ដែលបានបែងចែកជាតំបន់គ្រប់គ្រងទី៣ ចាត់វិធានការចាំបាច់ដើម្បីធ្វើការកែលំអកំហាប់នៃធូលីនៃទីកន្លែងធ្វើការងារនោះជាបន្ទាន់ ហើយកន្លែងធ្វើការងារនោះចាំបាច់ត្រូវតែធ្វើការកែលំអ ដោយបែងចែកជា តំបន់គ្រប់គ្រង់ទី១ តំបន់គ្រប់គ្រង់ទី២ និង តំបន់គ្រប់គ្រង់ទី៣។

2 ម្ចាស់សិទ្ធការងាររ៉ែ នៅពេលបានចាត់វិធានការតាមរយៈការកំណត់នៃចំនុចមុន ដើម្បីបញ្ជាក់អំពីលទ្ធផលនោះ ស្តីអំពីទីកន្លែងធ្វើការនៅក្នុងបន្ទប់នោះ យោង「សេចក្តីប្រកាសទាក់ទងនឹងចំនុចនានាត្រូវតែសរសេរកំណត់ក្នុងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ」ឲ្យអ្នកទទួលបន្ទុកការបំផ្ទុះផ្នែកសុវត្ថិភាពនៅក្រោមរូង ធ្វើការវាស់ នូវអត្រាភាគរយនៃ free silicic acid ដែលមាននៅក្នុងធូលី និង កំរិតកំហាប់ធូលី ស្តីអំពីលទ្ធផលនោះ ចាំបាច់ត្រូវតែអនុវត្តវាយតំលៃនៃបរិដ្ឋានការងារដូចគ្នា។

3 ម្ចាស់សិទ្ធការងាររ៉ែ លទ្ធផលវាយតំលៃតាមរយៈ ការកំណត់នៃមាត្រាមុន១ ស្តីអំពីទីកន្លែងធ្វើការក្រោមរូងក្នុងបន្ទប់ដែលត្រូវបានបែងចែកដោយតំបន់គ្រប់គ្រងទី២ ចាំបាច់ត្រូវតែខិតខំចាត់

វិធានការចាំបាច់ដើម្បីកែលំអកំហាប់ធូលីនៃទីកន្លែងធ្វើកាក្នុងបន្ទប់នោះ។

**ផ្នែក៤ ឧបករណ៍គ្រឿងចក្រទូទៅ**

**(របងហ៊ុំព័ទ្ធនិងបណ្តាបរិក្ខារទប់ស្កាត់គ្រោះថ្នាក់ផ្សេងទៀត**

មាត្រា២៧៧-២

ម្ចាស់សិទ្ធិការងាររ៉ែ ចំពោះគ្រឿងចក្រដែលមានផ្ទៃបាត ឬ ដង ដែលមានអ័ក្សឬអ័ក្សខាងចុងវែងចេញមានប្រវែង២ម៉ែត្រចុះ ចាំបាច់ធ្វើការរៀបចំបរិក្ខារសុវត្ថិភាពផ្សេងៗ គ្រប ហ៊ុំព័ទ្ធ របងព័ទ្ធ ចំពោះផ្នែកគ្រោះថ្នាក់។ល។មានចលនាតាមរយៈ ខ្សែពួរ ច្រវ៉ាក់ ឬ ខ្សែពាន។

មាត្រា២៧៧-៣

ម្ចាស់សិទ្ធិការងាររ៉ែ ចំពោះគ្រឿងចក្រដែលដំណើការដោយកំឡាំង ដែលគ្រឿងចក្រនីមួយៗចាំបាច់ត្រូវតែមានឧបករណ៍បិទបើកកំឡាំងនោះរួមមាន idler pulley, clutch។

**(ឧបករណ៍បង្កើតកំដៅខ្លាំង)**

មាត្រា២៧៧-៤

1 ម្ចាស់សិទ្ធិការងាររ៉ែ ចំពោះទីកន្លែងប្រើរបស់មានកំដៅខ្លាំងក្នុងបរិមាណច្រើនដូចជា cupolaនៃការដ្ឋានរ៉ែថ្មរូងថ្ម ក៏ដូចជាcupolaនៃការដ្ឋានរ៉ែលោហៈនិង converter ចាំបាច់ត្រូវតែមានវិធានការសមរម្យដើម្បីទប់ស្កាត់គ្រោះថ្នាក់ដែលចេញពីរបស់ក្តៅខ្លាំងនោះ ឬ ដោយសារការផ្ទុះនៃរបស់ទាំងនោះ។

2 ចំពោះទីកន្លែងតាមចំនុចមុន ចាំបាច់រៀបចំអោយមានឧបករណ៍ការពារសមរម្យ ស្រោមដៃ ស្បែកជើងសុវត្ថិភាពដើម្បីទប់ស្កាត់ភ្លើងដែលបង្ករបួសនិងគ្រោះថ្នាក់ផ្សេងទៀត ចាំបាច់ត្រូវអោយអ្នកមានសញ្ញាប័ត្រប្រើប្រាស់ឡ រំលាយមកធ្វើការងារនេះ ។

| | |
|---|---|
| | (arc welding)<br>មាត្រា២៧៧-៥<br>1 ម្ចាស់សិទ្ធិការងាររ៉ែ ទីកន្លែងធ្វើការផ្សារតាមបែប arc welding និងទីកន្លែងមានគ្រោះថ្នាក់ច្រើនដោយសារការជះនៃពន្លឺខ្លាំងផ្សេងទៀត ចាំបាច់ត្រូវតែធ្វើការបែងចែកតំបន់។<br>2 ចំពោះទីកន្លែងតាមការកំណត់នៃចំនុចមុន ចាំបាច់ត្រូវមានឧបករណ៍ការពារសមរម្យ ស្រោមដៃ បរិក្ខារការពារភ្នែក ។ល។ ចាំបាច់ត្រូវអោយអ្នកមានសញ្ញាប័ត្រផ្សា arc welding មកធ្វើការងារនេះ ។<br><br>**(ការដោះស្រាយចំពោះពេលជួសជុល)**<br>មាត្រា២៧៧-៦<br>ចំពោះនៅការដ្ឋានរ៉ែ នៅពេលធ្វើត្រួតពិនិត្យ ឬ ជួសជុលបរិក្ខារគ្រឿងចក្រ ដោយបញ្ឈប់ប្រតិបត្តិគ្រឿងចក្រ អ្នកដែលត្រូវបានចាត់តាំងដោយ អ្នកទទួលគ្រប់គ្រងការងារ ឬ អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកនេះ ការងារទាំងនោះដែលកំពុងតែអនុវត្ត ក្រៅពីការលើកផ្លាកសញ្ញាប្រយ័ត្នប្រាប់ពីគោលបំណងដោយបញ្ឈប់ប្រតិបត្តិការគ្រឿងចក្រ ចាំបាច់ត្រូវមានវិធានការច្បាស់លាស់ទប់ស្កាត់ការបើកបរគ្រឿងចក្រនោះពីសំណាក់អ្នកដ៏ទៃ ដោយធ្វើការចាក់សោរ ចាំបាច់ត្រូវតែមានវិធានការច្បាស់លាស់ទប់ស្កាត់អ្នកដ៏ទៃប្រើប្រាស់គ្រឿងចក្រទាំងនោះបាន។<br><br>**(ការថែទាំនៃបរិក្ខារសុវត្ថិភាព)**<br>មាត្រា២៧៧-៧<br>1 កម្មកររ៉ែ មិនត្រូវធ្វើការបំផ្លាញ ឬ ផ្លាស់ប្តូរ នូវ សញ្ញាប្រយ័ត្នដែលបានដាក់ប្រើដើម្បីសុវត្ថិភាព របងហ៊ុំព័ទ្ធបរិក្ខារដើម្បីកុំឲ្យមានការឆ្លងកាត់ ឬ គ្រឿងចក្រទាក់ទងនឹងសុវត្ថិភាព ការខូចនៃបរិក្ខារ និងសំភារៈផ្សេងទៀតៗ ។ |

| | |
|---|---|
| | 2 កម្មកររ៉ែ មិនត្រូវធ្វើការបង្អាក់ដំណើរការដល់បរិក្ខារគាំទ្រអគារចាំបាច់លើផ្នែកសុវត្ថិភាពផ្សេងៗបរិក្ខារចាំបាច់ បរិក្ខារបញ្ចេញទឹកកខ្វក់នៅក្នុងរូងនៃការដ្ឋានរ៉ែលោហៈនិងអលោហៈ ឬ ការបញ្ឈប់ការបរិក្ខារសំរាប់ផ្លាស់ប្តូរខ្យល់នៅក្នុងការដ្ឋានរ៉ែធ្យូងថ្ម។<br>3 អ្នកគ្រប់គ្រងសុវត្ថិភាពការងាររួម ក្រៅពីអ្នកដែលត្រូវបានគេកំណត់ ពីសំណាក់ អ្នកគ្រប់គ្រងសុវត្ថិភាពការងារ និង អ្នកគ្រប់គ្រងការងារ គឺមិនអាចចូលទៅក្នុងតំបន់ដែលមានរបងហ៊ុំព័ទ្ធហាមមិនឲ្យចូល ឬ ទីកន្លែងហាមមិនឲ្យចូលបានទេ។ |

| | |
|---|---|
| **(ការប្រើដីនៅពេលមានអសន្ន**<br>មាត្រា៣២ (សង្ខេប)<br><br>**ជំពូក៣ ស្ថាប័នអធិការកិច្ច**<br>**(រចនាសម្ព័ន្ធអធិការកិច្ច)**<br>មាត្រា៣៣ (សង្ខេប)<br><br>**(មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ**<br>មាត្រា៣៤ (សង្ខេប)<br><br>**(សិទ្ធិអំណាចនៃមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ**<br>មាត្រា៣៥～មាត្រា៣៦ (សង្ខេប)<br><br>**(ការរាយការណ៍ចំពោះស្ថាប័នអធិការកិច្ចតាមរយៈកម្មកររ៉ែ**<br>មាត្រា៣៧ (សង្ខេប)<br><br>**(គណៈកម្មាការសុវត្ថិភាពការដ្ឋានរ៉ែ** | |

| | |
|---|---|
| មាត្រា៣៨～មាត្រា៣៩ (សង្ខេប)<br><br>**(អង្គភាពបណ្តុះបណ្តាលសុវត្ថិភាពការដ្ឋានរ៉ែ)**<br><br>មាត្រា៤០ (សង្ខេប) | |
| សេចក្តីព្រៀងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ | សេចក្តីព្រៀងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ (វគ្គ២) |

# បែបបទនៃ ការវាស់កំហាប់ និងវាយតំលៃ ធូលីនៅការដ្ឋានរ៉ែ

March 1, 2016

# I. ការវាស់កំហាប់ធូលី

## 1. គោលបំណងនៃការវាស់កំហាប់ធូលី

នៅការដ្ឋានរ៉ែ ចំពោះការគ្រប់គ្រងសុខភាពពលកម្មសំរាប់ការពារកម្មកររ៉ែ ពី ឧបសគ្គទាំងឡាយកើតឡើងពីភាពរំញ័រ, សំឡេងថ្លង់ និងសារធាតុពុលដែលបំពុលបរិដ្ឋានការងារ នៅក្នុងបន្ទប់និងនៅក្នុងរូង គឺមានគោលបំណងដូចខាងក្រោម៖

(1) ការគ្រប់គ្រងបរិយាកាសការងារសំរាប់បង្កើតបរិយាកាសការងារដែលកម្មកររ៉ែត្រូវការ ដូចជាទប់ស្កាត់ការកើតឡើងនូវមូលហេតុមានសារធាតុពុល។

(2) ការគ្រប់គ្រងការងារសំរាប់កែលំអ និងយកចេញនូវមូលហេតុនាំអោយមានគ្រោះថ្នាក់ សំរាប់លើកកំពស់សុវត្ថិភាពការងារ។

(3) ការគ្រប់គ្រងសុខភាពសំរាប់រក្សាអោយបាននូវដំណើរការរលូននៃការងារ ក្តាប់បាននូវស្ថានភាពសុខភាពរបស់កម្មកររ៉ែ។

ចំពោះការគ្រប់គ្រងសុខភាពការងារ ក្តាប់អោយបានពិតប្រាកដនូវស្ថានភាពនៃសារធាតុពុលនៅក្នុងទីកន្លែងធ្វើការ ហើយដើម្បីការពារកម្មកររ៉ែដែលជាអ្នកទទួលរងគ្រោះដោយផ្ទាល់ពីសំណាក់ធូលីសារធាតុពុល ដូច្នោះហើយការវាស់គឺជាភាពចាំបាច់សំរាប់ទប់ស្កាត់ការផ្ទុះដោយសារធូលី និងជំងឺផ្លូវដង្ហើម តាមរយៈការស្រូបធូលី។ ដូច្នេះហើយការងារវាស់បរិមាណធូលីគឺជាការងារចំបង។

ក្នុងបទបែបនេះ មានគោលបំណងសំខាន់សំរាប់ទប់ស្កាត់ជំងឺក្រិនសួត ជំងឺផ្លូវដង្ហើម តាមរយៈការស្រូបយកធូលីដោយកម្មកររ៉ែ និងមានរចនាសម្ព័ន្ធដោយមានវិធីវាយតំលៃ និងរៀបចំលទ្ធផលតាមរយៈបានមកពីការវាស់ ការវាស់យកធ្វើជាគំរូ(Simpling) វិធីប្រើប្រាស់និងចំណេះដឹងទាក់ទងនឹងបរិក្ខារវាស់ ការរៀបចំ (design) ផែនការចាំបាច់ សំរាប់អនុវត្តការវាស់ធូលីដែលងាយចូលតាមផ្លូវដង្ហើម។

## 2. ធូលីដែលនឹងត្រូវវាស់

ធូលីដែលនឹងត្រូវវាស់គឺជាធូលីចូលទៅដល់ក្នុងសួតមនុស្សតាមរយៈការដកដង្ហើម ហើយធូលីនោះវានៅស្អិតជាប់នឹងនៅក្នុងប្រព័ន្ធដកដង្ហើមមនុស្ស វាជាប់នៅទីនោះនឹងបង្កើតអោយមានជំងឺសួតដែលបណ្តាលមកពីការដកដង្ហើមចូលដោយធូលីដែលមានគ្រោះថ្នាក់ ហើយពពួកធូលីនោះគេហៅថា 「ធូលីដែលងាយស្រូបចូល」។ ដូច្នេះនៅក្នុងការគ្រប់គ្រងបរិយាកាសការងារចាំបាច់ត្រូវតែវាស់ ធូលីដែលងាយស្រូបចូលនោះ។

ចំពោះ ស្តង់ដាទំហំសំរាប់ការវាស់ធូលីដែលងាយស្រូបចូលនឹងជាធូលីសំរាប់ធ្វើការវាស់កំហាប់របស់វា ហើយនៅឆ្នាំ១៩៩៣ ត្រូវបានគណៈកម្មការស្តង់ដាអឺរ៉ុបបានអនុម័តសំរេចយក (CEN) ដែលនៅក្នុងគណៈកម្មការនោះមានប្រទេសចំនួន១៨ចូលរួម។ ស្តង់ដានៃបរិក្ខារទំហំសំរាប់យកសំណាក Simpling សារធាតុដែលមានចំណែកតូចៗ ត្រូវបានគេកំណត់ 「អត្រាប្រមូលចំណែកតូចៗមាន4 $\mu$ m (micro

meter) នៃបរិក្ខារទំហំដែលមាន៥០ភាគរយ」។ ក្រសួងសុខភិបាលជប៉ុន ក៏បានយកស្តង់ដាទំហំនេះមកប្រើដែរចាប់តាំងពីឆ្នាំ២០០៥មក។

## 3. ការពិនិត្យនិងខ្លឹមសារនៃបរិក្ខារវាស់កំហាប់ធូលី

### （1） បរិក្ខាវាស់កំហាប់នៃបរិមាណ

បរិក្ខាវាស់កំហាប់បរិមាណ បរិក្ខារចាប់យកធូលីមានរចនាសម្ព័ន្ធដោយមានតំរងសំរាប់ចាប់ប្រមូលយកធូលី បរិក្ខារចាប់យកធូលី ប្រើសំរាប់ការវាស់កំហាប់ធូលីហុយនៅក្នុងបរិយាកាសការងារ អត្រាប្រមូលចំណែកតូចៗមាន 4 $\mu$ m(micro meter) នៃបរិក្ខារទំហំដែលមាន៥០ភាគរយ ត្រូវបានគេភ្ជាប់មកជាមួយ។

វិធីនៃចំណែកតូចៗ គឺជាវិធីប្រើសំរាប់អោយម៉ូលេគុលទាំងនោះធ្លាក់ចុះដោយកំឡាំងទំនាញរបស់វា ហើយក៏មានគេប្រើតាមវិធីប្រើនូវទំងន់របស់ម៉ូលេគុលនៃសារធាតុទាំងនោះផងដែរ។ ជាទូទៅគេប្រើបរិក្ខារទំហំដោយប្រើនូវទំងន់របស់កំឡាំងរបស់ម៉ូលេគុលនៃសារធាតុទាំងនោះ។

ធូលីដែលត្រូវបានគេប្រមូលយកតាមរយៈតំរង គឺជាបរិមាណនៃធូលីដែលគេចង់បានតាមរយៈការវាស់នូវទំងន់របស់វា។

### （2） បរិក្ខារវាស់កំហាប់ទាក់ទង(Relative concentration measuring instruments)

កំហាប់ទាក់ទង គឺជាបរិមាណជាក់ស្តែងនៃសារធាតុដែលមានទំនាក់ទំនង១នឹង១ជាមួយនឹងកំហាប់បរិមាណរបស់ធូលី។

បរិក្ខារវាស់កំហាប់ធូលីទាក់ទង មានលក្ខណៈពិសេសដូចខាងក្រោម, ក៏ប៉ុន្តែ ដោយសារវាងាយនឹងរងឥទ្ធិពល តាមរយៈទំហំនៃអង្កត់ផ្ចិត របាយ ទំងន់ អតចរិតពន្លឺរបស់សារធាតុ ស្ថានភាពទ្រង់ទ្រាយរបស់ធូលី។ ដូច្នេះ ត្រូវតែមានការប្រយ័ត្នបំផុតចំពោះប្រើនៃទូរលេខដែលបានមកពីការវាស់។

1） មានសមត្ថភាពវាស់បានក្នុងរយៈពេលខ្លី។
2） ការប្រើប្រាស់មានភាពងាយស្រួល មិនចាំបាច់ត្រូវការហ្វឹកហាត់ក្នុងក្នុងលក្ខណៈទ្រង់ទ្រាយធំទេ។ ក្នុងប្រើប្រាស់មិនមានភាពប្រែប្រួលរវាងអ្នកវាស់នឹងអ្នកវាស់ផ្សេងទៀត។
3） ជាទូទៅអាចចាប់បានល្អ ទោះបីធូលីមានមានកំហាប់តិចក៏ដោយក៏ងាយវាស់បានដែរ។
4） ករណីមានសារធាតុលំអងហុយក្រៅពីធូលីនិងអ័ក្រ។ល។ វានឹងទទួលឥទ្ធិពលផងដែរ។

ចំពោះបរិក្ខារវាស់កំហាប់ទាក់ទង មានវិធីបញ្ចេញពន្លឺ វិធីស្រូបពន្លឺ។ល។

ទ្រឹស្តីគោលចំពោះបរិក្ខារវាស់កំហាប់ទាក់ទង ដែល ប្រើតាមកាំរស្មីជាវិធីបាច់ពន្លឺ ក្នុងករណីអោយធូលីត្រូវនឹងពន្លឺ ប្រើការប្រៀបធៀបនឹងកំហាប់បរិមាណនៃបរិមាណដែលហុយក្នុងពន្លឺ ដោយប្រើកាំរស្មីបែបអេឡិចត្រូនិច ជាវិធីវាស់តាមរយៈការចេញពន្លឺខ្លាំងឬក៏ខ្សោយទៅនឹងកំហាប់បរិមាណនៃធូលីដែលហុយនៅក្នុងខ្យល់។

## ４. តំរងក្រដាស់ប្រើសំរាប់ចាប់យកធូលី (តំរង)

តំរងក្រដាស់ប្រើសំរាប់ចាប់យកធូលី មានលក្ខខណ្ឌភ្ជាប់ដូចខាងក្រោម ជាទូទៅគេប្រើតំរងធ្វើពីអំបោះកញ្ចក់ （glass fiber filter）និង quartz-fiber filters។

1）ចំពោះធូលីដែលមានអង្កត់０．３$\mu$m ចាំបាច់ត្រូវមានអត្រាចាប់បានអោយលើសពី៩៥ភាគរយ។

2）ចំពោះការបាត់បង់សំពាធនៃតំរង នោះល្បឿនខ្យល់ឆ្លងកាត់តំរងមានការកើនឡើង ហើយការបាត់បង់សំពាធដំបូងមានទាប មានចំនួនតិចចំពោះការកើនឡើងនៃការបាត់បង់សំពាធតាមរយៈការកកនៃធូលី។

3）មានភាពងាយស្រួលក្នុងការប្រើប្រាស់ មានភាពខ្លាំងក្នុងការយកសំណាក។

4）មានភាពសើមតិច។

## ５. ការរៀបចំសំរាប់ការវាស់កំហាប់ធូលី

### （1）រូបភាព flow chatនៃការវាស់កំហាប់ធូលី

ការវាស់កំហាប់ធូលីដែលហ៊ុយ ចាំបាច់ត្រូវតែក្តាប់អោយបាននូវស្ថានភាពជាក់ស្តែងនៃកំហាប់ធូលីដែលហ៊ុយនៅទីកន្លែងធ្វើការ រួចយោងតាមរយៈសភាពនោះ ត្រូវចាត់វិធានការមានប្រសិទ្ធភាពផ្សេងៗសំរាប់ទប់ស្កាត់ធូលី។ ការគ្រប់គ្រងបរិយាកាសការងារអោយមានភាពសមរម្យ គឺជាការងារសំខាន់។ ធ្វើការវាស់ផ្គួបចូលគ្នារវាងបរិក្ខារទាំងពីរប្រភេទនៃបរិក្ខាវាស់កំហាប់ធូលីទាក់ទង និង ការវាស់កំហាប់បរិមាណធូលី។

ដើម្បីក្តាប់បាននូវលំនាំនៃការវាស់កំហាប់ធូលី មានបង្ហាញតាមរយៈflow chatដែលមានដូចខាងក្រោម៖




Flowchart of dust concentration measurement

## (2) បរិក្ខារចាំបាច់ក្នុងការងារវាស់កំហាប់ធូលីនិងប្រភេទនៃឧបករណ៍ជាង

1) នាឡិកាវាស់កំហាប់បរិមាណធូលី

2) តំរងក្រដាស់ប្រើសំរាប់ចាប់យកធូលី (តំរង)

3) នាឡិកាវាស់ធូលីនៃកំហាប់ទាក់ទង

4) ថង់ផ្លាស្ទីកសំរាប់ច្រកសំណាក សំរាប់ការវិភាគអ ត្រាfree silicic acid

5) នាឡិកាវាស់ល្បឿនខ្យល់

6) នាឡិកាវាស់កំដៅ

7) នាឡិកាវាស់សំនើម

8) ម៉ែត្រមូល (មានប្រវែង៥ម៉ែត្រ ឬ លើសពី៥ម៉ែត្រដែលអាចវាស់របស់បាន)

9) ដីស

10) A stopwatch or watch

11) ប៊ិចសរសេ, ក្រដាស់សំរាប់ធ្វើការកត់ត្រា

１２）ឧបករណ៍ជាង　(ទូរវីស, ដង្កាប់, ខ្សែចរន្ត។ល។)

## ６. ការតំឡើងបរិក្ខារសំរាប់វាស់ (design)

ក្នុងការអនុវត្តការវាស់កំហាប់ធូលី ក្នុងគោលបំណងវាយតំលៃអោយបានត្រឹមត្រូវនូវបរិយាកាសការងារតាមរយៈការវាស់ វាចាំបាច់ត្រូវការតំឡើងអោយបានត្រឹមត្រូវនូវការងារសំរាប់វាស់។

### (1) ជ្រើសរើស ទីកន្លែងការងារជាឯកតា និង ទំហំសំ

ស្តីពីបរិយាកាសការងារដែលជាគោលដៅនៃការវាស់ ចាំបាច់ត្រូវតែជ្រើសរើសទីកន្លែងការងារជាឯកតានៅក្នុងទំហំនៃ「តំបន់ដែលជាគោលដៅនៃការគ្រប់គ្រង」។ ក៏ប៉ុន្តែ ចំពោះទីកន្លែងការងារជាឯកតា ត្រូវជាទីកន្លែងនៃទីតាំងដែលកម្មករកំពុងតែមានសកម្មភាពធ្វើការងារ និងជាតំបន់ចាំបាច់សំរាប់វាស់កំហាប់នានាដែលត្រូវបានកំណត់ ដោយអនុលោមតាមនូវស្ថានភាពរាយប៉ាយនៃធូលី។ល។

ចំពោះការជ្រើសរើសទំហំនៃទីកន្លែងការងារជាឯកតា ចាំបាច់ត្រូវតែមានការប្រយ័ត្នចំពោះចំនុចដែលមានដូចខាងក្រោម។

１）ខ្លឹមសារការងារនិងតំបន់ការងារ

ករណីនៅក្នុងតំបន់ដូចគ្នាក៏ដោយ ក្នុងករណីអាចធ្វើការព្យាករណ៍ចំពោះការប្រែប្រួលជាខ្លាំងរបស់ធូលី ដោយសារយោងតាមតាមសភាពនៃលំនាំការងារ និងម៉ោងពេលនៃការងារ ធ្វើការដកដកចេញចំពោះគោលដៅដែលបានកំណត់ថាជាទីកន្លែងការងារជាឯកតា ហើយជ្រើសរើសយកទីកន្លែងការងារជាឯកតាផ្សេងទៀត។

２）ស្ថានភាពធ្វើការងាររបស់កម្មករនៅទីកន្លែងការងារជាឯកតា

មានប្រភពនៃការកើតឡើងនូវធូលីច្បាស់លាស់ ករណីត្រូវបានអនុវត្តការងារទាំងនោះ នៅក្នុងតំបន់នោះ ជ្រើសរើសទីកន្លែងការងារជាឯកតា ដោយយោងតាម ទំហំនៃការងារជាធម្មតានិងទំហំនៃការសាយភាយនៃធូលីដែលកើតចេញពីប្រភពនោះ។

３）ស្ថានភាពសាយភាយហើរចេញនៃធូលីមកពីប្រភពនៃការកើតធូលី

តាមរយៈសភាពនៃការសាយភាយទៅក្នុងបរិស្ថាន និងទីតាំងនៃប្រភពកើតនូវធូលី ក្នុងករណីត្រូវបានព្យាករណ៍នូវកំរិតខ្ពស់ឬទាបដោយប្រៀបធៀបនឹងទីកន្លែងការងារផ្សេងទៀត ទីកន្លែងជាគោលដៅទាំងនោះត្រូវតែដកចេញ ហើយជ្រើសរើសយកទីកន្លែងការងារជាឯកតាផ្សេងទៀត។

４）ផ្សេងៗ

① ទីកន្លែងការងារជាឯកតា ក្នុងទំហំដែលអាចវាស់បាននៅក្នុងរយៈពេលក្នុង១ថ្ងៃនៃថ្ងៃការងារនូវចំនុចដែលបានតំឡើងនៅទីនោះ (នៅក្នុងរូងសំរាប់ធ្វើការងារ ក្នុងមួយទិសដៅនៃការអនុវត្តការងារគឺ៨ម៉ោង) បើក្នុងករណីមិនអាចវាស់បានគ្រប់ចំនុចដែលតំឡើងសំរាប់ការវាស់នៃ១ថ្ងៃការងារទេ　ចាំបាច់ត្រូវតែបំបែកនូវទីកន្លែងការងារជាឯកតា។

② នៅពេលទទួលបានទិន្នន័យនៅទីកន្លែងការងារជាឯកតាដែលបានតំឡើងកាលពីដំបូងក្រោយមកទៀត　ទិន្នន័យនោះនឹងមានការកត់ត្រាកើនឡើង ហើយក្នុងករណីលទ្ធផលនៃការវាស់មិន

បានដូចគ្នាជាមួយនឹងទិន្នន័យដែលបានពីមុនទេ ធ្វើការផ្លាស់ប្តូរទំហំនៃទីកន្លែងការងារជា ឯកតានោះ និងផ្លាស់ប្តូរចំនុចនៃការវាស់។

③ ក្នុងករណីទីកន្លែងដែលជាធម្មតាមិនមានកម្មកររ៉ែចូល ឬកន្លែងដែលបានតំឡើងរបងហាមចូល និង ជាទីកន្លែងដែលកម្មកររ៉ែម្នាក់ចូលបានតែត្រឹមតែ៣០នាទីនៃម៉ោងធ្វើការងារ៨ម៉ោង គឺមិនអាចកំណត់ថាជាទីកន្លែងការងារជាឯកតាបានទេ។

## （2） ការកំណត់នៃទីកន្លែងការងារជាឯកតា

ចំពោះ 「ទីកន្លែងធ្វើការងារនៅក្នុងបន្ទប់និងទីកន្លែងធ្វើការងារនៅក្នុងរូងដែលមានហ៊ុយធូលីគួរអោយកត់សំគាល់」 ដែលបានកំណត់នៅក្នុងមាត្រាទី២៣៩-១ និងមាត្រា២៦៨-១ នៃបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ គឺជាទីកន្លែងអនុវត្តការងារ ដែលនឹងមានលើកឡើងដូចខាងក្រោម៖

1) ការងារខួងតាមរយៈម៉ាស៊ីនខួងផ្ទាំងថ្មនិងប្រភេទរ៉ែផ្សេងៗ （លើកលែងពពួកម៉ាស៊ីនប្រើទឹក)
2) ការងារខួងតាមរយៈម៉ាស៊ីនខួងផ្ទាំងថ្ម ឬលោហៈនៅក្នុងរូង （លើកលែងពពួកម៉ាស៊ីនប្រើកំឡាំងទឹក)
3) ការងារដឹករ៉ែឬថ្មដែលចាក់នៅទីកន្លែងផ្ទុកដោយប្រើtipples។
4) ការងារលើកដាក់រ៉ែឬថ្ម តាមរយៈគ្រឿងចក្រជាប្រភេទយាន្តនៅការដ្ឋានរ៉ែ នៅក្នុងរូង។
5) ការងារដឹកជញ្ជូនរ៉ែឬថ្ម តាមរយៈខ្សែពានដឹកជញ្ជូន នៅក្នុងរូង។
6) ការងារលុបបន្ថែមនៅក្នុងរូងឬផ្លូវនៅក្នុងរូង។ល។ （លើកលែងការងារលុបបន្ថែមតាមរយៈកំឡាំងដៃ និងការងារលុបបន្ថែមតាមរយៈការបង្ហូរដោយកំឡាំងទឹក។ ）
7) ការងារដែលធ្វើអោយសាយភាយធូលីថ្មនៅក្នុងរូង ។
8) ការងាររ៉ែងបែងចែក ឬ កិនបំបែកតាមរយៈកំឡាំងម៉ូទ័រ ចំពោះថ្មរ៉ែឬថ្មនៅក្នុងបន្ទប់ឬនៅក្នុងរូង (លើកលែងការងាររ៉ែងបែងចែក ឬ កិនបំបែកតាមរយៈកំឡាំងម៉ូទ័របណ្តើរមានបរិក្ខារបាចទឹកបណ្តើរ ។)
9) ការងារបង្ហើយឬកាត់ថ្មរ៉ែឬថ្ម តាមរយៈម៉ូទ័រនៅក្នុងបន្ទប់ឬនៅក្នុងរូង （លើកលែងការងារបង្ហើយឬការកាត់តាមរយៈការប្រើម៉ូទ័រដោយបញ្ចូលប្រេងបណ្តើរឬការបញ្ចូលទឹកបណ្តើរ ឬការកាត់ដោយប្រើអណ្តាតភ្លើងឬសំពាធទឹក។)
10) ការងារកាត់លោហៈឬឆាប ឬប៉ូលាលោហៈ ថ្មតាមរយៈសារធាតុប៉ូលានៅក្នុងបន្ទប់ឬនៅក្នុងរូងក្រោមដី （លើកលែងការងារកាត់លោហៈឬឆាប ឬប៉ូលាលោហៈ ឬថ្មរ៉ែ ឬថ្ម តាមរយៈម៉ូទ័រដែលប្រើសារធាតុប៉ូលាបណ្តើរដែលមានបរិក្ខារបញ្ចូលប្រេងបណ្តើរ ឬបញ្ចូលទឹក។)
11) ការងារចាក់លាយឬកូរច្របល់ម្សៅរ៉ែ។ល។នៅក្នុងបន្ទប់ឬនៅក្នុងរូងក្រោមដី។
12) ការងាររំលាយ ឬ យកចេញ ឬដុតរំលាយ ឬបោះបញ្ចូលទៅក្នុងឡចំហានូវថ្មរ៉ែ ឬថ្មដីនៅក្នុងដំណាក់កាលចំរាញ់ （រួមទាំងដំណាក់កាលដុតថ្មកំបោរ) (លើកលែងការងាររំលាយចាក់ជាពុម្ពឬការបញ្ចេញពីឡវិល។)
13) ការងារដាក់ចូល ឬទុកដាក់ ឬ ការប្រមូល ផេះដែលជ្រុះ ឬអាចរ៉ែដែលបានគរទុក ឬ ម្រែងភ្លើង

ដែលជាប់ ផ្លូវផ្សែង ឡ នៅក្នុងដំណាក់កាលចំរាញ់។

14) ការងារបំបែក ឬរំលាយឡដែលបានប្រើរបស់ធន់នឹងភ្លើង ឬការជួសជុល ឬការតំឡើងឡដែលប្រើសារធាតុធន់នឹងភ្លើង។

15) ការងារផ្សាប្រើដែផ្សា ឬ ការផ្សាផ្តាច់លោហៈ នៅក្នុងផ្ទៃកនៃរថយន្តឬនៅក្នុងរូងក្រោមដី។ល។ (លើកលែងការងារផ្សាដោយស្វ័យប្រវត្តិ ឬផ្សាផ្តាច់ដោយស្វ័យប្រវត្តិនៅក្នុងបន្ទប់។)

16) ការងារទុកដាក់ ដាក:បញ្ចូល វេចខ្ចប់ សំងួតកំទេចផេះ និងផលិតជាម្សៅ ឬម្សៅរ៉ែ (លើកលែងរបស់សើម។)

## (3) ការតំឡើងចំនុចសំរាប់វាស់

ដើម្បីវាយតំលៃអោយបានត្រឹមត្រូវពីការឥទ្ធិពលរបស់ធូលីដល់កម្មកររ៉ែ ចាំបាច់ត្រូវតែក្តាប់អោយបានត្រឹមត្រូវនូវបរិមាណនៃធូលីដែលកម្មករស្រូបចូល។ ក៏ប៉ុន្តែ ជាក់ស្តែងវាមានការលំបាក ចំពោះការវាស់ពីបរិមាណធូលីដែលកម្មករទាំងនោះស្រូប។

ដូច្នេះហើយ ជាទូទៅបានជាធ្វើការកំណត់នូវទីកន្លែងការងារជា ឯកតា ក្នុងគោលបំណងគ្រប់គ្រងដែលនៅក្នុងនោះមានការជ្រើសរើសដោយមិនបានកំណត់ទុកជាមុន ប៉ុន្មានកន្លែងយកធ្វើជាចំនុចវាស់សំរាប់អនុវត្តការវាស់កំហាប់ធូលី។ (ការវាស់នេះ「ហៅថាការវាស់បែបA」) លើសពីនេះ ស្តីពីទីកន្លែងធ្វើការងារដែលអាចនឹងមានគ្រោះថ្នាក់ ដោយសារតែពុំមានការគ្រប់គ្រងអោយបានត្រឹមត្រូវដោយសារតែប្រើការវាស់បែបAតែមួយ។ ដើម្បីជួយដល់ការវាស់បែបA ទីកន្លែងអាចគិតថាវានឹងទទួលឥទ្ធិពលរបស់ធូលីហ៊ុតខ្លាំង ដោយមិនទាក់ទងនឹងចំនុចវាស់នៅក្នុងទីកន្លែងការងារជា ឯកតា ធ្វើការវាស់កំហាប់ជាមធ្យមចំនួន១០នាទី នៅក្នុងម៉ោងពេលនោះ (ការវាស់នេះ「ហៅថាការវាស់បែបB」) ធ្វើការវាយតំលៃនូវលទ្ធផលនៃការវាស់តាមរយៈការវាស់បែបB។

ក្នុងការវាស់នៃកំហាប់ធូលី ចាំបាច់អ្នកទទួលបន្ទុកមានចំណេះដឹងនិងមានសមត្ថភាពយល់ច្បាស់ពីស្ថានភាពនៃទីកន្លែងធ្វើការដែលជាកន្លែងវាស់និងគោលបំណងនៃការវាស់ ព្រមទាំងចេះតំឡើងទីតាំងនៃចំនុចវាស់ដោយអនុលោមតាមការគិតនៃការតំឡើង និងការយកសំណាក។

## (4) ការតំឡើងនៃចំនុចវាស់នៅក្នុងបរិយាកាសការងារនៅក្នុងបន្ទប់

ស្តីពីទីកន្លែងការងារជាឯកតានៅក្នុងបន្ទប់ ប្រុងប្រយ័ត្នចំពោះចំនុចដែលមានដូចខាងក្រោមបណ្តើរកំណត់តំឡើងចំនុចវាស់ដោយគ្មានធ្វើការព្រៀងទុកជាមុនបណ្តើរ។

1) ចំនួននៃចំនុចវាស់, ដើម្បីដឹងពីភាពរាយប៉ាយនៃកំហាប់ធូលី នៅទីកន្លែងការងារជាឯកតា ចាំបាច់ត្រូវតែមានចំនុចវាស់អោយបានលើសពី៥។

2) ចំនុចវាស់, គឺជាចំនុចប្រសព្វរវាងខ្សែបញ្ឈរនឹងខ្សែផ្តេកដែលមានគំលាតគ្នា៣ម៉ែត្រនៅលើផ្ទៃនៃទីកន្លែងការងារជាឯកតា (រូបទី១) ។ ក៏ប៉ុន្តែ ក្នុងករណីមានការសំរបសំរួលរវាងគំលាតខ្សែបញ្ឈរនឹងខ្សែផ្តេក ស្តីពីគំលាតនៃចំនុចវាស់នៃចំនុចប្រសព្វនៃខ្សែផ្តេកឬខ្សែបញ្ឈរ គឺចាំបាច់ត្រូវតែមានគំ

លាតឃ្លាតគ្នាស្មើ។

3) ទីកន្លែងការងារជាឯកតាដែលក្នុងករណីមិនអាចបែងចែកជាខ្សែត្រង់បាន ខ្សែស្របអាចយកតាមទ្រង់ទ្រាយនោះដោយជាខ្សែកោងបាន (រូបទី២) ។

4) ផ្ទៃក្រឡាដែលអាចតំណាងនៅចំនុចវាស់១ គឺមានប្រមាណ១០ ㎡។

5) ករណីទីកន្លែងការងារជាឯកតាព័ទ្ធដោយទំហំចង្អៀត ឬ មួយមានករណីកំណត់ទំហំ ក្នុងនាមជាទីកន្លែងការងារជាឯកតា ដោយសារតែវាមានភាពខុសគ្នាស្រឡាស់នឹងខ្លឹមសារការងារនៃការបញ្ចេញធូលី។ ក្នុងករណីបែបនេះ ដោយសារចំនួននៃចំនុចវាស់វានឹងមានក្រោម៥ចំនុច ចាំបាច់ត្រូវតែបង្រួមខ្សែបញ្ឈរនិងខ្សែផ្ដេក ធ្វើយ៉ាងណាអោយបានលើសពីចំនុចវាស់មានលើសពី៥ចំនុច (រូបទី៣) ។

6) ទីកន្លែងការងារជាឯកតាដែលបានលើកឡើងនូវចំនុច5) ហើយវាមានករណីរឹតតែពិបាកមិនអាចរក្សាបាននូវចំនុចវាស់បាន៥ចំនុច ចាំបាច់ត្រូវតែកំណត់ដោយខ្លួន ឯងយកចំនុចណាមួយសំរាប់វាស់អោយបានលើសពី៥ដង។




(ករណីទីកន្លែងការងារជាឯកតា) (ប្រយ័ត្ន) ○តំណាំងអោយចំនុចវាស់ (ករណីមានបរិក្ខារ)

(រូបភាព១ : វិធីកំណត់នៃចំនុចវាស់នៅទីកន្លែងការងារជាឯកតានៅក្នុងបន្ទប់)




(រូបភាព-២ : វិធីកំណត់នៃចំនុចវាស់ក្នុងករណីមានផ្នែកខ្សែកោងចំពោះទីកន្លែងការងារជាឯកតា)



(រូបភាព-៣ : វិធីតំឡើងនៃចំនុចវាស់ក្នុងករណីមានភាពចង្អៀត នៅទីកន្លែងការងារជាឯកតា)

### (5) ការកំណត់ចំនុចវាស់នៅក្នុងបរិយាកាសការងារនៅក្នុងរូង

ស្តីពីទីកន្លែងការងារជាឯកតានៅក្នុងរូង ធ្វើប្រយ័ត្នចំពោះចំនុចដែលមានដូចខាងក្រោមបណ្តើរ កំណត់ចំនុចវាស់ដោយគ្មានការព្រៀងទុកជាមុនបណ្តើរ។

1) ករណីទទឹងផ្លូវរូងមានទំហំលើសពី 2 m ចំនុចវាស់ត្រូវមានលើសពី២ជួរ, ករណីទទឹងផ្លូវមានទំហំតិចជាង 2 m ចំនុចវាស់ត្រូវមាន១ជួរ (រូបភាពទី៤) ។ ក៏ប៉ុន្តែ ប្រយ័ត្នចំពោះភាពហ៊ុយនៃធូលី មិនចាំបាច់មាន២ជួរក៏មិនអីដែរ។

2) ក្នុងករណីមានគំលាត៣ម៉ែត្រពីចំនុចវាស់នៃផ្នែកខាងបន្តនៃផ្លូវនៅក្នុងរូង គំលាតនេះត្រូវតែបែងចែកអោយស្មើៗគ្នា។

3) ចំនួននៃចំនុចវាស់ ត្រូវមានលើសពី៥ចំនុច ចំពោះក្នុងទីកន្លែងការងារជា១ឯកតា។ ក៏ប៉ុន្តែ ចំពោះចំនួនអតិបរិមា គួរតែធ្វើអោយបាន១០ចំនុច។

4) ទីកន្លែងការងារជាឯកតា នៅពេលមិនអាចបែងចែកខ្សែត្រង់បាន ខ្សែស្របអាចតំឡើងតាមបែបជាខ្សែកោងតាមរាងទាំងនោះបាន (រូបភាព-២) ។

5) ផ្ទៃក្រឡាដែលតំណាងអោយ១ចំនុចនៃការវាស់ មានប្រមាណ１０$m^2$។

6) ករណីទីកន្លែងការងារជាឯកតាព័ទ្ធដោយទំហំចង្អៀត ឬមួយមានករណីកំណត់ទំហំក្នុងនាមជាទីកន្លែងការងារជាឯកតា សំរាប់ការខុសគ្នាស្រឡាស់នឹងខ្លឹមសារការងារនៃការបញ្ចេញធូលី។ ក្នុងករណីបែបនេះ ដោយសារចំនួននៃចំនុចវាស់វានឹងមានក្រោម៥ចំនុច ចាំបាច់ត្រូវតែបង្រួមខ្សែបញ្ឈរនិងខ្សែផ្ដេក ធ្វើយ៉ាងណាអោយបានលើសពីចំនុចវាស់មានលើសពី៥ចំនុច (រូបភាព-៣) ។

7) ទីកន្លែងធ្វើការងារជាឯកតាដែលបានលើកឡើងនូវចំនុច6) ហើយវាមានករណីរឹតតែចង្អៀតពិបាកមិនអាចយកបាននូវចំនុចវាស់អោយបាន៥ចំនុច ចាំបាច់ត្រូវតែកំណត់ដោយខ្លួនឯងយកចំនុចណាមួយសំរាប់វាស់អោយបានលើសពី៥ដង។




(រូបភាពទី៤ : វិធីតំឡើងចំនុចវាស់នៅទីកន្លែងធ្វើការងារជាឯកតានៃផ្លូវរូងខួងទៅមុខ)

（6）ចំនុចត្រូវប្រយ័ត្នទាក់ទងនឹងការតំឡើងការវាស់ (Design)

តាមរយៈលទ្ធផលនៃការវាស់បរិយាកាសការងារ បើវាមិនបានលទ្ធផលច្បាស់លាស់ដូចខាងក្រោមទេ នោះមិនអាចប្រើសំរាប់ធ្វើការវាយតំលៃបរិស្ថានការងារបានទេ ដូច្នេះចាំបាច់ត្រូវតែធ្វើការតឡើងការវាស់Design) ដោយប្រុងប្រយ័ត្ន។

① គោលបំណងនៃការវាស់ត្រូវបានសំរេច។

② អាចព្យាករណ៍នូវភាពមានឬមិនមាននៃភាពហ៊ុយឡើងនូវកំហាប់ខ្ពស់ក្នុងរយៈពេលណាមួយ។

③ ទូរលេខនៃការវាស់ គឺជាទូរលេខតំណាងអោយកន្លែងដែលត្រូវបានតំឡើង។

លើសពីនេះ, ក្នុងពេលធ្វើការតំឡើងការវាស់ (Design) ចាំបាច់ត្រូវតែប្រយ័ត្ននូវចំនុចដែលមានដូចខាងក្រោម៖

1) ទោះបីនៅក្នុងតំបន់តែដូចគ្នាក៏ដោយ នៅពេលអាចព្យាករណ៍តាមរយៈពេលវាលាមួយ ស្តីពីការកើនឡើងឬថយចុះនៃកំហាប់ធូលីតាមរយៈដំណើរការនៃដំណាក់កាលការងារ ធ្វើការរៀបចំទិន្នន័យក្នុងនាមជាទីកន្លែងការងារជាឯកតាខុសគ្នា។

2) ប្រៀបធៀបនូវស្ថានភាពនៃទីកន្លែងការងារនឹងលទ្ធផលនៃការវាស់ នៅពេលទទួលស្គាល់ថាមានហេតុផលច្បាស់ចំពោះការប្រែប្រួលនៃកំហាប់ ធ្វើការមើលឡើងវិញនូវការតំឡើងទីកន្លែងការងារជាឯកតាម្តងទៀត។

3) រប៉ាយនៃកំហាប់ធូលី មានការជះឥទ្ធិពលដ៏ខ្លាំងចំពោះចរន្តខ្យល់នៃទីកន្លែងធ្វើការ នៅពេលកំណត់ទីកន្លែងការងារជាឯកតា ចាំបាច់ត្រូវតែប្រយ័ត្ននូវការជះ ឥទ្ធិពលនៃចរន្តខ្យល់នៅក្នុងទីកន្លែងធ្វើការងារ។

## (7) របៀបតំឡើងបរិក្ខារវាស់

នៅពេលទៅដល់ទីកន្លែង បរិក្ខារវាស់ទាំងឡាយត្រូវបានតំឡើង ក៏ប៉ុន្តែ មុនការងារនេះ អ្នកទទួលបន្ទុកការវាស់ ចាំបាច់ត្រូវតែយល់ជ្រាបច្បាស់លាស់ជាមុនសិនពីស្ថានភាពបរិស្ថាននៃការងារ។

① វិធីតំឡើងបរិក្ខារវាស់កំហាប់បរិមាណធូលី

i) អ្វីដែលត្រូវតែប្រយ័ត្នខ្លាំងរហូតដល់ពេលតំឡើងបរិក្ខារវាស់នៅទីកន្លែង គឺបរិក្ខារវាស់កំហាប់បរិមាណធូលី។ បរិក្ខារវាស់កំហាប់បរិមាណធូលី ត្រូវតំឡើងនៅទីកន្លែងដែលអាចប្រមូលបាននូវទូរលេខជាមធ្យម ដោយអាចវិភាគបានជាទូទៅពីស្ថានភាពនៃចរន្តធូលី និងការងារដែលបង្កើតធូលី ព្រមទាំងទីកន្លែងនៃចំនុចចវាស់ទាំងអស់នោះ និងទីកន្លែងធ្វើការងារជាឯកតា។

ii) ករណីរកមូលហេតុមិនឃើញស្តីពីស្ថានភាពនៃចរន្តធូលី ចាំបាច់ត្រូវតែតំឡើងវានៅចំចំនុចកណ្តាលនៃចំនុចវាស់ទាំងអស់។ លើសពីនេះ ចំពោះចំនុចកណ្តាលនេះ បើមិនអាចកំណត់បានទេ គួរតែតំឡើងនៅក្បែចំនុចកណ្តាលដែលយើងប្រុងនឹងដាក់នោះ។

iii) បើបានកំណត់ចំនុចតំឡើងរួច ត្រូវតំឡើងទីតាំងនៃច្រកយកខ្យល់របស់បរិក្ខារតាមរយៈជើងទ្របីដែលមានកំពស់ត្រូវបានកំណត់តាមការណែនាំ និងអោយស្របតាម។ បន្ទះចាប់យកធ្វើក៏តំឡើងដាក់អោយស្របដែរ ចំពោះកំពស់វា ត្រូវដាក់អោយបានចាប់ពីកំពស់០,៥ទៅ១,៥ម៉ែត្រពីផ្ទៃបាត ដើម្បីកុំអោយវាហ៊ុយឡើងវិញ។ ម៉ូទ័របឺតចូល និងនាឡិកាវាស់បរិមាណចរន្តខ្យល់ ត្រូវតភ្ជាប់គ្នាដោយកុំអោយមានការលេចខ្យល់ចេញបាន។

iv) នៅពេលធ្វើការវាស់បរិស្ថានការងារនៅក្នុងរូង ច្រកយកខ្យល់របស់បរិក្ខាវាស់បរិមាណកំហាប់ធូលី ត្រូវដាក់ទៅរកទិសដៅចរន្តខ្យល់រត់មក។

v) នៅពេលធ្វើការវាស់បរិស្ថានការងារនៅក្នុងបន្ទប់នៃការដ្ឋានរ៉ែនៅលើដី ស្តីពីទិសដៅនៃច្រក

យកខ្យល់នៃបរិក្ខារវាស់បរិមាណកំហាប់ធូលី មិនមានការកំណត់ទេ។ ក៏ប៉ុន្តែត្រូវប្រយ័ត្នកុំអោយវាទទួលនូវឥទ្ធិពលពីទីកន្លែងណាដែលមានចរន្តខ្យល់ទូទៅ។

② វិធីតំឡើងនៅពេលវាស់ផ្តួបចូលគ្នារវាងបរិក្ខាវាស់ធូលីនៃកំហាប់ទំនាក់ទំនងនឹងបរិក្ខាវាស់បរិមាណកំហាប់ធូលី

ករណីអនុវត្តវាស់ផ្តួបចូលគ្នារវាងបរិក្ខារវាស់ធូលីនៃកំហាប់ទាក់ទងនឹងបរិក្ខាវាស់បរិមាណកំហាប់ធូលី ច្រកចាប់ខ្យល់នៃបរិក្ខារទាំងសងខាង ត្រូវដាក់តាមទិសដៅដូចគ្នា និងតំឡើងបរិក្ខារទាំងពីរនោះ ក្នុងគំលាតមួយ ដោយប្រយ័ត្នពីភាពប្រែប្រួលនៃកំហាប់នៅក្នុងខ្យល់ និងបើអាចធ្វើបានសូមតំឡើងនៅក្បែរគ្នា។

③ វិធីតំឡើងបរិក្ខាវាស់ធូលីនៃកំហាប់ប្រៀបធៀបទំនាក់ទំនងនៅពេលធ្វើការបំលាស់ទី

ករណីមានបរិក្ខាវាស់ធូលីនៃកំហាប់ប្រៀបធៀបទំនាក់ទំនងជារបស់យួរដៃបានបរិក្ខារវាស់ត្រូវស្ពាយនៅខ្នង និងដៃរបស់វាត្រូវព្យួរនឹងក ហើយត្រូវដាក់វានៅខាងមុខអ្នកដែលត្រូវធ្វើការវាស់បណ្តើរ ច្រកចាប់យកខ្យល់ត្រូវមានទិសដៅដូចបរិក្ខារវាស់បរិមាណកំហាប់ធូលី សំរាប់ធ្វើការវាស់។

## 7. វិធីវាស់ (Sampling)

ដើម្បីវាយតំលៃបរិស្ថានការងារនៃចំនុចដែលត្រូវវាស់ ដោយអនុលោមតាមលទ្ធផលការវាស់បរិស្ថានការងារ ការវាស់ត្រូវបានគេកំណត់មានពីរប្រភេទគឺការវាស់បែបAនិងB។

（1）វាស់បែបA

វាស់បែបA គឺការវាស់សំរាប់ក្តាប់ពីស្ថានភាពជាមធ្យមនៃកំហាប់ធូលីនៅទីកន្លែងធ្វើការងារ គឺការវាស់ដែលមិនអាចវាស់ពីកំហាប់ធូលីហ៊ុំឡើងខ្លាំងជាមធ្យមដោយផ្តោតទៅលើម៉ោងពេលនៃកម្មកររ៉ែបានទេ។

លក្ខណ្ឌនៃការវាស់បែបA មាន៣គោលការណ៍ដែលត្រូវតែគោរពដូចខាងក្រោម៖

① ម៉ោងសំរាប់ការវាស់ គឺត្រូវអោយបានលើសពី៦០នាទី។

② រយៈពេលវាស់នៃចំនុចវាស់នីមួយៗ គឺត្រូវមានរយៈពេលស្មើរៗគ្នា។

③ គំលាតរវាងចំនុចវាស់នឹងចំនុចវាស់ ត្រូវតំឡើងក្នុងគំលាតមានប្រវែងដូចៗគ្នា។

វិធីវាស់បែបមូលដ្ឋានគ្រឹះតាមរយៈការវាស់បែបA គឺជាវិធីវាស់២គ្រឿង ដែលក្នុងនោះប្រើបរិក្ខាវាស់បរិមាណកំហាប់ធូលី១គ្រឿងនិងបរិក្ខាវាស់ធូលីទំនាក់ទំនង២គ្រឿង។ បរិក្ខាវាស់បរិមាណកំហាប់ធូលី១គ្រឿង និងបរិក្ខាវាស់ធូលីនៃកំហាប់ទំនាក់ទំនង១គ្រឿង (No. 1) ប្រើវាស់រួមគ្នានៅពេលស្របគ្នា ក្នុងគោលបំណងរកចំនួនលេខមេគុណប្រែប្រួលកំហាប់បរិមាណនៃទីកន្លែងការងារជាឯកតា (ខាងក្រោមកទៀតហៅកាត់ថា「លេខK」)។ នៅសល់១គ្រឿងទៀត គឺបរិក្ខាវាស់ធូលីនៃកំហាប់ទំនាក់ទំនង (No. 2) ប្រើសំរាប់វាស់នៅតាមចំនុចវាស់នីមួយៗ ក្នុងពេលវេលាស្មើរៗគ្នា សំរាប់រកវេខាគណិត (geometric mean value)។

ខ្លឹមសារនៃវិធីវាស់បែបមូលដ្ឋាគ្រឹះ មានដូចក្នុងរូបភាព-៥។ ក៏ប៉ុន្តែ n ជាចំនួននៃចំនុចវាស់មានចាប់តាំងពី ①、②、③រហូតដល់~ⓝ។ លើសពីនេះ, យោងតាម ( t /n ) កំណត់បែងចែកម៉ោងល្អ នៅចំពោះចំនុចវាស់នីមួយៗដែលមានពេលស្មើរៗ វាស់កំហាប់ទំនាក់ទំនងរយៈពេលក្នុង១នាទី។ ក្នុងករណីបែបនេះ ( t ) តំណាងអោយម៉ោងវាស់ និងចាំបាច់អោយវាមានលើសពី៦០នាទី។




(រូបភាព៥ : វិធីវាស់បែបមូលដ្ឋានគ្រឹះ តាមរយៈការវាស់បែបA)

(2) វាស់បែបB

ការវាស់បែបB គឺជាការវាស់ជំនួយបន្ថែមដល់ការវាស់បែបA ក្នុងករណីសន្និដ្ឋានថាការវាស់តាមបែបAតែមួយអាចនឹងធ្វើអោយការវាស់នោះមិនគ្រប់គ្រាន់ដែលបណ្តាលអោយមានគ្រោះថ្នាក់តាមរយៈការវាស់មិនបាននូវកំហាប់ធូលីហ៊ុយនោះ។

ដូច្នេះហើយ ត្រូវដាក់ទីតាំងការងារដែលនៅក្បែរប្រភពកើតធូលី ធ្វើការវាស់ដោយតំឡើងចំនុចវាស់ដែលអាចដឹងបាននូវកំហាប់ខ្ពស់នៃធូលី។ រយៈពេលវាស់នៃការវាស់បែបBនេះ មានរយៈពេល ១០នាទី ចាំបាច់ត្រូវប្រយ័ត្នចំពោះការដែលមិនអាចវាស់កំហាប់ហ៊ុយខ្លាំងបានទេ។

ក្នុងការវាស់បែបB ចាំបាច់ត្រូវតែប្រយ័ត្ននូវចំនុចដែលមានដូចខាងក្រោម៖

1) ការវាស់បែបB ចាំបាច់ត្រូវគិតពីដំណាក់កាលផលិតនៅក្នុងទីកន្លែងការងារជាឯកតា អនុវត្តការវាស់បែបA សន្និដ្ឋានពីស្ថានភាពហ៊ុយនៃធូលី និងបែបបទការងារ។ល។ អនុវត្តការវាស់អោយបានខ្ពស់នូវបរិមាណនៃកំហាប់ ដោយជ្រើសរើសទីកន្លែងនិងពេលវាលា សំរាប់ការវាស់ធូលីនោះ។
2) កំហាប់ធូលីខ្ពស់ដែលអាចគិតថាជាការងារធំនិងដ៏សំខាន់ ក្នុងករណីមិនអាចវាស់តាមបែបការវាស់Aបាន នៅក្នុងពេលវេលាកំពុងអនុវត្តនោះ ការវាស់បែបB ត្រូវអនុវត្តនៅម៉ោងពេលផ្សេងទៀតនឹងម៉ោងអនុវត្តបែបA ការងារនោះត្រូវអនុវត្តនៅក្នុងម៉ោងបែបនេះ។
3) ម៉ោងពេល Sampling នៃការវាស់បែបBត្រូវមានរយៈពេល១០នាទី។

4) វិធីSampling នៃការវាស់បែបB វិធីវិភាគ ប្រើដូចវិធីវាស់បែបAដែរ។

5) ក្នុងករណីប្រើបរិក្ខារវាស់កំហាប់ធូលីទាក់ទងចំពោះការវាស់បែបB ត្រូវតែអោយបរិក្ខារវាស់ដំណើរការ១០នាទីជាប់ៗគ្នា។

6) ក្នុងករណីវាស់បែបBដោយប្រើតែបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប ចំពោះមេគុណផ្លាស់ប្តូរកំហាប់បរិមាណ ប្រើមេគុណផ្លាស់ប្តូរកំហាប់បរិមាណនៃការវាស់បែបA ដែលបានអនុវត្តនៅទីកន្លែងការងារជាឯកតា។

**（3） ចំនុចប្រយ័ត្ននៅពេលវាស់កំហាប់ធូលី**

នៅពេលវាស់កំហាប់ធូលី អនុវត្តការវាស់បណ្តើរ ប្រយ័ត្នចំពោះចំនុចដែលមានដូចខាងក្រោម៖

１）អ្នកអនុវត្តការងារវាស់ធូលី ត្រូវពាក់ម៉ាស់ស្តង់ដាសំរាប់ការពារធូលី។

２）នៅពេលវាស់បរិស្ថានការងារនៅក្នុងរូង ក្នុងការវាស់ចាំបាច់ត្រូវតែដាក់ច្រកចាប់យកខ្យល់នៃបិរិក្ខារវាស់កំហាប់បរិមាណធូលីបែបទៅទិសដៅចរន្តខ្យល់។

នៅពេលធ្វើការវាស់បរិស្ថានការងារនៅក្នុងបន្ទប់នៃការដ្ឋានរ៉ែនៅលើដី ស្តីពីទិសដៅនៃច្រកយកខ្យល់នៃបរិក្ខារវាស់បរិមាណកំហាប់ធូលី មិនមានការកំណត់ទេ ក៏ប៉ុន្តែត្រូវប្រយ័ត្នកុំអោយវាទទួលនូវឥទ្ធិពលនៅទីកន្លែងណាដែលមានចរន្តខ្យល់ទូទៅឆ្លងកាត់។

３）ករណីបរិក្ខារវាស់កំហាប់ធូលីនៃបរិមាណដែលភ្ជាប់បរិក្ខារចាប់យកចំណែកជាច្រើនថ្នាក់ បន្ទះនៃថ្នាក់នោះ ត្រូវតែដាក់អោយស្រប ក្នុងសភាពអាចចាប់យក Sampling បាន។

４）ក្នុងពេលយក Sampling ត្រូវប្រយ័ត្នស្តីការចាប់យកបរិមាណតិចទួចនៃធូលីដែលប្រមូលបាន ចំពោះបរិមាណនៃធូលីដែលប្រមូលបានក្នុងករណីប្រើសារធាតុចាប់0. 01mg នោះបរិមាណដែលចាប់បានត្រូវតែអោយបានលើសពី២០ដង(ឧទាហរណ៍ប្រើសារធាតុចាប់ 0. 01mg នោះធូលីដែលនឹងចាប់បានត្រូវតែអោយបានលើសពី0. 2mg)។

５）ក្រោយពេលចាប់ផ្តើមយក Sampling ធ្វើការបញ្ជាក់មើល តាមរយៈបរិក្ខារវាស់បរិមាណខ្យល់រត់ ដោយបរិមាណនោះមានបរិមាណគ្រប់គ្រាន់តាមការកំណត់ដែរឬទេ តាមរយៈការបឺតបរិមាណខ្យល់នៃបរិក្ខារវាស់ធូលីនៃបរិមាណ។

６）ក្នុងពេលកំពុងយក Sampling ត្រូវមើលបរិមាណចរន្តខ្យល់ រក្សាអោយបាននូវបរិមាណខ្យល់ដែលបានកំណត់ដោយបរិក្ខារប្រើសំរាប់បឺតបរិមាណចរន្តខ្យល់។

７）ចំនួននៃការរាប់នៃបរិក្ខារវាស់កំហាប់ធូលីដោយប្រៀបធៀប នៅពេលលើសពីចំនួនអតិបរិមាដែលបានបង្ហាញចេញ（9, 999 カウント）ចាំបាច់ត្រូវប្រយ័ត្នក្នុងការរាប់នូវចំនួនសរុបទាំងកុំអោយខុស។

８）នៅពេលវាស់នៅតាមចំនុចវាស់តាមរយៈបរិក្ខារវាស់ធូលីប្រៀបធៀប ចាំបាច់ត្រូវតែរក្សាអោយបាននូវពេលវេលាគំលាតសមរម្យសំរាប់វាស់តាមចំនុចនីមួយៗ។

９）ក្នុងករណីវាស់ផ្ទួបចូលគ្នាក្នុងពេលតែមួយ តាមរយៈបរិក្ខារវាស់កំហាប់ធូលីនៃបរិមាណនឹងបិរក្ខារវាស់កំហាប់ធូលីប្រៀបធៀប ចាំបាច់ត្រូវតែអោយបរិក្ខារទាំងសងខាងដំណើរការព្រមគ្នា និង

វាស់ម៉ោងយក Sampling ។ ក្រោយពីបញ្ចប់យក Sampling ធ្វើការកត់ត្រានូវចំនួនដែលបានរាប់សរុបរបស់បរិក្ខារវាស់ធូលីប្រៀបធៀបនឹងម៉ោងយក Samplingជាក់ស្តែង។

１０）ក្រោយពីបានចាប់យកធូលីដោយបរិក្ខារវាស់កំហាប់បរិមាណធូលី ត្រូវពិនិត្យមើលលេខរៀងនៃតំរងក្រដាស់ដែលភ្ជាប់នោះ។

１１）នៅពេលប្រើកhigh volum air supplyចាំបាច់ត្រូវតែប្រយ័ត្នចំពោះចំនុចដែលមានដូចខាងក្រោម៖

① នៅពេលបរិមាណធូលីដែលចាប់បាននៃផ្នែកបរិក្ខារចំណែកមានកើនច្រើន វានឹងអាចមានការហ៊ុយឡើងវិញម្តងទៀតពីផ្នែកដែលចាប់យក ដូច្នេះសូមប្រយ័ត្ន។

②នៅផ្នែកតំរង នៅពេលបរិមាណធូលីដែលចាប់បានកើនឡើងច្រើន វានឹងនឹងធ្វើបរិមាណខ្យល់ដែលកំពុងបឺតចុះថយ ដូចក្នុងពេលវាស់ ចាំបាច់ត្រូវតាមដាន flow meter។ ក៏ប៉ុន្តែករណីមានការទទួលស្គាល់ថាទោះបីសំរបសំរួលចរន្តខ្យល់ក៏ដោយ បរិមាណចរន្តនៅតែទាប ក្រោយពីកត់ត្រាម៉ោងវាស់រួចហើយ ចាំបាច់ត្រូវតែបញ្ឈប់ការយក Sampling ជាបន្ទាន់។

１２）ចំពោះការវាស់នៃកំហាប់បរិមាណធូលី នៅពេលប្រើបរិក្ខារចំណែកតូចបែបមានភាពប៉ះទង្គិច ចាំបាច់ត្រូវតែប្រយ័ត្នដូចខាងក្រោម៖

① មុនពេលវាស់ធូលី ចាំបាច់ត្រូវតែសំអាតផ្នែកខាងចុងនៅក្នុងផ្នែកជញ្ជាំងជាមុនសិនពីព្រោះវាប្រលាក់នឹងធូលីដែលបានវាស់កាលពីលើកមុន រួចទើបធ្វើការវាស់។

② នៅពេលបរិមាណធូលីដែលចាប់បាននៃផ្នែកបរិក្ខារចំណែកមានកើនច្រើន វានឹងអាចមានការហ៊ុយឡើងវិញម្តងទៀតពីផ្នែកដែលចាប់យក ដូច្នេះសូមប្រយ័ត្ន។

１３）ករណីទូរលេខដូចគ្នាបានត្រូវបង្ហាញនៅក្នុងពេលកំពុងវាស់ដោយបរិក្ខារវាស់ធូលីប្រៀបធៀប （ករណីប្រើប្រភេទLD−1E) សូមប្រយ័ត្យនៅពេលមានសភាពដូចខាងក្រោមកើតឡើង។

① នៅករណីគុណនឹងទំហំ （× 1) នៅពេលវាស់ដោយបំលាស់ទី កំហាប់នៃធូលី ខ្ពស់ទូរលេខបង្ហាញក្នុងរយៈពេល១នាទី ករណីScale out ដោយសារតែការបង្ហាញជាប់ៗគ្នានូវទូរលេខ (1,200～1, 400cpm) របស់លេខដែលបានរាប់ ចាំបាច់ត្រូវតែជ្រើសរើសទំហំផែកកំហាប់ជាមុនសិន ទើបអនុវត្តការវាស់។ ក្នុងករណីជ្រើសរើសទំហំគុណនឹង(×１０)នោះនឹងបានទូរលេខកើន១០ដងផងដែរ។ លើសពីនេះ នៅពេលចុចកុតាក់ (× １０) ត្រូវធ្វើការបញ្ជាក់ពីpilot lumpdដែលនឹងលូតភ្លើងភ្លើបភ្លែតផងដែរ។

② ដោយសារមុខងាររវាងគុណនឹង (× 1) ជាមួយគុណនឹង (× 10) វាខុសគ្នា នៅពេលវាស់ហាមដាច់ខាតធ្វើការផ្លាស់ប្តូរ។

(4) ចំនុចប្រយ័ត្ននៅពេលវាស់ដំណាលគ្នា

នៅពេលវាស់ដំណាលគ្នា សូមប្រយ័ត្ននឹងចំនុចខាងក្រោម ក្នុងពេលវាស់៖

1) ទីតាំងនៃចំនុចវាស់ដំណាលគ្នា និងកំពស់

យោងតាមរយៈចំងាយពីប្រភពកើតធូលី ភាពរាយប៉ាយនៃធូលីមានខុសគ្នា។ ភាពរាយប៉ាយនៃធូលី ត្រូវបានចាត់ទុកថាទទួល ឥទ្ធិពលចំពោះមេគុណប្រែប្រួលកំហាប់បរិមាណK ការវាស់ដំណាលគ្នានៅទីតាំងដែលអាចតំណាងនូវធូលីនៃទីកន្លែងការងារជាឯកតានោះ គឺជាការសំខាន់។ ដូច្នេះហើយ បានជាមិនវាស់ដំណាលគ្នា ចំពោះកន្លែងណាឃ្លាតឆ្ងាយពេកពីប្រភពកើតធូលីដែលធូលីទាំងនោះហុយមិនដល់ និងទីកន្លែងឆ្ងាយពីប្រភពហុយដែលមិនទទួលឥទ្ធិពលដោយចរិតរបស់ធូលីដែលហុយចេញពីប្រភពហុយ។

ចំពោះបរិក្ខារវាស់កំហាប់បរិមាណធូលីនិងបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប មួយណាក៏ដោយត្រូវដាក់ក្នុងសភាពស្រប ហើយចំពោះកំពស់មានពី 0.5m～1.5m គឺជាកំពស់ដែលមិនទទួលឥទ្ធិពល យោងតាមរយៈការហុយម្តងទៀតដោយធូលី។

2) របៀបតំរៀបបរិក្ខារវាស់

បរិក្ខារចំណែកតូចមានច្រើនជាន់នៃបរិក្ខារវាស់កំហាប់បរិមាណធូលីនិងច្រកបឺតចូលខ្យល់នៃបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប ឬ ច្រកបឺតខ្យល់នៃបរិក្ខារចំណែកតូចបែបប៉ះទង្គិច ត្រូវធ្វើយ៉ាងណាអោយមានភាពលំអៀងតិច ដោយបើអាចធ្វើបានសូមដាក់នៅក្បែរគ្នា។

## ８. ចំនុចប្រយ័ត្ននិងការចាត់ចែងក្រោយពីវាស់រួច

### (１) ការវាស់ទំងន់តំរង

ករណីធម្មតា ក្រោយពីធ្វើការចាប់យកធូលីចប់ តាមរយៈបរិក្ខារវាស់កំហាប់បរិមាណធូលី តំរងត្រូវរក្សាទុកក្នុង Desiccators នៅពេលធ្វើការវាស់ ត្រូវវាស់ទំងន់ដូចនឹងបែបបទមុនពេលវាស់ដែរ។ ក៏ប៉ុន្តែ ករណីតំរងដែលបានប្រើរួច នៅទីកន្លែងការងារជា ឯកតា ដែលបានបាញ់ជាលំអងទឹកក្នុងគោលបំណងទប់ស្កាត់ធូលី។ល។ ក្រោយពីវាស់រួច ត្រូវសំងួតក្នុងកំដៅ 100° C ក្នុងរយៈពេល១ម៉ោង រួចហើយត្រូវរក្សាវា Desiccators នៅពេលធ្វើការវាស់ ត្រូវវាស់ទំងន់ដូចនឹងបែបបទមុនពេលវាស់ដែរ។

### (２) ការថែទាំបរិក្ខារវាស់

បរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប គឺដូចម៉ាស៊ីនអេឡិត្រូនិចផ្សេងទៀតដែរ ដូច្នេះក្នុងការប្រើប្រាស់វា ចាំបាច់ត្រូវតែមានការផ្ចិតផ្ចង់បំផុត។ លើសពីនេះ ករណីមានធូលីច្រើនគួរអោយកត់សំគាល់ នៅទីកន្លែងវាស់ បើអាចធ្វើបានសូមដោះបំបែកសំអាត ដើម្បីធ្វើយ៉ាងណាអាចធ្វើការវាស់សំរាប់លើកក្រោយបានទៀត។

### (３) ការសំរបសំរួលបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប (សំរបសំរួលម៉ាស៊ីន)

បរិក្ខារវាស់កំហាប់ធូលីប្រៀបធៀបគឺជាបរិក្ខារវាស់កំហាប់ក្នុងកំរិតតិចបំផុត ស្តីពីការគ្រប់គ្រងនិងសំរបសំរួលវា រក្សាអោយមានគុណភាព និងសមត្ថភាព គឺចាំបាច់ត្រូវតែប្រយ័ត្នប្រយែងបំផុត។

ដូច្នេះហើយ ដើម្បីមានភាពចាំបាច់សំរាប់សំរបសំរួលប្រើសំណាកដែលបានហ៊ុយជាធូលីស្តងដា ដោយសារមានភាពពិបាកខ្លាំងក្នុងសំរបសំរួលនៅការដ្ឋានរ៉ែ ចាំបាច់ត្រូវតែពឹងអោយក្រុមហ៊ុនមានជំនាញផ្នែកនេះ ដើម្បីធ្វើការសំរបសំរួលអោយបានលើសពី១ដង ក្នុង១ឆ្នាំ។

## (4) ការសំរបសំរួលទិន្នន័យនៃការវាស់

ការសំរបសំរួលទិន្នន័យនៃការវាស់ គឺត្រូវធ្វើជាបន្ទាន់ក្រោយពីវាស់រួច។ តារាង១「តារាងកត់ត្រាការវាស់កំហាប់ធូលី」ជាឧទាហរណ៍នៃក្រដាស់កត់ត្រាវាស់កំហាប់ធូលី តារាង២「តារាងកត់ត្រាការវាស់ តាមរយៈបរិក្ខារកំហាប់ធូលីប្រៀបធៀប」 និង បង្ហាញនូវភាពចាំបាច់ក្នុងការកត់ត្រានានា។

តារាង១ គឺជាតារាងកត់ត្រាលទ្ធផលវាស់នៃកំហាប់ធូលី បើមើលលើការកត់ត្រានោះ វាមានខ្លឹមសារអាចដឹងពីស្ថានភាពបរិយាកាសនៃទីកន្លែងការងារជាឯកតានោះ។

ក៏ប៉ុន្តែ ករណីអាចគិតថាមានភាពមិនគ្រប់គ្រាន់ បើតាមតែលើការកត់ត្រាលើតារាង១ ស្តីពីស្ថានភាពនៃពេលវាស់ ពីការកត់ត្រាស្ថានភាពការងារនៃទីកន្លែងផ្ទាល់ និងទូរលេខវាស់ យោងតាមបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប ធ្វើការពិនិត្យ និងធ្វើការពិចារណាលើលទ្ធផលនៃការវាស់នឹងភាពសំរបសំរួល។

## (5) របៀបរកមេគុណប្រែប្រួលកំហាប់បរិមាណធូលី (មេគុណK)

ករណីរកមេគុណប្រែប្រួលកំហាប់បរិមាណធូលី ខាងក្រោមមកទៀតហៅថា「មេគុណK」) នៅទីកន្លែងការងារជាឯកតានៃគោលដៅសំរាប់វាស់ ធ្វើការវាស់ដំណាលគ្នាជាមួយនឹងបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប នឹង បរិក្ខារវាស់កំហាប់បរិមាណធូលី យោងតាមវិធីខាងក្រោម គឺជាវិធីទូទៅមួយក្នុងការរកមេគុណK។

តំរៀបនូវច្រកចាប់យកខ្យល់នៃបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប និង បរិក្ខារវាស់កំហាប់បរិមាណធូលី ធ្វើការវាស់ម៉ោង t (min) ដូចគ្នាអោយបានជាប់រហូតនូវម៉ោងវាស់នៃបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប និងបរិក្ខាររវាស់កំហាប់បរិមាណធូលី នៅពេលវាស់នោះទទួលបានកំហាប់បរិមាណ$M_C$ ($mg/m^3$) ដែលត្រូវរកមានរូបមន្តដូចខាងក្រោម។

បន្ទាប់មកR c (cpm) កំហាប់ប្រៀបធៀបម៉ោងបានវាស់ t (min) និង ការបញ្ចូលទៅក្នុងរូបមន្តនូវD (cpm) count down ដែលត្រូវបានភ្ជាប់នឹងបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀបរួចរកតំលៃមេគុណK។

count down D (cpm) គឺជាលេខដែលគេបានសសេរនៅលើតារាងពិនិត្យ ជាលេខមិនប្រែប្រួលនៃបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀបនីមួយៗ សូមយកលេខទាំងនោះមកប្រើ។

$$Mc = W \div q \times t \div 1000$$

$$K = Mc / (Rc - D)$$

ក៏ប៉ុន្តែ, W : បរិមាណភាពជាធូលីដែលបានបឺតចាប់បាន (mg)

q : បរិមាណខ្យល់ស្រូបចូល (Liter/min)

## 9. ការវាស់អត្រាមានfree silicic acid

### (1) Free silicic acid

Free silicic acid ជាសារធាតុតប់ទល់នឹងbound silicicមានរចនាសម្ព័ន្ធផ្សំដោយsilicate minerals។ Silicon ភ្ជាប់ជាមួយនឹងអុកស៊ីសែនមានលក្ខណៈជា៣D វាពុំចាប់ជានឹងសារធាតុគីមីផ្សេងទៀតទេ វានៅតែរក្សានៅជាស្ថានភាពខនិជ ($SiO_2$) ដដែល ។ បន្ទាប់មកទៀតគឺជាប្រភេទខនិជដែលគេស្គាល់ច្រើនជាងគេ។

ក្វាត ($\alpha$、$\beta$), tridymite (α, β), និង cristobalite (α, β)។ល។ ភាគច្រើនក្វាតនោះក្នុង free silicic acid ដែលមាននៅក្នុងបរិយាកាសការងារ, ក្រៅពីនេះមានសារធាតុផ្សេងតិចតួចផងដែរ។ ក្វាតបើត្រូវកំដៅខ្ពស់និងមានរយៈពេលវែងវានឹងក្លាយទៅជា tridymite និង cristobalite ។ នៅក្នុងថ្មដែលបង្កើតបានជាខនិជ ដូចជា Chalcedony, agate, print, jasper ។ល។ គឺមានសារធាតុក្វាតផ្គុំឡើងជាមួយផងដែរ។ លើសពីនេះ opal និងand diatomaceous មានការផ្សំដោយ $SiO_2 \cdot H_2O$ ក៏ប៉ុន្តែ ចំពោះលើសុខភាពសុវត្ថិភាពពលកម្ម ពពួកទាំងនេះគេចាត់ទុកថាជា free silicic acid ទាំងអស់។

ជាទូទៅ មានការបង្ហាញតាមបែបរូបមន្តគីមី ដូចជា$K_2O \cdot Al_2O_3 \cdot 6SiO_2$ (orthoclase), $Na_2O \cdot Al_2O_3 \cdot 6SiO_2$ (albite), $3MgO \cdot 4SiO_2 \cdot H_2O$ (talc), $Al_2O_3 \cdot 2SiO_2 \cdot 2H_2O$ (kaolin)។ល។ ក៏ប៉ុន្តែ $SiO_2$នៃពពួកទាំងនោះ វាតោងជាប់ជាមួយនឹងសភាពគីមីផ្សេងទៀត ដូច្នេះវាមិនមែនជាfree silicic acid ទេ។

### (2) ការចាប់យក free silicic acid

ស្តីពីការវាស់អត្រាភាគរយ free silicic acid ដែលមាននៅក្នុងខ្យល់ (ខាងមកទៀតហៅថា「មេគុណQ」) នៅពេលវាស់កំហាប់ធូលី ជាគោលការណ៍គឺការវាស់តាមវិធីវិភាគដោយកាំរស្មី Xដែលមានអត្រាភាគរយ free silicic acid នៅក្នុងធូលីដែលស្រូបបានដោយតំរងក្រដាស់ដែលភ្ជាប់បរិក្ខារចំណែកតូចVolume air supply ។ ក៏ប៉ុន្តែ ដោយសារការណ៍ពិបាកប្រមូលយកនូវធូលីដែលហុយនោះ បាននូវបរិមាណគ្រប់គ្រាន់ ការវាស់នូវអត្រា free silicic acid ដែលមាននៅក្នុងខ្យល់ យោងតាមរយៈវិធីធ្លាក់ចុះសារធាតុរាវ ឬ វិធីធ្វើអោយហុយឡើងវិញនៃធូលីដែលបានធ្លាក់កករួចហើយ។

ដោយសារវិធីវាស់ចាប់យកធូលីដែលធ្លាក់កក ត្រូវបានទទួលស្គាល់ថាមានករណីអត្រាfree silicic acid ដែលមាននៅក្នុងខ្យល់ច្រើន ចំពោះទីកន្លែងការងារដែលធូលីហុយច្រើនរួមទាំង free silicic acid យកsampling ត្រូវការស៊ីពេលម៉ោង ក៏ប៉ុន្តែ ត្រូវយកតាមវិធីក្បែរនឹងអ្នកដែលបានអនុវត្តមុន ដែលជាវិធីប្រមូលយក។

ករណីចាប់យកធូលីកកផ្ដុំ យកធូលីដែលបានធ្លាក់គលើស្ពាន លើបរិក្ខារម៉ាស៊ីន លើរោមឬសក់ ដោយដាក់ក្នុងថង់ផ្លាស្ទីក។ ក៏ប៉ុន្តែ ចាំបាច់ត្រៀបរៀបចំភ្ជាប់ជាមួយនឹងតំរងស្តង់ដា២០០មេសីវ(74 $\mu$ m) អោយមាននៅក្នុងថង់ផ្លាស្ទីកនោះ អោយរួស្រាច់សិន។ លើថង់ផ្លាស្ទីក ត្រូវសសេរកាលបរិច្ឆេទយកសំណាក ទីកន្លែងយក។ល។

ធូលីកកគរដែលបានយក ក្រោយពីសំងួតរួច ត្រូវរក្សាទុកក្នុង desiccator ទុកប្រើជាសំណាកបរិមាណថេរនៃ free silicic acid ។

## II. វិធីគណនាតំលៃនៃការវាស់របស់កំហាប់ធូលី និងវិធីវាយតំលៃនូវលទ្ធផលនៃការវាស់

### 1. វិធីគណនាតំលៃនៃការវាស់របស់កំហាប់ធូលី

#### (1) ករណីវាស់កំហាប់ធូលីដំណាលគ្នាដោយប្រើបរិក្ខារវាស់កំហាប់បរិមាណធូលី និងបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប

ស្តីពីបរិស្ថានការងារ ករណីបានវាស់ដំណាល់គ្នាតាមរយៈការវាស់បែបA ស្តីពីលទ្ធផលនៃការវាស់នោះ យោងតាមបែបបទដែលមានខាងក្រោម គណនាកំរិតលំអៀងស្តងដា ($\sigma$) និងតំលៃមធ្យម(M)នៃចំនុចវាស់ទាំងអស់, កំហាប់បរិមាណនៃចំនុចវាស់, ចំនួនមេគុណប្រែប្រួលកំហាប់បរិមាណ (មេគុណK) ។

**1) គណនាចំនួនមេគុណប្រែប្រួលកំហាប់បរិមាណ (មេគុណK)**

នៅទីកន្លែងធ្វើការជាឯកតា តាមលទ្ធផលវាស់ដំណាលគ្នាជាមួយនឹងបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀបនឹងបរិក្ខារវាស់កំហាប់បរិមាណធូលី យោងតាមរយៈការគណនាតាមរូបមន្តដែលបានបង្ហាញចំពោះ I－8 (5) គណនាចំនួនមេគុណប្រែប្រួលកំហាប់បរិមាណ (មេគុណK) ។

**2) គណនាបរិមាណនៃកំហាប់**

យោងតាមបរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប យោងតាមមេគុណKចំពោះទូរលេខកំហាប់ប្រៀបធៀបនៅតាមចំនុចវាស់នីមួយៗ ធ្វើការគណនានូវកំហាប់បរិមាណ ($mg/m^3$) នៅតាមចំនុចវាស់នីមួយៗ។

3) គណនារេខាគណិត

តាមចំនុច 2) ខាងលើ ប្រើកំហាប់បរិមាណធូលី $Mc_1$ ($mg/m^3$)、$Mc_2$ ($mg/m^3$) ・・・・・$Mc_n$ ($mg/m^3$) នៅតាមចំនុចវាស់នីមួយៗដែលទទួលបាន យោងតាមវិធីគណនាដូចខាងក្រោម គណនាទូរលេខរេខាគណិត M នៅទីកន្លែងការងារឯកតា។

$$\overline{X} = \sqrt[n]{Mc_1 \times Mc_2 \times \cdots \times Mc_n}$$

$$\log \overline{X} = 1/n \left\{ \log Mc_1 + \log Mc_2 + \cdots + \log Mc_n \right\}$$

$\therefore \overline{M} = 10^{X1}$

4）**គណនានៃកំរិតលំអៀងស្តង់ដារេខាគណិត**

ប្រើកំហាប់បរិមាណធូលីតាមចំនុចនីមួយៗ យោងតាមវិធីគណនាខាងក្រោម គណនាកំរិតលំអៀងស្តង់ដារេខាគណិតσនៅតាមទីតាំងការងារជាឯកតា។

ក៏ប៉ុន្តែ នៅក្នុងរូបមន្តខាងក្រោម $\Sigma X^2$ មានចំនួនសរុបនៃស្វ័យគុណ២ចំពោះឡូការីតនៃទូរលេខកំហាប់បរិមាណធូលីនៅតាមចំនុចវាស់នីមួយៗ។

$$\log\sigma = \{ 1/(n-1)(\Sigma X^2 - n \cdot \overline{X}^2)\}^{1/2}$$

$$\Sigma X^2 = (\log Mc_1{}^2 + \log Mc_2{}^2 + \cdots + \log Mc_n{}^2)$$

5）**ករណីវាស់ក្នុងរយៈពេល២ថ្ងៃ**

ចំពោះករណីវាស់ក្នុងរយៈពេល២ថ្ងៃនៅទីកន្លែងធ្វើការងារជាឯកតា វិធីវាស់ដូចគ្នានឹងការចែងខាងលើ គណនាទូរលេខនៃការវាស់កំហាប់ធូលី។

ក៏ប៉ុន្តែ $M_1$ ជារេខាគណិតនៃថ្ងៃទី១ រេខាគណិត, $M_2$ជារេខាគណិតនៃថ្ងៃទី២ ហៅរេខាគណិតជាមធ្យមនៃទាំងពីរថ្ងៃនោះ មានការគណនាដូចខាងក្រោម៖

$$X = \sqrt{M_1 \times M_2}$$

$$\log X = 1/2 \ (\log M_1 + \log M_2)$$

$$\therefore \overline{M} = 10^{X1}$$

σ1ជាលេខនៃភាពលំអៀងស្តង់ដារេខាគណិតនៃថ្ងៃទី១ , σ2ជាលេខនៃភាពលំអៀងស្តង់ដារេខាគណិតនៃថ្ងៃទី២, σជាលេខនៃភាពលំអៀងស្តង់ដារេខាគណិតនៃរយៈពេល២ថ្ងៃ គណនាយោងតាមខាងក្រោម៖

$$\log \sigma = \sqrt{(\log^2 \sigma_1 + \log^2 \sigma_2)/2}$$

（2）**វិធីគណនាទូរលេខនៃការវាស់នៃកំហាប់ធូលី យោងតាមរយៈការវាស់ធម្មតា**

យោងតាមការតំឡើងទូរលេខនៃការប្រែប្រួលនៃកំហាប់បរិមាណធូលីដែលលើកឡើងនៅតារាងបន្ទាប់(cpm)កំហាប់ប្រៀបធៀបដែលបានវាស់ តែប្រើបរិក្ខារវាស់កំហាប់ប្រៀបធៀប១គ្រឿង អាចធ្វើការគណនាដោយធម្មតានូវបរិមាណកំហាប់នៅតាមចំនុចនីមួយៗបាន។

ចំពោះការវាស់នៃកំហាប់ប្រៀបធៀបនៃចំនុចវាស់នីមួយៗនៅតាមទីកន្លែងធ្វើការងារជាឯកតា t (លើសពី６０នាទី) តំណាងអោយម៉ោងវាស់ទាំងអស់, n តំណាងអោយចំនួននៃចំនុចវាស់, ការកំណត់ម៉ោងល្អនៃការបែងចែកពី t/n នៅក្នុងចន្លោះម៉ោងនោះ វាស់កំហាប់ប្រៀបធៀបក្នុងរយៈពេល ១នាទី។ (ឧទាហរណ៍, ម៉ោងទាំងអស់មាន៦០នាទី, ចំនុចវាស់មានចំនួន១០កន្លែង, ដូច្នេះយើងបានការវាស់កំហាប់ប្រៀបធៀបនៃចន្លោះម៉ោងនោះគឺ៦នាទី=６０／１０)

ក្រោយពីបានវាស់កំហាប់ប្រៀបធៀប នៅតាមចំនុចវាស់នីមួយៗរួច, ប្រើទូរលេខប្រែប្រួលនៃមេគុណប្រែប្រួលកំហាប់បរិមាណអនុលោមតាមរូបមន្តនៃការវាស់កំហាប់ធូលីប្រៀបធៀបដែលមានដូចខាងក្រោម, រកកំហាប់បរិមាណ ធ្វើការគណនាភាពលំអៀងស្តងដារខាគណិតដូចនឹងចំនុច(１)、４) និង５) ខាងលើ។

| រូបមន្តនៃការវាស់កំហាប់ធូលីប្រៀបធៀប | ទូរលេខប្រែប្រួល |
|---|---|
| P－５L | 1 cpm = 0.04 mg/$m^3$ |
| P－５H | 1 cpm = 0.004 mg/$m^3$ |
| LD－１L | 1 cpm = 0.02 mg/$m^3$ |
| LD－１H | 1 cpm = 0.002 mg/$m^3$ |
| LD－３K | 1 cpm = 0.002 mg/$m^3$ |
| LD－５D | 1 cpm = 0.02 mg/$m^3$ |
| LD－５ | 1 cpm = 0.002 mg/$m^3$ |
| ３４１１ | 1 cpm = 0.02 mg/$m^3$ |
| ３４２３ | 1 cpm = 0.003 mg/$m^3$ |
| ３４４２ | 1 cpm = 0.003 mg/$m^3$ |

ប្រភព : ការណែនាំទាក់ទងនឹងវិធានការចំពោះការសាងសង់រូងក្រោមដី
ឆ្នាំ២០០០ (ក្រសួងសុខាភិបាល ជប៉ុន)

## ２. ការគណនានៃវិធីវាយតំលៃ និង កំហាប់គ្រប់គ្រងអនុលោមតាមលទ្ធផលនៃការវាស់

### （１） ការគណនានៃកំហាប់គ្រប់គ្រង

ករណីធ្វើការវាយតំលៃបរិស្ថាន យោងតាមរយៈបែបស្តង់ដាគ្រប់គ្រងនិងលទ្ធផលវាស់នៅបរិស្ថានការងារ ចាំបាច់កំណត់ទុកＥជាកំហាប់គ្រប់គ្រងនៃធូលីដែលបានបឺតចូល (សារធាតុពុល) នៅក្នុងបរិស្ថានការងារវាស់។

ចំពោះកំហាប់គ្រប់គ្រងនោះ នៅដំណាក់កាលដំណើរការនុវការគ្រប់គ្រងបរិស្ថានការងារ ស្តីពីទីកន្លែងការងារជាឯកតាអនុលោមតាមស្តង់ដាបរិស្ថានការងារ ដើម្បីវាយតំលៃនូវស្ថានភាពបរិស្ថានការងារទាក់តងនឹងសារធាតុមានជាតិពុល តាមរយៈលទ្ធផលការវាស់ដែលបានអនុវត្តរួច នៅពេលសន្និដ្ឋានមានល្អឬមិនមានល្អនៃការគ្រប់គ្រងបរិស្ថានការងារជាឯកតា កំណត់មេគុណសំរាប់កំណត់នូវការបែងចែកគ្រប់គ្រង។

បានសេចក្តីថា កំហាប់គ្រប់គ្រង ត្រូវបានបកស្រាយដូចមានខាងក្រោម៖

① កំហាប់គ្រប់គ្រង ត្រូវតែប្រៀបធៀបនឹងរបស់ដែលបានចាត់ចែងហើយចំពោះភាពជាទិន្នន័យនូវទូរលេខវាស់ជាលក្ខណៈលំអិត មានការមិនអាចប្រៀបធៀបដោយផ្ទាល់នឹងទូរលេខវាស់នីមួយៗ។

②កំហាប់គ្រប់គ្រង មានភាពខុសគ្នារវាងកំរិតនៃភាពហ៊ុយដែលកំណត់ដោយជាមុននូវការប្រៀធៀបនឹងកំហាប់ហ៊ុយដែលកម្មកររ៉ែនីមួយៗទទួល។

③កំហាប់គ្រប់គ្រង ⅰ) ស្តង់ដាហ៊ុតនៃប្រទេសនីមួយៗនិងកំរិតនៃការហ៊ុយ ⅱ) ភាពមានលទ្ធភាពប្រើជាក់ស្តែងនូវបច្ចេកទេសគ្រប់គ្រងបរិស្ថានការងារ ⅲ) ប្រយ័ត្នទៅលើការវិវត្តជាលក្ខណៈអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងបរិស្ថានការងារផ្សេងៗ ធ្វើការកំណត់ យោងតាម「ការប្រមើលបែបរដ្ឋបាល」ស្របតាមគោលបំណងនៃការគ្រប់គ្រងបរិស្ថានការងារ។

ច្បាប់សុវត្ថិភាពសុខភាពជប៉ុន ចំពោះក្រុមហ៊ុន យោងតាមការហ៊ុយតាមរយៈការងារ ក្នុងនោះមានសារធាតុខ្លះបង្កអោយមានគ្រោះថ្នាក់ដល់សុខភាពរបស់កម្មករ ឬមានជាតិពុលខ្លាំង ស្តីពីភាពចាំបាច់សំរាប់កាអនុញ្ញាតផលិតដែលភ្ជាប់ជាមួយនឹងការពិន័យ និង ភាពចាំបាច់នៃវិធានការគ្រប់គ្រង មានការតាពកិច្ចអនុវត្តនូវការវាស់បរិស្ថានការងារ ដែលមានសារធាតុចំនួន៩២ត្រូវធ្វើការវាស់។

លើសពីនេះ ចំពោះក្រុមហ៊ុន ភ្ជាប់ជាមួយនឹងការវាយតំលៃដោយអនុលោមតាមស្តង់ដាវាយតំលៃបរិស្ថានការងារនូវលទ្ធផលនៃការវាស់បរិស្ថានការងារ ចំពោះស្តង់ដាវាយតំលៃបរិស្ថានការងារនោះកំណត់「កំហាប់គ្រប់គ្រង」ចំពោះសារធាតុនីមួយៗ។

ក្នុងការកំហាប់គ្រប់គ្រងនេះ ស្តីពី៣៤សារធាតុខ្លាំងដែលមានទូរលេខនៃកំហាប់ប្រៀធៀបនឹងទូរលេខនៃកំរិតនៃការហ៊ុយ (រួមទាំងទូរលេខបណ្តោះអសន្ន) បានចេញជាសំណើរដោយ ACGIH (កិច្ចប្រជុំអ្នកជំនាញការភ្នែកសុខភាពនៃឧស្សាហកម្មអាមេរិច) ឬ កំហាប់ទទួលយកបានដែលព្រមានដោយកិច្ចប្រជុំសុខភាពឧស្សាហកម្មជប៉ុន (រួមទាំងទូរលេខវាយតំលៃឆ្លើយតបនឹងកំរិតហានិភ័យនៃការកើតនូវជំងឺមហារីកដ៏ច្រើន និងទូរលេខបណ្តោះអសន្ន យោងតាមរយៈអ្នកជំនាញការ ក្នុងការ「ពិនិត្យមើលឡើងវិញនូវកំហាប់គ្រប់គ្រង」ដែលបានអនុវត្តមើលឡើងវិញ និងបានរាយការណ៏លទ្ធផលសរុបនៅខែមីនាឆ្នាំ២០០៤។

ស្តីកំហាប់ទទួលយកបាននៃធូលីនៅក្នុងរបាយការណ៍នេះ មានរបស់ដែលអាចទទួលយកបាននូវ「កំហាប់ហ៊ុយចំពោះធូលីងាយស្រូបយកដែលជំងឺរលាកសួតមិនទទួលយកបាននៃ២បែបដែលរកឃើញដោយសារការថតកាំរស្មីXមាន៥ភាគរយ ក្នុងនោះកម្មកររ៉ែដែលបានធ្វើការនៅទីកន្លែងដែលមានការងារពាក់ព័ន្ធនឹងធូលីក្នុងរយៈពេល៤០ឆ្នាំ」។ ក៏ប៉ុន្តែ យោងតាមចំនុចនៃការប្រមើលនូវវិធានការដ៏តឹងរឹងចំពោះការទប់ស្កាត់ភាពហ៊ុយនៃធូលី វាអាចមានភាពចាំបាច់មើលឡើងវិញនូវកំហាប់គ្រប់គ្រងដែលជាវិភាគទានសំរាប់បច្ចុប្បន្នកាល។

ចំពោះធូលីមិនជាស៊ីលីកាតនិងធូលីជាស៊ីលីកាតនៃរបស់អាមេរិចACGIH (ឆ្នាំ1999) យោងតាមការគិតនៃកំហាប់គ្រប់គ្រងបច្ចុប្បន្ន និងកំរិតនៃការហ៊ុយ (=កំហាប់ទទួលយកបានរបស់សមាគមសុខភាព

ឧស្សាហកម្មជប៉ុន) បានជ្រើសយកកំរិតនៃភាពហ៊ុយនៃធូលីស៊ិលីកាគ0. 05 $mg/m^3$និងមិនស៊ីលីកាត $mg/m^3$របស់ ACGIH ករបស់ដែលទទួលយកបានត្រូវបានចាត់ទុកជាកំហាប់គ្រប់គ្រងនូវរូបមន្តដែលមានដូចខាងក្រោម។

យោងតាមរបាយការណ៍នេះ ក្រសួងសុខាភិបាលជប៉ុន បានធ្វើការកែលំអនូវស្តង់ដាការវាយតំលៃបរិស្ថានការងារ ជាមួយនឹងក្រសួងសេដ្ឋកិច្ចពាណិជ្ជកម្មនិងឧស្សាហកម្ម ដោយទទួលយកនូវការគិតនៃស្តង់ដាបទបញ្ញិតរបស់ច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ នៅខែមីនាឆ្នាំ២០០៥ បានធ្វើការកែដោយដាក់ចេញជាសេចក្តីប្រកាស។

$E = 3.0 / (0.59\,Q + 1)$ ក៏ប៉ុន្តែ Q : អត្រាមាន free silicic acid (%)

(2) **ខ្លឹមសារនៃវិធីវាយតំលៃ**

ករណីវាយតំលៃនូវបរិស្ថានការងារ យោងតាមលទ្ធផលវាស់បរិស្ថានការងារ មានដូចខាងក្រោម ធ្វើការវាយតំលៃដោយបានបែងចែកជាតំបន់គ្រប់គ្រង៣ យោងតាមទូរលេខវាយតំលៃ២។

តំបន់គ្រប់គ្រងទី១

———ទូរលេខវាយតំលៃទី១ ($E_A1$) ———

តំបន់គ្រប់គ្រងទី២

———ទូរលេខវាយតំលៃទី២ ($E_A2$) ———

តំបន់គ្រប់គ្រងទី៣

1) **ស្តង់ដាគ្រប់គ្រងទាក់ទងនឹងការវាស់បែបA**

①ទូរលេខវាយតំលៃទី១ ($E_{A1}$)

$$\log E_{A1} = \log M + 1.645 \log \sigma$$

②ទូរលេខវាយតំលៃទី២ ($E_{A2}$)

$$\log E_{A2} = \log M + 1.151 \log^2 \sigma$$

2) **ស្តង់ដាគ្រប់គ្រងទាក់ទងនឹងការវាស់បែបB**

①ទូរលេខវាយតំលៃទី១

ក្នុងនាមជាទូរលេខវាយតំលៃទី១នូវទូរលេខដូចគ្នា និង កំហាប់គ្រប់គ្រង បង្ហាញនូវរូបមន្តបន្ទាប់។

$$C_{B1} = E$$

② ទូរលេខវាយតំលៃទី២

ក្នុងនាមជាទូរលេខវាយតមលៃនូវទូរលេខនៃ១,៥ដងរបស់កំហាប់គ្រប់គ្រង (E) បង្ហាញនូវរូបមន្តបន្ទាប់។

$C_{B2} = 1.5E$

## (3) តំបន់គ្រប់គ្រង

### 1) តំបន់គ្រប់គ្រងទី១

តាមរយៈការវាស់បែបAដែលទទួលបានគ្រប់ទូរលេខ បើនៅមានមិនទាន់ពេញនៃកំហាប់ការគ្រប់គ្រង ការគ្រប់គ្រងនៅក្នុងបរិស្ថានការងារមានភាពសំខាន់។

បានសេចក្តីថា ទីកន្លែងធ្វើការដែលធ្វើបែបនោះ មិនមានកំហាប់ធូលិហ៊ុអាចកើនឡើងលើសកំហាប់គ្រប់គ្រងបានទេ។

ក៏ប៉ុន្តែ នៅក្នុងទីកន្លែងធ្វើការងារជាឯកតា នៅពេលណា ក៏ដូចជាទីកន្លែងណា មានភាពពិបាកខ្លាំងក្នុងការធានាចំពោះការគ្រប់គ្រងកុំអោយកំហាប់នៃការគ្រប់គ្រងកើនលើសកំហាប់ធូលី។ វាមិនអាចអនុវត្តបានទេចំពោះភាពជាក់ស្តែ, នៅក្នុងទីកន្លែងធ្វើការងារជា ឯកតា យោងតាមទីកន្លែងឬម៉ោងពេល ក៏មានខ្លះដែរដែលកំហាប់ធូលីបានលើសកំហាប់គ្រប់គ្រង។ ក៏ប៉ុន្តែ ភាគរយជាក់ស្តែងមានត្រឹមក្រោម៥ភាគរយ ការគ្រប់គ្រងនោះគិតមានភាពត្រឹមត្រូវ នេះគឺជាការគិតគ្រឹះនៃទូរលេខវាយតំលៃទី១ចំពោះលទ្ធផលនៃការវាស់បែបA។

បានសេចក្តីថា ករណីធ្វើការងារដោយកម្មករ៉ែ១០០នាក់នៅទីកន្លែងធ្វើការងារជា ឯកតា នៅក្នុងចំណោមកម្មករ៉ែ១០០នាក់ ប្រហែលជាមាក្រោម៥នាក់ដែលទទួលនូវកំហាប់លើសពីកំហាប់គ្រប់គ្រង ត្រូវបានវាយតំលៃបែបនេះ ស្ថានភាពនៃទីកន្លែងធ្វើការជាឯកតាគឺតំបន់គ្រប់គ្រងទី១។

ទូរលេខវាយតំលៃទី១នៃការវាស់បែបB គឺចាត់ទុកជាទូរលេខគ្រប់គ្រងកំហាប់ ក៏ប៉ុន្តែ ការវាស់បែបB គឺដោយសារការវាស់យកកន្លែងណាដែលយល់ឃើញថាមានកំរិតខ្ពស់បំផុតនៅក្នុងទីកន្លែងធ្វើការជាឯកតា ទូរលេខនោះអាចលើសពីកំហាប់គ្រប់គ្រង នៅក្នុងទីកន្លែងធ្វើការងារជាឯកតា ដោយសារតែមានការស្មានថាកំហាប់ជាមធ្យមនៃភាពហ៊ុយក្នុង១ថ្ងៃអាចលើសពីកំហាប់គ្រប់គ្រង បើលទ្ធផលវាស់មានក្រោមកំហាប់គ្រប់គ្រង ទីកន្លែងការងារជា ឯកតានោះ នឹងវាយតំលៃសមនឹងតំបន់គ្រប់គ្រងទី១។

ដូចមានបែបនេះ តំបន់គ្រប់គ្រងទី១ លទ្ធផលនៃការវាស់បែប Aមានភាពល្អយោងតាមទូរលេខនៃការវាយតំលៃទី១ និង ក្នុងករណីអនុវត្តដោយការវាស់បែបB លទ្ធផលនោះអាចនិយាយថាករណីល្អយោងតាមការវាយតំលៃទី១។ ចំពោះករណីបែងចែកនេះ បរិស្ថានការងារត្រូវបានសន្និដ្ឋានថាមានភាពសមរម្យ។

### 2) តំបន់បែងចែកគ្រប់គ្រងទី២

លទ្ធផលនៃការវាស់បែបការវាស់Aកំហាប់គ្រប់គ្រងដែលម៉ោងជាមធ្យមនៃទូរលេខបានគណនាដោយបរិមាណខ្យល់នៃធូលីភាពស្រូបចូលនៅក្នុងបរិយាកាសការងារនៃទីកន្លែងធ្វើការជាឯកតានៅក្នុងម៉ោងពេល និង ស្ថានភាពស្មើគ្នា ចាត់ទុកទូរលេខវាយតំលៃទី២។

ដូចបែបនេះ កំហាប់ជាមធ្យមទូទៅនិងកំហាប់គ្រប់គ្រងមាននៅក្នុងស្ថានភាពដូចគ្នា នៅក្នុងបរិយាកាសការងារនោះ ២ភាគ១នៃកម្មករវ៉ែដែលធ្វើការ ទទួលភាពហ៊ុយដែលលើសពីកំហាប់គ្រប់គ្រង។

បានសេចក្តីថា មានកម្មករវ៉ែ១០០នាក់កំពុងធ្វើការ នៅកន្លែងធ្វើការងារជាឯកតា ដែលនៅក្នុងចំណោម១០០នាក់នោះ មានមនុស្សក្រោម៥០នាក់ប្រហែលជាបានរហនូវធូលីហ៊ុយដែលលើសពីកំហាប់គ្រប់គ្រង នឹងបានវាយតំលៃស្ថានភាពទីកន្លែងធ្វើការងារជា ឯកតាជាតំបន់គ្រប់គ្រងទី២។

លើសពីនេះ, ទូរលេខវាយតំលៃទី២នៃការវាស់បែបBមាន១,៥ដងនៃកំហាប់គ្រប់គ្រង។

ទាំងនេះ នៅក្នុងចំណោមសារធាតុដែលជាកំហិតនៃបច្ចុប្បន្នកាល កំហិតនៃភាពហ៊ុយ ចំពោះសារធាតុដែលបង្ហាញទាំងសងខាងនៃភាពជាមធ្យមនៃទំងន់និងពេលវេលា និងទូរលេខនៃពិដានការប្រៀបធៀបរវាងភាពជាមធ្យមនៃទំងន់និងពេលវេលា និងទូរលេខនៃពិដានមានភាពរាយប៉ាយក្បែរនឹង「១,៥នឹង១」គឺជាមូលដ្ឋាន នៅពេលស្ថានភាពកំហាប់មិនលើសពីកំហាប់១,៥ដងនៃកំហាប់គ្រប់គ្រង កំហាប់ហ៊ុយជាមធ្យមនៃ១ដងនៅទីកន្លែងធ្វើការជា ឯកតា គឺវាយតំលៃទីកន្លែងធ្វើការងារជាឯកតាថាជាតំបន់គ្រប់គ្រងទី២។

ករណីចំពោះតំបន់គ្រប់គ្រងទី២ បើប្រៀបធៀបនឹងកម្មករវ៉ែដែលទទួលអត្រាហ៊ុយធូលីខ្ពស់ចំពោះការកើនឡើងនូវកំហាប់ គឺសន្និដ្ឋានថាត្រូវតែធ្វើការកែលំនូវការគ្រប់គ្រងបរិយាកាសការងារ។

### 3) តំបន់បែងចែកគ្រប់គ្រងទី៣

តាមរយៈលទ្ធផលវាស់នៃការវាស់បែបA ទីកន្លែងធ្វើការជាឯកតាដែលត្រូវបានវាយតំលៃថាជាតំបន់បែងចែកគ្រប់គ្រងទី៣ ករណីកម្មករវ៉ែ១០០នាក់ធ្វើការនៅទីកន្លែងធ្វើការជាឯកតា ដែលនៅក្នុងចមណោម១០០នាក់នោះ មានកម្មករវ៉ែលើសពី៥០នាក់ បានទទួលរងនូវភាពហ៊ុយ ដែលកំហាប់នោះលើសពីកំហាប់គ្រប់គ្រង នឹងត្រូវបានសន្និដ្ឋានថាទីកន្លែងធ្វើការងារនោះមានស្ថានមានកំហាប់។

តាមរយៈលទ្ធផលវាស់នៃការវាស់បែបA ករណីមានភាពអាក្រក់លើសទូរលេខវាយតំលៃទី២ ឬករណីបានអនុវត្តដោយការវាស់តាមបែបB លទ្ធផលនោះ និយាយបានថាមានភាពអក្រក់លើសពីទូរលេខវាយតំលៃទី២។ ក្នុងករណីបែងចែកបែបនេះ ការគ្រប់គ្រងបរិយាកាសការងារត្រូវបានសន្និដ្ឋានថាពុំមានភាពត្រឹមត្រូវ។

## （4）បែបបទកំណត់នៃការបែងចែកតំបន់គ្រប់គ្រង

កំហាប់គ្រប់គ្រង យោងតាមស្តង់ដាគ្រប់គ្រង។ល។ មានបង្ហាញនូវរូបភាពទី៦នូវflow sheet សំរាប់ធ្វើការកំណត់នូវការបែងចែកតំបន់គ្រប់គ្រង។




រូបទី៦ flow sheet វាយតំលៃអនុលោមតាមលទ្ធផលវាស់បរិយាកាសការងារ

តំបន់បែងចែកនៃការវាស់បែបAនិងBដែលអនុលោមតាមរូបទី៦ តំបន់បែងចែកទាំងនោះបានកំណត់ដោយអនុលោមតាមតារាង៣ និង៤ដែលមានបន្ទាប់។

បើករណី លទ្ធផលនៃការវាស់បែប Aនិង Bចំពោះការវាស់បែបA មាន២តំបន់បែងចែកគ្រប់គ្រង , ការវាស់បែបBមាន១តំបន់តំបន់បែងចែកគ្រប់គ្រង, ការវាស់បែប Aមាន៣តំបន់គ្រប់គ្រង់ ការវាស់បែបBមាន១តំបន់គ្រប់គ្រង់ អាចគិតឃើញថានឹងមានបញ្ហាដោយសារអ្វីមួយចំពោះការតំឡើងការវាស់នៃការវាស់AនិងB ស្តីពីការតំឡើងការវាស់ ចាំបាច់គិតគួរអោយបានគ្រប់គ្រាន់ ករណីទទួលស្គាល់ថាមានបញ្ហា ចាំបាច់ត្រូវតែធ្វើការវាស់សារជាថ្មីម្តងទៀត។

តារាង-៣ វិធីកំណត់នៃការបែងចែកការគ្រប់គ្រងតាមរយៈតែការវាស់បែបA

| ការវាស់បែបA | | |
|---|---|---|
| លេខវាយតំលៃទី១< កំហាប់គ្រប់គ្រង | លេខវាយតំលៃទី២≦កំហាប់គ្រប់គ្រង ≦លេខវាយតំលៃទី១ | លេខវាយតំលៃទី២>កំ ហាប់គ្រប់គ្រង |
| បែងចែកតំបន់គ្រប់គ្រងទី១ | បែងចែកតំបន់គ្រប់គ្រងទី២ | បែងចែកតំបន់គ្រប់គ្រងទី៣ |

តារាង-៤ វិធីកំណត់នៃការបែងចែកការគ្រប់គ្រងតាមរយៈការវាស់បែបA និងការវាស់បែបB

| | | ការវាស់បែបA | | |
|---|---|---|---|---|
| | | លេខវាយតំលៃទី១<កំហាប់គ្រប់គ្រង ($E_1<E$) | លេខវាយតំលៃទី២≦កំហាប់គ្រប់គ្រង≦លេខវាយតំលៃទី១ ($E_2≦E≦E_1$) | លេខវាយតំលៃទី២>កំហាប់គ្រប់គ្រង ($E_2>E$) |
| វាស់បែបB | លេខវាស់បែបB<កំហាប់គ្រប់គ្រង | បែងចែកតំបន់គ្រប់គ្រងទី១ | បែងចែកតំបន់គ្រប់គ្រងទី២ | បែងចែកតំបន់គ្រប់គ្រងទី៣ |
| | កំហាប់គ្រប់គ្រង≦លេខវាស់បែបB ≦កំហាប់គ្រប់គ្រង×1.5 | បែងចែកតំបន់គ្រប់គ្រងទី២ | បែងចែកតំបន់គ្រប់គ្រងទី២ | បែងចែកតំបន់គ្រប់គ្រងទី៣ |
| | លេខវាស់បែបB >កំហាប់គ្រប់គ្រង×1.5 | បែងចែកតំបន់គ្រប់គ្រងទី៣ | បែងចែកតំបន់គ្រប់គ្រងទី៣ | បែងចែកតំបន់គ្រប់គ្រងទី៣ |

(5) វិធានការទប់ស្កាត់ធូលីនៅក្រោយពេលវាយតំលៃ

ករណីចង់ចាត់វិធានការទប់ស្កាត់ធូលី ជាបឋមចាំបាច់ត្រូវតែក្តាប់អោយបាននូវប្រភពនៃការកើតធូលី ករណីអាចគិតថានឹងមានការបំពុលពីប្រភពកើតធូលីទី២ សភាពនៃធូលីនោះក៏ចាំបាច់ត្រូវតែក្តាប់អោយបានដែរ ជាលទ្ធផល វាមានភាពច្បាស់លាស់នូវចំនុចដែលជាបញ្ហាសំរាប់ចាត់វិធានការទប់ស្កាត់។

ចំពោះការក្តាប់នូវការងារទាំងនោះ វានាំអោយមានការវាស់បរិយាកាសការងារបានត្រឹមត្រូវ។ លើសពីនេះ យោងតាមការវាយតំលៃអនុលោមតាមការវាយតំលៃនៃបរិយាកាសការងារនូវលទ្ធផលដែលទទួលបាន ស្ថានភាពនៃបរិយាកាសការងារនៅចំនុចជាក់ស្តែងនោះ នៅគ្រប់ចំនុចវាស់ទាំងអស់ ស្ថានភាពមិនលើសពីកំហាប់គ្រប់គ្រងនៃកំហាប់ធូលី (បែងចែកតំបន់គ្រប់គ្រងទី១) , ទូរលេខមធ្យមរេខាគណិតនៃកំហាប់ធូលីនៃចំនុចវាស់ ស្ថានភាពមិនលើសពីកំហាប់គ្រប់គ្រង (បែងចែកតំបន់គ្រប់គ្រងទី២) ,ទូរលេខមធ្យមរេខាគណិតនៃកំហាប់ធូលីនៃចំនុចវាស់ ស្ថានភាពមិនលើសពីកំហាប់គ្រប់គ្រង (បែងចែកតំបន់គ្រប់គ្រងទី៣) ។ល។ ត្រូវបានគេសន្និដ្ឋានបាន។

ផ្ទុយទៅវិញ លទ្ធផលវាស់នៃទីកន្លែងការងារជា ឯកតា ត្រូវបានគេវាយតំលៃនិងបែងចែកតំបន់គ្រប់គ្រងទី៣ លទ្ធផលនោះ វាជាការវាយតំលៃតាមតែតាមរយៈការវាស់បែប Aក៏មិនដឹង ឬ រួមទាំងតាមរយៈការវាយតំលៃតាមតែតាមរយៈការវាស់បែបBក៏មិនដឹង, វិធិនៃវិធានការកែលំអនោះវាមានភាពខុសគ្នា។

## (6) វិធានការចាំបាច់ចាត់ដោយម្ចាស់សិទ្ធអាជីវកម្មរ៉ែ

ម្ចាស់សិទ្ធអាជីវកម្មរ៉ែ ក្រៅពីចាត់នូវវិធានការកំណត់ដោយច្បាប់ ស្តីពីទិកន្លែងធ្វើការងារជាឯកតា បានអនុវត្តនូវការវាស់បរិយាកាសការងារ ចាំបាច់ចាត់វិធានការដូចខាងក្រោមដោយឆ្លើយតប់នឹងការបែងចែកតំបន់គ្រប់គ្រង។

1) វិធានការចំពោះការបែងចែកតំបន់គ្រប់គ្រងទី១

ការគ្រប់គ្រងបរិយាកាសការងារនៃទីកន្លែងធ្វើការជាឯកតានោះ ដោយសារមានការសន្និដ្ឋាននិងមានភាពត្រឹមត្រូវ មានការរក្សាបានក្នុងស្ថានភាពនោះ និងគិតខំអនុវត្តជាបន្តនូវការគ្រប់គ្រងសព្វថ្ងៃ។

2) វិធានការចំពោះការបែងចែកតំបន់គ្រប់គ្រងទី២

ការគ្រប់គ្រងបរិយាកាសការងារនៃទីកន្លែងការងារជាឯកតានោះ ត្រូវបានគេសន្និដ្ឋានថាចាំបាច់ត្រូវមានការកែលំអ។ ដូច្នេះ ការខិតខំរកអោយឃើញនូវមុលហេតុដែលបណ្តាលអោយមានភាពអាក្រក់នូវបរិយាកាសស្តីពីអគារ រួមទាំងទីកន្លែងអនុវត្តការវាស់បែប B វិធីការងារ។ល។ យោងតាមការអនុវត្តនូវវិធានការចាំបាច់ មានការណែនាំអោយបំលាស់ទៅកាន់ការបែងចែកគ្រប់គ្រងទី១។

លើសពីនេះ, លទ្ធផលនៃការវាស់បែប B ចំពោះករណីអាក្រក់យោងតាមរយៈទូរលេខវាយតំលៃទី១ អនុវត្តនូវិធានការសំរាប់យកចេញនូវមូលហេតុដែលធ្វើអោយមានភាពអាក្រក់នូវបរិយាកាសការងារនៃទីកន្លែងអនុវត្តវាស់បែប B។ ដូច្នេះ វាមានភាពចាំបាច់សំរាប់ការប្រយ័ត្នចំពោះការពង្រឹងការគ្រប់គ្រងការងាររួមទាំងការងារនេះផងដែរ។

3) វិធានការចំពោះតំបន់បែងចែកគ្រប់គ្រងទី៣

ការគ្រប់គ្រងបរិយាកាសការងារនៃទីកន្លែងការងារជាឯកតានោះ ត្រូវបានសន្និដ្ឋានថាមិនសមរម្យ។ ដូច្នេះ ស្តីពីទីកន្លែងធ្វើការងានៅក្នុងបន្ទប់នៃការដ្ឋានរ៉ែលើដី ចាត់វិធានការចាំបាច់សំរាប់ធ្វើការកែលំអនូវកំហាប់ធូលីដែលបានបែងចែកជាបន្ទាន់ជាតំបន់គ្រប់គ្រងទិ១ និងតំបន់បែងចែកការគ្រប់គ្រងទី២ ចំពោះទីកន្លែងធ្វើការនៅក្នុងរូងក៏ដោយ ក៏ខិតខំចាត់វិធានការចាំបាច់ដែរ។

ការវាស់បែបA ករណីមានភាពល្អយោងតាមទុរលេខវាយតំលៃទី១ ស្តីពីអគារនៃទីកន្លែងអនុវត្តការវាស់បែបBវិធីធ្វើការងារ។ល។ អនុវត្តនូវវិធានការសំរាប់យកចេញនូវមូលហេតុដែលធ្វើ

អោយមានភាពកាន់តែអាក្រក់នូវបរិយាកាសការងារ អនុវត្តបញ្ជាក់លទ្ធផលនៃវិធានការនោះផង ពង្រឹងវិធានការចាប់ផ្តែនៃការគ្រប់គ្រងសុខភាពផង។

①ស្តីពីវត្ថុធាតុដើម អគារ វិធីធ្វើការងារ។ល។ យោងតាមការអនុវត្តការស្រាវជ្រាវពិនិត្យលំអិតខិតខំរកអោយឃើញនូវផលប៉ះពាល់ ការកែលំអនៃវិធីធ្វើការងារ វិធានការបច្ចុប្បន្ន ជំរុញអោយអនុវត្តអោយបានប្រាកដប្រជា ចាត់វិធានការចំពោះការគ្រប់គ្រងបរិយាកាសការងារជាទូទៅរួមទាំងការផ្លាស់ប្តូរវិធិផលិត។ល។

② ក្រោយពីចាត់វិធានការគ្រប់គ្រងបរិយាកាសការងារដែលត្រូវការ ស្តីពីទីកន្លែងធ្វើការងារជាឯកតានោះ យោងតាមការអនុវត្តនុវការវាស់នៃការគ្រប់គ្រងបរិយាកាសការងារ បញ្ជាក់នុវប្រសិទ្ធភាពនៃវិធានការនោះ។

③ស្តីពីកម្មកររ៉ែនៅទីកន្លែងដែលគិតថានឹងមានទទួលឥទ្ធិពលធំតាមរយៈការហុយនៃធូលី ក្រៅពិចាត់វិធានការប្រើបរិក្ខារការពារប្រើសំរាប់ដកដង្ហើម អនុវត្តស្រាវជ្រាវទាក់តងនឹងភាបហុយនៅពេលមានភាពចាំបាច់និងការគ្រប់គ្រងការងារដោយលំអិត ពង្រឹងនូវការគ្រប់គ្រងសុខភាព និងខិតខំរក្សាសុខភាព។

## តារាង-១ បែបបទនៃតារាងកត់ត្រាការវាស់កំហាប់ធូលី

１．ឈ្មោះការដ្ឋានរ៉ែ（ប្រភេទរ៉ែ）:
２．ឈ្មោះទីកន្លែងធ្វើការងារជាឯកតានៃការវាស់កំហាប់ធូលី :
３．ប្រភេទនៃការងារនិងចំនួនកម្មកររ៉ែនៅទីកន្លែងការងារជាឯកតា :
４．ឈ្មោះបរិក្ខារវាស់（ម៉ូឌែល）:
５．អត្រា free silicic acid（%）、វិថីចាប់យកសំណាក、វិធិវិភាគនិងគុណភាពថ្ម :
６．ប្រើលំនឹង（ភាពចាប់បាននៃលំនឹង ឬ កំហិតនៃការអានបាន）និងប្រភេទនៃការប្រើតំរងក្រដាស់ :
７．វិធីប្រើសំខាន់ចំពោះគ្រឿងចក្រនៅទីកន្លែងការងារជាឯកតា :
８．ស្ថានភាពកើតធូលីនៅទីកន្លែងការងារជាឯកតា :
９．ស្ថានភាពអនុវត្តវិធានការទប់ស្កាត់ធូលីនៅទីកន្លែងការងារជាឯកតា :
１０．ឈ្មោះអ្នកវាស់និងការតំឡើងការវាស់（design）:
１１．លទ្ធផលការវាស់កំហាប់ធូលីនៅទីកន្លែងការងារជាឯកតា
（１）កាលបរិច្ឆេទនៃការវាស់ :
（２）ម៉ោងពេលនៃការវាស់ :
（３）សីតុណ្ណភាពនៃទីកន្លែងធ្វើការជាឯកតា, សំណើម និងល្បឿនខ្យល់ :

（4）បរិក្ខារវាស់កំហាប់បរិមាណធូលី

1）កំពស់ចាប់ពីផ្ទៃបាតរហូតដល់មាត់ច្រកបឺតចូល (m) :

2）បរិមាណបឺតខ្យល់ចូល q (litter/min) :

3）រយៈពេលនៃបឺតចូល t (min) :

4）បរិមាណបឺតចូលសរុប $Q = q \times t / 1,000$ ($m^3$)

（5）បរិក្ខារវាស់កំហាប់បរិមាណធូលីប្រៀបធៀបនៃការប្រើវាស់នៅពេលដំណាលគ្នា

1）រាប់សរុប Rn(count) :

2）ម៉ោងវាស់ t (min) :

3）កំហាប់ប្រៀបធៀបយោងតាមរយៈការវាស់ដំណាលគ្នា $Rc = Rn / t$ (cpm) :

（6）ចំនួនមេគុណប្រែប្រួលកំហាប់បរិមាណ

1）បរិមាណទំងន់នៃតំរងក្រោយការវាស់ $W_1$(mg) :

2）បរិមាណទំងន់នៃតំរងក្រោយការវាស់ $W_2$(mg) :

3）បរិមាណទំងន់ធូលីមានភាពបឺតចូលនៃការចាប់ប្រមូល $W = W_2 - W_1$ (mg) :

4）កំហាប់ធូលីនៃទីកន្លែងធ្វើការងារជាឯកតា $Mc = W / Q$ ($mg/m^3$) :

5）ចំនួនមេគុណប្រែប្រួលកំហាប់បរិមាណ $K = Mc / Rc - D$ :

## ចំនុចសំខាន់សំរាប់កត់ត្រារបស់ (តារាង-១ តារាងកត់ត្រាការវាស់កំហាប់ធូលី)

1. ឈ្មោះទីកន្លែងវាស់……សសេរឈ្មោះទីកន្លែងនៃការដ្ឋានរ៉ែ។
2. ឈ្មោះបរិក្ខារវាស់・ចំនួនម៉ាស៊ីនដែលប្រើ……បើការដ្ឋានរ៉ែនោះប្រើម៉ាស៊ីនប្រភេទដូចគ្នាសូមបិតលេខរៀងសំរាប់សំគាល់ម៉ាស៊ីននោះ។
3. បរិមាណដែលបានប្រើ……តំរងក្រដាស់ (តំរង) និងប្រភេទដែលបានប្រើនៅពេលវាស់បរិមាណនៃការប៉ះនឹងបន្ទះ ព្រមទាំងភាពចាប់បាន (គំរូសំរាប់សសេរ : បរិមាណចាប់បានតិច0.01mg) កត់ត្រាចូល។
4. ការប្រើតំរងក្រដាស់ (តំរង) ……សូមសសេរនូវ ប្រភេទនៃតំរង និង លេខតំរង។
5. អត្រា free silicic acid

(1) ប្រភេទនៃសំណាក・・・・សូមសសេរនៅចំនុចទាំងនេះ, ធូលីហ៊ុយ, ធូលីកកត, ផ្សេងៗ (ឧទាហរណ៍, ការយកថ្មម៉ាប់)

(2) វិធីវិភាគ・・・・ឧទាហរណ៍, សូមសសេរនូវវិធីដែលបានប្រើ the phosphoric acid method, X-ray diffraction analysis។

(3) ប្រភេទថ្ម・・・・សូមសសេរនូវ គុណភាពថ្មសំខាន់ (ថ្មកំបោរ, shale, ថ្មខ្សាច់, sandy shale។ល។) ដែលបង្កើតធូលីនៅទីកន្លែងធ្វើការងារជាឯកតា។

6. កម្មករវ៉ែ····សូមសសេរនូវចំនួនកម្មករវ៉ែទាំងអស់ដែលធ្វើការផ្ទាល់នៅទីកន្លែងធ្វើការងារជាឯកតា។
ករណីថ្ងៃទី១និងថ្ងៃទី ចំនួនកម្មករមានចំនួនខុសគ្នា សូមសសេរនូវថ្ងៃទី២មាន
ចំនួន （ ） ។

7. ប្រភេទនៃការងារ····ឧទាហរណ៍, រន្ធខួង, លើកដាក់, ដឹកជញ្ជូន, កិនបំបែក, ផ្សេងៗ

8. វិធីធ្វើការនៃការប្រើគ្រឿងចក្រការដ្ឋានវ៉ែ

(1) សូមសសេរនូវ ឈ្មោះគ្រឿងចក្រ, ម៉ាក, កំឡាំងម៉ាស៊ីន និងចំនួនគ្រឿង ដែលប្រើ និងជាមូលហេតុនៃការកើតឡើងនូវធូលី។

(2 ) ករណីការប្រើខុសពីថ្ងៃទី១និងទី២, សូមសសេរបែងចែកដាច់ពីគ្នា សំរាប់ថ្ងៃទី១ និង ថ្ងៃទី២។

9. លក្ខខណ្ឌនៃការវាស់······សីតុណ្ហភាព, សំណើម, ល្បឿន, សសេរនូវលេខបានវាស់ដោយគិតជាមធ្យមនៅទីកន្លែងធ្វើការងារជាឯកតា។

10. សសេរកត់ត្រានូវលទ្ធផលនៃការវាស់នៅក្នុងតារាងកត់ត្រា ប្រយ័ត្នចំពោះឯកតា Q/m、mg) នីមួយៗ សសេរពីរូបមន្តសំរាប់គណនានៅក្នុង （ ） ។

# តារាង-២ តារាងកត់ត្រារបស់បរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប

1. ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) :
2. ឈ្មោះទីកន្លែងធ្វើការងារជាឯកតានៃការវាស់កំហាប់ធូលី :
3. ប្រភេទនៃការងារនិងចំនួនកម្មកររ៉ែនៅទីកន្លែងការងារជាឯកតា :
4. ឈ្មោះបរិក្ខារវាស់ (ម៉ូឌែល) និងលេខរាប់dark count :
5. វិធីប្រើសំខាន់ចំពោះគ្រឿងចក្រនៅទីកន្លែងការងារជាឯកតា :
6. ស្ថានភាពកើតធូលីនៅទីកន្លែងការងារជាឯកតា :
7. ស្ថានភាពអនុវត្តវិធានការទប់ស្កាត់ធូលីនៅទីកន្លែងការងារជាឯកតា :
8. ឈ្មោះអ្នកវាស់និងការតំឡើងការវាស់ (design) :
9. លទ្ធផលការវាស់កំហាប់ធូលីនៅទីកន្លែងការងារជាឯកតា
   (1) កាលបរិច្ឆេទនៃការវាស់ :
   (2) ម៉ោងពេលនៃការវាស់ :
   (3) សីតុណ្ហភាពនៃទីកន្លែងធ្វើការជាឯកតា, សំណើម និងល្បឿនខ្យល់ :
   (4) លទ្ធផលនៃការវាស់កំហាប់ធូលី

| (ចំនុចវាស់) | (រយៈពេលវាស់ = ១នាទី) | (ចំនួនរាប់ជាdigital count) |
|---|---|---|
| No. 1 | | |
| No. 2 | | |
| No. 3 | | |
| No. 4 | | |
| No. 5 | | |
| No. 6 | | |
| No. 7 | | |
| No. 8 | | |
| No. 9 | | |
| No. 10 | | |

10. ទូរលេខប្រែប្រួល ឬ មេគុណប្រែប្រួលកំហាប់បរិមាណ(K)
11. អត្រា free silicic acid ឬ ចំនួនលេខប្រើសំរាប់គណនានៃកំហាប់គ្រប់គ្រង

ចំនុចសំខាន់សំរាប់សសេរ (តារាង-២ តារាងកត់ត្រារបស់បរិក្ខារវាស់កំហាប់ធូលីប្រៀបធៀប)

1. ឈ្មោះទីវាស់កន្លែងកំហាប់ធូលី……សសេរឈ្មោះទីកន្លែងនៃការដ្ឋានរ៉ែ។
2. កម្មកររ៉ែ‥‥សូមសសេរនូវចំនួនកម្មកររ៉ែទាំងអស់ដែលធ្វើការផ្ទាល់នៅទីកន្លែងធ្វើការងារជាឯកតា។
3. ប្រភេទនៃការងារ‥‥ឧទាហរណ៍, រន្ធខួង, លើកដាក់, ដឹកជញ្ជូន, កិនបំបែក, ផ្សេងៗ
4. វិធីធ្វើការនៃការប្រើគ្រឿងចក្រការដ្ឋានរ៉ែ
 សូមសសេរនូវ ឈ្មោះគ្រឿងចក្រ, ម៉ាក, កំឡាំងម៉ាស៊ីន និងចំនួនគ្រឿង ដែលប្រើ និងជាមូលហេតុការកើតឡើងនូវធូលី។
5. ចំពោះសីតុណ្ហភាព, សំណើម, ល្បឿន, សសេរនូវលេខបានវាស់ដោយគិតជាមធ្យមនៅទីកន្លែងធ្វើការងារជាឯកតា។
6. យោងតាមការវាស់បែបធម្មតា ដោយប្រើម៉ាស៊ីនវាស់កំហាប់ធូលីប្រៀបធៀប១គ្រឿង ក្នុងករណីចង់រកកំហាប់បរិមាណធូលីតាមរយៈបរិមាណដែលបានវាស់ សូមប្រើតារាងគណនាផ្លាស់ប្តូរដែលមានខាងក្រោម ក្នុងការគណនាលេខផ្លាស់ប្តូរចំពោះកំហាប់ប្រៀបធៀប។

| ម៉ូឌែលនៃបរិក្ខារវាស់កំហាប់ប្រៀបធៀបរិមាណ | លេខគណនាផ្លាស់ប្តូរ |
|---|---|
| P－5 L | 1 cpm = 0.04 $mg/m^3$ |
| P－5 H | 1 cpm = 0.004 $mg/m^3$ |
| L D－1 L | 1 cpm = 0.02 $mg/m^3$ |
| L D－1 H | 1 cpm = 0.002 $mg/m^3$ |
| L D－3 K | 1 cpm = 0.002 $mg/m^3$ |
| L D－5 D | 1 cpm = 0.02 $mg/m^3$ |
| L D－5 | 1 cpm = 0.002 $mg/m^3$ |
| 3 4 1 1 | 1 cpm = 0.02 $mg/m^3$ |
| 3 4 2 3 | 1 cpm = 0.003 $mg/m^3$ |
| 3 4 4 2 | 1 cpm = 0.003 $mg/m^3$ |

ប្រភព : ការណែនាំទាក់ទងនឹងវិធានការចំពោះការសាងសង់រូងក្រោមដី
ឆ្នាំ២០០០ (ក្រសួងសុខាភិបាល ជប៉ុន)

7. ដើម្បីគណនាកំហាប់គ្រប់គ្រង ចាំបាច់ត្រូវរកអត្រា free silicic acidនៅក្នុងធូលីនៅក្បែរទីកន្លែងធ្វើការងារជាឯកតា។ ក៏ប៉ុន្តែ ករណីពីបាកយោងតាមសភាពផ្សេងៗនៃការវិភាគទាក់ទងនឹងអត្រា free silicic acidនៅទីកន្លែងកើតធូលីដែលគិតថាវាចេញពីថ្មផ្សេងៗ (ដូចជា ថ្មកំបោរ, shale, ថ្មខ្សាច់, sandy shale។ល។) នៅក្បែរទីកន្លែងធ្វើការជាឯកតា ជាមុនសិន ទើបធ្វើការវាស់ដោយប្រើលេខដែលមានដូចខាងក្រោមជាលេខជំនួយក្នុងការផ្លាស់ប្តូរអត្រាfree silicic acidដែលបានមកពីការវាស់។ ក៏ប៉ុន្តែ អត្រាfree silicic acidដែលមាននៅក្នុងធូលីកកគរ ឬ នៅក្នុងធូលីដែលប្រមូលបាន ជាក់

ស្តែងវា មានលេខតូចចាំបាច់ត្រូវតែមានប្រយ័ត្នបំផុត។ ដូច្នេះ ក្នុងការវាយតំលៃនូវការមានឬក៏មាន នៃបរិយាកាសការងារនោះ គឺត្រូវប្រើវាក្នុងលក្ខខណ្ឌសមរម្យផងដែរ។

| ឈ្មោះថ្ម | អត្រាមានfree silicic acid（%） |
|---|---|
| ថ្មកំបោរ | 0 ～ 8 |
| សិលាដីឥដ្ឋ | 20～ 45 |
| ថ្មភក់ | 25～ 65 |
| Sandy shale | 22～ 58 |
| កំទេចផេះសិលាភ្នំភ្លើង | 25～ 58 |
| ដីឥដ្ឋ | 17～ 50 |
| ថ្មក្រានីត | 29 ～ 38 |
| Liparite (Rhyolite) | 21 ～ 34 |
| Dacite | 23 ～ 41 |
| Peridotite | 0 ～ 1 |
| Pyroxenite | 0 ～ 1 |
| Gabbro | 0 ～ 11 |
| Basalt | 8 ～ 28 |
| Diabase | 4 ～ 14 |

(Sources: Department of Resource and Environmental Engineering, Faculty of Science and Engineering. Waseda University of Japan)

(ឯកសារជំនួយ)　　　　វិធីគណនានិងវាយតំលៃនៃលទ្ធផលវាស់

**1．លក្ខខណ្ឌ**

（1）វិធីវាស់A

នៅទីកន្លែងខួងរុលទៅមុខនៃការដ្ឋានរ៉ែលោហៈជីកយករ៉ែបែបនៅក្នុងរូង ប្រើបរិក្ខារប្រភេទ(ＬＤ－３Ｋ) ១គ្រឿងសំរាប់វាស់កំហាប់ប្រៀបធៀប យោងតាមការវាស់ធម្មតា កំណត់យកទីកន្លែងធ្វើការជាឯកតា កំណត់យកទីតាំងវាស់ចំនួន១០ អនុវត្តការវាស់កំហាប់ធូលីតាមរយៈការវាស់បែបA។

ក៏ប៉ុន្តែ ក្នុងការប្រើជំនួសទូរលេខមេគុណប្រែប្រួលកំហាប់បរិមាណ ប្រើ 1 cpm =0.002mg/m$^3$ លេខមេគុណនៃបរិក្ខារＬＤ－３កបង្ហាញនូវក្នុងបែបＩ．２．（７）។

（2）វិធីវាស់B

ក្នុងម៉ោង និងទីកន្លែងដែលគិតថាមានកំហាប់ច្រើន នៅក្បែរទីកន្លែងធ្វើការងារជា ឯកតា លទ្ធផលនៃការវាស់បែបＢក្នុងរយៈពេល១០នាទីដោយប្រើបរិក្ខារវាស់កំហាប់ប្រៀបធៀបរិមាណ គឺ RB = 2,350 (count)។ លើសពីនេះ ធ្វើការយកធូលីកកគរនៅក្បែរទីកន្លែងធ្វើការងារខួងរុលទៅ

មុខនៅក្នុងរូង លទ្ធផលនៃអត្រាមានfree silicic acid គឺ Q = 7.5 %។

2. លទ្ធផលការវាស់នៃទីកន្លែងធ្វើការងារជាឯកតា យោងតាមរយៈបរិក្ខារវាស់កំហាប់ប្រៀបធៀប

(1) វិធីវាស់A

កំហាប់ប្រៀបធៀប $R_A$(cpm) ក្នុង១នាទី នៅតាមទីកន្លែងវាស់នីមួយៗនៃទីកន្លែងធ្វើការងារជាឯកតា គឺមានដូចខាងក្រោម៖

$R_{A1}$ = 55cpm, $R_{A2}$ = 70cpm, $R_{A3}$= 75cpm, $R_{A4}$= 60cpm, $R_{A5}$ = 90cpm,
$R_{A6}$ = 100cpm, $R_{A7}$ = 75cpm, $R_{A8}$ = 65cpm, $R_{A9}$ = 60cpm, $R_{A10}$ = 70cpm

កំហាប់បរិមាណ Mc ($mg/m^3$) នៅតាមទីកន្លែងវាស់នីមួយៗ អនុវត្តការការវាស់នូវលេខគណនាផ្លាស់ប្តូរនៃកំហាប់ប្រៀបធៀបដែលមានសសេរដូចខាងលើ។ លើសពីនេះ ចំពោះ σ លេខលំអៀងស្តង់ដាខេរាគណិត និងលេខMមធ្យមខេរាគណិតប្រើរូបមន្តដែលមានដូចនៅខាងក្រោម។

$Mc_1 = R_{A1} \times 0.002 = 0.11 mg/m^3$, $Mc_2 = 0.14 mg/m^3$, $Mc_3 = 0.15 mg/m^3$,
$Mc_4 = 0.12 mg/m^3$, $Mc_5 = 0.18 mg/m^3$, $Mc_6 = 0.20 mg/m^3$, $Mc_7 = 0.15 mg/m^3$,
$Mc_8 = 0.12 mg/m^3$, $Mc_9 = 0.12 mg/m^3$, $Mc_{10} = 0.14 mg/m^3$

$\overline{X}$ = 1/10 {log0.11 + log0.14 + log0.15 + log0.12 + Log0.18 + log0.20
+ log0.15 + log0.12 + log0.12 + log0.14}
= 1/10 {▲8.522} = ▲0.852

$\therefore M = 10^{X} = 10^{-0.852} = 0.140\ (mg/m^3)$

$\log\sigma = \{1/(n-1)(\Sigma X^2 - n \cdot X^2)\}^{1/2}$

ដូច្នេះ, $\Sigma X^2 = ( \log Mc_1^2 + \log Mc_2^2 + \log Mc_3^2 + \log Mc_4^2 + \log Mc_5^2 +$
$\log Mc_6^2 + \log Mc_7^2 + \log Mc_8^2 + \log Mc_9^2 + \log Mc_{10}^2)$
= (0.919 + 0.729 + 0.678 + 0.848 + 0.555 + 0.488 + 0.678 +
0.848 + 0.848 + 0.729)
= 7.32

$\log\sigma = \{1/(n-1)(\Sigma X^2 - n \cdot X^2)\}^{1/2}$
= {1/9 (7.32 – 10 × (▲0.852)$^2$ )}$^{1/2}$
= {1/9 (0.07)}$^{1/2}$
= 0.088
$\therefore\ \sigma = 10^{0.088} = 1.225$

(2) វិធីវាស់B

រកនូវកំហាប់បរិមាណ $M_B$ ($mg/m^3$) ពីកំហាប់ប្រៀបធៀប$R_B$នៃរយៈពេល១០នាទី នៃរយៈពេល និងទីកន្លែងដែលអាចគិតថាមានកំហាប់ធូលីច្រើន។

$M_B = R_B/10 \times 0.002 = 2{,}350 / 10 \times 0.002$
$= 0.470\ (mg/m^3)$

(3) វាយតំលៃ

1) លេខវាយតំលៃទី១ តាមរយៈការវាស់បែបA

$$\log E_1 = \log M + 1.645 \log \sigma$$
$$= \log 0.14 + 1.645 \log 1.225$$
$$= ▲\ 0.854 + 1.645 \times 0.088$$
$$= ▲\ 0.710$$

$\therefore\ E_1 = 10^{-0.710} = 0.194$

2) លេខវាយតំលៃទី២ តាមរយៈការវាស់បែបA

$$\log E_2 = \log M + 1.51 \log^2 \sigma$$
$$= \log 0.14 + 1.51 \times \log^2 1.225$$
$$= ▲\ 0.854 + 1.51 \times 0.007$$
$$= ▲\ 0.843$$

$\therefore\ E_2 = 10^{-0.843} = 0.143$

3) កំហាប់គ្រប់គ្រង

ដោយសារមាន $Q = 7.5\%$ជាអត្រា free silicic acid នៅក្នុងធូលីនៃទីកន្លែងធ្វើការខួងទៅមុខនៃកន្លែងនោះ រកតាមរយៈបែបរូបមន្ត E ($mg/m^3$)នៃកំហាប់គ្រប់គ្រង។

$$E = 3.0 / (0.59\,Q + 1)$$
$$= 3.0 / (0.59 \times 7.5 + 1)$$
$$= 0.552 \quad (mg/m^3)$$

4) លេខវាយតំលៃទី១ តាមរយៈការវាស់បែបB

$$C_{B1} = E = 0.552$$

5) លេខវាយតំលៃទី២ តាមរយៈការវាស់បែបB

$$C_{B2} = 1.5\,E = 1.5 \times 0.552 = 0.828$$

6) វាយតំលៃ

ស្តង់ដាគ្រប់គ្រងទាក់ទងនឹងការវាស់បែបA (លេខវាយតំលៃទី១ $E_1 = 0.194$ ,លេខវាយតំលៃទី២$E_2=0.143$) និងស្តង់ដាគ្រប់គ្រងទាក់ទងនឹងការវាស់បែបB (តាមរយៈការលទទួលបានពីលេខវាយតំលៃទី១$C_{B1} = 0.552$、លេខវាយតំលៃទី២ $C_{B2} = 0.828$) ធ្វើការកំណត់បែងចែកតំបន់គ្រប់គ្រង។

① **វិធីវាស់**A

$E_2=0.143 < E = 1.212$ (លេខវាយតំលៃទី២ មានកំហាប់គ្រប់គ្រងដូចខាងក្រោម)

$E_1 = 0.194 \quad < \quad E = 1.212$ （លេខវាយតំលៃទី១ មានកំហាប់គ្រប់គ្រងដូចខាងក្រោម）

② **វិធីវាស់**B

$C_{B2} = 0.470 < 1.5 \; E = 0.828$ （មានកំហាប់ក្រោម១,៥ដងនៃកំហាប់គ្រប់គ្រង យោងតាមការវាស់បែបB）

$C_{B1} = 0.470 < \quad E = 0.552$ （លេខវាយតំលៃទី១ មានកំហាប់ក្រោមកំហាប់គ្រប់គ្រង យោងតាមការវាស់បែបB）

③ **សន្និដ្ឋាន**

យោងតាមស្តង់ដាគ្រប់គ្រង ការវាស់បែប Aវាត្រូវនឹងការបែងចែកតំបន់គ្រប់គ្រងទី១ ការវាស់បែបBវាត្រូវនឹងការបែងចែកតំបន់គ្រប់គ្រងទី១។ យោងតាមការវាស់បែប AនិងបែបB ដោយសារតែលទ្ធផលរបស់វា មួយណាក៏ត្រូវនឹងការបែបចែកតំបន់គ្រប់គ្រងទី១ ដូច្នេះសន្និដ្ឋានបានថា ការគ្រប់គ្រងបរិយាកាសការងារនៅទីកន្លែងធ្វើការខួងរុលទៅមុខនៃការដ្ឋានរ៉ែលោហៈយករ៉ែបែបអណ្តូងរ៉ែបិទមានលក្ខណៈត្រឹមត្រូវ។

# បែបបទគ្រប់គ្រងហានិភ័យរបស់សុវត្ថិភាពការដ្ឋានរ៉ែ

２０１６年３月１日

## 1. ការបញ្ចូលវិធីគ្រប់គ្រងហានិភ័យនៅការដ្ឋានរ៉ែ និងគោលបំណងផ្សេងទៀត

យោងតាមរយៈការអនុវត្តស្រាវជ្រាវស្ថានភាពដែលបានបញ្ចូលនូវក្នុងវិធីគ្រប់គ្រងហានិភ័យ អាចចូលរួមទប់ស្កាត់នូវការបំពុលបរិដ្ឋានដែលនឹងត្រូវដោយសារអាជីវកម្មរ៉ែនិងភាពមានគ្រោះថ្នាក់នៅការដ្ឋានរ៉ែ យោងតាមរយៈការអនុវត្តនូវវិធានការសមស្រប អនុវត្តត្រួតពិនិត្យវិធានការតប់ទល់ ・វាយតំលៃ・វិភាគរកនូវមូលហេតុនៃគ្រោះថ្នាក់ ដែលធ្លាប់មានជាញឹកញាប់ នូវការបំពុលបរិដ្ឋានដែលនឹងត្រូវដោយសារអាជីវកម្មរ៉ែនិងភាពមានគ្រោះថ្នាក់កាលពីមុន។

## 2. ការប្រើប្រាស់នូវ「ការស្រាវជ្រាវស្ថានភាពសុវត្ថិភាព」 នៃ វិធីគ្រប់គ្រងហានិភ័យ

① ការរកឃើញនូវហានិភ័យ ⟹ ② វិភាគហានិភ័យ ⟹ ③វាយតំលៃចំពោះហានិភ័យ ⟹ ④ វិធានការចំពោះហានិភ័យ

1）តើ អាចនឹងកើតមានឡើង នូវ គ្រោះថ្នាក់ ឬ មានការបំពុលដោយសាររ៉ែ នៅការដ្ឋានរ៉ែដែរឬទេ ?

2）ក្នុងករណីមានកើតឡើងនូវគ្រោះថ្នាក់ ឬ មានការបំពុលដោយសាររ៉ែ នៅការដ្ឋានរ៉ែនោះ តើវាមានការជះឥទ្ធិពលបែបណាខ្លះ?

3）តើភាគរយនៃ គ្រោះគ្រោះថ្នាក់ ឬ ការបំពុលដោយសាររ៉ែ នៅការដ្ឋានរ៉ែនោះ អាចមានការកើតឡើងក្នុងប៉ុន្មានភាគរយ?

4）តើមូលហេតុនៃការកើតឡើងនូវគ្រោះថ្នាក់ ឬ ការបំពុលដោយសាររ៉ែ នៅការដ្ឋានរ៉ែនោះ ជាអ្វីដែរ?

(វិធានការតប់ទល់នឹងហានិភ័យ)

1）បញ្ជៀសហានិភ័យ ⟶ ចាកចេញពីហានិភ័យ（ឧទាហរណ៍, បញ្ឈប់ ឬ ផ្អាកប្រើគ្រឿងចក្រ, បរិក្ខារ ）

2）កាត់បន្ថយហានិភ័យ ⟶ ចាត់វិធានការសំរាប់ធ្វើអោយអត្រានៃការកើតឡើងនៃគ្រោះមហន្តរាយនៅការដ្ឋានរ៉ែឬ ការបំពុលដោយសាររ៉ែ ថយចុះ។

3）ផ្លាស់ប្តូរហានិភ័យ ⟶ ទទួលបន្ទុកបែងចែកការខាត់បង់ពីហានិភ័យជាមួយនឹងអ្នកផ្សេងទៀត（ឧទាហរណ៍, ការទិញបណ្ណ័ធានារ៉ាប់រងសំរាប់គ្រោះថ្នាក់កើតមាន)

4）រក្សាទុកនូវហានិភ័យ ⟶ ទទួលស្គាល់ដឹងថាមានហានិភ័យមាន, ធ្វើការខ្លំមើលហានិភ័យដែលបានកំណត់ទុកនោះ

3．ចំនុចកំណត់ទាក់ទងនឹងសុវត្ថិភាពចំពោះសេចក្តីព្រៀងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ និង បញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ

（1）ច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

មាត្រាទិ១៨ (ស្រាវជ្រាវស្ថានភាពសុវត្ថិភាពនិងការថែរក្សា)

1 ម្ចាស់អាជីវកម្មរ៉ែដែលមានកម្មកររ៉ែធ្វើការលើសពីចំនួន៣០នាក់ នៅពេលចង់បើកអាជីវកម្មរ៉ែ , នៅពេលចង់ផ្អាកសកម្មភាពអាជីកម្មរ៉ែលើសពី១ខែ និង ចង់បញ្ចប់ការងារអាជីវកម្មរ៉ែ ព្រមទាំងនៅពេលចង់ផ្លាស់ប្តូរវិធីនៃការអនុវត្តអាជីវកម្មរ៉ែ, ធ្វើការស្រាវជ្រាវនូវស្ថានភាពសុវត្ថិភាពនិងការថៃទាំការដ្ឋានរ៉ែ ស្តីពីលទ្ធផលដែលរកឃើញនូវពេលស្រាវជ្រាវនិងចាំបាច់ត្រូវធ្វើការកែលំអចាំត្រូវតែចាត់វិធានការសមស្របសំរាប់ការងារទាំងនោះ។

2 ម្ចាស់អាជីវកម្មរ៉ែ គោរពតាមបែបបទដែលកំណត់ដោយសេចក្តីប្រកាសរបស់ក្រសួង ធ្វើការកត់ត្រានូវលទ្ធផលស្រាវជ្រាវសុវត្ថិភាពនិងការថែរក្សា រួចចាំបាច់ត្រូវតែរក្សទុកនូវការកត់ត្រាទាំងនោះ។

（2）បញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ

មាត្រាទី៤០ (ការអនុវត្តនូវការស្រាវជ្រាវសុវត្ថិភាពនិងការថែរក្សា)

ម្ចាស់អាជីវកម្មរ៉ែ យោងតាមការកំណត់នៃមាត្រាទី១៨-១ ចាំបាច់ត្រូវតែធ្វើការស្រាវជ្រាវពីសុវត្ថិភាពនិងការថែរក្សាដែលមានលើកឡើងដូចចំនុចខាងក្រោម៖

1) នៅពេលចង់បើកអាជីវកម្មរ៉ែនៅការដ្ឋានរ៉ែ ដោយទទួលបានការអនុញ្ញាតពីសំណាក់រដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។
2) ពេលចង់ចាប់ផ្តើមឡើងវិញ ឬ ផ្អាកអាជីវកម្មរ៉ែលើសពី១ខែ នៅការដ្ឋានរ៉ែ។
3) ពេលចង់ផ្លាស់ប្តូរក្នុងទ្រង់ទ្រាយធំនូវវិធីអនុវត្តការងារអាជីវកម្មរ៉ែ នៅការដ្ឋានរ៉ែ។
4) ពេលចង់បោះបង់ចោល ឬឈប់ចោលនូវសិទ្ធធ្វើអាជីវកម្មរ៉ែ។

មាត្រាទី៤១ (ចំនុចនៃការស្រាវជ្រាវនូវស្ថានភាពសុវត្ថិភាពនិងការថែរក្សា)

ម្ចាស់អាជីកម្មរ៉ែ យោងតាមការកំណត់តាមមាត្រា១៨-១ ធ្វើការវាយតំលៃ និង ស្វែងរកមូលហេតុនៃគ្រោះថ្នាក់ ស្តីពីចំនុចដែលមានដូចខាងក្រោម ស្តីពីចំនុចដែលទទួលស្គាល់មានការកែប្រែចាំបាច់ ត្រូវតែចាត់វិធានការសមស្រប៖

1) ស្ថានភាពទីកន្លែងជីកយករ៉ែ នៃការដ្ឋានរ៉ែ និងទីកន្លែងដែលនៅជុំវិញទីនោះ
2) ស្ថានភាពនៅជុំវិញការដ្ឋានរ៉ែ
3) ចំនុចទាក់ទងនឹងការចាត់វិធានការចាំបាច់ ដោយម្ចាស់អាជីកម្មរ៉ែ កំណត់តាមមាត្រា៥នៃច្បាប់។
4) ក្រៅពីចំនុចដែលបានលើកឡើងតាមចំនុចនិមួយៗមុន ចំនុចបំផ្លាញសុវត្ថិភាព ការកើតឡើងការបំពុលដោយសាររ៉ែ ភាពគ្រោះថ្នាក់កើតឡើង ។ល។

មាត្រាទី៤១ (ការកត់ត្រានូវលទ្ធផលនៃការស្រាវជ្រាវស្ថានភាពសុវត្ថិភាពនិងការថែរក្សា)

យោងតាមការកំណត់តាមមាត្រា១៨-២ ម្ចាស់អាជីកម្មរ៉ែ ការកត់ត្រាលទ្ធផលនៃការស្រាវជ្រាវសុវត្ថិភាព ចាំបាច់ត្រូវរក្សាទុកក្នុងរយៈពេល៥ឆ្នាំ ដោយគិតចាប់ពីថ្ងៃបានស្រាវជ្រាវ។

## 4. ករណីគំរូនៃការប្រើនិងបញ្ចូលប្រព័ន្ធគ្រប់ហានិភ័យនៅក្នុងការដ្ឋានរ៉ែនៃប្រទេសជប៉ុន

### (1) អនុវត្តការដើរល្បាតមើលសុវត្ថិភាពការដ្ឋានរ៉ែ (1 ដង／ខែ)

1) វចនាសម្ព័ន្ធនៃអ្នកដើរល្បាតមើលសុវត្ថិភាពការដ្ឋានរ៉ែ : ត្រូវការអ្នកទទួលបន្ទុកផ្នែកសុវត្ថិភាពនៅតាមទីកន្លែងធ្វើការនីមួយៗ (1 ក្រុម 3 នាក់× 3 ក្រុម= 9 នាក់)

2) ខ្លឹមសារនៃការដើរល្បាតសំរាប់សុវត្ថិភាពការដ្ឋានរ៉ែ :

i ) បែងការងារសំរាប់ក្រុមនីមួយៗទទួលបន្ទុក ដើរល្បាតតាមអគារនិងទីកន្លែងធ្វើការ អនុវត្តពិនិត្យពីសុវត្ថិភាពនៃប្រភេទបរិក្ខារ គ្រឿងចក្រ និងស្ថានភាពដែលត្រូវគោរពតាមបែបបទការងារ។

ii ) បញ្ជាក់ និងរកមើលអោយឃើញនូវមូលហេតុដែលអាចមានគ្រោះថ្នាក់ ឬការបំពុលបរិស្ថានដោយសារអាជីវកម្មរ៉ែ។ (ការកំណត់ និងការមើលអោយឃើញនូវហានិភ័យ)

3) ការពិគ្រោះយោបល់នូវវិធានការទប់ទល់ វាយតំលៃ និងការវិភាគពីហានិភ័យយោងតាម ប្រជុំជាក្រុម :

i ) នៅក្នុងពេលប្រជុំជាក្រុម យោងតាមរយៈអ្នកចូលរួមទាំងអស់ក្នុងដើរល្បាតសុវត្ថិភាពការដ្ឋានរ៉ែ ទាក់នឹងមូលហេតុដែលបណ្តាលអោយមានគ្រោះថ្នាក់ឬការបំពុល ដែលបានរកឃើញឥទ្ធិពលនៃករណីមានគ្រោះថ្នាក់ឬការបំពុលដោយសាររ៉ែ ធ្វើការពិគ្រោះនូវអត្រាភាគរយនៃការកើតឡើងនូវគ្រោះថ្នាក់និងការបំពុលនោះ។ (វិភាគនូវហានិភ័យ)

ii ) នៅក្នុងកិច្ចប្រជុំជាក្រុម យោងតាម「តារាងស្តង់ដាវាយតំលៃហានិភ័យ」ចំពោះការបែងចែកនូវមូលហេតុនៃគ្រោះថ្នាក់ឬការបំពុលដោយសាររ៉ែ ធ្វើការកំណត់ និងពិគ្រោះ ស្តីពីចំណាត់ថ្នាក់និងកំរិតនៃការវាយតំលៃហានិភ័យ។ (វាយតំលៃហានិភ័យ)

iii) នៅក្នុងកិច្ចប្រជុំជាក្រុម ស្តីពីវិធានការសមរម្យតប់ទល់នឹងហានិភ័យ ចំពោះគ្រប់មូលហេតុនៃគ្រោះថ្នាក់និងការបំពុល ធ្វើការពិគ្រោះរួមគ្នា និងធ្វើការសរុបនូវវិធានការទប់ទល់វាយតំលៃនិងវិភាគហានិភ័យ។ (វិធានការតប់ទល់នឹងហានិភ័យ)

### (2) ការកំណត់នូវវិធានការតប់ទល់នឹងហានិភ័យនៅក្នុងគណៈម្មការសុវត្ថិភាព

1) ស្តីពីវិធានការសមស្របចំពោះហានិភ័យ និងមូលហេតុមានគ្រោះថ្នាក់និងការបំពុលដោយសាររ៉ែដែលបានរកឃើញ តាមរយៈការដើរល្បាតសុវត្ថិភាពការងាររ៉ែ ត្រូវតែធ្វើការរាយការណ៏ដល់គណៈកម្មការសុវត្ថិភាព។

2) គណៈកម្មការសុវត្ថិភាព ធ្វើការបញ្ជាក់ និងធ្វើការកំណត់ ស្តីពីខ្លឹមសារនៃវិធានការសមរម្យចំពោះហានិភ័យ និងចំណាត់ថ្នាក់វាយតំលៃទាំងនោះ។

3) ទាក់ទងដល់ខ្លឹមសារនៃវិធានការកាត់បន្ថយហានិភ័យ អាចធ្វើតាមសេចក្តីត្រូវការ ដោយបង្កើតនូវ

「បែបបទធ្វើការងារ 」នៅការដ្ឋានរ៉ែ ព្រមទាំងធ្វើការមើលឡើងនូវបែបទាំងនោះ និងធ្វើការមើលឡើងនូវ「បទបញ្ហាសុវត្ថិភាពផ្ទៃក្នុង」ផងដែរ។

（3）ការបញ្ជាក់និងអនុវត្តនូវវិធានការសមស្របផ្សេងៗ

1）ស្តីពីខ្លឹមសារនៃវិធានការទប់ទល់នឹងហានិភ័យដែលបានកំណត់នៅក្នុងគណៈកម្មាការសុវត្ថិភាព ត្រូវអនុវត្តនូវិធានការសមស្របកែលំអទាំងនោះជាបន្ទាន់នៅតាមទីកន្លែងធ្វើការនីមួយៗ។

2）នៅក្នុងគណៈកម្មាការសុវត្ថិភាពដែលនឹងត្រូវបានបើកនៅក្នុងខែបន្ទាប់ ធ្វើការរាយការណ៍ពីស្ថានភាពអនុវត្តនូវវិធានការទាំងនោះ និងបញ្ជាក់អំពីការងារទាំងនោះ។

## 5．កំរិតវាយតំលៃហានិភ័យនិងការបង្កើតចំណាត់ថ្នាក់ទាំងនោះ ដោយអនុលោមតាមតារាងស្តង់ដាវាយតំលៃហានិភ័យ

（1）ចំនុចនៃរចនាសម្ព័ន្ធស្តង់វាយតំលៃហានិភ័យទាក់ទងនឹងគ្រោះថ្នាក់នៅការដ្ឋានរ៉ែ

A： កំរិតនៃគ្រោះថ្នាក់នៅពេលមានគ្រោះថ្នាក់កើតឡើង （ពិន្ទុ）

| | |
|---|---|
| ស្លាប់ | |
| របួសធ្ងន់ ឬ ពិការ | |
| របួសស្រាល（ឈប់ពីការងារក្រោមរយៈពេល២សប្តាហ៍） | |
| របួសតិចតួច（មិនឈប់ ឬ ឈប់ពីការងារមិនលើសពី៣ថ្ងៃ） | |

B：គ្រោះថ្នាក់អាចនឹងកើតមានឡើងនៅការដ្ឋានរ៉ែ （ពិន្ទុ）

| | |
|---|---|
| ភាពមានគ្រោះថ្នាក់នឹងមានភាគរយខ្ពស់ខ្លាំង（មានគ្រប់ពេល） | |
| ភាពមានគ្រោះថ្នាក់នឹងមានភាគរយខ្ពស់（កំរិតនៃការកើតឡើង：លើសពី១ដងក្នុង១សប្តាហ៍） | |
| ភាពមានគ្រោះថ្នាក់នឹងមានភាគរយទាប（កំរិតនៃការកើតឡើង：ក្រោមពី១ដងក្នុង១ខែ） | |
| ភាពមានគ្រោះថ្នាក់នឹងមានភាគរយទាបបំផុត ឬ សឹងមិនមានអ្វីកើតឡើង | |

（2）ចំនុចនៃរចនាសម្ព័ន្ធស្តង់វាយតំលៃហានិភ័យទាក់ទងនឹងការបំពុលបរិស្ថានដោយសាររ៉ែ នៅការដ្ឋានរ៉ែ

A : កំរិតនៃការបំពុលដោយសាររ៉ែនៅពេលមានគ្រោះថ្នាក់កើតឡើង (ពិន្ទុ)

| | |
|---|---|
| រងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត | |
| ផ្អាកអាជីវកម្មលើសពីរាប់ខែ | |
| ផ្អាកអាជីវកម្មក្នុងរយៈពេល១សប្តាហ៍ | |
| ផ្អាកអាជីវកម្មក្នុងរយៈពេលប៉ុន្មានថ្ងៃ | |

B : ការបំពុលដោយសាររ៉ែអាចនឹងកើតមានឡើងនៅការដ្ឋានរ៉ែ (ពិន្ទុ)

| | |
|---|---|
| អត្រានៃការកើតឡើងមានខ្ពស់បំផុត (មានគ្រប់ពេលវេលា) | |
| អត្រានៃការកើតឡើងមានខ្ពស់ (1ដង/ឆ្នាំ) | |
| អត្រានៃការកើតឡើងមានទាប (1ដង/10ឆ្នាំ ) | |
| អត្រានៃការកើតឡើងមានទាបបំផុត ឬ សឹងមិនកើតឡើង | |

C : មានជះឥទ្ធិពលដល់សង្គម (ពិន្ទុ)

| | |
|---|---|
| ការបំពុលបរិមាណក្នុងសភាពធ្ងន់ធ្ងរ | |
| ការបំពុលបរិមាណក្នុងសភាពធំ | |
| ការបំពុលបរិមាណក្នុងសភាពមធ្យម | |
| ការបំពុលបរិមាណក្នុងសភាពតូច | |

（3）ការវាយតំលៃនិងចាត់ថ្នាក់ទាក់ទងនឹងគ្រោះថ្នាក់ ឬការបំពុលដោយសាររ៉ែ នៅក្នុងការដ្ឋានរ៉ែ

| A+B+C | កំរិតវាយតំលៃហានិភ័យ | ចំណាត់ថ្នាក់នៃការវាយតំលៃហានិភ័យ |
|---|---|---|
| | មានមូលហេតុនៃគ្រោះថ្នាក់ដែលមិនអាចបណ្តោយអោយទុកបាន | Ⅳ |
| | មានមូលហេតុនៃគ្រោះថ្នាក់ធ្ងន់ធ្ងរ | Ⅲ |
| | មានមូលហេតុនៃគ្រោះថ្នាក់ | Ⅱ |
| | មិនត្រូវការវិធានការទប់ទល់នឹងគ្រោះថ្នាក់ | Ⅰ |

(ចំណាត់ថ្នាក់នៃការវាយតំលៃ)

IV: ចាំបាច់ត្រូវតែមានវិធានការទប់ទល់ជាបន្ទាន់

III: ចាំត្រូវតែមានផែនការទប់ទល់

II: ឆ្លើយតបយោងតាមរយៈសកម្មភាពផ្សព្វផ្សាយ និងប្រយ័ត្ន

I: គ្មានបញ្ហាចាត់វិធានការ

(4) មូលហេតុមានគ្រោះថ្នាក់ កំរិតនៃការវាយតំលៃហានិភ័យ ទាក់ទងនឹងគ្រោះថ្នាក់និងការបំពុលដោយសារវ៉ែនៅការដ្ឋានវ៉ែ និងខ្លឹមសារនៃវិធានការតប់នឹងហានិភ័យ និងការចាត់ថ្នាក់

កាលបរិច្ឆេទ: ឈ្មោះក្រុម:

| ឈ្មោះអគារ ឬ ឈ្មោះទីកន្លែងធ្វើការនៃការដ្ឋានវ៉ែ | ខ្លឹមសារនៃវិធានការតប់ទល់នឹងហានិភ័យ និងមូលហេតុនៃគ្រោះថ្នាក់ទាក់ទងនឹងគ្រោះថ្នាក់ឬការបំពុលដោយសារវ៉ែ នៅការដ្ឋានវ៉ែ | កំរិតនៃការវាយតំលៃហានិភ័យ | |
|---|---|---|---|
| | | Σ (A + B + C) | វាយចំណាត់ថ្នាក់នៃការវាយតំលៃ |
| | | | |
| (វិធានការតប់ទល់នឹងមូលហេតុនៃគ្រោះថ្នាក់) | | | |
| | | | |
| (វិធានការតប់ទល់នឹងមូលហេតុនៃគ្រោះថ្នាក់) | | | |
| | | | |
| (វិធានការតប់ទល់នឹងមូលហេតុនៃគ្រោះថ្នាក់) | | | |

(6) ការគិតនៃការបង្កើតដំណាក់កាល (ទំហំ) នៃកំរិតវាយតំលៃហានិភ័យ និងចំណាត់ថ្នាក់

ក្នុងការបង្កើតដំណាក់កាល (ទំហំ) នៃការវាយតំលៃហានិភ័យ និងកំរិតវាយតំលៃហានិភ័យ ប្រើតារាងដែលមានដូចខាងក្រោម ស្តីពីលេខសរុបនៃសារធាតុរចនាសម្ព័ន្ធនីមួយៗដែលបានកំណត់ដោយ

តារាងស្តង់ដាវាយតំលៃហានិភ័យ ដោយធ្វើការក្រុម កំណត់នូវដំណាក់កាល (ទំហំ) នៃចំណាត់ថ្នាក់ និងកំរិតនៃការវាយតំលៃ ដោយអនុលោមតាមលទ្ធផលនោះ។



(ឯកសារជំនួយ)

## ការកំណត់ដំណាក់កាល (ទំហំ) នៃចំណាត់ថ្នាក់ និងកំរិតវាយតំលៃទាក់ទង នឹងគ្រោះថ្នាក់នៃការដ្ឋានរ៉ែ

1. ចំនុចនៃរចនាសម្ព័ន្ធស្តង់វាយតំលៃហានិភ័យទាក់ទងនឹងគ្រោះថ្នាក់នៅការដ្ឋានរ៉ែ

A : កំរិតនៃគ្រោះថ្នាក់នៅពេលមានគ្រោះថ្នាក់កើតឡើង (ពិន្ទុ)

| | | |
|---|---|---|
| a1 | ស្លាប់ | 20 |
| a2 | របួសធ្ងន់ ឬ ពិការ | 10 |
| a3 | របួសស្រាល (ឈប់ពីការងារក្រោមរយៈពេល២សប្តាហ៍) | 6 |
| a4 | របួសតិចតួច (មិនឈប់ ឬ ឈប់ពីការងារមិនលើសពី៣ថ្ងៃ) | 3 |

B : គ្រោះថ្នាក់អាចនឹងកើតមានឡើងនៅការដ្ឋានរ៉ែ (ពិន្ទុ)

| | | |
|---|---|---|
| b1 | ភាពមានគ្រោះថ្នាក់នឹងមានភាគរយខ្ពស់ខ្លាំង (មានគ្រប់ពេល) | 20 |
| b2 | ភាពមានគ្រោះថ្នាក់នឹងមានភាគរយខ្ពស់ (កំរិតនៃការកើតឡើង : លើសពី១ដងក្នុង១សប្តាហ៍) | 10 |
| b3 | ភាពមានគ្រោះថ្នាក់នឹងមានភាគរយទាប (កំរិតនៃការកើតឡើង : ក្រោមពី១ដងក្នុង១ខែ) | 6 |
| b4 | ភាពមានគ្រោះថ្នាក់នឹងមានភាគរយទាបបំផុត ឬ សឹងមិនមានអ្វីកើតឡើង | 2 |

2. ការកំណត់ដំណាក់កាល (ទំហំ) នៃចំណាត់ថ្នាក់ និងកំរិតវាយតំលៃទាក់ទងនឹងគ្រោះថ្នាក់នៃការដ្ឋានរ៉ែ

(A＋B)

1) a1 + b1 = 20 + 20 = 40
2) a1 + b2 = 20 + 10 = 30
3) a1 + b3 = 20 + 6 = 26
4) a1 + b4 = 20 + 2 = 22
5) a2 + b1 = 10 + 20 = 30
6) a2 + b2 = 10 + 10 = 20
7) a2 + b3 = 10 + 6 = 16

8)  a2 + b4 = 10 + 2 = 12
9)  a3 + b1 = 6 + 20 = 26
10) a3 + b2 = 6 + 10 = 16
11) a3 + b3 = 6 + 6 = 12
12) a3 + b4 = 6 + 2 = 8
13) a4 + b1 = 3 + 20 = 23
14) a4 + b2 = 3 + 10 = 13
15) a4 + b3 = 3 + 6 = 9
16) a1 + b4 = 3 + 2 = 5




３． ការកំណត់ទំហំនៃចំណាត់ថ្នាក់ និងកំរិតវាយតំលៃទាក់ទងនឹងគ្រោះថ្នាក់នៃការដ្ឋានរ៉ែ

| A+B | កំរិតនៃការវាយតំលៃហានិភ័យ | ចំណាត់ថ្នាក់នៃហានិភ័យ |
|---|---|---|
| 22 ～ 40 | មានមូលហេតុនៃគ្រោះថ្នាក់ដែលមិនអាចបណ្តោយអោយទុកបាន | Ⅳ |
| 12～ 20 | មានមូលហេតុនៃគ្រោះថ្នាក់ធ្ងន់ធ្ងរ | Ⅲ |
| 8～ 12 | មានមូលហេតុនៃគ្រោះថ្នាក់ | Ⅱ |
| ≦5 | មិនត្រូវការវិធានការទប់ទល់នឹងគ្រោះថ្នាក់ | Ⅰ |

(ចំណាត់ថ្នាក់នៃការវាយតំលៃ)

| | |
|---|---|
| IV : | ចាំបាច់ត្រូវតែមានវិធានការទប់ទល់ជាបន្ទាន់ |
| III : | ចាំត្រូវតែមានផែនការទប់ទល់ |
| II : | ឆ្លើយតបយោងតាមរយៈសកម្មភាពផ្សព្វផ្សាយ និងប្រយ័ត្ន |
| I : | គ្មានបញ្ហាចាត់វិធានការ |

# បែបបទអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ

## (ការត្រួតពិនិត្យទូទៅVol. 1៖ វគ្គទប់ស្កាត់គ្រោះថ្នាក់)

June 1, 2016

## ជំពូកទី១ :  ការរៀបចំមុនការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)

1. ចំនុចទាំងឡាយត្រូវតែក្តាប់ទុកជាមុន មុនការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)

មន្ត្រីពាក់ព័ន្ធនិងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែទទួលបន្ទុកការងារ ខាងក្រោមមកទៀតហៅកាត់ថា「មន្ត្រីអធិការកិច្ច」) មុននឹងអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)ចំពោះការដ្ឋានរ៉ែ ចាំត្រូវតែក្តាប់បានជាមុន ពីស្ថានភាពសុវត្ថិភាព, ភាពដំណើរការរបស់ការដ្ឋានរ៉ែនោះ និងត្រូវពិនិត្យ-ស្រាវជ្រាវពីចំនុចដែលមានដូចខាងក្រោម៖

(1) ផែនការនៃការជីកយក

មន្ត្រីអធិការកិច្ច ត្រូវក្តាប់អោយបានគ្រប់គ្រាន់ ស្តីពីចំនុចមានឬក៏មិនមានទាក់ទងនឹងសុវត្ថិភាពការដ្ឋានរ៉ែនៃតំបន់ក្បែរតំបន់រ៉ែដោយឆ្លើយតបនឹងភាពចាំបាច់ ក្រៅពីការក្តាប់បានមុនស្តីពីចំនុចមុនទាក់ទងនឹង「សុវត្ថិភាពការដ្ឋានរ៉ែ」នៅក្នុងផែនការជីកយកកំណត់ក្នុងមាត្រាទី២១-៤「ច្បាប់ទាក់ទងនឹងការជីកយក និងគ្រប់គ្រងធន ធានរ៉ែ」សំរាប់អនុវត្តការងាររ៉ែ ផងដែរ។

(2) បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុនសិន ស្តីពីខ្លឹមសារនិងស្ថានភាពដែលត្រូវបានកំណត់នៅក្នុងបទបញ្ញតិសុវត្ថិភាពនៅក្នុងការដ្ឋានរ៉ែ។

(3) ចំនុចត្រូវរាយការណ៍

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីការអនុញ្ញាត និងការរាយការណ៍ទាក់ទងនឹងឧបករណ៍ផលិតនិងអគារសំណង់។ល។ ប្រើប្រាស់នៅក្នុងការងារអាជីវកម្មរ៉ែ។

(4) រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពី ស្ថានភាពជ្រើសរើសអ្នកគ្រប់គ្រងសុវត្ថិភាពរួម, ស្ថានភាពនៃការជ្រើសរើសអ្នកតំណាំងអោយអ្នកគ្រប់គ្រងសុវត្ថិភាពរួមព្រមទាំងខ្លឹមសារនៃការរាយការណ៍ទាក់ទងនឹងការងារនេះ។

(5) ផែនទីសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីការបង្កើតផែនទីសុវត្ថិភាព ព្រមទាំងខ្លឹមសារនៃការរាយការណ៍ទាក់ទងនឹងការងារនេះ។

(6) ផែនការជីកយកពិសេស

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីខ្លឹមសារនៃករណីបានទទួលការការអនុញ្ញាតនិងរាយការណ៍ពី「ផែនការជីកយកពិសេស」នៅការដ្ឋានរ៉ែ ចំពោះការជីកយករ៉ែ នៅក្នុងដីដែលបណ្តាលនឹងអាចអោយមានគ្រោះថ្នាក់ឬការបំពុលបរិដ្ឋានកើតមាននៅការដ្ឋានរ៉ែ តាមរយៈការចេញទឹក ឬការបំពុលដោយរ៉ែ ឬនៅក្រោមបាតបឹងទន្លេសមុទ្រ។

(7) ចំនុចមិនទាន់បានសំរេចនិងចំនុចបញ្ហា

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីចំនុចមិនទាន់បានសំរេច និងចំនុចបញ្ហាទាក់ទងនឹងការដ្ឋានរ៉ែនោះ និងខ្លឹមសាររបស់មន្ត្រីអធិការកិច្ចដែលបានអនុវត្តការត្រួតពិនិត្យរួចមកហើយ។

(8) ទិដ្ឋភាពទូទៅនៃការដ្ឋានរ៉ែដែលត្រូវធ្វើការត្រួតពិនិត្យ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន តាមរយៈលទ្ធផលរបាយការណ៍ត្រួតពិនិត្យទូទៅដែលត្រូវបានអនុវត្តកាលពីអតីតកាល ស្ថានភាពដំណើរការការដ្ឋាននោះ ភាពប្រែប្រួលនៃបរិមាណរ៉ែដែលបានជីកយក ភាពប្រែប្រួលនៃចំនួនកម្មកររ៉ែ ស្ថានភាពគ្រោះថ្នាក់កាលពីអតីតកាលនិងស្ថានភាពកើតឡើងនូវបញ្ហាបំពុលបរិដ្ឋានដោយសាររ៉ែ និងស្តីពីស្ថានភាពនៃបទល្មើសនឹងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែនិងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ (ខាងក្រោមមកទៀតហៅកាត់ថា「ច្បាប់និងបទបញ្ញតិ」)។

2. ចំនុចរៀបចំជាមុនក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)

(1) បង្កើតផែនការអនុវត្តត្រួតពិនិត្យនិងពិគ្រោះយោបល់ជាមុនទាក់ទងនឹងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)

មន្ត្រីអធិការកិច្ច ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់) យោងតាមទំហំដំណើរការសកម្មភាពនៃការដ្ឋាននោះ, ចំនុចដែលត្រូវបានបញ្ជាអោយធ្វើការកែលំអនៅក្នុងពេលធ្វើការត្រួតពិនិត្យកាលពីលើកមុន, ស្ថានភាពកើតគ្រោះថ្នាក់នៅការដ្ឋានរ៉ែ, ស្ថានភាពកើតការបំពុលនៅការដ្ឋានរ៉ែ, ចំនុចដែលមិនទាន់បានដោះស្រាយនិងចំនុចជាបញ្ហានានា, ទិសដៅណែនាំការត្រួតពិនិត្យកំណត់ដោយស្ថានប័នរបស់រដ្ឋាភិបាល។ល។ ធ្វើយ៉ាងណាអនុវត្តការត្រួតពិនិត្យអោយមានប្រសិទ្ធិភាព-លទ្ធផលល្អ ដោយធ្វើការពិភាក្សាគ្នាជាមុនសំរាប់ចាប់យកនូវចំនុចធ្វើការពិនិត្យ(ចំនុចសំខាន់នានា)នៅក្នុងការដ្ឋានរ៉ែ លើសពីនេះ បើចាំបាច់អាច

ទទួលការបង្គាប់បញ្ជាពីសំណាក់ថ្នាក់លើទាក់ទងនឹងការត្រួតពិនិត្យ, ធ្វើការរៀបចំផែនការ (កាលបរិច្ឆេទនៃការត្រួតពិនិត្យ, ចំនុចសំខាន់ក្នុងការត្រួតពិនិត្យ, ការបែងចែកការទទួកបន្ទុកតំបន់សំរាប់ធ្វើការត្រួតពិនិត្យ។ល។តាមរយៈមន្ត្រីអធិការកិច្ច)អនុវត្តការត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)។

(2) រៀបចំនូវឧបករណ៍កាន់ជាប់ផ្ទាល់ខ្លួនក្នុងត្រួតពិនិត្យទូទៅ

ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់) ចាំបាច់ត្រូវរៀបចំនូវឯកសារនិងឧបករណ៍ដែលមានរៀបរាប់ដូចខាងក្រោម៖

1) ឯកសាររបាយការណ៍នៃត្រួតពិនិត្យទូទៅកាលពីមុន(ថតចំលង)។
2) បទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែ
3) ផែនទីសុវត្ថិភាពការដ្ឋានរ៉ែ(ថតចំលង)
4) លិខិតណែនាំកែលំអ និង លិខិតបញ្ជា(មិនទាន់បំពេញ)
5) **field note**
6) សំលៀកបំពាក់ការងារ, ស្បែកជើងសុវត្ថិភាព, ស្រោមដៃ
7) មួកសុវត្ថិភាព, ម៉ាសការពារធូល
8) **clinometer,** ម៉ែត្រមូល
9) ឧបករណ៍ត្រួតពិនិត្យឧស្ម័នមានជាតិឆេះ(ចំពោះការដ្ឋានរ៉ែធ្យូងថ្មក្រោមដី និងការដ្ឋានរ៉ែដែលត្រូវបានពិនិត្យថាមានឧស្ម័នជាតិឆេះ)
10) ឧបរកណ៍វាស់ឧស្ម័នគ្រប់ប្រភេទ ($CO$, $CO_2$, $H_2S$។ល។)
11) ម៉ាស៊ីនថតរូប
12) អត្តសញ្ញាណប័ណ្ណមន្ត្រីសុវត្ថិភាពការដ្ឋានរ៉ែ

## ជំពូក២ : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)

1. អនុវត្តត្រួតពិនិត្យទូទៅនៅការិយាល័យការដ្ឋានរ៉ែ (ទប់ស្កាត់គ្រោះថ្នាក់)

មន្ត្រីអធិការកិច្ច នៅការិយាល័យការដ្ឋានរ៉ែ ស្តីពីចំនុចមានដូចខាងក្រោម ត្រូវសាកសួរដល់អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព(ខាងក្រោមមកទៀតហៅថា អ្នកគ្រប់សុវត្ថិភាព)(និង/ឬ) និងអ្នកគ្រប់គ្រងការងារ ពីឯកសារកំណត់ដោយច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ(ឯកសារគ្រប់គ្រង, ឯកសារត្រួតពិនិត្យ, សៀវភៅកត់ត្រាសុវត្ថិភាពប្រចាំថ្ងៃ។ល។) និងព្រមទាំងធ្វើការពិនិត្យនូវខ្លឹមសារនៃកាត់ត្រាទាំងនោះ, ធ្វើការណែនាំកែលំអក្នុងករណីរកឃើញចំនុចមិនប្រក្រតីលើផ្នែកសុវត្ថិភាព។

(1) សាកសួរនូវស្ថានភាពដំណើរការងារ, ណែនាំនិងបញ្ជាក់

មន្ត្រីអធិការកិច្ច ស្តីពីផែនការជីកយក(បរិមាណនាំយកបរិមាណរ៉ែចេញ, ទីកន្លែងកំពុងយករ៉ែបច្ចុប្បន្នកាល, ស្ថានភាពនៃការផលិត) ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ពីស្ថានភាពពីការប្រតិបត្តិការលើការរក្សាសុវត្ថិភាពនៅការដ្ឋានរ៉ែ ពិនិត្យបញ្ជាក់តើមានឬមិនមានបញ្ហា ឬ មានឧបសគ្គចំពោះផែនការជីកយករ៉ែ, ស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើកាណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(2) ណែនាំ បញ្ជាក់ និងសាកសួរពីស្ថានភាពគ្រប់គ្រងកំលាំងពលកម្មនិងទំហំការងាររបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួម

1) ទំហំការងាររបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួម, អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងអ្នកគ្រប់គ្រងការងារ

មន្ត្រីអធិការកិច្ច ធ្វើការសាកសួរស្តីពីទំហំការងារលំអិតដែលអនុវត្តដោយអ្នកគ្រប់គ្រងសុវត្ថិភាពរួម, អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងអ្នកគ្រប់គ្រងការងារ បញ្ជាក់ស្តីពីទំហំការងារលំអិតនោះដែលត្រូវបានកំណត់ច្បាស់លាស់ឬមិនច្បាស់លាស់ បញ្ជីឯកសារការងារ ឬសៀវភៅកត់ត្រា។ល។ ពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើកាណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

2) ស្ថានភាពគ្រប់គ្រងកំលាំងពលកម្ម

មន្ត្រីអធិការកិច្ច ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីផែនការជ្រើសរើសកំលាំងពលកម្មមនុស្សទៅថ្ងៃអនាគត ការប្រែប្រួលនាំកំលាំងពលកម្មដែលមានស្រាប់នៅក្នុងការដ្ឋានរ៉ែ ធ្វើការបញ្ជាក់នូវមានឬមិនឧបសគ្គចំពោះស្ថានភាពគ្រប់គ្រកំលាំងពលកម្មលើការរក្សាបាននូវសុវត្ថិភាព ស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើកាណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(3) ណែនាំ ធ្វើការបញ្ជាក់ និងសាកសួរពីស្ថានភាពជ្រើសរើសអ្នកគ្រប់គ្រងការងារ

មន្ត្រីអធិការកិច្ច ធ្វើការបញ្ជាក់ពីបញ្ជីគ្រប់គ្រង បញ្ជីកត់ត្រា សៀវភៅសុវត្ថិភាពប្រចាំថ្ងៃដែលត្រូវបានកំណត់ដោយបទបញ្ញត្តិនិងច្បាប់សុវត្ថិភាពការងាររ៉ែ តើមានបានការបែងចែកទៅតាមគោលដៅនីមួយៗនៃទីតាំងជាក់ស្តែងដែរឬទេ ការជ្រើសរើសអ្នកគ្រប់គ្រងការងារមានភាពសមរម្យទៅតាមស្ថានភាពនៃបរិក្ខារគ្រឿងចក្រការដ្ឋានរ៉ែ ទំហំនៃការដ្ឋានរ៉ែដែរឬទេស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើកាណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(4) ណែនាំ បញ្ជាក់និងសាកសួរពីស្ថានភាពអប់រំសុវត្ថិភាពចំពោះកម្មកររ៉ែ

មន្ត្រីអធិការកិច្ច ធ្វើការបញ្ជាក់នូវការកត់ត្រាស្តីពីស្ថានភាពការអប់រំផ្នែកសុវត្ថិភាព ដោយ

ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ពីខ្លឹមសារអនុវត្តការអប់រំអំពីសុវត្ថិភាពចំពោះកម្មករ រ៉ែ នៅពេលចង់អនុវត្តការងារមានគ្រោះថ្នាក់ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិ និងអោយកម្មកររ៉ែអនុវត្តការងារនៅក្នុងរូងថ្មីនៅក្នុងការដ្ឋានរ៉ែនោះ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(5) ការណែនាំ បញ្ជាក់និងសាកសួរទាក់ទងនឹងការកំហិតការប្រើប្រាស់បរិក្ខារ គ្រឿងចក្រ។ល។ មានគ្រោះថ្នាក់ក្នុងការប្រើប្រាស់នៅក្នុងការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ធ្វើការបញ្ជាក់តាមរយៈលិខិតបញ្ជាក់ជាប់ស្តង់នៃការពិនិត្យស្តីពីបរិក្ខារ គ្រឿងចក្រ។ល។ សាកសួរតើប្រើប្រើប្រាស់បរិក្ខារជាប់ការពិនិត្យដែលទាក់ទងនឹងភាពមានគ្រោះថ្នាក់ដូចជា គ្រឿងចក្រ បរិក្ខារ ឬប្រភេទនៃរំសេវនិងសារធាតុប្រើប្រាស់ផ្សេងទៀតនៅក្នុងការដ្ឋានរ៉ែសំរាប់ការជីកយករ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(6) ណែនាំ បញ្ជាក់ សាកសួរ ទាក់ទងនឹងគណៈកម្មការសុវត្ថិភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព បញ្ជាក់ពីការកត់ត្រានូវខ្លឹមសារ។ល។ពីខ្លឹមសារនៃការពិភាក្សាទាក់ទងនឹងចំនុចសំខាន់ ស្តីសកម្មភាពគណៈកម្មការ សាកសួរពីស្ថានភាពសកម្មភាពទាំងនោះ និងការបង្កើតគណៈកម្មការសុវត្ថិភាព ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(7) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងការស្រាវជ្រាវស្ថានភាពសុវត្ថិភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព បញ្ជាក់ពីបញ្ជីកត្រា។ល។ស្តីពីខ្លឹមសារនៃលទ្ធផលការស្រាវជ្រាវនោះដោយសាកសួរតើមានការអនុវត្តនូវ「ការស្រាវជ្រាវផ្នែកសុវត្ថិភាព」ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិនៅក្នុងការដ្ឋានរ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(8) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងការងារទទួលធ្វើបន្ត

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីការងារទទួលបន្តដោយអ្នកក្រៅទទួលការងារដឹកជញ្ជូនកាកសំណល់រ៉ែឬបន្សាប មានធ្វើការលើសពី១ខែនៅក្នុងការដ្ឋានរ៉ែក្រោមដីក្នុងការងារយករ៉ែ ធ្វើការបញ្ជាក់តើមានបង្កើតផែនការការងារទទួលធ្វើបន្ត និងតើបានរាយការណ៍នូវផែនការនោះដែរឬទេ ពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

ករណីបានរាយការណ៍នូវផែនការការងារទទួលបន្ត ធ្វើការបញ្ជាក់នូវខ្លឹមសារនោះតើមានបញ្ហាឬមានឧបសគ្គក្នុងការរក្សាសុវត្ថិភាពនៅក្នុងការដ្ឋានរ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(៩) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងចំនុចបញ្ហាណែនាំកែលំអ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីស្ថានភាពកែលំអនៅក្នុង「លិខិតបញ្ជាក់កែលំអ」ដែលត្រូវបានប្រកាសផ្តល់នៃការអនុវត្តត្រួតពិនិត្យជាក់ស្តែងទូទៅកាលពីអតីតកាល, មានភាពត្រឹមត្រូវឬមិនត្រឹមត្រូវនៃស្ថានភាពកែលំអ, ស្ថានភាពនៃការដំណើរការការងារ, បញ្ជាក់នូវកាលបរិច្ឆេទបញ្ចប់ការងារ។ល។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

បើមានករណីពុំទាន់បានកែលំអ ស្តីពីចំនុចនៃនាំកែលំអកាលពីអតីតកាល ត្រូវសាកសួរនូវមូលហេតុទាំងថែមទៀតផង។

(១០) ណែនាំ បញ្ជាក់ សាកសួរទាក់តងនឹងផែនការប្រើប្រាស់ដីក្រោយពីបានធ្វើអាជីវកម្មរួច ឬការស្តារបរិស្ថានឡើងវិញក្រោយពីបានយករ៉ែរួចតាមបែបការដ្ឋានរ៉ែបើក

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីស្តីពីផែនការប្រើប្រាស់ឡើងវិញនៃដីដែលបានធ្វើអាជីវកម្មរ៉ែរួច ឬផែនការស្តារឡើងវិញទាក់ទងនឹងការដាំដើមឈើ និងការលុបគ្រប់ដី ការលុបឡើងវិញទាក់ទងនឹងកន្លែងបានយករ៉ែរួចនៃការដ្ឋានរ៉ែបើកដែលបានបញ្ចប់ការយករ៉ែ ឬកន្លែងដែលនឹងជិតបញ្ចប់ការយករ៉ែ បញ្ជាក់ពីខ្លឹមសារទាំងនោះតើមានបញ្ហាឬក៏គ្មានបញ្ហាលើផ្នែករក្សាសុវត្ថិភាពនៃការដ្ឋានរ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(១១) ណែនាំ បញ្ជាក់ និងសាកសួរទាក់តងនឹងរចសម្ព័ន្ធជួយសង្គ្រោះនៅពេលមានភាពអសន្នកើតឡើងជាបន្ទាន់ ឬនៅពេលមានគ្រោះថ្នាក់កើតឡើង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរអ្នកគ្រប់គ្រងសុវត្ថិភាព តើមានរៀបចំនូវរចនាសម្ព័ន្ធទាក់ទង និងជួយសង្គ្រោះនៅពេលមានស្ថានភាពអសន្ន ឬការកើតឡើងនូវការបំពុលឬគ្រោះថ្នាក់កើតឡើងធ្ងន់ធ្ងរ សាកសួរតើអនុវត្តការហ្វឹហាត់មានដូចខាងក្រោម ពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

១) អនុវត្តហ្វឹកហាត់ជន្លៀសខ្លួនអោយបាន១ដងក្នុងរយៈពេល៦ខែ ចំពោះកម្មកររ៉ែធ្វើការ

នៅក្នុងការដ្ឋានរ៉ែក្រោមដី

2) បង្កើតក្រុមសង្គ្រោះបន្ទាន់ អនុវត្តហ្វឹកហាត់ក្រុមសង្គ្រោះបន្ទាន់នៅការដ្ឋានរ៉ែ អោយបានលើសពី១ដងក្នុងរយៈពេល៦ខែ។

(១២) ណែនាំ បញ្ជាក់សាកសួរទាក់ទងនឹងការខិតខំជំរុញសកម្មភាពសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរ អ្នកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែស្តីពីការខិតខំជាលក្ខណៈលំអិតពីសកម្មភាពសុវត្ថិភាពការដ្ឋានរ៉ែដែលកំពុងតែមានផែនការអនុវត្តនិងសភាពបច្ចុប្បន្ននៅការដ្ឋានរ៉ែ , បញ្ជាក់ពិនិត្យផែនការនិងសម្មិទ្ធផលជាក់ស្តែង ពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(១៣) បញ្ជាក់ និងសាកសួរទាក់ទងនឹងអគារសាធារណៈ និងស្ថានភាពបរិដ្ឋាននៅជុំវិញការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអគារសាធារណៈ(ផ្លូវ, ស្ពាន, ទំបន់ទឹក, សួនច្បារ,មន្ទីរពេទ្យ, សាលារៀន។ល។) និងស្ថានភាពបរិដ្ឋានលំដាននៅជុំវិញការដ្ឋានរ៉ែដីកសិកម្ម, ទន្លេ។ល។ បើគិតថាមានភាពចាំបាច់ អាចនឹងធ្វើការវាស់បញ្ជាក់ពីគំលាតប្រវែងនឹងអគារទាំងនោះជាមួយនឹងទីកន្លែងធ្វើការជីកយករ៉ែ។

(១៤)បញ្ជាក់និងសាកសួរទាក់ទងនឹងមានឬក៏មានការប្តឹងពីប្រពលរដ្ឋរស់នៅក្នុងតំនប់នោះ។ល។

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរដល់អ្នកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ ក្នុងករណីមានការប្តឹងពីប្រជាពលរដ្ឋ សាកសួរពីការស្នើរសុំនិងការប្តឹងទៅលើការធ្វើអាជីវកម្មរ៉ែពីប្រជាពលរដ្ឋរស់នៅក្បែរការដ្ឋានរ៉ែ សាកសួរលំអិតពីស្ថានភាពទប់ទល់នឹងរបស់ការដ្ឋានរ៉ែ និងខ្លឹមសារទាំងនោះ។

(១៥) បញ្ជាក់និងសាកសួរទាក់ទងនឹងស្ថានភាពគ្រប់គ្រងការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរទាក់ទងនឹងស្ថានភាពគ្រប់គ្រងអាជីវកម្មរ៉ែតាមតែសេចក្តីត្រូវការចាំបាច់នៅពេលនោះ ពីសំណាក់អ្នកទទួលបន្ទុកគ្រប់គ្រងការដ្ឋានរ៉ែអនុវត្តបញ្ជាក់តើមានឧបសគ្គលើផ្នែកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែដែរឬទេ?

២. ណែនាំនិងបញ្ជាក់ទាក់ទងនឹងបញ្ជីគ្រប់គ្រងការកត់ត្រានិងសៀវភៅគ្រប់គ្រង, សៀវភៅសុវត្ថិភាពប្រចាំថ្ងៃគ្រប់ប្រភេទនីមួយៗដែលត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ

(១) ណែនាំ និងបញ្ជាក់ទាក់តងនឹងចំនុចកត់ត្រានៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃនៃប្រភេទនីមួយៗ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ស្តីពីចំនុចដែលបានអនុវត្តសំរាប់សុវត្ថិភាពនិងការងារទាក់ទងនឹងសុវត្ថិភាពតាមការកំណត់នៅក្នុងច្បាប់ដែលត្រូវអនុវត្តដោយអ្នកគ្រប់គ្រង ធ្វើការពិនិត្យនូវសៀវភៅសុវត្ថិភាពប្រចាំថ្ងៃគ្រប់ប្រភេទដែលបានកត់ត្រូវពីលទ្ធផលទាំងនោះ លើសពីនេះ តើមានសរសេរនៅលើបែបបទដែលមានគំរូស្រាប់ដែរឬទេ ពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនិងសុវត្ថិភាពក្រៅរូង។
2) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនិងសុវត្ថិភាពក្នុងរូង។
3) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកសុវត្ថិភាពគ្រឿងចក្រ
4) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកសុវត្ថិភាពអគ្គិសនី។
5) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកទប់ស្កាត់ការបំពុលបរិដ្ឋាន។
6) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកក្បាលរថភ្លើង។
7) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកប្រភេទនៃសារធាតុរំសេវ។
8) សៀវភៅសុវត្ថិភាពកត់ត្រាពីលទ្ធផលនៃការត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការងារទទួលផ្នែកសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព។

(2) ណែនាំនិងបញ្ជាក់ទាក់ទងនឹងចំនុចកត់ត្រាលើបញ្ជីគ្រប់គ្រងការកត់ត្រា, បញ្ជីគ្រប់ប្រភេទនៃលទ្ធផលការវាស់ឬលទ្ធផលការពិនិត្យក្នុងកាលបរិច្ឆេទថេរ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការបញ្ជាក់តើមានការពិនិត្យនៅលើបញ្ជីគ្រប់គ្រងប្រភេទនីមួយៗដោយអ្នកគ្រប់គ្រងសុវត្ថិភាព តើមានឬមិនមានបញ្ហាចំពោះលទ្ធផលការវាស់ ឬលទ្ធផលការពិនិត្យ តើមានថែរក្សាទុក រៀបចំនូវបញ្ជីគ្រប់គ្រងកត់ត្រា ឬសៀវភៅគ្រប់គ្រងប្រភេទនីមួយៗដែលបានកត់ត្រាពីលទ្ធផលបានវាស់ ឬពិនិត្យលំអិតជាប្រចាំដែលបានកំណត់ដោយច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ ពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលពិនិត្យលំអិតជាប្រចាំចំពោះបរិក្ខារ គ្រឿងចក្រ ដែលត្រូវការប្រយ័ត្នលើផ្នែកសុវត្ថិភាពដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពគ្រឿងចក្រ។

2) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលពិនិត្យលំអិតជាប្រចាំចំពោះការតំឡើងបរិក្ខារម៉ាស៊ីនប្រើចរន្តអគ្គិសនី, បរិក្ខារប្រើចរន្តអគ្គិសនី, ខ្សែចែកចាយ និងការតំឡើងខ្សែម៉ាស។ល។ដែលត្រូវការប្រយ័ត្នលើផ្នែកសុវត្ថិភាពដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពអគ្គិសនី។

3) អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបផ្ទុះនិងសុវត្ថិភាពក្រៅរូង ឬអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះក្នុងរូង ធ្វើការវាស់និងកត់ត្រានៃលទ្ធផលនូវអត្រាភាគរយរួមទាំងស៊ីលីកាត អាស៊ីតនៅក្នុងធូលីនោះ និងកំហាប់ធូលីនៅក្នុងខ្យល់ នៃទីកន្លែងធ្វើការនៅក្នុងបន្ទប់ ឬទីកន្លែងធ្វើការងារនៅក្នុងរូងដែលមានហុយនូវធូលីខ្លាំង។

4) អ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកបំផ្ទុះនៅក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្ម (រ៉ែធ្យូងថ្មប្រភេទ Aនិង B)បែបការដ្ឋានរ៉ែបិទ សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលការវាស់កំហាប់ឧស្ម័នមានភាពឆេះ, បរិមាណខ្យល់ឆ្លងកាត់, បរិមាណខ្យល់, កំរិតសំណើម, សំពាធខ្យល់នៅក្នុងរូង។

5 ) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលនៃការត្រួតពិនិត្យលំអិតជាប្រចាំនៃរថភ្លើងពិសេសនិងរថភ្លើងដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកក្បាលរថភ្លើង។

6)សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលនៃការត្រួតពិនិត្យលំអិតជាប្រចាំនៃរថយន្តនិងគ្រឿងចក្រប្រភេទយាន្តនៃការដ្ឋានរ៉ែ ដោយអ្នកម្ចាស់អាជីវកម្មរ៉ែ។

7) សៀវភៅកត់ត្រានូវលទ្ធផល ការត្រួតពិនិត្យពីបរិក្ខារទប់ស្កាត់ការផ្ទុះផ្ទួនៗគ្នា និងស្ថានភាពនៃការចាត់វិធានការចំពោះធូលីធ្យូងថ្មមានភាពផ្ទុះ ដោយអ្នកគ្រប់ក្រងការងារទទួលបន្ទុកសុវត្ថិភាពនៅក្នុងរូង (កំណត់នៅក្នុងបទបញ្ញតិតសុវត្ថិភាពការដ្ឋានរ៉ែ (ដំណាក់កាលទី២))

8 ) សៀវភៅកត់ត្រានូវលទ្ធផល ពីទិសដៅនៃការប៉ូមឧស្ម័ន ឬខ្ទង់ទុកជាមុនដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកសុវត្ថិភាពនៅក្នុងរូង។

9 ) ម្ចាស់អាជីវកម្មរ៉ែធ្វើការ កត់ត្រាបញ្ជីគ្រប់គ្រងការកត់ត្រាដែលបានវាយតំលៃនូវបរិដ្ឋានការងារអនុលោមតាមលទ្ធផលបានវាស់នូវអត្រាមានស៊ីលីស៊ីតអាស៊ីតនៅក្នុងធូលីនោះ និងកំហាប់ធូលីនៅក្នុងខ្យល់នៃទីកន្លែងធ្វើការនៅក្នុងបន្ទប់ ដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង។

1 0 ) ស់អាជីវកម្មរ៉ែធ្វើការ បញ្ជីគ្រប់គ្រងកត់ត្រាវាយតំលៃនុវបរិដ្ឋានការងារអនុលោមតាមលទ្ធផលបានវាស់នូវអត្រាលីស៊ីតអាស៊ីតនៅក្នុងធូលីនោះនិងកំហាប់ធូលីនៅក្នុងខ្យល់នៅ

ទីកន្លែងធ្វើការដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង
(កំណត់នៅក្នុងបទបញ្ញតិតសុវត្ថិភាពការដ្ឋានរ៉ែ (ដំណាក់កាលទី២))

3. អនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)នៅក្នុងទីកន្លែងធ្វើការនិងតាមអគារនៃការដ្ឋានរ៉ែ

(1) ចំនុចគ្រប់គ្រងទូទៅ

1) ការស្នើរចំពោះការចូលរួមការត្រួតពិនិត្យទូទៅចំពោះអ្នកគ្រប់គ្រងសុវត្ថិភាពទូទៅ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)ចំពោះទីកន្លែងធ្វើការនិងអគារការដ្ឋានរ៉ែ ធ្វើការស្នើរអោយមានការចូលរួមពីសំណាក់អ្នកគ្រប់គ្រងសុវត្ថិភាពរួមឬអ្នកតំណាំង, ឬ អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព បើមានភាពចាំបាច់អាចស្នើសុំអោយមានការចូលរួមពីសំណាក់អ្នកគ្រប់គ្រងការងារនៃទីកន្លែងធ្វើការងារឬអគាររបស់ការដ្ឋានរ៉ែ និងស្នើសុំអោយមានការពន្យល់ស្តីពីស្ថានភាពការងារឬស្ថានភាពប្រើប្រាស់នូវអគាររបស់ការដ្ឋានរ៉ែ។

2) ណែនាំនិងបញ្ជាក់ទាក់ទងនឹងភាពសំរបសំរួលនឹងផែនទីសុវត្ថិភាពព្រមទាំងផែនការជីកយករ៉ែនៅក្នុងទីកន្លែងជីកយករ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅទីកន្លែងជីកយករ៉ែ ស្តីពីចំនុចដែលត្រូវបានសន្និដ្ឋាននិងមានភាពមិនប្រក្រតីផ្នែកសុវត្ថិភាពនិងចំនុចខុសគ្នាខ្លាំង ធ្វើការបញ្ជាក់ពិនិត្យតើមានការសំរបសំរួលនឹង「ផែនទីសុវត្ថិភាពការដ្ឋានរ៉ែ」ដែលត្រូវបានរាយការណ៏តាមការកំណត់នៃច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

3) ណែនាំនិងបញ្ជាក់ទាក់ទងនឹងការសាងសង់ឬតំឡើងបរិក្ខារ អគារប្រើសំរាប់ការងាររ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ស្តីពីអគារ បរិក្ខារផលិត។ល។នៅក្នុងបរិវេណការដ្ឋានរ៉ែធ្វើការបញ្ជាក់តើបានរាយការណ៍ឬផ្លាស់ប្តូរតាមការកំណត់របស់ច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែដែរឬទេ ស្តីពីចំនុចដែលត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអរ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

4)ធ្វើការណែនាំនិងបញ្ជាក់ទាក់ទងនឹង「បែបបទរបៀបធ្វើការ」ត្រូវបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅក្នុងពេលល្បាតតាមទីកន្លែងធ្វើការជីកយករ៉ែ និងទីកន្លែងខួងរុលទៅមុខ។ល។ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិ

ភាព ធ្វើការណែនាំកែលំអរ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

5) ណែនាំនិងបញ្ជាក់ទាក់ទងនឹងការប្រើបរិក្ខារការពារ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅក្នុងពេលល្បាតតាមទីកន្លែងធ្វើការជីកយករ៉ែ និងទីកន្លែងខួងរុលទៅមុខ។ល។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការបញ្ជាក់តើបានអនុវត្តតាមការងារដោយប្រើបរិក្ខារការពារខ្លួន មានមួកសុវត្ថិភាព, ស្បែកជើងសុវត្ថិភាព, ស្រោមដៃសុវត្ថិភាព។ល។ដែរឬទេ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអរ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

6) ណែនាំនិងបញ្ជាក់ទាក់ទងនឹងផែនការជីកយករ៉ែបែបពិសេស

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅពេលធ្វើការខួងរុលទៅមុខសំរាប់ធ្វើផ្លូវនៅក្នុងរូងនិងជីកយករ៉ែនៅក្នុងដីដែលអាចនឹងមានគ្រោះថ្នាក់តាមរយៈទឹកចេញ ឬការបំពុលដោយសាររ៉ែតាមរយៈការខយងឬនៅក្រោមបាត់សមុទ្រ ឬបាតទន្លេដែលមានការដ្ឋានរ៉ែអនុវត្តការជីកយករ៉ែបែបការដ្ឋានរ៉ែបិទ ធ្វើការបញ្ជាក់រួមគ្នាតើមានការអនុវត្តតាមខ្លឹមសារដែលបានសរសេរនៅក្នុង ផែនការជីកយកពិសេស នៃវិធីជីកយករ៉ែដែរឬទេ អនុវត្តបញ្ជាក់ស្តីពីភាពញឹកញាប់និងទំហំ វិធីវាស់ស្តីពីលទ្ធផលនៃការផុងស្រទាប់ដីខាងលើ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអរ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

លើសពីនេះ, ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាពអាចនឹងមានគ្រោះថ្នាក់នៅការដ្ឋានរ៉ែ តាមរយៈការចេញទឹកពី 「ផែនទីសុវត្ថិភាពពិសេស」 និងស្ថានភាពអនុវត្តនៃការខួងទុកជាមុននៅក្នុងរូង ធ្វើការណែនាំកែលំអរ ដោយធ្វើការបញ្ជាក់ទៅវិញទៅមកនឹងអ្នកបានចូលរួមពីភាគីការដ្ឋានរ៉ែ។

7) ណែនាំនិងបញ្ជាក់ទាក់តងនឹងឧស្ម័ននៅក្នុងរូង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅពេលដើរល្បាតនៅទីកន្លែងមានគ្រោះថ្នាក់ដែលមានឧស្ម័នជាតិពុលនិងឧស្ម័នមានជាតិឆេះនៅការដ្ឋានរ៉ែបិទ ករណីមានកំហាប់លើសពីការកំណត់នៃច្បាប់និងបទបញ្ញត្តិពីឧស្ម័ននៅក្នុងចរន្តខ្យល់ ធ្វើការវាស់ឧស្ម័ននោះអោយបានញឹកញាប់នៅទីកន្លែងនោះដែលមានរៀបរាប់ដូចខាងក្រោម និងកាន់ភ្ជាប់មកជាមួយនូវបរិក្ខាវាស់ឧស្ម័នដែលត្រូវការប្រើចាំបាច់ ធ្វើការបញ្ជាក់រួមគ្នាជាមួយនឹងភាគីការដ្ឋានរ៉ែ ធ្វើការណែនាំកែលំអតាមរយៈចាត់វិធានការសុវត្ថិភាពជាបន្ទាន់។

a) ការដ្ឋានរ៉ែធ្យូងថ្ម មានឧស្ម័ននៅក្នុងចរន្តខ្យល់នៃខ្យល់ចេញនិងនៅតំបន់ក្បែរកន្លែងបិទជិត, រូងចាស់, ទីកន្លែងខួងទៅមុខ, ទីកន្លែងជីកយករ៉ែក្នុងរូង។ល។ដោយកម្មកររ៉ែ។

b) ចំពោះនៅការដ្ឋានរ៉ែលោហៈនិងអលោហៈ ឧស្ម័នជាតិពុលចំពោះទីកន្លែងបើកបរ-ទីកន្លែងធ្វើការងាររបស់រថយន្តគ្រឿងចក្រការដ្ឋានរ៉ែប្រើជាម៉ាស៊ីនកំឡាំងជាម៉ាស៊ីនចំហេះក្នុង, ទីកន្លែងជាច្រើនអាចមានគ្រោះថ្នាក់ដោយសារមានឧស្ម័នជាតិពុល។

（2）ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការបាក់រលំ និងបាក់ស្រុត

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅទីកន្លែងខួងធ្វើការងារនិងទីកន្លែងជិតទីនោះ អនុវត្តការងារយករ៉ែបែបការដ្ឋានបិត និង ទីកន្លែងយករ៉ែបែបការដ្ឋានរ៉ែបើក ទាក់ទងនឹងបាក់ស្រុត បាក់រលំ ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព អនុវត្តនវការត្រួតពិនិត្យតាមចំនុចសំខាន់ដូចមានខាងក្រោម ធ្វើការណែនាំកែលំអរ។ល។ ដោយអនុវត្តបញ្ជាក់រួមគ្នាជាមួយនឹងភាគីការដ្ឋានរ៉ែ។

1）ទីកន្លែងជីកក្នុងរូង

a) នៅពេលអាចនឹងមានគ្រោះថ្នាក់នៃការបាក់ស្រុតឬបាក់រលំ ចាំបាច់ត្រូវតំឡើងសរសរទ្រសមស្របសមរម្យតប់ទល់នឹងស្ថានភាពនៃផ្ទាំងជញ្ជាំងថ្មនិងពិដាន។

b) ចំពើនៅទីកន្លែងខួងរុលទៅមុខនៃផ្លូវក្នុងរូង, ធ្វើការតំឡើងទំរ ឬតំឡើងជន្ទល់ទប់ផ្ទៃជញ្ជាំងធ្វើការងារ។

c) តើមានការបែងចែកតំឡើងសរសរទ្រសមរម្យទៅតាមទីកន្លែងនីមួយៗដែរឬទេ។

d) ចំពោះសសរទ្រដែលពុក ឬខូច តើមានការផ្លាស់ពង្រឹងឡើងវិញបានឆាប់រហ័សដែរឬទេ?

e) ចំពោះទីកន្លែងមានភាពចាំបាច់សំរាប់សុវត្ថិភាព តើមានតំឡើងសរសរធ្យូងថ្មឬសរសររ៉ែសមរម្យទៅតាមសភាពនៃផ្ទាំងថ្មដែរឬទេ?

f) ចំពោះទីកន្លែងបានបញ្ចប់ការជីកយក ជើងទ្រ នៅពេលមានភាពចាំបាច់សំរាប់ផ្នែកសុវត្ថិភាព តើមានចាត់វិធានការសមរម្យដោយធ្វើការចាក់បន្ថែមតាមរយៈសារធាតុផ្សេងៗដូចជាដី និងខ្សាច់ជាដើម។

g) នៅក្នុងការងារនិងមុនចាប់ផ្តើមការងារ តើមានចាត់វិធានការចាំបាច់ ដោយធ្វើការទំលាក់ថ្មពក់ ពិនិត្យផ្ទៃការងារនិងផ្នែកជញ្ជាំង, ផ្ទាំងថ្ម ដែរឬទេ?

h）តើមានត្រៀមរៀបចំអោយមានបរិក្ខារសមរម្យសំរាប់ទំលាក់ថ្មពក់ពីជញ្ជាំង ពីពិដាននៃរូងដែរឬទេ?

2）ទីកន្លែងយករ៉ែបែបការដ្ឋានរ៉ែបើក

a) ក្នុងការយករ៉ែបែបការដ្ឋានរ៉ែបើក តើមានបានយកអាចម៍ដីខាងលើចេញដោយវិធីសុវត្ថិភាពជាមុនដែរឬទេ?

b) នៅផ្ទៃនៃជញ្ជាំងនៃទីកន្លែងធ្វើការងារ តើមានរក្សាបាននូវសុវត្ថិភាព ចំពោះជំរេល កំពស់

នៃជញ្ជាំងនោះ និងបានតំឡើងនូវថ្នាក់មានផ្លូវដើរនិងកំពស់សមរម្យដែរឬទេ?

c) តើមានបានយកចេញតាមវិធីសុវត្ថិភាពចំពោះថ្មពុកនៅកន្លែងជីកយកដែរឬទេ? ឬ តើមានតំឡើងនូវបរិក្ខារសំរាប់ទប់ស្កាត់នូវគ្រោះថ្នាក់តាមរយៈថ្មពុកធ្លាក់ដែរ?

d) ជញ្ជាំងនៅសល់ ដើម្បីទប់ស្កាត់នូវការបាក់រលំ តើមានបានរក្សានូវជំរេលសុវត្ថិភាពឆ្លើយតបនឹងស្ថានភាពនៃផ្ទាំងថ្មដែរឬទេ?

e) នៅទីកន្លែងមានជាច្រើនដែលមានគ្រោះថ្នាក់តាមរយៈថ្មធ្លាក់ ក្រៅពីតំឡើងជន្ទារសមរម្យ តើមានតំឡើងបរិក្ខារទប់ស្កាត់ការបាក់ធ្លាក់សមរម្យដូចជាខ្សែក្រវាត់សុវត្ថិភាព ឬសំណាញ់ទប់ស្កាត់ថ្មធ្លាក់ដែរឬទេ?

f) នៅពេលអាចនឹងមានគ្រោះថ្នាក់ច្រើនយោងតាមរយៈ ថ្មពកធ្លាក់នៅកន្លែងធ្វើការជីកយករ៉ែ តើមានធ្វើការលើក្រោមនៅក្នុងពេលតែមួយដែរឬទេ?

g) នៅពេលអាចនឹងមានគ្រោះថ្នាក់តាមរយៈភ្លៀងធ្លាក់ បញ្ឈប់ធ្វើការ ឬតើមានចាត់វិធានការសមរម្យសំរាប់កុំអោយមនុស្សចូលទៅក្នុងតំបន់មានគ្រោះថ្នាក់ដែរឬទេ?

h) នៅពេលអាចនឹងមានគ្រោះថ្នាក់យោងតាមរយៈថ្មផ្លោង ឬថ្មរមៀល តើមានតំឡើងបរិក្ខារការពារសមរម្យ ឬកំណត់តំបន់ហាមមិនអោយមនុស្សចូល និងដាក់មនុស្សយាម ឬមានចាត់វិធានការសមរម្យចាំបាច់ដោយលើកផ្លាក់សញ្ញាដែរឬទេ?

i) នៅពេលអនុវត្តការងារទំលាក់ថ្មរ៉ែចូលទៅក្នុងអណ្តូងរូង។ល។ ដើម្បីទប់ស្កាត់ការធ្លាក់រថយន្តឬគ្រឿងចក្រជាប្រភេទយាន្តនៅការដ្ឋានរ៉ែ តើមានចាត់វិធានការសមរម្យសំរាប់ទប់រថយន្តដែរឬទេ?

j) នៅពេលចង់បញ្ឈប់ឬបោះបង់ចោលនូវទីកន្លែងយកថ្មបែបការដ្ឋានរ៉ែបើក តើមានចាត់វិធានការចាំបាច់ សំរាប់ទប់ស្កាត់គ្រោះថ្នាក់តាមរយៈថ្មរមៀល ថ្មធ្លាក់ ឬមានទំរេលសុវត្ថិភាពសំរាប់ស្កាត់ការបាក់ធ្លាក់នៃជញ្ជាំងនិងជញ្ជាំងនៅសល់ ដែរឬទេ?

k) អ្នកគ្រប់គ្រងការងារនិងទទួលបន្ទុកសុវត្ថិភាពក្រៅរូង តើមានធ្វើការត្រួតពិនិត្យអោយបានលើសពី១ដងក្នុងរាល់ម៉ោងធ្វើការនូវទីកន្លែងងាយកើតថ្មពកនៃផ្ទៃថ្ម និងទិកន្លែងដែលអាចមានគ្រោះថ្នាក់ច្រើនទៀត ដែរឬទេ?

l) កម្មកររ៉ែអនុវត្តការងារជីកយករ៉ែ តើមានចាត់វិធានការចាំបាច់ទំលាក់ថ្មពក ដោយប្រើបរិក្ខារសមរម្យ ឬធ្វើការពិនិត្យនូវផ្ទាំងថ្មនៅក្នុងពេលធ្វើការងារ និងមុនធ្វើការងារដែរឬទេ?

（3）ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការងារបំផ្ទុះនិងប្រភេទនៃរំសេវ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ នៅក្នុងការដ្ឋានរ៉ែប្រើប្រភេទនៃរំសេវសំរាប់អនុវត្តការងាររ៉ែ ទាក់ទងនឹងការងារបំផ្ទុះ និង ការប្រើប្រភេទនៃរំសេវ ស្តីពីចំនុចត្រូវបានសន្និដ្ឋាន និងមិនសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយអនុវត្តបញ្ជាក់ជាមួយនឹងភាគី

ម្ចាស់ការដ្ឋានរ៉ែ។

1) ការប្រើប្រាស់ប្រភេទនៃរំសេវ

a) ទីកន្លែងប្រើប្រាស់ប្រភេទនៃរំសេវ តើមានរចនាសម្ព័ន្ធដែលត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែដែរឬទេ?

b) នៅទីកន្លែងប្រើប្រាស់ប្រភេទនៃរំសេវ ហាមប្រើប្រាស់ភ្លើង តើមានដាក់របស់ងាយនឹងឆេះ ងាយកើតភ្លើងដែរឬទេ?

c) នៅទីកន្លែងប្រើប្រាស់ប្រភេទនៃរំសេវ តើមានការរក្សាទុកដាក់រំសេវនិងសារធាតុបំផ្ទុះផ្សេងទៀតនៅដោយឡែកពីគ្នាដែរឬទេ?

d) នៅការដ្ឋានរ៉ែដែលបានបង្កើតទីកន្លែងប្រើប្រាស់ប្រភេទនៃរំសេវ តើអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែកប្រភេទនៃរំសេវ មានបានបង្កើតបញ្ជីទទួលនិងប្រគល់ប្រភេទនៃរំសេវ និងកត់ត្រាច្បាស់ពីការប្រគល់និងប្រើប្រាស់វាបានត្រឹមត្រូវដែរឬទេ?

e) នៅការដ្ឋានរ៉ែដែលមិនបានបង្កើតទីកន្លែងប្រើប្រាស់ប្រភេទនៃរំសេវ តើអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពក្នុងរូងឬគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពការងារក្រៅរូង មានបានបង្កើតបញ្ជីទទួលនិងប្រគល់ប្រភេទនៃរំសេវ និងកត់ត្រាច្បាស់ពីការប្រគល់និងប្រើប្រាស់វាបានត្រឹមត្រូវដែរឬទេ?

f) តើមានបានអនុវត្តការដឹកជញ្ជូនប្រភេទនៃរំសេវតាមវិធីមានសុវត្ថិភាពដែរឬទេ?

2) ការងារបំផ្ទុះនៅការដ្ឋានរ៉ែអនុវត្តយករ៉ែតាមបែបការដ្ឋានរ៉ែបើក

a) មានសារធាតុមិនល្អប្រើជាប្រអប់ដាក់ប្រភេទនៃរំសេវចល័ត តើផ្នែកខាងក្នុងនៃប្រអប់នោះមានលេចចេញដែកដែរឬទេ?

b) តើចំពោះបរិក្ខារបំពាក់និងញាត់ប្រើសំរាប់ការបំផ្ទុះ មានបានរៀបចំជារបស់មានសុវត្ថិភាពមានវិធានការចំពោះការកកិត-ទង្គិច-ចរន្តណឹត។ល។ដែរឬទេ?

c) ចំពោះម៉ាស៊ីនបំពាក់រំសេវ (ANFO) តើផ្ទៃផ្នែកខាងក្នុងវា មានជាដែកអ៊ីណុក ជាអាលុយមីញ៉ូម ។ល។ដែលមានភាពពុកផុយដែរឬទេ និងតើមានប្រើជាសារធាតុដែលមិនអោយរំសេវ (ANFO) អាចមានប្រតិកម្មបានដែរឬទេ? តើមានបានគោរពតាមការកំណត់នៃច្បាប់និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែដែរឬទេ?

d) នៅពេលអាចនឹងមានគ្រោះថ្នាក់ដោយថ្មរមៀល ឬថ្មផ្លោងពីការដ្ឋានរ៉ែទៅខាងក្រៅនៅពេលធ្វើការបំផ្ទុះ តើមានប្រើប្រាស់បរិមាណនៃរំសេវសមរម្យដែរឬទេ តើមានចាត់វិធានការទប់ស្កាត់សមរម្យដែរឬទេ? តើមានលើកផ្លាក់សញ្ញាប្រយ័ត្ន មានដាក់មនុស្សចាំមើលនិងមានកំណត់នូវជាតំបន់ហាមឃាត់កុំអោយមនុស្សចូលដែរឬទេ?

e) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង នៅពេលធ្វើការបំផ្ទុះដោយប្រើគិបអគ្គិសនី ខ្សែបំផ្ទុះ តើមានអនុវត្តការងារទាំងនោះនៅទីកន្លែងមានសុវត្ថិ

ភាពដែរឬទេ?

f) នៅពេលប្រើខ្សែចរន្តនិងគិបអគ្គិសនី រហូតដល់តដល់ខ្សែមេ តើមានចង់គួចចុងខ្សែខាងចុងចូលគ្នាទេ?

g) នៅពេលបញ្ចូលរំសេវចូលទៅក្នុងរន្ធបំផ្ទុះ តើមានប្រើអណ្តាតភ្លើង ឬជក់បារីដែរឬទេ?

h) ផ្នែកចុងខ្សែភ្ជាប់នឹងបរិក្ខារបំផ្ទុះនៃខ្សែមេសំរាប់បំផ្ទុះ ក្រៅពីធ្វើការបំផ្ទុះ តើមានធ្វើការគួចចូលគ្នាដែរឬទេ? ក៏ប៉ុន្តែ នៅពេលអាចនឹងមានកើតការផ្ទុះឡើងដោយចៃដន្យ តាមរយៈចរន្តណាមួយ ដូចជារន្ទះ ចូលមកមកប្រព័ន្ធនៃបំផ្ទុះតើមានបើកសៀគ្វីនៃខាងចុងខ្សែភ្ជាប់នឹងបរិក្ខារបំផ្ទុះនៃខ្សែមេសំរាប់ធ្វើការបំផ្ទុះដែរឬទេ។

i) តើមានប្រើខ្សែបំផ្ទុះជាខ្សែមេដែលមានប្រវែងសមរម្យសំរាប់អនុវត្តការងារបំផ្ទុះនៅទីកន្លែងភៀសខ្លួនដោយមាប្រើខ្សែដែលមានភាពរឹងមាំដោយមានស្រោមកៅស៊ូ-អំបោះ។

j) រំសេវដែលបានញាត់សំរាប់បំផ្ទុះ នៅពេលពុំមានការផ្ទុះក្រៅពីចុចកុងតាក់បំផ្ទុះរួច អ្នកទទួលគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង នៅពេលធ្វើតាមវិធីបំផ្ទុះអគ្គិសនី ដកយកបរិក្ខារបំផ្ទុះពីខ្សែមេ ធ្វើការគួចចុងខ្សែខាងចុងចូលគ្នា និងតើមានចាត់វិធានការសមរម្យដើម្បីធ្វើយ៉ាងណាមិនអាចអោយផ្ទុះបានដែរឬទេ?

k) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង ក្រោយការបំផ្ទុះ តើមានធ្វើការបញ្ជាក់ពិនិត្យមានឬមិនានគ្រោះថ្នាក់ផ្សេងទៀត ដោយឆែកប្រភេទរំសេវដែលមិនផ្ទុះ ស្ថានភាពថ្មរមៀលនិងបាក់រលំនៅទីកន្លែងបានធ្វើការបំផ្ទុះរួច ដែរឬទេ? លើសពីនេះ នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ច្រើន តើមានចាត់វិធានការហាមមិនអោយមនុស្សចូលដែររទេ?

3) ការងារបំផ្ទុះនៅការដ្ឋានរ៉ែបិទ

a) មានសារធាតុមិនល្អប្រើជាប្រអប់ដាក់ប្រភេទនៃរំសេវចល័ត តើផ្នែកខាងក្នុងនៃប្រអប់នោះមានលេចចេញដែកដែរឬទេ?

b) តើចំពោះបរិក្ខារបំពាក់និងញាត់ប្រើសំរាប់ការបំផ្ទុះ មានបានរៀបចំជារបស់មានសុវត្ថិភាពមានវិធានការចំពោះការកកិត-ទង្គិច-ចរន្តណឹត។ល។ដែរឬទេ?

c) នៅពេលធ្វើការបំផ្ទុះ អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្ម (ប្រភេទAនិងប្រភេទB) ប្រើបរិក្ខារវាស់ឧស្ម័ន តើមានវាស់អត្រាមានឧស្ម័នជាតិឆេះនិងតំបន់នៅជិតកន្លែងនោះគ្រប់រាល់ពេលនៃការបំផ្ទុះដែរឬទេ?

d) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង តើមានអនុវត្តនៅទីកន្លែងសុវត្ថិភាព ក្នុងពេលភ្ជាប់គិបអគ្គិសនីឬរំសេវទៅនឹងខ្សែបំផ្ទុះដែរឬទេ?

e) នៅពេលប្រើខ្សែចរន្តនិងគិបអគ្គិសនី រហូតដល់តដល់ខ្សែមេ តើមានចង់គួចចុងខ្សែខាងចុងចូលគ្នាទេ?

f) ចំពោះខ្សែបំផ្ទុះមេ ជាខ្សែដែលមានអ៊ីសូឡង់ល្អ និងជាខ្សែដែលត្រូវបានកំណត់តាមច្បាប់ឬបទបញ្ញត្តិដែរឬទេ?

g) នៅទីកន្លែងភៀសខ្លួនសំរាប់ធ្វើការបំផ្ទុះ សំរាប់ទប់ស្កាត់ថ្មផ្លោង តើមានបង្កើតជារចនសម្ព័ន្ធមានសុវត្ថិភាព ឬជាទីតាំងមានសុវត្ថិភាពដែរឬទេ?

h) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង ក្រោយធ្វើការបំផ្ទុះ តើមានបានចាត់វិធានការបញ្ជាក់ចាំបាច់នៅទីកន្លែងបានធ្វើការបំផ្ទុះដែរឬទេ?

(4) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងរថយន្តព្រមទាំងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងរថយន្តព្រមទាំងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព អនុវត្តនូវការត្រួតពិនិត្យដោយផ្ចិតផ្ចង់តាមចំនុចដែលមានដូចខាងក្រោម ធ្វើការណែនាំកែលំអរ។ល។ ដោយអនុវត្តបញ្ជាក់រួមគ្នាជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) ចំពោះរថយន្តព្រមទាំងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត តើមានបង្ហាញនូវចំនុចសំខាន់ៗលើផ្នែកគ្រប់គ្រងបើកបររថយន្តទាំងនោះ ដូចជាការបង្ហាញនូវ ទំនង់ដឹកអតិប្បរមា, ចំនួនទំងន់កំហិតនៃការដឹក, ផ្លាកលេខនៃរថយន្តបិទបានត្រឹមត្រូវដែរឬទេ?

2) តើមានប្រើរថយន្តព្រមទាំងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្តដែលមិនត្រូវនឹងស្តង់ដែលគេបានកំណត់ដែរឬទេ?

3 ) នៅក្នុងរូងតើមានប្រើប្រេងឥន្ធនៈដែលចេញផ្សែងមិនត្រូវនឹងស្តង់ដែលគេបានកំណត់ដែរឬទេ?

4) នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់កើតឡើងតាមរយៈផ្ទាំងថ្មធ្លាក់ និងថ្មរលំ។ល។ តើមានរៀបចំhead guard អោយមានរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ។

5) មុនចាប់ផ្តើមធ្វើការងារ តើមានធ្វើការត្រួតពិនិត្យរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែដែរឬទេ?

6 ) ចំពោះរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ តើមានដាក់មនុស្ស, បរិមាណទំនិញលើសពីចំណុះដែលត្រូវបានកំណត់ដែរឬទេ?

7) នៅពេលបញ្ជា ប៉ែលជូក ដង លើកឡើងនៃគ្រឿងចក្រការដ្ឋានរ៉ែ និងការងារត្រួតពិនិត្យជួសជុល តើមានចាត់វិធានការសមរម្យ។ល។ដោយប្រើសរសរជំទ្រសុវត្ថិភាព និងកំណល់សុវត្ថិភាពដែរឬទេ?

8) ចំពោះរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ យោងតាមរយៈវិធីនិងល្បឿនសុវត្ថិភាព តើមានការបើកបរគោរពតាមច្បាប់ចរាចរណ៍ទូទៅដែរឬទេ?

9 ) ចំពោះអ្នកបើកបររថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ នៅពេលចាកចេញពីយានទាំងនោះ :
តើមានគោរពនូវចំនុចដែលត្រូវបានកំណត់របស់ច្បាប់និងបទបញ្ញតិ។ល។ ដោយធ្វើការទំលាក់ប៉ែល ដាក់ក្រចកប៉ែលទៅនឹងផ្ទៃដី ពន្លត់ម៉ាស៊ីននិងចាប់ហ្វាំង ដកសោរយកចាប់ខ្លួនកុំអោយអ្នកដ៏ទៃប្រើប្រាស់បានដែរឬទេ?

10) រចនាសម្ព័ន្ធនៃផ្លូវការដ្ឋានរ៉ែ, តើមានគោរពនូវចំនុចដែលត្រូវបានកំណត់របស់ច្បាប់និងបទបញ្ញតិ។ល។ ដោយចាត់វិធានការ តំឡើងរនាំងទប់ស្កាត់ការធ្លាក់ ផ្លាក់សញ្ញាផ្លូវ ក្រៅពីមានការគិតគូរពីស្ថានភាពនៃផ្លូវរត់របស់រថយន្ត ដោយគ្រឿងចក្រប្រភេទការដ្ឋានរ៉ែ, ស្ថានភាពអាកាសធាតុ, សណ្ឋានដីនៅជុំវិញរបស់ការដ្ឋានរ៉ែ ដែរឬទេ?

11) ចំពោះផ្លូវនៅក្នុងរូងរត់ជាធម្មតាដោយគ្រឿងចក្រប្រភេទយានការដ្ឋានរ៉ែ និងរថយន្ត តើមានគោរពនូវចំនុចដែលត្រូវបានកំណត់របស់ច្បាប់និងបទបញ្ញតិ។ល។ ដោយរក្សាការរត់នោះកុំអោយមានឧបសគ្គ ធ្វើយ៉ាងណារក្សាអោយបាននូវផ្លូវអោយបានល្អដែរឬទេ?

(5) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹង បរិក្ខារខារ ខ្សែពានដឹកជញ្ជូន និងក្បាលរថភ្លើង
មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹង បរិក្ខារខារ ខ្សែពានដឹកជញ្ជូន និងក្បាលរថភ្លើង ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមិនសមរម្យលើផ្នែកសុវត្ថិភាពធ្វើការណែនាំកែលំអ ដោយអនុវត្តបញ្ជាក់ជាមួយនឹងភាគីម្ចាស់ការដ្ឋានរ៉ែ។

1) ដឹកជញ្ជូនតាមរយៈបរិក្ខារខារ

a) ចំពោះរទេះខាដោយស្វ័យប្រវត្តិ និងរូងបញ្ឈរដែលបានតំឡើងបរិក្ខារខារ តើមានតំឡើងបរិក្ខារផ្តល់សញ្ញាដែរឬទេ?

b) ចំពោះទីកន្លែងចាំបាច់ដែលមានជំលេ ឬផ្លូវរថយន្ត តើមានតឡើងបរិក្ខារទប់ស្កាត់ការរត់ដោយយថាហេតុដែរឬទេ?

c) ចំពោះផ្លូវដឹកជញ្ជូន និងទីកន្លែងសាងសង់នៅផ្លូវក្រៅរូង ឬទីកន្លែងមានគ្រោះថ្នាក់ តើមានបានបង្ហាញនូវផ្លាកសញ្ញាសមរម្យដែរឬទេ?

d) នៅពេលបានតំឡើងបរិក្ខារខារនៅក្នុងរូងបញ្ឈរសំរាប់លើកនិងដាក់មនុស្សចុះ តើមានតំឡើងបរិក្ខារមានដូចខាងក្រោមដែរឬទេ?

i) បរិក្ខារបង្ហាញនូវពីកំរិតជ្រៅ

ii) បរិក្ខារទប់ស្កាត់ល្បឿនលឿនជ្រុល និង ការខារជ្រុល

iii) បរិក្ខារទប់ស្កាត់នូវគ្រោះថ្នាក់នៅពេលមានភាពមិនប្រក្រតី

iv) ចំពោះច្រករូង ទីកន្លែងចុះនិងជិះ បរិក្ខារទប់ស្កាត់ធ្លាក់តាមរយៈទ្វាសុវត្ថិភាព។ល។

e) នៅពេលតំឡើងនូវបរិក្ខារខារជំរេលប្រើសំរាប់ដឹកជញ្ជូនមនុស្ស ក្រៅពីតំឡើងបរិក្ខារដែលមានដូចខាងក្រោម ចំពោះគំលាតរវាងពិដាននឹងផ្នែកដំបូលនៃរទេះ គំលាតរវាងជញ្ជាំង

រូង តើមានធ្វើតាមការកំណត់របស់ច្បាប់និងបទបញ្ញត្តិដែរឬទេ?

i ) បរិក្ខារទប់ស្កាត់នូវគ្រោះថ្នាក់តាមរយៈខ្សែកាបដាច់និងល្បឿនលឿនជ្រុល

ii ) ករណីត្រូវបានភ្ជាប់ដោយដែកទំពក់រវាងរទេះនឹងរទេះដឹកមនុស្ស ត្រូវមានខ្សែកាប និងច្រវាក់បំរុង

2 ) ដឹកជញ្ជូនតាមរយៈខ្សែពានដឹកជញ្ជូន

a) នៅពេលតំឡើងខ្សែពានដឹកជញ្ជូនសំរាប់ដឹកមនុស្ស ក្រៅពីតំឡើងបរិក្ខារដែលមានដូចខាងក្រោម ចំពោះគំលាតនឹងរបស់ជាឧបសគ្គឬពិដាននៃរូងនឹងខ្សែពាន តើមានអនុវត្តតាមការកំណត់នៃច្បាប់និងបទបញ្ញត្តិដែរឬទេ?

i ) តំឡើងនូវបរិក្ខារបំភ្លឺ ចំពោះទីកន្លែងជិះនិងចុះនិងកន្លែងនៅក្បែរទីនោះ

ii ) បរិក្ខារទប់ស្កាត់គ្រោះថ្នាក់យោងតាមរយៈជិះហួស និងល្បឿនលឿនជ្រួល

iii) បរិក្ខារបញ្ឈប់នៅពេលមានអសន្ន ប្រើដោយអ្នកជិះ

iv) បរិក្ខារទប់ស្កាត់គ្រោះថ្នាក់តាមរយៈខ្សែពានរត់ទៅតែម្ខាង

b) នៅពេលតំឡើងខ្សែពានដែលមានកំឡាំងម៉ូទ័រអូសលើពី 2 0 KWសំរាប់ដឹករបស់ តើមានតំឡើងបរិក្ខារដែលមានដូចខាងក្រោមដែរឬទេ?

i ) បរិក្ខារបញ្ឈប់នៅពេលមានអសន្ន នៅពេលមានភាពមិនប្រក្រតីនៅពេលដំណើរការខ្សែពាន

ii ) បរិក្ខារទប់ស្កាត់គ្រោះថ្នាក់តាមរយៈខ្សែពានឃ្លាតចេញ

iii) បរិក្ខារទប់ស្កាត់គ្រោះថ្នាក់តាមរយៈខ្សែពានរត់ទៅតែទិសម្ខាង

iv) នៅទីកន្លែងផ្លាស់ប្តូរការដឹករ៉ែធ្យូងថ្មនៅការដ្ឋានរ៉ែធ្យូងថ្ម (ប្រភេទAនិងប្រភេទB) បរិក្ខារទប់ស្កាត់គ្រោះថ្នាក់តាមរយៈកើតឡើងនូវភ្លើងឆេះតាមរយៈការកកិតរវាងខ្សែពាននឹងធ្យូងថ្មបានគរនៅទីនោះ

3 ) ដឹកជញ្ជូនតាមរយៈក្បាលរថភ្លើង

a) ចំពោះក្បាលរថភ្លើង តើមានត្រូវបានរៀបចំមានអំពូលបំភ្លឺនៅខាងមុខ និងបរិក្ខារបញ្ចេញសំឡេងអោយប្រយ័ត្ន បរិក្ខារប្រើសមរាប់ជួសជុលនៅពេលក្បាលរថភ្លើងចេញពីផ្លូវដែក។

b) អ្នកមានសញ្ញាប័ត្របើកបរក្បាលរថភ្លើង នៅក្នុងរូងសំរាប់ដឹកជញ្ជូន តើមានការបើកបរដោយរុញរទេះដឹកជញ្ជូនមនុស្សនិងរទេះដឹកថ្មរ៉ែដែរឬទេ?

c) អ្នកមានសញ្ញាប័ត្របើកបរក្បាលរថភ្លើង នៅពេលចាកចេញពីក្បាលរថភ្លើង តើបានចាត់វិធានការចាំបាច់ដែលត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ញត្តិដែរឬទេ?

d) ករណីបើកបរយានដែលបានតភ្ជាប់ជាមួយនឹងរទេះដឹកមនុស្សនិងរទេះដឹកថ្មរ៉ែ តាមរយៈក្បាលរថភ្លើង ចំពោះរទេះចុងក្រោយ តើមានបំពាក់ផ្លាកសញ្ញាសមរម្យ ឬ ភ្លើង

ក្របាមភ្លឹមផ្លែតដែរឬទេ។

(6) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងអគ្គិភ័យ និង ការឆេះដោយធម្មជាតិ

ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹង បរិក្ខារខារ ខ្សែពានដឹកជញ្ជូន និងក្បាលរថភ្លើងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងអគ្គិភ័យ និង ការឆេះដោយធម្មជាតិ ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមិនសមរម្យលើផ្នែកសុវត្ថិភាពធ្វើការណែនាំកែលំអ ដោយអនុវត្តបញ្ជាក់ជាមួយនឹងភាគីម្ចាស់ការដ្ឋានរ៉ែ។

1) ទប់ស្កាត់អគ្គិភ័យ

a) នៅការដ្ឋានរ៉ែ ជីកយករ៉ែក្នុងរូង នៅទីកន្លែងម៉ាស៊ីននៅក្នុងរូង អគារដែលត្រូវបានកំណត់ដូចជា ចំពោះបន្ទប់ប៉ូម និងបន្ទប់ម៉ាស៊ីនកង្ហាល, បន្ទប់ផ្លាស់ប្តូរចរន្ត, បន្ទប់សំពាធខ្យល់, បរិក្ខារបំលាស់ទីខ្សែពានដឹកជញ្ជូននិងទីកន្លែងតំឡើងពូលី, ទីកន្លែងតំឡើងបរិក្ខារសាកអាគុយ។ល។ តើមានជារចនាសម្ព័ន្ធទប់ស្កាត់ភ្លើងឆេះ និង ត្រូវបានបំពាក់បរិក្ខារពន្លត់អគ្គិភ័យដែរឬទេ?

b) នៅការដ្ឋានរ៉ែ ជីកយករ៉ែនៅក្នុងរូង ស្តីពីអគារដែលត្រូវបានកំណត់ ដូចជា បន្ទប់បិទបើកប្រេងចេញចូលសំខាន់ៗនៅក្នុងរូង, ទីកន្លែងស្តុកប្រភេទប្រេងផ្សេង និងទីកន្លែងតំឡើងបរិក្ខារបំលែងចរន្តសំខាន់ៗ តើមានជារចនាសម្ព័ន្ធទប់ស្កាត់ភ្លើងឆេះ និង ត្រូវបានបំពាក់បរិក្ខារពន្លត់អគ្គិភ័យដែរឬទេ?

c) នៅការដ្ឋានរ៉ែ ជីកយករ៉ែនៅក្នុងរូង, នៅពេលផ្គត់ផ្គង់ប្រេងឥន្ធនៈរបស់រថយន្ត ឬគ្រឿងចក្រការដ្ឋានរ៉ែ នៅក្នុងរូង តើមានពន្លត់ម៉ាស៊ីន និងមានហាមប្រើភ្លើងនៅក្បែរទីនោះដែរឬទេ?

d) នៅការដ្ឋានរ៉ែបិទ (រ៉ែធ្យូងប្រភេទAនិងប្រភេទB) ទីកន្លែងដែលត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ញត្តិ ដែលមានដូចខាងក្រោម តើមានតំឡើងបរិក្ខារពន្លត់អគ្គិភ័យដែរឬទេ?

i) នៅក្នុងរូងបានតំឡើងខ្សែចែកចាយចរន្តសំរាប់ប្រើកំឡាំង ផ្លូវនៅក្នុងរូងប្រើសំរាប់ដឹកជញ្ជូនដោយក្បាលរថភ្លើងប្រើចរន្តអគ្គិសនី ឬប្រើម៉ាស៊ីនប្រើប្រេងឥន្ធនៈ ដឹកតាមលំហ និងផ្លូវនៅក្នុងត្រូវបានតំឡើងខ្សែពានដឹកជញ្ជូន តើមានតំឡើងបរិក្ខារពន្លត់អគ្គិភ័យ នៅក្នុងរាល់ប្រវែង១០០ម៉ែត្រ និង នៅចំនុចបាច់ផ្តើម និងចំនុចដល់ទីដែរឬទេ?

ii) ទីកន្លែងតំឡើងបរិក្ខារបំលែងចរន្តអគ្គិសនីដោយប្រើប្រេង។

e) ចំពោះអគារនៅក្រៅរូង តើមានតំឡើងនូវបរិក្ខារសមរម្យសំរាប់តាមសភាពនៃទីកន្លែងនោះដែរឬទេ ដូច ស្រះទឹក, បរិក្ខារពន្លត់អគ្គិភ័យ, ខ្សាច់សំរាប់ពន្លត់អគ្គិភ័យ។ល។

2) ទប់ស្កាត់ការឆេះដោយធម្មជាតិ

a) នៅការដ្ឋានរ៉ែបិទ (រ៉ែធ្យូងប្រភេទAនិងប្រភេទB) និងការដ្ឋានរ៉ែលោហៈ ចំពោះទីកន្លែងអាចនឹងមានគ្រោះថ្នាក់ដោយសារមានការឆេះដោយធម្មជាតិ នៅក្នុងរូងធ្វើការតំឡើងបរិក្ខារពន្លត់អគ្គិភ័យ តើមានរៀបចំនូវសារធាតុដែលអាចនឹងធ្វើការបិទផ្សិតដោយភ្លាមៗបាននៅក្នុងតំបន់នោះ ដែរឬទេ?

b) នៅការដ្ឋានរ៉ែបិទ (រ៉ែធ្យូងប្រភេទAនិងប្រភេទB) និងនៅការដ្ឋានរ៉ែលោហៈ ចំពោះកន្លែងមានភ្លើងឆេះដោយធម្មជាតិ ឬទីកន្លែងជីកយករួចអាចនឹងមានគ្រោះថ្នាក់ច្រើន តើមានចាត់វិធានការសមរម្យ និងបិទផ្សិត, ចាក់ដីបន្ថែមទៅក្នុងរូង ដែរឬទេ?

c) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៅការដ្ឋានរ៉ែបិទ (រ៉ែធ្យូងប្រភេទAនិងប្រភេទB ) និងនៅការដ្ឋានរ៉ែលោហៈស្តីពី ការឆេះដោយធម្មជាតិ, ទីកន្លែងអាចនឹងមានគ្រោះថ្នាក់កើតឡើងច្រើន និងតំបន់ជិតផ្លូវក្នុងរូងនោះ តើបានធ្វើការត្រួតពិនិត្យពីក្លិនស្អុយ និងវាស់ពីសំណើម, ខ្យល់សើមនិងឧស្ម័នដែរឬទេ?

d) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៅការដ្ឋានរ៉ែបិទ (រ៉ែធ្យូងប្រភេទAនិងប្រភេទB) និងនៅការដ្ឋានរ៉ែលោហៈ ធ្វើការតើមានឬមិនមានភាពមិនប្រក្រតីចំពោះទីកន្លែងបានបិទផ្សិត ឆ្លើយតបនឹងភាពចាំបាច់តើបានធ្វើការវិភាគពីឧស្ម័ននៅក្នុងទីកន្លែងបិទផ្សិតដែរឬទេ?

(7) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងរូងបោះបង់ចោល

មន្ត្រីត្រួតពិនិត្យ ទាក់ទងនឹងវិធានការចំពោះរូងចាស់ ធ្វើការត្រួតពិនិត្យដោយយកចិត្តទុកដាក់ចំពោះចំនុចដែលមានដូចខាងក្រោម ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) នៅការដ្ឋានរ៉ែបិទ នៅពេលធ្វើការខួងរុលទៅមុខឈានទៅក្បែរចរន្តទឹកក្នុងរង្វង់ប្រវែង ៥0ម៉ែត្រ ទៅជិតរូងបោះបង់ចោលដែលនឹងអាចមានគ្រោះថ្នាក់ច្រើន ដូចជាមានទឹកចេញច្រើន មានឧស្ម័នឆេះ និងឧស្ម័នផ្សេងៗទៀត តើមានចាត់វិធានការ ខួងទុកជាមុន ឬ ចាត់វិធានការសមរម្យផ្សេងៗទៀតដែរឬទេ?

2) នៅពេលបរិមាណទឹកចេញច្រើនដែលនឹងអាចធ្វើអោយមានគ្រោះថ្នាក់ តើមានចាត់វិធានការតំឡើងទំនប់ទប់ទឹក សន្ទះទប់ទឹក ចំពោះទីកន្លែងនៃផ្លូវក្នុងរូងបានសមរម្យដែរឬទេ។

3) នៅការដ្ឋានរ៉ែបិត ចំពោះរូងបោះបង់ចោលដែលនឹងអាចមានគ្រោះថ្នាក់ ដោយសារទឹកចេញ ឬអាចលិចលង់ តើមានកំណត់ជាតំបន់ការពារ ឬតំឡើងជញ្ជាំងការពារ

ចាំបាច់សំរាប់ទប់ស្កាត់ការបំពុលឬទប់ស្កាត់គ្រោះថ្នាក់តាមរយៈទឹកចេញដែរឬទេ?

(8) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងបរិក្ខារផលិតប្រើចរន្តអគ្គិសនី

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងបរិក្ខារផលិតប្រើចរន្តអគ្គិសនី ធ្វើការត្រួតពិនិត្យដោយយកចិត្តទុកដាក់ចំពោះចំនុចដែលមានដូចខាងក្រោម ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ (ធ្យូងថ្មប្រភេទAនិងធ្យូងថ្មប្រភេទB) ចំពោះទីកន្លែងមានអត្រាបរិមាណឧស្ម័នជាតិឆេះលើសពី1. 5% តើមានតំឡើងបរិក្ខារផលិតប្រើចរន្តដែរឬទេ? ក៏ប៉ុន្តែមានការលើកលែងចំពោះ បរិក្ខារទូរស័ព្ទប្រើចរន្តអគ្គិសនីខ្សោយបំផុត។

2) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ចំពោះផ្នែកឌុយលេចលោហៈនៃបរិក្ខារផលិតប្រើចរន្តអគ្គិសនី និងផ្នែកលោហៈផ្សេងទៀត តើមានការពារបានសមរម្យក្នុងគោលបំណងកុំអោយប៉ះនឹងមនុស្សឬរបស់ដ៏ទៃ ដែរឬទេ?

3) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ចំពោះទីកន្លែងមានបរិក្ខារអគ្គិសនីដែលក្រៅពីអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពអគ្គិសនី ពុំមានសិទ្ធប្រើនោះ តើមានលើកជាផ្លាកសញ្ញាដាក់ថា「ហាមចូល」និងដោយតំឡើងរបង ក្នុងគោលបំណងមិនអោយចូលបាន ដែរឬទេ?

4) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ស្តីពីបរិក្ខារបំលែងចរន្ត ប្រអប់តខ្សែចរន្តផលិតពីលោហៈបរិក្ខារធ្វើពីលោហៈផ្សេងៗទៀតសំរាប់គ្របខ្សែចរន្ត ។ល។ តើមានភ្ជាប់ខ្សែម៉ាស់បានត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់ដែរឬទេ?

5) អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពអគ្គិសនី ស្តីបរិក្ខារផលិតប្រើចរន្តដែលត្រូវតំឡើងខ្សែម៉ាស់ដូចបានរៀបរាប់ខាងលើ តើមានធ្វើការពិនិត្យវាស់ពីរ៉េស៊ីតង់អោយបានទៀងទាត់តាមបទបញ្ញត្តិនិងច្បាប់ដែលបានកំណត់ដែរឬទេ?

6) ចំពោះបរិក្ខារបំលែងចរន្តនិងបរិក្ខារអគ្គិសនីដែលបានតំឡើងនៅក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មប្រភេទការដ្ឋានរ៉ែបិទ (ធ្យូងថ្មប្រភេទAនិងប្រភេទB) ដើម្បីទប់ស្កាត់ចរន្តឆ្លងកាត់លើស តើមានតំឡើងបរិក្ខារទប់ស្កាត់ចរន្តលើសដោយស្វ័យប្រវត្តិ នៅទីកន្លែងសមរម្យណាមួយដែរឬទេ?

7) ស្តីពីខ្សែចរន្តចែកចាយដែលមានស្រោមជាជ័រនៅក្នុងរូងនៃការដ្ឋានរ៉ែបិទ តើមានតំឡើងនៅក្នុងគំលាតសមរម្យតាមការកំណត់របស់បទបញ្ញត្តិនិងច្បាប់ ដោយកុំអោយខ្សែទាំងនោះប៉ះគ្នាបាន ដែរឬទេ?

8) ស្តីពីខ្សែចរន្តចែកចាយមានសំពាធទាបនិងខ្ពស់ នៃការដ្ឋានរ៉ែបិទ នៅក្បែរច្រកចូល

ទៅក្នុងរូង ចំពោះទូរទទួលចរន្តនិងចំនុចបែងចែកសំខាន់ៗ តើមានតំឡើងបរិក្ខារបិទបើកសំរាប់បែងចែកតំបន់ ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិ ដែរឬទេ។

9) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ដើម្បីទប់ស្កាត់គ្រោះថ្នាក់តាមរយៈមានសំពាធមិនប្រក្រតី ឬរន្ទះ តើមានតំឡើងនូវបរិក្ខារទប់ស្កាត់រន្ទះនៅក្បែរច្រកចូលទៅក្នុងរូងដែរឬទេ?

10) នៅក្នុងក្រៅរូងនៃការដ្ឋានរ៉ែ នៅពេលអោយធ្វើការត្រួតពិនិត្យការងារ ឬជួសជុលផ្នែកអគ្គិសនីនៃបរិក្ខារអគ្គិសនី ដោយធ្វើការផ្តាច់ចរន្តជាមុន និងតើមានអោយប្រើស្រោមដៃ។ល។សំរាប់ជាឧបករណ៍កុំអោយឆក់ដែរឬទេ?

(9) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងធូលីហ៊ុយ នៅក្នុងទីកន្លែងធ្វើការ និងនៅក្នុងរូង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទនឹងការគ្រប់គ្រងធូលីហ៊ុយនិងនៅទីកន្លែងធ្វើការ ឬនៅតាមផ្លូវដើរនៅក្នុងរូង ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) ផ្លូវដើរនៅក្នុងរូង

a) ចំពោះផ្លូវដើរនៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ដើម្បីអោយមានទំនាក់ទំនងគ្នាបានរវាងផ្នែកខាងក្រោមនៅក្នុងរូងនិងផ្នែកនៅលើដី តើមានបង្កើតអោយមានផ្លូវដើរអោយលើសពី២ដែរឬទេ?

b) ចំពោះជំរេលមានលើសពី៤០ដឺក្រេ ឬរូងបញ្ឈរសំរាប់ដឹកជញ្ជូនមនុស្ស តាមរយៈបរិក្ខារខារនៅក្នុងការដ្ឋានរ៉ែបិទ តើមានតំឡើងជណ្តើរបញ្ឈរសំរាប់នៅពេលមានអសន្នដែរឬទេ?

c) នៅផ្លូវក្នុងរូងដំណើរការជាប្រចាំនៃខ្សែពានដឹកជញ្ជូនសំខាន់ៗ និងផ្លូវដែកដោយប្រើក្បាលរថភ្លើង នៅក្នុងការដ្ឋានរ៉ែបិទ ស្តីពីគំលាតជាមួយនឹងជញ្ជាំងនៃរូង តើគ្មានផ្លូវសំរាប់ប្រើរួមរបស់កម្មកររ៉ែ ដែលពុំបានរក្សានូវគំលាតត្រូវបានកំណត់ដែរឬទេ?

d) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ករណីអនុវត្តការងារទំលាក់ថ្មរ៉ែ។ល។ចូលទៅក្នុងរូងបញ្ឈរ ដោយប្រើរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយាន តើមានចាត់វិធានការសមរម្យដោយប្រើកំណល់សំរាប់កង់យានកុំអោយរអិលធ្លាក់ដែរឬទេ?

e) នៅក្នុងការដ្ឋានរ៉ែបិទមានរូងទ្រេតមានជំរេលលើសពី៤០ដឺក្រេ ឬរូងបញ្ឈរដែលលែងត្រូវការប្រើ ក្រៅពីលើកផ្លាកសញ្ញាសំរាប់ទប់ស្កាត់ការធ្លាក់ តើមានតំឡើងរបង ឬបិទផ្ទិតច្រករូងទាំងនោះដែរឬទេ?

f) នៅក្នុងការដ្ឋានរ៉ែបិទ ចំពោះចំនុចនៃផ្លូវខ្វែងនៃផ្លូវដើររបស់កម្មកររ៉ែ និងទីកន្លែងសំខាន់ផ្សេងៗទៀត បានដាក់ឈ្មោះទីកន្លែងទាំងនោះ និងតើមានបង្ហាញទិសដៅ

នៃច្រកចេញដែរឬទេ?

2) ទីកន្លែងធ្វើការនៅក្នុងរូង

a) នៅក្នុងការដ្ឋានរ៉ែបិទ ស្តីពីទីកន្លែងធ្វើការនៅក្នុងរូង និងឈ្មោះកម្មកររ៉ែធ្វើការនៅក្នុងរូង តើមានធ្វើការបញ្ជាក់ឈ្មោះនៅពេលចូលច្រកនៃរូង និងតើមានបញ្ជាក់ពីការកត់ត្រានោះអោយបានច្បាស់នៅក្នុងការិយាល័យនៅលើដីដែរឬទេ?

b) នៅក្នុងការដ្ឋានរ៉ែបិទ ចំពោះទីកន្លែងធ្វើការសំខាន់ៗនិងទីកន្លែងចាំបាច់ផ្សេងៗ តើមានតំលឡើងបរិក្ខារទាក់ទង ដូចជាវិទ្យុទាក់ទង និងទូរស័ព្ទ។ល។ដែរឬទេ?

3) ការគ្រប់គ្រងធូលីហ៊ុយនៅក្នុងរូង

a) ចំពោះទីកន្លែងធ្វើការមានធូលីហ៊ុយច្រើននៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ដើម្បីទប់ស្កាត់ធូលីហ៊ុយនៅក្នុងរូង តើមានបាចទឹកសំរាប់រក្សាសុខភាពកម្មកររ៉ែ និងចាត់វិធានការសមរម្យផ្សេងៗទៀតសំរាប់ធូលីហ៊ុយ ដែរឬទេ?

b) នៅទីកន្លែងមានធូលីហ៊ុយច្រើន ចំពោះករណីចាំបាច់សំរាប់សុវត្ថិភាព តើមានអោយប្រើម៉ាសទប់ស្កាត់ធូលីត្រូវនឹងស្តង់ដាដល់កម្មកររ៉ែដែរឬទេ?

c) នៅទីកន្លែងធ្វើការមានធូលីហ៊ុយច្រើន នៅពេលអោយកម្មកររ៉ែឈប់សំរាក តើមានអោយកម្មកររ៉ែសំរាកនៅទីកន្លែងដែលពុំមានធូលីហ៊ុយដែរឬទេ?

d) នៅពេលប្រើខួងបុកបំបែក នៅទីកន្លែងធ្វើការនៅក្នុងរូង ហើយម៉ាស៊ីនខួងនោះជាម៉ាស៊ីនខួងបែបប្រភេទសើម តើមានអោយកម្មកររ៉ែប្រើម៉ាស៊ីននោះ ពាក់ម៉ាសត្រូវនឹងស្តង់សុវត្ថិភាពដែរឬទេ?

e) អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពក្នុងរូង ស្តីពីទីកន្លែងមានធូលីហ៊ុយច្រើន ធ្វើការវាស់ពីអត្រាអាស៊ីតសីលីកាតនៅក្នុងធូលីនោះ និងកំហាប់ធូលីនៅក្នុងខ្យល់តាមការកំណត់ តើមានធ្វើការកត់ត្រានូវលទ្ធផលទាំងនោះ ព្រមទាំងរាយការណ៍ដល់អ្នកគ្រប់គ្រងដែរឬទេ?

(10) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងឧស្ម័ននៅក្នុងរូងនិងនៅក្នុងខ្យល់ឆ្លងកាត់

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងឧស្ម័ននៅក្នុងរូងនិងនៅក្នុងខ្យល់ឆ្លងកាត់ ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) ខ្យល់ឆ្លងកាត់នៅក្នុងរូង

a) នៅក្នុងការដ្ឋានរ៉ែបិទ ចំពោះខ្យល់នៅក្នុងរូងនៃទីកន្លែងឆ្លងកាត់ ឬទីកន្លែងធ្វើការរបស់កម្មកររ៉ែ ចំពោះអត្រាភាគរយនៃឧស្ម័នកាបូនិច ឧស្ម័នអុកស៊ីសែន តើមានគោរពតាមការកំណត់តើមានរបស់ច្បាប់និងបទបញ្ញត្តិដែរឬទេ?

b) ចំពោះកំដៅនៅក្នុងរូងនៃទីកន្លែងធ្វើការ តើមានគោរពតាមការកំណត់តើមានរបស់ច្បាប់និងបទបញ្ញតិដែរឬទេ?

c) បរិមាណខ្យល់នៅក្នុងទីកន្លែងធ្វើការនៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែធ្យូងថ្ម (ប្រភេទAនិងប្រភេទB ) តើមានបានកំណត់ដោយអនុលោមតាមចំនួនកម្មកររ៉ែធ្វើការ បរិមាណនៃឧស្ម័នជាតិឆេះនិងឧស្ម័នពុល កំដៅ និងកំរិតសំណើមកើតឡើងដែរឬទេ?

d) ចំពោះល្បឿនខ្យល់នៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែធ្យូងថ្ម (ប្រភេទA និងប្រភេទB) តើមានបានគោរពតាមចំនួននៃការកំណត់ដោយបទបញ្ញតិនិងច្បាប់ដែរឬទេ?

e) ចំពោះនៅក្នុងការដ្ឋានរ៉ែបិទ តើបានតំឡើងដាច់ដោយឡែកពីគ្នាចំពោះខ្យល់ចូលនិខ្យល់ចេញដែរឬទេ?

f) ចំពោះកង្ហាលសំខាន់ៗ ត្រូវបានតំឡើងដោយមានរចនាសម្ព័ន្ធទប់ស្កាត់អគ្គិភ័យ និងតើត្រូវបានតំឡើងនៅទីតាំងដោយពុំមានការបឺតខ្យល់ដែលចេញពីរូងបានដែរឬទេ?

g) នៅការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែធ្យូងថ្ម (ប្រភេទA និងប្រភេទB) នៅពេលអោយខ្យល់ឆ្លងកាត់តាមរយៈកង្ហាលខ្នែង តើមានបានគោរពតាមចំនុចដែលត្រូវបានកំណត់ដោយច្បាប់និងបទញ្ញតិ ដែរឬទេ?

i ) ចំពោះកង្ហាលខ្នែង ត្រូវតំឡើងនៅទីតាំងដែលមិនអាចបឺតខ្យល់ចេញពីក្នុងរូង ចំពោះបរិមាណខ្យល់ឆ្លងកាត់ទីតាំងនោះគឺត្រូវមានសមត្ថភាពលើសពីកង្ហាលនោះ ដោយកុំអោយមានបាតុភូតការបឺតខ្យល់ដដែលៗនៅក្នុងទីនោះបាន។

ii ) ចំពោះកង្ហាលខ្នែង ត្រូវតែដំណើរការជាប់គ្នារហូត។

iii) បំពង់ខ្យល់នៃកង្ហាលខ្នែង ត្រូវតែតំឡើងដោយមានវិធានការទប់ស្កាត់ខ្យល់លេចនិងរក្សាអោយមានសភាពល្អរហូត។

iv ) ចំពោះខាងចុងនៃបំពង់ខ្យល់របស់កង្ហាលខ្នែង ត្រូវរក្សាអោយបានមិនអោយលើសពី៧ម៉ែត្រពីផ្ទៃមុខការងារ ឬពីកន្លែងជីកយករ៉ែ។

h) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង ក្រោយពីបានបញ្ឈប់ដំណើរការកង្ហាលខ្នែង នៅពេលចង់ដំណើរការកង្ហាលខ្នែងឡើងវិញ ធ្វើការវាស់ពីកំហាប់នាំឧស្ម័នជាតិឆេះ និងក្រោយពីបានបញ្ជាក់ថាគ្មានឧស្ម័នដែលអាចនឹងបណ្តាលគ្រោះថ្នាក់រួចហើយ តើបានដំណើរការកង្ហាលនោះឡើងវិញដែរឬទេ?

i) ចំពោះផ្លូវឆ្លងកាត់ទាក់ទងនឹង រវាងរូងបញ្ឈរសំរាប់បញ្ចេញខ្យល់និងរូងបញ្ឈរសំរាប់បញ្ចូលខ្យល់ ឬ រវាងផ្លូវបញ្ចូលខ្យល់សំខាន់ៗនឹងផ្លូវបញ្ចេញខ្យល់សំខាន់ៗ នៃការ

ដ្ឋានរ៉ែបិទអាជីវកម្មរ៉ែត្បូងថ្ម (ប្រភេទ A និងប្រភេទ B) តើមានតំឡើងជញ្ជាំងឬទ្វាបិទបើកដែរឬទេ?

2) ឧស្ម័ននៅក្នុងរូង

a) នៅពេលមានឧស្ម័នជាតិឆេះលើសពី 1. 5% នៅទីកន្លែងធ្វើការនៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ឬនៅក្នុងខ្យល់ចេញនោះ នៅពេលមានសភាពគ្រោះថ្នាក់ តើមានបានផ្តាច់ការបញ្ចូលចរន្ត និងមានជន្លៀសកម្មកររ៉ែចេញពីកន្លែងនោះ និងមានលើកផ្លាកសញ្ញាប្រយ័ត្នដែរឬទេ?

b) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែត្បូងថ្ម (ប្រភេទ A និងប្រភេទ B) នៅពេលជីកយករ៉ែនិងធ្វើការខួងទៅមុខ នៅពេលអាចនឹងមានគ្រោះថ្នាក់តាមរយៈការកើនឡើងជាខ្លាំងនៃឧស្ម័នជាតិ១ឆេះ តើមានចាត់វិធានការ ខួងទុកជាមុន ខួងយកឧស្ម័នចេញ និងចាត់វិធានការសមរម្យផ្សេងៗទៀតដែរឬទេ?

c) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែត្បូងថ្ម (ប្រភេទ A និងប្រភេទ B) ចំពោះផ្លូវបោះបង់ចោលឬទីកន្លែងយករ៉ែច្រើនដែលបានបោះបង់ចោល តើមានចាត់វិធានការ លុបបន្ថែម បិទផ្ជិត និងចាត់វិធានការសមរម្យផ្សេងៗទៀតដែរឬទេ?

3) កំហិតនៃការប្រើប្រាស់ភ្លើង

a) នៅក្នុងការដ្ឋានរ៉ែបិទ ករណីធ្វើការងារផ្សា ឬផ្សាកាត់តាមរយៈចរន្តអគ្គិសនី ដុសដុល នៅក្នុងទីកន្លែងមានសុវត្ថិភាពតាមវិធីសុវត្ថិភាព ដោយបានទទួលការណែនាំពីអ្នកគ្រប់គ្រងទទួលបន្ទុកសុវត្ថិភាពចរន្តអគ្គិសនី ឬលើកលែងករណីប្រើភ្លើង តើមានប្រើភ្លើងនៅក្នុងរូងនោះដែរឬទេ?

b) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែត្បូងថ្ម (ប្រភេទ A និងប្រភេទ B) ចំពោះតើមានធ្វើការពិនិត្យនៅមាត់ច្រកចូលរូង រកមើលមានអ្នកខ្លះអាចយកបារី ដែកកេះ បរិក្ខារបង្កើតភ្លើងដែរឬទេ?

c) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទអាជីវកម្មរ៉ែត្បូងថ្ម (ប្រភេទ A និងប្រភេទ B) នៅពេលចូលទៅក្នុងរូង តើកម្មកររ៉ែ មានបានកាន់យកបារី ដែកកេះ បរិក្ខារបង្កើតភ្លើងដែរឬទេ?

(11) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងធូលីហ៊ុយ នៅក្នុងទីកន្លែងធ្វើការ និងនៅក្រៅរូង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងការគ្រប់គ្រងធូលីហ៊ុយ នៅក្នុងទីកន្លែងធ្វើការ និងនៅក្រៅរូង ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

1) ការគ្រប់គ្រងធូលីហ៊ុយ នៅក្រៅរូង

a) អគារត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិ ដូចជាទីកន្លែងកិនថ្មដែលមានធូលីហុយច្រើន រទេះចាក់ថ្មរ៉ែ ទីកន្លែងជ្រើសរើសរ៉ែ ទីកន្លែងរំលាយរ៉ែ ទីកន្លែងលាងធ្យូងថ្ម និងទីកន្លែងជីកយករ៉ែបែបការដ្ឋានរ៉ែបើក តើទីតាំងទាំងនោះមានត្រូវបានចាត់វិធានការសមរម្យដោយមានការបិទផ្និតចំពោះបរិក្ខារឬម៉ាស៊ីនទាំងនោះ ប៉ូបធូលី បាចទឹកសំរាប់ការពារកម្មកររ៉ែតាមរយៈទប់ស្កាត់ធូលីហុយ។

b) ចំពោះទីកន្លែងធ្វើការងារត្រូវនឹងចំនុចa) ដែលបានសរសេរដូចខាងលើ ករណីមានភាពចាំបាច់សំរាប់សុវត្ថិភាព តើមានបានអោយកម្មកររ៉ែប្រើម៉ាសធូលីដែលត្រូវនឹងស្តង់ដាដែរឬទេ?

c) ចំពោះទីកន្លែងធ្វើការងារត្រូវនឹងចំនុចa) ដែលបានសរសេរដូចខាងលើ ដើម្បីការពារសុខភាពរបស់កម្មកររ៉ែ តើមានតំឡើងទីកន្លែងសំរាកនៅទីកន្លែងក្រៅពីទីកន្លែងធ្វើការដែរឬទេ? លើសពីនេះ ចំពោះទីកន្លែងសំរាកខាងលើ តើមានបំពាក់សំភារៈដែលអាចយកធូលីជាប់នៅនឹងសំលៀកបំពាក់កម្មកររ៉ែបាន។

d) អ្នកគ្រប់គ្រងការងារទទួលបន្ទុកបំផ្ទុះនិងសុវត្ថិភាពក្រៅរូង ស្តីពីទីកន្លែងមានធូលីហុយខ្លាំង នៅទីកន្លែងធ្វើការនៅក្នុងបន្ទប់ក្រៅរូង ធ្វើការវាស់នូវអត្រាភាគរយសារធាតុអាស៊ីតស៊ីលីស៊ីតនៅក្នុងធូលី និង កំហាប់នៃធូលីនៅក្នុងខ្យល់ដែលត្រូវបានកំណត់ដោយច្បាប់ តើមានធ្វើការរាយការណ៏ចំពោះគ្រប់គ្រងព្រមទាំងកត់ត្រានូវលទ្ធផលទាំងនោះដែរឬទេ?

2) ទីកន្លែងធ្វើការនិងផ្លូវដើរនៅក្នុងការដ្ឋានរ៉ែលើដី

a) ចំពោះជណ្តើរត្រូវបានបង្កើតនៅក្នុងអគារនៅក្រៅរូង តើចំនុចត្រូវបានគោរពមានដូចខាងក្រោម ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

i) ជារចនាសម្ព័ន្ធរឹងមាំ។

ii) ចំពោះថាសជណ្តើរនិងផ្នែកកាំជណ្តើរ ត្រូវបានតំឡើងនៅក្នុងគំលាតស្មើៗ។

iii) នៅពេលមានកំពស់លើសពី១០ម៉ែត្រ ត្រូវតំឡើងថាសជណ្តើរសមរម្យក្នុងប្រវែង១០ម៉ែត្រមួយ។

iv) ត្រូវតំឡើងបង្កាន់ដៃម្ខាងនៃជណ្តើរ។

b) នៅក្រៅរូងមានកម្មកររ៉ែធ្វើការមានលើសពី៣០នាក់ ចំពោះបន្ទប់នៅក្រោមដីឬអគារមានលើសពី២ជាន់ឡើង តើមានតំឡើងជណ្តើរលើសពី២សំរាប់ឆ្លងទៅកាន់ទីកន្លែងសុវត្ថិភាពនៅក្រៅអគារបានដោយស្រួលដែរឬទេ។

c) ចំពោះនៅជុំវិញផ្លូវមានទ្រង់ទ្រាយជាស្ពាន ជើងទំរ ជំណើរដែលត្រូវបានតំឡើងនៅក្រៅរូង។

d ) ចំពោះផ្ទៃបាតនៃទីកន្លែងធ្វើការនៅក្រៅរូង តើមានរក្សាបាននូវស្ថានភាពសុវត្ថិភាព

មានរចនាសម្ព័ន្ធមិនគ្រោះថ្នាក់តាមរយៈ ការជំពុប រអិល។ល។

e) ចំពោះនៅក្នុងទីកន្លែងធ្វើការងារ និងទីកន្លែងឆ្លងកាត់ទៅទីកន្លែងធ្វើការងារនៅក្រៅរូង តើមានតំឡើងផ្លូវដើរសុវត្ថិភាពសំរាប់កម្មកររ៉ែដែរឬទេ។

（１２）ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងការគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

１) ករណីដឹកជញ្ជូនសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព តើមានចាត់វិធានការចាំបាច់សំរាប់ទប់ស្កាត់ នូវការក្រឡុកចេញ លេចចេញ ហូរចេញ ឬជ្រាបចេញ សារធាតុទាំងនោះដែរឬទេ?

２) នៅពេលទុកដាក់នូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាពនៅក្នុងការដ្ឋានរ៉ែ តើមានតាមចំនុចដែលមានដូចខាងក្រោមតាមការកំណត់ដោយច្បាប់និងបទបញ្ញត្តិ ដែរឬ ទេ?

a) ត្រូវរក្សាដោយធ្វើការបែងចែកសារធាតុពុល សារធាតុបំផ្លាញសុខភាព និងសារធាតុផ្សេងទៀត អោយដាច់ពីគ្នា។

b) ចំពោះស៊ីទែន ធុង និងប្រដាក់សារធាតុពុល សារធាតុបំផ្លាញសុខភាព និងប្រដាប់ដាក់ផ្សេងទៀត ត្រូវធ្វើយ៉ាងណាកុំអោយមានការក្រឡុកចេញ លេចចេញ ហូរចេញ ឬជ្រាបចេញសារធាតុពុលបំផ្លាញសុខភាពដែលនឹងអាចមានគ្រោះថ្នាក់។

３) ចំពោះបរិក្ខាររក្សាដាក់សារធាតុពុលបំផ្លាញសុខភាពនៅក្នុងការដ្ឋានរ៉ែ តើមានជារចនាសម្ព័ន្ធចាក់សោរ ដើម្បីទប់ស្កាត់ភាពចោរកម្ម ដែរឬទេ?

បើក្នុងករណីមិនអាចធ្វើការចាក់សោរបានតាមរយៈអគាររក្សាទុកនូវសារធាតុទាំងនោះ ចំពោះនៅជុំវិញទីនោះ តើមានតំឡើងនូវរបងរឹងមាំដែរឬទេ?

４) ស្តីពីទីកន្លែងជ្រើសរើសរ៉ែប្រើប្រាស់សារធាតុពុលនិងបំផ្លាញសុខភាព ទីកន្លែងចំរាញ់រ៉ែ និងអគារផ្សេងៗ នៅការដ្ឋានរ៉ែ តើមានបានគោរពតាមចំនុចដែលមានដូចខាងក្រោមដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

a) ត្រូវជារចនាសម្ព័ន្ធមានក្តាបន្ទះទ្រាប់ ជាបេតុង សំរាប់កុំអោយជាការជ្រាប ហូរចេញ ជ្រាបចេញ ក្រឡុកហើរចេញ បាន។

b) ចាំបាច់ត្រូវរៀបចំអោយមាននូវបរិក្ខារ សារធាតុថ្នាំគីមីសំរាប់បន្សាបសារធាតុពុល ឬអគារចំរាញ់ទឹកកខ្វក់រួមទាំងប្រាស់សារធាតុពុលនិងបំផ្លាញសុខភាព។

５) នៅការដ្ឋានរ៉ែ ក្នុងការផលិតសារធាតុពុលនិងបំផ្លាញសុខភាព ក្នុងការប្រើប្រាស់សារធាតុទាំងនោះច្រើន នៅពេលផ្អាកការងារអាជីវកម្មរ៉ែ នៅពេលចង់ឈប់លើសពីរយៈ

ពេល៦ខែក្នុងការប្រើឬផលិតសារធាតុទាំងនោះ ឬ ចង់ឈប់ប្រើឬផលិតសារធាតុពុល និងបំផ្លាញសុខភាពតាមរយៈការបាត់បង់សិទ្ធធ្វើអាជីវកម្មរ៉ែ ស្តីពីសារធាតុនៅសល់មុននឹងបញ្ឈប់ឬផ្អាកសកម្មភាពនោះ១ខែ តើមានធ្វើការបំលែងបន្សាបសារធាតុទាំងនោះតាមការកំណត់ដោយច្បាប់និងបទបញ្ញតិដែរឬទេ?

**ចំណែកបន្ថែមនៃចំនុចត្រួតពិនិត្យទូទៅត្រូវបានកំណត់នៅក្នុងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ(ដំណាក់កាលទី២)**

**ជំពូក២ : អនុវត្តត្រួតពិនិត្យទូទៅ** (ចំនុចចំណែកបន្ថែម)

3. អនុវត្តត្រួតពិនិត្យទូទៅនៅទីកន្លែងធ្វើការងារ

ចំពោះនៅពេលត្រូវបានអនវត្តបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ ទាក់ទងនឹងការត្រួតពិនិត្យនៅទីកន្លែងធ្វើការ(ដំណាក់កាលទី២) ស្តីពីចំនុចខាងក្រោមត្រូវបានកំណត់ដោយបទបញ្ញតិនេះ ក្នុងនាមអនុវត្តត្រួតពិនិត្យចំនុចសំខាន់បន្ថែម ស្តីស្តីពីចំនុចត្រូវបានសន្និដ្ឋាននិងមានមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែ។

(3) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗទាក់ទងនឹងការងារបំផ្ទុះនិងប្រភេទនៃរំសេវ

4) នៅការដ្ឋានរ៉ែបិទប្រភេទរ៉ែធ្យូងថ្ម (ប្រភេទA) នៅពេលធ្វើការបំផ្ទុះនៅទីកន្លែងត្រូវបានកំណត់នៅទីកន្លែងប្រយ័ត្នចំពោះឧស្ម័នចេញ តើមានបានគោរពនូវចំនុចដូចមានខាងក្រោមត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញតិ ដែរឬទេ?

a) ក្រោយពីបានអោយកម្មកររ៉ែទីកន្លែងសុវត្ថិភាពចំពោះទីកន្លែងឧស្ម័នចេញ ការបំផ្ទុះតាមរយៈវិធីគីបអគ្គិសនី។

b) ការចុចកុងតាក់សំរាប់បំផ្ទុះ ត្រូវអនុវត្តនៅទីកន្លែងមានសុវត្ថិភាពនៅភាគខាងខ្យល់ចូល ឬនៅក្នុងអគារមានសុវត្ថិភាពទប់ទល់នឹងឧស្ម័នចេញ ។

c) ក្រោយបានបំផ្ទុះ តាមរយៈការធ្វើអោយផ្ទុះនូវប្រភេទនៃរំសេវដែលបានបំពាក់ មិនត្រូវអោយកម្មកររ៉ែចូលទៅជិតទីកន្លែងបានបំផ្ទុះ រហូតដល់បញ្ជាក់បានពីភាពមានសុវត្ថិភាពសិន។

d) ត្រូវប្រើសារធាតុបំផ្ទុះភ្ជាប់ដោយស្រោមមានសុវត្ថិភាព ឬប្រើសារធាតុណាមានកំរិសុវត្ថិភាពលើសពីនេះថែមទៀត។

5) នៅការដ្ឋានរ៉ែបិទប្រភេទរ៉ែធ្យូងថ្ម (ប្រភេទA) ស្តីពីទីកន្លែងធ្វើការអាចនឹងកើតមានគ្រោះថ្នាក់ច្រើនកើលឡើងគួរអោយកត់សំគាល់ តាមរយៈភាគរយមានឧស្ម័នជាតិឆេះ ឬទីកន្លែងធ្វើការងារអាចនឹងមានគ្រោះថ្នាក់ដោយសារការផ្ទុះនៃធូលីធ្យូងថ្ម តើមានបានគោរពតាមចំនុចដូចមានខាងក្រោម ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញតិដែរឬទេ?

a) ស្តីពីប្រភេទនៃវំសេវប្រើប្រាស់ និងបរិមាណព្រមទាំងចំនួនប្រភេទនៃបរិក្ខារបំផ្ទុះ និងគិប អគ្គិសនី ម្ចាស់អាជីវកម្មរ៉ែជាអ្នកកំណត់។

b) ត្រូវប្រើសារធាតុបំផ្ទុះមានសុវត្ថិភាពព្រមទាំងស្រោបដោយស្រោម។

6 ) នៅការដ្ឋានរ៉ែបិទប្រភេទរ៉ែធ្យូងថ្ម (ប្រភេទA ) នៅពេលធ្វើការបំផ្ទុះនៅក្នុងរូងដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុះនិងសុវត្ថិភាពក្នុងរូង តើមានបានគោរពតាមចំនុចដូចមានខាងក្រោម ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

a) នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ច្រើនដោយឆ្លោងប៉ើង ឬហ៊ុយដោយធូលីធ្យូងថ្មមានភាពផ្ទុះ ស្តីពីទំហំនៃ៥ម៉ែត្រម្តងនៃទីកន្លែបានធ្វើការបំផ្ទុះ ធ្វើការពិនិត្យពីភាពមានគ្រោះថ្នាក់ពីធូលីធ្យូងថ្មមានភាពផ្ទុះ។

b) នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ច្រើនដោយឆ្លោងប៉ើង ឬហ៊ុយដោយធូលីធ្យូងថ្មមានភាពផ្ទុះ ចំពោះករណីបំផ្ទុះផ្តាច់ចូលទៅក្នុងរូងផ្សេងទៀត ចំពោះផ្នែកខាងដែលបានផ្ទុះឆ្លងនោះ ធ្វើការពិនិត្យមានឬមិនមានគ្រោះថ្នាក់ ស្តីពីឧស្ម័នមានជាតិឆេះ និងធូលីធ្យូងថ្មមានភាពផ្ទុះគួរអោយកត់សំគាល់។

c) នៅពេលអាចនឹងមានគ្រោះថ្នាក់ច្រើនដោយធូលីធ្យូងថ្មមានភាពផ្ទុះ នៅពេលអាចនឹងមានគ្រោះថ្នាក់តាមរយៈឧស្ម័នច្រើន និងការកើនឡើងដោយឧស្ម័នមានភាពឆេះ នៅទីកន្លែងដូចគ្នាក្រៅពីវិធីបំផ្ទុះតាមបែបអគ្គិសនី មិនត្រូវធ្វើការបំផ្ទុះលើសពី២ដងក្នុងពេលតែមួយទេ។

(6) ចំនុចត្រួតពិនិត្យសំខាន់ៗទូទៅបន្ថែមទាក់ទងនឹងអគ្គភ័យនៅក្នុងរូងនិងការឆេះដោយធម្មជាតិ

3) នៅការដ្ឋានរ៉ែបិទប្រភេទរ៉ែធ្យូងថ្ម (ប្រភេទA) តើមានតំឡើងនូវបរិក្ខារវាស់នូវអត្រាបរិមាណឧស្ម័នជាតិឆេះ នៅក្នុងរូង តើមានតំឡើងបន្ទប់ត្រួតពិនិត្យតាមដាននៅក្រៅរូងពីនូវលទ្ធផលដែលចាប់បាន នោះដែរឬទេ?

4) ចំពោះបន្ទប់ត្រូវបានតំឡើង សំរាប់ត្រួតពិនិត្យតាមដាននៅក្រៅរូង នៃការដ្ឋានរ៉ែបិទប្រភេទរ៉ែធ្យូងថ្ម (ប្រភេទA) តើមានបានតំឡើងបរិក្ខារដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែលមានដូចខាងក្រោមដែរឬទេ?

a) នៅក្នុងបន្ទប់តាមដានពិសេស តើមានបានតំឡើងនូវបរិក្ខារវាស់ជាប់រហូត ពីអត្រានៃបរិមាណឧស្ម័នឆេះនៅក្នុងទីកន្លែងចាំបាច់សំខាន់ៗនៃតំបន់ប្រយ័ត្នឧស្ម័នចេញ ឬនៅក្នុងចរន្តខ្យល់ចេញនៃកន្លែងខ្វែងសំខាន់ៗនៅក្នុងរូង ដែរឬទេ?

b) នៅក្នុងបន្ទប់តាមដានពិសេស តើមានបានតំឡើងនូវបរិក្ខារវាស់ជាប់រហូតនូវអត្រាភាគរយនៃឧស្ម័នCOនៅទីកន្លែងសំខាន់ៗនៅក្នុងបំពង់ឧស្ម័ននៃបរិក្ខារនាំឧស្ម័ន ឬនៅក្នុងចរន្តខ្យល់នាំចរន្តខ្យល់ចេញនៅក្នុងរូង ដែរឬទេ?

ចំពោះទីកន្លែងសំខាន់ផ្សេងៗនៅក្នុងបំពង់ ចាំបាច់ត្រូវតំឡើងបរិក្ខារវាស់ជាប់រហូតនូវអត្រាភាគរយរួមទាំងបរិមាណឧស្ម័នCOនៅក្នុងបំពង់ផងដែរ។

c) ចំពោះបន្ទប់តាមដានពិសេស យោងតាមរយៈភាពប្រែប្រួលនៃស្ថានភាពនៅក្នុងរូង មានកើតផ្សេង ការកើនឡើងនៃភាគរយនៃឧស្ម័នCOនៅក្នុងរូង ចាំបាច់ត្រូវតែតំឡើងនូវបរិក្ខារចាប់នូវភាពមានគ្រោះថ្នាក់ឬការកើតឡើងនៃអគ្គិភ័យនៅក្នុងទីកន្លែងចាំបាច់ផ្សេងៗ ដូចជាផ្លូវប្រើសំរាប់ដឹកជញ្ជូនដោយប្រើliftសំរាប់ដឹកមនុស្ស និងខ្សែពានដឹកជញ្ជូន បន្ទប់បិទបើកសំខាន់ៗដោយប្រើជាបរិក្ខារមានប្រេងនៅខាងក្នុង ទីកន្លែងស្តុកពពួកប្រភេទប្រេង ទីកន្លែងបំលែងចរន្តអគ្គិសនី បន្ទប់បង្គាលសំខាន់ៗ បន្ទប់ប៉ូម បន្ទប់កុំប្រែស័រ និងបិក្ខារខារ។

5）ចំពោះបន្ទប់ត្រួតពិនិត្យដែលត្រូវបានតំឡើងនៅក្រៅរូងនៃការដ្ឋានរ៉ែធ្យូងបិទ (រ៉ែធ្យូងប្រភេទ A) តើមានចាត់អោយមានអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងដែរឬទេ?

6）អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងដែលត្រូវបានចាត់ដាក់យាមនៅបន្ទុកត្រួតពិនិត្យពិសេស តើមានគោរពនូវចំនុចខាងក្រោមដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

a) ធ្វើការត្រួតពិនិត្យពិសេស ត្រូវពិនិត្យតើមានឬមិនមានការផ្ទុះនូវធូលីធ្យូងថ្មឬឧស្ម័ន ការឆេះដោយធម្មជាតិ អគ្គិភ័យ និងគ្រោះថ្នាក់ផ្សេងៗទៀត។

b) ត្រូវទាក់ទងជាចាំបាច់សំរាប់សុវត្ថិភាពនឹងកម្មកររ៉ែ ឬអ្នកគ្រប់គ្រងការងារធ្វើការនៅក្នុងរូងតាមរយៈវិទ្យុទាក់ទងនៅក្នុងរូង។

c) នៅពេលអាចមានគ្រោះថ្នាក់ ឬគ្រោះថ្នាក់ ចាត់វិធានការចាំបាច់បន្ទាន់ ដូចជាបញ្ជាអោយភៀសខ្លួន បញ្ជាអោយឈប់ការងារជាបន្ទាន់ ដល់កម្មកររ៉ែ។

d) បង្កើតសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ កត់ត្រានូវចំនុចនានាសំរាប់អ្នកទទួលធ្វើបន្តវេន និងចាត់វិធានការសំរាប់សុវត្ថិភាព។

(8) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗ បន្ថែមទាក់ទងនឹងបរិក្ខារផលិតប្រើចរន្តអគ្គិសនី

11)នៅការដ្ឋានរ៉ែអលោហៈ ការដ្ឋានរ៉ែលោហៈ និងការដ្ឋានរ៉ែបិទធ្យូងថ្ម (រ៉ែធ្យូងថ្មប្រភេទB) នៅពេល ប្រើខ្សែចរន្តសំរាប់រថភ្លើង និងខ្សែចរន្តសំរាប់ប្រព័ន្ធដឹកជញ្ជូនតាមបែបកន្រ្តក ឬនៅពេលធ្វើការភ្ជាប់ខ្សែពីក្រៅរូងទៅក្នុងរូង តើមានគោរពនូវចំនុចខាងក្រោមដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

a) ចំពោះសំពាធចរន្តនៃខ្សែរថភ្លើង ត្រូវតែជាចរន្តស្របហើយមានសំពាធទាប។

b) ចំពោះកំពស់នៅលើផ្ទៃផ្លូវដែករបស់ខ្សែចរន្តផ្គត់ផ្គង់ប្រើសំរាប់ប្រព័ន្ធផ្លូវដែកបែបព្យួរនៅ

ក្នុងអាកាស និងខ្សែចរន្តសំរាប់រថភ្លើង ត្រូវអោយមានកំពស់លើសពី1. 8ម៉ែត្រឡើង។

c) ចំពោះខ្សែចរន្តផ្គត់ផ្គង់ប្រើសំរាប់ប្រព័ន្ធផ្លូវដែកបែបព្យួរនៅក្នុងអាកាស និងខ្សែចរន្តសំរាប់រថភ្លើងដែលបានកំណត់នៅចំនុចមុន ត្រូវតំឡើងដោយមិនអោយចរន្តអាចប៉ះនឹងពិដានរូង ជញ្ជាំងរូង ទ្វាខ្យល់ឆ្លងកាត់ សរសរ។ល។

d) តំឡើងបរិក្ខារបិទបើកនៅតាមតំបន់នីមួយៗ និងនៅចំនុចខ្វែងនៃផ្លូវ។

e) នៅផ្នែកខ្សែកោង ត្រូវចាត់វិធានការសមរម្យ។ល។ដោយតំឡើងទាញអោយតឹងពីគំលាតនីមួយៗដោយមិនអោយខ្សែនោះធូរបាន។

f) ចំពោះខ្សែតឹងដែលកំណត់នៅចំនុចមុន មានសារធាតុអ៊ីសូឡង់នៅក្នុងគំលាត0. 6ម៉ែត្រ និងត្រូវតែភ្ជាប់វាអោយជាប់។

g) ចំពោះនៅទីកន្លែងមានមនុស្សឆ្លងកាត់ ត្រូវចាត់វិធានការសមរម្យដោយកុំអោយមានគ្រោះថ្នាក់កើតឡើង។

(9) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗ បន្ថែមទាក់ទងនឹងការគ្រប់គ្រងធូលីហ៊ុយ និងទីកន្លែងធ្វើការ ផ្លូវដើរនៅក្នុងរូង

4) វាយតំលៃបរិដ្ឋានការងារនៅក្នុងរូង

a) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ នៅពេលបានអនុវត្តវាស់កំហាប់ធូលីនៅទីកន្លែងធ្វើការមានទីតាំងនៅក្នុងរូងដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង តើមានធ្វើការវាយតំលៃស្តីពីបរិដ្ឋានការងារនៅក្នុងរូងដែរឬទេ? លើសពីនេះ តើមានបានរក្សានូវការកត់ត្រាទាក់ទងនឹងការវាយតំលៃបរិដ្ឋានការងារទាំងនោះ អោយលើសពី៥ឆ្នាំដែរឬទេ។

b) ស្តីពីលទ្ធផលវាយតំលៃនៃបរិដ្ឋានការងារ ក្នុងករណីមានភាពចាំបាច់កែលំអនូវកំរិតនៃកំហាប់ធូលីនៅទីកន្លែងធ្វើការនៅក្នុងរូងដែលត្រូវបានវាយតំលៃជាតំបន់គ្រប់គ្រងទី២ និងទី៣ តើមានបានខិតខំចាត់វិធានការចាំបាច់សំរាប់ធ្វើការកែលំអនូវបរិដ្ឋានការងារដែរឬទេ?

(10) ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗ បន្ថែមទាក់ទងនឹងចរន្តខ្យល់ឆ្លងកាត់ និងឧស្ម័ននៅក្នុងរូង

2) ឧស្ម័ននៅក្នុងរូង

d) ចំពោះនៅក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មជាការដ្ឋានរ៉ែបិទ (រ៉ែធ្យូងថ្មប្រភេទA) ចំពោះចំពោះទីកន្លែងមានដូចខាងក្រោម តើមានបានគោរពតាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិដែលត្រូវអោយមានតំឡើងបរិក្ខារចាប់ឧស្ម័នឆេះដោយស្វ័យប្រវត្តិអោយបានលើសពី១ ដែរឬទេ?

i) ទីកន្លែងជីកយករ៉ែ

ii) ទីកន្លែងខួងរុលទៅមុខ (លើកលែងទីកន្លែងខួងរុលទៅមុខចំពោះផ្ទាំងថ្មដែលពុំមានគ្រោះថ្នាក់ដោយសារពុំមានចេញឧស្ម័នជាតិឆេះ)

iii) ទីកន្លែងបានតំឡើងនូវបរិក្ខារផលិតប្រើចរន្តអគ្គិសនីនៅទីកន្លែងលើសពី១ភាគរយនូវអត្រាមានឧស្ម័នជាតិឆេះ

iv) ទីកន្លែចាំបាច់ផ្សេងៗនិងទីកន្លែងបានតំឡើងបរិក្ខារផលិតប្រើចរន្តអគ្គិសនីនៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ដោយសារមានឧស្ម័នជាតិឆេះកកផ្តុំនៅពេលមានភាពមិនប្រក្រតីនៃចរន្តខ្យល់ឆ្លងកាត់។

e) នៅពេលធ្វើការខួងរុលទៅមុខនិងការខួងផ្សេងៗទៀត នៅក្នុងរូងនៃការដ្ឋានរ៉ែធ្យូងថ្មប្រភេទការដ្ឋានរ៉ែបិទ (រ៉ែប្រភេទA) តើមានកំណត់ជាតំបន់មានការប្រយ័ត្នចំពោះឧស្ម័នចេញនៃតំបន់អាចនឹងមានគ្រោះថ្នាក់កើតឡើងច្រើនតាមរយៈឧស្ម័នចេញដែរឬទេ?

f) នៅពេលបានកំណត់នូវតំបន់ប្រយ័ត្ននូវឧស្ម័នចេញ តើមានប្រាប់ដល់កម្មកររ៉ែ ពីការការបង្ហាញពីទីតាំងការិយាល័យរ៉ែនៅក្រៅរូង ច្រកចូលទៅក្នុងរូង ។ល។ ដែរឬទេ?

g ) នៅពេលខួងរុលទៅមុខក្នុងរូងនៅតំបន់ប្រយ័ត្នមានឧស្ម័នចេញ តើមានដាក់អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូងនៅតាមទីកន្លែងខួងរុលទៅមុខនីមួយៗដែរឬទេ?

h)នៅពេលខួងរុលទៅមុខក្នុងរូងនៅតំបន់ប្រយ័ត្នមានឧស្ម័នចេញ ធ្វើការខួងទុកជាមុននិង ចំពោះគំលាតរវាងផ្ទៃនៃការងារខួងទៅមុខនឹងរុន្ធខួង តើមានបានរក្សានូវគំលាតសុវត្ថិភាពដែលមានប្រវែងលើសពី៥ម៉ែត្រជានិច្ចកាលពីរន្ធខួងដែរឬទេ?

i) ដើម្បីក្តាប់បាននូវស្ថានភាពឧស្ម័នជាតិឆេះនៅក្នុងរុន្ធបានខួងទុកជាមុន តាមរយៈចំនុចh) ខាងលើ ធ្វើការវាស់ពីសំពាធឧស្ម័នផុលចេញនៅមាត់រុន្ធខួងនោះ និងវាស់ពីបរិមាណនិងចំនុចចាំបាច់ផ្សេងៗទៀត តើមានបានប្រយ័ត្នពីភាពប្រែប្រួលទាំងនោះដែរឬទេ?

j) នៅពេលខួងរុលទៅមុខក្នុងរូងនៅតំបន់ប្រយ័ត្នមានឧស្ម័នចេញ តើមានបានអោយឧស្ម័នទាំងនោះឆ្លងកាត់កន្លែងយករ៉ែធ្យូងថ្មដែរឬទេ?

k)នៅតំបន់ប្រយ័ត្នមានឧស្ម័នចេញ តើមានតំឡើងអគារមានសុវត្ថិភាពសំរាប់ភៀសខ្លួនរបស់កម្មកររ៉ែ ដែលទីនោះបានបំពាក់នូវបរិក្ខារផ្តល់ខ្យល់សមរម្យ ដែរឬទេ? លើសពីនេះ ចំពោះអគារនោះ គឺមានបំពាក់នូវបរិក្ខារផ្គត់ផ្គង់អុកស៊ីសែនឬខ្យល់ តើមានបំពាក់នូវបរិក្ខារទាក់ទង ដូចជាវិទ្យុទាក់ទងដែរឬទេ?

l) ដើម្បីទប់ស្កាត់គ្រោះថ្នាក់មកពីចរន្តណឺត នៅក្នុងរូងនៃការដ្ឋានរ៉ែបិទធ្យូងថ្ម (ប្រភេទ A ) តើមានបានគោរពតាមចំនុចខាងក្រោមដែលកំណត់ដោយច្បាប់និងបទបញ្ញត្តិដែរឬទេ?

i )ស្តីពីអគារអាចនឹងមានគ្រោះថ្នាក់តាមរយៈចរន្តណឺតនៅកកផ្តុំច្រើន តើមានចាត់

វិធានការដូចជាតំឡើង បំពង់ខ្យល់ប្រើពីដ៏រដែលមានការទប់ស្កាត់នឹងចរន្តណីតបាន ប្រើសំភារៈដ៏រផ្សេងៗ ប្រើម៉ាសដី បាចទឹកនិងវិធានការផ្សេងៗទៀត។

ii )នៅពេលធ្វើការងារអាចនឹងមានគ្រោះថ្នាក់តាមរយៈចរន្តណីតនៅកកផ្ញុំ តើមានចាត់វិធានការបាចទឹកនិងវិធានការផ្សេងៗទៀតឬទេ?

（１０－２） ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗ បន្ថែមទាក់ទងនឹងធ្យូងថ្មមានភាពផ្ទុះ

１) នៅក្នុងផ្លូវដឹកជញ្ជូន និងក្នុងផ្លូវផ្សេងទៀតនៃការដ្ឋានបិទរ៉ែធ្យូងថ្ម (ប្រភេទA) តើមានការសំអាតជាប្រចាំឆ្លើយតបនឹងកំរិតធូលីហ៊ុយកករបស់ធូលីធ្យូងថ្មមានភាពផ្ទុះ។

２) នៅការដ្ឋានបិទរ៉ែធ្យូងថ្ម (ប្រភេទA) នៅទីកន្លែងត្រូវបានកំណត់ដូចមានចំនុចខាងក្រោមពីធូលីធ្យូងថ្មមានជាតិផ្ទុះ ហ៊ុយ តើមានចាត់វិធានការសមរម្យ។ល។ពីការបាចទឹកចំពោះជញ្ជាំងធ្យូងថ្ម ឬបាចទឹកសំរាប់បំបាត់ធូលីធ្យូងថ្មមានជាតិផ្ទុះហ៊ុយ។

a) ទីកន្លែងឬទីកន្លែង ជីកយករ៉ែធ្យូងថ្មដែលងាយហ៊ុយធូលីធ្យូងថ្មមានជាតិឆេះ ទីកន្លែងជីករុលទៅមុខ ។ល។ ដោយប្រើម៉ាស៊ីនជីកយករ៉ែ ពីក។ល។

b) ទីកន្លែងឬទីកន្លែងក្បែរ បំផ្ទុះស្រទាប់ធ្យូងថ្ម

c) ច្រកដាក់ថ្មធ្យូង និង ទីកន្លែងលើកដាក់ដូរទីកន្លែងផ្សេងទៀត

d) ទីកន្លែងស្តុកធ្យូងថ្មនៅក្នុងរូង

e) ទីកន្លែងដាក់ធ្យូងថ្មទៅក្នុងរទេះដឹកធ្យូងថ្ម

３) នៅក្នុងរូងនៃការដ្ឋានបិទរ៉ែធ្យូងថ្ម (ប្រភេទA) ចំពោះទីកន្លែងមានធូលីធ្យូងថ្មមានជាតិផ្ទុះហ៊ុយកក តើមានការបាចម្សៅថ្ម ជានិច្ចជាកាលដែរឬទេ។

４) នៅក្នុងរូងនៃការដ្ឋានបិទរ៉ែធ្យូងថ្ម (ប្រភេទA) ដើម្បីទប់ស្កាត់ការផ្ទុះបន្តបន្ទាប់គ្នានៃធូលីធ្យូងថ្មមានភាពផ្ទុះ ចំពោះទីកន្លែងច្រកចេញនិងច្រកចូលនៃទីកន្លែងធ្វើការក្នុងរូង តើមានតំឡើងនូវបរិក្ខារទប់ស្កាត់ផ្ទុះបន្តបន្ទាប់គ្នាដោយរៀបចំអោយមានធ្នើដាក់ម្សៅថ្ម ឬធ្នើដាក់ទឹក។ល។ ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិ។

（１１） ចំនុចត្រួតពិនិត្យទូទៅសំខាន់ៗ បន្ថែមទាក់ទងនឹងការគ្រប់គ្រងធូលីហ៊ុយ ផ្លូវដើរ និងទីកន្លែងធ្វើការនៅក្រៅរូង

１－２) ការវាយតំលៃបរិដ្ឋានការងារនៅក្រៅរូង

a) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង នៅពេលបានវាស់កំហាប់ធូលីនៅទីកន្លែងធ្វើការនៅក្នុងអគារមានទីតាំងនៅក្រៅរូង តើមានវាយតំលៃស្តីពីបរិដ្ឋានការងារដែរឬទេ? លើសពីនេះ តើមានរក្សានូវការកត់ត្រាទាក់ទងនឹងការវាយតំលៃបរិដ្ឋានការងារទាំងនោះដែរឬទេ?

b) ស្តីពីលទ្ធផលវាយតំលៃបរិដ្ឋានការងារនៃចំនុចa)ដែលបានសរសេរនៅខាងលើ ស្តីពី

ទីកន្លែងធ្វើការងារនៅក្នុងបន្ទប់នៅក្រៅករូង តើមានចាត់វិធានការចាំបាច់សំខាន់សំរាប់កែលំអនូវកំហាប់ធូលី ជាបន្ទាន់បានដែរឬទេ? លើសពីនេះ លទ្ធផលនៃបរិដ្ឋានការងារ ស្តីពីទីកន្លែងធ្វើការនៅក្នុងបន្ទប់ក្រៅរូងដែលត្រូវបានបែងចែកជាតំបន់គ្រប់គ្រងទី២ តើមានបានខិតខំប្រឹងប្រែងចាត់វិធានការចាំបាច់សំរាប់កែលំអនូវបរិដ្ឋានការងារដែរឬទេ?

2) ផ្លូវដើរនិងទីកន្លែងធ្វើការនៅក្រៅរូង

e) នៅទីកន្លែងធ្វើការនៅក្រៅរូង ចំពោះផ្នែកមានគ្រោះថ្នាក់តាមរយៈចលនាវិលអូសខ្សែកាប ឬចង្វាក់ ខ្សែពាន និងដុំអ័ក្សពកចេញ ឬកង់យោងដែលមានកំពស់ពីផ្ទៃជាក់ម៉ាស៊ីននោះ និងកង់យោងនោះដែលមានកំពស់ក្រោមពី២ម៉ែត្រនៅក្រៅរូង តើធ្វើរបងព័ទ្ធ ឬតំឡើងបរិក្ខារគ្រប់ និងមានតំឡើងបរិក្ខារមានសុវត្ថិភាព។ល។ផ្សេងៗដែរឬទេ?

f) ចំពោះទីកន្លែងប្រើប្រាស់របស់មានកំដៅខ្ពស់ផ្សេងៗ ឡវិល និងឡដុតរំលាយលោហៈនៃការដ្ឋានរ៉ែលោហៈ តើមានចាត់វិធានការសមរម្យសំរាប់ទប់ស្កាត់គ្រោះថ្នាក់តាមរយៈលេចចេញនូវរបស់មានកំដៅខ្ពស់ ឬការផ្ទុះផ្សេងៗ ដែរឬទេ?

g)តើមានរៀបចំអោយមាននូវបរិក្ខារការពារខ្លួន ដូចជាស្រោមដៃ ស្បែកជើងសុវត្ថិភាព។ល។សំរាប់ទប់ស្កាត់ការរលាក ឬគ្រោះថ្នាក់ផ្សេងៗ និងតើមានអោយអ្នកមានសញ្ញាប័ត្រធ្វើការនៅទីកន្លែងរំលាយដែលកំដៅ ដែរឬទេ?

h) ចំពោះទីកន្លែងប្រើធូបផ្សា តើមានរៀបចំអោយមាននូវបរិក្ខារការពារខ្លួន ដូចជាស្រោមដៃ វែនតាការពារភ្នែក។ល។ និងតើមានអោយអ្នកមានសញ្ញាប័ត្រធ្វើការការងារផ្សាទាំងនោះដែរឬទេ?

i) ត្រូវបញ្ឈប់ម៉ាស៊ីនជាមុន នៅពេលធ្វើការជួសជុលគ្រឿងចក្រឬពិនិត្យគ្រឿងចក្រ អ្នកដែលត្រូវបានកំណត់ជាអ្នកគ្រប់ការងារទាំងឡាយ ឬអ្នកគ្រប់គ្រងការងារផ្នែកសុវត្ថិភាពគ្រឿងចក្រ ក្រៅពីលើកផ្លាកសញ្ញាប្រយ័ត្ន ប្រាប់ពីការបញ្ឈប់ម៉ាស៊ីន នៅក្នុងពេលធ្វើការងារ តើមានចាត់វិធានការមានសុវត្ថិភាពពិតប្រាកដសំរាប់ទប់ស្កាត់នូវការបើកបរគ្រឿងចក្រទាំងនោះពីសំណាក់អ្នកដ៏ទៃដែរឬទេ?

**ជំពូកទី៣ វិធានការក្រោយពីបានត្រួតពិនិត្យទូទៅរួច**

1 . វិធានការលើការត្រួតពិនិត្យនៅក្នុងករណីត្រូវបានទទួលស្គាល់មានគ្រោះថ្នាក់អាចនឹងឈានមកដល់ក្នុងពេលបន្ទាន់បន្តិចទៀត ឬចំនុចចាំបាច់ត្រូវកែលំអ ដែលល្មើសនឹងច្បាប់និងបទបញ្ញត្តិ

1) លទ្ធផលត្រួតពិនិត្យទូទៅ ករណីត្រូវបានទទួលស្គាល់ថាមានចំនុចចាំបាច់ត្រូវកែលំអ និងមាន

ល្មើសនឹងច្បាប់និងបទបញ្ញត្តិ ត្រូវធ្វើការបញ្ជាក់រួមគ្នាដោយមានការចូលរួមពីសំណាក់ភាគីខាងការដ្ឋានរ៉ែ យោងតាមការកំណត់នៃមាត្រាទី៧–១នៃ「បទបញ្ញត្តិត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ」 អនុវត្តណែនាំកែលំអ។ល។សំរាប់រក្សាបាននូវសុវត្ថិភាព ព្រមទាំងចេញ「លិខិតបង្គាប់ណែនាំកែលំអ」 ដល់ម្ចាស់អាជីវកម្មរ៉ែ។

2) ការងារទាំងនោះ ករណីត្រូវបានទទួលស្គាល់ថាមានចំនុចចាំបាច់ត្រូវកែលំអ និងមានល្មើសនឹងច្បាប់និងបទបញ្ញត្តិ យោងតាមការកំណត់នៃមាត្រាទី៨–១នៃ「បទបញ្ញត្តិត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ」ស្តីពីការងារទាំងនោះអាចនឹងមានគ្រោះថ្នាក់កាន់តែឈានមកកល់លើផ្នែកសុវត្ថិភាព និងល្មើសនឹងបទបញ្ញត្តិនិងច្បាប់ ត្រូវធ្វើការបញ្ជាក់រួមគ្នាដោយមានការចូលរួមពីសំណាក់ភាគីខាងការដ្ឋានរ៉ែ ធ្វើការបញ្ជាណែនាំនិងព្រមានអោយកែលំអជាបន្ទាន់ ព្រមទាំងលេច「លិខិតបញ្ជា」ដល់ម្ចាស់អាជីវកម្មរ៉ែ។

3) ស្តីពីចំនុចសំខាន់ដែលត្រូវធ្វើការកែលំអជាបន្ទាន់និងចំនុចចាំបាច់សំរាប់កែលំអដូចមានសរសេរខាងលើ ស្តីពីចំនុចត្រូវបានទទួលស្គាល់ថានឹងអាចមានគ្រោះថ្នាក់គំរាមមកដល់ ព្រមទាំងការងារដែលល្មើសនឹងច្បាប់និងបទបញ្ញត្តិ កំណត់ខ្លឹមសារការងារនិងទីកន្លែង ត្រូវកត់ត្រាអោយបានប្រាកដប្រជាលើសៀវភៅពីចំនុចទាំងនោះ និងព្រមទាំងស្រាវជ្រាវដោយលំអិត វាស់ដោយឆ្លើយតបនឹងភាពចាំបាច់ ចំពោះលទ្ធផលទាំងនោះ ក៏ត្រូវធ្វើការកត់ត្រា ក្រៅពីនោះស្តីពីស្ថានភាពការងារ ទីកន្លែងចាំបាច់មួយចំនួនធ្វើការកត់ត្រាលើសៀវភៅ និងការថតរូបថែមទៀត។

2. ពិធីបើកសំពោធពន្យល់ស្តីពីលទ្ធផលការត្រួតពិនិត្យពិសេស (ទប់ស្កាត់គ្រោះថ្នាក់)

បុគ្គលិកពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ដែលបានអនុវត្តការត្រួតពិនិត្យពិសេស (ទប់ស្កាត់គ្រោះថ្នាក់) ចំពោះម្ចាស់អាជីវកម្មរ៉ែ អ្នកគ្រប់គ្រងសុវត្ថិភាពទូទៅ អ្នកតំណាំងអ្នកគ្រប់គ្រងទូទៅ អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និងអ្នកគ្រប់គ្រងការងារ អនុវត្តការសាកសួរពីភាគីការដ្ឋានរ៉ែ ព្រមទាំងពន្យល់ដោយលំអិតពីការមើលឃើញទូទៅស្តីពីលទ្ធផលត្រួតពិនិត្យអនុវត្តដោយមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ និងបានស្នើរសុំអោយមានការកែលំអ ចំនុចត្រូវបានទទួលស្គាល់អោយមានការកែប្រែជាបន្ទាន់ ក្រោយពីបញ្ចប់ការត្រួតពិនិត្យ។

3. របាយការណ៍និងការបង្កើតរបាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)

បុគ្គលិកពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ដែលបានអនុវត្តការត្រួតពិនិត្យពិសេស (ទប់ស្កាត់គ្រោះថ្នាក់) អនុលោមតាមបទបញ្ញត្តិត្រួតពិនិត្យការដ្ឋានរ៉ែមាត្រាទី២–៣ យោងតាមរយៈបែបបទគំរូដែលត្រូវបានកំណត់នៅក្នុងបែបបទនៅក្នុងសៀវភៅនេះ ចាំបាច់ត្រូវតែរាយការណ៍ដល់អគ្គទទួលបន្ទុកការងាររ៉ែ (ចំពោះករណីមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែដែលត្រូវបានបែងចែកនៅតាមមន្ទីរនានា ត្រូវរាយការណ៍ឆ្លងប្រធានមន្ទីជាមុនសិន) និងបង្កើតនូវ「របាការណ៏ត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)」។

ចំពោះរបាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់) ក្រៅពីចំនុចដែលត្រូវបានកំណត់នៅក្នុងបែបបទនេះ ត្រូវរៀបចំសរុបនូវចំនុចដែលមានដូចខាងក្រោម ស្តីពីស្ថានភាពទាំងនោះ ត្រូវសរសេរលំអិតដែលមានដូចខាងក្រោម។

1) លទ្ធផលនៃការត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់) ចំនុចត្រូវបានទទួលស្គាល់ដែលបានល្មើសនឹងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ
2) ចំនុចបានប្រកាសណែនាំនូវ លិខិតបង្គាប់ណែនាំកែលំអ ដោយអនុលោមតាមបទបញ្ញតិត្រួតពិនិត្យការដ្ឋានរ៉ែ។
3) ចំនុចបានប្រកាសជា「លិខិតបញ្ជា」ដោយអនុលោមតាមបទបញ្ញតិត្រួតពិនិត្យការដ្ឋានរ៉ែ។
4) ចំនុចនៅមានការសង្ស័យ ចំនុចត្រូវមានការត្រួតពិនិត្យទូទៅសំរាប់បន្តត្រួតពិនិត្យលើកក្រោយ។
5) ការមើលសរុបទូទៅរបស់មន្ត្រីត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ។

## បែបបទរបាយការណ៍ពីការត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)

1. ឈ្មោះការដ្ឋានរ៉ែ (ឈ្មោះប្រភេទរូងនៅក្នុងការដ្ឋានរ៉ែធ្យូងថ្ម) :
2. ឈ្មោះប្រភេទរ៉ែនិងលេខតំបន់រ៉ែ :
3. ទីតាំងនៃការដ្ឋានរ៉ែ :
4. ទីតាំងការិយាល័យ លេខទូរស័ព្ទទំនាក់ទំនង។ល។ :
5. ម្ចាស់អាជីវកម្មរ៉ែ (ឈ្មោះអ្នកតំណាំង ក្នុងករណីជាក្រុមហ៊ុន) :
6. អាស័យដ្ឋានរបស់ម្ចាស់អាជីវកម្មរ៉ែ លេខទូរស័ព្ទទំនាក់ទំនង។ល។ :
7. ឈ្មោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម (កាលបរិច្ឆេទនៃថ្ងៃចាត់តាំង) :
8. ឈ្មោះអ្នកតំណាំងអ្នកគ្រប់គ្រងសុវត្ថិភាពរួម (កាលបរិច្ឆេទនៃថ្ងៃចាត់តាំង) :
9. ឈ្មោះអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និងចំនួនអ្នកគ្រប់គ្រងការងារតាមផ្នែកនីមួយៗ
   1) នួនអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព
   2) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្រៅរូង
   3) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះនិងសុវត្ថិភាពក្នុងរូង
   4) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ
   5) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពអគ្គិសនី
   6) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន
   7) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកក្បាលរថភ្លើង
   8) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកផ្នែករំសេវ

9) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសារធាតុពុលនិងបំផ្លាញសុខភាព

១០. ចំនួនកម្មកររ៉ែដែលកំពុងធ្វើការរាល់ថ្ងៃ (លើកលែងចំនួនកម្មកររ៉ែទទួលបន្ទុកផ្នែកផ្សេងៗ និងអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព)

1) ចំនួនកម្មកររ៉ែដែលកំពុងធ្វើការក្រៅរូង

2) ចំនួនកម្មកររ៉ែដែលកំពុងធ្វើការនៅក្នុងរូង

១១. ទំនាក់ទំនងនឹងការងាររ៉ែ

1) ប្រវត្តិនៃការងាររ៉ែនិងកាលបរិច្ឆេទចាប់ផ្តើមការងាររ៉ែ :

2) វិធីនៃការជីកយករ៉ែ :

3) បរិមាណផលិត (តោន／ខែ) :

4) បរិមាណបំបែកឬចំរាញ់រ៉ែ (តោន／ខែ)

a) បរិមាណបំបែករ៉ែ (តោន／ខែ) :

b) បរិមាណចំរាញ់រ៉ែនិងគុណភាពរ៉ែ (តោន／ខែ) :

5) បរិមាណរំលាយចំរាញ់ ឬដុតរ៉ែ (តោន／ខែ)

a) បរិមាណដុតចំរាញ់រ៉ែ (តោន／ខែ) :

b) បរិមាណចំរាញ់រំលាយរ៉ែនិងគុណភាព (តោន／ខែ) :

6) បរិមាណផលិតនិងបរិមាណលក់ (តោន／ខែ)

a) បរិមាណផលិតនៃផលិតបែងចែក (តោន／ខែ) :

b) បរិមាណលក់ផលិតផលបែងចែក (តោន／ខែ) :

7) កំឡាំងអគ្គិសនីសរុបសំរាប់បរិក្ខារផលិត (KW) :

8) បរិមាណប្រើប្រភេទរំសេវផ្សេងៗ (Kg／月) :

១២. ទំនាក់ទំនងនឹងសុវត្ថិភាពការងាររ៉ែ

1) សុវត្ថិភាពចំពោះអគារផ្សេងៗ និងបរិក្ខារផលិត អគារប្រើសំរាប់ការងាររ៉ែកំណត់ដោយមាត្រាទី៩នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

(ស្តីពីចំនុចខាងក្រោម ធ្វើការរៀបចំអគារគ្រប់អគារ និងកត់ត្រានូវចំនុចនានា។)

a) ឈ្មោះអគារ :

b) កាលបរិច្ឆេទរាយការណ៍ពីផែនការណ៍របស់អគារ :

c) កាលបរិច្ឆេទនៃការអនុញ្ញាតិរបស់រដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ :

d) ខ្លឹមសាររបស់អគារ :

2） សុវត្ថិភាពចំពោះការងារទទួលធ្វើបន្តកំណត់នៅក្នុងមាត្រាទី១៩នៃច្បាប់សុវត្ថិភាពរ៉ែ

a) កាលបរិច្ឆេទរាយការណ៍នៃផែនការការងារទទួលធ្វើបន្ត :

b) ខ្លឹមសារការងារទទួលធ្វើបន្ត ចំនួនកម្មកររ៉ែអនុវត្តការងារទទួលធ្វើបន្ត :

c) រយៈពេលការងារទទួលធ្វើបន្ត :

3） សុវត្ថិភាពចំពោះការជីកយកពិសេសកំណត់នៅក្នុងមាត្រាទី២០នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

a) កាលបរិច្ឆេទនៃការរាយការណ៍ការជីកយកពិសេស :

b) កាលបរិច្ឆេទនៃការអនុញ្ញាតិរបស់រដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ :

c) ខ្លឹមសារនៃផែនការជីកយកពិសេស :

4） ស្ថានភាពរាយការណ៍ពីផែនទីសុវត្ថិភាពការដ្ឋានរ៉ែ និងបទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែ

a) កាលបរិច្ឆេទរាយការណ៍ពីបទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែ :

b) កាលបរិច្ឆេទរាយការណ៍ពីផែនទីសុវត្ថិភាពការដ្ឋានរ៉ែ :

5） ស្ថានភាពកើតឡើងនូវការបំពុលបរិដ្ឋានដោយសារអាជីវកម្មរ៉ែ

(កត់ត្រានិងរៀបចំគ្រប់រាល់ពេលកើតឡើង ស្តីពីការបំពុលធ្ងន់ធ្ងរដោយសារអាជីវកម្មរ៉ែកើតឡើងនៅក្នុងអតីតកាល និងស្តីពីចំនុចខាងក្រោម)

a) កាលបរិច្ឆេទនៃគ្រោះថ្នាក់នៅការដ្ឋានរ៉ែ :

b) ប្រភេទនៃគ្រោះថ្នាក់នៅការដ្ឋានរ៉ែ :

c) ស្ថានភាពកើតឡើងនូវគ្រោះថ្នាក់នៅការដ្ឋានរ៉ែ :

d) ចំនួនជនរងគ្រោះនៃគ្រោះថ្នាក់នៅក្នុងការដ្ឋានរ៉ែ និងកំរិតនៃការរគ្រោះ :

13. ការមើលឃើញទូទៅរបស់មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ

a) រយៈពេលអនុវត្តត្រួតពិនិត្យទូទៅ :

b) លទ្ធផលត្រួតពិនិត្យទូទៅ ចំនុចត្រូវបានទទួលស្គាល់ដែលល្មើសនឹងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ :

c) ចំនុចបានចេញប្រកាសនូវលិខិតបង្ហាញការណែនាំកែលំអ អនុលោមនឹងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ :

d) ចំនុចបានចេញប្រកាសនូវលិខិតបញ្ជា អនុលោមនឹងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ :

e) ចំនុចសង្ស័យ ចំនុចបញ្ហា និងចំនុចត្រូវធ្វើការត្រួតពិនិត្យទូទៅសំរាប់លើកក្រោយទៀត :

f) ចំនុចឃើញទូទៅរបស់មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ :

៩) ចំនុចទាក់ទងផ្សេងៗទៀត :

※ កាលបរិច្ឆេទដាក់របាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)

※ ឈ្មោះមន្ត្រីពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានដែលបានអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់គ្រោះថ្នាក់)

# បែបបទត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ (ត្រួតពិនិត្យទូទៅVol. 2 ៖ វគ្គទប់ស្កាត់បំពុលបរិដ្ឋាន)

8 August 2016

## ជំពូកទី១ : ការរៀបចំមុនការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន)

1. ចំនុចត្រូវតែក្តាប់អោយបានទុកជាមុន មុនការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន)

មន្ត្រីពាក់ព័ន្ធនិងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែទទួលបន្ទុកការងារ ខាងក្រោមមកទៀតហៅកាត់ថា「មន្ត្រីអធិការកិច្ច」) មុននឹងអនុវត្តត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន)ចំពោះការដ្ឋានរ៉ែ ចាំត្រូវតែក្តាប់បានជាមុន ពីស្ថានភាពសុវត្ថិភាព, ភាពដំណើរការរបស់ការដ្ឋានរ៉ែនោះ និង ត្រូវពិនិត្យ-ស្រាវជ្រាវពីចំនុចដែលមានដូចខាងក្រោម៖

（1） ផែនការនៃការជីកយកនិងវាយតំលៃការជះឥទ្ធិពលលើបរិដ្ឋាន(EIA)

មន្ត្រីអធិការកិច្ច ត្រូវក្តាប់អោយបានគ្រប់គ្រាន់ ស្តីពីចំនុចទាក់ទងនឹង「ការទប់ស្កាត់ការបំពុលបរិដ្ឋាន」និង「ការវាយតំលៃការជះឥទ្ធិពលលើបរិដ្ឋាន」ដែលកំណត់នៅក្នុងមាត្រា៨នៃ「ច្បាប់ទាក់ទងនឹងបែបបទវាយតំលៃការជះឥទ្ធិពលលើបរិដ្ឋាន」និង មាត្រាទី៦「ច្បាប់ទាក់ទងនឹងការគ្រប់គ្រងធនធានរ៉ែនិងការពារបរិដ្ឋាន」ព្រមទាំង「សុវត្ថិភាពការដ្ឋានរ៉ែ」នៅក្នុងផែនការជីកយកកំណត់នៅក្នុងមាត្រា២១-៤「ច្បាបទាក់ទងនឹងការជីកយករ៉ែនិងការគ្រប់គ្រងធនធានរ៉ែ」ដើម្បីអនុវត្តការងារអាជីវកម្មរ៉ែ ។

（2） បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុនសិន ស្តីពីខ្លឹមសារនិងស្ថានភាពដែលត្រូវបានកំណត់នៅក្នុងបទបញ្ញតិសុវត្ថិភាព នៅក្នុងការដ្ឋានរ៉ែ។

（3） ចំនុចត្រូវរាយការណ៍

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីការអនុញ្ញាត និងការរាយការណ៍ទាក់ទងនឹងឧបករណ៍ផលិតនិងអគារសំណង់។ល។ ប្រើប្រាស់នៅក្នុងការងារអាជីវកម្មរ៉ែ។

（4） រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពី ស្ថានភាពជ្រើសរើសអ្នកគ្រប់គ្រងសុវត្ថិភាពរួម, ស្ថានភាពនៃការជ្រើសរើសអ្នកតំណាំងអោយអ្នកគ្រប់គ្រងសុវត្ថិភាពរួមព្រមទាំងខ្លឹមសារនៃការរាយការណ៍ទាក់ទងនឹងការងារនេះ។

(5) ផែនទីសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីការបង្កើតផែនទីសុវត្ថិភាព ព្រមទាំងខ្លឹមសារនៃការរាយការណ៍ទាក់ទងនឹងការងារនេះ។

(6) ផែនការជីកយកពិសេស

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន ស្តីពីខ្លឹមសារនៃករណីបានទទួលការការអនុញ្ញាតនិងរាយការណ៍ពី 「ផែនការជីកយកពិសេស」 នៅការរដ្ឋានរ៉ែ ចំពោះការជីកយករ៉ែ នៅក្នុងដីដែលបណ្តាលនឹងអាចអោយមានគ្រោះថ្នាក់ឬការបំពុលបរិដ្ឋានកើតមាននៅការដ្ឋានរ៉ែ តាមរយៈការចេញទឹក ឬការបំពុលដោយរ៉ែ ឬនៅក្រោមបាតបឹងទន្លេសមុទ្រ។

(7) ឯកសារទប់ស្កាត់ការបំពុលបរិដ្ឋាន

មន្ត្រីអធិការកិច្ច ចំពោះការដ្ឋានរ៉ែមានទីកន្លែងចោលថ្ម ទីកន្លែងស្តុកអាចម៍រ៉ែ ទីកន្លែងស្តុ កកាកសំណល់រងឬអគារជ្រើសរើសរ៉ែ និងផ្លូវក្នុងរូងរួមទាំងរូងរាប ទេរនិងបញ្ឈរ ស្តីពីអគារសំខាន់ៗសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋានក្នុងថ្ងៃអនាគត ចាំចាប់ត្រូវតែក្តាប់អោយបានជាមុន តើការដ្ឋានរ៉ែនោះមានបានបង្កើតផែនការសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន និងបានរាយការណ៍មកដែរឬទេ។

(8) ប្រព័ន្ធប្រាក់សន្សំសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន

មន្ត្រីអធិការកិច្ច ស្តីពីអគាររបស់ការដ្ឋានរ៉ែដែលបានធ្វើបែបបទរាយការណ៍ពីវិធានការទប់ស្កាត់ការបំពុលបរិដ្ឋានចំពោះ (7) ខាងលើ ចាំបាច់ក្តាប់អោយបានគ្រប់គ្រាន់ជាមុន តើមានបានអនុវត្តច្បាស់លាស់ពីប្រព័ន្ធប្រាក់សន្សំសំរាប់ទប់ស្កាត់បរិដ្ឋាន ដែរឬទេ។

(9) ចំពោះចំនុចបញ្ហា និងចំនុចសង្ស័យ

មន្ត្រីអធិការកិច្ច ស្តីចំនុចបញ្ហា និងចំនុចសង្ស័យរបស់ការដ្ឋានរ៉ែនោះ ចាំបាច់ត្រូវតែក្តាប់អោយបានជាមុនពីខ្លឹមសារទាំងនោះ និង ពីខ្លឹមសារដែលត្រូវបានសាកសួរដោយមន្ត្រីអធិការកិច្ចដែលបានធ្វើការត្រួតពិនិត្យកាលពីលើកមុន។

(10) ស្ថានភាពទូទៅនៃការដ្ឋានរ៉ែដែលត្រូវធ្វើការត្រួតពិនិត្យ

មន្ត្រីអធិការកិច្ច ចាំបាច់ត្រូវតែក្តាប់អោយបានគ្រប់គ្រាន់ជាមុន តាមរយៈលទ្ធផលរបាយការណ៍ត្រួតពិនិត្យទូទៅដែលត្រូវបានអនុវត្តកាលពីកន្លងមក ស្ថានភាពដំណើរការការដ្ឋាននោះ ភាពប្រែប្រួលនៃបរិមាណរ៉ែដែលបានជីកយក ភាពប្រែប្រួលនៃចំនួនកម្មកររ៉ែ ស្ថានភាពគ្រោះថ្នាក់កាលពីអតីតកាលនិងស្ថានភាពកើតឡើងនូវបញ្ហាបំពុលបរិដ្ឋានដោយសាររ៉ែ និងស្តីពីស្ថានភាពនៃបទល្មើសនឹងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែនិងច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ (ខាង

ក្រោមមកទៀតហៅកាត់ថា 「ច្បាប់និងបទបញ្ញត្តិ」)។

2. ចំនុចរៀបចំជាមុនក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់គ្រោះថ្នាក់)

(1) បង្កើតផែនការអនុវត្តត្រួតពិនិត្យនិងពិគ្រោះយោបល់ទុកជាមុន ទាក់ទងនឹងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន)

មន្ត្រីអធិការកិច្ច ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន) យោងតាមទំហំដំណើរការសកម្មភាពនៃការដ្ឋាននោះ, ចំនុចដែលត្រូវបានបញ្ជាអោយធ្វើការកែលំអនៅក្នុងពេលធ្វើការត្រួតពិនិត្យកាលពីលើកមុន, ស្ថានភាពកើតគ្រោះថ្នាក់នៅការដ្ឋានរ៉ែ, ស្ថានភាពកើតការបំពុលនៅការដ្ឋានរ៉ែ, ចំនុចដែលមិនទាន់បានដោះស្រាយនិងចំនុចជាបញ្ហានានា, ទិសដៅណែនាំការត្រួតពិនិត្យកំណត់ដោយស្ថានប័នរបស់រដ្ឋាភិបាល។ល។ ធ្វើយ៉ាងណាអនុវត្តការត្រួតពិនិត្យអោយមានប្រសិទ្ធិភាព-លទ្ធផលល្អ ដោយធ្វើការពិភាក្សាគ្នាទុកជាមុនសំរាប់ចាប់យកនូវចំនុចធ្វើការពិនិត្យ(ចំនុចសំខាន់នានា)នៅក្នុងការដ្ឋានរ៉ែ។ លើសពីនេះ បើចាំបាច់អាចទទួលការបង្គាប់បញ្ជាពីសំណាក់ថ្នាក់លើទាក់ទងនឹងការត្រួតពិនិត្យ, ធ្វើការរៀបចំផែនការ(កាលបរិច្ឆេទនៃការត្រួតពិនិត្យ, ចំនុចសំខាន់ក្នុងការត្រួតពិនិត្យ, ការបែងចែកការទទួកបន្ទុកតំបន់សំរាប់ធ្វើការត្រួតពិនិត្យ។ល។តាមរយៈមន្ត្រីអធិការកិច្ច)អនុវត្តការត្រួតពិនិត្យទូទៅ (ទប់ស្កាត់បំពុលបរិដ្ឋាន)។

(2) រៀបចំនូវឧបករណ៍កាន់ជាប់ផ្ទាល់ខ្លួនក្នុងត្រួតពិនិត្យទូទៅ

មន្ត្រីអធិការកិច្ច ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន) ចាំបាច់ត្រូវរៀបចំនូវឯកសារនិងឧបករណ៍ដែលមានរៀបរាប់ដូចខាងក្រោម៖

1) ឯកសាររបាយការណ៍នៃត្រួតពិនិត្យទូទៅ(ទប់ស្កាត់បំពុលបរិដ្ឋាន)កាលពីមុន(ថតចំលង)។
2) បទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែនោះ
3) ផែនទីសុវត្ថិភាពការដ្ឋានរ៉ែ(ថតចំលង)
4) លិខិតណែនាំកែលំអ និង លិខិតបញ្ជា (មិនទាន់បំពេញ)
5) field note
6) សំលៀកបំពាក់ការងារ, ស្បែកជើងសុវត្ថិភាព, ស្រោមដៃ
7) មួកសុវត្ថិភាព, ម៉ាសការពារធូលី
8) clinometer, ម៉ែត្រមូល
9) ម៉ាស៊ីនថតរូប
10) អត្តសញ្ញាណប័ណ្ណមន្ត្រីសុវត្ថិភាពការដ្ឋានរ៉ែ

**ជំពូក២ : អនុវត្តត្រួតពិនិត្យទូទៅ** (ទប់ស្កាត់បំពុលបរិដ្ឋាន)

1. សាកសួរ បញ្ជាក់និងណែនាំ នៅការិយាល័យរបស់ការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច នៅការិយាល័យការដ្ឋានរ៉ែ ស្តីពីចំនុចមានដូចខាងក្រោម ត្រូវសាកសួរដល់អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព(ខាងក្រោមមកទៀតហៅថា អ្នកគ្រប់សុវត្ថិភាព)(និង/ឬ) និង អ្នកគ្រប់គ្រងការងារ ពីឯកសារកំណត់ដោយច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ (ឯកសារគ្រប់គ្រង, ឯកសារត្រួតពិនិត្យ, សៀវភៅកត់ត្រាសុវត្ថិភាពប្រចាំថ្ងៃ។ល។) និងព្រមទាំងធ្វើការពិនិត្យនូវខ្លឹមសារនៃកាត់ត្រាទាំងនោះ, ធ្វើការណែនាំកែលំអក្នុងករណីរកឃើញចំនុចមិនប្រក្រតីលើផ្នែកសុវត្ថិភាព។

（1） សាកសួរ បញ្ជាក់ និងណែនាំ ពីស្ថានភាពដំណើរការងារអាជីវកម្មរ៉ែ

មន្ត្រីអធិការកិច្ច ស្តីពីផែនការជីកយក(បរិមាណនាំយកបរិមាណរ៉ែចេញ, ទីកន្លែងកំពុងយករ៉ែបច្ចុប្បន្នកាល, ស្ថានភាពនៃការផលិត) ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ពីស្ថានភាពការប្រតិបត្តិការលើការរក្សាសុវត្ថិភាពនៅការដ្ឋានរ៉ែ ពិនិត្យបញ្ជាក់ តើមានឬមិនមានបញ្ហា ឬ មានឧបសគ្គចំពោះផែនការជីកយករ៉ែ, ស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

（2） ណែនាំ បញ្ជាក់ និងសាកសួរពីស្ថានភាពគ្រប់គ្រងកំលាំងពលកម្ម និងទំហំការងាររបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួម

1）ទំហំការងាររបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួម, អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងអ្នកគ្រប់គ្រងការងារ

មន្ត្រីអធិការកិច្ច ធ្វើការសាកសួរស្តីពីទំហំការងារលំអិតដែលអនុវត្តដោយអ្នកគ្រប់គ្រងសុវត្ថិភាពរួម, អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងអ្នកគ្រប់គ្រងការងារ បញ្ជាក់ស្តីពីទំហំការងារលំអិតនោះដែលត្រូវបានកំណត់ច្បាស់លាស់ឬមិនច្បាស់លាស់ បញ្ជីឯកសារការងារ ឬ សៀវភៅកត់ត្រា។ល។ ពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើកាណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

2） ស្ថានភាពគ្រប់គ្រងកំលាំងពលកម្ម

មន្ត្រីអធិការកិច្ច ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីផែនការជ្រើសរើសកំលាំងពលកម្មមនុស្សទៅថ្ងៃអនាគត ការប្រែប្រួលកំលាំងពលកម្មដែលមានស្រាប់នៅក្នុងការដ្ឋានរ៉ែ ធ្វើការបញ្ជាក់នូវភាព មានឬមិនឧបសគ្គ ចំពោះស្ថានភាពគ្រប់គ្រកំលាំងពលកម្មលើការងាររក្សាបាននូវសុវត្ថិភាព។ ស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

（3） ណែនាំ ធ្វើការបញ្ជាក់ និងសាកសួរ ពីស្ថានភាពជ្រើសរើសអ្នកគ្រប់គ្រងការងារ

មន្ត្រីអធិការកិច្ច ធ្វើការបញ្ជាក់ពីបញ្ជីគ្រប់គ្រង បញ្ជីកត់ត្រា សៀវភៅសុវត្ថិភាពប្រចាំថ្ងៃ

ដែលត្រូវបានកំណត់ដោយបទបញ្ញត្តិនិងច្បាប់សុវត្ថិភាពការងាររ៉ែ តើមានបានការបែងចែកទៅតាមគោលដៅនីមួយៗនៃទីតាំងជាក់ស្តែងដែរឬទេ ការជ្រើសរើសអ្នកគ្រប់គ្រងការងារមានភាពសមរម្យទៅតាមស្ថានភាពនៃបរិក្ខារគ្រឿងចក្រការដ្ឋានរ៉ែ ទំហំនៃការដ្ឋានរ៉ែដែរឬទេស្តីពីចំនុចដែលមិនប្រក្រតីផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(4) ណែនាំ បញ្ជាក់ និងសាកសួរពីស្ថានភាពអប់រំសុវត្ថិភាពចំពោះកម្មកររ៉ែ

មន្ត្រីអធិការកិច្ច ធ្វើការបញ្ជាក់នូវការកត់ត្រាស្តីពីស្ថានភាពការអប់រំផ្នែកសុវត្ថិភាព ដោយធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ពីខ្លឹមសារអនុវត្តការអប់រំអំពីសុវត្ថិភាពចំពោះកម្មកររ៉ែ នៅពេលចង់អនុវត្តការងារមានគ្រោះថ្នាក់ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិ និងអោយកម្មកររ៉ែអនុវត្តការងារនៅក្នុងវេងថ្មីនៅក្នុងការដ្ឋានរ៉ែនោះ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(5) ណែនាំ បញ្ជាក់ សាកសួរ ទាក់ទងនឹងគណៈកម្មការសុវត្ថិភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព បញ្ជាក់ពីការកត់ត្រានូវខ្លឹមសារ។ល។ ពីខ្លឹមសារនៃការពិភាក្សាទាក់ទងនឹងចំនុចសំខាន់ ស្តីសកម្មភាពគណៈកម្មការ សាកសួរពីស្ថានភាពសកម្មភាពទាំងនោះ និងការបង្កើតគណៈកម្មការសុវត្ថិភាព ស្តីពីចំនុចត្រូវបានសន្និដ្ឋាន មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(6) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងការស្រាវជ្រាវស្ថានភាពសុវត្ថិភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព បញ្ជាក់ពីបញ្ជីកត្រា។ល។ស្តីពីខ្លឹមសារនៃលទ្ធផលការស្រាវជ្រាវនោះដោយសាកសួរតើមានការអនុវត្តនូវ「ការស្រាវជ្រាវផ្នែកសុវត្ថិភាព」ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញត្តិនៅក្នុងការដ្ឋានរ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(7) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងការងារទទួលធ្វើបន្ត

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីការងារទទួលបន្តដោយអ្នកក្រៅ ដូចជាទទួលការងារដឹកជញ្ជូនកាកសំណល់រ៉ែ ឬការបន្សាប ដែលមានរយៈពេលធ្វើការលើសពី១ខែ នៅក្នុងការដ្ឋានរ៉ែក្រោមដី ធ្វើការបញ្ជាក់តើមានបង្កើតផែនការ ទទួលធ្វើការងារបន្ត និងតើបានរាយការណ៍នូវផែនការទាំងនោះដែរឬទេ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នក

គ្រប់គ្រងសុវត្ថិភាព។

(៨) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងចំនុចបញ្ហាណែនាំកែលំអ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីស្ថានភាពកែលំអនៅក្នុង「លិខិតបញ្ជាក់កែលំអ」ដែលត្រូវបានប្រកាសផ្តល់នៃការអនុវត្តត្រួតពិនិត្យជាក់ស្តែងទូទៅកាលពីអតីតកាល, មានភាពត្រឹមត្រូវឬមិនត្រឹមត្រូវនៃស្ថានភាពកែលំអ, ស្ថានភាពនៃការដំណើរការការងារ, បញ្ជាក់នូវកាលបរិច្ឆេទបញ្ចប់ការងារ។ល។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។ លើសពីនេះ ករណីពុំទាន់បានកែលំអ ស្តីពីចំនុចនៃនាំកែលំអកាលពីអតីតកាល ត្រូវសាកសួរពីមូលហេតុទាំងនោះថែមទៀត។

(៩) ណែនាំ បញ្ជាក់ សាកសួរទាក់ទងនឹងផែនការប្រើប្រាស់ទីតាំងនោះ ក្រោយពីបានធ្វើអាជីវកម្មរួច ឬ ការស្តារបរិស្ថានឡើងវិញក្រោយពីបានយករ៉ែរួច នៃការដ្ឋានរ៉ែបើក

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអ្នកគ្រប់គ្រងសុវត្ថិភាព ស្តីពីផែនការប្រើប្រាស់ឡើងវិញនៃទីតាំងនោះក្រោយពីបានធ្វើអាជីវកម្មរ៉ែរួច ឬផែនការស្តារឡើងវិញទាក់ទងនឹងការដាំដើមឈើ និងការលុបគ្រប់ដី ការលុបឡើងវិញ ទាក់ទងនឹងកន្លែងបានយករ៉ែរួចនៃការដ្ឋានរ៉ែបើកដែលបានបញ្ចប់ការយករ៉ែ ឬកន្លែងដែលនឹងជិតបញ្ចប់ការយករ៉ែ បញ្ជាក់ពីខ្លឹមសារទាំងនោះតើមានបញ្ហា ឬក៏គ្មានបញ្ហាលើផ្នែករក្សាសុវត្ថិភាពនៃការដ្ឋានរ៉ែ។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(១០) ណែនាំ បញ្ជាក់ និងសាកសួរទាក់ទងនឹងរចសម្ព័ន្ធជួយសង្គ្រោះនៅពេលមានភាពអសន្នកើតឡើង

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរអ្នកគ្រប់គ្រងសុវត្ថិភាព តើមានរៀបចំនូវរចនាសម្ព័ន្ធទាក់ទង និងជួយសង្គ្រោះនៅពេលមានស្ថានភាពអសន្ន ឬការកើតឡើងនូវការបំពុល ឬគ្រោះថ្នាក់កើតឡើងធ្ងន់ធ្ងរ សាកសួរតើមានអនុវត្តការហ្វឹកហាត់ដែរឬទេ។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(១១) ណែនាំ បញ្ជាក់សាកសួរទាក់ទងនឹងការខិតខំជំរុញសកម្មភាពសុវត្ថិភាពការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរ អ្នកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ ស្តីពីការខិតខំជាលក្ខណៈលំអិតពីសកម្មភាពសុវត្ថិភាពការដ្ឋានរ៉ែដែលកំពុងតែមានផែន

ការអនុវត្តនិងសភាពបច្ចុប្បន្ននៅការដ្ឋានរ៉ែ , បញ្ជាក់ពិនិត្យផែនការនិងសម្មិទ្ធផលជាក់ស្តែង ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(１２) បញ្ជាក់ និងសាកសួរទាក់ទងនឹងអគារសាធារណៈ និងស្ថានភាពបរិដ្ឋាននៅជុំវិញការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរពីអគារសាធារណៈ(ផ្លូវ, ស្ពាន, ទំបន់ទឹក, សួនច្បារ,មន្ទីរពេទ្យ, សាលារៀន។ល។) និងស្ថានភាពបរិដ្ឋានលំដាននៅជុំវិញការដ្ឋានរ៉ែ ដីកសិកម្ម, ទន្លេ។ល។ បើគិតថាមានភាពចាំបាច់ អាចនឹងធ្វើការវាស់បញ្ជាក់ ពីគំលាតប្រវែងនឹងអគារទាំងនោះ លំនៅដ្ឋានប្រជាជន ដីស្រែ ជាមួយនឹងទីកន្លែងធ្វើការជីកយករ៉ែ។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(１３) បញ្ជាក់និងសាកសួរទាក់ទងនឹង តើមានឬក៏មានការប្តឹងពីប្រពលរដ្ឋរស់នៅក្នុងតំនប់នោះ។ល។

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការសាកសួរអ្នកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ តើមានករណីប្តឹង ឬការស្នើរសុំ ពីប្រជាពលរដ្ឋ។ ករណីមាន ការស្នើរសុំ ឬប្តឹងពីប្រជាពលរដ្ឋ ព្រមជាមួយនឹងការសាកសួរនូវខ្លឹមសារទាំងនោះដែលពាក់ព័ន្ធជាមួយនឹងការដ្ឋានរ៉ែ ធ្វើការបញ្ជាក់ តើមានឬមិនមានបញ្ហា ឬឧបសគ្គចំពោះខ្លឹមសារតបទល់របស់ការដ្ឋានលើការងារទប់ស្កាត់ការបំពុលបរិដ្ឋានកើតឡើងនៅការដ្ឋានរ៉ែនោះ។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

(１４) បញ្ជាក់និងសាកសួរទាក់ទងនឹងស្ថានភាពគ្រប់គ្រងការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ សាកសួរទាក់ទងនឹងស្ថានភាពគ្រប់គ្រងអាជីវកម្មរ៉ែតាមតែសេចក្តីត្រូវការចាំបាច់នៅពេលនោះ ពីសំណាក់អ្នកទទួលបន្ទុកគ្រប់គ្រងការដ្ឋានរ៉ែអនុវត្ត បញ្ជាក់តើមានឧបសគ្គលើផ្នែកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែដែរឬទេ? ស្តីពីចំនុចត្រូវបានសន្និដ្ឋានថា មានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

２. ណែនាំនិងបញ្ជាក់ទាក់ទងនឹងបញ្ជីគ្រប់គ្រងការកត់ត្រានិងសៀវភៅគ្រប់គ្រង, សៀវភៅសុវត្ថិភាពប្រចាំថ្ងៃគ្រប់ប្រភេទនីមួយៗដែលត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ

(１) ណែនាំ និងបញ្ជាក់ទាក់ទងនឹងចំនុចកត់ត្រានៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃនៃប្រភេទ

នីមួយៗ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ស្តីពីចំនុចដែលបានអនុវត្តសំរាប់សុវត្ថិភាពនិងការងារទាក់ទងនឹងសុវត្ថិភាពតាមការកំណត់នៅក្នុងច្បាប់ដែលត្រូវអនុវត្តដោយអ្នកគ្រប់គ្រង ធ្វើការពិនិត្យសៀវភៅសុវត្ថិភាពប្រចាំថ្ងៃគ្រប់ប្រភេទដែលបានកត់ត្រូវពីលទ្ធផលទាំងនោះ។ លើសពីនេះតើមានសរសេរនៅលើបែបបទដែលមានគំរូស្រាប់ដែរឬទេ។ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1) សៀវភៅសុវត្ថិភាពកត់ត្រាពីចំនុចសំខាន់និងស្ថានភាពផ្អាក ជួសជុល ដំណើរការបរិក្ខារផលិតនិងគ្រឿងចក្រ ទាក់ទងនឹងការទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ។

2) សៀវភៅសុវត្ថិភាពកត់ត្រាពីចំនុចសំខាន់និងស្ថានភាពផ្អាក ជួសជុល ដំណើរការរៀបចំចែកចាយខ្សែចរន្តនិងបរិក្ខារ បរិក្ខារផលិតប្រើចរន្តអគ្គិសនី ទាក់ទងនឹងការទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពបរិក្ខារអគ្គិសនី។

3 ) សៀវភៅសុវត្ថិភាពកត់ត្រាពីចំនុចសំខាន់និងវិធានការទប់ស្កាត់ការបំពុល ស្ថានភាពដំណើរការអគារទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពទប់ស្កាត់ការបំពុលបរិដ្ឋាន។

4) សៀវភៅសុវត្ថិភាពកត់ត្រាពីចំនុចសំខាន់និងការប្រើប្រាស់ គ្រប់គ្រង ថែរក្សា សារធាតុជាតិពុលនិងបំផ្លាញសុខភាព ដោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកសារធាតុជាតិពុលនិងបំផ្លាញសុខភាព។

(2) ណែនាំនិងបញ្ជាក់ទាក់ទងនឹងចំនុចកត់ត្រាលើបញ្ជីគ្រប់គ្រងការកត់ត្រា, បញ្ជីគ្រប់ប្រភេទនៃលទ្ធផលការវាស់ឬលទ្ធផលការពិនិត្យក្នុងកាលបរិច្ឆេទថេរ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការបញ្ជាក់តើមានការពិនិត្យនៅលើបញ្ជីគ្រប់គ្រងប្រភេទនីមួយៗដោយអ្នកគ្រប់គ្រងសុវត្ថិភាព តើមានឬមិនមានបញ្ហាចំពោះលទ្ធផលការវាស់ ឬលទ្ធផលការពិនិត្យ តើមានថែរក្សាទុក រៀបចំនូវបញ្ជីគ្រប់គ្រងកត់ត្រា ឬសៀវភៅគ្រប់គ្រងប្រភេទនីមួយៗដែលបានកត់ត្រាពីលទ្ធផលបានវាស់ ឬពិនិត្យលំអិតជាប្រចាំដែលបានកំណត់ដោយច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលនៃការវាស់ និងពិនិត្យដោយលំអិតជាប្រចាំនូវបរិក្ខារគ្រឿងចក្រដែលត្រូវការនូវភាពប្រយ័ត្នចាំបាច់ផ្នែកសុវត្ថិភាព ជាពិសេសសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយគ្រប់គ្រងការងារទទួលសុវត្ថិភាពគ្រឿងចក្រ។

2) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលនៃការវាស់ និងពិនិត្យដោយលំអិតជាប្រចាំនូវការងារតំឡើងម៉ាស់ដី ការចែកចាយខ្សែចរន្ត បរិក្ខារអគ្គិសនី បរិក្ខារប្រើចរន្តអគ្គិសនី ដែលត្រូវការនូវភាពប្រយ័ត្នចាំបាច់ផ្នែកសុវត្ថិភាព ជាពិសេសសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយគ្រប់គ្រងការងារទទួលសុវត្ថិភាពអគ្គិសនី។

3) សៀវភៅគ្រប់គ្រងបានកត់ត្រានូវលទ្ធផលនៃការវាស់ និងពិនិត្យការវាស់និងការវាស់ដោយសុក្រឹតជាប្រចាំពីស្រះស្តុករបស់កករង slagនិងកន្លែងស្តុកtailing ថ្មចោល ព្រមទាំងអគារបំលែងភាពរំញ័រ និងអគារបង្កើតភាពរំញ័រនៅការដ្ឋានរ៉ែកំហិតភាពរំញ័រ អគារចំរាញ់កាកសំណល់រ៉ែ អគារបង្កើតប្រភេទdioxide អគារចំរាញ់ទឹកកខ្វក់ឬទឹកក្នុងរូង អគារចំរាញ់ធូលីនិងអគារបង្កើតធូលីដោយម៉ាស៊ីបែងចែក ឬម៉ាស៊ីនប៉ូលាដែលមានកំឡាំង ម៉ូទ័រលើសពី 15KW ម៉ាស៊ីបំបែកមានកំឡាំងម៉ូទ័រលើសពី75KW អគារចចំរាញ់ផ្សែង និងអគារបង្កើតផ្សែងដែលត្រូវការនូវភាពប្រយ័ត្នចាំបាច់ផ្នែកសុវត្ថិភាព ជាពិសេសសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន ដោយគ្រប់គ្រងការងារទទួលសុវត្ថិភាពគ្រឿងចក្រ។

3. អនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់ការបំពុលបរិដ្ឋាន)នៅក្នុងទីកន្លែងធ្វើការនិងតាមអគារនៃការដ្ឋានរ៉ែ

(1) ចំនុចគ្រប់គ្រងទូទៅ

1) ការស្នើរសុំអោយចូលរួមក្នុងការត្រួតពិនិត្យទូទៅ ចំពោះអ្នកគ្រប់គ្រងសុវត្ថិភាព

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ក្នុងការអនុវត្តការត្រួតពិនិត្យទូទៅ(ទប់ស្កាត់ការបំពុលបរិដ្ឋាន)ចំពោះទីកន្លែងធ្វើការនិងអគារការដ្ឋានរ៉ែ ធ្វើការស្នើរអោយមានការចូលរួមពីសំណាក់អ្នកគ្រប់គ្រងសុវត្ថិភាពរួមឬអ្នកតំណាង ឬ អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព បើមានភាពចាំបាច់អាចស្នើសុំអោយមានការចូលរួមពីសំណាក់អ្នកគ្រប់គ្រងការងារនៃទីកន្លែងធ្វើការងារឬអគាររបស់ការដ្ឋានរ៉ែ និងស្នើសុំអោយមានការពន្យល់ស្តីពីស្ថានភាពការងារឬស្ថានភាពប្រើប្រាស់នូវអគាររបស់ការដ្ឋានរ៉ែ។

2) បញ្ជាក់និងណែនាំទាក់ទងនឹងការតំឡើងនៃបរិក្ខារផលិត។ល។ ឬការងារសាងសង់ផ្លាស់ប្តូរអគារប្រើសំរាប់ការងាររ៉ែ

មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ធ្វើការបញ្ជាក់តើមានការរាយការណ៍ឬការដាក់សុំផ្លាស់ប្តូរដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិ ស្តីពីបរិក្ខារផលិត អគារដែលត្រូវបានតំឡើងនៅក្នុងបរិវេណការដ្ឋានរ៉ែ ធ្វើការបញ្ជាក់តើមានខ្លឹមសារដែលបញ្ហាឬមានឧបសគ្គលើការទប់ស្កាត់បញ្ហាបំពុលបរិដ្ឋានដែរឬទេ។ ចំពោះចំនុចត្រូវបានសន្និដ្ឋានថាមិនមានភាពសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដោយមានការបញ្ជាក់ជាមួយនឹងភាគីការដ្ឋានរ៉ែផងដែរ។

3) បញ្ជាក់និងណែនាំទាក់ទងនឹង「បែបបទធ្វើការងារ」ដែលត្រូវបានកំណត់នៅក្នុងបទបញ្ញត្តិសុវត្ថិភាព

មន្ត្រីអធិការកិច្ច ក្នុងពេលដើរល្បាតតាមទីកន្លែងធ្វើការនីមួយៗ ធ្វើការបញ្ជាក់តើកម្មកររ៉ែមានធ្វើការងារតាមបែបបទធ្វើការងារដែលបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋាននោះតាមការងារនីមួយៗដែរឬទេ។ ស្តីពីចំនុចដែលត្រូវបានសន្និដ្ឋានមិនសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការបញ្ជាក់នូវខ្លឹមសារនោះតើវាមានបញ្ហាឬគ្មាន ឬមានឧបសគ្គកើតឡើងលើការទប់ស្កាត់ការបំពុលបរិដ្ឋានដែរឬទេ ធ្វើការណែនាំកែលំអ ដោយធ្វើការបញ្ជាក់រួមគ្នាជាមួយនឹងភាគីការដ្ឋានរ៉ែ។

4) បញ្ជាក់និងណែនាំទាក់ទងនឹងផែនការជីកយកពិសេស

មន្ត្រីអធិការកិច្ច នៅពេលជីកយករ៉ែនៅបាតសមុទ្រ បាតទន្លេ ឬបាតបឹង តាមរយៈការជីកដីនោះវានឹងបណ្តាលអោយចេញទឹក ឬការបំពុលបរិដ្ឋាន ធ្វើការបញ្ជាក់រួមគ្នាតើមានបានអនុវត្តតាមខ្លឹមសារដែលបានសរសេរក្នុងផែនការជីកយកពិសេស ដែលជាវិធីជីកយករ៉ែនោះដែរឬទេ ការណែនាំកែលំអ ដោយធ្វើការបញ្ជាក់រួមគ្នាជាមួយនឹងភាគីការដ្ឋានរ៉ែស្តីពីចំនុចដែលត្រូវបានសន្និដ្ឋានមិនសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការបញ្ជាក់នូវខ្លឹមសារនោះតើវាមានបញ្ហាឬគ្មាន ឬមានឧបសគ្គកើតឡើងលើការទប់ស្កាត់ការបំពុលបរិដ្ឋានដែរឬទេ ធ្វើការបញ្ជាក់តើអាចនឹងមានការបំពុលកើតឡើង តាមរយៈដីស្រុតផ្នែកស្រទាប់សំបកផែនដី ដោយពិនិត្យតាមផៃណទីសុវត្ថិភាពពិសេស និងតាមស្ថានភាពជាក់ស្តែងនៃការខួងទុកជាមុននៅក្នុងរូង។

**ជំពូក៣** : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង។

(សូមមើលឧបសម្ព័ន្ធ－1)

**ជំពូក៤** : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ទឹកក្នុងរូង ឬទឹកកខ្វក់

(សូមមើលឧបសម្ព័ន្ធ－2)

**ជំពូក៥** : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង សំឡេងថ្លង់

(សូមមើលឧបសម្ព័ន្ធ－3)

**ជំពូក៦** : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ភាពរំញ័រ

(សូមមើលឧបសម្ព័ន្ធ－4)

**ជំពូក៧** :  អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ផ្សែងរ៉ែ (ម្រេង ភ្លើង) និងធូលី

(សូមមើលឧបសម្ព័ន្ធ－5)

**ជំពូក៨** :  អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង កាកសំណល់អាជីវកម្មរ៉ែ ប្រភេទdioxide ការខួងដី

(សូមមើលឧបសម្ព័ន្ធ－6)

## ជំពូក៩  វិធានការក្រោយពីបានត្រួតពិនិត្យទូទៅរួច

1 . វិធានការលើការត្រួតពិនិត្យនៅក្នុងករណីត្រូវបានទទួលស្គាល់មានគ្រោះថ្នាក់អាចនឹងឈានមកដល់ក្នុងពេលបន្ទាន់បន្តិចទៀត ឬចំនុចចាំបាច់ត្រូវកែលំអ ដែលល្មើសនឹងច្បាប់និងបទបញ្ញតិ

1) លទ្ធផលត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ករណីត្រូវបានទទួលស្គាល់ថាមានចំនុចចាំបាច់ត្រូវកែលំអ និងមានល្មើសនឹងច្បាប់និងបទបញ្ញតិ ត្រូវធ្វើការបញ្ជាក់រួមគ្នាដោយមានការចូលរួមពីសំណាក់ភាគីខាងការដ្ឋានរ៉ែ យោងតាមការកំណត់នៃមាត្រាទី៧–១នៃ「បទបញ្ញតិត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ」 អនុវត្តណែនាំកែលំអ។ល។សំរាប់រក្សាបាននូវសុវត្ថិភាព ព្រមទាំងចេញ「លិខិតបង្គាប់ណែនាំកែលំអ」 ដល់ម្ចាស់អាជីវកម្មរ៉ែ។

ចំពោះ「លិខិតបញ្ជាកែលំអ」 ត្រូវធ្វើពីរច្បាប់ មួយច្បាប់សំរាប់ផ្តល់ជូនដល់ម្ចាស់អាជីវកម្មរ៉ែ និងមួយច្បាប់ទៀត(ចតចំលង)សំរាប់ភ្ជាប់ជាមួយនឹងរបាយការណ៍ធ្វើការត្រួតពិនិត្យ។

2) ការងារទាំងនោះ ករណីត្រូវបានទទួលស្គាល់ថាមានចំនុចចាំបាច់ត្រូវកែលំអ និងមានល្មើសនឹងច្បាប់និងបទបញ្ញតិ យោងតាមការកំណត់នៃមាត្រាទី៨–១នៃ「បទបញ្ញតិត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ」 ស្តីពីការងារទាំងនោះអាចនឹងមានគ្រោះថ្នាក់កាន់តែឈានមកកល់លើផ្នែកសុវត្ថិភាព និងល្មើសនឹងបទបញ្ញតិនិងច្បាប់ ត្រូវធ្វើការបញ្ជាក់រួមគ្នាដោយមានការចូលរួមពីសំណាក់ភាគីខាងការដ្ឋានរ៉ែ ធ្វើការបញ្ជាណែនាំនិងព្រមានអោយកែលំអជាបន្ទាន់ ព្រមទាំងលេច「លិខិតបញ្ជា」ដល់ម្ចាស់អាជីវកម្មរ៉ែ។

ចំពោះ「លិខិតបញ្ជា」 ត្រូវធ្វើពីរច្បាប់ មួយច្បាប់សំរាប់ផ្តល់ជូនដល់ម្ចាស់អាជីវកម្មរ៉ែ និងមួយច្បាប់ទៀត(ចតចំលង)សំរាប់ភ្ជាប់ជាមួយនឹងរបាយការណ៍ធ្វើការត្រួតពិនិត្យ។

3) ស្តីពីចំនុចសំខាន់ដែលត្រូវធ្វើការកែលំអជាបន្ទាន់និងចំនុចចាំបាច់សំរាប់កែលំអដូចមានសរសេរខាងលើ ស្តីពីចំនុចត្រូវបានទទួលស្គាល់ថានឹងអាចមានការបំពុលបរិដ្ឋានគំរាមមកដល់ ព្រមទាំងការងារដែលល្មើសនឹងច្បាប់និងបទបញ្ញតិ កំណត់ខ្លឹមសារការងារនិងទីកន្លែង ត្រូវកត់ត្រាអោយបានប្រាកដប្រជាលើសៀវភៅពីចំនុចទាំងនោះ និងព្រមទាំងស្រាវជ្រាវដោយលំអិត វាស់ដោយ

ឆ្លើយតបនឹងភាពចាំបាច់ ចំពោះលទ្ធផលទាំងនោះ ក៏ត្រូវធ្វើការកត់ត្រា ក្រៅពីនោះស្ដីពីស្ថានភាពការងារ ទីកន្លែងចាំបាច់មួយចំនួនធ្វើការកត់ត្រាលើសៀវភៅ និងការថតរូបថែមទៀត។

2. វាយតំលៃទាក់ទងនឹងលទ្ធផលការត្រួតទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

បុគ្គលិកពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ដែលបានអនុវត្តការត្រួតពិនិត្យពិសេស (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ចំពោះម្ចាស់អាជីវកម្មរ៉ែ អ្នកគ្រប់គ្រងសុវត្ថិភាពទូទៅ អ្នកតំណាងអ្នកគ្រប់គ្រងទូទៅ អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និងអ្នកគ្រប់គ្រងការងារ អនុវត្តការសាកសួរពីភាគីការដ្ឋានរ៉ែ ព្រមទាំងពន្យល់ដោយលំអិតពីការមើលឃើញទូទៅស្ដីពីលទ្ធផលត្រួតពិនិត្យអនុវត្តដោយមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ និងបានស្នើរសុំអោយមានការកែលំអ ចំនុចត្រូវបានទទួលស្គាល់អោយមានការកែប្រែជាបន្ទាន់ ក្រោយពីបញ្ចប់ការត្រួតពិនិត្យ។

3. របាយការណ៏និងការបង្កើតរបាយការណ៏ត្រួតពិនិត្យទូទៅរួម (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

បុគ្គលិកពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ ដែលបានអនុវត្តការត្រួតពិនិត្យពិសេស (ទប់ស្កាត់ការបំពុលបរិដ្ឋាន) អនុលោមតាមបទបញ្ញតិត្រួតពិនិត្យការដ្ឋានរ៉ែមាត្រាទី២–៣ យោងតាមរយៈបែបបទគំរូដែលត្រូវបានកំណត់នៅក្នុងបែបបទនៅក្នុងសៀវភៅនេះ ចាំបាច់ត្រូវតែរាយការណ៏ដល់អគ្គទទួលបន្ទុកការងាររ៉ែ (ចំពោះករណីមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែដែលត្រូវបានបែងចែកនៅតាមមន្ទីនានា ត្រូវរាយការណ៏ឆ្លងប្រធានមន្ទីជាមុនសិន) និងបង្កើតនូវ「របាការណ៏ត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)」។

ចំពោះរបាយការណ៏ត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ក្រៅពីចំនុចដែលត្រូវបានកំណត់នៅក្នុងបែបបទនេះ ត្រូវរៀបចំសរុបនូវចំនុចដែលមានដូចខាងក្រោម ស្ដីពីស្ថានភាពទាំងនោះ ត្រូវសរសេរលំអិតដែលមានដូចខាងក្រោម។

1) លទ្ធផលនៃការត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ចំនុចត្រូវបានទទួលស្គាល់ដែលបានល្មើសនឹងច្បាប់និងបទបញ្ញតិសុវត្ថិភាពការដ្ឋានរ៉ែ។
2) ចំនុចបានប្រកាសណែនាំនូវ លិខិតបង្គាប់ណែនាំកែលំអ ដោយអនុលោមតាមបទបញ្ញតិត្រួតពិនិត្យការដ្ឋានរ៉ែ។
3) ចំនុចបានប្រកាសជា「លិខិតបញ្ជា」ដោយអនុលោមតាមបទបញ្ញតិត្រួតពិនិត្យការដ្ឋានរ៉ែ។
4) ចំនុចនៅមានការសង្ស័យ ចំនុចត្រូវមានការត្រួតពិនិត្យទូទៅសំរាប់បន្តត្រួតពិនិត្យលើកក្រោយ។
5) ការមើលសរុបទូទៅរបស់មន្ត្រីត្រួតពិនិត្យសុវត្ថិភាពការដ្ឋានរ៉ែ។

# បែបបទរបាយការណ៍ពីការត្រួតពិនិត្យទូទៅរួម (ទប់ស្កាត់គ្រោះថ្នាក់)

1. ឈ្មោះការដ្ឋានរ៉ែ (ឈ្មោះប្រភេទរូងនៅក្នុងការដ្ឋានរ៉ែធ្យូងថ្ម) :
2. ឈ្មោះប្រភេទរ៉ែនិងលេខតំបន់រ៉ែ :
3. ទីតាំងនៃការដ្ឋានរ៉ែ :
4. ទីតាំងការិយាល័យ លេខទូរស័ព្ទទំនាក់ទំនង។ល។ :
5. ម្ចាស់អាជីវកម្មរ៉ែ (ឈ្មោះអ្នកតំណាង ក្នុងករណីជាក្រុមហ៊ុន) :
6. អាស័យដ្ឋានរបស់ម្ចាស់អាជីវកម្មរ៉ែ លេខទូរស័ព្ទទំនាក់ទំនង។ល។ :
7. ឈ្មោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម (កាលបរិច្ឆេទនៃថ្ងៃចាត់តាំង) :
8. ឈ្មោះអ្នកតំណាងអ្នកគ្រប់គ្រងសុវត្ថិភាពរួម (កាលបរិច្ឆេទនៃថ្ងៃចាត់តាំង) :
9. ឈ្មោះអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និងចំនួនអ្នកគ្រប់គ្រងការងារតាមផ្នែកនីមួយៗ
   1) ចំនួនអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព
   2) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ
   3) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពអគ្គិសនី
   4) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន
   5) ចំនួនអ្នកគ្រប់គ្រងការងារទទួលបន្ទុកសារធាតុពុលនិងបំផ្លាញសុខភាព

10. ចំនួនកម្មកររ៉ែដែលកំពុងធ្វើការរាល់ថ្ងៃ (លើកលែងចំនួនកម្មកររ៉ែទទួលបន្ទុកផ្នែកផ្សេងៗ និងអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព)
   1) ចំនួនកម្មកររ៉ែដែលកំពុងធ្វើការក្រៅរូង
   2) ចំនួនកម្មកររ៉ែដែលកំពុងធ្វើការនៅក្នុងរូង

11. ទំនាក់ទំនងនឹងការងាររ៉ែ
   1) ប្រវត្តិនៃការងាររ៉ែនិងកាលបរិច្ឆេទចាប់ផ្តើមការងាររ៉ែ :
   2) វិធីនៃការជីកយករ៉ែ :
   3) បរិមាណផលិត (តោន／ខែ) :
   4) បរិមាណបំបែកឬចំរាញ់រ៉ែ (តោន／ខែ)
      a) បរិមាណបំបែករ៉ែ (តោន／ខែ) :
      b) បរិមាណចំរាញ់រ៉ែនិងគុណភាពរ៉ែ (តោន／ខែ) :
   5) បរិមាណរំលាយចំរាញ់ ឬដុតរ៉ែ (តោន／ខែ)
      a) បរិមាណដុតចំរាញ់រ៉ែ (តោន／ខែ) :
      b) បរិមាណចំរាញ់រំលាយរ៉ែនិងគុណភាព (តោន／ខែ) :

6）បរិមាណផលិតនិងបរិមាណលក់ (តោន／ខែ)

a) បរិមាណផលិតនៃផលិតបែងចែក (តោន／ខែ) :

b) បរិមាណលក់ផលិតផលបែងចែក (តោន／ខែ) :

7）កំឡាំងអគ្គិសនីសរុបសំរាប់បរិក្ខារផលិត (KW) :

១２. ទំនាក់ទំនងនឹងសុវត្ថិភាពការងាររ៉ែ

1）សុវត្ថិភាពចំពោះអគារផ្សេងៗ និងបរិក្ខារផលិត អគារប្រើសំរាប់ការងាររ៉ែកំណត់ដោយមាត្រាទី៩នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

(ស្តីពីចំនុចខាងក្រោម ធ្វើការរៀបចំអគារគ្រប់អគារ និងកត់ត្រានូវចំនុចនានា។)

a) ឈ្មោះអគារ :

b) កាលបរិច្ឆេទរាយការណ៍ពីផែនការណ៍របស់អគារ :

c) កាលបរិច្ឆេទនៃការអនុញ្ញាតិរបស់រដ្ឋមន្រ្តីទទួលបន្ទុកការងាររ៉ែ :

d) ខ្លឹមសាររបស់អគារ :

2）សុវត្ថិភាពចំពោះការងារទទួលធ្វើបន្តកំណត់នៅក្នុងមាត្រាទី១៩នៃច្បាប់សុវត្ថិភាពរ៉ែ

a) កាលបរិច្ឆេទរាយការណ៍នៃផែនការការងារទទួលធ្វើបន្ត :

b) ខ្លឹមសារការងារទទួលធ្វើបន្ត ចំនួនកម្មកររ៉ែអនុវត្តការងារទទួលធ្វើបន្ត :

c) រយៈពេលការងារទទួលធ្វើបន្ត :

3）សុវត្ថិភាពចំពោះការជីកយកពិសេសកំណត់នៅក្នុងមាត្រាទី២០នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

a) កាលបរិច្ឆេទនៃការរាយការណ៍ការជីកយកពិសេស :

b) កាលបរិច្ឆេទនៃការអនុញ្ញាតិរបស់រដ្ឋមន្រ្តីទទួលបន្ទុកការងាររ៉ែ :

c) ខ្លឹមសារនៃផែនការជីកយកពិសេស :

4）ស្ថានភាពរាយការណ៍ពីផែនទីសុវត្ថិភាពការដ្ឋានរ៉ែ និងបទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែ

a) កាលបរិច្ឆេទរាយការណ៍ពីបទបញ្ជាផ្ទៃក្នុងសុវត្ថិភាពការដ្ឋានរ៉ែ :

b) កាលបរិច្ឆេទរាយការណ៍ពីផែនទីសុវត្ថិភាពការដ្ឋានរ៉ែ :

5）ស្ថានភាពកើតឡើងនូវការបំពុលបរិដ្ឋានដោយសារអាជីវកម្មរ៉ែ

(កត់ត្រានិងរៀបចំគ្រប់រាល់ពេលកើតឡើង ស្តីពីការបំពុលធ្ងន់ធ្ងរដោយសារអាជីវកម្មរ៉ែកើតឡើងនៅក្នុងអតីតកាល និងស្តីពីចំនុចខាងក្រោម)

a) កាលបរិច្ឆេទនៃការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែ :

b) ប្រភេទនៃការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែ :

c) ស្ថានភាពកើតឡើងនូវការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែ :

d) ចំនួនជនរងគ្រោះនៃការបំពុលបរិដ្ឋាននៅក្នុងការដ្ឋានរ៉ែ និងកំរិតនៃការបំពុលបរិដ្ឋាន :

១៣. ការមើលឃើញទូទៅរបស់មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ

a) រយៈពេលអនុវត្តត្រួតពិនិត្យទូទៅ :

b) លទ្ធផលត្រួតពិនិត្យទូទៅ ចំនុចត្រូវបានទទួលស្គាល់ដែលល្មើសនឹងច្បាប់និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ :

c) ចំនុចបានចេញប្រកាសនូវលិខិតបង្ហាញការណែនាំកែលំអ អនុលោមនឹងច្បាប់និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ :

d) ចំនុចបានចេញប្រកាសនូវលិខិតបញ្ជា អនុលោមនឹងច្បាប់និងបទបញ្ញត្តិសុវត្ថិភាពការដ្ឋានរ៉ែ :

e) ចំនុចសង្ស័យ ចំនុចបញ្ហា និងចំនុចត្រូវធ្វើការត្រួតពិនិត្យទូទៅសំរាប់លើកក្រោយទៀត :

f) ចំនុចឃើញទូទៅរបស់មន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែ :

g) ចំនុចទាក់ទងផ្សេងៗទៀត :

※ កាលបរិច្ឆេទដាក់របាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

※ ឈ្មោះមន្ត្រីពាក់ព័ន្ធ និងមន្ត្រីអធិការកិច្ចសុវត្ថិភាពការដ្ឋានរ៉ែបានអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

(ឧបសម្ព័ន្ធ —1)

# ជំពូក៣ : អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង

8 August 2016

## 1. ការរៀបចំបរិក្ខារផ្ទាល់ខ្លួនមុននឹងអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

ក្នុងការអនុវត្តត្រួតពិនិត្យទូទៅទាក់ទងនឹងទីកន្លែងស្តុកធាតុកករង ទីកន្លែងថ្មចោល ឬslagចាំបាច់ត្រូវយកទៅជាមួយរបស់ដែលមានដូចខាងក្រោមដោយសំរបសំរួលចាំបាច់តាមស្ថានភាពការដ្ឋាននីមួយៗ រួមទាំងបរិក្ខារដែលបានរាយរាប់នៅក្នុង「ជំពូកទី១ ចំនុច2 . ( 2 ) ស្តីពីបរិក្ខារដែលត្រូវយកទៅជាមួយក្នុងពេលធ្វើការត្រួតពិនិត្យទូទៅ」។

1) បរិក្ខារវាស់គុណភាពទឹក។ល។ (បរិក្ខារវាស់ p H, pack test)

2) Polyethylene bottleសំរាប់យកទឹក

3) ថ្នាំសារធាតុគីមី (nitric acid, sodium hydroxide .etc.)

4) *Paper filter*

5) ជីវឡាវ funnel

## 2. អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹង ទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង

(1) អនុវត្តត្រួតពិនិត្យទូទៅនៅក្នុងការិយាល័យរបស់ការដ្ឋានរ៉ែ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)

មន្ត្រីអធិការកិច្ច រួមទាំង នៅក្នុង「ជំពូក២ ចំនុច1. ការអនុវត្តត្រួតពិនិត្យទូទៅនៅការិយាល័យរបស់ការដ្ឋានរ៉ែ」ទាក់ទងនឹងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករងនៅការដ្ឋានរ៉ែនោះ សាកសួរពីអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព តាមចំនុចដែលមានដូចខាងក្រោម ដោយធ្វើការបញ្ជាក់តើមានឬមិនមានឧបសគ្គលើការទប់ស្កាត់បញ្ហាបំពុលបរិដ្ឋានរ៉ែដែរឬទេ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអចំពោះអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព។

1) នៅក្នុងបទបញ្ញាផ្ទៃក្នុងសុវត្ថិភាព តើមានត្រូវបានកំណត់ដូចចំនុចដែលមានដូចខាងក្រោមដែរឬទេ។

**a)** ទាក់ទងនឹងការគ្រប់គ្រងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង។

**b)** ទាក់ទងនឹងវិធានការចាត់ចែងនៅពេលមានភ្លៀងធ្លាក់ ភ្លៀងខ្លាំង និងនៅក្នុងរដូវវស្សា។

**c)** ទាក់ទងនឹងស្ថានភាពគ្រប់គ្រងបរិក្ខារប្រើសំរាប់ពេលមានគ្រោះអសន្ន សំភារៈ បរិក្ខារប្រើសំរាប់សង្គ្រោះបន្ទាន់។

**d)** ទាក់ទងនឹងព្រៃការពាររបស់កន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង។

2) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន ស្តីពី កន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង តើគោរពតាមចំនុចដូចមានខាងក្រោមសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋា

ន តាមរយៈសារធាតុកករងហូរចេញ ឬការបាក់ធ្លាយនៅទីនោះដែរឬទេ?

a) តើមានឬមិនមាន ដីរអិល ទីកន្លែងស្តុកថ្មចោលនិងslag ស្ថានភាពជញ្ជាំងទំនប់ឬទំនប់ បាក់ទីកន្លែងស្តុក ធ្វើការដើរល្បាតរាល់ថ្ងៃ និងធ្វើការកត់ត្រាលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

b) តើមានឬមិនមានភាពមិនប្រក្រតីចំពោះអគារបញ្ចេញទឹកនៅទីកន្លែងស្តុក និងផ្លូវទឹកប្រើសំរាប់ពេលមានអសន្នៈ ផ្លូវនៅតាមចង្កេះភ្នំ ផ្លូវទឹកសំរាប់បញ្ចេញទឹកពីអូខាងលើ ស្ថានភាពទំនប់ ឬជញ្ជាំងទំនប់នៃទីកន្លែងស្តុកសារធាតុកករង។

c) នៅពេលទទួលស្គាល់មានបាតុភូតនៃដីរអិល បាក់រលំ បាកផុងតួរទំនប់ ប្រេះស្រាំផ្ទៃជញ្ជាំងទំបន់នៃទីកន្លែងស្តុកសារធាតុកករងឬទីកន្លែងស្តុកអាចម៍រ៉ែ ទីកន្លែងស្តុកថ្មចោល ធ្វើការចាត់វិធានការតបទល់ជាបន្ទាន់ និងព្រមទាំងធ្វើការរាយការណ៍ដល់អ្នកគ្រប់គ្រង។

3）នៅពេលមានភ្លៀងធ្លាក់ខ្លាំង នៅតំបន់នៃកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង ចាំបាច់ត្រូវបង្កើនការដើរល្បាតចំពោះទីកន្លែងទាំងនោះ ព្រមទាំងធ្វើការពិនិត្យមើលតើមានឬមិនមានភាពមិនប្រក្រតីនៅក្នុងទីកន្លែងបញ្ចេញទឹក និងផ្លូវទឹកសំរាប់បញ្ចេញនៅពេលមានគ្រោះអសន្ន ផ្លូវទឹកតាមចង្កេះភ្នំសំរាប់បញ្ចៀសទឹកកុំអោយចូលក្នុងទំនប់ ផ្លូវទឹកបញ្ចេញទៅទឹកទន្លេ ស្ថានភាពប្រាំងទំនប់ ដីរអិល និងព្រមទាំងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងទាក់ទងនឹងកន្លែងទាំងនោះ។

４）នៅពេលមានការបំពុលកើតឡើង និងអាចនឹងមានការបំពុលកើតច្រើន នៅទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង អនុលោមតាមការកំណត់របស់ច្បាប់និងបទបញ្ញត្តិចំពោះស្ថានភាពគ្រោះថ្នាក់នោះ ខ្លឹមសារនៃវិធានការទប់ទល់នឹងគ្រោះថ្នាក់ ព្រមទាំងនៅពេលបានជួសជុលចប់ព្រមទាំងផែនការនៃការជួសជុលនោះ ស្តីពីខ្លឹមសារទាំងនោះ តើមានបានរាយការណ៍ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែជាបន្ទាន់ដែរឬទេ។

5）ស្តីពីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង ដើម្បីទប់ស្កាត់ការហូរចេញនូវាសារធាតុទាំងនោះ ពីកន្លែងស្តុក ដែលបានបញ្ឈប់ការប្រើ ឬបោះបង់ចោលការប្រើ តើមានចាត់វិធានការសមរម្យដោយមានបានលុបដីឬដាំដើមឈើ។ល។ដែរឬទេ។

a) ស្ថានភាពទំបន់ឬជញ្ជាំងទំនប់

b) បរិមាណសារធាតុកករងក្នុង១ខែឬ របស់យកមកស្តុកទុក

c) បរិមាណកកស្តុកបច្ចុប្បន្នសរុប និង បរិមាណសំរាប់លទ្ធភាពស្តុកសំរាប់អនាគត

(2) មន្ត្រីអធិការកិច្ច អនុវត្តការត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ចំពោះទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង បូករួមទាំងចំនុចបានសរសេរខាងលើ 「ជំពូក២ ：２. **អនុវត្តត្រួតពិនិត្យទូទៅ**（**ទប់ស្កាត់បំពុលបរិដ្ឋាន**）」ស្តីពីចំនុចខាងក្រោម ធ្វើការបញ្ជាក់តើមានឬមិនមានឧបសគ្គលើការងារទប់ស្កាត់ការបំពុលបរិដ្ឋាន ស្តីពីចំនុចត្រូវបានទទួលស្គាល់ថាមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាពជាន់ខ្ពស់។

1) ទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង អនុលោមតាមការកំណត់នៃច្បាប់ និងបទបញ្ញត្តិ តើមានធ្វើការសំរបសំរួលនឹងលិខិតផែនការអគារដែលបានទទួលការអនុញ្ញាតិពីរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ដែរឬទេ។

2) ទីកន្លែងស្តុករបស់កករង ទីកន្លែងស្តុកថ្មចោល ទីកន្លែងស្តុកslag តើមានតំឡើងផ្លូវទឹកបញ្ចេញទឹកនៅទីកន្លែងសមរម្យនៃទីកន្លែងនោះ សំរាប់ត្រៀមអាចនឹងមានគ្រោះថ្នាក់នៅពេលមានបរិមាណទឹកហូរចូលមកច្រើន។

3) ទីកន្លែងស្តុករបស់កករង ទីកន្លែងស្តុកថ្មចោល ទីកន្លែងស្តុកslag តើមានចាត់វិធានការនៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ច្រើនកើតឡើងនូវការបំពុលតាមរយៈបាក់រលំ ដីរអិល។ល។ ដែរឬទេ?

4) ចំពោះកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង តើមានតំឡើងអោយឃ្លាតឆ្ងាយអោយលើសពី៣០ម៉ែត្រពី ផ្ទះប្រជាជន ការិយាល័យការដ្ឋានរ៉ែ អគារសាធារណៈដូចជាសាលារៀន ទំនប់ ទន្លេ ផ្លូវដែក។ល។ ដែរឬទេ?

5) ចំពោះកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង ទីកន្លែងដែលបានប្រើរួចដើម្បីទប់ស្កាត់ការហូរចេញនូវកាកសំណល់ ឬទឹកកខ្វក់ តើមានចាត់វិធានការសមរម្យដូចជាដាំដើមឈើ លុបដីគ្របទំនប់ និងនៅក្នុងទំនប់ ដែរឬទេ?

6) ទីកន្លែងស្តុករបស់កករង តើមានតំឡើងផ្លូវទឹកចេញ នៅបញ្ចៀសទឹកហូរពីភ្នំ តើបានត្រៀមការពារកុំអោយ និងទីកន្លែងបញ្ចេញទឹកផ្សេងៗទៀតដែរឬទេ។

7) ចំពោះទីកន្លែងស្តុករបស់កករងមានជញ្ជាំងទំនប់ដែលបង្កើតពីដី ដើម្បីតបទល់នឹងគ្រោះថ្នាក់ដោយទឹកហូរពីខាងក្រៅទំនប់មកច្រើន តើមានតំឡើងនូវផ្លូវទឹកបញ្ចេញទឹកប្រើសំរាប់ពេលមានអសន្ននៅទិតាំងសមរម្យនៃទីកន្លែងស្តុកដែរឬទេ?

8) ស្ថានភាពគ្រប់គ្រងទីកន្លែងស្តុកសារធាតុកករង ឬទីកន្លែងស្តុកថ្មចោល ទីកន្លែងស្តុកslag

a) តើមានវិធានការតប់ទល់នឹងពេលមានគ្រោះអសន្នដែរឬទេ? លើសពីនេះ អ្នកទទួលគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន តើមានបានទទួលការហ្វឹកហាត់ដោយធ្វើការស្មានទុកជាមុននៅពេលមានគ្រោះអសន្ន។ល។ ដែរឬទេ?

b) ស្ថានភាពគ្រប់គ្រងថែទាំបរិក្ខារប្រើសំរាប់នៅពេលមានគ្រោះអសន្ន មានសភាពត្រឹមត្រូវល្អដែរឬទេ។

c) តើមានវាស់កំពស់ទឹកដែលបានហូរចូលនៅក្នុងទំនប់នៃទីកន្លែងស្តុកសារធាតុកករងដែរឬទេ។ ស្ថានភាពគ្រប់គ្រងបរិក្ខាវាស់ទាំងនោះ មានភាពល្អត្រឹមត្រូវដែរឬទេ។

d) តើមានបានធ្វើការត្រួតពិនិត្យជាប្រចាំពីទីកន្លែងបញ្ចេញទឹកដែរឬទេ។

9) រចនាសម្ព័ន្ធរបស់ទំនប់ទាក់ទងនឹងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង

a) តើសារធាតុដែលយកមកតំឡើងទំនប់ជាសារធាតុសមរម្យដែរឬទេ។ លើសពីនេះ តើសភាពបង្ហាប់នៅជញ្ជាំងទំនប់មានភាពសមស្របត្រឹមត្រូវដែរឬទេ។

b) តើទំហំនៃកំពស់ទំនប់មានទំហំគ្រប់គ្រាន់ដែរឬទេ។

c) តើទំហំនៃកន្លាក់ជញ្ជាំងទំនប់មានបានសាងសង់តំឡើងតាមផែនការសាងសង់ដែលមានជំរេលនិងមានជំហំអាចឆ្លេអាចរត់បានដែរឬទេ។

d) ចំពោះស្ថានភាពកំពីកកំពកនៃផ្ទៃជំរ្លៃងនិងកំពស់ទំនប់ តើមានបាតុភូតមិនប្រក្រតី បាក់ផុង ប្រេះស្នាំ ដែរឬទេ។

e) តើមានបានដាំស្មៅឬគ្របដី ជាបន្ទាន់ក្រោយពីបានសាងសងទំនប់រួចហើយដែរឬទេ។ លើសពីនេះ ចំពោះផ្ទៃជញ្ជាំងឬជំរេលជញ្ជាំង តើមានទឹកភ្លៀងហូរស៊ីច្រោះដែរឬទេ។

១០) វិធីស្តុករបស់កករងទាក់ទងទីកន្លែងស្តុកសារធាតុកករង

a) តើមានភាពប្រេះ បាក់បែក ចំពោះបំពង់ទឹកជញ្ជូនសារធាតុរាវ ហើយតើសារធាតុរាវនិងទឹកកខ្វក់ទាំងនោះមានហូរចេញក្រៅដែរឬទេ។

b) សារធាតុរាវដែលត្រូវបានដឹកជញ្ជូនតាមបំពង់ មានត្រូវបានបង្ហូរចេញពីបំពង់ពីទិសដៅពីជញ្ជាំងទំនប់ទៅក្នុងទំនប់ដែរឬទេ។

c) សារធាតុរាវដែលត្រូវបានបង្ហូរចូលក្នុងទំនប់ តើផ្ទៃខាងលើមានសភាពស្មើរគ្នាដែរឬទេ។

d) កំពស់ទឹកនៅក្នុងទីកន្លែងកករង តើមានបានរក្សានូវកំពស់១ម៉ែត្រទាបជាងកំពស់ជញ្ជាំងទំនប់ដែរឬទេ។

e) ផ្ទៃនៃសារធាតុកករងនៅក្នុងទីកន្លែងស្តុក តើមានបានរក្សានូវកំពស់ក្រោម៥០សង្ទីម៉ែត្រពីកំពស់ជញ្ជាំងទំនប់ដែរឬទេ។

f) តើមានទឹកហូរចេញពីផ្ទៃជញ្ជាំងទំនប់ទប់សារធាតុកករងដែរឬទេ។

g) តើមានឃើញផ្ទៃជញ្ជាំងស្តុកសារធាតុរាវផុងស្រុត តើមានរកឃើញបាតុភូតមិនប្រក្រតីផ្សេងៗ ដូចជាភាពប្រេះស្រាំ ។ល។ ដែរឬទេ។

h) តើមានទឹកផុសចេញនៅក្បែរតំបន់ទំនប់ ដែរឬទេ។ លើសពីនេះ តើមានបាតុភូតបាក់រលំ បាក់ស្រុត ជំញ្ជាំងទំនប់រអិល។ល។ ដែរឬទេ។

i) តើកំពស់ទឹកដែលបានហូរចូលក្នុងទំនប់មានការកើនឡើងគួរអោយកត់សំគាល់ដែរឬទេ។

**11)** ប្រព័ន្ធបង្ហូរទឹកចេញទាក់ទងនឹងទីកន្លែងស្តុកសារធាតុកករង

(ទឹកនៅក្នុងទំនប់)

a) ប្រព័ន្ធបញ្ចេញទឹកនៅក្នុងទំនប់ តើមានសមត្ថភាពអាចបញ្ចេញទឹកបានគ្រប់គ្រាន់ និងមានដំណើរការបានគ្រប់គ្រាន់ដែរឬទេ។

b) ស្ថានភាពគ្រប់គ្រងផ្លូវទឹកបញ្ចេញនៅពេលមានគ្រោះអសន្ន តើមានសភាពត្រឹមត្រូវល្អដែរឬទេ។

c) តើច្រកផ្លូវទឹកបញ្ចេញទឹកនៅពេលមានអសន្ន និងកំពស់ទំនប់ មានកំពស់គ្រប់គ្រាន់ដែរឬទេ។

(ផ្លូវទឹកបញ្ចៀសទឹកសាធារណៈ)

d) ផ្លូវទឹកបញ្ចៀសទៅទឹកសាធារណៈ តើមានបរិមាណអាចបញ្ចេញទឹកបានគ្រប់គ្រាន់ដែរឬទេ។

e) នៅពេលតំឡើងផ្លូវទឹកសំរាប់ជាផ្លូវទឹកបញ្ចៀសទឹកសាធារណៈនៅបាតទំនប់ តើវាជារចនាសម្ព័ន្ធរឹងមាំ ពុំមានភាពប្រេះស្រាំ បែកបាក់ និងមានភាពកកស្ទះ ឬមានភាពមិនប្រក្រតីដែរឬទេ។

f) ចំពោះច្រកចូលនៃផ្លូវបញ្ចៀសទឹកសាធារណៈ តើមានតំឡើងទំនប់ការពារ ឬមានតំឡើងសំណាញ់ដែកសំរាប់ទប់ការហូរចូលនៃថ្ម មែកឈើ។ល។ ដែលហូរពីផ្នែកខាងលើដែរឬទេ។

g) តើបរិក្ខារទប់មែកឈើហូរមកឬដើមឈើហូរមក និងទំនប់ការពារមានសមត្ថភាពគ្រប់គ្រាន់ដែរឬ

ទេ។

(ផ្លូវទឹកបញ្ចៀសទឹកហូរពីភ្នំ)

h) ផ្លូវទឹកបញ្ចៀសទឹកហូរពីភ្នំ តើមានដី ដីខ្សាច់ និងស្លឹមឈើកកលុបដែរឬទេ។

i) ផ្លូវទឹកបញ្ចៀសទឹកហូរពីភ្នំ តើមានបានប្រមូលទឹកបានត្រឹមត្រូវ មានសមត្ថភាពបង្ហូរទឹក និងមានមុខងារត្រឹមត្រូវដែរឬទេ។

j) ផ្លូវទឹកបញ្ចៀសទឹកហូរពីភ្នំ មានភាពប្រេះស្រាំខូចខាតដែរឬទេ។

**(3)** （3）ការយកសំណាក់ចំពោះទឹកផុសចេញ ឬទឹកត្រូវបានបញ្ចេញ នៅទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង

1）ចំពោះទឹកនៅក្នុងទំនប់ ធ្វើការវាស់ｐHនៅទីកន្លែងបញ្ចេញទឹក វាស់កំដៅទឹក និងបរិមាណទឹកត្រូវបានបញ្ចេញ ធ្វើការវិភាគគុណភាពទឹកជាលក្ខណៈធម្មតាដោយប្រើ*pack test* ព្រមទាំងធ្វើការកត់ត្រាលទ្ធផលនៃការវាសើនោះលើសៀវភៅកំណត់ហេតុ ក្នុងករណីត្រូវបានសន្និដ្ឋានថាមានភាពចាំបាច់សំរាប់វាស់គុណភាពទឹក ធ្វើការយកសំណាក់ទឹកបញ្ចេញទាំងនោះ។

ក្នុងករណីធ្វើការបន្សាបទឹកនៅទីកន្លែងចំរាញ់ទឹកកខ្វក់ដែលចេញពីទំនប់ ស្តីពីទឹកដែលត្រូវបានបញ្ចេញក្រោយពីចំរាញ់រួចពីកន្លែងចំរាញ់ក៏ត្រូវវាស់ｐHសដូចខាងលើដែរ ធ្វើការវាស់បរិមាណទឹកត្រូវបានបញ្ចេញពីកន្លែងបញ្ចេញ និងកំដៅទឹក ធ្វើការកត់ត្រាលទ្ធផលទាំងនោះលើសៀវភៅកំណត់ហេតុ បើចាំបាច់ធ្វើការយកសំណាក់ទឹកដែលបានបញ្ចេញពីកន្លែងចំរាញ់ទឹកកខ្វក់ថែមទៀតផង។

2）ករណីត្រូវបានទទួលស្គាល់មានទឹកផុសចេញពីតួទំនប់ដែលជាកន្លែងស្តុក គឺត្រូវធ្វើដូចគ្នាដូចខាងលើ គឺត្រូវធ្វើការវាស់ｐH កំដៅទឹក និងវាស់បរិមាណទឹកបានផុសចេញ ធ្វើការវាស់គុណភាពទឹកតាមរយៈ *pack test* ព្រមទាំងធ្វើការកត់ត្រាលទ្ធផលទាំងនោះលើសៀវភៅកំណត់ហេតុ ករណីត្រូវបានសន្និដ្ឋានថានឹងធ្វើការវិភាគគុណភាពទឹក គឺត្រូវយកសំណាក់ទឹកផុសនោះ។

លើសពីនេះ ស្តីពីទឹកផុសចេញពីតួទំនប់ដែលជាកន្លែងស្តុក ធ្វើគូសចំណាំជាផែនទីដែលងាយយល់ព្រមទាំងធ្វើការថតរូបផងដែរ។

3）ករណីត្រូវបានទទួលស្គាល់មានទឹកផុសចេញនៅជិតតំបន់ក្បែរតួទំនប់ដែលជាកន្លែងស្តុក ត្រូវអនុវត្តដូចលេខ2）ខាងលើ គឺត្រូវធ្វើការវាស់ｐH កំដៅទឹក និងវាស់បរិមាណទឹកបានផុសចេញ ធ្វើការវាស់គុណភាពទឹកតាមរយៈ *pack test* ព្រមទាំងធ្វើការកត់ត្រាលទ្ធផលទាំងនោះលើសៀវភៅកំណត់ហេតុ ត្រូវយកសំណាក់ទឹកផុសនោះ ធ្វើការគូសចំណាំជាផែនទីដែលងាយយល់ព្រមទាំងធ្វើការថតរូបផងដែរ។

4) ស្តីពីវិធីអនុវត្តលក្ខណៈលំអិតនៃការយកសំណាកទឹកចេញឬទឹកហូរចេញ សូមមើលឯកសារជំនួយ「 3.ការអនុវត្តយកសំណាក់សំរាប់ការស្រាវជ្រាវគុណភាពទឹកនៃទឹកកខ្វក់ឬទឹកក្នុងរូងល។ល។」របស់「ជំពូក៤ ：ការអនុវត្តត្រួតពិនិត្យទូទៅទាក់ទងនឹងទឹកកខ្វក់ឬទឹកក្នុងរូង」។

៣. ការសរសេររបាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង

# របាយការណ៍ត្រួតពិនិត្យទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង (របៀបគំរូ)

(ត្រូវសរសេរតាមទីកន្លែងស្តុកនីមួយៗ) ថ្ងៃខែឆ្នាំនៃការត្រួតពិនិត្យ :

| | |
|---|---|
| ១. ឈ្មោះទីកន្លែងប្រមូលស្តុក | |
| ២. ថ្ងៃខែឆ្នាំនៃការចាប់ផ្តើបស្តុក<br>៣. កំពុងប្រើ ឈប់ប្រើ បញ្ចប់ផ្សេងៗ | |
| ៤. ជញ្ជាំងទំនប់<br>១) ប្រវែងទំនប់<br>២) ទំហំទទឹងកំពស់ទំនប់<br>៣) ជំរេល<br>(ផ្នែកខាងលើចរន្តទឹក)<br>(ផ្នែកខាងក្រោមចរន្តទឹក)<br>៤) កំពស់<br>(កំពស់ចាប់ពីបាតដល់កំពូល)<br>៥) ប្រភេទនៃសារធាតុយកមកកសាងទំនប់<br>៦) ប្រភេទទំនប់ (បែងចែកប្រភេទ) | |
| ៥. សមត្ថភាពស្តុក<br>១) សមត្ថភាពស្តុកសរុប (ផែនការទៅថ្ងៃអនាគត)<br>២) សមត្ថភាពស្តុកមានប្រសិទ្ធភាព (បច្ចុប្បន្នកាល) | |
| ៦. ស្ថានភាពគ្រប់គ្រងទីកន្លែងបញ្ចេញទឹក | |

| | |
|---|---|
| 1）ទីកន្លែងបញ្ចេញទឹកនៅក្នុងទំនប់<br><br>2）ទីកន្លែងបញ្ចេញទឹកប្រើនៅពេលមានអសន្ន<br><br>3）ទីកន្លែងបញ្ចេញទឹកសាធារណៈ<br><br>4）ផ្លូវទឹកបញ្ចៀសទឹកពីភ្នំ | |

| | |
|---|---|
| 7. ស្ថានភាពផ្ទៃរបស់ទំនប់<br>1）ស្ថានភាពផ្ទៃ<br><br>2）មានទឹកចេញឬក៏គ្មានទឹកចេញ | |
| 8. បរិមាណបញ្ចេញទឹកពីកន្លែងស្តុក ($m^3$／min) | |
| 9. ស្ថានភាពនៅផ្នែកខាងលើចរន្តទឹកនៃទីកន្លែងស្តុក<br>1）ស្ថានភាពតំឡើងទំនប់បន្ទាប់បន្សំ<br><br>2）ស្ថានភាពតំឡើងបរិក្ខារទប់ស្កាត់ឈើហូរតាមទឹក | |
| 10. ស្ថានភាពនៅជុំវិញទំនប់<br><br>1）ស្ថានភាពតំឡើងផ្លូវទឹកមកពីភ្នំ (ឧទាហរណ៍ ព្រៃភ្នំ ផ្ទាំងថ្ម ) | |
| 11. ស្ថានភាពចរន្តទឹកខាងក្រោមនៃទីកន្លែងស្តុក<br><br>1）មានឬមិនមានទន្លេ បឹងស្រះ | |

| | |
|---|---|
| (ឈ្មោះទន្លេ បរិមាណទឹក )<br>(ឈ្មោះបឹង)<br><br>2) ស្ថានភាពប្រើទឹកទន្លេ។ល។<br>(ទឹកប្រើសំរាប់ប្រឡាយកសិកម្ម<br>ទឹកបរិភោគ)<br><br>3) កំរិតទទួលឥទ្ធិពលក្នុងករណីមាន<br>បាក់ទំនប់ស្តុក<br>(ស្ថានភាពមានការរងគ្រោះ។ល។) | |
| 12. ស្ថានភាពគ្រប់គ្រងថែរក្សាទំនប់ | |

13. លទ្ធផលយកំណាក់របស់ទឹកផុសចេញឬទឹកចេញពីក្នុងទំនប់។ល។

| ឈ្មោះ ទីកន្លែង យក សំណាក់ ទឹក | បរិមាណ ទឹកផុស ចេញ ឬ ទឹកចេញ ( m3/min ) | កំដៅ ទឹក (កំដៅ ទឹក) | **pH** | ភាព ល្អក់ ខុសគ្នា | ទង់ដែង **(ppm)** | សំណ **(ppm)** | សង្ក៏ **(ppm)** | …… | …… |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

14. ស្ថានភាពកើតការបំពុលតាមរយៈទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង

| កាលបរិច្ឆេទនៃការកើត | ទីកន្លែងកើត | កំរិតនៃការរងគ្រោះ ខ្លឹមសារនៃបញ្ហាបំពុល |
|---|---|---|
| | | |
| | | |

15. ឯកសារឧបសម្ព័ន្ធ

1) ផែនទីនៃទីកន្លែងស្តុក (សូមសរសេរនូវទីន្លែងដែលបានយកសំណាក់ទឹកផុសចេញពីកន្លែងស្តុក និង

ទឹកចេញពីទីកន្លែងបញ្ចេញទឹកនៅក្នុងកន្លែងស្តុក ទីតាំងទឹកផុសចេញ និងទីកន្លែងប្រភេទនីមួយៗនៃការបញ្ចេញទឹក)

2) ផែនទីបានបង្ហាញទីតាំងទន្លេ បឹង។ល។ដែលមាននៅផ្នែកចរន្តទឹកខាងក្រោមនៃទីកន្លែងស្តុក

3) ផែនទីបង្ហាញទីតាំង អគារសាធារណៈ ដីស្រែ លំនៅដ្ឋាននៅផ្នែកចរន្តទឹកខាងក្រោមនៃទីកន្លែងស្តុក

4) រូបថតទាក់ទងនឹងទីកន្លែងស្តុក

## (ពន្យល់)

1. វិធីស្តុកសារធាតុរាវនៅទីកន្លែងស្តុកសារធាតុរាវកករង

1) ដើម្បីរក្សាលំនឹងរបស់តួរទំនប់ស្តុកសារធាតុកករង តាមការកើនឡើងនៃផ្ទៃសារធាតុរាវ (slime) ដែលបានស្តុកនៅក្នុងទំនប់ ធ្វើយ៉ាងណាអោយទីតាំងនៃផ្ទៃទឹកនៅក្នុងទំនប់ឃ្លាតឆ្ងាយពីទំនប់។

2) កំពស់នៃផ្ទៃស្តុកសារធាតុរាវ (slime) ចាំបាច់ត្រូវរក្សាអោយបានទាប៥០សង្ទីម៉ែត្រពីទំនប់ស្តុក។ គោលបំណងនោះ គឺក្នុងករណីកើនឡើងកំពស់ទឹកនៅពេលមានភ្លៀងធ្លាក់ខ្លាំង សំរាប់កុំអោយទឹកនៅក្នុងទំនប់ហូរចេញពីទំនប់បាន។

3) ស្ថានភាពផ្ទៃទឹកខិតប៉ះជាប់នឹងទំនប់ បើនិយាយពីភាពមានលំនឹងរបស់ទីកន្លែងស្តុក គឺមានសភាពអាក្រក់បំផុត។ ទីកន្លែងស្តុកសារធាតុកករង គឺមិនមែនគូសប្លង់សាងសង់សំរាប់មានគោលបំណងស្តុកទឹកទេ គឺជាការគូសប្លង់តំលើងសំរាប់អោយទឹករងថ្លាបានល្អ។

4) បើករណីត្រូវបានពិនិត្យមើលផ្ទៃសារធាតុកករង (slime) មានប្រេះបែក និងមានរន្ធបាក់ផុងគឺអាចគិតបានថា វាអាចនឹងមានទឹកឆ្លងកាត់គំនសារធាតុកករង (slime) បាន។
ទាំងនេះ គឺមានន័យថា សារធាតុសាងសងទំនប់នៅផ្នែកព្រំប្រទល់ចរន្តទឹកខាងលើនៃទីកន្លែងស្តុក ពុំមានមុខងារធ្វើការច្រោះបានល្អ។ បើករណីមានរន្ធរីតតែរីកធំដោយសារទឹកឆ្លងកាត់ ទឹកដែលបានជ្រៀបចូលនោះវានឹងអាចទឹកផុសចេញពីផ្ទៃទំនប់នៅផ្នែកចរន្តទឹកខាងក្រោមនៃទីកន្លែងស្តុក ជាចុងក្រោយវានឹងជាមូលហេតុនៃការបាក់ទំនប់តែម្តង។


slime disposal pipe
slime face
water face
embankment
downstream
upstream


slime disposal pipe
0.5m or more
water face
slime
embankment
culvert






This parts do not play the role of a filter layer.

2. ជញ្ជាំងទំនប់នៅទីកន្លែងស្តុកសារធាតុកករង

1) ទាក់ទងនឹងភាពមានលំនឹងរបស់ទីកន្លែងស្តុកសារធាតុកករង វាមានទំនាក់ទំនងជិតស្និតនៅពេលសង់ជញ្ជាំងទំនប់ ជាពិសេសរចនាសម្ព័ន្ធនៅក្នុងទំនប់គឺសំខាន់ណាស់។

2) នៅពេលត្រូវបានពិនិត្យឃើញថាមានទឹកជ្រៀប និងទឹកផុសនៅនឹងផ្ទៃជញ្ជាំងទំនប់ គឺមិនអាចនិយាយបានថាទំនប់នោះមានលំនឹងល្អបានឡើយ។ ក្នុងករណីបែបនេះ វាចាំបាច់ត្រូវការស្រាវជ្រាវរកនូវមូលហេតុ និងចាត់វិធានការចាំបាច់។

3) នៅពេលត្រូវបានទទួលស្គាល់ថាមានប្រេះស្រាំ ស្ថានភាពរជិករដុបនៅនឹងផ្ទៃនៃជញ្ជាំងទំនប់ នៅក្នុងជញ្ជាំងទំនប់មានសភាពមិនហាប់ល្អ គឺអាចគិតបានថាវានឹងមានរន្ធឆ្លងកាត់បានតាមរយៈមូលហេតុនៃទឹកជ្រៀប។
ករណីនៃស្ថានភាពបែបនេះ ចាំបាច់ធ្វើការស្រាវជ្រាវឡើងវិញ និងចាត់វិការ។

4) បើមានការហូរជាច់ដីតាមរយៈទឹកភ្លៀងលើផ្ទៃជញ្ជាំង នោះភាពមានលំនឹងរបស់ទំបន់នឹងមានការថយចុះ។ (បូករួម តាមរយៈការហូរជាច់ដីនៃផ្ទៃជញ្ជាំងទំនប់ វាបណ្តាលអោយទឹកនៅក្នុងទន្លេមានភាពកខ្វក់។) ដូច្នេះ ចាំបាច់ចាត់វិធានការការពារផ្ទៃជញ្ជាំងទំនប់ វិធានការទប់ស្កាត់ទឹកហូរកាត់តាមរយៈទឹកភ្លៀងហូរលើផ្ទៃនៃជញ្ជាំងទំនប់។

5) បើករណីត្រូវបានទទួលស្គាល់មានភាពរង្គើនៅជុំវិញជើងនៃទំនប់ នៅក្នុងជញ្ជាំងទំនប់ គឺនឹងអាចមានសភាពមិនហាប់ល្អ។ ចំពោះករណីនេះ ក៏ចាំបាច់ត្រូវចាត់វិធានផងដែរ។

3. ទីកន្លែងបញ្ចេញទឹកនៅទីកន្លែងស្តុកសារធាតុកករង (ផ្លូវទឹកបញ្ចៀសទឹកអូរ ផ្លូវទឹកបញ្ចៀសទឹកពីភ្នំ)

1) ផ្លូវទឹកបញ្ចេញទឹកប្រើសំរាប់នៅពេលមានអសន្ន វាមានប្រយោជន៏តប់ទល់នៅពេលមានភាពអសន្នតាមរយៈគ្រោះធម្មជាតិដូចជាភ្លៀងធ្លាក់ខ្លាំង។ល។ ដូច្នេះហើយ ចាំបាច់ត្រូវតែរក្សានិងរៀបចំវាអោយរក្សាបាននូវមុខងារល្អ គ្រប់ពេលវេលា។

2) ជាធម្មតាមានទឹកហូរមកពីចរន្តទឹកខាងលើមកភាគខាងលើកន្លែងស្តុក ហើយក៏គ្មានការបំពុលបរិដ្ឋានអ្វីកើតឡើងដែរ ទឹកទាំងនោះត្រូវបាននាំបញ្ចេញតាមផ្លូវទឹកដែលបានត្រៀមទុករួច។ ក៏ប៉ុន្តែ បើទឹកទាំងនោះវាហូរចូលទៅក្នុងទីកន្លែងស្តុក នោះកំពស់ទឹកនៅក្នុងទីកន្លែងស្តុកនឹងកើនឡើង។

3) មានករណីតំឡើងលូកប់នៅក្នុងបាតទំនប់ស្តុកសារធាតុកករង ករណីជាច្រើន លូដែលត្រូវបានកប់នៅក្នុងទីកន្លែងស្តុកសារធាតុកករងនោះ គឺត្រូវបានប្រើផ្លូវសំរាប់បញ្ចេញទឹកទន្លេ។

4) បើពុំមានទាក់ទងនឹងទឹកដែលហូរចូលទៅក្នុងទីកន្លែងស្តុក ករណីបើមានទឹកល្អក់ចេញពីលូរដែលបានបង្កប់ គឺអាចសន្និដ្ឋានថា វានឹងមានភាពមិនប្រក្រតីចំពោះលូរដែលបានបង្កប់នោះ។ ឧទាហរណ៏ វានឹងអាចមានល្បាប់ដីហូរចូលក្នុងបំពង់លូរនោះតាមរយៈការប្រេះស្រាំ ។

5) ករណីមានបរិមាណទឹកបញ្ចេញចោលកើនឡើងពីលូដែលបានបង្កប់សំរាប់ធ្វើការបញ្ចេញចោល អាចគិតបានថា បរិមាណទឹកដែលហូរចេញពីប៉ុន្មានចំនុចរបស់លូដែលបានបង្កប់ ឬ តាមរយៈស្រទាប់ផ្នែកខាងក្រោម ឬមកពីបរិមាណទឹកដែលបានផុសចេញ។

6) នៅពេលមានភ្លៀងធ្លាក់ខ្លាំង ផ្នែកចរន្តទឹកខាងលើនៃផ្លូវទឹកសំរាប់បញ្ចៀសទឹក ដើម្បីទប់ស្កាត់បាក់និងទប់ស្កាត់របស់ដែលជាឧបស្គផ្សេងៗ ហូរចូលផ្លូវទឹកសំរាប់បញ្ចៀសចេញ ចាំចាប់ត្រូវតំឡើងទំនប់ និងបរិក្ខារទប់ស្កាត់ឈើហូរតាមទឹកមក។ ដូច្នេះហើយ ចាំបាច់រក្សាអោយបានល្អជាប្រចាំដោយធ្វើការសំអាតយកដីខ្សាច់និងឈើចេញ។ បើមិនបានយកខ្សាច់ និងឈើដែលហូរមកចេញទេ វានឹងអាចធ្វើស្ទះផ្លូវទឹកសំរាប់បញ្ចេញទឹក។

7) ផ្លូវទឹកបញ្ចៀសទឹកមកពីភ្នំ គឺជាផ្លូវទឹកសំរាប់ទប់ស្កាត់ការហូរចូលដោយទឹកពីភ្នំ ទៅក្នុងទីកន្លែងស្តុកកាកសំណល់រាវកករង។

បើករណីត្រូវស្ទះតាមរយៈការបាក់បែក នៃផ្លូវទឹកសំរាប់បញ្ចៀសទឹកពីផ្លូវ កុំអោយចូលក្នុងទីកន្លែងស្តុកកាកសំណល់រាវ។

នៅពេលត្រូវបានពិនិត្យនៅពេលភ្លៀងខ្លាំងបរិមាណទឹកមកពីផ្លូវទឹកដដែលនេះវាមានប្រសិទ្ធិភាពនៅដំណាក់កាលដំបូងនៃការដំឡើងផ្លូវទឹកបញ្ចៀសទឹកពីភ្នំ ចាំបាច់ត្រូវគិតពីការហូរចូលទៅក្នុងទីកន្លែងស្តុកពីស្រទាប់ដីក្រោមនៅពេលមានភ្លៀងធ្លាក់។

ដូច្នេះហើយ ចាំបាច់ត្រូវប្រយ័ត្នចំពោះការកើនឡើងពីកំពស់ទឹកនៅក្នុងកន្លែងស្តុក។

4. ស្តង់ដាទាក់ទងនឹងទីកន្លែងស្តុកសារធាតុកករង (ទំនប់ទប់ធ្វើពីដី)

(1) លក្ខខណ្ឌជ្រើសរើសកំណត់ទីតាំងសាងសង់ទីកន្លែងស្តុកសារធាតុកករង

1) គឺជាទីកន្លែងដែលភាគខាងក្រោមមិនមានផ្ទះប្រជាជន ឬមិនមានសំណង់សំខាន់ៗ។

2) គឺជាទីកន្លែងមិនមានការបាក់ដីពីលើភ្នំ ឬដីរអិលធ្លាក់មក។

3) ចាំបាច់ត្រូវតែមិនមែនជាទីតាំងសភាពបិទជ្រោះដែលមានផ្ទៃធំប្រមូលទឹក។

4) ជាគ្រឹះមានសភាពសមរម្យ។

(2) អនុវត្តស្រាវជ្រាវគ្រឹះដី

ស្តីពីគ្រឹះដីនិងតំបន់នៅជិតទីនោះ ដែលជាដីសំរាប់ជ្រើសរើសជាទីតាំងសាងសង់ទីកន្លែងស្តុក ចាំបាច់ត្រូវស្រាវជ្រាវតាមចំនុចដែលមានដូចខាងក្រោម។

1) ស្ថានភាពនៃបរិមាណមាននិងស្ថានភាពនៃចរិតរបស់ប្រភេទនៃគុណភាពដី ឬផ្ទាំងថ្មដែលផ្សំកកើតជាគ្រឹះដី

2) ស្ថានភាពនៃទឹកក្រោមដី

3) ស្ថានភាពនិងទីតាំងនៃទឹកផុសចេញ

(3) អនុវត្តពិសោធន៏គុណភាពដី

ការគូសប្លង់ទីកន្លែងស្តុក ចំពោះការដាំរុក្ខជាតិទាក់ទងនឹងរបស់ស្តុក ដីគ្រឹះសំខាន់ៗចាំបាច់បញ្ជាក់ពីភាពមានស្ថេរភាពនិងការគ្រប់គ្រងការសាងសង់ ចាំបាច់ត្រូវការសន្និដ្ឋានតើវាសាកសម្បឬមិនសាកសម្បដោយប្រើលទ្ធផលវិភាគគុណភាពដីដែលមានដូចខាងក្រោម។

ប្រភេទនៃការវិភាគដីសំរាប់សារធាតុស្តុកនិងគ្រឹះដី មានដូចខាងក្រោម ចំនុចទាំងឡាយដែលត្រូវវិភាគហើយទទួលបាននូវកំរិតសុក្រិតគ្រប់គ្រាន់ក្នុងការវិភាគនៃភាពមានលំនឹងនៃទីកន្លែងស្តុក ត្រូវបានកំណត់នូវវិធីយកដីជាសំណាក និងទីតាំងយកដីសំណាក។

ការយកសំណាក ធ្វើការកំណត់នូវទីតាំងដែលអាចយកសំណាកជាសំណាកតំណាំងអោយទីកន្លែងទាំងមូន ចំពោះវិធីនៃការយក មាន វិធីខួងយក វិធីជីកយកជារុន្ធ ការជីយកជាអណ្តៅ។ល។

moisture test、mechanical analysis、specific gravity test、liquid limit test; test for liquid limit、plastic limit test、compaction test、organic matter content test、consolidation test、box shear test、triaxial compression test、field density test、standard penetration test、static penetration test、field permeability test

(4) សមត្ថភាពនៃការបញ្ចេញទឹករបស់កន្លែងបញ្ចេញទឹក

1) ចំពោះបរិមាណទឹកហូរចូលពីចង្កេះភ្នំ និងនៅពេលមានភ្លៀងធ្លាក់ ដើម្បីកំណត់សមត្ថភាពការបញ្ចេញទឹកដែលចាំបាច់ត្រូវមានដោយទីកន្លែងបញ្ចេញទឹកនៅក្នុងទីកន្លែងនោះ និងការបញ្ចេញទឹកនៅក្រៅកន្លែងនោះ ចាំបាច់ត្រូវតែតាមគោលការណ៏នីមួយៗដែលមានដូចខាងក្រោម។

2) ចំពោះបរិមាណទឹកធ្លាក់ ត្រូវគិតចំពោះបរិមាណទឹកភ្លៀងធ្លាក់ច្រើនបំផុតដែលអាចមានម្តងក្នុង ១០០ឆ្នាំ។

ក៏ប៉ុន្តែ ចំពោះការគណនាសមត្ថភាពបញ្ចេញទឹកអតិបរមា នៃទីកន្លែងបញ្ចេញទឹកនៅពេលមានគ្រោះអសន្នក៏អាចគិតដល់អាចនឹងមាន១ដងក្នុងរយៈ២ឆ្នាំផងដែរ។

３）បរិមាណទឹកធ្លាក់ ត្រូវធ្វើការគណនាអនុលោមតាមឯកសារនៃការវាស់កំពស់ទឹកភ្លៀងក្នុងរយៈវែងរបស់ទីកន្លែងវាស់ទឹកភ្លៀងដែលជាកន្លែងតំណាំងនៃតំបន់ប្រមូលទឹកភ្លៀង។ ក៏ប៉ុន្តែ ករណីមិនអាចប្រមូលនូវឯកសារទាក់ទងនឹងបរិមាណទឹកភ្លៀងធ្លាក់ ទាំងនោះបាន ក៏អាចធ្វើការជ្រើសរើសទីកន្លែងនៅជិតតំបន់នោះដែលមានទិន្នន័យពីបរិមាណទឹកភ្លៀងធ្លាក់ដែលមានឯកសារនៃការវាស់កំពស់ទឹកភ្លៀងក្នុងរយៈវែងរបស់ទីកន្លែងវាស់ទឹកភ្លៀងដែលជាកន្លែងតំណាំងនៃតំបន់ប្រមូលទឹកភ្លៀង។

４）ចំពោះការគណនាបរិមាណទឹកភ្លៀងហូរចូល ផ្ទៃក្រឡានៃកន្លែងប្រមូលទឹក ភាពរឹងមាំចំពោះបរិមាណជាមធ្យមនៃទឹកភ្លៀងធ្លាក់ មេគុណបរិមាណទឹកហូរពីតំបន់ទឹកដែលត្រូវបានប្រមូលទាំងអស់នេះហើយនឹងជា*Factor*។

5）តាមរយៈស្ថានភាពនៃតំបន់ប្រមូលទឹក ចាំបាច់ត្រូវប្រយ័ត្នចំពោះដីហូរចូលឬថ្មហូរចូល។

（5）ចំនុចទូទៅនៃការគូសប្លង់ជញ្ជាំងទំនប់នៃទីកន្លែងស្តុក

1）ចំពោះជញ្ជាំងទំនប់ ចាំបាច់ត្រូវធ្វើយ៉ាងណាមិនផ្តល់ទំងន់អោយលើសពីកំឡាំងទទួលការស្តុក។

2）ចាំបាច់ត្រូវមានស្ថេរភាពចំពោះកំឡាំងខាងក្រៅនិងកំឡាងទំនាញខ្លួនឯង។

3）ត្រូវតែជារចនាសម្ព័ន្ធ សមស្របសំរាប់បញ្ចេញទឹកដែលមាននៅក្នុងសារធាតុស្តុក។

4）មិនត្រូវអោយខ្សែផ្ទៃទឹកលិចមាននៅផ្នែកខាងក្រោមជារទឹក។

5）មិនត្រូវអោយមានលេចចេញជារន្ធនៅក្នុងតួរជញ្ជាំងទំនប់និងគ្រឹះដី។

6）ចំពោះផ្ទៃជញ្ជាំងទំនប់ ជារចនាសម្ព័ន្ធដែលមិនអោយទឹកហូរជាច់បាន។

7）ចំពោះសារធាតុស្តុកនិងសារធាតុយកមកសាងសង់ ជារចនាសម្ព័ន្ធមិនអោយទឹកហូរចេញទៅខាងក្រៅទំនប់ស្តុកបាន។

8）សារធាតុសាងសង់គឺជាសារធាតុមិនអាចហើររាយប៉ាយបានដែរ។

（6）វិភាគស្ថានភាពមានលំនឹង និងស្តង់ដានៃការគូសប្លង់របស់ជញ្ជាំងទំនប់

１）ក្នុងនាមជាសារធាតុសាងសង់ជញ្ជាំងទំនប់ ចាំបាច់មិនត្រូវអោយមានសារធាតុដីឥដ្ឋ ច្រើនពេក សារធាតុមានទំហំធំពេក និងជាដីមិនអោយមានសារធាតុមេរោគស្ថិតនៅច្រើនពេក ទេ។

2）ស្តីពីជំរេលនៃផ្ទៃជញ្ជាំង ចាំបាច់ត្រូវមានទូរលេខមានដូចខាងក្រោម។

ផ្នែកជារទឹកខាងលើ　１：１．８　（ជំរេល２９°）

ផ្នែកជារទឹកខាងក្រោម１：２．５　（ជំរេល２１°）

3）ទំហំនៃកំពស់ទំនប់ គឺជាស្តង់ដាដែលត្រូវបានគណនាដោយរូបមន្តមានដូចខាងក្រោម។

$$W = 1.3\sqrt{H} \quad (m)$$

ក៏ប៉ុន្តែ、W : ទំហំត្រង់ចំនុចកំពូល　(m)

H : កំពស់មានប្រសិទ្ធិភាពនៃជញ្ជាំងទំនប់ (m)

４）ដើម្បីទប់ស្កាត់ការជ្រាបទៅក្នុងតួរទំនប់ដោយរួមទាំងទឹកដែលមាននៅក្នុងសារធាតុស្តុក តំឡើង

អាងស្តុកទឹកនៅភាគផ្នែកធារទឹកខាងលើ។

5）ចំពោះផ្ទៃនៃផ្នែកធារទឹកខាងក្រោម ត្រូវតំឡើងកាំជណ្តើរក្នុងប្រវែង១០ម៉ែត្រ អោយមានកាំជណ្តើរមួយ។

6）ចំពោះផ្ទៃនៃផ្នែកធារទឹកខាងក្រោម ដើម្បីបញ្ចេញទឹកដែលប្រមូលបានពីទឹកភ្លៀង ចាំបាច់ត្រូវតំឡើងប្រលាយសំរាប់ទឹកភ្លៀង។

7）ចំពោះជញ្ជាំងទំនប់ទាំងសងខាង ចាំបាច់ត្រូវតំឡើងប្រលាយទឹកភ្លៀង បើត្រូវការចាំបាច់។

8）ដើម្បីទប់ស្កាត់វត្ថុយកមកសាងសង់កុំអោយរបើកប៉ើង ចំពោះផ្ទៃនៃផ្នែកធារទឹកខាងក្រោម ចាំបាច់ត្រូវចាត់វិធានការសមរម្យដោយដាំដើមឈើ គ្របដោយផ្ទាំងថ្មធំៗ។ល។

9）ចំពោះការវិភាគពីភាពមានលំនឹងនៃជញ្ជាំងទំនប់ អនុវត្តការគណនាយោងតាមវិធី circular arc analysis។

１０）ចំពោះការវិភាគពីភាពមានលំនឹងនៃជញ្ជាំងទំនប់ ក្រៅពីនៅពេលគណនាគូសប្លង់ ករណីត្រូវបានទទួលស្គាល់ថាមានភាពមិនប្រក្រតីនៅទីកន្លែងស្តុកនោះ នៅពេលបញ្ចប់ការស្តុកក៏ធ្វើដូចគ្នាដែរ។

１１）ស្តីពីលទ្ធផលវិភាគភាពមានលំនឹងរបស់ជញ្ជាំងទំនប់ ត្រូវតែមានកំរិតលំនឹងមានលើសពី １．２ដង។

（ឧបសម្ព័ន្ធ－２）

# ជំពូក៤： ការអនុវត្តការត្រួតពិនិត្យ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទូទៅទាក់ទងនឹងទឹកកខ្វក់ឬទឹកក្នុងរូង

28 July 2016

１．ការរៀបចំយកទៅជាមួយមុននឹងអនុវត្តការត្រួតពិនិត្យទូទៅ （ទប់ស្កាត់ការបំពុលបរិដ្ឋាន）

ក្នុងការអនុវត្តត្រួតពិនិត្យទូទៅទាក់ទងនឹងទឹកកខ្វក់ឬទឹកនៅក្នុងរូង សំភារៈចាំបាច់ត្រូវយកទៅជាមួយរបស់ដែលមានដូចខាងក្រោមដោយសំរបសំរួលចាំបាច់តាមស្ថានភាពការដ្ឋាននីមួយៗរួមទាំងបរិក្ខារដែលបានរាយរាប់នៅក្នុង「ជំពូកទី១ ចំនុច２．（２）ស្តីពីបរិក្ខារដែលត្រូវយកទៅជាមួយក្នុងពេលធ្វើការត្រួតពិនិត្យទូទៅ」។

１）បរិក្ខារវាស់គុណភាពទឹក។ល។ (បរិក្ខារវាស់ｐＨ、**pack test**)

２）polyethylene bottle ប្រើសំរាប់ដាក់ទឹក**1000ml**

３）ក្រដាស់តំរង

４）ជីបឡាវ

５）ថ្នាំសារធាតុគីមី（nitric acid、sodium hydroxide។ល។)

６）បរិក្ខារវាស់សីតុណ្ហភាព

２．ការអនុវត្តការត្រួតពិនិត្យ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទូទៅទាក់ទងនឹងទឹកកខ្វក់ឬទឹកក្នុងរូង

（１）ការអនុវត្តការត្រួតពិនិត្យ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទូទៅនៅក្នុងការិយាល័យរ៉ែ

មន្ត្រីអធិការកិច្ច ឬកររួមទាំងនៅក្នុង「ជំពូក២ １．អនុវត្តការត្រួតពិនិត្យ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទូទៅនៅក្នុងការិយាល័យរ៉ែ 」ទាក់ទងនឹងទឹកកខ្វក់ឬទឹកនៅក្នុងរូងរបស់ការដ្ឋានរ៉ែនោះសាកសួរពីអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព តាមចំនុចដែលមានដូចខាងក្រោម ដោយធ្វើការបញ្ជាក់តើមានឬមិនមានឧបសគ្គលើការទប់ស្កាត់បញ្ហាបំពុលបរិដ្ឋានរ៉ែដែរឬទេ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអចំពោះអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព។ ព្រមទាំងសាកសួរចំនុចដែលមានដូចខាងក្រោម។

１）ចំពោះ「បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព」របស់ការដ្ឋានរ៉ែ តើមានបានកំណត់ដូចចំនុចដែលមានដូចខាងក្រោមដែរឬទេ។

**a)** ទាក់ទងនឹងការគ្រប់គ្រងបរិក្ខារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូង។

**b)** ទាក់ទងនឹងការវាស់គុណភាពទឹកផ្សេងៗ បរិមាណទឹកកខ្វក់ឬទឹកនៅក្នុងរូង និងបរិមាណកំរិតｐＨ។

**c)** ទាក់ទងនឹងចាត់វិធានការនៅពេលអាចនឹងកើតឡើង ឬកើតឡើងនូវការបំពុល តាមរយៈកកខ្វក់ឬទឹកនៅក្នុងរូង ដោយសារការខូចបរិក្ខារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូង បាក់បែក គ្រោះថ្នាក់ផ្សេងៗកើតឡើង ដូចជាការដាច់ចរន្តអគ្គិសនី ឬ ភ្លៀងធ្លាក់ខ្លាំង ឬតាមមូលហេតុពិសេស

ផ្សេងទៀត ។

2) ចំពោះករណីមានការបញ្ចេញទឹកកខ្វក់ ឬទឹកនៅក្នុងរូងមានស្ថានភាពពុលដែលមានទូរលេខមិនជាប់នឹងស្តង់ដាដែលបានកំណត់ ដែលទឹកនោះចេញពីគំនរនៃកន្លែងស្តុក កាកសំណល់កករង ឬ *slag* ថ្មចោល ឬពីផ្លូវដែលប្រើសំរាប់ការងាររ៉ែ យោងតាមការកំណត់របស់ច្បាប់និងបទបញ្ញត្តិស្តីពីបរិមាណនិងស្ថានភាពបំពុលរបស់ប្រព័ន្ធបញ្ចេញទឹកកខ្វក់ឬទឹកនៅក្នុងរូង តើមានបានធ្វើការរាយការណ៍ដល់រដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែដែរឬទេ?

3) នៅច្រកបញ្ចេញទឹកកខ្វក់ពីការដ្ឋានរ៉ែ តើមានធ្វើការបញ្ចេញទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមានស្ថានភាពពុលមិនត្រូវនឹង「ច្បាប់គ្រប់គ្រងធនធានរ៉ែនិងការពារបរិដ្ឋាន」 និងការកំណត់របស់ច្បាប់ទាំងឡាយផ្សេង (ខាងក្រោមមកទៀតហៅកាត់ថា「ស្តង់នៃការកំណត់」) ទៅក្នុងតំបន់ទឹកសាធារណៈ។

4 ) តើមានទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមានស្ថានភាពពុលមិនត្រូវនឹងស្តង់ដាបានកំណត់ ជ្រាបចូលទៅក្នុងដីដែរឬទេ?

5 ) នៅក្នុងអគារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូង តើមានចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ចំពោះករណីមានគ្រោះថ្នាក់ ឬចាត់វិធានការទប់ទល់នឹងចំពោះគ្រោះថ្នាក់នោះ ជាបន្ទាន់ នៅពេលមានកើតឡើងនូវការជ្រាបទឹកចូលទៅក្នុងដី ដោយទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមានស្ថានភាពពុល ដែលលមិនត្រូវនឹងស្តង់ដាបានកំណត់ ឬមានការកើតឡើងនូវគ្រោះថ្នាក់ផ្សេងៗទៀតដូចជាការខូច បែកបាក់ ការដាច់ចរន្តអគ្គិសនី។ល។

6) នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតឡើងនូវការបំពុលបរិដ្ឋាន តាមរយៈការហូរប្រេងចេញ។ល។ មានគ្រោះថ្នាក់ផ្សេងៗកើតឡើង ការខូចបរិក្ខារអគារប្រើនៅក្នុងពេលធ្វើអាជីវកម្មរ៉ែ តើមានចាត់វិធានការទប់ទល់នឹងគ្រោះថ្នាក់នោះដែរឬទេ និងមានធ្វើការជួសជុលស្តារឡើងវិញជាបន្ទាន់ដែរឬទេ?

7 ) ស្តីរូងដែលត្រូវបានប្រើប្រាស់រួចក្នុងអាជីវកម្មរ៉ែ ចំពោះបរិមាណទឹកដែលហូរចេញនិងស្ថានភាពការបំពុលដែលមិនជាប់នឹងស្តង់ដាបានកំណត់ តើមានចាត់វិធានការសមរម្យដល់បរិក្ខារបំលែងទឹកកខ្វក់នៅក្នុងរូង ឬសាងសង់បិទផ្ចិតរូងនោះដែរឬទេ?

8 ) ក្នុងករណីបានទទួលបញ្ជាអោយចាត់វិធានការអោយធ្វើអោយត្រូវនឹងស្តងដាដែលបានកំណត់សំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់ ឬទឹកនៅក្នុងរូង ដោយរដ្ឋមន្ត្រីទទួបន្ទុកការងាររ៉ែ តើការដ្ឋានរ៉ែនោះបានគោរពតាមបញ្ជាទាំងនោះដែរឬទេ?

9 ) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំពុលបរិដ្ឋាន ដើម្បីទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់និងទឹកនៅក្នុងរូង តើមានគោរពតាមចំនុចដែលមានដូចខាងក្រោមដែរឬទេ?

a) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

b) ស្តីពីស្ថានភាពបំពុលនិងបរិមាណទឹកកខ្វក់និងទឹកនៅក្នុងរូងដែលចាំបាច់ត្រូវការវាស់ និងតាមដាន ត្រូវធ្វើការវិភាគនិងវាស់ជាប្រចាំ និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

c) លទ្ធផលនៃការវិភាគនិងវាស់ឬការដើរល្បាត នៅពេលអាចនឹងមានគ្រោះថ្នាក់កើតឡើងច្រើននៅអគារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូងតាមរយៈស្ថានភាពផ្សេងៗ ការខូច ការដាច់ចរន្តភ្លៀងខ្យល់ មានច្រើនដែលបណ្តាលអោយមានការបំពុលតាមទឹកកខ្វក់ឬទឹកក្នុងរូង តើមានបានរាយការណ៍ដល់អ្នកគ្រប់គ្រងដែរឬទេ?

１０) នៅពេលបានបញ្ចប់ការងារសាងសង់ជួសជុល និងខ្លឹមសារនៃវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និងស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់កើតឡើងពីការបំពុល ឬការកើតឡើងបញ្ហាបំពុលបរិដ្ឋានយោងតាមរយៈការបញ្ចេញទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមិនត្រូវនឹងស្តង់ដាបានកំណត់ទប់ស្កាត់ធ្វើអោយគុណភាពទឹកមានភាពល្អក់ ស្តីពីខ្លឹមសារទាំងនោះ តើមានបានរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែដែរឬទេ?

(2) អនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) នៅទីកន្លែងធ្វើការងារនិងអគាររបស់ការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច បូករួមទាំង「ជំពូក២ 2. ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) នៅទីកន្លែងធ្វើការងារនិងអគាររបស់ការដ្ឋានរ៉ែ」 ដែលមានទាំងលើ ស្តីពីចំនុចខាងក្រោម ធ្វើការបញ្ជាក់នៅទីកន្លែងធ្វើការនិងនៅតាមអគាររបស់ការដ្ឋានរ៉ែ តើមានបញ្ហាឬមិនមានបញ្ហាក្នុងការទប់ស្កាត់ការកើតឡើងនូវបញ្ហាបំពុលបរិដ្ឋានទាក់ទងនឹងទឹកកខ្វក់និងទឹកនៅក្នុងរូង ស្តីពីចំនុចត្រូវបានសន្និដ្ឋានបញ្ជាក់ថាមានភាពមិនសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1) តើអគារទាំងនោះ មានសមត្ថភាពគ្រប់គ្រាន់សំរាប់ចំរាញ់ទឹកកខ្វក់និងទឹកនៅក្នុងរូងដែរឬទេ?

2) ចំពោះស្ថានភាពគ្រប់គ្រងថែទាំអគារសំរាប់ចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង មានភាពល្អដែរឬទេ? បញ្ជាក់ពីការដើរល្បាតមើលសីកណា ការប្រមូលទឹក បំពង់បញ្ជូនទឹក ទឹកលេច និងភាពមានប្រក្រតីឬមិនមានភាពប្រក្រតី។

3) ចំពោះទឹកនៅក្នុងរូងត្រូវបានបញ្ចេញតាមច្រកមាត់រូង តើមានត្រូវនឹងស្តង់ដាបានកំណត់ដែរឬទេ?

4) ចំពោះទឹកកខ្វក់ដែលត្រូវបានបញ្ចេញពីអគារនៃការដ្ឋានរ៉ែ ទីកន្លែងជ្រើសរើសរ៉ែ ឬកន្លែងរំលាយរ៉ែ។ល។ តើទឹកនោះបានជាប់នឹងស្តង់ដាបានកំណត់ដែរឬទេ?

5) ធ្វើការកំណត់បញ្ជាក់ពីប្រភេទសារធាតុថ្នាំដែលប្រើនៅក្នុងអគារចំរាញ់ទឹកកខ្វក់និងទឹកនៅក្នុងរូង បញ្ជាក់ពីចំនួនការប្រើប្រាស់ និងបរិមាណនៃការរក្សាទុក។ល។

6 ) តើមាបានអោយទឹកកខ្វក់ឬទឹកនោក្នុងរូងដែលមិនជាប់នឹងស្តងដាបានកំណត់ ជ្រាបចូលទៅក្នុងដីដែរឬទេ?

7) មានបានរក្សាទុកនូវបរិក្ខារសង្គ្រោះបន្ទាន់ សំរាប់ទប់ទល់នឹងគ្រោះថ្នាក់ដែលអាចនឹងកើតមានឡើងនៅក្នុងអគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូងដែរឬទេ?

3. អនុវត្តការយកសំណាកសំរាប់ស្រាវជ្រាវគុណភាពទឹកកខ្វក់និងទឹកក្នុងរូង។ល។

(1) បង្កើតផែនការការងារសំរាប់ស្រាវជ្រាវគុណភាពទឹកកខ្វក់និងទឹកក្នុងរូង។ល។

អនុលោមតាម 「ប្រព័ន្ធចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង」 នៅការដ្ឋានរ៉ែនោះ បង្កើតផែនការយកសំណាកសំរាប់ស្រាវជ្រាវគុណភាពទឹកដែលទាក់ទងទឹកកខ្វក់និងទឹកក្នុងរូង។

ចំពោះផែនការនេះ ចាំបាច់ត្រូវសរសេរពី វិធីយកសំណាក បែបបទនៃការស្រាវជ្រាវគុណភាពទឹក រចនាសម្ព័ន្ធទាក់ទងនឹងនៅពេលមានគ្រោះអសន្ន វិធានការទប់ស្កាត់គ្រោះថ្នាក់។ល។

(2) រៀបចំទុកជាមុនសមរាប់ស្រាវជ្រាវគុណភាពទឹក

ក្នុងការយកសំណាកសំរាប់ធ្វើការស្រាវជ្រាវគុណភាពទឹកទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូង ព្រមជាមួយនឹងការស្នើរសុំអោយភាគីការដ្ឋារ៉ែ ដែលមានអ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលដោយសាររ៉ែទាក់ទងនឹងទឹកកខ្វក់និងទឹកនៅក្នុងរូង អោយចូលរួមចំពោះនៅទីកន្លែងមួយដូចគ្នា ក៏ស្នើសុំអោយមានការយកសំណាកដូចគ្នាដែរ។

(3) ស្រាវជ្រាវគុណភាពទឹកកខ្វក់និងទឹកក្នុងរូង

1) មន្រ្តីអធិការកិច្ចការដ្ឋានរ៉ែ ធ្វើការត្រួតពិនិត្យ តើមានឬមិនមានភាពមិនប្រក្រតី ចំពោះការប្រមូលទឹកកខ្វក់និងទឹកក្នុងរូង ការដើរល្បាតមើលបំពង់បញ្ជូនទឹក ទឹកលេច មានការលេចល្បាប់កករងចេញ។

2) ស្តីពីការស្រាវជ្រាវគុណភាពទឹកកខ្វក់និងទឹកនៅក្នុងរូង ត្រូវអនុវត្តតាមបែបបទមានដូចខាងក្រោម៖

**a)** ចំពោះនៅពេលយកសំណាកដែលជាទឹកកខ្វក់និងទឹកក្នុងរូង ត្រូវធ្វើការកត់ត្រា វាស់បរិមាណទឹក ស្ថានភាពការល្អក់ កំដៅទឹក **pH** ។ ក៏ប៉ុន្តែ ចំពោះករណីត្រូវបានទទួលស្គាល់ថាមានក្លិន បើចាំបាច់ត្រូវធ្វើការវាស់បរិមាណឧស្ម័នអុកស៊ីសែនរលាយក្នុងទឹកថែមទៀត។ ចំពោះករណីនេះ ធ្វើការកត់ត្រាក្នុងនាមជាការកត់ចំនុចពិសេស។ (ស្តីពីការវាស់ខាងក្រោមក៏ដូចគ្នាដែរ។)

**b)** នៅការដ្ឋានរ៉ែលោហៈ ជាទូទៅចំពោះការយកសំណាកទឹក ត្រូវប្រើ polyethylene bottle ដែលមានចំណុះ**1000ml**។

**c)** ករណីទឹកនោះល្អក់ខ្លាំង ប្រើតំរងច្រោះ បន្ថែមបរិមាណ nitric acidចំនួន**10 ml** ដើម្បីបានកំរិត **pH 1**។

ចំពោះpolyethylene bottle វាអាចចាប់បាននូវភាពជាប់របស់ metal ionដោយសារតាមការបញ្ចូលនូវសារធាតុnitric acid នេះគឺជាការចាំបាច់វិធីបំរុងសំរាប់ទប់ស្កាត់កុំអោយមានភាពជាប់ស្រូបយកនោះបាន។២១០៥

（4） ស្រាវជ្រាវគុណភាពទឹករបស់អគារចំរាញ់ទឹកកខ្វក់និងទឹកនៅក្នុងរូង

1） ស្តីពីអគារចំរាញ់ទឹកកខ្វក់និងទឹកនៅក្នុងរូង ពិនិត្យមើលស្ថានភាពមានភាពមិនប្រក្រតីឬមានភាពប្រក្រតី ស្ថានភាពគ្រប់គ្រងដំណើរការអគារ ស្ថានភាពលាយថ្នាំគីមី សមត្ថភាពចំរាញ់របស់អគារសំរាប់ទឹកកខ្វក់និងទឹកនៅក្នុងរូង។

2）ស្តីពីការស្រាវជ្រាវគុណភាពទឹកនៃអគារចំរាញ់ទឹកកខ្វក់និងទឹកនៅក្នុងរូង ត្រូវអនុវត្តតាមបែបបទដូចមានខាងក្រោម៖

**a)** ចំពោះករណីត្រូវបានបំលែងទឹកកខ្វក់ឬទឹកក្នុងរូងនៅអគារ ស្តីពីការបញ្ចេញទឹកក្រោយពេលចំរាញ់រួច ចាំបាច់ត្រូវយកសំណាកទឹកនោះឡើងវិញ ហើយនៅពេលយកសំណាកទឹក ត្រូវធ្វើការកត់ត្រា វាស់បរិមាណទឹក ស្ថានភាពការល្អក់ កំដៅទឹក **pH** ។

**b)** ចំពោះនៅការដ្ឋានរ៉ែលោហៈ ក្នុងការយកសំណាកទឹក គឺត្រូវធ្វើដូចខាងលើ ដោយប្រើ polyethylene bottle ដែលមានចំណុះ**1000ml**។

**c)** ករណីមានទឹកភាពល្អក់ខ្លាំង ប្រើតំរងសំរាប់ច្រោះ ដោយលាយបន្ថែមបរិមាណ nitric acidចំនួន**10 ml** ដើម្បីបានកំរិត **pH 1**។

（5） ស្រាវជ្រាវគុណភាពទឹកបឹងនិងទឹកស្រះ

1） ស្តីពីការស្រាវជ្រាវទឹកបឹងឬទឹកស្រះ ទឹកទន្លេដែលត្រូវបានបង្ហូរចេញពីអគារចំរាញ់ និងទឹកកខ្វក់ ទឹកនៅក្នុងរូង ត្រូវអនុវត្តតាមបែបបទដូចមានខាងក្រោម៖

**a)** ស្តីពីការស្រាវជ្រាវទឹកបឹងឬទឹកស្រះ ទឹកទន្លេដែលត្រូវបានបង្ហូរចេញពីអគារចំរាញ់ និងទឹកកខ្វក់ ទឹកនៅក្នុងរូង នៅពេលយកចំណាកទឹកគឺចាំបាច់ត្រូវនៅកន្លែងធារទឹកខាងក្រោម និងធារទឹកផ្នែកខាងលើនៃទន្លេ នៃទីកន្លែងដែលទឹកទាំងឡាយនោះបានហូរចូល ហើយនៅពេលយកសំណាកទឹក ត្រូវធ្វើការកត់ត្រា វាស់បរិមាណទឹក ស្ថានភាពល្អក់ កំដៅទឹក **pH** ។

**b)** នៅពេលយកសំណាកទឹកនៅចំនុចធារទឹកខាងលើនិងចំនុចធារទឹកខាងក្រោម ចាំបាច់ត្រូវប្រើ polyethylene bottle ដែលមានចំណុះ**1000ml**។

**c)** ករណីមានទឹកភាពល្អក់ខ្លាំង ប្រើតំរងសំរាប់ច្រោះ ដោយលាយបន្ថែមបរិមាណ nitric acidចំនួន**10 ml** ដើម្បីបានកំរិត **pH 1**។

ក្នុងការជ្រើសរើសទឹកន្លែងយកសំណាកទឹកនៅចំនុចធារទឹកខាងក្រោម ត្រូវជ្រើសរើសយកចំនុចណាដែលគិតថានឹងអាចមានការហូរលាយឡំបានគ្រប់គ្រាន់រវាងទឹកទន្លេនឹងទឹកដែលបានបង្ហូរចេញពីការដ្ឋានរ៉ែ សំរាប់យកជាទឹកន្លែងយកសំណាក់ទឹកទើបជាការប្រសើរ។

**d)** ចំពោះករណីយកទឹកនោះមកប្រើដែលទឹកទន្លេនោះត្រូវបានបង្ហូរទឹកពីការដ្ឋានរ៉ែចូល ចាំបាច់ត្រូវតែយកសំណាកទឹកផ្នែកខាងក្រោមនៃធារទឹកដែលគេយកទឹកនោះជាប្រភពទឹកសំរាប់បរិភោគ ឬប្រើសំរាប់ប្រព័ន្ធធារាសាស្ត្រ នៅពេលយកសំណាកទឹក ត្រូវធ្វើការកត់ត្រា វាស់បរិមាណទឹក ស្ថានភាពល្អក់ កំដៅទឹក **pH** ។

**e)** នៅពេលយកសំណាកទឹកនៅចំនុចសំរាប់យកទឹកមកប្រើ គឺត្រូវអនុវត្តដូចខាងលើនិងចាំបាច់ត្រូវប្រើ polyethylene bottle ដែលមានចំណុះ**1000ml**។

**f)** ករណីមានទឹកភាពល្អក់ខ្លាំង ប្រើតំរងសំរាប់ច្រោះ ដោយលាយបន្ថែមបរិមាណ nitric acidចំនួន**10 ml** ដើម្បីបានកំរិត **pH 1**។

**g)** ស្តីពីទឹកបឹងឬទឹកស្រះដែលមានទឹកចេញពីក្នុងរូង ឬទឹកកខ្វក់ ឬទឹកពីអគារចំរាញ់ហូរចូល គឺត្រូវជ្រើសរើយកចំនុចដែលគិតថាអាចនឹងមានការលាយឡំបានគ្រប់គ្រាន់ជាមួយនឹងទឹកដែលមាននៅក្នុងបឹងឬស្រះនោះ បន្ទាប់មក ធ្វើការវាស់ពីស្ថានភាពល្អក់របស់ទឹក កំដៅទឹក **pH** ក្រោយពីការធ្វើការកត់ត្រារួចសូមធ្វើការយកសំណាក់។ ទឹកបឹងឬទឹកស្រះ ករណីត្រូវបានគេប្រើជាប្រភពទឹកសំរាប់ប្រើធ្វើជាទឹកប្រើប្រាស់ ឬប្រភពទឹកប្រឡាយ នៅចំនុចដែលគេយកទឹកនោះមកប្រើ ត្រូវអនុវត្តស្រាវជ្រាវគុណភាពទឹកដូចខាងលើ ហើយត្រូវអនុវត្តដូច **d), e)**និង**f)**ដែលមានដូចខាងលើដែរ។

（6）វិធានការរៀបចំសំរាប់ការយកសំណាក និងបរិមាណសំណាក

ចំពោះករណីយកសំណាកទឹកដោយប្រើ polyethylene bottleនិងបរិមាណសំណាកដែលត្រូវយកជាចាំបាច់សំរាប់ការស្រាវជ្រាវ ដោយឆ្លើយតបនឹងសារធាតុដែលមាននៅក្នុងសំណាក ចាំបាច់ត្រូវចាត់ចែងរៀបចំអោយមានដូចខាងក្រោម៖

| សារធាតុនៅក្នុងសំណាកទឹក | បរិមាណត្រូវយក | ចាត់ចែងរៀបចំអោយមាន |
|---|---|---|
| ទង់ដែង សំណ សង្កី កាដ្យូម អាសេនិច ដែក ម៉ង់ហ្គាណែស ក្រូម នីកែល កូប៉ាល់ | **1,000 ml** | ដាក់លាយបន្ថែមបរិមាណ nitric acid ចំនួន**10 ml** ដើម្បីបានកំរិត **pH 1**។ បរិមាណលាយបន្ថែម គឺក្នុងទឹក**1000 ml** ត្រូវការ nitric acidចំនួន**10 ml**។ |

| | | |
|---|---|---|
| បារត | **1,000 ml** | ប្រើដបកញ្ចក់រឹង ចាក់លាយnitric acidសំរាប់អោយ**pH**មានកំរិត 1 ។ បរិមាណលាយបន្ថែម គឺក្នុងទឹក**1000 ml** ត្រូវការ nitric acidចំនួន**10 ml**។ |
| សារធាតុរបស់ស៊ីអាន | **500 ml** | នបូកបន្ថែមល្បាយ sodium hydroxide និង tabula ដើម្បីបាន**pH** ប្រមាណ**12**។ បរិមាណលាយបន្ថែម គឺក្នុងទឹកសំណាក់**1000 ml** ត្រូវការល្បាយ sodium hydroxide 4 %ចំនួន**10 ml** ។ |
| hexavalent chromium | **500 ml** | នៅក្នុងស្ថានភាពណឹត រក្សានៅក្នុងកន្លែងត្រជាក់និងងងឹត។ |

7 ) បង្កើតផែនទីនៃទីតាំងយកសំណាក និងកំណត់ចំនុចយកសំណាក

នៅក្នុងការស្រាវជ្រាវគុណភាពទឹកទាក់ទងនឹងទឹកក្នុងរូងនិងទឹកកខ្វក់ បើមិនមានការផ្លាស់ប្តូរវិធី នៃការចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង ស្ថានភាពនៃការបញ្ចេញទឹកកខ្វក់និងទឹក្នុងរូង ស្ថានភាពនៃការដំណើរការការដ្ឋានរ៉ែ កំណត់ចំនុចយកសំណាកទឹក និចាំបាច់ត្រូវយកសំណាកទឹកនៅកន្លែងដដែលៗអោយបានជាប់រហូត នៅកន្លែងតែដដែល។

លើសពីនេះ នៅរាល់ពេលយកសំណាកសមរាប់ស្រាវជ្រាវគុណភាពទឹកទាកើទងនឹងទឹកកខ្វក់និងទឹកក្នុងរូង ចាំបាច់ត្រូវបង្កើតផែនទីកំណត់ចំនុចយកសំណាកនោះ។

ចំពោះផែនទីបង្ហាញចំនុចយកសំណាក ត្រូវកំណត់យកចំនុចទាំងឡាយដែលបានយកទឹកនោះជាសំណាក ដូចជា ចំនុចយកទឹកកខ្វក់និងទឹកក្នុងរូង ចំនុចយកទឹកត្រូវបានបញ្ចេញពីអគារចំរាញ់ទឹកកខ្វក់និងទឹក្នុងរូង ចំនុចធារទឹកខាងក្រោមនិងចំនុចធារទឹកខាងលើនៃទន្លេដែលត្រូវបានបង្ហូរចូលដោយទឹកពីអគារចំរាញ់ទឹកកខ្វក់និងទឹក្នុងរូង ករណីយកទឹកប្រើជាប្រភពសំរាប់ផលិតទឹកបរិភោគ និងទឹកជាប្រភពទឹកសំរាប់ប្រើក្នុងប្រព័ន្ធធារាសាស្ត្រ និងទន្លេ ដែលត្រូវបានហូរចូលដោយទឹកមកពីការដ្ឋានរ៉ែ និងចំនុចយកសំណាកទឹកបឹង ឬទឹកស្រះ ក៏ត្រូវកំណត់និងសរសេរកត់ត្រាឡើងផងដែរ។

4. ស្តង់ដានៃការបញ្ចេញទឹកចោល

ស្តង់ដានៃការបញ្ចេញទឹកចោលរបស់ប្រទេសកម្ពុជា (មួយផ្នែកនៃចំនុចទាំងឡាយនោះ)

| **parameters** | **Allowable limits for pollutant substance discharging to protected public water area** | **Allowable limits for pollutant substance discharging to public water area and sewer** |
|---|---|---|
| **Temperature** | **< 45℃** | **< 45℃** |
| **pH** | **6 ～ 9** | **5 ～ 9** |
| **COD** | **< 50 mg/l** | **< 100 mg/l** |
| **Total suspended solids** | **< 50 mg/l** | **< 80 mg/l** |
| **Grease and oil** | **< 5.0 mg/l** | **< 15 mg/l** |
| **Cyanide (CN)** | **< 0.2 mg/l** | **< 1.5 mg/l** |
| **Arsenic (As)** | **< 0.1 mg/l** | **< 1.0 mg/l** |
| **Tin (Sn)** | **< 2.0 mg/l** | **< 8.0 mg/l** |
| **Iron (Fe)** | **< 1.0 mg/l** | **< 20 mg/l** |
| **Manganese (Mn)** | **< 1.0 mg/l** | **< 5.0 mg/l** |
| **Cadmium (Cd)** | **< 0.1 mg/l** | **< 0.5 mg/l** |
| **Chromium ($Cr^{+6}$)** | **< 0.05 mg/l** | **< 0.5 mg/l** |
| **Copper (Cu)** | **< 0.2 mg/l** | **< 1.0 mg/l** |
| **Lead (Pb)** | **< 0.1 mg/l** | **< 1.0 mg/l** |
| **Mercury (Hg)** | **< 0.002 mg/l** | **< 0.05 mg/l** |
| **Nickel (Ni)** | **< 0.2 mg/l** | **< 1.0 mg/l** |
| **Selenium (Se)** | **< 0.05 mg/l** | **< 0.5 mg/l** |
| **Zinc (Zn)** | **< 1.0 mg/l** | **< 3.0 mg/l** |
| | | |
| | | |

5. បង្កើតរបាយការណ៍ត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុល) ទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូង

## របាយការណ៍ត្រួតពិនិត្យទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូង (បែបបទ)

1. អគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង

1) អគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង

| ឈ្មោះអគារ | កាលបរិច្ឆេទនៃការអនុញ្ញាត | ប្រភេទនៃម៉ាស៊ីនសំខាន់ៗ រចនាសម្ព័ន្ធ និងសមត្ថភាព | វិធីនៃការចំរាញ់ | ផ្សេងៗ |
|---|---|---|---|---|

| | និងរាយការណ៍ | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

2） ចំនុចបញ្ហានិងស្ថានភាពគ្រប់គ្រងដំណើរការអគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង

| ឈ្មោះអគារចំរាញ់ | ចំនុចបញ្ហានិងស្ថានភាពគ្រប់គ្រងដំណើរការ |
|---|---|
| | |
| | |

2. លទ្ធផលជាក់ស្តែងនៃការចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង

| ខែ ឆ្នាំ | ឈ្មោះ អគារ ចំរាញ់ | បរិមាណ ទឹកចំរាញ់ ($m^3$/min) | ប្រភេទ នៃសារ ធាតុគីមី | បរិមាណប្រើថ្នាំ (t／ខែ) | បរិមាណសារ ធាតុកករង (t／ខែ) | ផ្សេ ងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |

3. លទ្ធផលស្រាវជ្រាវគុណភាពទឹកទាក់ទងទឹកកខ្វក់និងទឹកក្នុងរូង

1） កាលបរិច្ឆេទនៃការយកសំណាក់ : 2） អាកាសធាតុ :

3） លទ្ធផលនៃការវិភាគគុណភាពទឹក

| No. | ឈ្មោះទីកន្លែងយកសំណាក | បរិមាណធារទឹក m³/min | pH | កំដៅទឹកស្ថានភាពល្អក់ | ទូរលេខនៃការវាស់ (mg/ℓ) | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Cu | Pb | Zn | Cd | | | | |
| | | | | | | | | | | | | |

4． ស្ថានភាពកើតឡើងបញ្ហាបំពុលបរិដ្ឋានទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូង

| កាលបរិច្ឆេទនៃការកើតឡើង | ទីកន្លែងកើតឡើង | ខ្លឹមសារបញ្ហាបំពុលបរិដ្ឋាន ស្ថានភាពរងគ្រោះថ្នាក់ |
|---|---|---|
| | | |
| | | |

5 ． យោបល់និងការវាយតំលៃលទ្ធផលស្រាវជ្រាវទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូងរបស់មន្ត្រីអធិការកិច្ច

| |
|---|
| |

6． ឯកសារឧបសម្ព័ន្ធ

a) ផែនទីនៃទីតាំងយកសំណាកទឹកសំរាប់ស្រាវជ្រាវគុណភាពទឹក

b) ផែនទីនៃប្រព័ន្ធចំរាញ់ទាក់ទងនឹងទឹកកខ្វក់និងទឹកក្នុងរូង

c) រូបភាព

《ការពន្យល់》

1． ករណីសរសេរលើផែនទីចំពោះទីតាំងយកសំណាកសំរាប់ស្រាវជ្រាវគុណភាពទឹក

(○ជាសញ្ញាចំនុចយកសំណាក់ទឹក)




2. វិធីវាស់បរិមាណធារទឹក និងការកំណត់ជ្រើសរើសចំនុចយកទឹកនៅក្នុងទន្លេ

(1) ចំនុចយកទឹក

1) ចំនុចមុនហូរចូលដោយទឹកដែលត្រូវបានបញ្ចេញពីការដ្ឋានរ៉ែ (ផ្នែកធារទឹកខាងលើ)

2) ចំនុចបានប្រសព្វគ្រប់គ្រាន់ ក្រោយពីបានហូរចូលទៅក្នុងទន្លេដោយការបង្ហូរចេញមកពីការដ្ឋានរ៉ែ (ផ្នែកធារទឹកខាងក្រោម)

3) ចំនុចយកទឹកប្រើ ក្នុងនាមជាប្រភពទឹកសំរាប់ធារាសាស្រ្ត ឬប្រភពទឹកបរិភោគ

(2) វិធីនៃការយកទឹក

1) ចំនុចយកទឹក ជាគោលការណ៍យកពីផ្ទៃទឹកចោលទៅក្នុងទឹក ប្រមាណ 20%ពីផ្ទៃទឹក។

2) ចាំបាច់ត្រូវការប្រើបរិក្ខារសំរាប់ដាក់ទឹក ក៏ប៉ុន្តែ ដោយឆ្លើយតបនឹងបរិមាណធារទឹកទន្លេ ស្ថានភាពបរិដ្ឋាននានា អាចយកទឹកនោះដោយប្រើធុងជ័រ។ល។បាន។

(2) វិធីវាស់បរិមាណធារទឹកនៃទឹកទន្លេ

1) ជ្រើសរើសចំនុចដែលទឹកទន្លេហូរយឺត ដូចនឹងរូបភាពមានដូចខាងក្រោម រកល្បឿនធារទឹក និងផ្ទៃមុខកាត់នៃការបែងចែកជាផ្នែកពីទន្លេ និងគណនាតំលៃ។

$$Q = \Sigma An \times Vn = A1\,V1 + A2\,V2 + \cdots + AnVn \quad (m3/min)$$

២）វិធីវាស់ល្បឿនធារទឹក

**a)** ករណីមានជំរៅលើពី 1 m វិធី២ចំនុច two points methodតាមរយៈនាឡិកាវាស់ធារទឹក (ជ្រើសរើសយកលេខមធ្យមនៃល្បឿនធារទឹកនៅចំនុចមានជំរៅ８０%និង ក្នុងជំរៅ２０% ពីផ្ទៃទឹក។

**b)** ករណីជំរៅទឹកមានក្រោម 1 m វិធីមួយចំនុច one points methodតាមរយៈនាឡិកាវាស់ធារទឹក (ជ្រើសរើសយកល្បឿនធារទឹកនៅទីតាំងមានជំរៅ６０%ពីផ្ទៃទឹក។

３） ករណីមានជំរៅរាកពេក សូមជ្រៀសរើសយក២ចំនុចដែលមានទឹកយឺតហើយមានសភាពស្ងប់ស្ងាត់ល្អ ធ្វើការគណនាផ្ទៃក្រឡាមុខកាត់នៃទឹកន្លែងនីមួយៗ។

បន្ទាប់មក វាស់គណនាពេលវេលាពីឈើដែលអណ្តែតហូរពីធារទឹកខាងលើ ដល់ចំនុចធារទឹកខាងក្រោម គណនាបរិមាណធារទឹកដែលមានដូចខាងក្រោម។ (ករណីពិបាកវាស់តាមរយៈការគណនាបរិមាណធារទឹក)

លើសពីនេះ ចំពោះការវាស់ឈើអណ្តែត ធ្វើការសំរបសំរួលដោយមានមេគុណ１． 2 សំរាប់សំរបសំរួលល្បឿនខុសគ្នានៃទីតាំងមានជំរៅ６０%នឹងផ្ទៃទឹកទន្លេ ។

$$Q = 1/2\,(S1 + S2) \times D \times 1.2 \times 60/T \quad (m3/min)$$

ក៏ប៉ុន្តែ **S1:** ផ្ទៃមុខកាត់ទន្លេនៃធារទឹកខាងលើ **(m2)**

**S2:** ផ្ទៃមុខកាត់ទន្លេនៃធារទឹកខាងក្រោម **(m2)**

**D:** គំលាតរវាង **S1** នឹង **S2 (m)**

**T :** ពេលវេលាវាស់ឈើអណ្តែតហូរ **(sec)**

(ឧបសម្ព័ន្ធ – 3)

# ជំពូក៥ ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹងសំឡេងថ្លង់

25 July 2016

1. ការរៀបចំយកទៅជាមួយមុននឹងអនុវត្តការត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)
ក្នុងការអនុវត្តត្រួតពិនិត្យទូទៅទាក់ទងនឹងទឹកកខ្វក់ឬទឹកនៅក្នុងរូង សំភារៈចាំបាច់ត្រូវយកទៅជាមួយរបស់ដែលមានដូចខាងក្រោមដោយសំរបសំរួលចាំបាច់តាមស្ថានភាពការដ្ឋាននីមួយៗរួមទាំងបរិក្ខារដែលបានរាយរាប់នៅក្នុង「ជំពូកទី១ ចំនុច2.(2)ស្តីពីបរិក្ខារដែលត្រូវយកទៅជាមួយក្នុងពេលធ្វើការត្រួតពិនិត្យទូទៅ」។

1) បរិក្ខារវាស់កំរិតសំឡេងថ្លង់
2) level recorder ឬdata recorder (ករណីចាំបាច់)
3) ក្រដាស់សំរាប់កត់ត្រា
4) បរិក្ខារវាស់កំដៅ
5) បរិក្ខារវាស់ល្បឿនខ្យល់

2. ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹងសំឡេងថ្លង់

(1) ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) នៅការដ្ឋានរ៉ែ

មន្ត្រីអធិការកិច្ច ប្ញកររួមទាំងនៅក្នុង「ជំពូក២ 1. អនុវត្តការត្រួតពិនិត្យ (ទប់ស្កាត់ការបំពុលបរិដ្ឋាន)ទូទៅនៅក្នុងការិយាល័យរ៉ែ」ទាក់ទងនឹងសំឡេងថ្លង់របស់ការដ្ឋានរ៉ែនោះ សាកសួរពីអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព តាមចំនុចដែលមានដូចខាងក្រោម ដោយធ្វើការបញ្ជាក់តើមានឬមិនមានឧបសគ្គលើការទប់ស្កាត់បញ្ហាបំពុលបរិដ្ឋានរ៉ែដែរឬទេ ស្តីពីចំនុចត្រូវបានសន្និដ្ឋានមានភាពមិនប្រក្រតីលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអចំពោះអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាព។
ព្រមទាំងសាកសួរចំនុចដែលមានដូចខាងក្រោម។

1) ចំពោះ「បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព」របស់ការដ្ឋានរ៉ែ តើមានបានកំណត់ដូចចំនុចដែលមានដូចខាងក្រោមដែរឬទេ។
   a) ទាក់ទងនឹងការគ្រប់គ្រងអគារទប់ស្កាត់សំឡេងថ្លង់ និងអគារបង្កើតសំឡេងថ្លង់។
   b) ទាក់ទងនឹងការវាស់កំរិតសំឡេងថ្លង់។
   c) ទាក់ទងនឹងចាត់វិធានការនៅពេលអាចនឹងកើតឡើង ឬកើតឡើងនូវការបំពុល តាមរយៈសំឡេងថ្លង់ ដោយសារការខូចបរិក្ខារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូង បាក់បែក គ្រោះថ្នាក់ផ្សេងៗកើតឡើង ដូចជាការដាច់ចរន្តអគ្គិសនី ឬ ភ្លៀងធ្លាក់ខ្លាំង ឬតាមមូលហេតុពិសេសផ្សេងទៀត ។

２）ការដ្ឋានរ៉ែដែលត្រូវបានកំណត់សំឡេងថ្លង់ តើមានសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដាបានកំណត់នៅក្បែរព្រំប្រទល់ដែលតំឡើងនៅខាងក្រៅរូងបង្កើតសំឡេងថ្លង់ ដែរឬទេ?

3）នៅការដ្ឋានរ៉ែត្រូវបានកំហិតសំឡេងថ្លង់ ស្តីពីអគារបង្កើតសំឡេងថ្លង់ឬអគារទប់ស្កាត់សំឡេងថ្លង់ តើមានចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ចំពោះករណីមានគ្រោះថ្នាក់ ឬចាត់វិធានការទប់ទល់នឹងចំពោះគ្រោះថ្នាក់នោះ ជាបន្ទាន់ នៅពេលមានកើតឡើងនូវសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់កំណត់ ឬអាចនឹងកើតឡើង ដែរឬទេ?

4）ការដ្ឋានរ៉ែដែលត្រូវបានកំណត់សំឡេងថ្លង់ នៅពេលរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ទទួលស្គាល់ថាមានភាពចាំបាច់ ករណីត្រូវបានបញ្ជាត្រូវតែចាត់វិធានការសមរម្យសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន តាមរយៈសំឡេងថ្លង់ តើមានបានគោរពតាមចំនុចដែលបានបញ្ជាទាំងនោះដែរឬទេ?

5）អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែដែលបានកំណត់សំឡេងថ្លង់ ដើម្បីទប់ស្កាត់ការបំពុលដោយសារសំឡេងថ្លង់ តើមានគោរពតាមចំនុចដែលមានដូចខាងក្រោមដែរឬទេ?

a) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារបង្កើតសំឡេងថ្លង់ និងអគារទប់ស្កាត់សំឡេងថ្លង់ និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

b) ស្តីពីសំឡេងថ្លង់ចេញពីអគារបង្កើតសំឡេងថ្លង់ ធ្វើការវាស់ជាប្រចាំនូវទំហំសំឡេងថ្លង់នៅក្បែរព្រំប្រទល់ផ្នែកខាងក្រៅរូង និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

c) នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬកើតមាននូវការបំពុលតាមរយៈសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដាបានកំណត់សំរាប់សំឡេងថ្លង់ ចាំបាច់ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

6）នៅពេលបានបញ្ចប់ការងារសាងសង់ជួសជុល និងខ្លឹមសារនៃវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និងស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬកើតមាននូវការបំពុលតាមរយៈសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដាបានកំណត់សំរាប់សំឡេងថ្លង់ ស្តីពីខ្លឹមសារទាំងនោះ តើមានបានរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែដែរឬទេ?

（2）ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) ទាក់ទងនឹងសំឡេងថ្លង់នៅអគារនៃការដ្ឋានរ៉ែនិងទីកន្លែងធ្វើការ

មន្ត្រីអធិការកិច្ច បូករួមទាំង「ជំពូក២ 2. ការអនុវត្តត្រួតពិនិត្យទូទៅ (ទប់ស្កាត់ការបំពុលបរិដ្ឋាន) នៅទីកន្លែងធ្វើការងារនិងអគាររបស់ការដ្ឋានរ៉ែ」 ដែលមានទាំងលើ ស្តីពីចំនុចខាងក្រោម ធ្វើការបញ្ជាក់នៅទីកន្លែងធ្វើការនិងនៅតាមអគាររបស់ការដ្ឋានរ៉ែ តើមានបញ្ហាឬមិនមានបញ្ហាក្នុងការទប់ស្កាត់ការកើតឡើងនូវបញ្ហាបំពុលបរិដ្ឋានទាក់ទងនឹងសំឡេងថ្លង់ ស្តីពីចំនុចត្រូវបានសន្និដ្ឋានបញ្ជាក់ថាមានភាពមិនសមរម្យលើផ្នែកសុវត្ថិភាព ធ្វើការណែនាំកែលំអដល់អ្នកគ្រប់គ្រងសុវត្ថិភាព។

1）តើស្ថានភាពគ្រប់គ្រងអគារទប់ស្កាត់សំឡេងថ្លង់ និងអគារបង្កើតសំឡេងថ្លង់របស់ការដ្ឋានរ៉ែ

ដែលត្រូវបានកំណត់សំឡេងថ្លង់ មានភាពល្អប្រសើរដែរឬទេ?

២）នៅក្បែរព្រំប្រទល់នៃការដ្ឋានរ៉ែដែលត្រូវបានកំណត់សំឡេងថ្លង់ ចំពោះសំឡេងថ្លង់មានទំហំធំ កើតចេញពីអគារបង្កើតសំឡេងថ្លង់ តើសំឡេងទាំងនោះត្រូវនឹងស្តង់កំណត់ដែរឬទេ?

a) ម៉ាស៊ីនបែងចែក ម៉ាស៊ីនខាត (រ៉ែ) ម៉ាស៊ីនបំបែកប្រើសំរាប់ថ្មរ៉ែ ឬថ្មសំណង់ដែលមានកំឡាំងលើសពី７．５Ｋｗ។

b) ម៉ាស៊ីនបញ្ជូនខ្យល់ ឬម៉ាស៊ីនបូមខ្យល់ដែលមានកំឡាំងម៉ូទ័រលើសពី７．５Ｋｗ។

３）តើមានការរិះគន់ពីប្រជាពលរដ្ឋនៅក្បែរការដ្ឋានរ៉ែ ពីបញ្ហាសំឡេងថ្លង់ដែរឬទេ? បើមានការរិះគន់ស្តីពីសំឡេងថ្លង់ ស្តីពីស្ថានភាពឆ្លើយតបរបស់ការដ្ឋានរ៉ែ និងខ្លឹមសារនៃការរិះគន់នោះ ចាំបាច់ត្រូវធ្វើការវាស់ឡើងវិញទាក់ទងនឹងសំឡេងថ្លង់ទាំងនោះ។

## ３．វាយតំលៃនិងវាស់កំរិតសំឡេងថ្លង់

### （１）ការពន្យល់និងការអោយនិយមន័យពាក្យបច្ចេកទេសទាក់ទងនឹងសំឡេងថ្លង់

#### １）កំរិតសំឡេងសំពាធទាប (Lp)

នៅផ្នែកសំឡេងថ្លង់ រលកសំឡេងខ្លាំងខ្សោយ(សំពាធសំឡេង)ត្រូវបានប្រើជាខ្នាតសំរាប់វាស់、P (Pa)គឺជាទូរលេខជាក់ស្តែងនៃសំពាធសំឡេងនៅពេលតែមួយផ្លែត និង $P_0$ (Pa)គឺជាខ្នាតសំពាធសំឡេងស្តង់ដា、វិធីគណនាកំរិតសំពាធសំឡេង$L_P$ (dB)ដែលមានដូចខាងក្រោម។ ខ្នាតតំណាងអោយ (dB) ។

ស្តីពីសំពាធសំឡេងស្តង់ដានៅក្នុងខ្យល់ ប្រើ( 20μPa)ដែលជាសំពាធសំឡេងស្តាប់បានអប្បរិមារបស់មនុស្ស។

$$L_P = 10 \log_{10} P^2／P_0^2 = 20 \log_{10} P／P_0 = 20 \log_{10} P／2\times10^{-5}$$

ស្តីពីវិធីរកសំពាធសំឡេងបូករួមជាមួយនឹងមានប្រភពសំឡេងច្រើន សំពាធនៃប្រភពសំឡេង

កំរិតមាន $L_1, L_2, \cdots\cdots L_n$ (dB)、

$$L_1 = 10 \log_{10} P_1^2／P_0^2、L_2 = 10 \log_{10} P_2^2／P_0^2 \cdots\cdots L_n = 10 \log_{10} P_n^2／P_0^2$$

តាមរូបមន្តខាងលើ នៅពេលសរសេរជាអនុគមន៍អិចស្ប៉ូតង់ស្យែល、

$$P_1^2／P_0^2 = 10^{L1/10}, P_2^2／P_0^2 = 10^{L2/10} \cdots\cdots P_n^2／P_0^2 = 10^{Ln/10}$$

ដូច្នេះ、កំរិតសំពាធសំឡេងត្រូវបានបូកបញ្ចូលគ្នា ត្រូវគណនាដូចសមីការ（１）ខាងក្រោម។

$$L_P = 10 \log_{10}\{ (P_1^2 + P_2^2 + \cdots P_n^2)／P_0^2\} = 10\log_{10}\{ 10^{L1/10}+10^{L2/10}+\cdots$$

$10^{Ln/10}\}$ …… （1）

លើសពីនេះ、ស្តីពីវិធីរកនូវទូរលេខមធ្យម (ទូរលេខកំឡាំងមធ្យម) របស់កំរិតសំពាធសំឡេងច្រើន、កំរិតសំពាធសំឡេងនៃប្រភពសំឡេងគឺតំណាងដោយ$L_1$, $L_2$, ……$L_n$ (dB)、ទូរលេខមធ្យមនៃចំនួនបូកសរុបគឺ$Lp_{(av)}$ 、ខាងក្រោមគឺរូបមន្តគណនា（2）៖

$$Lp_{(av)} = 10 \log_{10}\{1/n \cdot (P_1^2 + P_2^2 + \cdots P_n^2) / P_0^2\}$$
$$= Lp - 10 \log_{10} n \quad \cdots\cdots (2)$$

ឧទាហរណ៍ ករណីរកកំរិតសំពាធសំឡេងដែលត្រូវបានបូកបញ្ចូលប្រើតាមវិធី（1）ដែលមានការគណនាដូចខាងក្រោម៖

a) កំរិតសំពាធសំឡេង、ករណីមាន６０dB និង７０dB

កំរិតសំឡេងបូកផ្សំគឺ

$$L_P = 10 \log_{10}\{10^{L1/10}+10^{L2/10}\} = 10 \log_{10}(10^{60/10} + 10^{70/10})$$
$$= 10 \log_{10} 10^6 (1 + 10) = 10 \log_{10} 10^6 + 10 \log_{10} 11 = 60 + 10.4 = 70.4 \text{ dB}$$

b) មានការប្រើក្នុងករណីអនុវត្តជួយសំឡេងនៃសំឡេងខ្មៅ (dark noise)、ឧទាហរណ៍កំរិតសំពាធសំឡេង ករណីមាន90dB និងសំឡេងខ្មៅ (dark noise) 85dB ចំពោះកំរិតសំពាធសំឡេងបានជួយសំឡេងខ្មៅ (dark noise) គឺ៖

$L_P$ = 90 − ▲2 = 88 dB (ដោយសារសំឡេងខ្មៅមានតែក្រោម10dB ជួយសំឡេងខ្មៅដោយប្រើតារាងផ្សេងទៀត។)

c) ចំពោះករណីរកលេខកំឡាំងមធ្យមនៃកំរិតសំពាធសំឡេងច្រើន ធ្វើការគណនាដូចខាងក្រោម ដោយប្រើរូបមន្តទី（2）។

កំរិតសំពាធសំឡេងមាន、ឧទាហរណ៍ ករណីមាន L1=７０dB、L2=８０dB、L3=９０dB、L4=１００dB、ចំពោះទូរលេខកំឡាំងមធ្យមនៃកំរិតសំពាធសំឡេងនោះគឺ

$$Lp_{(av)} = 10 \log_{10}\{1/n \cdot (10^{L1/10}+10^{L2/10}+10^{L3/10}+10^{L4/10})\} = 10 \log_{10}\{1/4 \cdot (10^{70/10}+10^{80/10}+10^{90/10}+10^{100/10})\}$$
$$= 10 \log_{10}\{10^7 + 10^8 + 10^9 + 10^{10}\} - 10 \log_{10} 4 = 10 \log_{10} 10^{80}(10^{-1}+1+10+10^2) - 10 \log_{10} 4$$
$$= 10 \log_{10} 10^{80} + \log_{10} 101 - 10 \log_{10} 4 = 94.4 \text{ dB}$$

２）កំរិតសំឡេងថ្លង់ ($L_A$)

កំរិតសំពាធសំឡេងគឺមានការបង្ហាញពីការជួយជាលក្ខណៈពិសេសAជាសំពាធសំឡេងជាខ្នាតមានទំហំជាសំឡេងពិត។ មាន១០ដងប្រើតាមលោការីតដែលបានយកចេញស្វ័យគុណ២ចេញនៃសំពាធសំឡេងពីសេសAទាំងនោះគេហៅថាកំរិតសំពាធសំឡេងAមានលក្ខណៈពិសេស។ ខ្នាតគិតជា ឌីស៊ីប៉េល (dB) ។

ក្នុងនាមជាទូរលេខAជំនួយមានលក្ខណៈពិសេស  គឺមាន４ ０ dB、ស្តង់ដាកំរិតសំពាធសំឡេងគឺ 1 kHz（0 dB）។ ក្នុងនាមជាសំពាធសំឡេងស្តង់ដា គឺប្រើ(20μPa)សំពាធសំឡេងអាចស្តាប់បានអតិប្បរិមារបស់មនុស្ស។

$$L_A = 10 \log_{10} P^2／P_0^2 = 20 \log_{10} P／P_0 = 20 \log_{10} P／2\times10^{-5}$$

３）កំរិតសំឡេងស្មើគ្នា( $L_{Aeq}$ ) equivalent sound level

ដែលហៅថាកំរិតសំឡេងស្មើ  ស្តីពីទំហំម៉ោងមាន  មានបង្ហាញជាទូរលេខមធ្យមពីថាមពលរបស់កំរិតសំឡេងថ្លង់ប្រែប្រួល។   ចំពោះកំរិតសំឡេងថ្លង់ស្មើគ្នានៅក្នុងទំហំមានរយៈពេលប្រែប្រួលបែបជាពេលវេលា ទំហំពេលវាលានៃសំឡេងថ្លង់នោះ : Tស្វ័យគុណ២ជាមធ្យមនៃសំពាធសំឡេង   នឹងត្រូវចំពោះសំឡេងថ្លង់នៃសំឡេងមានជាធម្មតារបស់សំពាធសំឡេងជាមធ្យមស្វ័យគុណ២។ ខ្នាតគិតជាឌីស៊ីប៉េល（dB）។

ចំពោះកំរិតសំឡេងថ្លង់ស្មើគ្នា ក្នុងបរិដ្ឋានទូទៅ ត្រូវបានគេយកវាយតំលៃសំរាប់សំឡេងថ្លង់បរិដ្ឋានការងារ។ល។ ស្តីពីវិធីគណនាសំឡេង「កំរិតសំឡេងថ្លង់ស្មើគ្នា」ប្រើកំរិតសំឡេងថ្លង់ត្រូវបានវាស់ គណនារកដោយប្រើតាមរូបមន្តមានដូចខាងក្រោម៖

$$L_{Aeq,T} = 10 \log_{10}\{1／t_2 - t_1 \cdot \int P_A^2(t) / P_0^2\, dt\}$$
$$= 10 \log_{10}\{1／n\,[10^{LA1/10} + 10^{LA2/10} + \cdots 10^{LAn/10}]\}$$
$$= 10 \log_{10}\{[10^{LA1/10} + 10^{LA2/10} + \cdots 10^{LAn/10}]\} - 10 \log_{10} n$$

ក៏ប៉ុន្តែ、 $P_A(t)$ : សំពាធសំឡេងត្រូវបានភ្ជាប់ផ្ទួនគ្នាដោយភាពពិសេសA

$P_0$ : សំពាធសំឡេងស្តង់ដា＝ ２０μPa

$t_1$ : ម៉ោងចាប់ផ្តើមការវាស់

$t_2$ : ម៉ោងចប់ការវាស់

T : ម៉ោងវាស់ជាក់ស្តែង（$t_2 - t_1$）

n : ចំនួនសរុបនៃទូរលេខវាស់

$L_{A1}, L_{A2}, \cdots L_{An}$ : ទូរលេខវាស់របស់កំរិតសំឡេងទាប



4 ) កំរិតសំឡេងថ្លង់អត្រាតាមម៉ោង percentile noise level ( $L_{AN,T}$ )

ជាបរិមាណសំរាប់វាយតំលៃសំឡេងថ្លង់ប្រែប្រួល ដែលត្រូវបានគេប្រើតាំងពីយូរលង់មកហើយ។ ក៏ប៉ុន្តែ បច្ចុប្បន្នកាលត្រូវបានគេប្រើកំរិតសំឡេងថ្លង់ស្មើគ្នា វាមានប្រសិទ្ធិភាពចំពោះការវាយតំលៃនូវស្ថានភាពរប៉ាតរប៉ាយនៃកំរិតសំឡេងថ្លង់ប្រែប្រួល។

កំរិតសំឡេងថ្លង់ ទំហំពេលវេលាដែលនឹងត្រូវធ្វើ : ករណីលើសពីកំរិតនៅក្នុងកំឡុងពេលម៉ោងN%នៃT កំរិតនោះ គេហៅថា「កំរិតសំឡេងអត្រាម៉ោងNជាភាគរយ (%)」។ ឧទាហរណ៍ ចំពោះ「កំរិតសំឡេងថ្លង់អត្រាម៉ោង ៥ ០ %」គឺតំលៃកណ្តាល ($L_{A50}$)、ចំពោះ「កំរិតសំឡេងថ្លង់អត្រាម៉ោង ៥ %」គឺ ៩ ០ %នៃទូរលេខទំហំខាងលើ ($L_{A5}$)、「កំរិតសំឡេងថ្លង់អត្រាម៉ោង ៩ ៥ %」 គឺ ៩ ០ %ទូរលេខទំហំខាងក្រោម ($L_{A95}$) ។ ឯកតាគិតជាឌីស៊ីប៉ែល (dB) ។

ករណីរកកំរិតសំឡេងថ្លង់អត្រាម៉ោងជាក់ស្តែង រកកំរិតសំឡេថ្លង់អត្រាម៉ោងនៃកន្លែងកំណត់ថេរជាកន្លែងយកកំរិតសំឡេងគំរូនៅតាមគំលាតថេរក្នុងម៉ោងថេរ $\Delta t$ ។ វិធីបំលែងទិន្នន័យ រកទូរលេខរាយបាយមានផ្ទុកច្រើនពីលេខយកជាគំរូ ជាធម្មតា កំរិតសំឡេងថ្លង់អត្រាម៉ោង x %នឹងទៅជា (１００－x) %។

ក្នុងវិធីវាស់កំរិតសំឡេងអត្រាម៉ោង ជាទូទៅ ប្រើវិធី៥០ដងនៃគំលាតម៉ោង៥វិនាទីម្តង(ត្រូវនឹង $\Delta t$) ។




5 ) កំរិតសំឡេងថ្លង់អតិបរិមា ( $L_{A, Fmax}$ )

គឺគេហៅថាជាទូរលេខអតិបរិមានៃសំឡេងថ្លង់ដែលត្រូវបានវាស់នៅតាមការកើតឡើងនូវសំឡេងថ្លង់នីមួយៗ។ឯកតាគិតជាឌីស៊ីប៉ែល ( dB ) ។ សូមមើលឯកសារឧបសម្ព័ន្ធ*indecator*សំរាប់ក្តាប់នូវមូលហេតុប្រែប្រួលនៃ $L_{Aeq}$ : កំរិតសំឡេងថ្លង់ស្មើតាមរយៈការលាយឡំសំឡេងថ្លង់ដែលមិនចង់ត្រូវការវាស់។

6 ) កំរិតសំឡេងថ្លង់អប្បរិមា ( $L_{A,Fmin}$ )

គឺគេហៅថាជាទូរលេខអតិប្បរិមានៃសំឡេងថ្លង់ដែលត្រូវបានវាស់នៅតាមការកើត

ឡើងនូវសំឡេងថ្លង់នីមួយៗ។ឯកតាគិតជាឌីស៊ីប៉ែល （ dB ）។សូមមើលឯកសារឧបសម្ព័ន្ធ*indecator*សំរាប់ក្តាប់នូវមូលហេតុប្រែប្រួលនូវសំឡេងថ្លង់ខ្មៅ។

7）សំឡេងថ្លង់ខ្មៅ

សំឡេងថ្លង់ខ្មៅ គឺជាសំឡេងបានមកពីប្រភពសំឡេងក្រៅពីសំឡេងដែលបង្កើតដោយអគារបង្កើតសំឡេងដែលជាគោលបំណងសំរាប់ការវាស់សំឡេង។

ចំពោះកំរិតសំពាធសំឡេងបានវាស់សំឡេងថ្លង់នៅក្នុងស្ថានភាពដំណើរការអគារបង្កើតសំឡេងថ្លង់ ជាទូរលេខបានបូករួមលាយឡំនឹងសំឡេងថ្លង់ពីអគារបង្កើតសំឡេងថ្លងដូចគ្នា។

ដូច្នេះ ដែលហៅថាការជួយសំឡេងថ្លង់ខ្មៅ គឺការគណនានូវកំរិតសំពាធសំឡេងបានដកចេញពីឥទ្ធិពលនៃសំឡេងថ្លង់ខ្មៅពីទូរលេខថេរនៃសំឡេងថ្លង់។

8）រយៈកំឡុងម៉ោងស្តង់ដា

មានរយៈពេលម៉ោងស្តង់ដាប្រើសំរាប់ជាទូរលេខតំណាំងនូវកំរិតសំឡេងថ្លង់ស្មើគ្នាចំពោះ「ស្តង់ដាបរិដ្ឋានទាក់ទងនឹងសំឡេងថ្លង់」ត្រូវបានគេកំណត់យក ពេលថ្ងៃគឺ（6：00～22：00）និងពេលយប់（22：00～6：00）។

9）ម៉ោងពិនិត្យនិងវាស់

មានម៉ោងសំរាប់ជាឯកតាឬជាគោលការណ៏វាស់នូវកំរិតសំឡេងថ្លង់ ជាការកំណត់ម៉ោងទុកចោលក្នុងភាពថេរណាមួយនៃស្ថានភាពថ្លង់។ ក្នុងបែបបទនេះ គឺកំណត់យករយៈពេល១ម៉ោងសំរាប់ជារយៈពេលពិនិត្យនិងវាស់។

10）រយៈពេលវាស់ជាក់ស្តែង

គឺជារយៈពេលវាស់សំឡេងជាក់ស្តែងនៅក្នុងពេលម៉ោងពិនិត្យនិងវាស់។ ក្នុងបែបបទនេះ គឺកំណត់យករយៈពេល១០នាទីជារយៈពេលវាស់ជាក់ស្តែង។

11）ភាពពិសេសជំនួយសំរាប់ចំនួនរលកសំឡេង（ស៊ៀគ្វី）

មានភាពពិសេសជំនួយសំរាប់ចំនួនរលកសំឡេង（ស៊ៀគ្វី）ត្រូវបានគេបញ្ចូលទៅក្នុងបរិក្ខារវាស់សំឡេង ដោយមានការកំណត់ពីភាពចាប់បានផ្សេងៗតាមរយៈចំនួនរលកសំឡេង ដែលមនុស្សអាចលឺបាន។ ក្នុងការវាស់កំរិតសំឡេងថ្លង់ ប្រើ「ភាពពិសេសA」។

12）ភាពពិសេសត្រួតម៉ោងគ្នា

មានភាពពិសេសត្រួតម៉ោងគ្នា សំរាប់រកលេខប្រសិទ្ធិភាពជាក់ស្តែងនៃសំពាធសំឡេងដែលត្រូវបានប្រើនៅlevel recorder និងបរិក្ខារវាស់សំឡេង ភាពរហ័សនៃការរៀសរបស់ទ្រនិចវាស់ ត្រូវបានគេហៅថា 「ភាពពិសេសនៃចលនាកំរើក」។ ត្រូវបានគេប្រើជា២ មួយគឺ ភាពពិសេសF（Fast）នៃភាពពិសេសកំរើកលឿននិង ភាព

ពិសេស S (Slow) នៃភាពពិសេសកំរើកយឺត។

(2) វិធីវាស់កំរិតសំឡេងថ្លង់

1) ទីតាំងវាស់និងចំនុចវាស់

ស្តីពីចំនុចធ្វើការវាស់កំរិតសំឡេងថ្លង់ គឺត្រូវស្ថិតនៅលើព្រំប្រទល់ការដ្ឋានរ៉ែដែលជាចំនុចមានគំលាតខ្លីបំផុតជាមួយនឹងតំបន់លំនៅដ្ឋានដែលមានការរិះគន់ពីសំឡេងថ្លង់ពីប្រជាជន ឬអគារត្រូវបានផ្តល់ប្រើជាលំនៅដ្ឋានដែលគិតថាអាចរងនូវឥទ្ធិពលពីអគារកើតសំឡេងថ្លង់។

2) កំពស់នៃទីតាំងធ្វើការវាស់

ស្តីពីកំពស់ម៉ាក្រូហ្វូនរបស់បរិក្ខារវាស់សំឡេងថ្លង់ ចំពោះការវាស់កំរិតសំឡេងថ្លង់ធម្មតា ស្តីពីកំពស់របស់ម៉ាក្រូហ្វូន គឺត្រូវស្ថិតនៅកំពស់ 1. 2 mពីផ្ទៃដី។ ក៏ប៉ុន្តែបច្ចុប្បន្នកាល បើមានកំពស់នៃផ្ទៃជីវភាពរបស់អគារដែលត្រូវបានផ្តល់ប្រើសំរាប់លំនៅដ្ឋានដែលអាចគិតថានឹងរងទទួលឥទ្ធិពលសំឡេងថ្លង់ បានគឺល្អ។

3) បរិក្ខារវាស់

បរិក្ខារវាស់សំឡេងថ្លង់ ដូចជាបរិក្ខារសំឡេងថ្លង់ធម្មតា បរិក្ខារវាស់សំឡេងមានភាពសុក្រឹត ឬក្នុងបណ្តាបរិក្ខារវាស់ផ្សេងៗ។ល។ នៅជប៉ុនបរិក្ខារវាស់ទាំងឡាយនោះត្រូវតែជាបរិក្ខារជាប់ការធ្វើតេស្តត្រូវនឹងលក្ខខណ្ឌនៃច្បាប់រង្វាស់ Measurement Law ។

4) ម៉ោងត្រួតពិនិត្យការវាស់ និង ម៉ោងប្រសិទ្ធិភាព

ម៉ោងវាស់នៃកំរិតសំឡេងថ្លង់ ជាគោលការណ៍គឺគិតជាឯកតា១ម៉ោង ចំពោះម៉ោងប្រសិទ្ធិភាពវិញ ជាគោលការណ៍គឺអោយលើសពីរយៈពេល១០នាទី គឺត្រូវរកកំរិតសំឡេងថ្លង់ស្មើគ្នា $L_{Aeq}$ នៅក្នុងតំបន់ម៉ោងស្តង់ដា។

ជាលក្ខណៈលំអិត បែងចែកម៉ោងប្រសិទ្ធិភាពនៅក្នុងម៉ោងវាស់ ដោយរក $L_{Aeq}$ នៃគ្រប់ការបែងចែកតំបន់នីមួយៗ ក្រោយវាស់ $L_{Amax}$ ៊ ធ្វើការសន្និដ្ឋានចាប់ពី $L_{A5}$ លើកលែងនូវការបែងចែកម៉ោងប្រសិទ្ធិភាពដែលត្រូវបានវាស់ពីការវាស់មានភាពមិនប្រក្រតី ធ្វើមធ្យមភាគថាមពលនៃតំលៃវាស់ដែលនៅសល់ រក $L_{Aeq}$ កំរិតសំឡេងស្មើគ្នានៅម៉ោងវាស់នោះ។

ស្តីពីសំឡេងថ្លង់ខ្លាំងតាមរយៈស្ថានភាពដំណើរការការដ្ឋានរ៉ែ ដោយសារមានភាពខុសគ្នាតាមម៉ោងបង្កើតសំឡេងទាំងនោះ អនុវត្តជ្រើសរើសកំណត់នូវម៉ោងវាស់ដោយឆ្លើយតបនឹងស្ថានភាពរបស់ការដ្ឋានរ៉ែ។

ឧទាហរណ៏ ម៉ោងថ្ងៃជាតំបន់ម៉ោងស្តង់ដារបស់ជប៉ុនគឺ (6:00～22:00) និងម៉ោងយប់គឺ (22:00～6:00) ដែលត្រូវបានគេកំណត់យក។ ក៏ប៉ុន្តែ

ម៉ោងថ្ងៃជាកំឡុងម៉ោងវាស់ត្រូវបានគិតពីស្ថានភាពដំណើរការអគារបង្កើតសំឡេងនៃការដ្ឋានរ៉ែ គឺចាប់ពីម៉ោង៧ព្រឹក ដល់ម៉ោង១២ មានក្នុងរយៈពេល៥ម៉ោងនេះ អនុវត្តនូវម៉ោងប្រសិទ្ធិភាពអោយបាន៥ដងដែលនៅក្នុង១ម៉ោងឯកតាអោយបានលើសពី ១០នាទី ចំពោះម៉ោងយប់គឺចាប់ពីម៉ោង២២ ដល់៣ព្រឹក ក្នុងរយៈពេល៥ម៉ោងនេះ គឺអនុវត្តនូវម៉ោងប្រសិទ្ធិភាពអោយបាន៥ដង ដោយអោយបានលើសពី១០នាទីក្នុង១ម៉ោងឯកតា ទាំងអស់នេះហៅថាវិធីជ្រើសរើសសំរាប់អនុវត្ត។

5) ការបំលែងសំឡេងដែលត្រូវតែយកចេញ

a) ករណីត្រួតពិនិត្យជាប្រចាំ

ករណីធ្វើការវាស់កំរិតសំឡេងថ្លង់ត្រួតពិនិត្យជាប្រចាំដោយអ្នកវាស់ ក្រោយពីបានបញ្ជាក់នូវសំឡេងដែលត្រូវយកចេញរួច ចុចកុងតាក់(Pause)ជាបន្ទាន់បញ្ឈប់ការវាស់ ក្រោយពីបានយកសំឡេងថ្លង់ចេញរួច សូមចុចកុងតាក់(Start)ឡើងវិញដើម្បីដំណើរការវាស់ឡើងវិញ។

b) ករណីការវាស់ដោយគ្មានអ្នកនៅប្រចាំការ ឬគ្មានអ្នកត្រួតពិនិត្យ

ក្រោយពីវាស់រួច នៅក្នុងដំណើរការបំលែងទិន្នន័យ ធ្វើអោយថាមពលនៃលេខវាស់ដែលនៅសល់បានយកចេញចំពោះការបែងចែកម៉ោងប្រសិទ្ធិភាពដែលត្រូវបានវាស់ ដោយលេខវាស់មានភាពមិនប្រក្រតីពីទំហំធំបំផុត ($L_{A5}$) មានវិធីរក「កំរិតសំឡេងថ្លង់ស្មើគ្នា $L_{Aeq}$」នៃម៉ោងវាស់នោះ។

6) លក្ខខណ្ឌបរិដ្ឋាននៃម៉ោងវាស់កំរិតសំឡេងថ្លង់

លក្ខខណ្ឌអាកាសធាតុនៅពេលវាស់កំរិតសំឡេងថ្លង់ សូមផ្អាកការវាស់នៅពេលមានភ្លៀងធ្លាក់។

លើសពីនេះ ក្នុងករណីមានខ្យល់មានល្បឿនលើសពី 1 m/sec សូមភ្ជាប់គំរងពីលើម៉ាក្រូហ្វូន។ ក៏ប៉ុន្តែ បើភ្ជាប់គំរងពីលើហើយនៅមានសំឡេងផ្សេងៗលាយឡំ ឬសំឡេងខ្យល់នៅជាមួយដដែល សូមធ្វើផ្អាកការវាស់។

នៅពេលបានភ្ជាប់គំរងខ្យល់លើម៉ាក្រូហ្វូន វាអាចធ្វើអោយរងឥទ្ធិពលនៅសល់តិច ធ្លាក់នៅសល់ត្រឹម 5 m/sec ។

(3) វិធីវាយតំលៃសំឡេងថ្លង់តាមរយៈកំរិតសំឡេងថ្លង់អត្រាម៉ោង

នៅក្នុងការវាយតំលៃសំឡេងថ្លង់ ស្តីពីការកំណត់ទំហំនោះ មានដូចខាងក្រោម៖

1) ករណី មានឃើញទូរលេខពីម៉ាស៊ីនវាស់សំឡេងថ្លង់មិនប្រែប្រួល ឬ មានភាពប្រែប្រួលតិច គឺកំណត់យកលេខនោះតែម្តង។

2) លេខបង្ហាញដោយម៉ាស៊ីនវាស់ ក្នុងករណី មានជាចង្វាក់ ឬផ្លាស់ប្តូរតាមពេលខ្លះ ដែលមានលេខធំចេញមក គឺកំណត់យកលេខមធ្យមនោះជាលេខអតិបរិមានៃការបង្ហាញ

ប្រែប្រួលនោះ។

3) ករណីប្រែប្រួលក្នុងទំហំ និងមិនមានភាពពិតប្រាកដថេរទេ ចេញពីម៉ាស៊ីនវាស់ គឺកំណត់យកទំហំនៃលេខវាស់ខ្ពស់បំផុតគឺ９０%។

4) ករណីមិនមានភាពថេរ ដែលជាលេខធំបានបង្ហាញនោះ ដោយសារមិនភាពជាចង្វាក់ ឬមិនប្រាកដ គឺកំណត់ទំហំនៃលេខបង្ហាញនោះគឺ９０%ក្នុងការផ្លាស់ម្តងៗ

1) ករណីមិនមានប្រែប្រួលច្រើនពីលេខដែលបានបង្ហាញដោយម៉ាស៊ីនសំឡេងថ្លង់




4) លេខបង្ហាញមានការប្រែប្រួលមិនបានល្អ ឬជាចហ្វាក់ ករណីមិនថេរគឺកំណត់យកលេខអតិបរមា

2) ករណីប្រែប្រួលដោយបាត់ខ្លះ ឬមានជាចង្វាក់




3) ករណីលេខមានភាពប្រែប្រួលធំនិងមិនមានភាពដូចគ្នា

## (4) ស្តង់ដាទាក់ទងនឹងកំណត់សំឡេងថ្លង់

### 1) ទូរលេខស្តង់ដាកំណត់សំឡេងថ្លង់បានកំណត់ដោយក្រសួងបរិដ្ឋានកម្ពុជា

| | ６：００～１８：００ | １８：００～２２：００ | ２２：００～６：００ |
|---|---|---|---|
| តំបន់ស្ងាត់ | 45dB | 40dB | 35dB |
| តំបន់លំនៅដ្ឋាន | 60dB | 50dB | 45dB |

| | | | |
|---|---|---|---|
| តំបន់អាជីវកម្ម | 70dB | 65dB | 50dB |
| តំបន់លំនៅដ្ឋាន និងតំបន់ឧស្សាហកម្មខ្នាតតូច | 75dB | 70dB | 50dB |

2) ស្តង់ដាទូរលេខទាក់ទងនឹងការកំហិតសំឡេងថ្លង់នៅរោងចក្រកំណត់ពិសេស។ល។នៃការដ្ឋានវ៉ែជប៉ុន។ល។

| | ពេលថ្ងៃត្រង់ | ព្រឹក・ល្ងាច | ពេលយប់ |
|---|---|---|---|
| តំបន់ប្រភេទទី១ | 45dB ～ 50dB | 40dB ～ 45dB | 40dB ～ 45dB |
| តំបន់ប្រភេទទី២ | 50dB ～ 60dB | 45dB ～ 50dB | 40dB ～ 50dB |
| តំបន់ប្រភេទទី៣ | 60dB ～ 65dB | 55dB ～ 65dB | 50dB ～ 55dB |
| តំបន់ប្រភេទទី៤ | 65dB ～ 70dB | 60dB ～ 70dB | 55dB ～ 60dB |

ឯកសារជំនួយ) (1) ទំហំនៃម៉ោងប្រសិទ្ធិភាព និងម៉ោងវាស់

1) ម៉ោងថ្ងៃ គឺចាត់ទុកថា ចាប់ពីម៉ោង៧ព្រឹកឬម៉ោង៨ព្រឹក ដល់ម៉ោង៦ល្ងាច ម៉ោង៧ល្ងាច ឬម៉ោង៨ល្ងាច។

2) ម៉ោងព្រឹក គឺចាត់ទុកថា ចាប់ពីព្រឹកម៉ោង៥ ឬម៉ោង៦ ដល់ ម៉ោង៧ព្រឹក ឬដល់ម៉ោង៨ព្រឹក។ ម៉ោងល្ងាចគឺចាត់ទុកថា ចាប់ពីល្ងាចម៉ោង៦ ម៉ោង៧ល្ងាច ឬម៉ោង៨ល្ងាច ដល់ម៉ោង៩យប់ ម៉ោង១០យប់ ឬម៉ោង១១យប់។

3) ម៉ោងយប់ គឺចាត់ទុកថា ចាប់ពីម៉ោង៩យប់ ម៉ោង១០យប់ ឬម៉ោង១១យប់ រហូតដល់ម៉ោងព្រឹកថ្ងៃបន្ទាប់ ម៉ោង៥ព្រឹកឬម៉ោង៦ព្រឹក។

(2)ចំពោះការវាស់កំរិតសំឡេងថ្លង់ ត្រូវប្រើបរិក្ខារវាស់សំឡេងថ្លង់ណាដែលជាប់តេស្តត្រូវនឹងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់រង្វាស់។ ក្នុងករណីនេះប្រើភាពពិសេសAចំពោះស្មៀគ្នីជំនួយចំនួនរលកប្រេកង់ ចំពោះភាពពិសេសនៃចលនា ប្រើភាពពិសេសចលនារហ័ស(Fast)។

（3） ស្តីពី「ការបែងចែកតំបន់នៃតារាងខាងលើ」មានដូចខាងក្រោមៈ

1）ចំពោះតំបន់ប្រភេទទី១ ដើម្បីរក្សាការពារបរិដ្ឋានល្អនៃលំនៅដ្ឋាន ជាពិសេស និយាយពីតំបន់ដែលត្រូវការចាំបាច់។

2）ចំពោះតំបន់ប្រភេទទី២ ដោយសារត្រូវបានផ្តល់សំរាប់ជាលំនៅដ្ឋាន គឺជាតំបន់ចាំបាច់រក្សាអោយបានភាពស្ងាត់ល្អ។

3）ចំពោះតំបន់ប្រភេទទី៣ ជាតំបន់ពាណិជ្ជកម្មរួមជាមួយប្រើជាលំដ្ឋានផង មានតំបន់ត្រូវបានគេផ្តល់ប្រើជារោងចក្រ។ល។ ជាតំបន់ត្រូវការទប់ស្កាត់ការកើតសំឡេងថ្លង់ដើម្បីរក្សាបាននូវបរិដ្ឋានជីវភាពរស់នៅនៅក្នុងតំបន់នោះ។

4）ចំពោះតំបន់ប្រភេទទី៤ ជាតំបន់ប្រើសំរាប់តែរោងចក្រ។ល។ ដើម្បីកុំអោយមានភាពអាក្រក់ដល់បរិដ្ឋានរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះ គឺជាតំបន់ត្រូវការចាំបាច់ទប់ស្កាត់ភាពថ្លង់ខ្លាំង។

（4） ជំនួយសំឡេងថ្លង់ខ្មៅ

កំរិតសំពាធសំឡេងបានវាស់សំឡេងថ្លង់ដោយស្ថានភាពកំពុងដំណើរការអគារបង្កើតសំឡេង មានទូរលេខលាយឡំគ្នារវាងសំឡេងថ្លង់ខ្មៅនិងសំឡេងថ្លង់ពីអគារបង្កើតនោះ ។

ដូច្នេះ ដែលហៅថាជំនួយសំឡេងថ្លង់ខ្មៅ គឺការគណនានូវកំរិតសំពាធសំឡេងដោយដកចេញពីការជះឥទ្ធិពលរបស់សំឡេងថ្លង់ខ្មៅពីទូរលេខវាស់សំឡេងថ្លង់។

ជូនចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

ស្ដីពីប្រាក់សន្សំសំរាប់ទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែនៃឆ្នាំYYYY、អនុលោមតាមកថាខណ្ឌ១មាត្រា២២នៃច្បាប់និងកថាខណ្ឌ៤និងកថាខណ្ឌ៣មាត្រា៥០នៃបទបញ្ញតិ សូមរាយការណ៏នូវខ្លឹមសារពីប្រាក់បង់រំលួសសន្សំសំរាប់ទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែដូចមានខាងក្រោម៖

| **រាយការណ៏នូវខ្លឹមសារពីប្រាក់បង់រំលួសសន្សំសំរាប់ទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែ** | |
|---|---|
| ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) | |
| លេខតំបន់រ៉ែ | |
| អស័យដ្ឋាននៃការដ្ឋានរ៉ែ(ទូរស័ព្ទ) | |
| ឈ្មោះម្ចាស់អាជីវកម្មរ៉ែ | |
| អគារជាគោលដៅនៃការចាត់វិធានការទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែ<br>1) ឈ្មោះនិងប្រភេទនៃអគារ<br>2) អស័យដ្ឋាន | |
| ចំនួនទឹកប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែដែលបានផ្តល់ជាដំណឹងដោយរដ្ឋមន្ត្រីដែលបានគណនារួច | |
| ខ្លឹមសារពីប្រាក់បង់រំលួសនៃប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែ<br>1) ចំនួនដងនៃការបង់រំលួស<br>2) ចំនួនទឹកប្រាក់សន្សំនៃការបង់រាល់លើក<br>3) ចំនួនទឹកប្រាក់សន្សំនៃការបង់រាល់លើក×ចំនួនលើកនៃការបង់រំលួស=ចំនួនទឹកប្រាក់សរុប | |
| ហេតុផលបង់ប្រាក់រំលួសនៃប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែ | |

អ្នកដាក់ពាក្យសុំ : ឈ្មោះម្ចាស់អាជីវកម្មរ៉ែ signature

មាត្រា១៣ ស្ដីពី「បែបបទសុំទាក់ទងនឹងការដកប្រាក់បង់រំលួសប្រាក់សន្សំសំរាប់ទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ」អនុលោមតាមការកំណត់របស់កថាខណ្ឌ៣មាត្រា២២នៃច្បាប់និងកថាខណ្ឌ១មាត្រា៥២នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

1. ម្ចាស់អាជីវកម្មរ៉ែ នៅពេលចង់ដកប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ យោងតាមពាក្យគំរូលេខ១១ ចាំបាច់ត្រូវតែដាក់ពាក្យរាយការណ៍ជូនដល់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

ពាក្យគំរូលេខ12

ថ្ងៃ ខែ ឆ្នាំ

ជូនចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

ស្ដីពីប្រាក់សន្សំសំរាប់ទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ、អនុលោមតាមកថាខណ្ឌ៣មាត្រា២២នៃច្បាប់និងកថាខណ្ឌ១និងកថាខណ្ឌ៣មាត្រា៥២នៃបទបញ្ញត្តិ សូមរាយការណ៍បញ្ជាក់ពីការចង់ដកប្រាក់ទាំងនោះដែលមានខ្លឹមសារដូចខាងក្រោម៖

| **ពាក្យសុំបញ្ជាក់ពីការសុំដកប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ** | |
|---|---|
| ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) | |
| លេខតំបន់រ៉ែ | |
| អស័យដ្ឋាននៃការដ្ឋានរ៉ែ(ទូរស័ព្ទ) | |
| ឈ្មោះម្ចាស់អាជីវកម្មរ៉ែ | |
| អគារជាគោលដៅនៃការចាត់វិធានការទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ<br>1) ឈ្មោះនិងប្រភេទនៃអគារ<br>2) អស័យដ្ឋាន | |
| ចំនួនទឹកប្រាក់សរុបនៃប្រាក់សន្សំទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ ទាក់ទងនឹងអគារដែលជាគោលដៅនៃវិធានការទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែ | |
| ការរៀបរាប់លំអិតនៃថវិការចំណាយទាំងនោះនិងខ្លឹមសារនៃការងារទប់ស្កាត់ការបំពុលដោយសាររអាជីវកម្មរ៉ែដែលចង់ដកប្រាក់មកវិញ | |

អ្នកដាក់ពាក្យសុំ : ឈ្មោះម្ចាស់អាជីវកម្មរ៉ែ signature

មាត្រា១៤ ស្តីពី「បែបបទដាក់ជូននិងបង្កើតរបាយការណ៍ទាក់ទងនឹងគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា២៩នៃច្បាប់និងកថាខណ្ឌ២មាត្រា៥៤នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

1. ម្ចាស់អាជីវកម្មរ៉ែ ស្តីពីស្ថានភាពនៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែដែលបានកើតឡើង យោងតាមពាក្យគំរូលេខ១២ ត្រូវរាយការណ៍ដល់អគ្គនាយកទទួលបន្ទុកវិស័យរ៉ែ ក្នុងរយៈពេល៣០ថ្ងៃ ដោយគិតពីថ្ងៃកើតហេតុ ។

ពាក្យគំរូលេខ13

ថ្ងៃ ខែ ឆ្នាំ

ជូនចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

ស្តីពីស្ថានភាពនៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែដែលបានកើតឡើង、អនុលោមតាមកថាខណ្ឌ១មាត្រា២៩នៃច្បាប់និងកថាខណ្ឌ២មាត្រា៥៤នៃបទបញ្ញត្តិ សូមរាយការណ៍ដែលមានខ្លឹមសារដូចខាងក្រោម៖

| **របាយការណ៍នៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយ** | |
|---|---|
| 1. ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) | |
| 2. អស័យដ្ឋាននៃការដ្ឋានរ៉ែ(ទូរស័ព្ទ) | |
| 3. ឈ្មោះម្ចាស់អាជីវកម្មរ៉ែ | |
| 4. ឈ្មោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម | |
| 5. កាលបរិច្ឆេទនៃគ្រោះថ្នាក់និងគ្រោះមហន្តរាយ | |
| 6. ខ្លឹមសារនៃគ្រោះថ្នាក់ឬគ្រោះមហន្តរាយ (ប្រភេទ) | |
| 7. ទីកន្លែងកើតនូវគ្រោះថ្នាក់ឬគ្រោះមហន្តរាយនៅក្នុងការដ្ឋានរ៉ែ | |
| 8. ឈ្មោះជនរងគ្រោះ អាយុ មុខងារ កំរិតនៃការរងគ្រោះ និងកាលបរិច្ឆេទនៃការយកមកធ្វើការ | |
| 9. ស្ថានភាពនៃគ្រោះថ្នាក់ ឬគ្រោះមហន្តរាយនៅក្នុងការដ្ឋានរ៉ែ និងមូលហេតុទាំងនោះ | |
| 10. ខ្លឹមសារនៃការចាត់ចែងតប់ទល់នឹងគ្រោះថ្នាក់ ឬគ្រោះមហន្តរាយនៅក្នុងការដ្ឋានរ៉ែដោយអ្នកគ្រប់គ្រងសុវត្ថិភាពរួមឬដោយអ្នកគ្រប់គ្រងការងារ | |
| 11. ការចាត់ចែងតប់ទល់នឹងគ្រោះថ្នាក់ ឬគ្រោះមហន្តរាយនៅក្នុងការដ្ឋានរ៉ែដោយម្ចាស់អាជីវកម្មរ៉ែ និងវិធានការសំរាប់ថ្ងៃអនាគត | |
| 12. ខ្លឹមសារនៃការចាត់ចែងតប់ទល់ចំពោះអ្នករងគ្រោះដោយម្ចាស់ | |

| | |
|---|---|
| អាជីវកម្មរ៉ែ | |
| ឯកសារឧបសម្ព័ន្ធ | ផែនទីពន្យល់នៅពេលកើតគ្រោះថ្នាក់ ឬគ្រោះមហន្តរាយនៅក្នុងការដ្ឋានរ៉ែ |

អ្នកដាក់ពាក្យសុំ : ឈ្មោះម្ចាស់អាជីវកម្មរ៉ែ signature

មាត្រា១៥ ស្តីពី「បែបបទដាក់ជូននិងបង្កើតរបាយការណ៍ប្រចាំខែពីសុវត្ថិភាពរបស់ការដ្ឋានរ៉ែ」អនុលោមតាមការកំណត់របស់កថាខណ្ឌ២មាត្រា២៩នៃច្បាប់និងមាត្រា៥៥នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

1. ម្ចាស់អាជីវកម្មរ៉ែ ស្តីពីការបង្កើត「របាយការណ៍ប្រចាំខែពីសុវត្ថិភាពរបស់ការដ្ឋានរ៉ែ」ទាក់ទងនឹង ស្ថានភាពនៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែដែលបានកើតឡើង និងស្ថានភាពសុវត្ថិភាពនៃទីកន្លែងជីកយករ៉ែ យោងតាមពាក្យគំរូលេខ១៣ ត្រូវរាយការណ៍ដល់អគ្គនាយកទទួលបន្ទុកវិស័យរ៉ែ ក្នុងចុងខែនីមួយៗ ហើយយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់។

ពាក្យគំរូលេខ14

ថ្ងៃ ខែ ឆ្នាំ

ជូនចំពោះរដ្ឋមន្រ្តីទទួលបន្ទុកវិស័យរ៉ែ

ស្តីពីរបាយការណ៍ប្រចាំខែពីសុវត្ថិភាពរបស់ការដ្ឋានរ៉ែ ៊ អនុលោមតាមកថាខណ្ឌ២មាត្រា២៩នៃច្បាប់និងមាត្រា៥៥នៃបទបញ្ញត្តិ សូមរាយការណ៍ដែលមានខ្លឹមសារដូចខាងក្រោម៖

| **របាយការណ៍ប្រចាំខែពីសុវត្ថិភាពរបស់ការដ្ឋានរ៉ែ** | |
|---|---|
| 1. ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) | |
| 2. អស័យដ្ឋាននៃការដ្ឋានរ៉ែ(ទូរស័ព្ទ) | |
| 3. ឈ្មោះម្ចាស់អាជីវកម្មរ៉ែ | |
| 4. ឈ្មោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម | |

| 5. ចំនួនកម្មកររ៉ែ | ក្រៅរូង | ក្នុងរូង | សរុប |
|---|---|---|---|
| 1) ចំនួនអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងចំនួនអ្នកគ្រប់គ្រងការងារ | | | |
| 2) ចំនួនកម្មកររ៉ែ | | | |
| 3) ចំនួនអ្នកទទួលធ្វើការងារបន្ត | | | |

| | |
|---|---|
| ៦. ចំនួនទីកន្លែងការងារជីកយករ៉ែ<br>និងចំនួនទីកន្លែងខួងរុលទៅមុខ | |
| ១) ចំនួនទីកន្លែងការងារជីកយករ៉ែ | ក្នុងរូង ទីកន្លែង、ក្រៅរូង ទីកន្លែង |
| ២) ចំនួនទីកន្លែងខួងរុលទៅមុខ | ក្នុងរូង ទីកន្លែង |

| | |
|---|---|
| ៧. ស្ថានភាពផលិត | |
| បរិមាណផលិតរ៉ែដើម | **ton/M** |

៨. ស្ថានភាពនៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ (កត់ត្រាដោយឡែកស្តីពីស្ថានភាពកើតឡើងកាលពីខែមុន។)

| ថ្ងៃខែម៉ោងពេលកើតគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ | ខ្លឹមសារនៃគ្រោះថ្នាក់និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ | ចំនួនជនរងគ្រោះ、កំរិតនៃការរងគ្រោះ | ខ្លឹមសារសំខាន់ៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

សំគាល់) ស្តីពី「កំរិតនៃការរងគ្រោះ」នៃស្ថានភាពគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែមានកំណត់ប្រើដូចខាងក្រោម៖

១) កំរិត「ស្រាល」គឺជនរងគ្រោះប្រើរយៈពេលព្យាបាលអស់ក្រោម៣ថ្ងៃ

២) កំរិត「មធ្យម」គឺជនរងគ្រោះប្រើរយៈពេលព្យាបាលអស់ចាប់ពី៣ថ្ងៃដល់ក្រោម១៤ថ្ងៃ

៣) កំរិត「ធ្ងន់」គឺជនរងគ្រោះប្រើរយៈពេលព្យាបាលអស់ចាប់ពី១៤ថ្ងៃឡើងទៅ

អ្នកដាក់ពាក្យសុំ : ឈ្មោះម្ចាស់អាជីវកម្មរ៉ែ **signature**

មាត្រា១៦ ស្តីពី「សញ្ញាប្រើក្នុងផែនទីសុវត្ថភាពការដ្ឋានរ៉ែ」អនុលោមតាមការកំណត់របស់កថាខណ្ឌ១ មាត្រា៣០នៃច្បាប់និងកថាខណ្ឌ២មាត្រា៥៦នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

១. ក្នុងការបង្កើតផែនទីសុវត្ថភាពការដ្ឋានរ៉ែ ស្តីពី សញ្ញាដែលកំណត់ប្រើនៅការដ្ឋានរ៉ែ មានដូចនៅក្នុង「ឯកសារឧបសម្ព័ន្ធ-២ 」ដែលមានដូចខាងក្រោម៖

២. ក្នុងករណីមិនត្រូវនឹសញ្ញដែលបានកំណត់ជាសញ្ញាសំរាប់ការដ្ឋានរ៉ែ អាចប្រើសញ្ញាដែលអាចបង្ហាញនូចំនុចសាមញ្ញនិងងាយស្រួលយល់បាន។

មាត្រា១៧ ស្តីពី「ស្តង់ដារចនាសម្ព័ន្ធរបស់គ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្ត」「ការកំហិតប្រើប្រេងឥន្ធនៈដែលមិនត្រូវនឹងស្តង់នៃការបញ្ចេញឧស្ម័ន និងការកំហិតប្រើគ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្តដែលបានបញ្ចេញឧស្ម័នមិនត្រូវនឹងស្តង់ដានៃការបញ្ចេញ」អនុលោមតាមការ

កំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់និងកថាខណ្ឌ១និងកថាខណ្ឌ២មាត្រា១១៣នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

1. ស្តីពីស្តង់ដារចនាសម្ព័ន្ធរបស់គ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្តប្រើនៅក្នុងការដ្ឋានរ៉ែលោហៈនិងធ្យូងថ្ម មានដូចមាននៅក្នុង「ឯកសារឧបសម្ព័ន្ធ-៣ : ស្តង់ដារចនាសម្ព័ន្ធរបស់គ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្ត」។

2 . ស្តីពីស្តង់ដារនៃការបញ្ចេញឧស្ម័នរបស់ការបញ្ចេញឧស្ម័ននៃគ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្តប្រើនៅក្នុងការដ្ឋានរ៉ែលោហៈនិងធ្យូងថ្ម នៅក្នុងស្ថានភាពពុំមានសកម្មភាពដឹក ចាំបាច់ត្រូវអោយឧស្ម័នដែលត្រូវបានបញ្ចេញមាននៅក្រោម០．０６%នៃឧស្ម័នកាបូនិច CO ដោយគិតយក បរិមាណមាឌនៃ COគុណនឹងលេខ１．３５５។

ស្តង់ដាបញ្ចេញនៃឧស្ម័ន ＝ CO（មាឌ）×1.355＜０．０６%

ការវាស់ឧស្ម័ន CO វិធីវាស់គឺអោយត្រូវនឹងស្តង់ដានៃ「វិធីវាស់វិភាគ CO ដែលមាននៅក្នុងឧស្ម័នបញ្ចេញចោល」ស្តង់ឧស្សាហកម្មជប៉ុនＪＩＳ Ｋ００９８ឬត្រូវធ្វើតាមរយៈវិធីណាមួយមានប្រសិទ្ធិភាពដែលអោយលើសពីវិធីមុន។

3. ស្តង់ដាប្រើប្រេងឥន្ទនៈដោយគ្រឿងចក្រការដ្ឋានរ៉ែបែបយានឬរថយន្តប្រើនៅក្នុងការដ្ឋានរ៉ែលោហៈនិងធ្យូងថ្ម គឺអោយត្រូវនឹងស្តង់ដានៃប្រេងម៉ាស៊ូតនៃស្តង់ឧស្សាហកម្មជប៉ុនＪＩＳ Ｋ２２０４ដែលមានស្តង់ទាំងនោះដូចខាងក្រោម៖

ស្តង់ឧស្សាហកម្មជប៉ុនＪＩＳប្រេងម៉ាស៊ូត

| ចំនុចឆេះ（℃） | cetane index | កំដៅចេញ９０%（℃） | បរិមាណសារធាតុស៊ុលផួរ（%） |
|---|---|---|---|
| លើសពី45～50 | លើសពី45～50 | ក្រោមពី330～360 | ក្រោមពីបរិមាណ 0.01% |

មាត្រា១៨ ស្តីពី「ការគណនាអត្រាសុវត្ថិភាពនៃខ្សែកាបនិងបរិក្ខារលោហៈសំរាប់ភ្ជាប់នឹងបរិក្ខារខារទាញរទេះដឹកមនុស្ស ឬបរិក្ខារខារក្នុងរូងបញ្ឈរសំរាប់លើកដាក់មនុស្សចុះឡើង」អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់និងកថាខណ្ឌ២មាត្រា១៣១នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

ស្តីពីវិធីគណនាអត្រាសុវត្ថិភាពនៃខ្សែកាបនិងបរិក្ខារលោហៈសំរាប់ភ្ជាប់នឹងបរិក្ខារខារទាញរទេះដឹកមនុស្ស ឬបរិក្ខារខារក្នុងរូងបញ្ឈរសំរាប់លើកដាក់មនុស្សចុះឡើង មានរូបមន្តដូចខាងក្រោម៖

$$F_1 = \frac{Sr}{W} \quad \cdots\cdots\cdots\cdots\cdots\cdots\cdots\cdots\cdots (1)$$

$$F_2 = \frac{Sr}{W + W\frac{a}{g} + E \times A \times \frac{d}{D}} \quad \cdots\cdots (2)$$

$F_1$ ; អត្រាសុវត្ថិភាពចំពោះបន្ទុកអតិបរិមា (លើសពី１０)

$F_2$ ; អត្រាសុវត្ថិភាពចំពោះបន្ទុកអតិបរិមាសរុប (លើសពី５)

Sr ; កំឡាំងបំបែកធានាដោយមានការបង្ហាញពីអ្នកផលិតខ្សែកាប(kilo Newton)

W ; ក្នុងនាមជាThe biggest dead load(គីឡូក្រាម)、ចំពោះរូងជំរេល ត្រូវគណនាយោងតាមរូបមន្តគណនាដែលមានក្រោម។

$$W = W_t \sin\theta + \alpha \cdot W_t \cos\theta + W_r \sin\theta' + \beta \cdot W_r \cos\theta' \quad \cdots\cdots\cdots\cdots (3)$$

$W_t$ ; បរិមាណទំងន់ធំសរុបរបស់ទូររទេះ(តោន)

$W_r$ ; Wគឺជាបរិមាណទំងន់របស់ខ្សែកាបនៃទីតាំងដែលនឹងមានធំបំផុត(តោន)

$\theta$ ; Wគឺជាមុំជំរេលនៃទីតាំងធំបំផុត

$\theta'$ ; Wគឺជាមុំជំរេលនៃមធ្យមនៃខ្សែទាំងអស់របស់ទីតាំងដែលនឹងក្លាយទៅធំជាងគេ

$\alpha$ ; ចំនួនមេគុណភាពកកិតរបស់ទូរ

$\beta$ ; ចំនួនមេគុណនៃភាពកកិតរបស់ខ្សែកាប

a ; ល្បឿនបន្ថែម(m/ per second per second)

g ; ចំនួនថេរ(9.8 m/ per second per second)

E ; elastic coefficient (ចំពោះរាល់មីលីម៉ែត្រការ៉េ、ត្រូវគណនាជា９８kilo Newton)

A ; ផ្ទៃក្រឡាមុខកាត់មានប្រសិទ្ធិភាព(មីលីម៉ែត្រគូប)

d ; អង្កត់ផ្ចិតធំបំផុតនៃខ្សែកាប(មីលីម៉ែត្រ)

D ; អង្កត់ផ្ចិតតូចបំផុតនៃsheaveឬdram(មីលីម៉ែត្រ)

មាត្រា១៩ ស្តីពី「ការគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនិងបរិក្ខារលោហៈបន្ទាប់បន្សំសំរាប់តភ្ជាប់ទ្រSka Hoadនៃរូងបញ្ឈរ និងការគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនៃបរិក្ខារខារendless សំរាប់រូងទេរ ការគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនិងបរិក្ខារលោហៈបន្ទាប់បន្សំសំរាប់តភ្ជាប់ទ្រទូរដឹកមនុស្ស ឬcage នៅបរិក្ខារខារដឹកជញ្ជូនរបស់ក្រៅពីមនុស្ស」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ ព្រមទាំងកថាខណ្ឌ១ កថាខណ្ឌ២ កថាខណ្ឌ៣មាត្រា១៣២នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោម៖

1．ចំពោះវិធីគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនិងបរិក្ខារលោហៈបន្ទាប់បន្សំសំរាប់តភ្ជាប់ទ្រSka Hoadនៃរូងបញ្ឈរ និងការគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនៃបរិក្ខារខារendless សំរាប់រូងទេរ ការគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនិងបរិក្ខារលោហៈបន្ទាប់បន្សំសំរាប់តភ្ជាប់ទ្រទូរដឹកមនុស្ស ឬcage

នៅបរិក្ខារខារដឹកជញ្ជូនរបស់ក្រៅពីមនុស្ស អនុលោមតាមការកំណត់របស់កថាខណ្ឌ១ និងកថាខណ្ឌ៣ មាត្រា១៣២ នៃបទបញ្ញតិ យោងតាមរយៈរូបមន្តគណនានៃមាត្រាមុន、 គឺកំណត់ $F_1$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតមិនទាន់បានដឹក (លើសពី６)、$F_2$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតបានដឹក (លើសពី３) ។

２. ចំពោះវិធីគណនាអត្រាសុវត្ថិភាពរបស់ខ្សែកាបនៃបរិក្ខារខារendless អនុលោមតាមការកំណត់របស់កថាខណ្ឌ២មាត្រា១៣២ នៃបទបញ្ញតិ យោងតាមរយៈរូបមន្តគណនានៃមាត្រាមុន、 គឺកំណត់ $F_1$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតមិនទាន់បានដឹក (លើសពី៣)、$F_2$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតបានដឹក (លើសពី២) ។

មាត្រា២០ ស្តីពី「ការគណនាអត្រាសុវត្ថិភាពរបស់ខ្សែពាននៃខ្សែពានដឹកជញ្ជូនដឹកមនុស្ស」អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ ព្រមទាំងកថាខណ្ឌ២មាត្រា១៣៣ នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោម៖

ចំពោះការគណនាអត្រាសុវត្ថិភាពរបស់ខ្សែពាននៃខ្សែពានដឹកជញ្ជូនដឹកមនុស្ស មានរូបមន្តគណនាដូចខាងក្រោម៖

$$F_1 = S_B / F_M \times \eta_1 \times \eta_2$$
$$F_2 = S_B / (K_2 \cdot F_M \cdot T_B) \times \eta_1 \times \eta_2$$

$F_1$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតមិនទាន់បានដឹក (លើសពី１０)

$F_2$ ; ជាអត្រាសុវត្ថិភាពចំពោះទំងន់ធ្ងន់បំផុតបានដឹក (លើសពី５)

$S_B$ ; កំឡាំងបំបែកធានាដោយមានការបង្ហាញពីអ្នកផលិតខ្សែពាន (kilo Newton)

$F_M$ ; កំឡាំងយឺតអតិបរិមា (kilo Newton)

$\eta_1$ ; Coupling efficiency

$\eta_2$ ; Material factor of safety efficiency

$K_2$ ; មេគុណបន្ថែមល្បឿន (ចាត់ទុកយក１３８មកធ្វើការគណនា។)

$T_B$ ; ជាFlexural loadរបស់ខ្សែពាន (kilo Newton)、ធ្វើការគណនាតាមរយៈរូបមន្តមានដូចខាងក្រោម៖

$$T_B = E \times A \times d / D \times n$$

E ; elastic coefficient (ក្នុងរាល់ ㎜$^2$、យក９８kilo Newtonមកគណនា។)

A ; ផ្ទៃក្រឡាមុខកាត់មានប្រសិទ្ធិភាពរបស់steel cord (មីលីម៉ែត្រការ៉េ : ㎜$^2$)

d ; អង្កត់ផ្ចិតធំបំផុតនៃខ្សែកាបរបស់steel cord (មីលីម៉ែត្រ : ㎜)

D ; អង្កត់ផ្ចិតរបស់ពូលីទាក់ទាញកំឡាំងអតិបរិមា (មីលីម៉ែត្រ : ㎜)

n ; ចំនួនខ្សែនៃsteel cord (ចំនួនខ្សែ)

មាត្រា២១ ស្តីពី「វិធីវាស់នៃការចុះថយអត្រាសុវត្ថិភាពរបស់បរិក្ខារខាររូងបញ្ឈរលើកដាក់មនុស្ស」

អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ២មាត្រា១៣៧នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

１．ចំពោះស្តង់ដាបោះបង់ចោល អនុលោមតាមលទ្ធផលទាំងនោះនិងការត្រួតពិនិត្យទាក់ទងនឹងការចុះថយអត្រាសុវត្ថិភាពរបស់ខ្សែកាបមានកំណត់ដូចខាងក្រោម៖

（1）ការត្រួតពិនិត្យទាក់ទងនឹងការសរសៃខ្សែ

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ករណីចំពោះខ្សែកាបមួយដែលនៅក្នុងនោះមានសរសៃដាច់លើសពី１０%ឡើង ឬករណីមានខ្សែកាប៥មានដាច់សរសៃខ្សែលើសពី２０%ឡើង នោះខ្សែកាបនឹងត្រូវបានបោះបង់ចោល។

（2）ការវាស់ទាក់ទងនឹងភាពកកឹត

ក្នុងការវាស់ដោយប្រើmicrometer caliper ចំពោះករណីលើសពី7 %នៃ nominal diameter តាមរយៈការកកឹតដោយមានភាពចុះថយនៃអង្កត់ផ្ចិតខ្សែកាប ចំពោះខ្សែកាបនោះនឹងត្រូវបោះបង់ចោល។

គណនាគំរូ) អង្កត់ផ្ចិតខ្សែកាប∮１０mm、ចំពោះករណីលើសពី7%ដោយលទ្ធផលនៃការវាស់ប្រើmicrometer caliper។

１０mm×０．０７＝ ０．７mm

１０－０．７＝9．３mmអាចប្រើបន្តបន្ទាប់ត្រឹម9．３mmបាន

（3）ការត្រួតពិនិត្យទាក់ទងនឹងការពុកផុយ

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក、ករណីមានក្លាយទៅជាច្រេះចាប់ Form of pockmark មានការកើតឡើងនូវpitchingនៅលើផ្ទៃនៃសរសៃខ្សែកាប ករណីក្លាយជាសភាពគួចសរសៃខ្សែកាបតាមរយៈការពុកផុយនៅផ្នែកខាងក្នុងនៃខ្សែកាប ខ្សែកាបនោះនឹងត្រូវបោះបង់ចោល។

（4）ការត្រួតពិនិត្យទាក់ទងនឹងការប្រែប្រួលទ្រង់ទ្រាយដើម

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ករណីមានកើតឡើងនូវការប្រែប្រួលទ្រង់ទ្រាយដើម kink និង flattening រមូល ឬក្លាយជាជំពាក់ចូលគ្នា ខ្សែកាបនោះនឹងត្រូវបោះបង់ចោល។

2．ចំពោះស្តង់ដាបោះបង់ចោលអនុលោមតាមលទ្ធផលនោះនិងការវាស់ព្រមទាំងការត្រួតពិនិត្យទាក់ទងនឹងការថយចុះអត្រាសុវត្ថិភាពនៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ មានការកំណត់ដូចខាងក្រោម៖

（1）ការត្រួតពិនិត្យទាក់ទងនឹងការប្រែប្រួលរូបរាង

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ចំពោះករណីត្រូវបានទទួលស្គាល់ថាមានភាពរៀកបត់ រមូល ។ល។នៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

（2）ការត្រួតពិនិត្យទាក់ទងនឹងរបេកឬកំពិត

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ចំពោះករណីត្រូវបានទទួលស្គាល់ថារបេកធ្ងន់ធ្ងរ

មានការផ្លុះធ្លាយ នៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

(3) ការវាស់និងត្រួតពិនិត្យដោយភ្នែកទាក់ទងនឹងការប្រេះ

1) តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ចំពោះករណីត្រូវបានទទួលស្គាល់ថាមានភាពប្រេះស្រាំ នៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

2) តាមរយៈPenetration sounding out wound test methodចំពោះករណីត្រូវបានទទួលស្គាល់ថាមានភាពប្រេះស្រាំ នៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

3) តាមរយៈវិធីធ្វើតេស្តរកភាពប្រេះតាមរយៈម៉ាញេទិកនៃបន្ទះដែក ចំពោះករណីត្រូវបានទទួលស្គាល់ថាមានភាពប្រេះស្រាំ នៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

(4) ការវាស់ទាក់ទងនឹងការកកឹត

នៅពេលវាស់ប្រើmicrometer caliper។ល។ ករណីបាត់បង់លើសពី១០%នៃខ្នាតដែលមានស្រាប់ដោយសារការកកឹតបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់នោះ បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

(5) ការត្រួតពិនិត្យទាក់ទងនឹងការពុកផុយ

តាមរយៈការត្រួតពិនិត្យដោយមើលនឹងភ្នែក ចំពោះករណីត្រូវបានទទួលស្គាល់ថាមានភាពពុកផុយនៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ទាំងមូល បរិក្ខានោះនឹងត្រូវបានបោះបង់ចោល។

មាត្រា២២ ស្តីពី「វិធីវាស់នៃការចុះថយអត្រាសុវត្ថិភាពរបស់បរិក្ខារខាររូងជំរេលលើកដាក់មនុស្ស」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ២មាត្រា១៣៨នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម៖

1. ចំពោះស្តង់ដាបោះបង់ចោល អនុលោមតាមលទ្ធផលទាំងនោះនិងការត្រួតពិនិត្យទាក់ទងនឹងការចុះថយអត្រាសុវត្ថិភាពរបស់ខ្សែកាប ត្រូវបានយកតាមខ្លឹមសារដែលបានកំណត់ក្នុងមាត្រា២១ខាងលើ។

2. ចំពោះស្តង់ដាបោះបង់ចោលអនុលោមតាមលទ្ធផលនោះនិងការវាស់ព្រមទាំងការត្រួតពិនិត្យទាក់ទងនឹងការថយចុះអត្រាសុវត្ថិភាពនៃបរិក្ខារលោហៈបន្ទាប់បន្សំប្រើសំរាប់តភ្ជាប់ ត្រូវបានយកតាមខ្លឹមសារដែលបានកំណត់ក្នុងមាត្រា២១ខាងលើ។

មាត្រា២៣ ចំពោះ「រចនាសម្ព័ន្ធជាទូទៅទាក់ទងនឹង ការបិទផ្ចិតក្នុងករណីធ្វើការបិទផ្ចិតផ្លូងក្នុងរូងនៃទីកន្លែងមានការឆេះដោយឯកឯងឬទីកន្លែងអាចនឹងមានគ្រោះថ្នាក់ខ្លាំង」អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ៥មាត្រា១៦១នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម។


①
Select the suitable site to make sealing by natural ground condition
Pit mouth
Goaf side


Dig up the roof for install the throw in pipe
②
Dig surround of the tunnel (gallery) over 30 cm to appear the natural ground at sealing wall installing points.
Sealing wall distance between front side to goaf side is 3 ~ 5 meter

③


Install the sealing walls by pillars (round timbers) and boarding. Pillars being fixed by wedges in place.

④


Observation pipe for inside of sealing
Filling material throw in pipe
Install pipes
Water drainage pipe
Filling material: Fly ash + water or Spigot slime + cement (3~5%)

⑤




⑥




Only water is discharged through the PP filter cloth. Volume of filling material is reduced and make empty space at up side of sealing. So it need several times to re-inject filling materials.



មាត្រា២៤　ចំពោះ「ការសាងសង់និងគូសប្លង់ទាក់ទងនឹង ការងារបិទផ្ទិតច្រករូងទាំងនោះ ដើម្បីទប់ស្កាត់ការបំពុលដោយសារអាជីវកម្មរ៉ែ តាមរយៈទឹកក្នុងរូង」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ២មាត្រា១៧៦នៃបទបញ្ញត្តិ មានកំណត់ដូចខាងក្រោម។

1．វិធីនិងបច្ចេកទេសនៃការបិទផ្ទិតផ្លូវក្នុងរូង

ចំពោះវិធានការបិទផ្ទិតផ្លូវក្នុងរូង、គឺមានការគិតអនុវត្តធ្វើការបិទច្រករូងដើម្បីកុំអោយទឹកក្នុងរូងហូរចេញក្រៅ ដោយប្រើការចាក់បេ៉តុងបិទច្រករូងនៃអតីតការដ្ឋានរ៉ែបោះបង់ចោលឬផ្អាកអាជីវកម្មរ៉ែ ក៏ប៉ុន្តែបច្ចុប្បន្នកាលនេះ មានវិធីផ្សេងៗដែលគេយកមកប្រើ ដែលចែកជា៣ប្រភេទធំៗដូចមាននៅខាងក្រោម៖

1）វិធីបិទផ្ទិតផ្លូវក្នុងរូង（បិទផ្ទិតទាំងស្រុង・ប្រភេទបិទទឹក)

ជាវិធីបិទមិនអោយទឹកចេញក្រៅពីក្នុងច្រករូងទាំងស្រុងដោយគ្មានទឹកហូរចេញតែម្តង បិទរូងទាំងស្រុងដោយអោយទឹកស្ថិតនៅក្នុងរូងតាមរយៈការបិទនោះ។

2）វិធីបិទផ្ទិតផ្លូវក្នុងរូង(ប្រភេទoverflow)

ទោះបីបិទជិតរូងផ្លូងយ៉ាងណាក៏ដោយ 、មានករណីទាំងអស់ a) មិនអាចជាប្រភេទទប់ទឹកបានទាំងស្រុងទេ។ ជាធម្មតាមានផ្លូវរូងជាច្រើននៅក្នុងការដ្ឋានរ៉ែ ហើយរូងទាំងមានការឆ្លងកាត់គ្នាបានច្រើនកន្លែងទៀត ដូច្នេះទឹកដែលបានឃាត់មិនអោយចេញពីច្រកណាមួយនោះ វានឹងហូរចេញតាមច្រកផ្សេងមួយទៀតបាន ករណីបែបនេះមានច្រើន។ ចំពោះចំនុចល្អនៃវិធីបិទផ្ទិតផ្លូវក្នុងរូង(ប្រភេទ overflow) យោងតាមរយៈទឹកហូរចេញច្រើនពីក្នុងរូង ធ្វើអោយជាតិអាស៊ីតកើតឡើងថយចុះពីក្នុងជំរករ៉ែ ហើយគុណភាពទឹកនៅក្នុងរូងត្រូវបានកែលំអប្រសើរឡើង លើសពីនេះសង្ឃឹមថា តាមរយៈទឹកដែលដក់នៅក្នុងរូងមានសំពាធ ដែលជ្រាបចូលទៅក្នុងរូងមានការថយចុះ។

3）វិធីបិទផ្ទិតផ្លូវក្នុងរូងក្នុងគោលបំណងឃាត់តែខ្យល់តែប៉ុណ្ណោះ

ករណីមិនអាចតំឡើងទំបន់បិទច្រករូងបានល្អទេ និង ករណីមិនអាចបិទផ្ទិតច្រករូងដោយសារទឹកលេចចេញទៅស្រទាប់ដី មានបច្ចេកទេសដែលគេពិនិត្យនឹងយកមកប្រើ។ វិធីនេះ គឺការផ្ទុកទឹកមួយផ្នែកអោយស្ថិតនៅក្នុងរូង មានចាត់វិធានការទប់ស្កាត់ការជ្រាបចូលនៃខ្យល់ទៅក្នុងរូង ចំពោះករណីបិទផ្ទិតរូងដែលមានទំហំធំនិងមានស្ថានភាពជាផ្លាក់បិទផ្ទិត គឺវាខុសគ្នាស្រឡះ។

ទឹកហូរចេញពីក្នុងរូងតាមច្រករូងមិនអាចបញ្ឈប់បាន ក៏ប៉ុន្តែ លទ្ធផលដែលត្រូវទទួលបានគឺមិនអោយខ្យល់ចូលទៅក្នុងរូងបាន បានសេចក្តីថានៅក្នុងរូងខ្វះឧស្ម័នអុកស៊ីសែន នេះជាការព្រងឹងគុណភាពទឹកតាមរយៈការបន្ថយជាតិអាស៊ីតនៃជំរក។ តាមរយៈនេះ មានការប្រើផ្គួបគ្នានៃវិធីសង់ទាំងនោះ ក្នុងករណីចំរាញ់ទឹកក្នុងរូង ｉ）វិធីសំរបសំរួល បង្ហូរបរិមាណទឹកក្នុងរូងតាមរយៈក្បាលរូមប៊ីណេនៃផ្នែកបិទជិត、ⅱ）មានវិធីអនុវត្តតែមួយនូវការចំរាញ់ទឹកក្នុងរូងដោយបិទច្រករូងផ្សេងៗជាច្រើនទៀត អាចមានលទ្ធភាពកាត់បន្ថយថវិការចំរាញ់ទឹកក្នុងរូងតាមរយៈការប្រើផ្គុំគ្នាបែបនេះ។

| | | |
|---|---|---|
| 1) វិធីបិទផ្ទិតផ្លូវក្នុងរូង (បិទផ្ទិតទាំងស្រុង) | 2)វិធីបិទផ្ទិតផ្លូវក្នុងរូង (ប្រភេទoverflow) | 3) ឃាត់តែខ្យល់ |




2. ករណីសង់ដោយប៉េតុងសំរាប់បង្កើតផ្នុកបិទផ្ទិតរូង ក្នុងការអនុវត្តតាមវិធីបិទផ្ទិតរូង ចំពោះប្រវែងនៃផ្នុកបិទផ្ទិតរូង ជាទូទៅមានការគណនាតាមរយៈរូបមន្តដូចមានខាងក្រោម៖

$$L = \frac{PA}{\tau_a l} \times Fs$$

L : ប្រវែងនៃផ្នុកបិទផ្ទិត (m)

p : សំពាធធ្លាក់មកផ្នុកបិទផ្ទិត $(t/m^2)$

A : ផ្ទៃក្រឡាមុខកាត់នៃផ្ទៃមុខរបស់ផ្នុកបិទផ្ទិត $(m^2)$

$\tau_a$ : ភាពម៉ាំមុខកាត់នៃការទទួលសំពាធ (មានករណីធំលើសពីភាពម៉ាំនៃប៉េតុងដោយភាពម៉ាំនៃផ្ទាំងថ្មរបស់ទីកន្លែងបិទផ្ទិតគឺកំណត់យក55 $t/m^2$, មានករណីតូចគឺកំណត់យកទូរលេខរបស់ផ្ទាំងថ្មត្រូវបានទទួលតាមរយៈការធ្វើតេស្ត។ល។) $(t/m^2)$

t : ប្រវែងជុំវិញជាមធ្យមនៃផ្នុកបិទផ្ទិត (m)

F s : អត្រាសុវត្ថិភាព (យក2ជាស្តង់ដា។)



មាត្រា២៥ ចំពោះ「ការវាយតំលៃបរិយាកាសការងារឆ្លើយតបនឹងមានភាគរយ Free silicic acid នៅក្នុងធូលីនិងកំហាប់ធូលីមាននៅក្នុងខ្យល់នៃទីកន្លែងធ្វើការក្នុងរូង」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ១មាត្រា២៤៣-២នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោម។

1．ចំពោះការវាយតំលៃបរិយាកាសការងារឆ្លើយតបនឹងមានភាគរយ Free silicic acid នៅក្នុងធូលីនិងកំហាប់ធូលីមាននៅក្នុងខ្យល់នៃទីកន្លែងធ្វើការក្នុងរូង ធ្វើការវាយតំលៃបរិយាកាសការងារយោងតាមរយៈ「Ⅱ. វិធីវាយតំលៃនៃលទ្ធផលវាស់និងវិធីគណនាទូរលេខវាស់នៃកំហាប់ធូលី」 នៅក្នុង「បែបបទវាយតំលៃ វាស់កំហាប់ធូលីនៅការដ្ឋានរ៉ែ」។

មាត្រា២៦ ចំពោះ「វិធីវាស់បរិមាណនៃសារធាតុមានភាពមិនឆេះ និងវិធីយកសំណាក់ទាំងនោះ ទីកន្លែងចាំបាច់ត្រូវតែយកសំណាក់ដែលហ៊ុយធ្លាក់កកដោយធូលីធ្យូងថ្មមានភាពផ្ទុះ」 អនុលោមតាមការកំណត់របស់កថាខណ្ឌ២មាត្រា៣១នៃច្បាប់ និងកថាខណ្ឌ២មាត្រា២៦៦-៨នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោម។

1．វិធីវាស់បរិមាណនៃសារធាតុមានភាពមិនឆេះ ព្រមទាំងកាលបរិច្ឆេទ និងវិធីយកសំណាក់ទាំងនោះ ទីកន្លែងចាំបាច់ត្រូវតែយកសំណាក់បង្ហាញនូវបង្ហាញលទ្ធផលនៃរ៉ាយម្សៅថ្ម។

(1) ទីកន្លែងយកសំណាក់

ចំពោះសំណាក់ គឺជារបស់យកនៅក្នុងទីកន្លែងដែលមានដូចខាងក្រោម (កំហិតចំពោះទីកន្លែងមានធូលីធ្យូងថ្មហ៊ុយធ្លាក់កក។) ។ក៏ប៉ុន្តែ ចំពោះទីកន្លែងបានកំណត់នៅចំនុច2) និង3) បន្ទាប់ ចំពោះករណីចំនុចកំណត់4) ដែលនៅក្បែរទីកន្លែងទាំងនោះ ក៏ជាកន្លែងដែលត្រូវយកដែរ។

1) ទីកន្លែង៣នៃគំលាតចំងាយរវាងគ្នានឹងគ្នា30mចំពោះផ្នែកច្រកខ្យល់ចូលនិងផ្នែខ្យល់ចេញជាចំនុចចាប់ផ្តើមនៅក្នុងផ្នែកជ្រៅ (ឬទីកន្លែងធ្វើការខួងរុលទៅមុខ) និងផ្នែកនៃទីកន្លែងធ្វើការងារ

2) ទីកន្លែងទាំង៥ខាងលើបានកំណត់ពីគំលាតស្មើរៗគ្នានៅក្នុងប្រវែង500mនៅផ្លូវដឹកជញ្ជូនសំខាន់ៗ (លើកលែងរូងផ្លូវរាបនិងរូងបញ្ឈរ។)

3) ទីកន្លែងបានកំណត់នូវគំលាតស្មើរៗគ្នានៅក្នុងប្រវែង500mនៅផ្លូវរូងរាបដឹកជញ្ជូនសំខាន់ៗនិងផ្លូវរូងដឹកជញ្ជូនក្រៅពីផ្លូវរូងរាបដឹកជញ្ជូនសំខាន់ៗ (លើកលែងផ្លូងរូងបញ្ឈរ។)

4) ទីកន្លែងលើកដាក់ប្លាស់ប្តូរនិងច្រកលើកដាក់ធ្យូងថ្ម

5) ទីកន្លែងសំខាន់ៗផ្សេងទៀត

(2) វិធីយកសំណាក

ចំពោះសំណាក គឺជារបស់ត្រូវយកតាមវិធីមានដូចខាងក្រោម៖

1) ចំពោះសំណាក គឺយកក្នុងសភាពអោយលើសពីទំហំទទឹង20cm ស្របនឹងជុំវិញនៃផ្ទៃកាត់ទទឹងនៃផ្លូងរូង ព្រមទាំងយកពីកន្លែងកកគរនៃពិដាន និងផ្នែកជញ្ជាំង ស្តីពីបាតផ្លូវយកសំណាករហូតដល់ជំរៅ2cmនៃផ្នែកកកគរ។

2）ចំពោះសំណាក លើកលែងទីកន្លែងកំណត់ចំពោះ 1） មុន ត្រូវយកសំណាកចំពោះកន្លែងផ្សេងៗគ្នានៃផ្នែកខាងលើបាត (បាតរូងនិងត្រង់កំពស់2／3នៃកំពស់ផ្លូវរូង។ ខាងក្រោមមកទៀតក៏ដូចគ្នា) និង ផ្នែកពីដាន (ផ្នែកជញ្ជាំងមិនរួមទាំងផ្នែកខាងលើបាតនិងពិដាន។ ខាងក្រោមមកទៀតក៏ដូចគ្នា។

3）ចំពោះសំណាក ត្រូវយកតាមលំដាប់លំដោយពីកន្លែង បាតផ្លូវរូង ផ្នែកជញ្ជាំងនៃផ្នែកខាងលើជញ្ជាំងនៃផ្នែកពិដាននិងពិដាន យកពីទីកន្លែងនៅខាងក្រោមខ្យល់។ ក្នុងករណីមានខ្យលបក់ត្រូវប្រយ័ត្នធ្វើយ៉ាងណាកុំអោយមានឧបសគ្គដល់ការយកសំណាក់។

(3) ពេលវេលានៃការយកសំណាក

1）ចំពោះករណីត្រូវបានកំណត់ទីកន្លែងយកផ្សូងថ្មនៅកន្លែងថ្មី ចំពោះផ្លូវរូងមានធូលីហ៊ុយកកគរដែលជាធូលីមានភាពផ្ទុះតាមការកំណត់នោះ យកសំណាក១កន្លែងក្នុង១ខែម្តងក្រោយពីបានកំណត់ជាកន្លែងយកផ្សូងថ្ម។

2）ចំពោះទីកន្លែងផ្សេងទៀត ត្រូវយកសំណាកអោយបានលើសពី១ដងក្នុងរយៈពេល៦ខែ។

(4) វិធីវាស់បរិមាណនៃសារធាតុមិនឆេះ

ចំពោះការវាស់បរិមាណនៃសារធាតុមិនឆេះ ស្តីពីសំណាកបានឆ្លងកាត់ការរែងមានខ្នាត８４０ micron(２０mesh)កំណត់ដោយស្តង់ដាឧស្សាហកម្មជប៉ុន JIS ត្រូវអនុវត្តតាមវិធីមានដូចខាងក្រោម៖

1）ចំពោះសារធាតុទឹក ស្តីពីសំណាកបានយកពីផ្នែកផ្សូងថ្មនៅក្នុងស្រទាប់ដែលមានទូរលេខជាតិទឹកបានមកដោយការវាស់តាមរយៈបរិក្ខារវាស់ជាតិទឹក ឬវិធីវិភាគឧស្សាហកម្មកំណត់ដោយស្តង់ដាឧស្សាហកម្មជប៉ុន JIS M8811។ តាមរយៈវិធីបូករួមទាំងទូរលេខសារធាតុទឹកសំណាកមានសំណើម (មានសារធាតុទឹកស្រាប់) ដែលត្រូវបានវាស់តាមរយៈវិធីវិភាគបែបឧស្សាហកម្មកំណត់ដោយស្តង់ដាឧស្សាហកម្មជប៉ុន JIS M8812 (វិធីវិភាគចំពោះទឹកសំណាកមានសំណើម។

2）ស្តីពីសារធាតុពុំមានជាតិឆេះក្រៅពីទឹក តាមរយៈវិធីវិភាគបែបឧស្សាហកម្ម (វិធីវិភាគពីសារធាតុផេះ) កំណត់ដោយស្តង់ដាឧស្សាហកម្មជប៉ុន JIS M8812 ឬវិធីវិភាគតាមរយៈ Pit polarizing microscope ឬតាមvolume menometer។

មាត្រា២៧ ចំពោះ「ការវាយតំលៃឡើងវិញក្រោយចាត់វិធានការអនុលោមតាមការវាយតំលៃនៃបរិដ្ឋានការងារនៅទីកន្លែងធ្វើការក្រៅរូង」 អនុលោមតាមការកំណត់របស់កថាខណ្ឌ២មាត្រា២៧០-៣នៃបទបញ្ញតិ ព្រមទាំង「ការវាយតំលៃបរិដ្ឋានការងារឆ្លើយតបនឹងអត្រាមានស៊ីលីស៊ីតអាស៊ីតនៅក្នុងធូលីនិងកំហាប់ធូលមាននៅក្នុងខ្យល់នៃទីកន្លែងធ្វើការនៅក្នុងបន្ទប់ក្រៅរូង」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣១នៃច្បាប់និងអនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា២៧០-២នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោម៖

1．ធ្វើការវាយតំលៃបរិដ្ឋានការងារតាមរយៈ「Ⅱ．វិធីវាយតំលៃនៃលទ្ធផលវាស់និងវិធីគណនាទូរលេខវាស់

នៃកំហាប់ធូលី」 នៅក្នុង「បែបបទវាយតំលៃ វាស់កំហាប់ធូលីនៅការដ្ឋានរ៉ែ」 ។ ចំពោះការវាយតំលៃបរិយាកាសការងារឆ្លើយតបនឹងមានភាគរយ Free silicic acid នៅក្នុងធូលីនិងកំហាប់ធូលីមាននៅក្នុងខ្យល់នៃទីកន្លែងធ្វើការក្នុងរូង។

មាត្រា២៨ ចំពោះ「បែបទាក់ទងនឹងការចូលទៅក្នុងដីអ្នកដ៏ទៃឬប្រើប្រាស់ដីនោះក្នុងរយៈពេលខ្លី នៅពេលមានគ្រោះអសន្ន」 អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣២នៃច្បាប់និងមាត្រា២៨២នៃបទបញ្ញតិ មានកំណត់ដូចខាងក្រោមៈ

ពាក្យគំរូលេខ១៣

ថ្ងៃ ខែ ឆ្នាំ

ជូនចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

ទាក់ទងនឹងការចូលទៅក្នុងដីអ្នកដ៏ទៃឬប្រើប្រាស់ដីនោះក្នុងរយៈពេលខ្លី នៅពេលមានគ្រោះអសន្ន អនុលោមតាមការកំណត់របស់កថាខណ្ឌ១មាត្រា៣២នៃច្បាប់និងមាត្រា២៨២នៃបទបញ្ញតិ សូមដាក់ពាក្យសុំការអនុញ្ញាតដែលមានដូចខាងក្រោមៈ

| **ពាក្យសុំការអនុញ្ញាតទាក់ទងនឹងការចូលទៅក្នុងដីអ្នកដ៏ទៃឬប្រើប្រាស់ដីនោះក្នុងរយៈពេលខ្លី នៅពេលមានគ្រោះអសន្ន** | |
|---|---|
| 1. ឈ្មោះការដ្ឋានរ៉ែ (ប្រភេទរ៉ែ) | |
| 2. អស័យដ្ឋាននៃការដ្ឋានរ៉ែ(ទូរស័ព្ទ) | |
| 3. ឈ្មោះម្ចាស់អាជីវកម្មរ៉ែ | |
| 4. ឈ្មោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម | |
| 5. ចំនុចទាក់ទងនឹងដីអ្នកដ៏ទៃ<br>1) អស័យដ្ឋាននៃដីនោះ<br>2) ឈ្មោះម្ចាស់ដីនោះ | |
| 6. គោលបំណងនៃការប្រើនិងគោលបំណងចូលទៅក្នុងដីអ្នកដ៏ទៃ | |
| | |

អ្នកដាក់ពាក្យសុំ : ឈ្មោះម្ចាស់អាជីវកម្មរ៉ែ signature

**ឯកសារឧសម្ព័ន្ធ– 1）**

## បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព ការដ្ឋានវ៉ៃ ABE (ករណីគំរូ)

មាតិកា

ជំពូក១ រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព

1 – 1 ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព

ជំពូក 2 គណៈកម្មការសុវត្ថិភាព

2 – 1 វិធីជ្រើសរើសសមាជិកគណៈកម្មការ

2 – 2 កាលបរិច្ឆេទនៃការបើកកិច្ចប្រជុំ

2 – 3 ដំណើរការ

2 – 4 ចំនុចទាក់ទងនឹងការកត់ត្រានូវលទ្ធផលនៃកិច្ចពិភាក្សា

ជំពូក 3 សកម្មភាពសំរាប់ជំរុញអោយមានសុវត្ថិភាព

3 – 1 រចនាសម្ព័ន្ធនិងខ្លឹមសារនៃការអនុវត្តសកម្មភាពសំរាប់ជំរុញអោយមានសុវត្ថិភាព

3 – 2 ចំនុចទាក់ទងនឹងការកត់ត្រានូវការកត់ត្រាសំរាប់ជំរុញអោយមានសុវត្ថិភាព

ជំពូក 4 ការបណ្តុះបណ្តាលពីសុវត្ថិភាព

4 - 1 អ្នកជាគោលដៅនៃការបណ្តុះបណ្តាល、វិធីបណ្តុះបណ្តាលពីសុវត្ថិភាពនិងកំរិតនៃការបណ្តុះបណ្តាលពីសុវត្ថិភាព

4 – 2 វិធីកំរិតនៃការបណ្តុះបណ្តាលឡើងវិញម្តងទៀតពីសុវត្ថិភាព

4 – 3 ចំនុចទាក់ទងនឹងការកត់ត្រានូវពីសុវត្ថិភាព

ជំពូក 5 ការតប់ទល់នៅពេលមានគ្រោះថ្នាក់កើតឡើងនៅក្នុងការដ្ឋានវ៉ៃ

5 – 1 រចនាសម្ព័ន្ធទាក់ទងគ្នា

5 – 2 វិធីនៃការជន្លៀសខ្លួន

5 – 3 វិធីនៃជួយសង្គ្រោះជនរងគ្រោះ

5 – 4 វិធីអនុវត្តការហ្វឹកហាត់នៃការជួយសង្គ្រោះនិងការភៀសខ្លួន

5 – 5 វិធានការនៅតាមអគារឬនៅតាមទីកន្លែងធ្វើការនីមួយៗសំរាប់ត្រៀមតបទល់នឹងគ្រោះថ្នាក់កើតឡើងនៅក្នុងការដ្ឋានវ៉ៃ

ជំពូក 6 ចំនុចលំអិតសំរាប់អនុវត្តចាត់នូវវិធានការចាំបាច់ដោយម្ចាស់អាជីវកម្មរ៉ែ

6 – 1 ការប្រើគ្រឿងចក្រ ឧបករណ៍បរិក្ខារនិងឧបករណ៍ផលិតកម្ម

6 - 2 ទប់ស្កាត់គ្រោះថ្នាក់តាមរយៈថ្មលយធ្លាក់និងថ្មបាក់រលំនៅការដ្ឋានរ៉ែបើកព្រមទាំងទប់ស្កាត់ការបាក់រលំនិងបាក់ស្រុតនៅការដ្ឋានរ៉ែបិទ

6 - 3 ការប្រើប្រាស់ប្រភេទនៃរំសេវ

6 - 4 រថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត

6 – 5 ការគ្រប់គ្រងធូលីហ៊ុយ នៅក្នុងទីកន្លែងធ្វើការ និងនៅក្នុងរូង

6 – 6 ការគ្រប់គ្រងធូលីហ៊ុយនិងទីកន្លែងធ្វើការងារ ផ្លូវដើរនៅក្រៅរូង

6 - 7 ការប្រើប្រាស់សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ព្រមទាំងការបំលែងនូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព

6 - 8 ការប្រើប្រាស់ភ្លើង

6 - 9 ការចំរាញ់ទឹកក្នុងរូងឬទឹកកខ្វក់

6 — 1 0 ការគ្រប់គ្រងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង

6 — 1 1 ការគ្រប់គ្រងអគារចំរាញ់និងបង្កើតទឹកកខ្វក់ឬទឹកក្នុងរូង

6 — 1 2 ការគ្រប់គ្រងអគារបង្កើតសំឡេងថ្លង់និងអគារទប់ស្កាត់សំឡេងថ្លង់

6 — 1 3 ការគ្រប់គ្រងអគារបង្កើតភាពរំញ័រ និងអគារទប់ស្កាត់ភាពរំញ័រ

6 — 1 4 ការគ្រប់គ្រងអគារបង្កើតផ្សែងរ៉ែ និងអគារទប់ស្កាត់ផ្សែងរ៉ែ

6 — 1 5 ការគ្រប់គ្រងអគារបង្កើតធូលី និងអគារទប់ស្កាត់ធូលី

6 — 1 6 ការគ្រប់គ្រងទាក់ទងនឹងកាកសំណល់អាជីវកម្មរ៉ែ

6 — 1 7 ការគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព

6 — 1 8 ការគ្រប់គ្រងទាក់ទងនឹងការជីកយកដី

ជំពូក 7 វិធីវាយតំលៃនិងវិធានការសំរាប់រក្សាបាននូវសុវត្ថិភាព

7 – 1 រចនាសម្ព័ន្ធនិងខ្លឹមសារក្នុងការអនុវត្តស្រាវជ្រាវជាក់ស្តែង

7 – 2 រចនាសម្ព័ន្ធនិងខ្លឹមសារក្នុងការបញ្ជាក់នូវស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

7 – 3 រចនាសម្ព័ន្ធនិងខ្លឹមសារក្នុងវាយតំលៃស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

7 – 4 ការកត់ត្រានូវលទ្ធផលវាយតំលៃនិងលទ្ធផលបញ្ជាក់

ជំពូក 8 វិធានការសំរាប់រក្សាបាននូវសុវត្ថិភាព ចំនុចទាក់ទងនឹងការសើររើពិនិត្យមើលឡើងវិញ

## ជំពូក 1 រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព

ម្ចាស់អាជីវកម្មរ៉ែ ជ្រើសរើសអ្នកគ្រប់គ្រងសុវត្ថិភាពរួមជាប្រធានការដ្ឋានរ៉ែ ABE និងអ្នកជំនួសអ្នកគ្រប់គ្រងសុវត្ថិភាពរួមជាប្រធានផ្នែកអាជីវកម្មរ៉ែ។

1 – 1 ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព

នៅការដ្ឋានរ៉ែ ABEបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពមានដូចខាងក្រោម។

លើសពីនេះ ម្ចាស់អាជីវកម្មរ៉ែ បានជ្រើសរើសនិងដាក់បែងចែក នៅក្រោមការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួម មានអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព អនុអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព អ្នកគ្រប់គ្រងការងារ។

រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពរបស់ការដ្ឋានរ៉ែ ABE កំណត់នូវ「ផែនទីរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាព」 ភ្ជាប់នៅផ្សេងទៀត។

（1） ក្នុងករណីមានអ្នកគ្រប់គ្រងសុវត្ថិភាពរួមអវត្តមាន អ្នកតំណាំងអោយអ្នកគ្រប់គ្រងសុវត្ថិភាពរួមអនុវត្តការងារជំនួសបាន។

（2） អ្នកគ្រប់គ្រងសុវត្ថិភាពរួមជាប្រធានការដ្ឋានរ៉ែ、អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពជាប្រធានផ្នែកអាជីវកម្មរ៉ែ អនុអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពជាប្រធានការងារតាមផ្នែក អ្នកគ្រប់គ្រងការងារគឺជាអ្នកទទួលបន្ទុកការងារដែលបានបែងចែកនិងអ្នកទទួលខុសត្រូវការងារ។

## ជំពូក 2 គណៈកម្មការសុវត្ថិភាព

【គោលបំណង】

គណៈកម្មការសុវត្ថិភាព ជាស្ថាប័នកំណត់សំរេចទាក់ទងនឹងវិធានការសុវត្ថិភាពរបស់អគារផ្សេងៗ នៃការដ្ឋានរ៉ែ ASEAN មានភារកិច្ចពិភាក្សានូវចំនុចសំខាន់ៗទាក់ទងនឹងសុវត្ថិភាព ទទួលស្គាល់ការសំរេចនៅពេលប្រជុំ។ លើសពីនេះ ស្តីពីការងារទាក់ទងនឹងសុវត្ថិភាពរបស់អ្នកគ្រប់គ្រងសុវត្ថិភាពរួមនិងអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព ធ្វើការសហការព្រមទាំងផ្តល់យោបល់តាមភាពចាំបាច់និងធ្វើការព្រមានបាន។

គណៈកម្មការសុវត្ថិភាព、គឺមានមុខងារជា「គណៈកម្មការសុវត្ថិភាពអនាម័យ」ផងដែរ។

2－1 វិធីជ្រើសរើសសមាជិករបស់គណៈកម្មការសុវត្ថិភាព

（1） គណៈកម្មការសុវត្ថិភាព មានអ្នកគ្រប់គ្រងសុវត្ថិភាពរួមជាប្រធានគណៈកម្មការ សមាជិកផ្សេងទៀតត្រូវបានជ្រើសតាំងដោយក្រុមហ៊ុន ដោយសហជីព និងដោយផ្នែករដ្ឋបាល។

（2） ចំនួនពាក់កណ្តាលនៃសមាជិកត្រូវជាអ្នកគ្រប់គ្រងសុវត្ថិភាព និង ត្រូវជ្រើរើសចេញពីចំណោមកម្មកររ៉ែដោយភាគីក្រុមហ៊ុន នៅសល់សមាជិកចំនួនពាក់កណ្តាលទៀត គឺត្រូវជ្រើសរើសចេញពី

កម្មករដោយសហជីពជាអ្នកជ្រើសរើស។

（3） សមាជិករបស់គណៈកម្មការមានរយៈពេល១ឆ្នាំ ហើយអាចជ្រើសរើសបន្តឡើងវិញបាន។ ចំពោះនៅពេលមានការផ្លាស់ប្តូរសមាជិក ចាំបាច់ត្រូវជ្រើសរើសអ្នកជំនួស រយៈពេលរបស់អ្នកជំនួសថ្មី គឺមានជាពេលវេលាសល់ពីអ្នកមុន។

（4） ការិយាល័យរបស់គណៈកម្មការសុវត្ថិភាព គឺផ្នែកសុវត្ថិភាពបរិស្ថានជាអ្នកទទួលបន្ទុក ហើយប្រធានការិយាល័យគឺប្រធានផ្នែកសុវត្ថិភាពបរិស្ថាន។

（5） នៅពេលមានការទទួលស្គាល់និងការសំរេចសេចក្តីរបស់គណៈកម្មការសុវត្ថិភាព អ្នកឃ្លាំមើលនិងក្រៅពីសមាជិកគណៈកម្មការអាចចូលរួមបាន។

2－2 កាលបរិច្ឆេទនៃការបើកកិច្ចប្រជុំ

（1） គណៈកម្មការសុវត្ថិភាពត្រូវបើកកិច្ចប្រជុំរបស់ខ្លួន១ដងក្នុង១ខែ។ ក៏ប៉ុន្តែ នៅពេលអ្នកគ្រប់គ្រងសុវត្ថិភាពរួមទទួលស្គាល់ថាមានភាពចាំបាច់ ឬនៅពេលមានសមាជិកលើសពី១ភាគ២បានស្នើសុំ នោះកិច្ចប្រជុំរបស់គណៈកម្មការសុវត្ថិភាពនឹងអាចបើកបាន។

2－3 ដំណើរការ

（1） បើមានចំនួនសមាជិក២ភាគ៣របស់គណៈកម្មការសុវត្ថិភាពអវត្តមាន នោះកិច្ចប្រជុំរបស់គណៈកម្មការសុវត្ថិភាមិនអាចបើកបានឡើយ។

（2） ចំពោះគណៈកម្មការសុវត្ថិភាព មានមុខងារពិភាក្សាដោះស្រាយនូវ វិធានការអនុវត្តសុវត្ថិភាពសំខាន់ៗ ស្ថានភាពអនុវត្តវិធានការសុវត្ថិភាព ចំនុចរាយការណ៍សំខាន់ៗនៃគ្រោះថ្នាក់និងអគ្គិភ័យរបស់ការដ្ឋានរ៉ែ ពិភាក្សានិងរាយការណ៍នូវចំនុចទាក់ទងនឹងបទបញ្ញាផ្ទៃក្នុងសុវត្ថិភាព

（3） ចំពោះការសំរេចរបស់គណៈកម្មការ ចាំបាច់ត្រូវការសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា ប្រធានគណៈកម្មការជាអ្នកសំរេច។

（4） ចំពោះអ្នកឃ្លាំមើលនិងអ្នកមានវត្តមានបណ្តោះអសន្ន អាចមានសិទ្ធចញ្ចេញមតិបាន តែពុំមានសិទ្ធិបោះឆ្នោតសំរេចទេ។

2－4 ចំនុចទាក់ទងនឹងការកត់ត្រានូវលទ្ធផលនៃកិច្ចពិភាក្សា

（１）ចំពោះអ្នកគ្រប់គ្រងសុវត្ថិភាពរួម មានការសហការពីសំណាក់ការិយាល័យគណៈកម្មការនិងពីសមាជិកគណៈកម្មការ ស្តីពីការកត់ត្រានូវលទ្ធផលនៃកិច្ចប្រជុំពិភាក្សា។ល។ ចាំបាច់ត្រូវផ្សព្វផ្សាយពត៌មានទាំងនោះដល់កម្មកររ៉ែគ្រប់ៗគ្នា។

（2） ស្តីពីការកត់ត្រានូវលទ្ធផលនៃកិច្ចប្រជុំពិភាក្សារបស់គណៈកម្មការសុវត្ថិភាព ត្រូវរក្សាទុកក្នុងរយៈពេល៣ឆ្នាំ។

## ជំពូក 3 សកម្មភាពសំរាប់ជំរុញអោយមានសុវត្ថិភាព

3 – 1 រចនាសម្ព័ន្ធនិងខ្លឹមសារនៃការអនុវត្តសកម្មភាពសំរាប់ជំរុញអោយមានសុវត្ថិភាព

（1） ខ្លឹមសារសកម្មភាព

1） ផែនការសុវត្ថិភាពប្រចាំឆ្នាំ

អ្នកគ្រប់គ្រងសុវត្ថិភាពរួម បញ្ជាអោយប្រធានការិយាល័យគណៈកម្មការសុវត្ថិភាព （ប្រធានផ្នែកសុវត្ថិភាពបរិស្ថាន） បង្កើតគោលការណ៍សុវត្ថិភាពសំខាន់ប្រចាំឆ្នាំ និងដើម្បីអោយអនុវត្តបានតាមគោលការណ៍នោះ បង្កើតផែនការសុវត្ថិភាពប្រចាំឆ្នាំ និងអនុវត្ត។

2） សកម្មភាពសុវត្ថិភាពជានិរន្តភាព

ការដ្ឋានរ៉ែ ABE ក្រៅពីអនុវត្តគោលការណ៍សុវត្ថិភាពសំខាន់បានកំណត់តាមផែនការសុវត្ថិភាពប្រចាំឆ្នាំ ចំពោះសកម្មភាពជំរុញពីសុវត្ថិភាពមានដូចខាងក្រោម ក៏ត្រូវខិតខំប្រឹងប្រែងធ្វើជានិរន្តផងដែរ។

a) សកម្មភាពជំរុញកាត់បន្ថយនូវមូលហេតុនាំអោយមានគ្រោះថ្នាក់
b) សកម្មភាពជំរុញពង្រឹងភាពទុកចិត្តលើសំភារៈបរិក្ខារនិងអគារ
c) សកម្មភាពជំរុញពីសុវត្ថិភាពប្រចាំថ្ងៃ
d) សកម្មភាពជំរុញបើកបរអោយមានសុវត្ថិភាព

（2） រចនាសម្ព័ន្ធអនុវត្ត

1） ចំពោះសកម្មភាពសំរាប់ជំរុញនូវសុវត្ថិភាព អ្នកគ្រប់គ្រងសុវត្ថិភាពរួមក្នុងនាមជាអ្នកដឹកនាំកំពូល ត្រូវខិតខំប្រឹងប្រែងដឹកនាំជាផ្ទុងមួយនូវរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនអនុវត្តការងាររបស់ការដ្ឋានរ៉ែ ABE ។

2） ស្តីពីសកម្មភាពជំរុញសុវត្ថិភាពនិងផែនការសុវត្ថិភាពប្រចាំឆ្នាំ កំណត់ផែនការដោយមានការសហការពីផ្នែកពាក់ព័ន្ធនានាដោយមានការចូលរួមពីការិយាល័យរបស់គណៈកម្មការសុវត្ថិភាព （ប្រធានផ្នែកសុវត្ថិភាពបរិស្ថាន） ក្រោយពីបានទទួលស្គាល់របស់ អ្នកគ្រប់គ្រងសុវត្ថិភាពរួម នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការសុវត្ថិភាព ធ្វើការសំរេច ពិភាក្សានូវសកម្មភាពចំបងៗជំរុញពីសុវត្ថិភាពនិងសំណើរផែនការសុវត្ថិភាពប្រចាំឆ្នាំ។

3） ចំពោះតាមផ្នែកនីមួយៗរបស់ការដ្ឋានរ៉ែ ABE ស្តីពីសកម្មភាពសុវត្ថិភាពនិងផែនការសុវត្ថិភាពប្រចាំឆ្នាំ ខិតខំទាញបញ្ចូលទៅក្នុង 「ផែនការសុវត្ថិភាព ការផលិតប្រចាំឆ្នាំ」 ។

（3） ការវាយតំលៃ

សូមចូលរួមពិនិត្យលើ 「ជំពូក 7 វិធីវាយតំលៃនិងវិធានការសំរាប់រក្សាបាននូវសុវត្ថិភាព។

3 – 2 ចំនុចទាក់ទងនឹងការកត់ត្រានូវការកត់ត្រាសំរាប់ជំរុញអោយមានសុវត្ថិភាព

（1） ការកត់ត្រាពីសកម្មភាព

1） នៅការិយាល័យគណៈកម្មការសុវត្ថិភាព (ប្រធានផ្នែកសុវត្ថិភាពបរិស្ថាន) ធ្វើការរក្សាទុកនូវការកត់ត្រានូវលទ្ធផលការស្តាប់មតិជាប្រចាំពីសំណាក់អ្នកពាក់ព័ន្ធ អ្នកគ្រប់គ្រងសុវត្ថិភាពរួមស្ថានភាពនៃ 「ផែនការសុវត្ថិភាព ការផលិតប្រចាំឆ្នាំ」 របស់ផ្នែកនីមួយៗនិង 「ផែនការប្រចាំឆ្នាំសារពើព័ន្ធ」 ។ លើសពីនេះ ធ្វើអោយផែនការប្រចាំឆ្នាំបន្ទាប់មានខ្លឹមសាររឹតតែប្រសើរតាមរយៈខ្លឹមសារនៃការកត់ត្រានោះ។

## ជំពូក 4 ការបណ្តុះបណ្តាលពីសុវត្ថិភាព

4－1 អ្នកជាគោលដៅនៃការបណ្តុះបណ្តាល、 វិធីបណ្តុះបណ្តាលពីសុវត្ថិភាពនិងកំរិតនៃការបណ្តុះបណ្តាលពីសុវត្ថិភាព

（1） គោលបំណង អ្នកជាគោលដៅនៃការបណ្តុះបណ្តាល

ដើម្បីអនុវត្តការងារចាំបាច់និងអោយមានភាពរលូននិងមានសុវត្ថិភាព កំណត់នូវខ្លឹមសារនៃការគ្រេបយកបច្ចេកទេសនិងការបណ្តុះបណ្តាលពីសុវត្ថិភាពចំពោះអ្នកអនុវត្តការងារនៃផ្នែកការងារនីមួយៗ ។

（2） ចំពោះប្រព័ន្ធបណ្តុះបណ្តាលទាក់ទងនឹងសុវត្ថិភាព បង្កើតឡើងពី៣ផ្នែកមានដូចខាងក្រោម៖

1） បណ្តុះបណ្តាលមូលដ្ឋានគ្រឹះទាក់ទងនឹងសុវត្ថិភាព

a) អប់រំបណ្តុះបណ្តាលទូទៅពីសុវត្ថិភាព

b) ច្បាប់អនាម័យសុខភាពពលកម្មនៅក្នុងក្រុមហ៊ុន ការហ្វឹកហាត់ពីបច្ចេកទេសរបស់ច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ

2） បណ្តុះបណ្តាលទាក់ទងនឹងសុវត្ថិភាពនៃកម្មវិធីអប់រំប្រព័ន្ធបច្ចេកទេស

3） ហ្វឹកហាត់សំរាប់បណ្តុះបណ្តាលយកសញ្ញាប័ត្រទាក់ទងនឹងបរិស្ថាននិងសុវត្ថិភាព សិក្សានៅក្នុងក្រុមហ៊ុននិងក្រុមហ៊ុនជាអ្នកអនុវត្តការងារនេះ

（3） វិធី កំរិត ខ្លឹមសារ និងចំនុននានានៃការបណ្តុះបណ្តាលពីសុវត្ថិភាព

1） បណ្តុះបណ្តាលមូលដ្ឋានគ្រឹះទាក់ទងនឹងសុវត្ថិភាព

a) អប់រំបណ្តុះបណ្តាលទូទៅ

| ផ្នែកនៃការងារ | ខ្លឹមសារ | វិធី | កំរិត | សញ្ញាប័ត្រត្រូវបានលើកលែងដោយការអប់រំ |
|---|---|---|---|---|
| ការងារបំផ្ទុះប្រើ | 1ការអប់រំតាមបែប | ការអប់រំដាច់ | 1ការអប់រំតាមបែប | 1លើកលែងអោយ |

| | | | | |
|---|---|---|---|---|
| ប្រភេទរំសេវ (ការងារជំនួយទាក់ទងនឹងការងារទាំងនោះ) | វិទ្យាសាស្ត្រ<br>1) ចំណេះដឹងពីប្រភេទរំសេវ<br>2) វិធីប្រើប្រភេទរំសេវ<br>3) វិធីការងារបំផុទុះ<br>2. បណ្តុះបណ្តាលអនុវត្តជាក់ស្តែង (OJT) | ដោយឡែក ឬជាក្រុមនិងOJT តាមរយៈឯកសារបច្ចេកទេសទាក់ទងនឹងសុវត្ថិភាពផ្សេងៗ បទបញ្ញត្តិនិងឯកសារបែបបទធ្វើការងារកំណត់ដោយឡែកផ្សេងទៀត បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព | វិទ្យាសាស្ត្រ<br>1) ចំណេះដឹងពីរំសេវ : លើសពី 4h<br>2) វិធីប្រើរំសេវ : លើសពី6h<br>3) វិធីការងារតាមរយៈរំសេវ : លើសពី8h<br>2. បណ្តុះបណ្តាលអនុវត្តជាក់ស្តែង : លើសពី18h និងរយៈពេលកម្មសិក្សាផ្ទាល់លើសពី១ខែ | អ្នកទទួលខុសត្រូវសុវត្ថិភាពប្រភេទរំសេវ<br>2 អនុញ្ញាតចំពោះអ្នកបច្ចេកទេសបំផ្ទុះ |
| ការងារប្រើប្រាស់សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព | 1. ការអប់រំតាមបែបវិទ្យាសាស្ត្រ<br>1) សារធាតុបែបគីមីនៃសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព<br>2) ទាក់ទងនឹងច្បាប់នានា<br>3) វិធីប្រើសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព<br>4) វិធីតបទល់នៅពេលមានអសន្នចំពោះសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព | ការអប់រំដាច់ដោយឡែក ឬជាក្រុម តាមរយៈឯកសារបច្ចេកទេសទាក់ទងនឹងសុវត្ថិភាពផ្សេងៗ បទបញ្ញត្តិនិងឯកសារបែបបទធ្វើការងារកំណត់ដោយឡែកផ្សេងទៀត បទបញ្ជាផ្ទៃក្នុងសុវត្ថិភាព | 1. ការអប់រំតាមបែបវិទ្យាសាស្ត្រ : មុខវិជ្ជានីមួយៗមានលើសពី២ម៉ោង សរុបចំនួនលើសពី៨ម៉ោង | 1 អ្នកទទួលខុសត្រូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព |
| បុគ្គលិកថ្មី | ការអប់រំតាមបែប | 1 ការអប់រំតាម | 1 ការអប់រំតាម | |

| | | | | |
|---|---|---|---|---|
| | វិទ្យាសាស្ត្រ<br>1) មូលដ្ឋានគ្រឹះទាក់ទងនឹងអនាម័យនិងសុខភាព<br>2) មូលដ្ឋានគ្រឹះទាក់ទងនឹងសុវត្ថិភាពចរាចរណ៍<br>3) ទាក់ទងនឹងច្បាប់នានា | បែបជាក្រុមតាមរយៈសៀវភៅបង្រៀន ឬការបង្ហាញជាវីដេអូ។ល។ | បែបវិទ្យាសាស្ត្រ<br>・មុខវិជ្ជានីមួយៗមានលើសពី២ម៉ោង សរុបចំនួនលើសពី៦ម៉ោង | |

＊ អ្នកទទួលបន្ទុកការបណ្តុះបណ្តាល ជាគោលការណ៍គឺជាអ្នកមានមុខងារជាអ្នកគ្រប់គ្រងការងារឬមានមុខងារលើសពីនេះ។

＊ចំពោះអ្នកមានសញ្ញាប័ត្រត្រូវបានលើកលែងមិនបាច់ទទួលការអប់រំ អាចដកចេញពីគោលដៅជាអ្នកទទួលការអប់រំបាន។

（4）ការអប់រំសុវត្ថិភាព ចំពោះអ្នកផ្ទេរមកពីកន្លែងផ្សេង អ្នកទទួលការងារបន្ត

1）ចំពោះអ្នកផ្ទេរមកពីកន្លែងផ្សេង ណែនាំពីការងារដោយអនុលោមតាមបទពិសោធន៍ដែលគាត់មានកន្លងមក អប់រំចាំបាច់តាមតំរូវការ ដោយប្រើសៀវភៅបែបបទការងារនិងការអប់រំមូលដ្ឋានគ្រឹះទាក់ទងនឹងសុវត្ថិភាព។

2）ចំពោះអ្នកទទួលការងារធ្វើបន្ត ស្តីពីការងារបានកំណត់ដោយអ្នកគ្រប់គ្រងការងារនិងអ្នកទទួលខុសត្រូវនោះ អប់រំសំរាប់អនុវត្តអោយបានប្រកដប្រជានិងមានសុវត្ថិភាពដល់ការសាងសង់ ដោយប្រើនូវឯកសារប្រើសំរាប់អប់រំពីសុវត្ថិភាពរបស់ក្រុមហ៊ុននិងឯកសារការងារ ដោយផ្អែកលើសមត្ថភាព បទពិសោធន៍ សញ្ញាប័ត្រ។ល។

3）ចំពោះអ្នកទទួលការងារធ្វើបន្ត មុននឹងចាប់ផ្តើមការងារ អនុវត្តនូវការអប់រំដល់គ្រប់អ្នកអនុវត្តការងារទាំងអស់ ព្រមទាំងរក្សានូវការកត់ត្រាទាំងនោះ។

## 4－2 វិធីកំរិតនៃការបណ្តុះបណ្តាលឡើងវិញម្តងទៀតពីសុវត្ថិភាព

（1）អនុវត្តការបណ្តុះបណ្តាលឡើងវិញម្តងទៀត

ក្នុងករណីមានដូចខាងក្រោម អនុវត្តការអប់រំឡើងវិញ ដោយមានការសហការពីបណ្តាផ្នែកផ្សេងៗ ហើយផ្នែកសុវត្ថិភាពបរិស្ថានជាអ្នកទទួលបន្ទុកលើការអប់រំសុវត្ថិភាព។

1）ករណីបានកើតឡើងនូវគ្រោះថ្នាក់និងអគ្គិភ័យនៅការដ្ឋានរ៉ែ

a) នៅក្នុងគណៈកម្មការត្រួតពិនិត្យទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យនៅការដ្ឋានរ៉ែ (មានប្រធាន

ការិយាល័យជាប្រធានផ្នែកសុវត្ថិភាពបរិស្ថាន ផ្នែកសុវត្ថិភាពបរិស្ថានគឺជាការិយាល័យ។)
អនុវត្តការអប់រំទប់ស្កាត់កើតឡើងវិញចំពោះផ្នែកដែលជាគោលដៅនៃការអប់រំ ក្រោយពីបាន
រកឃើញនូវមូលហេតុ ពិនិត្យនូវវិធានការនិងមូលហេតុទាំងនោះ។

（2）ករណីត្រូវទទួលស្គាល់ថាជាគោលដៅនិងលើផ្នែកសុវត្ថិភាពមានបញ្ហា នៅការក្នុងស្រាវជ្រាវសុវត្ថិភាព

1）នៅក្នុងគណៈកម្មការត្រួតពិនិត្យទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យនៅការដ្ឋានរ៉ែ អនុវត្តការអប់រំទប់ស្កាត់កើតឡើងវិញចំពោះផ្នែកដែលជាគោលដៅនៃការអប់រំ ក្រោយពីបាន
រកឃើញនូវមូលហេតុ ពិនិត្យនូវវិធានការនិងមូលហេតុទាំងនោះ។

2）អនុវត្តនូវវិធានការកែលំអនិងពិនិត្យនូវវិធានការកែលំអ វាយតំលៃ វិភាគ រកពីមូលហេតុនៃគ្រោះថ្នាក់តាមរយៈការគ្រប់គ្រងហានិភ័យRisk assessment method។

4－3 ចំនុចទាក់ទងនឹងការកត់ត្រានូវពីសុវត្ថិភាព

（1）ចំពោះករណីបានអនុវត្តការបណ្តុះបណ្តាលពសុវត្ថិភាព ផ្នែកបានអនុវត្ត ត្រូវកត់ត្រានិងរក្សាទុកពី ឯកសារពាក់ព័ន្ធនឹងពេលវេលាអនុវត្ត កាលបរិច្ឆេទ អ្នកបណ្តុះបណ្តាល អ្នកទទួលការបណ្តុះបណ្តាល មុខវិជ្ជាត្រូវយកមកបណ្តុះបណ្តាល។

## ជំពូក 5　ការតប់ទល់នៅពេលមានគ្រោះថ្នាក់កើតឡើងនៅក្នុងការដ្ឋានរ៉ែ

5－1 រចនាសម្ព័ន្ធទាក់ទងគ្នា

（1）រចនាសម្ព័ន្ធទាក់ទង（ផែនទីប្រព័ន្ធទាក់ទងនៅពេលមានគ្រោះអសន្ន គោលការណ៍គ្រោះនៃរបាយការណ៍）

1）ណៅពេលមានកើតឡើងនូវស្ថានភាពមានគ្រោះអសន្ននៃគ្រោះថ្នាក់ អគ្គិភ័យនៅការដ្ឋានរ៉ែ។ល។ ដើម្បីធ្វើការទាក់ទងអោយលឿនឆាប់រហ័សដល់ អគ្គនាយកដ្ឋាន មន្ទីរពាក់ព័ន្ធនៅតាមខេត្តនានា និងអ្នកពាក់ព័ន្ធរបស់ក្រុមហ៊ុន ធ្វើការកំណត់នូវ「ផែនទីរចនាសម្ព័ន្ធទាក់ទងនៅពេលមានគ្រោះអសន្ន」រួចធ្វើការបិទប្រកាសនៅតាមទីកន្លែងសំខាន់ៗដូចជាអគារសំខាន់ៗតាមផ្នែកនានា មជ្ឈមណ្ឌលគ្រប់គ្រងរួម។ល។

2）ចំពោះ「ផែនទីរចនាសម្ព័ន្ធទាក់ទងនៅពេលមានគ្រោះអសន្ន」ករណីមានការផ្លាស់ប្តូរមនុស្សទោធ្វើការនៅកន្លែងដ៏ទៃ ចាំបាច់ត្រូវធ្វើការកែប្រែឡើងវិញជាបន្ទាន់ និងធ្វើការផ្សព្វផ្សាយ។

3）ចំពោះរបាយការណ៍នៅពេលមានគ្រោះអសន្ន ចាំបាច់ត្រូវតែរាយការណ៍អោយបានច្បាស់លាស់និងត្រូវបានគោលដៅនៃការរាយការណ៍ ដូចជាប្រើ 5 W 1 H（ពេលណា（When)、នៅទីណា（Where)、អ្នកណា（Who)、អ្វី（What)、ហេតុអ្វី（Why)、ធ្វើយ៉ាងម្តេច(How)）រួចរាយការណ៍ផ្សព្វផ្សាយចាប់តាំងពីអ្នកដឹកនាំការដ្ឋានរ៉ែរហូតដល់កម្មកររ៉ែ។

4）ករណីបានកើតឡើងនូវគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ រៀបចំជា「បែបបទសំរាប់តបទល់នឹងគ្រោះ

ថ្នាក់」ដែលមានភ្ជាប់នៅទំព័រផ្សេង។

（2）វិធានការទប់ស្កាត់រីកដុះដាលនៃគ្រោះថ្នាក់នៅការដ្ឋានរ៉ែ

1）តបទល់ដំណាក់កាលដំបូង

a) នៅពេលមានកើតនូវគ្រោះធម្មជាតិ ខ្យល់ព្យុះ ភ្លៀងធ្លាក់ខ្លាំង។ល។
ករណីត្រូវបានអោយដឹងនូវការប្រយ័ត្ន និងការណ៍កើតឡើងនូវគ្រោះធម្មជាតិ ខ្យល់ព្យុះ ភ្លៀងធ្លាក់ខ្លាំង។ល។ ត្រូវរៀបចំជា「បែបបទសំរាប់តបទល់នឹងគ្រោះថ្នាក់」ដែលមានភ្ជាប់នៅទំព័រផ្សេង។

b) នៅពេលមានកើតនូវគ្រោះអគ្គិភ័យ និងគ្រោះមហន្តរាយផ្សេង
អ្នកបានរកឃើញនៃគ្រោះអគ្គិភ័យ និងគ្រោះមហន្តរាយផ្សេង ត្រូវរាយការណ៍ទាក់ទងទៅនឹងអ្នកពាក់ព័ន្ធជាបន្ទាន់ ដោយអនុវត្តតាម「ផែនទីរចនាសម្ព័ន្ធទាក់ទងនៅពេលមានគ្រោះអសន្ន」និងធ្វើតាមការណែនាំនោះ។ ក៏ប៉ុន្តែករណី មានកើតឡើងនូវអគ្គិភ័យ ត្រូវរាយការណ៍ដល់ភ្នាក់ងារពន្លត់អគ្គិភ័យជាបន្ទាន់។

（3）បង្កើតនូវទីស្នាក់ការចាត់វិធានការចំពោះគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ

1）ករណីបានកើតគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ ឆ្លើយតបនឹងសភាពទូទៅនៃគ្រោះមហន្តរាយនោះ ដើម្បីជំរុញអោយមានប្រសិទ្ធិភាពក្នុងការអនុវត្តចំពោះវិធានការទប់ស្កាត់គ្រោះថ្នាក់ បង្កើត「ទីស្នាក់ការចាត់វិធានការតបទល់នឹងគ្រោះថ្នាក់」នៅក្នុងការដ្ឋានរ៉ែ ASEAN ។

a) ករណីបានកើតគ្រោះថ្នាក់មានជនរងគ្រោះជាកម្មកររ៉ែលើសពី៣នាក់

b) ករណីបានកើតគ្រោះថ្នាក់នៅអគារនៃការដ្ឋានរ៉ែ ដូចជា គ្រោះអគ្គិភ័យធំ ឬការផ្ទុះ

c) នៅទីកន្លែងស្តុកថ្មចោល ឬទីកន្លែងស្តុកកាកសំណល់កករង មានកើតឡើងនូវគ្រោះថ្នាក់ដោយសារការហូរចេញនៃកាកសំណល់ បណ្តាលអោយបាក់ទំនប់

d) ករណីបានសន្និដ្ឋានថាមានភាពចាំបាច់បង្កើត「ទីស្នាក់ការចាត់វិធានការតបទល់នឹងគ្រោះថ្នាក់」ដោយអ្នកគ្រប់គ្រសុវត្ថិភាពរួម នៅការដ្ឋានរ៉ែមានគ្រោះថ្នាក់កើតឡើង

2）ចំពោះ「ទីស្នាក់ការចាត់វិធានការតបទល់នឹងគ្រោះថ្នាក់」បានបង្កើតឡើងនៅក្នុងបន្ទប់ប្រជុំនៃការដ្ឋានរ៉ែ ASEAN ដែលមានអ្នកគ្រប់គ្រងសុវត្ថិភាពរួមជាប្រធានចាត់វិធានការចំពោះគ្រោះថ្នាក់។ លើសពីនេះ ឆ្លើយតបនឹងភាពចាំបាច់ បង្កើត「ទីស្នាក់ចាត់វិធានការនៅនឹងទីកន្លែងកើតហេតុ」 ដោយមានអ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពជាប្រធានចាត់វិធានការនៅនឹងទីកន្លែងកើតហេតុ។

3）ស្តីពីវិធានការផ្សេងៗទៀត រៀបចំឆ្លើយតបនឹង「បែបបទសំរាប់តបទល់នឹងគ្រោះថ្នាក់」ដែលមានភ្ជាប់នៅទំព័រផ្សេង។

（4）រចនាសម្ព័ន្ធក្រុមពន្លត់អគ្គិភ័យ

1）រចនាសម្ព័ន្ធក្រុមពន្លត់អគ្គិភ័យនៃការដ្ឋានរ៉ែ ASEAN

a) ប្រធានពន្លត់គឺប្រធាននៃអគារនីមួយៗ ដែលមានសមាជិកធ្វើការនៅទីនោះជាសមាជិកក្រុមពន្លត់អគ្គិភ័យ។

b) អ្នកគ្រប់គ្រងសុវត្ថិភាពរួម អាចបញ្ចាបង្កើតក្រុមពន្លត់អគ្គិភ័យផ្សេងទៀតដោយឆ្លើយតបនឹងសភាពជាក់ស្តែង។

c) ករណីមានភាពចាំបាច់នៃការប្លាស់ប្តូរសមាជិកក្រុមពន្លត់អគ្គិភ័យ អាចធ្វើការពិនិត្យមើលឡើងវិញតាមសភាពជាក់ស្តែង។

d) ធ្វើការហ្វឹកហាត់ជាប្រចាំដោយស្របតាម「បែបបទវិធានការតបទល់នឹងអគ្គិភ័យ」ដែលមានកំណត់នៅទំព័រផ្សេងទៀត។

2) មុខងាររបស់រចនាសម្ព័ន្ធក្រុមពន្លត់អគ្គិភ័យ

a) ការទៅជាបន្ទាន់ចំពោះទីកន្លែងមានអគ្គិភ័យ

b) ការជួយសកម្មភាពពន្លត់អគ្គិភ័យដំណាក់កាលដំបូងតាមរយៈបរិក្ខារពន្លត់អគ្គិភ័យ

c) ការប្រើបរិក្ខារពន្លត់អគ្គិភ័យសាធារណៈ

d) ទប់ស្កាត់ការឆេះរាលដាលនៅពេលមានអគ្គិភ័យ、ប្រយ័ត្នចំពោះទីកន្លែងនោះ

e) ការជួយបណ្តុះបណ្តាលទាក់ទងនឹងវិធីប្រើបរិក្ខារពន្លត់អគ្គិភ័យ

3) របាយការណ៍នៅពេលមានគ្រោះថ្នាក់និងគ្រោះមហន្តរាយកើតឡើង

(5) ការរាយការណ៍ចាំបាច់ពីគ្រោះថ្នាក់និងគ្រោះមហន្តរាយកើតឡើងដល់អគ្គនាយកទទួលការងាររ៉ែ

| គ្រោះថ្នាក់និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ | ពេលវេលានៃរបាយការណ៍ |
|---|---|
| 1) នៅពេលកើតគ្រោះមហន្តរាយមានអ្នកស្លាប់ ឬមានអ្នករបួសដែលបណ្តាលអោយផ្អាកការងារលើសពិ៤សប្តាហ៍។<br>2) នៅពេលកើតមានបញ្ហាការបំពុលបរិស្ថាន។ | 1) រាយការណ៍ជាបន្ទាន់ទៅអគ្គនាយកទទួលការងាររ៉ែ<br>2) រាយការណ៍នូវ「របាយការណ៍គ្រោះមហន្តរាយនិងគ្រោះថ្នាក់នៅការដ្ឋានរ៉ែ」ក្រោយពេលកើតឡើងក្នុងរយៈពេល៣០ថ្ងៃ |

(6) ការកត់ត្រាពីរបាយការណ៍

1) ស្តីពីការកត់ត្រាពីរបាយការណ៍គ្រោះមហន្តរាយនិងគ្រោះថ្នាក់នៅការដ្ឋានរ៉ែ ផ្នែកសុវត្ថិភាពបរិស្ថានជាអ្នកធ្វើ និងរាយការណ៍ដល់អគ្គនាយកទទួលការងាររ៉ែ ព្រមទាំងរក្សាទុកអោយបានក្នុងរយៈពេល៥ឆ្នាំ។

(7) វិធានការទប់ស្កាត់និងការវិភាគ

1) គ្រោះមហន្តរាយនិងគ្រោះថ្នាក់នៅការដ្ឋានរ៉ែកើតឡើង នៅក្នុងដំណាក់កាលបានបញ្ចប់វិធានការ អ្នកគ្រប់គ្រងសុវត្ថិភាពរួម ធ្វើការសិក្សាស្វែងរកពីមូលហេតុ ក្តាប់បាននូវសភាព

លំអិត សើររើមើលបែបបទនៃការងារឡើងវិញ ធ្វើការកែលំអឡើងវិញនិងធ្វើការអប់រំឡើងវិញ។ល។ ព្រមទាំងខិតខំប្រឹងប្រែងទប់ស្កាត់កុំអោយមានគ្រោះមហន្តរាយនិងគ្រោះថ្នាក់នៅការដ្ឋានរ៉ែកើតឡើងជាថ្មីម្តងទៀត។

2) ចំពោះវិធានការទប់ស្កាត់ការកើតឡើងជាថ្មីម្តងទៀតនិងលទ្ធផលនៃការវិភាគស្តីពីមូលហេតុនៃគ្រោះថ្នាក់និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ ត្រូវអោយជួយដល់ការកែលំអនៃបែបបទការងារនិងផែនការសុវត្ថិភាពប្រចាំនៃឆ្នាំសារពើព័ន្ធក្រោយថែមទៀត។

5－2　វិធីនៃការជន្លៀសខ្លួន

（1）អ្នកគ្រប់គ្រងការងារ ចំពោះបានសន្និដ្ឋានថាមានគ្រោះថ្នាក់កើតឡើងឬ កើតគ្រោះថ្នាក់ចំពោះកម្មកររ៉ែ ចាំបាច់ត្រូវចាត់វិធានការបញ្ចៀសគ្រោះថ្នាក់នោះរួមទាំងបញ្ឈប់ការងារទាំងនោះផងដែរ។

（2）ករណីបានអោយភៀសខ្លួន ក្រោយពីបានភៀសខ្លួនចប់សព្វគ្រប់ ធ្វើការពិនិត្យមើលរាប់ចំនួនគ្នាឡើងវិញ តើមានបានភៀសខ្លួនទាំងអស់គ្នាហើយឬនៅ?

5－3　វិធីនៃជួយសង្គ្រោះជនរងគ្រោះ

（1）ករណីមានជនរងគ្រោះ អ្នករកឃើញគ្រោះថ្នាក់ ត្រូវចាត់ចែងដឹកជញ្ជូនទៅកាន់មន្ទីរពេទ្យជាបន្ទាន់ បន្ទាប់មក ត្រូវរាយការណ៍ដល់អ្នកពាក់ព័ន្ធ ថ្នាក់ដឹកនាំការដ្ឋានរ៉ែ តាម「បែបបទវិធានការតបទល់នឹងអគ្គិភ័យ」ដែលមានកំណត់នៅទំព័រផ្សេងទៀត។

（2）អ្នករកឃើញគ្រោះថ្នាក់ ក្រោយពីរថយន្តសង្គ្រោះបានមកដល់ បើអាចធ្វើបានត្រូវតែធ្វើដំណើរតាមជនរងគ្រោះ។ ក៏ប៉ុន្តែ ករណីជួបការលំបាកក្នុងការធ្វើដំណើរជាមួយដោយត្រូវចាត់វិធានការតប់ទល់នឹងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ។ល។ ត្រូវពឹងដោយធ្វើការទាក់ទងនឹងទៅផ្នែកសុវត្ថិភាពបរិស្ថានឬផ្នែករដ្ឋបាលពីមូលហេតុនោះ។

5－4 វិធានការចំពោះអគារនៃការដ្ឋានឬនៅទីកន្លែងធ្វើការនីមួយៗ នៅពេលមានគ្រោះថ្នាក់កើតឡើងឬការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែ

នៅតាមផ្នែកគ្រប់គ្រងនីមួយៗ ត្រូវអនុវត្តនូវចំនួចមានដូចខាងក្រោម៖

（1）នៅតាមផ្នែកនីមួយៗ ត្រូវដាក់បរិក្ខារសង្គ្រោះបន្ទាន់ចាំបាច់ សំរាប់សង្គ្រោះជនរងគ្រោះនៅតាមទីកន្លែងអគារ ឬទីកន្លែងធ្វើការ ព្រមទាំងប្រាប់ដល់កម្មកររ៉ែអោយដឹងពីវិធីប្រើប្រាស់និងទីកន្លែងដែឡបានដាក់ទុករបស់ទាំងនោះ។

1) ក្រណាត់រុំរបួស ដង្កៀប និងថ្នាំសំលាប់មេរោគ
2) ចំពោះទីកន្លែងធ្វើការមានគ្រោះថ្នាក់ខ្លាំងតាមរយៈការប្រើភ្លើង និងទីកន្លែងប្រើរបស់មានកំដៅខ្ពស់ ត្រូវមានថ្នាំរលាកភ្លើងបំរុងទុក។
3) ចំពោះទីកន្លែងមានគ្រោះថ្នាក់កើតឡើងដោយមានអ្នករបួសធ្ងន់ ត្រូវមានបង់ឃាត់ឈាម និង

ប្រដាប់សែង។

4) ស្នែង

（2） ចំពោះនៅតាមទីកន្លែងធ្វើការនីមួយៗ តាមអគារការដ្ឋានរ៉ែនិងនៅតាមគ្រឿងចក្របែបជាយានយន្តការដ្ឋានរ៉ែ ត្រូវបំពាក់នូវបរិក្ខារពន្លត់អគ្គិភ័យសំរាប់ធ្វើការពន្លត់ក្នុងដំណាក់កាលដំបូង។

（3） ត្រូវកាប់ដើមឈើណាដែលអាចនឹងងាយរលំ សំរាប់ទប់ស្កាត់គ្រោះថ្នាក់ ឬយកដើមឈើដែលរលំចេញ។

（4） បង្កើតបែបទការងារនូវវិធីដំណើរការគ្រឹះនៃអគារ ដោយព្រៀងទុកពីគ្រោះថ្នាក់អាចនឹងកើតនៅការដ្ឋានរ៉ែ។

（5） ត្រូវរក្សាអោយបាននូវសំភារៈបរិក្ខារជួយសង្គ្រោះ។

（6） សំរាប់ទប់ស្កាត់ការបង្កខូចខាត់ដល់អគារតាមរយៈទង្វើរដោយអចេតនាឬដោយមានចេតនាពីសំណាក់អ្នកទី៣ ចាំចាប់ត្រូវលើកផ្លាកសញ្ញាបង្ហាញថាមានកប់របស់នៅក្នុងដី ឬ មានផ្លាកសញ្ញាហាមប្រើប្រាស់ភ្លើង ហាមចូល ទីកន្លែងទាក់ទងផ្សេងៗ។ល។

（7） ចំពោះករណីមានគំរោងសាងសង់ដោយក្រុមហ៊ុនផ្សេងនៅតំបន់ក្បែរអគារទាំងនោះ ធ្វើការព្រមានដល់កម្មករ ព្រមទាំងក្នុងករណីទទួលស្គាល់ថាមានទទួលឥទ្ធិពលដល់អគារ នៃការដ្ឋានរ៉ែ ធ្វើការឈចាំមើលពីសកម្មភាពនៃការសាងសង់នោះ។ លើសពីនេះ បង្កើនចំនួននៃការដើរល្បាតសំរាប់រក្សាបាននូវសុវត្ថិភាពរបស់អគារ។

（8） រៀបចំត្រៀមចំពោះគ្រោះថ្នាក់ធម្មជាតិតាមរយៈខ្យល់ព្យុះ ភ្លៀងធ្លាក់ខ្លាំង។ល។ អនុវត្តតបទល់នឹងតាមចំនុចចាំបាច់មានដូចខាងក្រោម។

1） ចំពោះពត៌មានតាមរយៈ ទូរទស្សន៍ វិទ្យុ អ៊ីនទ័រណេត។ល។ ផ្នែកសុវត្ថិភាពបរិស្ថានត្រូវក្តាប់ចាប់តាំងពី ដំណាក់កាលព្យាករណ៍ ទោះបីនៅពេលមានគ្រោះមហន្តរាយកើតឡើងក្តី និងត្រូវរាយការណ៏ដល់ផ្នែកនានា។

2） ចំពោះទីកន្លែងត្រូវប្រយ័ត្ន បង្កើនចំនួននៃការដើរល្បាតបើមានភាពចាំបាច់។

3） បញ្ជាក់ឡើងវិញនូវរចនាសម្ព័ន្ធទាក់ទង រក្សាបាននូវចំនួនមនុស្សចាំបាច់ក្នុងការសង្គ្រោះនិងចាត់វិធានការសំរាប់រងចាំជួយសង្គ្រោះ។

4） ករណីអនុវត្តការជីកយករ៉ែ នៅទីកន្លែងការដ្ឋានរ៉ែបើក ត្រូវសន្និដ្ឋានពីស្ថានភាពនៃអាកាសធាតុ អាចបញ្ឈាបញ្ឈប់ការងារដោយផ្អែកលើការអនុវត្តពីវិធានការសុវត្ថិភាព។

## ជំពូក 6　　ចំនុចលំអិតសំរាប់អនុវត្តចាត់នូវវិធានការចាំបាច់ដោយម្ចាស់អាជីវកម្មរ៉ែ

6－1　　ការប្រើគ្រឿងចក្រ ឧបករណ៍បរិក្ខារនិងឧបករណ៍ផលិតកម្ម

ចំពោះវិធីការងារនិងវិធីប្រើបរិក្ខារផលិត បរិក្ខារគ្រឿងចក្រដែលជាគោលដៅនោះ មានកំណត់នៅ「ស្តង់ដាពិនិត្យនិងប្រើបរិក្ខារគ្រឿងចក្រ របស់ការដ្ឋានរ៉ែ ASEAN」ផ្សេងទៀត។

6 – 2 ទប់ស្កាត់គ្រោះថ្នាក់តាមរយៈថ្មពកធ្លាក់និងថ្មបាក់រលំនៅការដ្ឋានរ៉ែបើកព្រមទាំងទប់ស្កាត់បាក់រលំ បាក់ស្រុតនៅការដ្ឋានរ៉ែបិទ

(1) នៅទីកន្លែងធ្វើការខួងរូលទៅមុខនិងទីកន្លែងជីកយកថ្មនៅក្នុងការដ្ឋានរ៉ែបិទ ដើម្បីទប់ស្កាត់នូវការបាក់រលំ បាក់ស្រុត ចាំបាច់ត្រូវចាត់វិធានការដូចខាងក្រោម។

1) នៅពេលអាចនឹងមានគ្រោះថ្នាក់នៃការបាក់ស្រុតឬបាក់រលំ ចាំបាច់ត្រូវតំឡើងសរសរទ្រសមស្របសមរម្យតប់ទល់នឹងស្ថានភាពនៃផ្ទាំងជញ្ជាំងថ្មនិងពិដាន។

2) ចំពោះនៅទីកន្លែងខួងរុលទៅមុខនៃផ្លូវក្នុងរូង, ធ្វើការតំឡើងទំរ ឬតំឡើងជន្ទល់ទប់ផ្ទៃជញ្ជាំងធ្វើការងារ។

3) តើមានការបែងចែកតំឡើងសរសរទ្រសមរម្យទៅតាមទីកន្លែងនីមួយៗដែរឬទេ។

4) ចំពោះសសរទ្រដែលពុក ឬខូច តើមានការផ្លាស់ពង្រឹងឡើងវិញបានឆាប់រហ័សដែរឬទេ?

5) ចំពោះទីកន្លែងមានភាពចាំបាច់សំរាប់សុវត្ថិភាព តើមានតំឡើងសរសរធ្យូងថ្មឬសរសររ៉ែសមរម្យទៅតាមសភាពនៃផ្ទាំងថ្មដែរឬទេ?

6) ចំពោះទីកន្លែងបានបញ្ចប់ការជីកយក ជើងទ្រ នៅពេលមានភាពចាំបាច់សំរាប់ផ្នែកសុវត្ថិភាព តើមានចាត់វិធានការសមរម្យដោយធ្វើការចាក់បន្ថែមតាមរយៈសារធាតុផ្សេងៗដូចជាដី និងខ្សាច់ជាដើម។

7) នៅក្នុងការងារនិងមុនចាប់ផ្តើមការងារ តើមានចាត់វិធានការចាំបាច់ ដោយធ្វើការទំលាក់ថ្មពក់ ពិនិត្យផ្ទៃការងារនិងផ្នែកជញ្ជាំង, ផ្ទាំងថ្ម ដែរឬទេ?

8) តើមានត្រៀមរៀបចំអោយមានបរិក្ខារសមរម្យសំរាប់ទំលាក់ថ្មពក់ពីជញ្ជាំង ពីពិដាននៃរូងដែរឬទេ?

(2) ចំពោះនៅទីកន្លែងជីកយករ៉ែនៃការដ្ឋានរ៉ែបើក ដើម្បីទប់ស្កាត់គ្រោះថ្នាក់តាមរយៈផ្ទាំងថ្មបាក់រលំនិងថ្មពកធ្លាក់ ត្រូវចាត់វិធានការដូចខាងក្រោម។

1) ក្នុងការយករ៉ែបែបការដ្ឋានរ៉ែបើក តើមានបានយកអាចម៍ដីខាងលើចេញដោយវិធីសុវត្ថិភាពជាមុនដែរឬទេ?

2) នៅផ្ទៃនៃជញ្ជាំងនៃទីកន្លែងធ្វើការងារ តើមានរក្សាបាននូវសុវត្ថិភាព ចំពោះជំរេល កំពស់នៃជញ្ជាំងនោះ និងបានតំឡើងនូវថ្នាក់មានផ្លូវដើរនិងកំពស់សមរម្យដែរឬទេ?

3) តើមានបានយកចេញតាមវិធីសុវត្ថិភាពចំពោះថ្មពកនៅកន្លែងជីកយកដែរឬទេ? ឬ តើមានតំឡើងនូវបរិក្ខារសំរាប់ទប់ស្កាត់នូវគ្រោះថ្នាក់តាមរយៈថ្មពុកធ្លាក់ដែរ?

4) ជញ្ជាំងនៅសល់ ដើម្បីទប់ស្កាត់នូវការបាក់រលំ តើមានបានរក្សានូវជំរេលសុវត្ថិភាពឆ្លើយតបនឹងស្ថានភាពនៃផ្ទាំងថ្មដែរឬទេ?

5) នៅទីកន្លែងមានជាច្រើនដែលមានគ្រោះថ្នាក់តាមរយៈថ្មធ្លាក់ ក្រៅពីតំឡើងជន្ទារសមរម្យ តើមានតំឡើងបរិក្ខារទប់ស្កាត់ការបាក់ធ្លាក់សមរម្យដូចជាខ្សែក្រវាត់សុវត្ថិភាព ឬសំណាញ់ទប់

ស្កាត់ថ្មធ្លាក់ដែរឬទេ?

6 ) នៅពេលអាចនឹងមានគ្រោះថ្នាក់ច្រើនយោងតាមរយៈ ថ្មពកធ្លាក់នៅកន្លែងធ្វើការជីកយករ៉ែ តើមានធ្វើការលើក្រោមនៅក្នុងពេលតែមួយដែរឬទេ?

7) នៅពេលអាចនឹងមានគ្រោះថ្នាក់តាមរយៈភ្លៀងធ្លាក់ បញ្ឈប់ធ្វើការ ឬតើមានចាត់វិធានការសមរម្យសំរាប់កុំអោយមនុស្សចូលទៅក្នុងតំបន់មានគ្រោះថ្នាក់ដែរឬទេ?

8 ) នៅពេលអាចនឹងមានគ្រោះថ្នាក់យោងតាមរយៈថ្មផ្លោង ឬថ្មរមៀល តើមានតំឡើងបរិក្ខារការពារសមរម្យ ឬកំណត់តំបន់ហាមមិនអោយមនុស្សចូល និងដាក់មនុស្សយាម ឬមានចាត់វិធានការសមរម្យចាំបាច់ដោយលើកផ្លាក់សញ្ញាដែរឬទេ?

9) នៅពេលអនុវត្តការងារទំលាក់ថ្មរ៉ែចូលទៅក្នុងអណ្តូងរូង។ល។ ដើម្បីទប់ស្កាត់ការធ្លាក់រថយន្តឬគ្រឿងចក្រជាប្រភេទយាន្តនៅការដ្ឋានរ៉ែ តើមានចាត់វិធានការសមរម្យសំរាប់ទប់រថយន្តដែរឬទេ?

１０) នៅពេលចង់បញ្ឈប់ឬបោះបង់ចោលនូវទីកន្លែងយកថ្មបែបការដ្ឋានរ៉ែបើក តើមានចាត់វិធានការចាំបាច់ សំរាប់ទប់ស្កាត់គ្រោះថ្នាក់តាមរយៈថ្មរមៀល ថ្មធ្លាក់ ឬមានទំរេលសុវត្ថិភាពសំរាប់ស្កាត់ការបាក់ធ្លាក់នៃជញ្ជាំងនិងជញ្ជាំងនៅសល់ ដែរឬទេ?

１１) អ្នកគ្រប់គ្រងការងារនិងទទួលបន្ទុកសុវត្ថិភាពក្រៅរូង តើមានធ្វើការត្រួតពិនិត្យអោយបានលើសពី១ដងក្នុងរាល់ម៉ោងធ្វើការនូវទីកន្លែងងាយកើតថ្មពកនៃផ្ទៃថ្ម និងទិកន្លែងដែលអាចមានគ្រោះថ្នាក់ច្រើនទៀត ដែរឬទេ?

１２) កម្មកររ៉ែអនុវត្តការងារជីកយករ៉ែ តើមានចាត់វិធានការចាំបាច់ទំលាក់ថ្មពក ដោយប្រើបរិក្ខារសមរម្យ ឬធ្វើការពិនិត្យនូវផ្ទាំងថ្មនៅក្នុងពេលធ្វើការងារ និងមុនធ្វើការងារដែរឬទេ?

## 6－3 ការប្រើប្រាស់ប្រភេទនៃរំសេវ

（1）អ្នកប្រើប្រាស់ប្រភេទនៃរំសេវ

1）អ្នកគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវ និងអ្នកគ្រប់គ្រងការងារទទួលការបំផ្ទុះ ជ្រើសរើសអ្នកគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវ និងអ្នកគ្រប់គ្រងការងារទទួលការបំផ្ទុះពីមនុស្សមានលក្ខខណ្ឌចាំបាច់នៃការជ្រើសរើសកំណត់នៅក្នុងការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពនៃជំពូក១ រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពរបស់ការដ្ឋានរ៉ែASEAN។

2）អ្នកធ្វើការងារជំនួយការដល់ការងារបំផ្ទុះ

អនុវត្តការងារជំនួយដល់ការបំផ្ទុះ តាមរយៈការបង្ហាញបញ្ជាដល់អ្នកគ្រប់គ្រងការងារទទួលការបំផ្ទុះ អ្នកអនុវត្តការងារបានទទួលការអប់រំចប់កំណត់ដោយការងារជំនួយការងារបំផ្ទុះសំរាប់អ្នកជាគោលដៅនៃការបណ្តុះបណ្តាល、វិធីបណ្តុះបណ្តាលពីសុវត្ថិភាពនិងកំរិតនៃការបណ្តុះបណ្តាលពីសុវត្ថិភាពនៃជំពូក４－1 ។

(2) ការប្រគល់និងទទួលយកមកវិញនូវប្រភេទនៃរំសេវ

1) វិធានការនៅពេលប្រគល់ទទួលប្រភេទនៃរំសេវ

a) ចំពោះនៅពេលប្រើប្រភេទរំសេវនៅទីកន្លែងជីកយកបែបការដ្ឋានរ៉ែបើក អ្នកគ្រប់គ្រងការងារទទួលការបំផ្ទុះ សរសេរនូវបរិមាណប្រភេទរំសេវដែលត្រូវការនៅក្នុង「ប័ណ្ណស្នើសុំប្រភេទរំសេវ」 ដោយស្នើរសុំទៅអ្នកគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវ។

b) អ្នកគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវ ចេញចំនួនបរិមាណប្រភេទរំសេវ រួចធ្វើការកត់ត្រាលើ「បញ្ជីប្រគល់ទទួលប្រភេទរំសេវ」។

c) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះ ក្នុងករណីមានសល់ប្រភេទរំសេវក្រោពីការប្រើនៃការបំផ្ទុះ ត្រូវសងប្រគល់មកអោយអ្នកគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវជាបន្ទាន់។កគ្រប់គ្រងការងារទទួលបន្ទុកប្រភេទរំសេវជាបន្ទាន់នៅពេលទទួលចំនួនប្រភេទរំសេវដែលត្រូវបានប្រគល់នោះ ត្រូវកត់ត្រាលើ「បញ្ជីប្រគល់ទទួលប្រភេទរំសេវ」។

d) អ្នកគ្រប់គ្រងការងារទទួលការបំផ្ទុះ ប្រភេទរំសេវបានប្រើនៅការងារបំផ្ទុះ ស្តីពីចំនួនបរិមាណប្រភេទរំសេវសល់ហើយបានប្រគល់ត្រឡប់វិញនោះ គឺត្រូវកត់ត្រាលើ「សៀវសុវត្ថិភាពប្រចាំថ្ងៃ」។

2) ការទុកដាក់ប្រភេទរំសេវមួយរយៈខ្លី

a) ការទុកដាក់ប្រភេទរំសេវមួយរយៈខ្លីនៅទីកន្លែងធ្វើការងារជីកយករ៉ែ ក្បែរកន្លែងធ្វើការបំផ្ទុះ។

b) ចំពោះទីកន្លែងរក្សាប្រភេទរំសេវទុកមួយរយៈខ្លី គឺជ្រើសរើសយកជាទីកន្លែងមានសុវត្ថិភាពពុំមានគ្រឿងចក្រការដ្ឋានរ៉ែឬរថយន្តឆ្លងកាត់ និងដាកព័ទ្ធជារបង និងលើកផ្លាក សញ្ញា「ហាមចូល」「ហាមប្រើភ្លើង」។

(3) វិធានការទប់ស្កាត់គ្រោះថ្នាក់តាមរយៈប្រភេទនៃរំសេវ

1) ទប់ស្កាត់ការផ្ទុះ

a) បរិក្ខារផ្ទុកប្រភេទរំសេវ ជារបស់មិនមានចរន្តឆ្លងកាត់បាន និងផ្ទៃខាងក្នុងមិនបង្ហាញពីសារធាតុលោហៈ។

b) ចំពោះគីបអគ្គិសនី បរិក្ខារភ្លើងនិងរំសេវផ្ទុះ ត្រូវដាក់នៅក្នុងបរិក្ខារផ្ទុកអោយដាច់ដោយឡែកពីគ្នា។

(4) វិធានការនៅទីកន្លែងការងារប្រើប្រភេទរំសេវ (រួទាំងទីកន្លែងទុកមួយរយៈ)

1) ហាមប្រើប្រាស់ភ្លើង។

2) ហាមទុកនៅទីកន្លែងដែលមិនត្រូវការទុកដាក់ការប្រើប្រាស់ប្រភេទនៃរំសេវ។

3) បើអ្នកគ្មានសញ្ញាប័ត្រនៃការប្រើប្រាស់ប្រភេទរំសេវទេ មិនអាចអោយប្រើប្រាស់ប្រភេទនៃរំសេវបានទេ។

（5）វិធានការសុវត្ថិភាពនៅពេលធ្វើការបំផ្ទុះ

1）អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះ ត្រូវភ្ជាប់គីបអគ្គិសនីនឹងសារធាតុនៅទីកន្លែងមានសុវត្ថិភាព។

2）ព្រមានដល់អ្នកធ្វើការងារនៅក្បែរការងារធ្វើការបំផ្ទុះ និងជន្លៀសទៅកន្លែងមានសុវត្ថិភាព។

3）ដាក់មនុស្សអោយចាំមើល និងបញ្ជាក់នូវពីសុវត្ថិភាព ព្រមទាំងបញ្ចេញ「សញ្ញាបំផ្ទុះ」។

4）អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះ ចុងកាត់បំផ្ទុះនៅទីកន្លែងមានសុវត្ថិភាព។

5）ក្រោយពីការបំផ្ទុះ អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះ ធ្វើការផ្តាច់ខ្សែមេពីកុងតាក់បំផ្ទុះ រងចាំរយៈពេលក្រោយ៥នាទី ហើយបើតាមវិធីផ្សេងទៀតត្រូវរងចាំអោយបានលើសពី១៥នាទី ទើបចូលធ្វើការត្រួតពិនិត្យតើមានឬមិនមានសុវត្ថិភាព។

（6）វិធានការសំរាប់ទប់ស្កាត់នូវគ្រោះថ្នាក់តាមរយៈប្រភេទរំសេវនៅពេលមិនផ្ទុះ

1）នៅពេលមិនផ្ទុះក្រោយពីចុចកុងតាក់រួចដោយប្រភេទរំសេវដែលបានញាត់ចូល ឬនៅពេលមានភាពលំបាកបញ្ជាក់ពីការផ្ទុះ មានវិធានការដូចខាងក្រោម៖

a) ក្រោយពីដកខ្សែមេចេញពីបរិក្ខារចុចកុងតាក់ ចំពោះរូងមិនផ្ទុះនោះញាត់រំសេវចូលបន្ថែម និងធ្វើការបំផ្ទុះជាថ្មី។

b）យោងតាមសំពាធខ្យល់បាញ់ចូលឬតាមការបាញ់ទឹកចូលទៅក្នុងរូង ដើម្បីប្រមូលប្រភេទនៃរំសេវមិនផ្ទុះឡើងវិញ។

c) រូងខួងរុន្ធថ្មីមួយទៀត ដែលមានគំលាតលើសពី０．５mស្របនឹងរុន្ធចាស់ រួចធ្វើការបំផ្ទុះ។

d) នៅពេលប្រមូលប្រភេទរំសេវមិនផ្ទុះមិនបាន ធ្វើការកាយដោយដៃ និងអនុវត្តតាមវិធីមានសុវត្ថិភាព។

（7）វិធានការចំពោះការបាត់ឬចោរកម្ម

1）ហាមមិនអោយអ្នកមិនពាក់ព័ន្ធឬអ្នកមិនមានសញ្ញាប័ត្រប្រើប្រភេទរំសេវ ចូល។

2）ស្តីពី ការបាត់ប្រភេទរំសេវ ចោរកម្មនិងនៅពេលមានគ្រោះថ្នាក់ផ្សេងៗ អនុវត្តតាម「ផែនទីនៃរចនាសម្ព័ន្ធទាក់ទងនៅពេលមានអសន្ន」ដែលមានកំណត់នៅទំព័រផ្សេងទៀត អ្នកគ្រប់គារងារទទួលបន្ទុកប្រភេទរំសេវ ឬអ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំផ្ទុះត្រូវរាយការណ៏ដល់ អ្នកគ្រប់គ្រងសុវត្ថិភាពរួម ឬអ្នកគ្រប់គ្រងបច្ចេទេសសុវត្ថិភាពជាបន្ទាន់ពីការងារនោះ ព្រមទាំងធ្វើការរាយការណ៏ដល់អគ្គនាយកដ្ឋានធនាធានរ៉ែឬដល់ស្ថាប័នរដ្ឋបាលពាក់ព័ន្ធផ្សេងទៀត។

## 6－4　រថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត

（1）ចំពោះរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែប្រភេទយានយន្ត នៅពេលប្រើប្រាស់ ត្រូវគោរពតាមចំ

ចំនុចមានដូចខាងក្រោម៖

១) នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់កើតឡើងតាមរយៈផ្ទាំងថ្មធ្លាក់ និងថ្មរលំ។ល។ តើមានរៀបចំhead guard អោយមានរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ។

២) មុនចាប់ផ្តើមធ្វើការងារ តើមានធ្វើការត្រួតពិនិត្យរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែដែរ។

៣) ចំពោះរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ តើមានដាក់មនុស្ស, បរិមាណទំនិញលើសពីចំណុះដែលត្រូវបានកំណត់។

4) នៅពេលបញ្ចា ប៉ែលដូក ដង លើកឡើងនៃគ្រឿងចក្រការដ្ឋានរ៉ែ និងការងារត្រួតពិនិត្យជួសជុល តើមានចាត់វិធានការសមរម្យ។ល។ដោយប្រើសរសរជំទ្រសុវត្ថិភាព និងកំណល់សុវត្ថិភាព។

5) ចំពោះរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែ យោងតាមរយៈវិធីនិងល្បឿនសុវត្ថិភាព តើមានការបើកបរគោរពតាមច្បាប់ចរាចរណ៍ទូទៅ។

៦) ចំពោះអ្នកបើកបររថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយានយន្តប្រើប្រាស់នៅការដ្ឋានរ៉ែនៅពេលចាកចេញពីយានទាំងនោះ :

a) ទំលាក់ប៉ែល ដាក់ក្រចកប៉ែលទៅនឹងផ្ទៃដី

b) ពន្លត់ម៉ាស៊ីននិងចាប់ហ្វ្រាំង

c) ដកសោរយកចាប់ខ្លួនកុំអោយអ្នកដ៏ទៃប្រើប្រាស់បាន

7) រចនាសម្ព័ន្ធនៃផ្លូវការដ្ឋានរ៉ែ, តើមានគោរពនូវចំនុចដែលត្រូវបានកំណត់របស់ច្បាប់និងបទបញ្ញតិ។ល។ ដោយចាត់វិធានការ តំឡើងរនាំងទប់ស្កាត់ការធ្លាក់ ផ្លាក់សញ្ញាផ្លូវ ក្រៅពីមានការគិតគូរពីស្ថានភាពនៃផ្លូវរត់របស់រថយន្ត ដោយគ្រឿងចក្រប្រភេទការដ្ឋានរ៉ែ, ស្ថានភាពអាកាសធាតុ, សណ្ឋានដីនៅជុំវិញរបស់ការដ្ឋានរ៉ែ។

## ៦－៥ ការគ្រប់គ្រងធូលីហ៊ុយ នៅក្នុងទីកន្នែងធ្វើការ និងនៅក្នុងរូង

### (១) ផ្លូវដើរនៅក្នុងរូង

១) ចំពោះផ្លូវដើរនៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ដើម្បីអោយមានទំនាក់ទំនងគ្នាបានរវាងផ្នែកខាងក្រោមនៅក្នុងរូងនិងផ្នែកនៅលើដី តើមានបង្កើតអោយមានផ្លូវដើរអោយលើសពី២។

2) ចំពោះជំរេលមានលើសពី40℃ ឬរូងបញ្ឈរសំរាប់ដឹកជញ្ជូនមនុស្ស តាមរយៈបរិក្ខារខារនៅក្នុងការដ្ឋានរ៉ែបិទ តើមានតំឡើងជណ្តើរបញ្ឈរសំរាប់នៅពេលមានអសន្នដែរឬទេ?

3) នៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ករណីអនុវត្តការងារទំលាក់ថ្មរ៉ែ។ល។ចូលទៅក្នុងរូងបញ្ឈរ ដោយប្រើរថយន្តនិងគ្រឿងចក្រការដ្ឋានរ៉ែបែបយាន ត្រូវមានចាត់វិធានការសមរម្យដោយប្រើ

កំណល់សំរាប់កង់យានកុំអោយរអិលធ្លាក់។

4） នៅក្នុងការដ្ឋានរ៉ែបិទមានរូងទ្រេតមានជំរេលលើសពី40℃ ឬរូងបញ្ឈរដែលលែងត្រូវការប្រើ ក្រៅពីលើកផ្លាកសញ្ញាសំរាប់ទប់ស្កាត់ការធ្លាក់ តើមានតំឡើងរបង ឬបិទផ្ចិតច្រករូងទាំងនោះ។

5） នៅក្នុងការដ្ឋានរ៉ែបិទ ចំពោះចំនុចនៃផ្លូវខ្វែងនៃផ្លូវដើររបស់កម្មកររ៉ែ និងទីកន្លែងសំខាន់ផ្សេងៗទៀត បានដាក់ឈ្មោះទីកន្លែងទាំងនោះ និងតើមានបង្ហាញទិសដៅនៃច្រកចេញ។

6） នៅទីកន្លែងធ្វើការងារជីកយកថ្មនៅក្នុងរូង នៅពេលធ្វើការខួងទៅក្បែររូងចាស់ក្នុងរង្វង់50mឬចំពោះប្រភពទឹក ឬទីកន្លែងអាចនឹងមានគ្រោះថ្នាក់ដោយសារមានឧស្ម័នច្រើន ឬទឹកលេចចេញច្រើន ត្រូវចាត់វិធានការសមរម្យឬខួងទុកជាមុន។

7） នៅទីកន្លែងធ្វើការងារជីកយកថ្មនៅក្នុងរូង នៅពេលអាចនឹងមានគ្រោះថ្នាក់តាមរយៈទឹកចេញច្រើន ត្រូវតំឡើងទំនប់ទប់ទឹកអោយបានសមរម្យ។

（2） ទីកន្លែងធ្វើការងារនៅក្នុងរូង

1） ស្តីពីទីកន្លែងធ្វើការងារនិងឈ្មោះកម្មកររ៉ែធ្វើការនៅក្នុងរូង នៅពេលចូលទៅក្នុងរូងធ្វើការបញ្ជាក់ ពីឈ្មោះនិងកត់ត្រាឈ្មោះទាំងនោះនៅការិយាល័យនៅលើដី។

2）ចំពោះទីកន្លែងធ្វើការងារសំខាន់ៗនិងកន្លែងផ្សេងទៀត ត្រូវតំឡើងបរិក្ខារទំនាក់ទំនងជា វិទ្យុទាក់ទងនិងទូរស័ព្ទ។ល។

（3） ការគ្រប់គ្រងធូលីហ៊ុយនៅក្នុងរូង

1） ចំពោះទីកន្លែងធ្វើការមានធូលីហ៊ុយច្រើននៅក្នុងរូងនៃការដ្ឋានរ៉ែបិទ ដើម្បីទប់ស្កាត់ធូលីហ៊ុយនៅក្នុងរូង តើមានបាចទឹកសំរាប់រក្សាសុខភាពកម្មកររ៉ែ និងចាត់វិធានការសមរម្យផ្សេងៗទៀតសំរាប់ធូលីហ៊ុយ។

2） នៅទីកន្លែងមានធូលីហ៊ុយច្រើន ចំពោះករណីចាំបាច់សំរាប់សុវត្ថិភាព តើមានអោយប្រើម៉ាសទប់ស្កាត់ធូលីត្រូវនឹងស្តង់ដាដល់កម្មកររ៉ែ។

3） នៅទីកន្លែងធ្វើការមានធូលីហ៊ុយច្រើន នៅពេលអោយកម្មកររ៉ែឈប់សំរាក តើមានអោយកម្មកររ៉ែសំរាកនៅទីកន្លែងដែលពុំមានធូលីហ៊ុយ។

4）នៅពេលប្រើខួងបុកបំបែក នៅទីកន្លែងធ្វើការនៅក្នុងរូង ហើយម៉ាស៊ីនខួងនោះជាម៉ាស៊ីនខួងបែបប្រភេទសើម តើមានអោយកម្មកររ៉ែប្រើម៉ាស៊ីននោះ ពាក់ម៉ាសត្រូវនឹងស្តង់សុវត្ថិភាព។

5）អ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពក្នុងរូង ស្តីពីទីកន្លែងមានធូលីហ៊ុយច្រើនធ្វើការវាស់ពីអត្រាអាស៊ីតសីលីកាតនៅក្នុងធូលីនោះ និងកំហាប់ធូលីនៅក្នុងខ្យល់តាមការកំណត់ តើមានធ្វើការកត់ត្រានូវលទ្ធផលទាំងនោះ ព្រមទាំងរាយការណ៍ដល់អ្នកគ្រប់គ្រង។

6 — 6　ការគ្រប់គ្រងធូលីហ៊ុយនិងទីកន្លែងធ្វើការងារ ផ្លូវដើរនៅក្រៅរូង

（1）ទីកន្លែងធ្វើការងារនិង ផ្លូវដើរនៅក្រៅរូង

1 ） ពោះជណ្តើរត្រូវបានបង្កើតនៅក្នុងអគារនៅក្រៅរូង តើចំនុចត្រូវបានគោរពមានដូចខាងក្រោម ដែលត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញតិ។

a) ជារចនាសម្ព័ន្ធរឹងមាំ។

b) ចំពោះថាសជណ្តើរនិងផ្នែកាំជណ្តើរ ត្រូវបានតំឡើងនៅក្នុងគំលាតស្មើៗ។

c) នៅពេលមានកំពស់លើសពី10m ត្រូវតំឡើងថាសជណ្តើរសមរម្យក្នុងប្រវែង10m មួយ។

d) ត្រូវតំឡើងបង្កាន់ដៃម្ខាងនៃជណ្តើរ។

2） នៅក្រៅរូងមានកម្មកររ៉ែធ្វើការមានលើសពី៣០នាក់ ចំពោះបន្ទប់នៅក្រោមដីឬអគារមានលើសពី២ជាន់ឡើង តើមានតំឡើងជណ្តើរលើសពី២សំរាប់ឆ្លងទៅកាន់ទីកន្លែងសុវត្ថិភាពនៅក្រៅអគារបានដោយស្រួលដែរឬទេ។

3） ចំពោះនៅជុំវិញផ្លូវមានទ្រង់ទ្រាយជាស្ពាន ជើងទំរ ជំណើ្តរដែលត្រូវបានតំឡើងនៅក្រៅរូង។

4）ចំពោះផ្ទៃបាតនៃទីកន្លែងធ្វើការនៅក្រៅរូង ត្រូវមានរក្សាបាននូវស្ថានភាពសុវត្ថិភាព មានរចនាសម្ព័ន្ធមិនគ្រោះថ្នាក់តាមរយៈ ការជំពុប រអិល។ល។

5）ចំពោះនៅក្នុងទីកន្លែងធ្វើការងារ និងទីកន្លែងឆ្លងកាត់ទៅទីកន្លែងធ្វើការងារនៅក្រៅរូង ត្រូវមានតំឡើងផ្លូវដើរសុវត្ថិភាពសំរាប់កម្មកររ៉ែ។

6）ចំពោះនៅក្នុងទីកន្លែងធ្វើការងារនៅក្រៅរូង ចំពោះផ្នែកមានគ្រោះថ្នាក់មានបរិក្ខាររឹលតាមរយៈខ្សែកាប ច្រវាក់ ឬខសែពាន ព្រមទាំងផ្នែកពូលីឬអ័ក្សដែលមានកំពស់ពីផ្ទៃដីក្រោមប្រវែង២ម៉ែត្រ ត្រូវតំឡើងបរិក្ខារសុវត្ថិភាពដូចជា របង គ្រប។ល។

（2）ការគ្រប់គ្រងធូលីហ៊ុយ នៅក្រៅរូង

1 ）អគារត្រូវបានកំណត់ដោយច្បាប់និងបទបញ្ញតិ ដូចជាទីកន្លែងកិនថ្មដែលមានធូលីហ៊ុយច្រើន រទេះចាក់ថ្មរ៉ែ ទីកន្លែងជ្រើសរើសរ៉ែ ទីកន្លែងរំលាយរ៉ែ ទីកន្លែងលាងធ្យូងថ្ម និងទីកន្លែងជីកយករ៉ែបែបការដ្ឋានរ៉ែបើក តើទីតាំងទាំងនោះមានត្រូវបានចាត់វិធានការសមរម្យដោយមានការបិទផ្ជិតចំពោះបរិក្ខារឬម៉ាស៊ីនទាំងនោះ ប៉ូបធូលី បាចទឹកសំរាប់ការពារកម្មកររ៉ែតាមរយៈទប់ស្កាត់ធូលីហ៊ុយ។

2）ចំពោះទីកន្លែងធ្វើការងារត្រូវនឹងចំនុច1）ដែលបានសរសេរដូចខាងលើ ករណីមានភាពចាំបាច់សំរាប់សុវត្ថិភាព ត្រូវអោយកម្មកររ៉ែប្រើម៉ាសធូលីដែលត្រូវនឹងស្តង់ដា។

3） ចំពោះទីកន្លែងធ្វើការងារត្រូវនឹងចំនុច1）ដែលបានសរសេរដូចខាងលើ ដើម្បីការពារសុខភាពរបស់កម្មកររ៉ែ ត្រូវតំឡើងទីកន្លែងសំរាកនៅទីកន្លែងក្រៅពីទីកន្លែងធ្វើការ។ លើសពីនេះ ចំពោះទីកន្លែងសំរាកខាងលើ ត្រូវមានបំពាក់សំភារៈដែលអាចយកធូលីជាប់នៅនឹងសំលៀកបំពាក់កម្មកររ៉ែបាន។

4) អ្នកគ្រប់គ្រងការងារទទួលបន្ទុកបំផ្ទុះនិងសុវត្ថិភាពក្រៅរូង ស្តីពីទីកន្លែងមានធូលីហ៊ុយខ្លាំង នៅទីកន្លែងធ្វើការនៅក្នុងបន្ទប់ក្រៅរូង ធ្វើការវាស់នូវអត្រាភាគរយសារធាតុអាស៊ីតស៊ីលីស៊ីតនៅក្នុងធូលី និង កំហាប់នៃធូលីនៅក្នុងខ្យល់ដែលត្រូវបានកំណត់ដោយច្បាប់ ត្រូវធ្វើការរាយការណ៍ចំពោះគ្រប់គ្រងព្រមទាំងកត់ត្រានូវលទ្ធផលទាំងនោះ។

5) ចំពោះទីកន្លែងធ្វើការងារប្រើកំដៅក្តៅខ្លាំងនិងមានបរិមាណច្រើន ដូចជានៅឡវិល ឡដុតរំលាយនៅការដ្ឋានរ៉ែ ត្រូវចាត់វិធានការសមរម្យទប់ស្កាត់គ្រោះថ្នាក់តាមរយៈការបញ្ចៀសកំដៅឬការផ្ទុះរបស់វា ។

6) ដើម្បីទប់ស្កាត់គ្រោះថ្នាក់តាមរយៈការរលាក។ល។ ចាំបាច់ត្រូវអោយអ្នកមានសញ្ញាប័ត្រធ្វើការងារដុតរំលាយរបស់ទាំងនោះ ព្រមទាំងបំពាក់នូវបរិក្ខារការពារដូចជាស្បែកជើងសុវត្ថិភាព ស្រោមដៃសុវត្ថិភាព។ល។

7) ចំពោះទីកន្លែងផ្សា ត្រូវអោយអ្នកមានសញ្ញាប័ត្រធ្វើការងារនោះ ព្រមទាំងបំពាក់នូវបរិក្ខារការពារដូចជាស្រោមដៃ វ៉ែនតាការពារ។ល។

8) នៅពេលធ្វើការត្រួតពិនិត្យឬជួសជុលគ្រឿងចក្រ ចាំបាច់ត្រូវផ្អាក់ប្រើគ្រឿងចក្រទាំងនោះសិន អ្នកដែលត្រូវបានទទួលបញ្ជាពីសំណាក់អ្នកគ្រប់គ្រងការងារឬអ្នកគ្រប់គ្រងការងារទទួលបន្ទុកសុវត្ថិភាពគ្រឿងចក្រ ត្រូវបញ្ឈប់ដំណើរការគ្រឿងចក្រទាំងនោះ និងលើកផ្លាកសញ្ញាប្រយ័ត្ន ព្រមទាំងចាក់សោរ និងចាត់វិធានការដ៏ទៃទៀតសំរាប់កុំអោយអ្នកដ៏ទៃអាចបើកបរគ្រឿងចក្រទាំងនោះបាន។

6-7 ការចំរាញ់ទឹកកខ្វក់រួមមានសារធាតុពុលនិងសារធាតុបំផ្លាញសុខភាពព្រមទាំងការប្រើប្រាស់សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព

(1) វិធានការសំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែ

1 ) នៅពេលប្រើប្រាស់សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវតែអោយប្រើស្រោមដៃការពារ ស្បែកជើងសុវត្ថិភាព សំលៀកបំពាក់ការពារ ម៉ាស់ការពារជាតិពុល វ៉ែនតាការពារ ជាដាច់ខាត។

2) ត្រូវរក្សាទុកសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ដោយបែងចែកដាច់ដោយឡែកពីគ្នា។

3) ចំពោះស៊ីទែន ធុង និងប្រដាក់សារធាតុពុល សារធាតុបំផ្លាញសុខភាព និងប្រដាប់ដាក់ផ្សេងទៀត ត្រូវធ្វើយ៉ាងណាកុំអោយមានការក្រឡុកចេញ លេចចេញ ហូរចេញ ឬជ្រាបចេញសារធាតុពុលបំផ្លាញសុខភាពដែលនឹងអាចមានគ្រោះថ្នាក់។

4) ចំពោះបរិក្ខាររក្សាដាក់សារធាតុពុលបំផ្លាញសុខភាពនៅក្នុងការដ្ឋានរ៉ែ ត្រូវមានជារចនាសម្ព័ន្ធចាក់សោរ ដើម្បីទប់ស្កាត់ភាពចោរកម្ម។

5) បើក្នុងករណីមិនអាចធ្វើការចាក់សោរបានតាមរយៈអគាររក្សាទុកនូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាពបានទេ ចំពោះនៅជុំវិញទីនោះ ត្រូវមានតំឡើងនូវរបងរឹងមាំ។

6）ត្រូវកំណត់អ្នកទទួលខុសត្រូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ចំពោះអ្នកគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវធ្វើការកត់ត្រាយ៉ាងល្អិតល្អន់នូវការប្រើ សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព និងធ្វើការគ្រប់គ្រងយ៉ាងម៉ឹងម៉ាត់បំផុត។

7）នៅពេលចំរាញ់ទឹកកខ្វក់រួមទាំងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវគោរពតាមស្តង់នៃការបញ្ចេញទឹកកខ្វក់នៅពេលធ្វើការបង្ហូរទឹកកខ្វក់ទាំងនោះទៅក្នុងទន្លេពីអគារចំរាញ់ទឹកកខ្វក់។

（2）វិធានការតប់ទល់ជាបន្ទាន់

1）ពោះករណីមាន ហើរ លេច ហូរចេញ ជ្រាបចេញ ឬជ្រាបចូលទៅក្នុងដី ដោយសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព នៅពេលអាចនឹងមានគ្រោះថ្នាក់លើផ្នែកអាម័យសុខភាពចំពោះមនុស្សជាច្រើនឬមិនកំណត់មិនបាន ត្រូវ រាយការណ៏ដល់អគ្គនាយកដ្ឋានធនធានរ៉ែ ភ្នាក់ងារសុខភាព ប៉ូលីស ឬភ្នាក់ងារពន្លត់អគ្គិភ័យពីការងារទាំងនោះ ព្រមទាំងចាត់វិធានការបន្ទាន់ចាំបាច់សំរាប់ទប់ស្កាត់នូវគ្រោះថ្នាក់លើផ្នែកសុខភាពអនាម័យ។

2）នៅពេលមានការបាត់បង់ឬមានអំពើរចោរកម្មដល់សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវរាយការណ៏ជាបន្ទាន់ដល់ស្ថានីយ៏ប៉ូលីសព្រមទាំងទាក់ទងទៅនឹងអគ្គនាយកដ្ឋានធនធានរ៉ែ។

（3）ផ្សេងៗ

ស្តីពីស្តង់ដាគ្រប់គ្រងទាក់ទងនឹងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវយោងតាម「ស្តង់ដានៃការគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព」។

## 6－8　ការប្រើប្រាស់ភ្លើង

（1）វិធានការសំរាប់ទប់ស្កាត់អគ្គិភ័យ

1）ការប្រើភ្លើង

a) ហាម「ប្រើអណ្តាតភ្លើង」 ក្នុងគំលាត 8 m ចំពោះតំបន់ដែលអាចមានអគ្គិភ័យនិងការផ្ទុះកើតឡើង។

ក៏ប៉ុន្តែ ចំពោះអគារអាចនឹងមានគ្រោះថ្នាក់ដោយការផ្ទុះឬអគ្គិភ័យតាមរយៈការឆេះរាលដាល ដូចជាទីកន្លែងស្តុកប្រេងឥន្ទនៈ ទីកន្លែងផ្គត់ផ្គងប្រេងឥន្ទនៈ បន្ទាប់កុំប្រែស័រ អគារផលិតឧស្ម័នមានសំពាធខ្ពស់។

b) វិធានការសំរបសំរួល

មានការយកតាមវិធានការសុវត្ថិភាពនីមួយៗដែលមានដូចខាងក្រោម នៅពេល អ្នកគ្រប់គ្រងសុវត្ថិភាពរួម ទទួលស្គាល់វិធានការទាំងនោះ អាចទទួលវិធានការសំរបសំរួលបាន។

① ក្នុងករណីបានតំឡើងជញ្ជាំងមានកំពស់គ្រប់គ្រាន់ហើយមានចំងាយលើសពី 8 m ឡើងនៃគំលាតរវាងអគារប្រើប្រាស់ភ្លើង។

② ក្នុងករណីបានចាត់វិធានការអោយឈប់ប្រើភ្លើងដោយស្វ័យប្រវត្តិ ដូចជាបរិក្ខារចាប់ឧស្ម័នលេច ការតំឡើងបរិក្ខាររោទិ៍ ចំពោះឧស្ម័ននៅក្បែរអគារប្រើភ្លើងនោះ។

③ ក្នុងករណីបានបានប្រើទ្វារទប់ស្កាត់ភ្លើងនូវច្រកបើកនៃអគា ការតំឡើងប្រើនូវសារធាតុមិនឆេះចំពោះអគារប្រើប្រាស់ភ្លើង។

2）វិធានការទាក់ទងនឹងការស្តុកសារធាតុឆេះនិងប្រភេទខ្លាញ់

a) ចំពោះការស្តុកសារធាតុឆេះនិងប្រភេទខ្លាញ់ ត្រូវរក្សាអោយបានគំលាតចាំបាច់ពីមាត់រូងឬពីអគារសំណង់ផ្សេងៗ។

b) ចំពោះប្រភេទខ្លាញ់ ត្រូវរក្សាទុកនៅក្នុងបរិក្ខារបិទជិត។

3）វិធានការនៅពេលតំឡើងបំពង់ផ្សែងឬផ្លូវសំរាប់ផ្សែង

a) ពោះបំពង់ផ្សែងឬផ្លូវសំរាប់ផ្សែង ត្រូវជារចនាសម្ព័ន្ធដែលអាចងាយធ្វើការត្រួតពិនិត្យនិងសំអាតផ្នែកខាងក្នុងបាន។

b) ចំពោះអគារគ្មានជញ្ជាំង ត្រូវពាក់វែនតាការពារ ឬការពារដោយសារធាតុផ្តាច់។

c) ចំពោះច្រកទ្វានៃបំពង់ផ្សែងឬផ្លូវសំរាប់ផ្សែង ត្រូវមានគំលាតលើស១ម៉ែត្រឡើងពីអគារ។

4）វិធានការផ្សេងៗ

a) ចំពោះសារធាតុមានភាពឆេះ ធ្វើការការពារដោយសារធាតុធុននឹងកំដៅ។

b) ស្តីពីកំទេចក្រដាស់ rag ។ល។ដែលជ្រាបដោយខ្លាញ់ ត្រូវផ្ទុកក្នុងបរិក្ខារដែលមិនឆេះនិងមានគំរប។

c) ការប្រើភ្លើង។ល។ក្នុងរយៈពេលខ្លីនៅពេលខ្លី

ករណីប្រើភ្លើងដោយជៀសមិនផុតតាមរយៈការសាងសង់។ល។ នៅក្នុងប្រវែង8mពីអគារអាចនឹងមានគ្រោះថ្នាក់ដោយការផ្ទុះឬអគ្គិភ័យតាមរយៈភ្លើងឆេះ ត្រូវរាយការណ៍ជាមុននូវ「លិខិតអនុញ្ញាតប្រើភ្លើងបណ្តោះអសន្ន」ដល់អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពនិងទទួលការអនុញ្ញាត។

ប្រើក្នុងនាមជាចំនុចគោរពនៃពេលប្រើភ្លើងបណ្តោះអសន្ន៖

① ចំពោះក្នុងការប្រើភ្លើង ត្រូវកាន់ជាប់ខ្លួននូវ「លិខិតអនុញ្ញាតប្រើភ្លើងបណ្តោះអសន្ន」និងបង្ហាញលិខិតនេះ។

② មុនចាប់ផ្តើមប្រើភ្លើង ត្រូវធ្វើការពិនិត្យឧស្ម័ននៅក្បែរទីនោះជាមុន ព្រមទាំងបញ្ជាក់នូវកំរិតសុវត្ថិភាពនៃកំហាប់ឧស្ម័ន។

③រៀបចំនូវបរិក្ខារពន្លត់អគ្គិភ័យ និងឧបករណ៍ពន្លត់អគ្គិភ័យ។

d) គ្រឿងចក្រការដ្ឋានរ៉ែបែបជាយានប្រើភ្លើង នៅក្នុងរង្វង់៨ម៉ែត្រពីអគារ ដែលអាចនឹងមានការផ្ទុះឬអគ្គិភ័យកើតឡើងតាមរយៈភ្លើង ជាគោលការណ៍គឺមិនប្រើ។

ក៏ប៉ុន្តែ ចំពោះករណីចូលទៅក្បែរក្នុងប្រវេង៨ម៉ែត្រដោយជៀសមិនបាន ត្រូវបំពាក់បរិក្ខារ

ទប់ស្កាត់ភ្លើងផ្លាតមកវិញចំពោះសំបុកបំពង់ស៊ីម៉ាំង មុនចូលទៅជិតត្រូវបញ្ជាក់ពីសុវត្ថិភាពកំហាប់ឧស្ម័នជាតិឆេះជាមុន។

（2）វិធានការសំរាប់ទប់ស្កាត់គ្រោះថ្នាក់រីករាលដាល

1）គំលាតនៃការភៀសខ្លួន

នៅពេលតំឡើងថ្មីឬផ្លាស់ប្តូរអគារប្រើសំរាប់អាជីវកម្មរ៉ែ ចំពោះគំលាតនៃអគារសំខាន់ៗដែលមានលើសពី២ឡើង និងរវាងនៃខ្សែព្រំប្រទល់ជិតខាងនិងអគារសំខាន់ៗ ត្រូវរក្សានូវគំលាតចាំបាច់(អោយបានលើសពី1. 5m)សំរាប់ការភៀសខ្លួន។

2）គំលាតនៃការទប់ស្កាត់ភ្លើង

ចំពោះរវាងនឹងសារធាតុឆេះផ្សេង អគារនិងបរិក្ខារគ្រោះថ្នាក់កើតនូវអគ្គិភ័យផ្សេងដូចជាបំពង់ផ្សែង បរិក្ខារបង្កើនកំដៅ ឡដុត ត្រូវរក្សានូវគំលាតចាំបាច់សំរាប់ទប់ស្កាត់ភ្លើង។

3）ដាក់បែងចែកបរិក្ខារពន្លត់អគ្គិភ័យ

a) នៅក្នុងអគារនៃការដ្ឋានរ៉ែ ទីកន្លែងត្រូវបានអនុញ្ញាតប្រើភ្លើង នៅទីកន្លែងទទួលនូវការអនុញ្ញាតប្រើភ្លើងបណ្តោះអសន្ន នៅពេលធ្វើការងារផ្សាកាត់ឬផ្សាភ្ជាប់តាមរយៈអណ្តាតភ្លើងឬអគ្គិសនី ត្រូវបំពាក់នូវ បរិក្ខារពន្លត់អគ្គិសនី ឧបករណ៏ពន្លត់អគ្គិសនី។ល។នៅក្បែរទីនោះ។

b) នៅការដ្ឋានរ៉ែASEAN រឆ្លើយតបឆ្លើយតបនឹងទំហំនៃអគារ ត្រូវតំឡើងនូវ បំពង់ទុយោតពន្លត់អគ្គិភ័យ ឧបករណ៏ពន្លត់អគ្គិភ័យ អាងស្តុកទឹក និងបរិក្ខារអគ្គិភ័យផ្សេងៗទៀត។

4）រចនាសម្ព័ន្ធទប់ស្កាត់ភ្លើង

ចំពោះបន្ទប់កុំប្រែស័រ និងបរិក្ខារទទួលចរន្ត ត្រូវជារចនាសម្ព័ន្ធទប់ស្កាត់ភ្លើង។

5）ស្តីពីការប្រើភ្លើងផ្សេងទៀត

a) តំឡើងផ្លាកសញ្ញាប្រយ័ត្ន

ចំពោះតំបន់ហាមឃាត់ប្រើភ្លើងច្រើនអាចនឹងផ្ទុះ ឬឆេះ ត្រូវតំឡើងផ្លាក់សញ្ញា។ល។「ហាមឃាត់ការប្រើភ្លើង」 ជំរុញអោយកម្មកររ៉ែប្រយ័ត្ន។

b) ទីកន្លែងជក់បារី

① ចំពោះការជក់បារី ធ្វើការហាមឃាត់ជីកបារីក្រៅពីកន្លែងហាមឃាត់។

② ចំពោះការជក់បារីនៅទីកន្លែងធ្វើការងារ របស់ការដ្ឋានរ៉ែ ជាកន្លែងកំណត់ជក់បាន ភ្លើងនៅសល់ត្រូវតែពន្លត់ទាំងស្រុង។

c) ការគ្រប់គ្រងប្រភេទខ្លាញ់

① ចំពោះប្រេងឥន្ធនៈនិងប្រភេទខ្លាញ់ ត្រូវរក្សាទុកនៅក្នុងបរិក្ខារធ្វើពីសារធាតុមិនឆេះហើយបិទជិតឬមានគំរប។ ក៏ប៉ុន្តែ មានករណីពិសេសចំពោះប៉ុតបានបែងចែកតូចៗ។

② ពោះការស្តុកឬរក្សាទុកនូវប្រភេទខ្លាញ់ ត្រូវចាត់វិធានការសំរាប់ទប់ស្កាត់ការហូរចេញ។

6－9　　វិធីអនុវត្តការហ្វឹកហាត់នៃការជួយសង្គ្រោះនិងការភៀសខ្លួន

សុវត្ថិភាពបរិស្ថាន ស្ដីពីចំនុចមានដូចខាងក្រោម បង្កើតផែនាករ អនុវត្តតាមពេលវេលាជាប្រចាំដោយសហាករជាមួយនឹងផ្នែកពាក់ព័ន្ធនានា។

(1) អនុវត្តក្នុងពេលជាប្រចាំ (អោយបាន១លើកលើសពី១ឆ្នាំ) នូវការហ្វឹកហាត់ព្រៀងទុកនូវគ្រោះថ្នាក់និងគ្រោះមហន្តរាយនៅការដ្ឋានរ៉ែ។

(2) នៅពេលហ្វឹកហាត់ អនុវត្តហ្វឹកហាត់គៀសខ្លួន និងការសង្គ្រោះ និងពីវិធីប្រើបរិក្ខារសង្គ្រោះ។

(3) ធ្វើការបញ្ជាក់ស្ដីពីភាពអនុវត្តពិតនៃរចនាសម្ព័ន្ធទាក់ទងនៅពេលមានគ្រោះថ្នាក់នៅការដ្ឋានរ៉ែ អនុវត្តហ្វឹកហាត់ ការហៅចេញមកហ្វឹកហាត់នៅថ្ងៃសំរាក់ និងពេលយប់អនុលោមតាមបែបបទវិធានការតបទល់នឹងអគ្គិភ័យ」ដែលមានកំណត់នៅទំព័រផ្សេងទៀត។

(4) ត្រូវខិតខំប្រឹងប្រែងក្រេបយកបច្ចេកទេសគ្រឹះនៃការសង្គ្រោះកម្មកររ៉ែ ប្រើតាមរយៈពិធីធ្វើកម្មសិក្សាអនុវត្តដោយក្រុមពាក់ព័ន្ធនិងភ្នាក់ងារអគ្គិភ័យ។ល។

6－10 ការគ្រប់គ្រងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង

(1) ចំពោះទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag និងទីកន្លែងស្តុកសារធាតុកករង ត្រូវតំឡើងបរិក្ខារសមរម្យដូចជាទំនប់ឬជញ្ជាំងសំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែតាមរយៈការហូរចេញនៃសារធាតុកករង ការបាក់រំលំនៃគំនរដី។

(2) ទីកន្លែងស្តុករបស់កករង ទីកន្លែងស្តុកថ្មចោល ទីកន្លែងស្តុកslag មានចាត់វិធានការមិនសង់នៅទីកន្លែងអាចនឹងមានគ្រោះថ្នាក់ច្រើនកើតឡើងនូវការបំពុលតាមរយៈបាក់រលំ ដីរអិល។ល។។

(3) ចំពោះកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង ត្រូវតំឡើងអោយឃ្លាតឆ្ងាយអោយលើសពី៣០ម៉ែត្រពី ផ្ទះប្រជាជន ការិយាល័យការដ្ឋានរ៉ែ អគារសាធារណៈដូចជាសាលារៀន ទំនប់ ទន្លេ ផ្លូវដែក។ល។

(4) ចំពោះកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង ទីកន្លែងដែលបានប្រើរួច ដើម្បីទប់ស្កាត់ការហូរចេញនូវកាកសំណល់ ឬទឹកកខ្វក់ ត្រូវចាត់វិធានការសមរម្យដូចជាដាំដើមឈើ លុបដីគ្របទំនប់ និងនៅក្នុងទំនប់។

(5) ទីកន្លែងស្តុករបស់កករង តើមានតំឡើងផ្លូវទឹកចេញ នៅបញ្ចៀសទឹកហូរពីភ្នំ ត្រូវត្រៀមការពារកុំអោយ និងទីកន្លែងបញ្ចេញទឹកផ្សេងៗទៀត។

(6) ចំពោះទីកន្លែងស្តុករបស់កករងមានជញ្ជាំងទំនប់ដែលបង្កើតពីដី ដើម្បីតបទល់នឹងគ្រោះថ្នាក់ដោយទឹកហូរពីខាងក្រៅទំនប់មកច្រើន ត្រូវតំឡើងនូវផ្លូវទឹកបញ្ចេញទឹកប្រើសំរាប់ពេលមានអសន្ននៅទីតាំងសមរម្យនៃទីកន្លែងស្តុក។

(7) ស្ថានភាពគ្រប់គ្រងទីកន្លែងស្តុកសារធាតុកករង ឬទីកន្លែងស្តុកថ្មចោល ទីកន្លែងស្តុកslag៖

1) តើមានវិធានការតប់ទល់នឹងពេលមានគ្រោះអសន្នដែរឬទេ? លើសពីនេះ អ្នកទទួលគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន ត្រូវទទួលការហ្វឹកហាត់ដោយធ្វើការស្មានទុកជាមុននៅពេលមានគ្រោះអសន្ន។ល។

2) ស្ថានភាពគ្រប់គ្រងថៃទាំបរិក្ខារប្រើសំរាប់នៅពេលមានគ្រោះអសន្ន មានសភាពត្រឹមត្រូវល្អ។

3) ត្រូវមានវាស់កំពស់ទឹកដែលបានហូរចូលនៅក្នុងទំនប់នៃទីកន្លែងស្តុកសារធាតុកករង។ ស្ថានភាពគ្រប់គ្រងបរិក្ខាវាស់ទាំងនោះ មានភាពល្អត្រឹមត្រូវ។

4) ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំពីទីកន្លែងបញ្ចេញទឹក។

(8) រចនាសម្ព័ន្ធរបស់ទំនប់ទាក់ទងនឹងទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង

1 ) សារធាតុដែលយកមកតំឡើងទំនប់ជាសារធាតុសមរម្យ។ លើសពីនេះ សភាពបង្ហាប់នៅជញ្ជាំងទំនប់មានភាពសមស្របត្រឹមត្រូវល្អ។

2) ទំហំនៃកំពស់ទំនប់មានទំហំគ្រប់គ្រាន់ល្អ។

3) ត្រូវមានបានដាំស្មៅឬគ្របដី ជាបន្ទាន់ក្រោយពីបានសាងសងទំនប់រួច។ លើសពីនេះ ចំពោះផ្ទៃជញ្ជាំងឬជំរេលជញ្ជាំង មានទឹកភ្លៀងហូរស៊ីច្រោះ។

(9) វិធីស្តុករបស់កករងទាក់ទងទីកន្លែងស្តុកសារធាតុកករង

1 ) សារធាតុរាវដែលត្រូវបានដឹកជញ្ជូនតាមបំពង់ មានត្រូវបានបង្ហូរចេញពីបំពង់ពីទិសដៅពីជញ្ជាំងទំនប់ទៅក្នុងទំនប់។

2) សារធាតុរាវដែលត្រូវបានបង្ហូរចូលក្នុងទំនប់ ត្រូវផ្ទៃខាងលើមានសភាពស្មើរគ្នា។

3) កំពស់ទឹកនៅក្នុងទីកន្លែងកករង ត្រូវមានបានរក្សានូវកំពស់១ម៉ែត្រទាបជាងកំពស់ជញ្ជាំងទំនប់។

4 ) ផ្ទៃនៃសារធាតុកករងនៅក្នុងទីកន្លែងស្តុក ត្រូវមានបានរក្សានូវកំពស់ក្រោម៥០សង្ទីម៉ែត្រពីកំពស់ជញ្ជាំងទំនប់។

(10) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន ស្តីពី កន្លែងទុកថ្មចោល ទីកន្លែងស្តុក slag និងទីកន្លែងស្តុកសារធាតុកករង ត្រូវគោរពតាមចំនុចដូចមានខាងក្រោមសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន តាមរយៈសារធាតុកករងហូរចេញ ឬការបាក់ធ្លាយនៅទីនោះ។

1) មានឬមិនមាន ដីរអិល ទីកន្លែងស្តុកថ្មចោលនិងslag ស្ថានភាពជញ្ជាំងទំនប់ឬទំនប់ បាក់ទីកន្លែងស្តុក ធ្វើការដើរល្បាតរាល់ថ្ងៃ និងធ្វើការកត់ត្រាលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) មានឬមិនមានភាពមិនប្រក្រតីចំពោះអគារបញ្ចេញទឹកនៅទីកន្លែងស្តុក និងផ្លូវទឹកប្រើសំរាប់ពេលមានអសន្នៈ ផ្លូវនៅតាមចង្កេះភ្នំ ផ្លូវទឹកសំរាប់បញ្ចេញទឹកពីអូខាងលើ ស្ថានភាពទំនប់ឬជញ្ជាំងទំនប់នៃទីកន្លែងស្តុកសារធាតុកករង។

3) នៅពេលទទួលស្គាល់មានបាតុភូតនៃដីរអិល បាក់រលំ បាកផុងតួរទំនប់ ប្រេះស្រាំផ្ទៃជញ្ជាំងទំបន់នៃទីកន្លែងស្តុកសារធាតុកករងឬទីកន្លែងស្តុកអាចម៍រ៉ែ ទីកន្លែងស្តុកថ្មចោល ធ្វើការចាត់វិធានការតបទល់ជាបន្ទាន់ និងព្រមទាំងធ្វើការរាយការណ៏ដល់អ្នកគ្រប់គ្រង។

(11) នៅពេលមានភ្លៀងធ្លាក់ខ្លាំង នៅតំបន់នៃកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុក

សារធាតុកករង ចាំបាច់ត្រូវបង្កើនការដើរល្បាតចំពោះទីកន្លែងទាំងនោះ ព្រមទាំងធ្វើការពិនិត្យមើលតើមានឬមិនមានភាពមិនប្រក្រតីនៅក្នុងទីកន្លែងបញ្ចេញទឹក និងផ្លូវទឹកសំរាប់បញ្ចេញនៅពេលមានគ្រោះអសន្ន ផ្លូវទឹកតាមចង្កេះភ្នំសំរាប់បញ្ចៀសទឹកកុំអោយចូលក្នុងទំនប់ ផ្លូវទឹកបញ្ចេញទៅទឹកទន្លេ ស្ថានភាពច្រាំងទំនប់ ដីរអិល និងព្រមទាំងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងទាក់ទងនឹងកន្លែងទាំងនោះ។

（１２）នៅពេលមានការបំពុលកើតឡើង និងអាចនឹងមានការបំពុលកើតច្រើន នៅទីកន្លែងទុកថ្មចោល ទីកន្លែងស្តុកslag ឬទីកន្លែងស្តុកសារធាតុកករង អនុលោមតាមការកំណត់របស់ច្បាប់និងបទបញ្ញត្តិ ចំពោះស្ថានភាពគ្រោះថ្នាក់នោះ ខ្លឹមសារនៃវិធានការទប់ទល់នឹងគ្រោះថ្នាក់ ព្រមទាំងនៅពេលបានជួសជុលចប់ព្រមទាំងផែនការនៃការជួសជុលនោះ ស្តីពីខ្លឹមសារទាំងនោះ តើមានបានរាយការណ៍ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែ ឬរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ជាបន្ទាន់។

## 6－１１ ការគ្រប់គ្រងអគារចំរាញ់និងបង្កើតទឹកកខ្វក់ឬទឹកក្នុងរូង

(1) ការធ្វើអោយត្រូវនឹងស្តង់នៃការបញ្ចេញទឹក

ចំពោះទឹកកខ្វក់ឬទឹកក្នុងរូងដែលនឹងត្រូវបានបញ្ចេញទៅតំបន់ទឹកប្រើជាសាធារណៈ ស្តីពីគុណភាពទឹកបញ្ចេញគឺត្រូវធ្វើយ៉ាងណាអោយត្រូវនឹងស្តង់ដានៃការបញ្ចេញទឹកដែលត្រូវបានកំណត់នៅក្នុងការកំណត់មានដូចខាងក្រោម និង「ច្បាប់គ្រប់គ្រងធនធានរ៉ែនិងការពារបរិដ្ឋាន」របស់កម្ពុជា ចំពោះការគ្រប់គ្រងនោះត្រូវតែធ្វើអោយបានម៉ឺងម៉ាត់បំផុត។

(2) វិធានការតប់ទល់ជាបន្ទាន់នៅពេលមានបញ្ហាបំពុលកើតឡើង

នៅក្នុងអគារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូង តើមានចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ចំពោះករណីមានគ្រោះថ្នាក់ ឬចាត់វិធានការទប់ទល់នឹងចំពោះគ្រោះថ្នាក់នោះ ជាបន្ទាន់ នៅពេលមានកើតឡើងនូវការជ្រាបទឹកចូលទៅក្នុងដី ដោយទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមានស្ថានភាពពុល ដែលលមិនត្រូវនឹងស្តង់ដាបានកំណត់ដោយរដ្ឋមន្ត្រីបរិស្ថានឬមានការកើតឡើងនូវគ្រោះថ្នាក់ផ្សេងៗទៀត ដូចជាការខូច បែកបាក់ ការដាច់ចរន្តអគ្គិសនី។ល។

1) ធ្វើការបញ្ឈប់បញ្ចេញទឹកកខ្វក់ឬទឹកក្នុងរូងទៅក្នុងតំបន់ទឹកសារធារណៈ ធ្វើការរក្សាទឹកទាំងនោះនៅក្នុងស្រះឬពីតដែលមាននៅក្នុងការដ្ឋានរ៉ែ។

2) ករណីអាចមានការបំពុលដល់បរិស្ថានខាងក្រៅការដ្ឋានរ៉ែ ត្រូវតែផ្តល់ពត៌មានដល់ប្រជាពលរដ្ឋរស់នៅជុំវិញតំបន់នោះ ផ្តល់ពត៌មានដល់អជ្ញារធរខេត្ត ក្រសួង និងអគ្គនាយកដ្ឋានធនធានរ៉ែ ព្រមទាំងធ្វើការទប់ស្កាត់កុំអោយការរងគ្រោះនោះមានការរីកដុះដាលថែមទៀត។

(3) កំហិតនៃខ្លឹមសារសំរាប់ការអនុញ្ញាតនិងកំរិតញឹកញាប់នៃការវាស់

ចំពោះកំហិតនៃខ្លឹមសារសំរាប់ការអនុញ្ញាតនិងកំរិតញឹកញាប់នៃការវាស់ ចំពោះទឹកដែលបានហូរចេញពីការដ្ឋានរ៉ែ ត្រូវធ្វើការវាស់តាមស្តង់ដាដែលត្រូវបានកំណត់តាមបញ្ញតិពាក់ព័ន្ធទាំងឡាយនិងតាម「ច្បាប់គ្រប់គ្រងធនធានរ៉ែនិងការពារបរិដ្ឋាន」របស់កម្ពុជា។

លើសពីនេះ ស្តីពីលទ្ធផលវិភាគគុណភាពទឹក ត្រូវរក្សាអោយបានក្នុងរយៈពេល៣ឆ្នាំ។

（4） ការគោរពតាមវិធានការដាក់បន្ថែមលើស្តង់ដាបានកំណត់រួច

ក្នុងករណីបានទទួលបញ្ជាអោយចាត់វិធានការអោយធ្វើអោយត្រូវនឹងស្តងដាដែលបានកំណត់សំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់ ឬទឹកនៅក្នុងរូង ដោយរដ្ឋមន្ត្រីទទួបន្ទុកការងាររ៉ែ តើការដ្ឋានរ៉ែនោះបានគោរពតាមបញ្ជាទាំងនោះ។

（5） នៅពេលបានបញ្ចប់ការងារសាងសង់ជួសជុល និងខ្លឹមសារនៃវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និងស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់កើតឡើងពីការបំពុល ឬការកើតឡើងបញ្ហាបំពុលបរិដ្ឋានដែលល្មើសនឹង「ច្បាប់គ្រប់គ្រងធនធានរ៉ែនិងការពារបរិដ្ឋាន」របស់យោងតាមរយៈការបញ្ចេញទឹកកខ្វក់ឬទឹកនៅក្នុងរូងដែលមិនត្រូវនឹងស្តង់ដាបានកំណត់ទប់ស្កាត់ធ្វើអោយគុណភាពទឹកមានភាពល្អក់ ស្តីពីខ្លឹមសារទាំងនោះ តើមានបានរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែ ឬរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។

（6） អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំពុលបរិដ្ឋាន ដើម្បីទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈទឹកកខ្វក់និងទឹកនៅក្នុងរូង ត្រូវមានគោរពតាមចំនុចដែលមានដូចខាងក្រោម៖

1） ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារចំរាញ់ទឹកកខ្វក់និងទឹកក្នុងរូង និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2） ស្តីពីស្ថានភាពបំពុលនិងបរិមាណទឹកកខ្វក់និងទឹកនៅក្នុងរូងដែលចាំបាច់ត្រូវការវាស់ និងតាមដាន ត្រូវធ្វើការវិភាគនិងវាស់ជាប្រចាំ និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

3） លទ្ធផលនៃការវិភាគនិងវាស់ឬការដើរល្បាត នៅពេលអាចនឹងមានគ្រោះថ្នាក់កើតឡើងច្រើននៅអគារចំរាញ់ទឹកកខ្វក់ឬទឹកនៅក្នុងរូងតាមរយៈស្ថានភាពផ្សេងៗ ការខូច ការដាច់ចរន្ត ភ្លៀងខ្យល់ មានច្រើនដែលបណ្តាលអោយមានការបំពុលតាមទឹកកខ្វក់ឬទឹកក្នុងរូង ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រង។

## 6－12 ការគ្រប់គ្រងអគារបង្កើតសំឡេងថ្លង់និងអគារទប់ស្កាត់សំឡេងថ្លង់

（1） ករណីត្រូវបានកំហិតនូវសំឡេងថ្លង់ពីការដ្ឋានរ៉ែ ដែលមានតំឡើងអគារបង្កើតសំឡេងថ្លង់ដែលមានដូចខាងក្រោម នៅខ្សែបន្ទាត់ព្រំប្រទល់ផ្នែកខាងក្រៅការដ្ឋានរ៉ែ ត្រូវមិនអោយកើតនូវសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដាកំហិតសំឡេងថ្លង់។

1） ម៉ាស៊ីនបែងចែក ម៉ាស៊ីនខាត (រ៉ែ) ម៉ាស៊ីនបំបែកប្រើសំរាប់ថ្មរ៉ែ ឬ ថ្មសំណង់ដែលមានកំឡាំងលើសពី7. 5kw។

2） ម៉ាស៊ីនបញ្ជូនខ្យល់ ឬ ម៉ាស៊ីនបូមខ្យល់ដែលមានកំឡាំងម៉ូទ័រលើសពី 7.5kw។

（2） នៅការដ្ឋានរ៉ែត្រូវបានកំហិតសំឡេងថ្លង់ ស្តីអគារបង្កើតសំឡេងថ្លង់ឬអគារទប់ស្កាត់សំឡេងថ្លង់ ត្រូវចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ នៅពេលមានកើតឡើងនូវសំឡេងថ្លង់ដែល

មិនត្រូវនឹងស្តង់ដារកំណត់ ឬ អាចនឹងកើតឡើង។

(3) ការដ្ឋានរ៉ែដែលត្រូវបានកំណត់សំឡេងថ្លង់ នៅពេលរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ទទួលស្គាល់ថាមានភាពចាំបាច់ ករណីត្រូវបានបញ្ជាត្រូវតែចាត់វិធានការ សមរម្យសំរាប់ទប់ស្កាត់ការបំពុលបរិស្ថាន តាមរយៈសំឡេងថ្លង់ ត្រូវគោរពតាមចំនុចដែលបានបញ្ជាទាំងនោះ។

( 4 ) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិស្ថាននៅការដ្ឋានរ៉ែដែលបានកំណត់សំឡេងថ្លង់ ដើម្បីទប់ស្កាត់ការបំពុលដោយសំឡេងថ្លង់ តើមានគោរពតាមចំនុចដែលមានដូចខាងក្រោមដែរឬទេ។

1) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអាគារបង្កើតសំឡេងថ្លង់ និងអាគារទប់ស្កាត់សំឡេងថ្លង់ និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) ស្តីពីសំឡេងថ្លង់ចេញពីអាគារបង្កើតសំឡេងថ្លង់ ធ្វើការវាស់ជាប្រចាំនូវទំហំសំឡេងថ្លង់នៅក្បែរព្រំប្រទល់ផ្នែកខាងក្រៅរូងនិងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

3) នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតមាននូវការបំពុលតាមរយៈសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដារបានកំណត់សំរាប់សំឡេងថ្លង់ចាំបាច់ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

(5) នៅពេលបានបញ្ចប់ការងារសាងសងជួសជុល និង ខ្លឹមសារនៃវិធានការទប់ស្កាត់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និង ស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតមាននូវការបំពុលតាមរយៈសំឡេងថ្លង់ដែលមិនត្រូវនឹងស្តង់ដារបានកំណត់សំរាប់សំឡេងថ្លង់ ស្តីអំពីខ្លឹមសារទាំងនោះ ត្រូវរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកបន្ទុកការងាររ៉ែ ឬរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។

6－13 ការគ្រប់គ្រងអគារបង្កើតភាពរំញ័រ និងអគារទប់ស្កាត់ភាពរំញ័រ

(1) ករណីត្រូវបានកំហិតនូវភាពរំញ័ពីការដ្ឋានរ៉ែ ដែលមានតំឡើងអគារបង្កើតភាពរំញ័ដែលមានដូចខាងក្រោម នៅខ្សែបន្ទាត់ព្រំប្រទល់ផ្នែកខាងក្រៅការដ្ឋានរ៉ែ ត្រូវមិនអោយកើតនូវភាពរំញ័ដែលមិនត្រូវនឹងស្តង់ដាកំហិតភាពរំញ័។

1) ម៉ាស៊ីនបែងចែក ម៉ាស៊ីនខាត (រ៉ែ) ម៉ាស៊ីនបំបែកប្រើសំរាប់ថ្មរ៉ែ ឬ ថ្មសំណង់ដែលមានកំឡាំងលើសពី7. 5kw។

2) ម៉ាស៊ីនបញ្ជូនខ្យល់ ឬ ម៉ាស៊ីនបូមខ្យល់ដែលមានកំឡាំងម៉ូទ័រលើសពី 7.5kw។

( 2 ) នៅការដ្ឋានរ៉ែត្រូវបានកំហិតភាពរំញ័រ ស្តីអគារបង្កើតសំឡេងថ្លង់ឬអគារទប់ស្កាត់ភាពរំញ័រត្រូវចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ នៅពេលមានកើតឡើងនូវភាពរំញ័រដែលមិនត្រូវនឹងស្តង់ដារកំណត់ ឬ អាចនឹងកើតឡើង។

(3) ការដ្ឋានរ៉ែដែលត្រូវបានកំណត់ភាពរំញ័រ នៅពេលរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ទទួលស្គាល់ថាមានភាពចាំបាច់ ករណីត្រូវបានបញ្ជាត្រូវតែចាត់វិធានការ សមរម្យសំរាប់ទប់ស្កាត់ការបំពុលបរិស្ថាន តាមរយៈភាពរំញ័រ ត្រូវគោរពតាមចំនុចដែលបានបញ្ជាទាំងនោះ។

(4) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិស្ថាននៅការដ្ឋានរ៉ែដែលបានកំណត់ភាពរំញ័រ ដើម្បីទប់ស្កាត់ការបំពុលដោយភាពរំញ័រ តើមានគោរពតាមចំនុចដែលមានដូចខាងក្រោមដែរឬទេ។

1) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអាគារបង្កើតភាពរំញ័រ និងអាគារទប់ស្កាត់ភាពរំញ័រ និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) ស្តីពីសំឡេងថ្លង់ចេញពីអាគារបង្កើតភាពរំញ័រ ធ្វើការវាស់ជាប្រចាំនូវទំហំភាពរំញ័រនៅក្បែរព្រំប្រទល់ផ្នែកខាងក្រៅរូង និង ធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

3) នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតមាននូវការបំពុលតាមរយៈភាពរំញ័រដែលមិនត្រូវនឹងស្តង់ដារបានកំណត់សំរាប់ភាពរំញ័រ ចាំបាច់ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

(5) នៅពេលបានបញ្ចប់ការងារសាងសងជួសជុល និង ខ្លឹមសារនៃវិធានការទប់ស្កាត់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និង ស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតមាននូវការបំពុលតាមរយៈភាពរំញ័រដែលមិនត្រូវនឹងស្តង់ដារបានកំណត់សំរាប់ភាពរំញ័រ ស្តីអំពីខ្លឹមសារទាំងនោះត្រូវរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកបន្ទុកការងាររ៉ែ ឬរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។

## 6－14　ការគ្រប់គ្រងអគារបង្កើតផ្សែងរ៉ែ និងអគារទប់ស្កាត់ផ្សែងរ៉ែ

(1) មិនបញ្ចេញផ្សែងរ៉ែ ដែលមិនត្រូវនឹងស្តង់ដានៃការបញ្ចេញទៅក្នុងបរិយាកាស តាមរយៈច្រកបញ្ចេញ។

(2) នៅពេលអាចនឹងកើតមានឡើងនូវការបញ្ចេញ ឬការបញ្ចេញផ្សែងរ៉ែ (ម្រែងភ្លើង) ដែលមិនត្រូវស្តង់ដានៃការបញ្ចេញផ្សែងរ៉ែ (ម្រែងភ្លើង) កើតមានគ្រោះថ្នាក់ ឬការខូច បែកបាក់ ត្រូវចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ចំពោះករណីមានគ្រោះថ្នាក់ ឬចាត់វិធានការទប់ទល់នឹងចំពោះគ្រោះថ្នាក់នោះ ជាបន្ទាន់។

(3) នៅពេលរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ទទួលស្គាល់ថាមានភាពចាំបាច់ ករណីត្រូវបានបញ្ជាត្រូវតែចាត់វិធានការសមរម្យសំរាប់ទប់ស្កាត់ការបំពុលបរិដ្ឋាន តាមរយៈផ្សែងរ៉ែ (ម្រែងភ្លើង) ត្រូវគោរពតាមចំនុចដែលបានបញ្ជាទាំងនោះ។

(4) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាននៅការដ្ឋានរ៉ែ ដើម្បីទប់ស្កាត់ការបំពុលដោយសារផ្សែងរ៉ែ (ម្រែងភ្លើង) ត្រូវគោរពតាមចំនុចដែលមានដូចខាងក្រោម។

1) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារបង្កើតផ្សែងរ៉ែ (ម្រែងភ្លើង) និងអគារទប់ស្កាត់ផ្សែងរ៉ែ (ម្រែងភ្លើង) និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) ស្តីពីបរិមាណនិងកំហាប់នៃផ្សែងរ៉ែ (ម្រែងភ្លើង) មាននៅក្នុងផ្សែងចេញពីអគារបង្កើតផ្សែងរ៉ែ (ម្រែងភ្លើង) ធ្វើការវាស់ជាប្រចាំនូវបរិមាណនិងកំហាប់ ធ្វើការវិភាគ ផ្សែងរ៉ែ (ម្រែងភ្លើង) និង ធ្វើការកត់ត្រាលទ្ធផលទាំងនោះ លើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

3) នៅពេលអាចនឹងមានគ្រោះថ្នាក់ កើតមាននូវការបំពុលតាមរយៈផ្សែងរ៉ែ(ម្រែងភ្លើង) ចាំបាច់

ដើរល្បាត ឬវាស់ ធ្វើការវិភាគនូវលទ្ធផលទាំងនោះ និងត្រូវរាយការណ៏ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

（5）នៅពេលបានបញ្ចប់ការងារសាងសង់ជួសជុល និងខ្លឹមសារនៃវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និងស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬកើតមាននូវការបំពុលតាមរយៈផ្សែងរ៉ែ (ម្រេងភ្លើង) ដែលមិនត្រូវនឹងស្តង់ដាបានកំណត់សំរាប់ផ្សែងរ៉ែ (ម្រេងភ្លើង) ស្តីពីខ្លឹមសារទាំងនោះ ត្រូវរាយការណ៏ជាបន្ទាន់ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែ ឬរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។

6－15　ការគ្រប់គ្រងអគារបង្កើតធូលី និងអគារទប់ស្កាត់ធូលី

（1）មាន ទីកន្លែងសំរាប់ទុកកាកសំណល់អាជីវកម្មរ៉ែ ឬស្តុកកាកសំណល់ តាមរយៈការចំរាញ់ទឹកកខ្វក់ ទឹកនៅក្នុងរូងឬអាចម៍រ៉ែ ថ្មចោលឬទីកន្លែងស្តុកថ្មរ៉ែ ស្តីពីទីកន្លែងទាំងឡាយនោះដែលមានផ្ទៃក្រឡាលើសពី1,000 $m^2$ ករណីអាចនឹងមានធូលីហ៊ុយ ត្រូវអនុវត្តតាមចំនុចមានដូចខាងក្រោម។

a) ចាំបាច់ត្រូវតំឡើងនៅក្នុងអគារដែលមានរចនាសម្ព័ន្ធមិនងាយអោយធូលីហ៊ុយ។
b) ចាំបាច់ត្រូវធ្វើការបាចទឹកតាមរយៈបាចទឹក។
c) ចាំបាច់ត្រូវគ្របទប់ស្កាត់ធូលីហ៊ុយ។
d) ចាំបាច់ធ្វើអោយរឹងផ្នែកស្រទាប់ខាងលើ ឬបាចថ្នាំរាវ។
e) ចាំបាច់ចាត់វិធានការមានប្រសិទ្ធិភាពអោយលើសពីចំនុចដែលមានពីខាងលើ។

（２）ពីកញ្ចែងដែលត្រូវបានតំឡើងនៅក្រៅរូងមានកំឡាំងម៉ូទ័រលើសពី15Kw និងម៉ាស៊ីនបំបែកម៉ាស៊ីនប៉ូលា (លើកលែងជារបស់មានប្រព័ន្ធបិទជិត និងបែបសើម។) ដែលត្រូវបានតំឡើងនៅក្រៅរូងមានកំឡាំងម៉ូទ័រលើសពី75Kw តើមានបានអនុវត្តតាមចំនុចនីមួយៗដែលមានដូចខាងក្រោមដែរឬទេ?

a) ត្រូវបានតំឡើងនៅក្នុងអគារដែលមានរចនាសម្ព័ន្ធមិនងាយអោយធូលីហ៊ុយបាន។
b) ត្រូវបានតំឡើងម៉ាស៊ីនប្រមូលធូលី និងfood។
c) ត្រូវបានបាចទឹកតាមរយៈបរិក្ខារបាចទឹក។
d) ចាំបាច់ត្រូវគ្របទប់ស្កាត់ធូលីហ៊ុយ។
e) ចាំបាច់ចាត់វិធានការមានប្រសិទ្ធិភាពអោយលើសពីចំនុចដែលមានពីខាងលើ។

（3）ស្តីពីBUCKET CONVEYORដែលត្រូវបានតំឡើងនៅក្រៅរូង មានចំនុចលើសពី0.03 $m^3$ និងខ្សែពានទឹកជញ្ជូនដែលត្រូវបានតំឡើងនៅក្រៅរូងមានទំហំ លើសពី0.75 m (លើកលែងជារបស់មានប្រព័ន្ធបិទជិត) ករណីមានធូលីហ៊ុយខ្លាំង។ តើមានបានអនុវត្តតាមចំនុចនីមួយៗដែលមានដូចខាងក្រោមដែរឬទេ?

a) ត្រូវបានតំឡើងនៅក្នុងអគារដែលមានរចនាសម្ព័ន្ធមិនងាយអោយធូលីហ៊ុយបាន។

b) ត្រូវបានតំឡើងម៉ាស៊ីនប្រមូលធូលី និងfood នៅផ្នែកដាក់ចុះ និងផ្នែកលើកដាក់លើខ្សែពានដឹកជញ្ជូន ព្រមទាំងចំពោះផ្នែកអាចនឹងមានធូលីហុយនៃខាងក្រៅនៃផ្នែកដាក់ចុះ និងផ្នែកលើកដាក់លើខ្សែពានដឹកជញ្ជូន តើមានចាត់វិធានការបាចទឹក ឬតំឡើងគំរបទប់ស្កាត់ធូលីដែរឬទេ?

c) ត្រូវបានបាចទឹកតាមរយៈបរិក្ខារបាចទឹក។

d) ចាំបាច់ត្រូវគ្របទប់ស្កាត់ធូលីហុយ។

e) ចាំបាច់ចាត់វិធានការមានប្រសិទ្ធិភាពអោយលើសពីចំនុចដែលមានពីខាងលើ។

(4) ស្ដីប្រកចេញនៃធូលីរបស់បរិក្ខារម៉ាស៊ីនថ្មកំបោរ (រួមទាំងបំបែកដូឡូមីត)តើមានអនុវត្តតាមចំនុចដែលមានដូចខាងក្រោមដែរឬទេ?

a) ត្រូវបានតំឡើងម៉ាស៊ីនប្រមូលធូលី ។

b) ត្រូវបានបាចទឹកតាមរយៈបរិក្ខារបាចទឹក។

c) ចាំបាច់ចាត់វិធានការមានប្រសិទ្ធិភាពអោយលើសពីចំនុចដែលមានពីខាងលើ។

(5) ស្ដីពីអគារបង្កើតធូលី ឬអគារទប់ស្កាត់ធូលី នៅពេលអាចនឹងកើតមានគ្រោះថ្នាក់ ឬកើតបញ្ហាបំពុលបរិដ្ឋាន តាមរយៈធូលី កើតមានគ្រោះថ្នាក់ផ្សេងៗ ឬការខូច បែកបាក់ ត្រូវចាត់វិធានការជួសជុលឡើងវិញជាបន្ទាន់ចំពោះករណីមានគ្រោះថ្នាក់ ឬចាត់វិធានការទប់ទល់នឹងចំពោះគ្រោះថ្នាក់នោះ ជាបន្ទាន់។

(6) នៅពេលរដ្ឋមន្ត្រីទទួបន្ទុកការងាររ៉ែ បានទទួលស្គាល់និងមានភាពចាំបាច់ ដោយដាក់បញ្ហាអោយចាត់វិធានការសមរម្យសំរាប់ទប់ស្កាត់ការបំពុលដោយសារធូលី ការដ្ឋានរ៉ែនោះបានគោរពអនុវត្តតាមបញ្ហាទាំងនោះ។

(7) អ្នកគ្រប់គ្រងការងារទទួលបន្ទុកទប់ស្កាត់ការបំពុលបរិដ្ឋាន ដើម្បីទប់ស្កាត់ការបំពុលដោយសារធូលី ត្រូវគោរពតាមចំនុចដែលមានដូចខាងក្រោម។

1)ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារបង្កើតធូលី និងអគារទប់ស្កាត់ធូលី និងកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) នៅតាមរយៈលទ្ធផលនៃការដើរល្បាតតាមអគារបង្កើតធូលី និងអគារទប់ស្កាត់ធូលី ពេលអាចនឹងមានគ្រោះថ្នាក់ ឬកើតមាននូវការបំពុលតាមរយៈធូលី ចាំបាច់ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

( 8 ) នៅពេលបានបញ្ចប់ការងារសាងសង់ជួសជុល និងខ្លឹមសារនៃវិធានការទប់ទល់ជាបន្ទាន់ចំពោះគ្រោះថ្នាក់ និងស្ថានភាពគ្រោះថ្នាក់ នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬកើតមាននូវការបំពុលតាមរយៈធូលី ស្ដីពីខ្លឹមសារទាំងនោះ ត្រូវរាយការណ៍ជាបន្ទាន់ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែឬ រដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ។

6－16 ការគ្រប់គ្រងទាក់ទងនឹងកាកសំណល់អាជីវកម្មរ៉ែ

(1) ចាំបាច់ត្រូវចាត់វិធានការសំរាប់ទប់ស្កាត់ការជ្រាបចូលទៅក្នុងដី ការហូរចេញ និងការហើរហុយ

នៃកាកសំណល់អាជីវកម្មរ៉ែ។

(2) មិនត្រូវអោយដឹកជញ្ជូនកាកសំណល់អាជីវកម្មរ៉ែ តាមវិធីមិនត្រូវនឹងស្តង់ដាកំណត់ចំរាញ់ កាកសំណល់អាជីវកម្មរ៉ែជាដាច់ខាត។

(3) មិនត្រូវអោយលុបនូវកាកសំណល់អាជីវកម្មរ៉ែក្នុងទីកន្លែងលុបដែលមិនត្រូវនឹងស្តង់ដាផ្នែកបច្ចេកទេសនៃកាកសំណល់អាជីវកម្មរ៉ែ ជាដាច់ខាត។

(4) មិនត្រូវអោយលុបកាកសំណល់អាជីវកម្មរ៉ែនៅទីកន្លែងជីកយករ៉ែរួច ឬរូងចាស់។ល។ដែលបានបោះបង់ចោល។

(5)មិនត្រូវអោយអ្នកទី៣ ចំរាញ់ដឹកជញ្ជូនកាកសំណល់អាជីវកម្មរ៉ែ ដោយវិធីមិនត្រូវស្តង់ដាកំណត់ចំរាញ់ ជាដាច់ខាត។

(6) ករណីបានទទួលបញ្ជាអោយចាត់វិធានការអោយធ្វើអោយត្រូវនឹងស្តង់ដាដែលបានកំណត់សំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈកាកសំណល់អាជីវកម្មរ៉ែ ដោយរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ត្រូវតែគោរពតាមបញ្ជាទាំងនោះ។

(7) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំពុលបរិដ្ឋាន ដើម្បីទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈកាកសំណល់អាជីវកម្មរ៉ែ ត្រូវគោរពតាមចំនុចដែលមានដូចខាងក្រោម៖

1) ធ្វើការដើរល្បាតរាល់ថ្ងៃចំពោះអគារចំរាញ់ដំណាក់កាលកណ្តាលនៃកាកសំណល់អាជីវកម្មរ៉ែ និងធ្វើការកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

2) ធ្វើការដើរល្បាតរាល់ថ្ងៃ ចំពោះទីកន្លែង លុបកាកសំណល់អាជីវកម្មរ៉ែ មាននៅលើដី និងធ្វើការកត់ត្រានូវលទ្ធផលនៃការល្បាតនោះ នៅលើសៀវភៅសុវត្ថិភាពប្រចាំថ្ងៃ។

3) ស្តីពីគុណភាពទឹកក្រោមដីនៅក្បែរទីកន្លែងលុបលុបកាកសំណល់អាជីវកម្មរ៉ែ ត្រូវធ្វើការវិភាគ និងវាស់ជាប្រចាំ និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

4) ធ្វើការដើរល្បាតរាល់ថ្ងៃជាប្រចាំស្តីពីស្ថានភាព កំពស់ទឹកនៅក្នុងទីកន្លែងលុបកាកសំណល់នៅក្នុងរូង និងកំពស់ទឹកនៃទឹកក្នុងរូងទាក់ទងនឹងទីនោះ និងស្ថានភាពផ្សេងទៀត ធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

5) ករណីមានទឹកជ្រាបចូលទៅក្នុងទីកន្លែងលុបនៅក្នុងរូង ធ្វើការវិភាគ វាស់ដោយជាប្រចាំស្តីពីគុណភាពនោះ និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

6) នៅពេលដើរល្បាត ទីកន្លែងលុប អគារចំរាញ់កាកសំណល់រ៉ែ ឬ តាមរយៈលទ្ធផលនៃការវាស់វិភាគ កាក់សំណល់រ៉ែ អាចនឹងមានការបំពុលបរិដ្ឋាន ចាំបាច់ត្រូវតែរាយការណ៏ដល់អ្នកគ្រប់គ្រង ជាបន្ទាន់។

7 ) ស្តីពីវិធីបំលែងនិងដឹកជញ្ជូនព្រមទាំងបរិមាណកើតតាមប្រភេទនីមួយៗមានរាល់ខែ នៃកាកសំណល់អាជីវកម្មរ៉ែ តើត្រូវតែធ្វើការកត់ត្រាលើ「សៀវភៅលុបបំបាត់កាកសំណល់អាជីវកម្មរ៉ែមានជាតិពុល」។

8) នៅពេលអាចនឹងមានគ្រោះថ្នាក់ នៅទីកន្លែងលុបក្នុងរូង ឬទីកន្លែងលុបកាកសំណល់រ៉ែ ត្រូវរាយការណ៍ជាបន្ទាន់ ដល់អគ្គនាយកទទួលបន្ទុកការងាររ៉ែឬរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។

6－17 ការគ្រប់គ្រងសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព

(1) នៅពេលអាចនឹងមានគ្រោះថ្នាក់ ឬ កើតឡើងនូវការបំពុលបរិដ្ឋាន តាមរយៈសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ក្នុងករណីមានការជ្រាបចូលទៅក្នុងដី ជ្រាបចេញ ហូរចេញ លេចចេញ ហើរសាយភាយ សារធាតុពុលនិងសារធាតុបំផ្លាញសុខភាព តើមានចាត់វិធានការទប់ទល់នឹងគ្រោះថ្នាក់នោះដែរឬទេ និងមានធ្វើការជួសជុលស្តារឡើងវិញជាបន្ទាន់។

(2) អ្នកគ្រប់គ្រងការងារទទួលបន្ទុកការបំពុលបរិដ្ឋាន ដើម្បីទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ត្រូវគោរពតាមចំនុចដែលមានដូចខាងក្រោម៖

1) ធ្វើការដើរល្បាតរាល់ថ្ងៃជាប្រចាំចំពោះ អគារចំរាញ់ទឹកកខ្វក់រួមទាំងមានលាយនូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព អគារប្រើសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ទីកន្លែងស្តុកសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព និងធ្វើការកត់ត្រាលើសៀវភៅគ្រប់គ្រងលទ្ធផលទាំងនោះ។

2) នៅពេលអាចនឹងមានការបំពុល តាមរយៈសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព តាមលទ្ធផលនៃការដើរល្បាត អគារចំរាញ់ទឹកកខ្វក់រួមទាំងមានលាយនូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព អគារប្រើសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ទីកន្លែងស្តុកសារធាតុពុលនិងសារធាតុបំផ្លាញសុខភាពចាំបាច់ត្រូវតែរាយការណ៍ដល់អ្នកគ្រប់គ្រងជាបន្ទាន់។

(3) ក្នុងករណីបានទទួលបញ្ជាអោយចាត់វិធានសមរម្យសំរាប់ទប់ស្កាត់បំពុលដោយសាររ៉ែ ឬការយកចេញនូវភាពពុល ការប្រមូលឡើងនូវសារធាតុពុលនិងសារធាតុបំផ្លាញសុខភាព ដោយរដ្ឋមន្ត្រីទទួបន្ទុកការងាររ៉ែ ត្រូវគោរពតាមបញ្ជាទាំងនោះ។

6－18 ការគ្រប់គ្រងទាក់ទងនឹងការជីកយកដី

(1) នៅពេលចង់ខួងយករ៉ែនៅក្នុងដីដែលអាចនឹងមានគ្រោះថ្នាក់កើតឡើងនូវការបំពុលបរិដ្ឋានតាមរយៈការបាក់ដីផុង ដើម្បីទប់ស្កាត់នូវការបញ្ហាបំពុលបរិដ្ឋាន ត្រូវចាត់វិធានការសមរម្យ ស្តីពីវិធីនៃការបញ្ចេញទឹកនិងការលុបបន្ថែម ការជីកយក។

(2) ករណីបានទទួលបញ្ជាអោយចាត់វិធានការអោយធ្វើអោយត្រូវនឹងស្តង់ដាដែលបានកំណត់សំរាប់ទប់ស្កាត់ការបំពុលដោយសាររ៉ែ តាមរយៈកាកសំណល់អាជីវកម្មរ៉ែ ដោយរដ្ឋមន្ត្រីទទួលបន្ទុកការងាររ៉ែ ត្រូវគោរពតាមបញ្ជាទាំងនោះដោយម៉ឹងម៉ាត់។

(3) ចំពោះករណីបោះបង់អាជីវកម្មរ៉ែ នៅពេលមានភាពចាំបាច់សំរាប់ទប់ស្កាត់ការកើតឡើងបញ្ហា

បំពុលនៅក្រោយពីបោះបង់ ត្រូវចាត់វិធានការចាំបាច់សំរាប់ទប់ស្កាត់បញ្ហាបំពុល ដូចការបិទផ្ចិតរូង តាមរយៈការប្រើប៉េតុង ឬលុបបំពេញដោយបើដីទៅរូងបានជីករួចនិងផ្លូវក្នុងរូងដែលមិនត្រូវការ។

(4) ចំពោះករណីបោះបង់ការងាររ៉ែចោល នៅពេលមានភាពចាំបាច់សំរាប់ទប់ស្កាត់បញ្ហាបំពុលកើតឡើង ត្រូវចាត់វិធានការលុបដីទៅលើកន្លែងជីករួច ឬការដាំដើមឈើឡើងវិញ។

## ជំពូក 7 វចនាសម្ព័ន្ធអនុវត្តសំរាប់រក្សាបាននូវសុវត្ថិភាព វិធីវាយតំលៃនិងចាត់វិធានការ

7－1 វចនាសម្ព័ន្ធអនុវត្តដើម្បីរក្សាបាននូវសុវត្ថិភាព

(1) អនុវត្តស្រាវជ្រាវស្ថានភាពជាក់ស្តែង

ក្នុងការអនុវត្តស្រាវជ្រាវស្ថានភាពជាក់ស្តែង អនុលោមតាមការកំណត់នៃច្បាប់សុវត្ថិភាពការដ្ឋានរ៉ែ អ្នកគ្រប់គ្រងសុវត្ថិភាពរួមត្រូវកំណត់សមាជិកក្រុមនិងបង្កើតក្រុម។

ក្រុមស្រាវជ្រាវស្ថានភាពជាក់ស្តែង ធ្វើការស្រាវជ្រាវស្ថានភាពជាក់ស្តែងនៅពេលកើតបាតុភូតមានដូចខាងក្រោមនៅការដ្ឋានរ៉ែ ពិនិត្យ វាយតំលៃវិធានការតប់ទល់ ព្រមទាំងរាយការណ៍ដល់អ្នកគ្រប់គ្រងសុវត្ថិភាពរួមនិង គណៈកម្មការសុវត្ថិភាព ។

1) នៅពេលចង់ចាប់ផ្តើមការងាររអាជីវកម្មរ៉ែក្រោយពីបានទទួលការអនុញ្ញាពីរដ្ឋមន្ត្រី។

2) នៅពេលផ្អាកអាជីវកម្មលើសពី១ខែ ឬនៅចង់ផ្តើមអាជីវកម្មរ៉ែ។

3) នៅពេលបានផ្លាស់ប្តូរទ្រង់ទ្រាយធំក្នុងការធ្វើអាជីវកម្មរ៉ែ។

4) នៅពេលចង់បោះបង់សិទ្ធធ្វើអាជីវកម្មរ៉ែ ឬចង់បោះបង់ការងាររអាជីវកម្មរ៉ែ។

(2) អនុវត្តស្រាវជ្រាវដឹងទុកជាមុនពីគ្រោះថ្នាក់ដោយប្រើប្រព័ន្ធការគ្រប់គ្រងហានិភ័យ

នៅតាមផ្នែកនីមួយៗនៃការដ្ឋានរ៉ែ ប្រើប្រព័ន្ធការគ្រប់គ្រងហានិភ័យ សំរាប់អនុវត្តស្រាវជ្រាវដឹងពីគ្រោះថ្នាក់ទុកជាមុននៅការដ្ឋានរ៉ែ ពិនិត្យ វាយតំលៃ ចាត់វិធានការ កត់ត្រា ព្រមទាំងរាយការណ៍ដល់អ្នកគ្រប់គ្រងសុវត្ថិភាពរួមនិង គណៈកម្មការសុវត្ថិភាព ។

(3) ការអនុវត្តដើរល្បាតមើលសុវត្ថិភាពការដ្ឋានរ៉ែ

1) អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព អ្នកអនុគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព ចំពោះសុខភាពអនាម័យប្រចាំឆ្នាំ និងសុវត្ថិភាពប្រចាំសប្តាហ៏ដែលបានកំណត់នៅក្នុងផែនការប្រចាំឆ្នាំ ត្រូវដើរល្បាតមើលអគារការដ្ឋានរ៉ែ និងទីកន្លែងធ្វើការងារនៅការដ្ឋានរ៉ែ ព្រមទាំងក្តាប់នូវសភាពជាក់ស្តែងទាំងនោះ។

2) អ្នកអនុគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព ក្រៅពីសុខភាពអនាម័យប្រចាំឆ្នាំ និងសុវត្ថិភាពប្រចាំសប្តាហ៏ ស្តីពីអគារការដ្ឋានរ៉ែនិងទីកន្លែងធ្វើការដែលទទួលបន្ទុក ត្រូវដើរល្បាតដោយឆ្លើយតបនឹងភាពចាំបាច់ ព្រមទាំងខិតខំកែលំអនូវចំនុចជាបញ្ហានៅទីកន្លែងធ្វើការរបស់កម្មកររ៉ែ។

7－2 បញ្ជាក់នូវស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

(1) វិធីបញ្ជាក់ទាក់ទងនឹងស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

ដើម្បីបញ្ជាក់នូវស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព បង្កើតក្រុមសិក្សាស្រាវជ្រាវពីសុវត្ថិភាព ដោយមានការជ្រើសតាំងដោយអ្នកគ្រប់គ្រងសុវត្ថិភាពរួម អនុវត្តសិក្សាស្រាវជ្រាវទាក់ទងនឹងស្ថានភាពអនុវត្តជាក់ស្តែងពីសុវត្ថិភាព។ ការិយាល័យទាក់ទងនឹងការសិក្សាស្រាវជ្រាវ ត្រូវមាននៅក្នុងផ្នែកសុវត្ថិភាពបរិស្ថាន។

(2) កាលបរិច្ឆេទទាក់តងនឹងស្ថានភាពអនុវត្តជាក់ស្តែងពីសកម្មភាពសុវត្ថិភាព

ស្តីពីកាលបរិច្ឆេទអនុវត្តសកម្មភាពសិក្សាស្រាវជ្រាវ មានពីរលើកក្នុង១ឆ្នាំ គឺនៅខែមេសានិងនៅខែតុលា ចំពោះករណីអនុវត្តសិក្សាស្រាវជ្រាវពិសេសគឺកំណត់ដោយអ្នកគ្រប់គ្រងសុវត្ថិភាពរួម។

(3) ខ្លឹមសារអនុវត្តការត្រួតពិនិត្យ

ស្តីពីខ្លឹមសារលំអិតនៃការអនុវត្តការត្រួតពិនិត្យ ត្រូវបង្កើតផែនការជាមុនដោយបុគ្គលិកការិយាល័យមុននឹងធ្វើការត្រួតពិនិត្យ ខ្លឹមសារទាំងនោះនឹងត្រូវចាត់ទុកថាបានការយល់ព្រមពីសំណាក់អ្នកគ្រប់គ្រងសុវត្ថិភាពរួម និងពីសំណាក់គណៈកម្មការសុវត្ថិភាព។

(4) របាយការណ៍ត្រួតពិនិត្យទាក់ទងនឹងស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

ចំពោះរបាយការណ៍លទ្ធផលនៃការត្រួតពិនិត្យទាក់ទងនឹងស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព បុគ្គលិកការិយាល័យ ក្រោយពីធ្វើការត្រួតពិនិត្យរួច សរុបនិងបង្កើត 「របាយការណ៍លទ្ធផលនៃការត្រួតពិនិត្យទាក់ទងនឹងស្ថានភាពអនុវត្តជាក់ស្តែងនៃសកម្មភាពសុវត្ថិភាព」 ក្រោយពីមានការពន្យល់នូវខ្លឹមសាររបស់របាយការណ៍ដល់អ្នកគ្រប់គ្រងសុវត្ថិភាពរួច នឹងធ្វើការរាយការណ៍ដល់គណៈកម្មការសុវត្ថិភាព។

## 7－3 ការវាយតំលៃនូវស្ថានភាពអនុវត្តសកម្មភាពសុវត្ថិភាព

(1) ស្តីពីខ្លឹមសារនៃការអនុវត្តជាក់ស្តែងនូវការស្រាវជ្រាវដឹងទុកជាមុនពីគ្រោះថ្នាក់និងស្រាវជ្រាវស្ថានភាពជាក់ស្តែង ធ្វើការរាយការណ៍ដល់គណៈកម្មការសុវត្ថិភាពនិងពិនិត្យពិភាក្សាលើខ្លឹមសារទាំងនោះ។

លើសពីនេះ តាមរយៈការពិនិត្យពិភាក្សានោះ គណៈកម្មការសុវត្ថិភាពអាចមានសិទ្ធបញ្ជាអោយដាក់បន្ថែមនូវវិធានការចាំបាច់មួយចំនួនទៀត ឬប្រគល់អោយតាមផ្នែកនីមួយៗពិនិត្យមើលឡើងវិញនូវវិធានការទាំងនោះ។

## 7－4 ការកត់ត្រាទុកនូវលទ្ធផលនៃការវាយតំលៃនិងលទ្ធផលនៃការបញ្ជាក់

(1) ចំពោះការកត់ត្រាទាក់ទងនឹងការស្រាវជ្រាវស្ថានភាពជាក់ស្តែង ត្រូវរក្សាទុកក្នុងរយៈពេល១០ឆ្នាំ។

(2) ចំពោះការកត់ត្រាសេចក្តីពិភាក្សានៅក្នុងគណៈកម្មការសុវត្ថិភាពនៃការស្រាវជ្រាវដឹងទុកជាមុនពីគ្រោះថ្នាក់។ល។ ត្រូវរក្សាទុកក្នុងរយៈពេល៣ឆ្នាំ។

**ជំពូក ៨　ការផ្លាស់ប្តូរ និងមើលឡើងវិញនូវខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងសុវត្ថិភាព**

នៅពេលត្រូវបានទទួលស្គាល់ថាមានបាតុភូតដូចខាងក្រោម ធ្វើការមើលឡើងវិញនូវបទបញ្ញតិសុវត្ថិភាពដោយឆ្លើយតបតាមភាពចាំបាច់ និងធ្វើការកែប្រែឡើងវិញនូវចំនុចមួយចំនួន។

1) តាមលទ្ធផលបានស្រាវជ្រាវនូវស្ថានភាពជាក់ស្តែង នៅពេលមានភាពច្បាស់លាស់ចាំបាច់ដោះស្រាយនូវបញ្ហាសំរាប់រក្សាបានសុវត្ថិភាពការដ្ឋានរ៉ែ។

